**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ៥៦)

ភាគីដាក់ឯកសារ៖ អោ អាន

ដាក់ជូន៖ អង្គបុរេជំនុំជម្រះ

ភាសាដើម៖ អង់គ្លេស

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Jan-2019, 08:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សម្ងាត់**

ចំណាត់ថ្នាក់ឯកសារដោយអង្គបុរេជំនុំជម្រះ៖ **សម្ងាត់/Confidential**

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

# បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

---

**ដាក់ដោយ៖**

**សហមេធាវីការពារក្តី**

មុំ លុជ្ស

Richard ROGERS
Göran SLUITER

**ផ្ញើជូន៖**

**ចៅក្រមអង្គបុរេជំនុំជម្រះ**

ចៅក្រម ប្រាក់ គឹមសាន

ចៅក្រម Olivier BEAUVALLET

ចៅក្រម ន័យ ថុល

ចៅក្រម Kang Jin BAIK

ចៅក្រម ហួត វុទ្ធី

**សហព្រះរាជអាជ្ញា៖**

ជា លាង

Nicholas KOUMJIAN

**ដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/២**

# មាតិកា

សេចក្តីផ្តើម និងសេចក្តីសង្ខេបនៃទឡ្ហីករណ៍........................................................................ 8

ប្រវត្តិនីតិវិធី....................................................................................................10

ច្បាប់ជាធរមាន..............................................................................................12

ភាពអាចទទួលយកបាន ....................................................................................12

បទដ្ឋាននៃការត្រួតពិនិត្យឡើងវិញ ......................................................................16

សំអាងហេតុនៃបណ្តឹងឧទ្ធរណ៍ ...........................................................................18

I. សំអាងហេតុទី១៖ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស្របពេលជាមួយគ្នានឹងការចេញដីកាលើកលែងការចោទប្រកាន់ ត្រូវបានសំអាងទៅលើកំហុសអង្គច្បាប់.......................................................18

ក .ក្របខណ្ឌគតិយុត្តិចែងយ៉ាងច្បាស់អំពីដីកាដំណោះស្រាយតែមួយ.......................................19

ខ .ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺមិនធ្លាប់មានពីមុនមក ហើយមិនស្របទៅនឹងសិទ្ធិជាមូលដ្ឋានរបស់ អោ អាន និងគោលការណ៍សច្ចភាពគតិយុត្តិឡើយ.....................................................21

គមកនេះ ត្រូវតែដោះស្រាយមានពីមុនមិនធ្លាប់ស្ពានភាពទាល់ច្រកផ្នែកនីតិវិធីដែល . ដោយផ្តល់ជាប្រយោជន៍ដល់ អោ អាន ..........................................................................................25

ឃ១សន្និដ្ឋានលើសំអាងហេតុទីសេចក្តី ...........................................................................26

II. សំអាងហេតុទី ២ ដល់ ៧ ពាក់ព័ន្ធនឹងការយល់ឃើញខុសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយហេតុដូច្នេះ គាត់ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់តុលាការនេះ.............................................................................................27

ក ៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញខុសថា២ សំអាងហេតុទី .គាត់មានឆន្ទានុសិទ្ធិដោយសេរីដើម្បីសម្រេចអំពីយុត្តាធិការបុគ្គល .............................................................................28

i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើចំពោះការលើកឡើងរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/១ ហើយបែរជាអនុវត្តតាមសំអាងហេតុខុសឆ្គង របស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០១ ទៅវិញ ...................................................................................29

ii. ចេតនា និងការអនុវត្តជាបន្តបន្ទាប់របស់ភាគីទាំងឡាយទៅនឹងកិច្ចព្រមព្រៀងរវាង អ ប.ស. និងរាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីកម្រិតឆន្ទានុសិទ្ធិរបស់ សស.ច. .......................................................30

ខ អំពី៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បកស្រាយ៣ ទីសំអាងហេតុ ."ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខណៈទូលំទូលាយហួសហេតុពេក ............31

i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើទៅលើការយល់ឃើញក្នុងន័យចង្អៀតនៃពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលបានសំអាងលើប្រវត្តិនៃកិច្ចចរចា ការអនុវត្ត ជាបន្តបន្ទាប់របស់ភាគីនានា ព្រមទាំងទស្សនៈរបស់សហព្រះរាជអាជ្ញាជាតិ និងបណ្តាចៅក្រមជាតិ ............33

ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀត............34

iii. ទស្សនៈរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" តាមរយៈ ការស្តែងចេញពីសហឧក្រិដកម្មរួមទម្រង់ទី១ )JCE I( និងការភាន់ច្រឡំ ទៅលើទស្សនទានស្តីពីយុត្តាធិការបុគ្គល ជាមួយនឹងទម្រង់នៃការទទួលខុសត្រូវ ............34

iv. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កម្រិតការវិភាគប្រៀបធៀបរបស់គាត់យ៉ាងចម្លែកដោយមិនអាច/អ៊ឹម ចែម និង ឌុច ទៅនឹង ឲ្យយល់បាន ............36

គបទដ្ឋាន៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុវត្ត៤ ទីសំអាងហេតុ .ស្តីពីការបង្ហាញភ័ស្តុតាងពុំបានត្រឹមត្រូវ ............38

ឃ .សំអាងហេតុទី ៥៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្កើត និងសំអាងខុសទៅលើឋានានុក្រមនៃភ័ស្តុតាងជំនួសឲ្យការពិនិត្យខ្លឹមសារនៃភ័ស្តុតាងទៅវិញ............40

i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការខកខានអនុវត្តសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/១ ............41

ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានវាយតម្លៃលើភាពអាចជឿទុកចិត្តបានរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗដែលផ្តល់ភ័ស្តុតាងសំខាន់អំពីថាតើតុលាការមានយុត្តាធិការលើ អោ អាន ឬទេ? ............45

ក) ប្រាក់ យុត ............45

ខ) យូ វ៉ាន់............50

គ) ពៅ សារ៉ុម, ពុត កុល និង កែវ វឿន............53

ឃ) ញ៉ែម ចេន............54

ង) ជុំ វង្ស (ង៉ូវ)............57

ច) ពេញ វ៉ា និង ញឹម កុល ......................................................................59

iii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានពិចារណាវិធីសាស្ត្រគួរឱ្យសង្ស័យដែលប្រើប្រាស់ក្នុងកសារយកភ័ស្តុតាង និង ផ្អែកលើភ័ស្តុតាងដែលប្រឡូកប្រឡាក់នេះ ....................................61

iv. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានជាប្រព័ន្ធមិនផ្តល់ភ័ស្តុតាងស៊ីសង្វាក់ដើម្បីគាំទ្រសំអាងហេតុ ......................................................................................................62

v. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានប្រុងប្រយ័ត្នក្នុងការផ្អែកលើភ័ស្តុតាងចចាមអារ៉ាម ......................................................................................................64

vi. សេចក្តីសន្និដ្ឋានលើសំអាងហេតុទី៥.........................................................................66

ង. សំអាងហេតុទី៦៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការរកឃើញថា អោ អាន មានមុខតំណែង កាន់តែសំខាន់នៅ ក្នុង បក្សកុម្មុយនីស្តកម្ពុជា និង ដើរតួនាទីនៅក្នុងបទល្មើសធ្ងន់ធ្ងរបំផុត ជាងមន្ត្រីខ្មែរក្រហម ដទៃទៀតដែលគេស្គាល់.........................................................................66

i. អោ អាន មិនបានកំណត់ ឬបកស្រាយគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា ទេ .....................67

ii. អោ អាន មិនមែនជាឧបករណ៍ក្នុងការអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា បើប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមដទៃៗទៀត ដែលគេស្គាល់ .................................................68

iii. អោ អាន មិនបានរៀបចំផែនការ សហការ ឬ ដឹកនាំការបោសសម្អាតអតីតកម្មាភិបាលភូមិភាគ កណ្តាល ឬជនស៊ីវិល នៅចុងឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៧ ឡើយ..........................................72

iv. អោ អាន មិនមានតួនាទីឬសិទ្ធិអំណាចសំខាន់នៅក្នុងភូមិភាគកណ្តាលឡើយ ...........................76

ក) អោ អាន មិនមែនជាលេខាស្តីទីនៃភូមិភាគកណ្តាលឡើយនៅពេល កែ ពក អវត្តមាន...............76

ខ) អោ អាន មិនមែនជាអនុលេខាតំបន់ តាមនីតិន័យនោះទេ................................................79

គ) អោ អាន មិនមែនជាអនុលេខាភូមិភាគតាមព្រឹត្តិន័យទេ ..................................................82

v. អោ អាន មិនមានតួនាទីឬសិទ្ធិអំណាចធំនៅក្នុងតំបន់៤១នោះទេ .........................................86

ក) អោ អាន មិនមែនជាលេខាតំបន់៤១ តាមនីតិន័យទេ.........................................................87

ខ) អោ អាន មិនមែនជា លេខាតំបន់៤១តាមព្រឹត្តន័យឡើយ ................................................89

គឡើយ ហើយបើ ៤១ អោ អាន មិនមានអំណាចទៅលើបញ្ជាសន្តិសុខ ឬមន្ទីរសន្តិសុខនៅក្នុងតំបន់ ( ទោះបីជាធ្លាប់ឃើញគាត់នៅទីនោះក៏ដោយ ក៏គាត់កម្រមានវត្តមាននៅទីនោះណាស់..................106

ឃ ឡើយ ៤១ អោ អាន ពុំមានសិទ្ធិអំណាចលើយោធាតំបន់ ( ....................................110

ច អោ អាន ជាបីបើទោះ (ជាលេខាតំបន់ ៤១ ឬមានសិទ្ធិអំណាចនៅកម្រិតតំបន់ ក៏ការនេះមិនមានន័យថា គាត់ស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតដែរ ....................................119

vi. អោ អាន មិនមានតួនាទីនៅក្នុងអំពើ ប្រល័យពូជសាសន៍ជនជាតិចាម ដែលត្រូវបានចោទប្រកាន់នោះទេ ....................................120

vii. អោ អាន មិនមានតួនាទីនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភផ្លូវភេទដែលត្រូវបានចោទប្រកាន់ នៅស្រុកកំពង់សៀមនិងព្រៃឈរ....................................122

viii. អោ អាន មិនមានតួនាទីនៅក្នុងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ នៅទីតាំងឧក្រិដ្ឋកម្មឡើយ...125

ix. ការសន្និដ្ឋានលើសំអាងហេតុទី៦....................................125

ចដែលសម្រេចថា ឧក្រិដ្ឋកម្មការក្នុងឆ្លងកំហុសអង្កេតអន្តរជាតិ មានស៊ើបចៅក្រម៖ សហា៧ទីសំអាងហេតុ . គ្រាន់ល្មមគ្រប់ទម្ងន់ស្ថានប្រកាន់ មានចោទបានត្រូវ ....................................126

i. សហាចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់ភ័ស្តុតាងជាចម្បង ពាក់ព័ន្ធតែតំបន់ភូមិសាស្ត្រតូចមួយ......126

ii. សហាចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភ័ស្តុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការគណនារាបស់គាត់ ទៅលើចំនួនជនរងគ្រោះយ៉ាងខ្ពស់ នៅក្នុងភូមិភាគកណ្តាល ឬតំបន់៤១....................................127

iii. សហាចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអាចដាក់បន្ទុកអំពើប្រល័យពូជសាសន៍ ទៅលើ អោ អាន តាមរយៈទម្រង់នៃការទទួលខុសត្រូវ ដែលបានចោទប្រកាន់នោះឡើយ....................................128

ឆ៧ទីដល់២ទីសំអាងហេតុសម្រាប់សន្និដ្ឋានការ . ....................................130

III. សំអាងហេតុទី៨ ដល់ទី១៧ ពាក់ព័ន្ធកំហុសឆ្គងរបស់សហាចៅក្រមស៊ើបអង្កេតអន្តរជាតិ លើច្បាប់សារធាតុ ....................................130

កអន្តរទម្លាប់ទំនៀមឆ្គងនូវ ច្បាប់ខុសដោយអន្តរជាតិ អនុវត្តអង្កេតស៊ើបចៅក្រម៖ សហា៨ទីសំអាងហេតុ . ភាពនីត្យានុកូលការណ៍លើ គោលទៅបំពានរំលោភជាតិ ដោយ ....................................130

ខ.វ.នៅ អបានអនុវត្តអាចខុសត្រូវ ដែលទទួលការនៃទម្រង់ ជាមែនមិនរួមឧក្រិដ្ឋកម្ម៖ សហា៩ទីសំអាងហេតុ . ក ឡើយ.ត....................................134

គបាន អនុវត្តអាចត្រូវដែលខុសទទួលការនៃជាទម្រង់គឺ រួមឧក្រិដ្ឋកម្មសហាបើ៖ ប្រសិន១០ទីសំអាងហេតុ . អអង្កេតស៊ើបចៅក្រមសហាន្តរជាតិមិនបានកំណត់និយមន័យឲ្យបានគ្រប់គ្រាន់ និងមិនបានអនុវត្តលក្ខខណ្ឌរបស់សហាឧក្រិដ្ឋកម្មរួមឲ្យបានគ្រប់គ្រាន់ ....................................137

ឃក .ត.វ.អ ជាធរមាន នៅត្រូវខុសទទួលការនៃទម្រង់មែនជាមិនគឺ ផែនការចំរៀប៖ ការ១១សំអាងហេតុទី . ឡើយ ....140

ង៖ ការ១២ទីសំអាងហេតុ .ទទួលខុសត្រូវរបស់ថ្នាក់លើ គឺមិនមែនជាទម្រង់នៃការ ទទួលខុសត្រូវជាធរមាន នៅក្នុងសំណុំរឿង អោ អាន ឡើយ ហើយបើទោះបីវាជាទម្រង់ នៃការទទួលខុសត្រូវជាធរមានក្តី ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុវត្តដោយមិនត្រឹមត្រូវនូវធាតុផ្សំគតិយុត្តិ....141

ចពីចន្លោះប្រព្រឹត្តបានជាតិដែលឧក្រិដ្ឋកម្មជម្រះជំនុំការយុត្តាធិការក្នុងមានក មិន.ត.វ.៖ អ១៣ទីសំអាងហេតុ . ១៩៧៩ឆ្នាំដល់ ១៩៧៥ឆ្នាំ....143

ឆត្រូវ គតិយុត្តិត្រឹមតម្រូវលក្ខខណ្ឌអនុវត្តបានអន្តរជាតិ មិនអង្កេតស៊ើបចៅក្រម៖ សហ១៤ទីសំអាងហេតុ . ទៀតផ្សេងធម៍មនុស្សអំពើសម្រាប់....145

i. តម្រូវឲ្យមានពិរុទ្ធភាពជាមូលដ្ឋានសម្រាប់អំពីអមនុស្សធម៌ផ្សេងៗទៀត....145

ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុវត្តមិនត្រឹមត្រូវនូវបទដ្ឋានធាតុផ្សំអត្តនោម័តចំពោះអំពើអមនុស្សធម៍ផ្សេងៗទៀត....148

ជ៖៥សំអាងហេតុទី . អាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសក្រោមយុត្តាធិការ អ.វ.ត.ក ទេ....149

ឈ. សំអាងហេតុទី១៦៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានកំណត់ និងអនុវត្តបានត្រឹមត្រូវនូវធាតុផ្សំនៃអំពើប្រល័យពូជសាសន៍....150

i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធលក្ខខណ្ឌបង្កើតអត្ថិភាពនៃធាតុផ្សំនៃអំពើប្រល័យ ពូជសាសន៍តាមបរិបទ....151

ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញថា ប្រជាជនចាមត្រូវបានកំណត់អត្តសញ្ញាណ និងកំណត់មុខសញ្ញាជាវិជ្ជមាន "ជាអាទិ៍"....152

iii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានអនុវត្តលក្ខខណ្ឌអត្តនោម័តនៃអំពើប្រល័យពូជសាសន៍ចំពោះ អោ អាន និង ខកខានមិនបានបង្ហាញថា អោ អាន មានចេតនាជាក់លាក់....154

ញ. សំអាងហេតុទី១៧៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខាកខានមិនបានបញ្ចូលបទប្រល័យពូជសាសន៍នៅក្នុងគោលបំណងរួមនៃក្រុមសហកម្មឧក្រិដ្ឋកម្មរួម....157

ដ. សេចក្តីសន្និដ្ឋានសំអាងហេតុទី៨-១៧....159

IV. សំអាងហេតុទី១៨៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ឬរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដោយខកខានមិនបានបដិសេធ ឬ ផ្អាកសំណុំរឿង០០៤/០២ ដើម្បីធានាភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចនីតិវិធី និង សិទ្ធិ

របស់អោ អាន ........................................................................................................159

ក. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានតួនាទីធានាឯករាជភាពតុលាការ ភាពយុត្តិធម៌ និងសុចរិតភាពកិច្ច នីតិវិធី និង សិទ្ធិ របស់ អោ អាន ........................................................................................160

ខ. វិធានមតិភាគច្រើនលើសលុបបានរំលោភសច្ចធាណ៍និរទោសរបស់ អោ អាន.............................162

គ. កំហុស ការខកខានមិនបានអនុវត្ត និង ការអនុវត្តដោយឆ្វេសប្រហែសទាំងឡាយដែលរំលោភ សិទ្ធិនីតិវិធី របស់ អោ អាន......................................................................................................165

ង. ផលប៉ះពាល់នៃការរំលោភបំពានដែលចេះតែកើនឡើង បណ្តាលឲ្យមានព្យសនកម្មដែលមិនអាចជួសជុលបាន ..........................................................................................................................179

ង. ការផ្អាកបណ្តោះអាសន្នឬការបដិសេធ គឺជាឧបាស្រ័យគ្រប់គ្រាន់តែមួយគត់.............................182

ច. សេចក្តីសន្និដ្ឋានសម្រាប់សំអាងហេតុទី១៨ ..................................................................184

សេចក្តីសន្និដ្ឋាន និងសំណើ ....................................................................................................184

## សេចក្តីផ្តើម និងសេចក្តីសង្ខេបនៃទឡ្ហីករណ៍

1. តាមរយៈសហមេធាវី (បន្ទាប់ពីនេះហៅកាត់ថា‘*មេធាវីការពារក្តី*’) របស់ខ្លួន លោក អោ អាន សូមដាក់*បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ*[1] អនុលោមតាមវិធាន២១ វិធាន ៦៧(៥) និងវិធាន៧៤(៣) នៃវិធានផ្ទៃក្នុង។ អង្គបុរេជំនុំជម្រះ (ហៅកាត់ "អ.ប.ជ") ត្រូវតែច្រានចោលដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ និងបដិសេធរឿងក្តីរបស់ អោ អាន ដោយយោងទៅលើសំអាងហេតុនៃបណ្តឹងឧទ្ធរណ៍ ដែលត្រូវបានលើកឡើងដូចតទៅនេះ។ មេធាវីការពារក្តីបញ្ជាក់តាំងពីដំបូងមកថា សិទ្ធិរបស់ខ្លួនក្នុងការប្តឹងឧទ្ធរណ៍ត្រូវបានកម្រិតយ៉ាងតឹងរ៉ឹងបំផុតតាមរយៈចំនួនពាក្យពេចន៍ដែលបានកម្រិត និងពេលវេលាកំណត់ ហើយមេធាវីការពារក្តីរក្សាសិទ្ធិជំទាស់តវ៉ាទៅនឹងការចោទប្រកាន់ទាំងអស់នៅក្នុងសវនាការ។ អោ អាន អះអាងថា គាត់ពុំមានទោសពៃរ៍អ្វីចំពោះបទចោទទាំងអស់នេះទេ។

2. *សំអាងហេតុទី ១*៖ ក្រោយពីការស៊ើបអង្កេតអស់រយៈពេលជិត ១០ ឆ្នាំកន្លងមក អោ អាន កំពុងស្ថិតក្នុងស្ថានភាពពិសេសដែលលោកត្រូវបានចោទប្រកាន់ និងស្នើឲ្យបញ្ជូនខ្លួនទៅជំនុំជម្រះពីសំណាក់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ហៅកាត់ថា "ស.ច.ស.អ") ហើយត្រូវបានសហចៅក្រមស៊ើបអង្កេតជាតិ បដិសេធសំណុំរឿងរបស់គាត់ ក្នុងពេលតែមួយ។[2] ស្ថានភាពមិនច្បាស់លាស់គ្មានកម្រិតនេះ ត្រូវតែដោះស្រាយដោយឲ្យប្រយោជន៍ដល់ អោ អាន។ ការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាបែបនេះ គឺមិនធ្លាប់មានពីមុនមកទេ មិនស្របទៅនឹងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ហៅកាត់ថា "អ.វ.ត.ក") ទេ ព្រមទាំងរំលោភសិទ្ធិជាមូលដ្ឋានរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងគោលការណ៍សច្ចភាពផ្លូវច្បាប់ថែមទៀតផង។ ក្របខណ្ឌច្បាប់សម្រាប់ អ.វ.ត.ក អនុញ្ញាតឲ្យមានដីកាដំណោះស្រាយតែមួយប៉ុណ្ណោះ ដែលអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះក្តី ឬដីកាលើកលែងចោទប្រកាន់ក្តី។

---

[1] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាដំណោះស្រាយរបស់ ស.ច.ស.អ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ **D360** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[2] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន* (‘*ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ*’), ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៥៥២-៥៥។

3. *សំអាងហេតុទី ២ ដល់ ៧៖* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រព្រឹត្តកំហុសអង្គច្បាប់ និងកំហុសអង្គហេតុជាច្រើន នៅពេលសម្រេចថា អោ អាន ជា'អ្នកទទួលខុសត្រូវខ្ពស់បំផុត' និងស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់តុលាការនេះ។ ដោយការធ្វើមិនដឹងមិនឮចំពោះការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រកាសទាំងខុសឆ្គងថាគាត់មានឆន្ទានុសិទ្ធិដោយសេរី ដើម្បីពិចារណាអំពីយុត្តាធិការ និងកំណត់អំពី 'អ្នកទទួលខុសត្រូវខ្ពស់បំផុត' នៅក្នុងលក្ខណៈមួយដែលទូលំទូលាយបំផុត។ គាត់ពង្រីកបទដ្ឋាននៃភ័ស្តុតាងដែលតម្រូវឲ្យមានជាចាំបាច់ ជាលទ្ធផល បទដ្ឋាននេះទៅជាមើលលែងស្គាល់ ហើយគាត់មិនបានពិចារណាពេញលេញលើខ្លឹមសារនៃភ័ស្តុតាងទេ។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ហាក់មិនអើពើចំពោះកង្វះភ័ស្តុតាងដែលគួរឲ្យជឿជាក់បាន នៅក្នុងសំណុំរឿង សូម្បីតែក្រោយរយៈពេល ១០ ឆ្នាំនៃកិច្ចស៊ើបសួរមកហើយក្តី ហើយសំអាងតែទៅលើចម្លើយដែលមិនស្របគ្នា ជាប់ប្រឡាក់ប្រឡូកមិនស៊ីសង្វាក់គ្នា ឮតៗគ្នា និងលម្អៀង ពីសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗមួយចំនួនប៉ុណ្ណោះ។ នៅពេលណាដែលភ័ស្តុតាងនេះត្រូវបានវាយតម្លៃយ៉ាងត្រឹមត្រូវហើយ នោះវាច្បាស់ណាស់ថា អោ អាន ពិតជាពុំមានតួនាទីអ្វីសំខាន់នៅក្នុងភូមិភាគកណ្តាល ឬតំបន់ ៤១ ទេ និងពុំមានតួនាទីអ្វីនៅក្នុងចំណោមឧក្រិដ្ឋកម្មណាមួយដែលបានយកមកចោទប្រកាន់នោះឡើយ។ អោ អាន ពុំស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវបំផុតទេ បើប្រៀបធៀបនឹងកម្មាភិបាលខ្មែរក្រហមដទៃទៀតដែលគេស្គាល់ច្បាស់នោះ។

4. *សំអាងហេតុទី ៨ ដល់ ១៧៖* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រព្រឹត្តកំហុសមួយចំនួនទាក់ទងនឹងច្បាប់សារធាតុ។ មានន័យថា គាត់មានកំហុសនៅក្នុង៖ (ក) ការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនបានត្រឹមត្រូវដែលជាការរំលោភលើគោលការណ៍នីត្យានុកូលភាព (ខ) សំអាងតែលើសហឧក្រិដ្ឋកម្មរួម (Joint Criminal Enterprise "JCE") ថាជាទម្រង់នៃការទទួលខុសត្រូវមួយដែលអាចយកមកអនុវត្តបាន (គ) ខកខានពុំបានកំណត់ និងអនុវត្តព្រំដែននៃសហឧក្រិដ្ឋកម្មរួមឲ្យបានគ្រប់ជ្រុងជ្រោយ (ខ) លើកឡើងថាការរៀបចំផែនការជាទម្រង់នៃការទទួលខុសត្រូវមួយដែលអាចយកមកអនុវត្តបាន (ង) អនុវត្តលក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់ពុំបានត្រឹមត្រូវសម្រាប់ការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើ (ច) យល់ឃើញថា អ.វ.ត.ក មានយុត្តាធិការទៅលើបទល្មើសជាតិ (ឆ) អនុវត្តលក្ខខណ្ឌតម្រូវតាមផ្លូវច្បាប់ពុំបានត្រឹមត្រូវចំពោះអំពើអមនុស្សធម៌ផ្សេងទៀត (ជ) យល់ឃើញថា អ.វ.ត.ក មានយុត្តាធិការទៅលើការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ (ឈ) ខកខាន

ពុំបានអនុវត្ត និងកំណត់ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឲ្យបានត្រឹមត្រូវ និង (ញ) ខកខានពុំបានដាក់បញ្ចូលអំពើប្រល័យពូជសាសន៍ទៅក្នុងគោលបំណងរួមរបស់ក្រុមសហឧក្រិដ្ឋកម្មរួម។

5. *សំអាងហេតុទី ១៨៖* ចុងក្រោយបង្អស់ ចាប់តាំងពីដើមដំបូងនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការរហូតទល់នឹង រួមទាំងពេលចេញដីកាដំណោះស្រាយផង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកាតព្វកិច្ចជាវិជ្ជមានក្នុងការចាត់វិធានការចាំបាច់នានាដើម្បីធានាឲ្យមានភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីនាបច្ចុប្បន្ន និងអនាគតនៅក្នុងសំណុំរឿង ០០៤/២ ព្រមទាំងសិទ្ធិរបស់ អោ អាន។ គាត់ពុំបានអនុវត្តបែបនេះទេ។ វិធានស្តីពីសំឡេងភាគច្រើនលើសលប់ បានធ្វើឲ្យអន្តរាយដល់សច្ចធារណ៍នៃភាពគ្មានទោសរបស់ អោ អាន ក្នុងកិច្ចស៊ើបសួរទាំងមូល។ លើសពីនេះទៀត កំហុសមួយចង្កោម ការខកខាន និងការអនុវត្តពុំបានត្រឹមត្រូវ បានរំលោភលើបទដ្ឋានមូលដ្ឋានជំនុំជម្រះក្តីដោយយុត្តធម៌ រួមទាំងសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានមេធាវីការពារក្តី សិទ្ធិទទួលបានការជូនដំណឹងអំពីបទចោទប្រកាន់មកលើគាត់ សិទ្ធិក្នុងការរៀបចំការពារខ្លួនប្រកបដោយប្រសិទ្ធិភាព សិទ្ធិទទួលបានសមភាពក្នុងការតតាំងក្តី និងសិទ្ធិប្តឹងឧទ្ធរណ៍។ វិបត្តិថវិកា និងភាពពុំច្បាស់លាស់អំពីបញ្ហាថវិកានាពេលអនាគតរបស់តុលាការនេះ កាន់តែបណ្តាលឲ្យសិទ្ធិរបស់ អោ អាន និងសុចរិតភាពរបស់តុលាការនេះស្ថិតក្នុងភាពអន្តរាយបន្ថែមទៀត។ ដោយសារតែការរំលោភបំពាននីមួយៗធ្វើឲ្យអន្តរាយដល់លទ្ធភាពរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ នោះផលប៉ះពាល់ដែលកាន់តែកើតឡើងបន្ថែមចេញពីការរំលោភទាំងនេះ បណ្តាលឲ្យប៉ះពាល់ដល់ភាពត្រឹមត្រូវ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីតាមរបៀបមួយដែលអាក្រក់បំផុត និងមិនអាចជួសជុលបានដែលបណ្តាលឲ្យការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ មិនអាចប្រព្រឹត្តទៅបានឡើយ។

6. អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមស្នើសុំដោយគោរពថា អង្គបុរេជំនុំជម្រះ ត្រូវច្រានចោល *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* និង លើកលែងការចោទប្រកាន់លើ អោ អាន។

## ប្រវត្តិនីតិវិធី

7. មេធាវីការពារក្តីសូមដាក់បញ្ចូលដោយយោងចាប់ពីកថាខណ្ឌ ១៥ ដល់កថាខណ្ឌ ២៤ *នៃចម្លើយតប*

*របស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ("ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអន្តរជាតិ")*។[3]

8. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេត បានចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នាជាភាសាអង់គ្លេសមួយ និងភាសាខ្មែរមួយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចោទប្រកាន់ និងបញ្ជូនសំណុំរឿងរបស់ អោ អាន ទៅជំនុំជម្រះ[4] ចំណែកឯសហចៅក្រមស៊ើបអង្កេតជាតិ បានលើកលែងការចោទប្រកាន់ដោយសំអាងថាតុលាការនេះពុំមានយុត្តាធិការបុគ្គលលើ អោ អាន។[5] សំណៅបកប្រែនៃដីកាដំណោះស្រាយទាំងពីរ ត្រូវបានដាក់ជូនដាច់ដោយឡែកពីគ្នាកាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ និងថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨។

9. នៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨ មេធាវីការពារក្តីបានដាក់*ការជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍របស់ខ្លួន* និងបានស្នើសុំពេលវេលាបន្ថែម និងការបង្កើនចំនួនទំព័រសម្រាប់*បណ្តឹងឧទ្ធរណ៍នេះ*។[6] នៅថ្ងៃទី០៦ ខែតុលា ឆ្នាំ២០១៨ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ចម្លើយតបរបស់ខ្លួន។[7] ថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ អង្គបុរេជំនុំជម្រះ បានចេញសេចក្តីសម្រេចរបស់ខ្លួនដោយកម្រិតកាលបរិច្ឆេទកំណត់សម្រាប់ភាគីដាក់បណ្តឹងឧទ្ធរណ៍ក្នុងរយៈពេល ៤៥ ថ្ងៃ ចាប់ពីថ្ងៃទទួលបានឯកសារបកប្រែនៃដីកាដំណោះស្រាយទាំងពីរ និងកំណត់ចំនួនទំព័រសម្រាប់ការដាក់បណ្តឹងឧទ្ធរណ៍នីមួយៗ

---

[3] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៦៦* ឯកសារ **D351/6** ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ១៥-២៤។

[4] សំណុំរឿង ០០៤/២-ឯកសារ **D360**, បទចោទ ១-៣ ទំព័រ ៤០៩-៤១៥។ ស.ច.ស.អ ក៏បានច្រានចោលបទចោទមួយចំនួនប្រឆាំងនឹង អោ អាន ទំព័រ ៤០៧-៤០៨។

[5] សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៥៥២-៥៥៥។

[6] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៥៦) *សេចក្តីជូនដំណឹងអំពីបណ្តឹងឧទ្ធរណ៍* ឯកសារ **D360/5** ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១៨។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៥៦) *សំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយ* ឯកសារ **D360/4** ចុះថ្ងៃទី០៥ ខែតុលា ឆ្នាំ ២០១៨ កថាខណ្ឌ ៤។

[7] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៥៦) *ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងណើរបស់ អោ អាន ស្នើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ **D360/6** ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ កថាខណ្ឌ ១។

ចំនួន ១០០ ទំព័រ។[8]

## ច្បាប់ជាធរមាន

10. មេធាវីការពារក្តីសូមដាក់បញ្ចូលច្បាប់ជាធរមានទៅក្នុងផ្នែកស្តីពីសំអាងហេតុក្នុងបណ្តឹងឧទ្ធរណ៍ ដូចខាងក្រោមនេះ។

## ភាពអាចទទួលយកបាន

11. បណ្តឹងឧទ្ធរណ៍នេះអាចទទួលយកបាន ស្របតាមវិធាន ៦៧(៥) វិធាន ៧៤(៣)(ក) និងវិធាន ២១ នៃវិធានផ្ទៃក្នុង ដោយហេតុថាបណ្តឹងឧទ្ធរណ៍នេះលើកឡើងពីកំហុសអង្គច្បាប់ និងអង្គហេតុពាក់ព័ន្ធនឹងការពិចារណាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីយុត្តាធិការបុគ្គល និងយុត្តាធិការលើបទល្មើស ព្រមទាំងការរំលោភបំពានរបស់គាត់មកលើសិទ្ធិរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ អនុលោមតាមវិធាន ៦៧(៥) ដីកាដំណោះស្រាយ *(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* គឺជាកម្មវត្ថុចំពោះការប្តឹងឧទ្ធរណ៍ដូចមានចែងក្នុងវិធាន ៧៤។ មេធាវីការពារក្តីបានដាក់ *បណ្តឹងឧទ្ធរណ៍*នៅក្នុងរង្វង់ព្រំដែនដែលកំណត់ដោយអង្គបុរេជំនុំជម្រះ។ មេធាវីការពារក្តីលើកឡើងពីសំអាងហេតុនានាសម្រាប់ភាពអាចទទួលយកបាននៃសំអាងហេតុនីមួយៗដូចខាងក្រោមនេះ។

12. *វិធាន ៧៤(៣)(ក) និងយុត្តាធិការបុគ្គល*៖ វិធាន ៧៤(៣) អនុញ្ញាតយ៉ាងច្បាស់លាស់ឱ្យមេធាវីការពារក្តីធ្វើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើយុត្តាធិការ និងគ្រប់ដីកាសម្រេច។ ក្នុងសំណុំរឿង ០០៤/១ អង្គបុរេជំនុំជម្រះ បានសម្រេចថាការពិចារណាអំពីយុត្តាធិការបុគ្គលអាចពិនិត្យឡើងវិញបាន ហើយអង្គបុរេជំនុំជម្រះ បានប្រើប្រាស់វិធីសាស្ត្រដ៏ទូលំទូលាយនៅក្នុងការទទួលយកការជំទាស់តវ៉ានានារបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅលើបញ្ហាយុត្តាធិការទៅនឹង

---

[8] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលា និងចំនួនទំព័រកំណត់សម្រាប់បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ **D360/7** ចុះថ្ងៃទី០៨ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៦។

ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។[9] អង្គបុរេជំនុំជម្រះ បានពន្យល់ថា ក្នុងឋានៈជាតុលាការជាន់ខ្ពស់ អង្គបុរេជំនុំជម្រះត្រូវតែពិនិត្យទៅលើការយល់ឃើញទាំងអស់របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលនាំឱ្យឈានដល់ការសម្រេចលើយុត្តាធិការបុគ្គល រួមទាំង ការពិនិត្យលើបញ្ហាទាក់ទងនឹងអត្ថិភាពនៃបទល្មើស ទម្រង់ជាក់លាក់នៃបទល្មើស និងភវនីយភាព (likelយhood) នៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនត្រូវចោទ។[10]

13. *សំអាងហេតុទី ១ ដល់ ៧, ១០, ១២, ១៤, និងទី ១៦ ដល់ ១៧* អាចទទួលយកបាន អនុលោមតាម វិធាន ៧៤(៣)(ក) ដែលជាការជំទាស់តវ៉ាមានសុពលភាព ចំពោះការអះអាងរបស់ សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ អំពីយុត្តាធិការបុគ្គលរបស់តុលាការនេះមកលើ អោ អាន។ សំអាងហេតុទី១ លើកឡើងពីកាចេញដីកាដំណោះស្រាយទាំងមិនត្រឹមត្រូវរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលអះអាងអំពីយុត្តាធិការរបស់តុលាការនេះ ខណៈដែល សហចៅក្រមស៊ើបអង្កេតជាតិ បាន ច្រានចោលរឿងក្តីយ៉ាងត្រឹមត្រូវ ដោយសារតែពុំមានយុត្តាធិការបុគ្គល។ សំអាងហេតុទី ២ ដល់ ៧ ពាក់ព័ន្ធនឹងកំហុសអង្គហេតុ និងអង្គច្បាប់របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅពេល សម្រេចថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបាន ចោទប្រកាន់។ ចុងក្រោយ សំអាងហេតុទី ១០, ១២, ១៤, និង ១៦ ដល់ ១៧ គឺជាការជំទាស់តវ៉ា ចំពោះចង្កោមនៃបទល្មើសប្រល័យពូជសាសន៍ អំពើអមនុស្សធម៌ដទៃទៀត និងសហឧក្រិដ្ឋកម្មរួម នៅក្នុងដីកាដំណោះស្រាយ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានកំណត់ឧក្រិដ្ឋកម្ម ទាំងនេះ និងបានអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវបំផុត នោះ អោ អាន មិនអាចស្ថិតក្នុងចំណោមអ្នក ទទួលខុសត្រូវខ្ពស់បំផុតឡើយ។

---

[9] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៥០) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ)* ឯកសារ **D308/3/1/20** ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ២០, ២៦។ អបជ បានកត់សម្គាល់ថា បណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ដោយ ស.ព.អ អនុលោមតាមវិធាន ៧៤(២) នៃវិធានផ្ទៃក្នុង។ វិធាននេះពុំបានបញ្ជាក់បំភ្លឺថាតើមេធាវីការពារក្តីនឹងមានលទ្ធភាពទូលំទូលាយដូចគ្នាក្នុងការប្តឹងបញ្ហាយុត្តាធិការបុគ្គលដែរឬយ៉ាងណានោះទេ។ មេធាវីការពារក្តីសន្និដ្ឋានថា វិសាលភាពនៃបណ្តឹងឧទ្ធរណ៍លើយុត្តាធិការត្រូវមានដូចគ្នាចំពោះមេធាវីការពារក្តី និង ក.ស.ព ដោយសារ មិនខុសពីវិធាន ៧៤(២) នៃវិធានផ្ទៃក្នុងនោះទេ វិធាន ៧៤(៣)(ក) អនុញ្ញាតយ៉ាងជាក់លាក់ឱ្យមេធាវីការពារក្តីប្តឹងឧទ្ធរណ៍ប្រឆាំងដីកា និងសេចក្តីសម្រេចតម្កល់យុត្តាធិការរបស់តុលាការ។

[10] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២៤-២៦។

14. *វិធាន ៧៤(៣)(ក) និងយុត្តាធិការលើបទល្មើស៖* សំអាងហេតុទី ៨ ដល់ ៩, ១១, ១៣ និង ១៥ អាចទទួលយកបាន ស្របតាមវិធាន ៧៤(៣)(ក) ដែលជាការជំទាស់តវ៉ាមានប្រសិទ្ធភាពចំពោះយុត្តាធិការលើបទល្មើសរបស់តុលាការនេះ។ សំអាងហេតុទាំងនេះរៀបរាប់ពីអត្ថិភាពនៃឧក្រិដ្ឋកម្មជាក់លាក់មួយចំនួន ព្រមទាំងទម្រង់នៃការទទួលខុសត្រូវ និងថាតើការអនុវត្តទម្រង់នៃការទទួលខុសត្រូវទាំងនេះនៅក្នុងសំណុំរឿង ០០៤/២ រំលោភគោលការណ៍នីត្យានុកូលភាពដែរឬយ៉ាងណា។ អង្គបុរេជំនុំជម្រះ បានលើកឡើងពីមុនរួចមកហើយថាការជំទាស់តវ៉ាទៅលើយុត្តាធិការលើបទល្មើសអាចទទួលយកបាននៅក្នុងបណ្តឹងឧទ្ធរណ៍លើដីកាដំណោះស្រាយនានា ដោយអនុលោមតាមវិធាន ៧៤(៣)(ក)។[11] ការជំទាស់តវ៉ាទាំងនេះអាចត្រូវបានលើកឡើងប្រឆាំងនឹងអត្ថិភាពផ្លូវច្បាប់ចំពោះបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មទាំងមូល ឬអត្ថិភាពនៃធាតុផ្សំទូទៅសម្រាប់ឧក្រិដ្ឋកម្មទាំងនេះ។[12]

15. *វិធាន ៧៤(៣) ដោយយោងទៅវិធាន ២១៖* សំអាងហេតុទី ១ និង ៨ អាចទទួលយកបានចំពោះការបកស្រាយទូលំទូលាយនៃវិធាន ៧៤(៣) ដោយយោងតាមវិធាន ២១។ សំអាងហេតុទាំងនេះលើកឡើងពីការរំលោភធ្ងន់ធ្ងរ ទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន។ អង្គបុរេជំនុំជម្រះ បានទទួលស្គាល់រួចមកហើយថាក្នុងករណីដែលអង្គហេតុ និងកាលៈទេសៈតម្រូវខ្លួនអាចពិចារណាទៅលើសំអាងហេតុដែលមិនបានរៀបរាប់ច្បាស់លាស់ ដោយអនុលោមតាមវិធាន ៧៤(៣) "តាមរយៈការបកស្រាយដោយសេរីអំពីសិទ្ធិរបស់ជនត្រូវចោទក្នុងបណ្តឹងឧទ្ធរណ៍ស្របតាមវិធាន ២១ នៃវិធានផ្ទៃក្នុង"។[13] ជាពិសេស អង្គបុរេជំនុំជម្រះបានទទួលយកបណ្តឹងឧទ្ធរណ៍ទាំងឡាយដែលលើកឡើងពីបញ្ហាបន្ទាន់បង្ខំដែលវិធានផ្ទៃក្នុងមិនបានប្រមើលឃើញជា

---

[11] សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ៧៥) *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង សារី ប្រឆាំងនឹងដីកាដំណោះស្រាយ* ឯកសារ **D427/1/30** ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤៥-៤៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១។ សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ១៤៥ & ១៤៦) ឯកសារ **D427/2/15** ចុះថ្ងៃទី ១៥ ខែកុម្ភៈ ឆ្នាំ២០១១ កថាខណ្ឌ ៦០-៦១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២។ សូមមើលផងដែរ សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ៣៨) *សាលដីកាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម* ឯកសារ **D97/15/9** ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ២២-២៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣។

[12] សំណុំរឿង ០០២-ឯកសារ **D427/1/30** កថាខណ្ឌ ៤៦។ សំណុំរឿង ០០២-ឯកសារ **D427/2/15** កថាខណ្ឌ ៦០, ៦១។

[13] សំណុំរឿង ០០២-ឯកសារ **D427/2/15** កថាខណ្ឌ ៧១។

មុន[14] និងបណ្តឹងឧទ្ធរណ៍ដែលលើកឡើងពីបញ្ហាធ្ងន់ធ្ងរនៃភាពត្រឹមត្រូវ។[15]

16. ដោយសារតែវិធាន ២១ មិនមានចែងពីសំអាងហេតុនៃបណ្តឹងឧទ្ធរណ៍ ទើបអង្គបុរេជំនុំជម្រះ បានទទួលស្គាល់ថា "ការពិចារណាលើសលុបនៅក្នុងរាល់កិច្ចដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺភាពយុត្តិធម៌[16] នៃកិច្ចដំណើរការនីតិវិធីទាំងនេះ"។[17] លើសពីនេះទៅទៀត អង្គបុរេជំនុំជម្រះ បានសម្រេចថា ក្នុងករណីដែលបណ្តឹងឧទ្ធរណ៍ត្រូវបានដាក់ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជម្រះ "លើកឡើងអំបញ្ហាដែលមិនអាចឱ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការកែប្រែបាន" និងមិនអនុញ្ញាតឱ្យមានលទ្ធភាព ប្តឹងឧទ្ធរណ៍ "នឹងបង្កការខូចខាតដែលមិនអាចឱ្យជួសជុលបានដល់សិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌" វិធាន ២១ នៃវិធានផ្ទៃក្នុងអាច "ធានាការអនុវត្តដើម្បីពង្រីកវិសាលភាពវិសាលភាពនៃវិធាន៧៤នៃវិធានផ្ទៃក្នុង មួយករណីជាក់ស្តែងមួយៗ" ។[18] អាស្រ័យហេតុនេះ បញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងសំអាងហេតុទី ១ និង ៨ អាចទទួលយកបានដោយសារតែសំអាងហេតុទាំងអស់នេះមានលក្ខណៈធ្ងន់ធ្ងរ និងត្រូវតែដោះស្រាយមុនការជំនុំជម្រះ។

[14] សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ១៩) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់ អ៊ឹម ចែម ប្រឆាំងនឹងដីការបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រេចដាក់អ្នកស្រីឱ្យស្ថិតក្រោមការពិនិត្យដោយកំបាំងមុខ* ឯកសារ **D239/1/8** ចុះថ្ងៃទី១ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ២៣។ សំណុំរឿង ០០២-ឯកសារ **D427/2/15** កថាខណ្ឌ ៧១។

[15] សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ៤២) *សាល សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើសុំផ្អាកកិច្ចស៊ើបសួរដោយមូលហេតុរំលោភនីតិវិធី (D264/1)*, ឯកសារ **D264/2/6** ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ កថាខណ្ឌ ១៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥។

[16] ការបង្កើតជាភាពយុត្តិធម៌នៅគ្រប់ដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក គួរមើលតាមច្បាប់ និងបទដ្ឋានអន្តរជាតិ។ ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តនៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ('*ច្បាប់ អ.វ.ត.ក*') មាត្រា ៣៣ *ថ្មី*។ សំណុំរឿង ០០២-ឯកសារ **D264/2/6** កថាខណ្ឌ ១៣។ សំណុំរឿង ០០២-ឯកសារ **D97/15/9** កថាខណ្ឌ ៣១-៣៤។

[17] សំណុំរឿង ០០២-ឯកសារ **D264/2/6** កថាខណ្ឌ ១៤។

[18] សំណុំរឿង ០០២-ឯកសារ **D427/1/30** កថាខណ្ឌ ៤៨-៤៩។ *សូមមើល* សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ១០៤) *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាដំណោះស្រាយ* ឯកសារ **D427/4/15** ចុះថ្ងៃទី២១ ខែមករា ឆ្នាំ២០១១ កថាខណ្ឌ ១៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥។ សំណុំរឿង ០០២-ឯកសារ **D427/2/15** កថាខណ្ឌ ៧១-៧៣។

## បទដ្ឋាននៃការត្រួតពិនិត្យឡើងវិញ

17. អង្គបុរេជំនុំជម្រះ អាចត្រួតពិនិត្យឡើងវិញទៅលើសេចក្ដីសម្រេចនានារបស់ ស.ច.ស ក្នុងករណីដែលសេចក្ដីសម្រេចទាំងនេះ៖ (ក) បានសំអាងទៅលើការបកស្រាយខុសចំពោះច្បាប់ដែលគ្របដណ្ដប់ (កំហុសអង្គច្បាប់) (ខ) បានសំអាងទៅលើសេចក្ដីសន្និដ្ឋានផ្នែកអង្គហេតុខុសយ៉ាងច្បាស់ក្រឡែត (កំហុសអង្គហេតុ) ឬ (គ) មិនត្រឹមត្រូវ ឬមិនសមហេតុផលទាល់តែសោះក្នុងការបន្តរំលោភឆន្ទានុសិទ្ធិបែបនេះ។[19] អង្គបុរេជំនុំជម្រះ បានសម្រេចថា កំហុសឆ្គង ឬការរំលោភបំពានត្រូវតែ"មានអានុភាព" ទៅលើការអនុវត្តឆន្ទានុសិទ្ធិដែលនាំឲ្យឈានដល់ការសម្រេចសេចក្ដីរងការជំទាស់តវ៉ាបែបនេះ ។[20] បទដ្ឋាននេះ[21] ស្របនឹងយុត្តិសាស្ត្រអន្តរជាតិ។[22]

---

[19] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២០-២១។ សំណុំរឿង ០០២-ឯកសារ **D427/2/15** កថាខណ្ឌ ៨៦។ សំណុំរឿង ០០២-ឯកសារ **D427/1/30** កថាខណ្ឌ ១១១។ សូមមើលផងដែរ សំណុំរឿង ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ៣៥) *សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ អោ អាន* ឯកសារ **D320/1/1/4** ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ ១០។ សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/ក.ស.ច.ស (អបជ ៦៧) *សាលដីកាស្ដីពីការពិចារណាឡើងវិញទៅលើបណ្ដឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតទៅលើសំណើសុំដាក់បញ្ចូលឯកសារភស្តុតាងបន្ថែមទៅក្នុងសំណុំរឿងដែលនឹងជួយដល់ការបញ្ជាក់ការដឹងឮរបស់ជនជាប់ចោទចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើង* ឯកសារ **D365/2/17** ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៣៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦។

[20] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ 21។ សំណុំរឿង ០០៤/២-ឯកសារ **D320/1/1/4** កថាខណ្ឌ ១០។

[21] ច្បាប់កម្ពុជា ច្បាប់ អ.វ.ត.ក និងវិធានផ្ទៃក្នុងពុំចែងបញ្ជាក់បទដ្ឋាននៃការពិនិត្យមើលឡើងវិញ ហើយអនុលោលតាមមាត្រា ១២ នៃកិច្ចព្រមព្រៀង អ.ស.ប ជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា អ.ប.ជ អាចស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធី និងយុត្តិសាស្ត្រដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិ។

[22] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* *Kenyatta* រឿងក្ដីលេខ ICC-01/09-02/11 OA 5 សាលក្រមលើបណ្ដឹងឧទ្ធរណ៍របស់រដ្ឋអាជ្ញាប្រឆាំងនឹងអង្គជំនុំជម្រះសាលាដំបូង *V(B)'s "សេចក្ដីសម្រេចលើពាក្យសុំរបស់អយ្យការឲ្យសម្រេចលើភាពគ្មានអនុលោមភាពអនុលោមតាមមាត្រា ៨៧(៧) នៃលក្ខន្តិកៈ"* ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ កថាខណ្ឌ ២៣-២៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Taylor*, សំណុំរឿងលេខ SCSL-03-01-A, *សាលដីកា* ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៣ កថាខណ្ឌ ២៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Karadžić* សំណុំរឿង IT-95-5/18-AR72.1, IT-95-5/18-AR72.2, IT-95-5/18-AR72.3 *សាលដីកាលើសំណើរបស់ Karadžić សុំតវ៉ាលើយុត្តាធិការ (ការទទួលខុសត្រូវចំពោះអំពើអកម្ម JCE III - ឧក្រិដ្ឋកម្មដែលមានចេតនាពិសេស ការទទួលខុសត្រូវរបស់ថ្នាក់លើ* ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ១០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Hadžihasanović and Kubura* សំណុំរឿងលេខ IT-01-

18. អង្គបុរេជំនុំជម្រះ បានលើកឡើងយ៉ាងស៊ីសង្វាក់គ្នាថា កំហុសអង្គច្បាប់ដូចដែលបានលើកឡើង ត្រូវបានត្រួតពិនិត្យ*សារជាថ្មី*ឡើងវិញ ដើម្បីពិចារណាថាតើការលើកឡើងផ្នែកច្បាប់ត្រឹមត្រូវដែរ ឬអត់ និងកំហុសអង្គហេតុដូចដែលបានលើកឡើង ត្រូវបានត្រួតពិនិត្យឡើងវិញនៅក្រោមបទដ្ឋាន ស្ដីពីភាពសមហេតុផល ដើម្បីសម្រេចថាតើមានអ្នកវិនិច្ឆ័យសេចក្ដីអង្គហេតុដែលសមស្រប បាន ធ្វើសំអាងផ្នែកអង្គហេតុដែលបានលើកឡើងដែរឬទេ។[23]

19. មេធាវីការពារក្ដីក៏សូមលើកឡើងផងដែរថា អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការព្រហ្មទណ្ឌ អន្តរជាតិ (ICC) បានក្រើនរំឭកដល់ចៅក្រមទាំងអស់នាពេលថ្មីៗ កុំឲ្យរារាំងហួសហេតុដល់ ដំណើរការពិនិត្យឡើងវិញរបស់ខ្លួនតាមផ្លូវឧទ្ធរណ៍ អំពីកំហុសអង្គច្បាប់ ឬអង្គហេតុ ជាពិសេស នៅពេលដែលវិធីសាស្ត្រគួរឲ្យយកចិត្តទុកដាក់នេះ អាចប្រឆាំងទៅនឹងផលប្រយោជន៍នៃយុត្តិធម៌

---

47-A, *សាលដីកា* ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨ កថាខណ្ឌ ១៣០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០ (ដកស្រង់ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង* Galič, សំណុំរឿង IT-98-29-A, *សាលដីកា* ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៦ កថាខណ្ឌ ២១។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Kordič and Čerkez*, សំណុំរឿង IT-95-14/2-A, *សាលដីកា* ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ២០០៤ កថាខណ្ឌ ១១៩)។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Gotovina, Čermak, និង Markač*, សំណុំរឿង IT-06-90-AR72.1 *សាលដីកាលើបណ្ដឹងឧទ្ធរណ៍បន្ទាន់បន្ទំរបស់ Ante Gotovina ប្រឆាំងនឹងសេចក្ដីសម្រេចលើពាក្យសុំជាច្រើនដែលតវ៉ាលើយុត្តាធិការ* ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ ៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១។

[23] សំណុំរឿង ០០២-ឯកសារ **D427/1/30** កថាខណ្ឌ ១១៣ (*ដកស្រង់ រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Haradinaj និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-84-A, សាលដីកា ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ១១-១២)។ សំណុំរឿង ០០២-ឯកសារ **D427/2/15** កថាខណ្ឌ ៨៦ (ដកស្រង់ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Haradinaj និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-04-84-A *សាលដីកា* ចុះថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ១១-១២)។ សូមមើលផងដែរ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Bemba*, សំណុំរឿងលេខ ICC-01/05-01/08 A, *សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក Jean-Pierre Bemba Gombo ប្រឆាំងនឹងអង្គជំនុំជម្រះសាលាដំបូងទីIII "សាលក្រមអនុលោមតាមមាត្រា ៧៤ នៃលក្ខន្តិកៈ"* (*'សាលដីកា Bemba'*) ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៣៨, ៤៥-៤៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Ntaganda* សំណុំរឿងលេខ ICC-01/04-02/06 OA 2, *សាលក្រមលើបណ្ដឹងឧទ្ធរណ៍របស់លោក Bosco Ntaganda ប្រឆាំងនឹង "ដីកាសម្រេចលើការតវ៉ារបស់មេធាវីការពារក្ដីចំពោះយុត្តាធិការរបស់តុលាការពាក់ព័ន្ធនឹងបទចោទទី៦ និងទី៩"* ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៣៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06 A5, *សាលដីកាកោសលុបជាសាធារណៈស្ដីពីបណ្ដឹងឧទ្ធរណ៍របស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងការសម្រេចឲ្យមានពិរុទ្ធភាព* ចុះថ្ងៃទី១ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ១៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៤។

ហើយច្បាប់មិនតម្រូវឱ្យមានការយកចិត្តទុកដាក់បែបនេះនោះ។[24] មេធាវីការពារក្តីកត់សម្គាល់ថា ទាំងច្បាប់កម្ពុជា ទាំងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ពុំបានចែងពីការគោរពចាំបាច់ដល់សេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអំពីអង្គហេតុ ឬអង្គច្បាប់នោះទេ ហើយមេធាវីការពារក្តីសូមទទូចឱ្យអង្គបុរេជំនុំជម្រះ សម្រេចយកតាមវិធីសាស្ត្រថ្មីៗរបស់អង្គជំនុំជម្រះតុលាការកំពូលក្នុងរឿងក្តីរបស់ *Bemba*។

## សំអាងហេតុនៃបណ្តឹងឧទ្ធរណ៍

### I. សំអាងហេតុទី១÷ ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ស្របពេលជាមួយគ្នានឹងការចេញដីកាលើកលែងការចោទប្រកាន់ ត្រូវបានសំអាងទៅលើកំហុសអង្គច្បាប់

20. នៅថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ សហចៅក្រមស៊ើបអង្កេតទាំងពីរបានចេញដីកាដំណោះស្រាយពីរផ្ទុយគ្នានៅក្នុងសំណុំរឿង ០០៤/២។[25] ជំហររបស់សហចៅក្រមស៊ើបអង្កេតគឺថា "សហចៅក្រមស៊ើបអង្កេត អាចចេញដីកាដំណោះស្រាយដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នា យោងតាមការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរតាមច្បាប់ជាធរមាននៅចំពោះមុខអ.វ.ត.ក" ។[26] មេធាវីការពារក្តីសង្កត់ធ្ងន់ថា នេះគឺជាការបកស្រាយខុសទៅលើច្បាប់ស្តីពីការបង្កើតតុលាការនេះ។ ក្របខណ្ឌច្បាប់សម្រាប់ អ.វ.ត.ក ចែងយ៉ាងច្បាស់ និងពុំមានស្រពិចស្រពិលចំពោះការ

---

[24] *សាលដីកា* Bemba កថាខណ្ឌ ៣៨, ៤០, ៤៥-៤៦ (ជាពិសេស ពាក់ព័ន្ធនឹងកំហុសអង្គហេតុ និងបទដ្ឋាននៃភាពសមហេតុសមផល អង្គជំនុំជម្រះតុលាការកំពូលនៃតុលាការ ICC បានសម្រេចថា គោលគំនិតដែលថា ត្រូវមានការបង្ហាញនូវសេចក្តីគោរពចំពោះសំអាងហេតុរបស់តុលាការថ្នាក់ទាប ត្រូវយកមកអនុវត្តដោយប្រុងប្រយ័ត្នបំផុត។ តុលាការបានបញ្ជាក់ថា "នៅពេលបុគ្គលមានហេតុផលសមរម្យ និងសត្យានុម័ត អាចបង្ហាញវិមតិសង្ស័យខ្លាំងអំពីភាពត្រឹមត្រូវនៃសំអាងហេតុណាមួយ [...] និងអាចគាំទ្រទស្សនៈនេះដោយមានទឡ្ហីករណ៍ជាក់លាក់នោះ វាជាការបង្ហាញយ៉ាងច្បាស់ [...] ថា អាចមានកំហុសអង្គហេតុ"។ ម្យ៉ាងវិញទៀត នៅពេលអង្គជំនុំជម្រះដែលពិនិត្យលើបណ្តឹងឧទ្ធរណ៍ អាចកំណត់សំអាងហេតុដែលអាចមានវមតិសង្ស័យសមហេតុផល អង្គជំនុំជម្រះត្រូវច្រានចោលសំអាងហេតុទាំងនោះ)។

[25] សំណុំរឿង ០០៤/២-ឯកសារ **D359**។ សំណុំរឿង ០០៤/២-ឯកសារ **D360**។

[26] ជាក់ស្តែង ស.ច.ស.អ បង្កើតសិទ្ធិអនុញ្ញាតឱ្យខ្លួនឯង អនុវត្តទម្លាប់អនុវត្តកន្លងមក និងបន្ទាប់មក អះអាងថា វាអនុញ្ញាតតាមផ្លូវច្បាប់។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៤ (ដក់ស្រង់មតិយោបល់មុនៗនៅក្នុងសំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារដែលពាក់ព័ន្ធនឹងការខ្វែងយោបល់គ្នា* ឯកសារ **D355/1** ចុះថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៧ កថាខណ្ឌ ១៣-១៦)។

ចេញដីកាដំណោះស្រាយតែមួយ នៅចុងបញ្ចប់នៃកិច្ចស៊ើបសួរ អាចជាដីកាលើកលែងការចោទប្រកាន់[27] ឬជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ។[28] ដីកាដំណោះស្រាយផ្ទុយគ្នាបែនេះ គឺមិនធ្លាប់មានទេនៅក្នុងប្រទេសកម្ពុជា ព្រមទាំងតុលាកាជាតិ និងអន្តរជាតិ ហើយពុំស្របជាមួយច្បាប់ជាធរមានទេ។[29] ដីកាដំណោះស្រាយទាំងពីរនេះក៏រំលោភលើកាសន្មតជាមុនថាគ្មានទោស និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន និងទុកឱ្យ អោ អាន ស្ថិតក្នុងស្ថានភាពមួយមិនច្បាស់លាស់គ្មានច្បាប់កំណត់ ដែលមិនមែនជាចេតនារបស់អ្នករៀបចំតាក់តែងសេចក្តីព្រាងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នោះឡើយ។ មាត្រា ៣៨ នៃរដ្ឋម្មនុញ្ញកម្ពុជាចែងថា វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ។[30] អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំឱ្យ អង្គបុរេជំនុំជម្រះ (ក) ប្រកាសថា ការចេញដីកាដំណោះស្រាយទាំងពីរ គឺមិនស្របច្បាប់នោះឡើយ និង (ខ) ធ្វើមោឃៈភាព *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* និងលើកលែងការចោទប្រកាន់លើ អោ អាន។

## ក.ក្របខណ្ឌ .គតិយុត្តិចែងយ៉ាងច្បាស់អំពីដីកាដំណោះស្រាយតែមួយ

21. ច្បាប់បានកំណត់យ៉ាងច្បាស់ថាក្របខណ្ឌច្បាប់សម្រាប់តុលាការនេះត្រូវតែបកស្រាយ “ដោយសុទ្ធចិត្តស្របតាមអត្ថន័យធម្មតានៃពាក្យពេចន៍ទាំងនេះ ដែលមាននៅក្នុង [ឯកសារនេះ] នៅក្នុងបរិបទ

---

[27] មេធាវីការពារក្តីកត់សម្គាល់លើការប្រើប្រាស់ “ដីកាដំណោះស្រាយ” នៅ អ.វ.ត.ក។ វិធាន ៦៧ នៃវិធានផ្ទៃក្នុង។

[28] ដីកាបញ្ជូនរឿងទៅជំនុំជម្រះមានសុពលភាពមួយអាចច្រានចោលអង្គហេតុ និងបទចោទខ្លះ។ វិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង។

[29] តុលាការអន្តរជាតិដែលអនុញ្ញាតការធ្វើសេចក្តីសម្រេចតាមផ្លូវតុលាការ រួមជាមួយមតិយោបល់ស្របគ្នា ដោយឡែក ឬ មតិយោបល់ផ្ទុយគ្នា ចែងយ៉ាងច្បាស់អំពីករណីនេះនៅក្នុងឯកសារសំខាន់ៗរបស់តុលាការ។ នៅគ្រប់កាលៈទេសៈទាំងអស់ តុលាការចេញដីកាសម្រេចតែមួយ។ តុលាការជាតិអនុវត្តគោលការណ៍ស្រដៀងគ្នានេះ។ *សូមមើល* Sluiter, ‘ឯកភាព និងការខ្វែងយោបល់គ្នានៅក្នុងការធ្វើសេចក្តីសម្រេច – ច្បាប់ និងការអនុវត្តស្តីពីមតិយោបល់បុគ្គលនៅតុលាការ ICTY) នៅក្នុងសៀវភៅរៀបរៀងដោយ Swart, Zahar & Sluiter (eds.) ដែលមានចំណងជើងថា *កេរ្តិ៍ដំណែលនៃសាលាក្តីឧក្រិដ្ឋកម្មអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី* (Oxford: Oxford University Press, 2011) ទំព័រ ១៩១-២១៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៥។

[30] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា (‘*រដ្ឋធម្មនុញ្ញកម្ពុជា*’) មាត្រា ៣៨។ គោលការណ៍ច្បាប់ព្រហ្មទណ្ឌនេះចែងបញ្ចូលនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (‘*លក្ខន្តិកៈទីក្រុងរ៉ូម*’) ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ មាត្រា ២២។

នៃពាក្យពេចន៍ទាំងនេះ និងទៅតាមកម្មវត្ថុ និងគោលបំណងនៃកិច្ចព្រមព្រៀងនេះ”។[31]

22. អត្ថន័យធម្មតានៃពាក្យពេចន៍ វាក្យសម្ព័ន្ធ និងវាយ្យករណ៍នៅក្នុងវិធាន ៦៧ គឺច្បាស់លាស់ហើយ។ អ្នកតាក់តែងសេចក្តីព្រាងច្បាប់បានប្រមើលឃើញយ៉ាងច្បាស់អំពីការមានដីកាដំណោះស្រាយមួយសម្រាប់កិច្ចស៊ើបសួរមួយ។ ចំណុចនេះគឺច្បាស់លាស់បំផុតនៅក្នុងអនុកថាខណ្ឌទីមួយ ដែលចែងកំណត់សម្រាប់ “ដីកាដំណោះស្រាយមួយ *អាចជា* ការសម្រេចចោទប្រកាន់ និងបញ្ជូនខ្លួនទៅជំនុំជម្រះ *ឬ* ជាការលើកលែងការចោទប្រកាន់” (មានបញ្ជាក់បន្ថែម)។ ចំណុចនេះត្រូវបានបញ្ជាក់បន្ថែមដោយការសំអាងទៅលើពាក្យថាដីកាដំណោះស្រាយមួយ ‘a’ ឬ នេះ ‘the’ នៅក្នុងទម្រង់ឯកវចនៈរបស់វានៅទូទាំងបទប្បញ្ញត្តិនេះ និងនៅក្នុងវិធានផ្សេងៗទៀតនៃវិធានផ្ទៃក្នុង។[32]

23. កម្មវត្ថុ និងគោលបំណងនៃវិធាន ៦៧ គឺដើម្បីកំណត់ឲ្យមានលទ្ធផលនៃកិច្ចស៊ើបសួរមួយច្បាស់លាស់ និងស្របច្បាប់នៅចំពោះមុខ អ.វ.ត.ក។ ទីបំផុត វិធានផ្ទៃក្នុងចែងសម្រាប់ឲ្យមានដីកាដំណោះស្រាយតែមួយ ដោយយកតាមទស្សនៈច្បាប់ និងទម្រង់ចេញពីយុត្តិសាស្ត្រប្រព័ន្ធច្បាប់ស៊ីវិលក្នុងស្រុក ដូចជា ប្រទេសកម្ពុជា[33] និងប្រទេសបារាំង[34]។ វាមិនមែនជាចេតនារបស់អ្នកតាក់តែងសេចក្តីព្រាងច្បាប់ ដើម្បីអនុញ្ញាតឲ្យមានស្ថានភាពមួយដែលរឿងក្តីរបស់ អោ អាន ត្រូវបានបដិសេធដោយសហចៅក្រមស៊ើបអង្កេតជាតិ និងបញ្ជូនរឿងទៅជំនុំជម្រះដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខណៈដែលចៅក្រមទាំងពីររូបមានឋានៈ និងសិទ្ធិអំណាចស្មើគ្នាទេ។[35]

24. លើសពីនេះទៅទៀត ពុំមានបទប្បញ្ញត្តិនៅក្នុងក្របខណ្ឌគតិយុត្តិរបស់ អ.វ.ត.ក ដែលអាចកែប្រែ

---

[31] អនុសញ្ញាទីក្រុងវីយ៉ែនស្តីពីច្បាប់សន្ធិសញ្ញា (‘*អនុសញ្ញាទីក្រុងវីយ៉ែន*’) 1155 UNTS 331 ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ១៩៦៩ មាត្រា ៣១(*១*)។ សូមមើល កិច្ចព្រមព្រៀង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ២(២)។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក សាលដីកា (‘*សាលដីកា ឌុច*’) ឯកសារ **F28** ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៥៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៦។

[32] ឧទាហរណ៍ វិធានផ្ទៃក្នុង អ.វ.ត.ក សទ្ទានុក្រម (កំណត់និយមន័យដីកាដំណោះស្រាយជា ‘ដីកាស្ថាពរចេញដោយ [សចស] ឬ [អបជ] នៅចុងបញ្ចប់កិច្ចស៊ើបសួរមិនថាជាដីកាបញ្ជូនរឿងឲ្យជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់’) វិធាន ៦៨, ៦៩ (សំដៅលើដីកាដំណោះស្រាយក្នុងន័យតែមួយ)។

[33] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ២០០៧) (‘*ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០០៧)*’) មាត្រា ២៤៧។

[34] ក្រមនីតិវិធីព្រហ្មទណ្ឌ (បារាំង) មាត្រា ១៧៥-១៨៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៧។

[35] ច្បាប់ អ.វ.ត.ក មាត្រា ២៧ *ថ្មី*។

ការបកស្រាយវិធាន ៦៧ នេះទេ។ ផ្ទុយទៅវិញ មាត្រា ៣២ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ចែងយ៉ាងច្បាស់ថា "រាល់ការស៊ើបអង្កេត *គឺជាការទទួលខុសត្រូវរួមគ្នា*របស់ចៅក្រមពីរនាក់" ដែលបញ្ជាក់ន័យថា តម្រូវឱ្យមានសេចក្តីសម្រេចរួមគ្នាមួយចំពោះលទ្ធផលរបស់ខ្លួន (មានបញ្ជាក់បន្ថែម)។ បន្ថែមលើនេះទៀត វិធាន ១៤(៤)[36] អានផ្គួបគ្នាជាមួយសំអាងហេតុនានាយោងទៅដីកាដំណោះស្រាយតែមួយនៅក្នុងវិធាន ៦៧ បញ្ជាក់ថា ដីកាដំណោះស្រាយត្រូវតែជាលទ្ធផលកិច្ចការរួមគ្នារបស់សហចៅក្រមស៊ើបអង្កេតទាំងពីរ។

25. បើបកស្រាយដោយសុទ្ធចិត្ត នោះវិធាន ៦៧ អាចមានន័យថា លទ្ធផលនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការត្រូវតែចេញលទ្ធផលនៅក្នុងដីកាដំណោះស្រាយតែមួយ អាចជាការបញ្ជូនខ្លួនជនត្រូវចោទទៅជំនុំជម្រះ ឬជាការលើកលែងការចោទប្រកាន់គ្រប់បទចោទទាំងអស់។ ការបកស្រាយនេះស្របគ្នាជាមួយនឹងគ្រប់បទដ្ឋានគតិយុត្តិដទៃទៀតដែលមេធាវីការពារក្តីបានដឹង។ ហេតុដូច្នេះ ការចេញដីកាដំណោះស្រាយពីរពីកិច្ចស៊ើបសួរតែមួយ គឺមិនស្របទៅនឹងក្របខណ្ឌគតិយុត្តិ អ.វ.ត.ក ក្របខណ្ឌគតិយុត្តិកម្ពុជា និងក្របខណ្ឌគតិយុត្តិអន្តរជាតិឡើយ។

### ខ .ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា គឺមិនធ្លាប់មានពីមុនមក ហើយមិនស្របទៅនឹងសិទ្ធិជាមូលដ្ឋានរបស់ អោ អាន និងគោលការណ៍សច្ចភាពគតិយុត្តិឡើយ

26. មិនមានចុងចោទណាម្នាក់នៅក្នុងប្រទេសកម្ពុជា ឬនៅចំពោះមុខយុត្តាធិការតុលាការណាផ្សេងទៀតនៅក្នុងពិភពលោកធ្លាប់ទទួលរងការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នា (ឬសមមូលតាមផ្លូវនីតិវិធីនោះឡើយ)។ ស្ថានភាពដែល អោ អាន បានប្រឈម គឺមិនធ្លាប់មានពីមុនមក និងមិនត្រឹមត្រូវទាល់តែសោះ។

27. ចរិតលក្ខណៈនៃស្ថានភាពរបស់ អោ អាន ដែលមិនធ្លាប់មាពីមុនមក គឺរំលោភលើសិទ្ធិរបស់គាត់ក្នុងការទទួលបានសមភាពនៅចំពោះមុខច្បាប់ ដែលមានចែងក្នុងមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា និងសមភាពនៅចំពោះមុខតុលាការនានា ដូចមានចែងក្នុងមាត្រា ១៤ នៃកតិកាសញ្ញាអន្តរជាតិស្តីពី

---

[36] វិធាន ១៤(៤)('វៀរលែងតែសកម្មភាពណាដែលតម្រូវឱ្យអនុវត្តដោយរួមគ្នា ដូចមានចែងក្នុងច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ និងវិធានផ្ទៃក្នុងនេះ សហចៅក្រមស៊ើបអង្កេតអាចផ្ទេរភារកិច្ចទៅឱ្យសហចៅក្រមស៊ើបអង្កេតណាមួយក្នុងចំណោមសហចៅក្រមស៊ើបអង្កេតទាំងពីរ តាមរយៈលិខិតរួមគ្នាជាលាយលក្ខណ៍ ដើម្បីឱ្យបំពេញកិច្ចតែម្នាក់ឯងបាន')។

សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។ ពិសេសបំផុត វារំលោភលើការទទួលបានដោយសមភាពនូវការជំនុំជម្រះក្តីដោយយុត្តិធម៌របស់គាត់[37] ដូចជា៖

28. *សិទ្ធិដែលត្រូវចាត់ទុកថាគ្មានទោស ដរាបណាពិរុទ្ធភាពមិនទាន់ត្រូវបានរកឃើញ*[38] ដែលជាបន្ទុកក្នុងការបង្ហាញភ័ស្តុតាងរបស់អយ្យការ ចាប់តាំងពីដើមដំបូងនៃសំណុំរឿងរហូតដល់ចុងបញ្ចប់នៃសំណុំរឿង។[39] អយ្យការត្រូវតែបំពេញភារៈរបស់ខ្លួននៅគ្រប់ដំណាក់កាលនីមួយដើម្បីឲ្យរឿងក្តីនេះដំណើរការជឿនលឿនទៅមុខ។[40] ដើម្បីឲ្យសំណុំរឿង ០០៤/០២ ចាប់ដំណើរការចេញពីកិច្ចស៊ើបសួររហូតឈានដល់ការជំនុំជម្រះបាន អយ្យការត្រូវធ្វើឲ្យសហចៅក្រមស៊ើបអង្កេតទាំងពីរជឿជាក់ថា សម្ភារៈភ័ស្តុតាងនៅក្នុងសំណុំរឿងគឺត្រូវតែ "មានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ដើម្បីឲ្យមានតម្លៃជាភ័ស្តុតាងបន្ទាល់"។[41] *ដីកាដំណោះស្រាយ(ដីកាលើកលែងការចោទប្រកាន់)របស់សហចៅក្រមស៊ើបអង្កេតជាតិ* បង្ហាញយ៉ាងច្បាស់ថា សហព្រះរាជអាជ្ញាអន្តរជាតិ

---

[37] ច្បាប់ អ.វ.ត.ក មាត្រា ៣៥ *ថ្មី* ។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (*'ICCPR'*), 999 UNTS 171 ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា ១៤។

[38] ICCPR មាត្រា ១៤(២)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៥។ វិធាន ២១(ឃ) នៃវិធានផ្ទៃក្នុង។

[39] ករណីលើកលែងជាក់លាក់មួយចំនួនតូចចំពោះវិធានមូលដ្ឋាននេះអាចកើតឡើងនៅក្នុងយុត្តាធិការមួយចំនួន។ ឧទាហរណ៍ នៅពេលការការពារក្តីត្រូវបានលើកឡើងដោយជនជាប់ចោទ ដូចជា ការគៀបសង្កត់ វិប្បល្លាស្មារតី សមត្ថភាពផ្លូវចិត្ត និង "ស្ថានសម្រាល" ផ្សេងទៀត មេធាវីការពារក្តីមានបន្ទុកបង្ហាញភ័ស្តុតាងផ្ទុយតែក្នុងលក្ខណៈមិនសូវតឹងរ៉ឹងនោះទេ។ ឧទាហរណ៍ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ *សាលក្រម សំណុំរឿង ០០២/១* (*'សាលក្រម ០០២/១'*) ឯកសារ **E313** ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៤ កថាខណ្ឌ ១០១០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៨។ បន្ទុកនៃការបង្ហាញភ័ស្តុតាងផ្ទុយកម្រិតត្រឹមករណីពិសេសប៉ុណ្ណោះ ហើយពុំរាបបញ្ចូលធាតុផ្សំបទល្មើស ឬ ស្ថានសម្រាលនៃបទល្មើសដូចបានចោទប្រកាន់នោះទេ។ ឧទាហរណ៍ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Čelebići* សំណុំរឿងលេខ IT-96-21-A, *សាលដីកា* ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ២០០១ កថាខណ្ឌ ៧៦៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៩។

[40] ក្រុមប្រឹក្សាសិទ្ធិមនុស្ស អ.ស.ប. *មតិយោបល់ទូទៅលេខ ៣២ មាត្រា ១៤ សិទ្ធិសមភាពនៅចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌* (*'យោបល់ទូទៅលេខ ៣២ របស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស'*) CCPR/C/GC/32 ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ៦, ៣០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២០។

[41] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស *ដីកាដំណោះស្រាយ* ឯកសារ **D427** ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣២០-១៣២៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២១។ បទដ្ឋាននេះអនុវត្តលើសំអាងហេតុអង្គសេចក្តីលើបទចោទ ព្រមទាំង យុត្តាធិការ។ ឧទាហរណ៍ សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាដំណោះស្រាយ (សំអាងហេតុ)* ឯកសារ **D308/3** ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២។

មិនបានបំពេញបន្ទុកនៃការបង្ហាញភ័ស្តុតាងរបស់ខ្លួនជូន សហចៅក្រមស៊ើបអង្កេតជាតិ ទេ។[42] ដោយសារថា សហចៅក្រមស៊ើបអង្កេតជាតិ និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានឋានៈ និងសិទ្ធិអំណាចស្មើគ្នានៅចំពោះមុខ[43] អ.វ.ត.ក នោះការអនុញ្ញាតឲ្យសំណុំរឿងនេះដំណើរការទៅមុខប្រឆាំងនឹងជំហររបស់ សហចៅក្រមស៊ើបអង្កេតជាតិ គឺរំលោភលើសិទ្ធិត្រូវចាត់ទុកថាគ្មានទោសរបស់ អោ អាន ដរាបណាពិរុទ្ធភាពរបស់គាត់មិនទាន់ត្រូវបានរកឃើញនៅឡើយ។

29. *សិទ្ធិដែលត្រូវទទួលបានការជំនុំជម្រះដោយតុលាការ មានសមត្ថកិច្ចឯករាជ្យ និងមិនលំអៀង*[44] ដែលតម្រូវឲ្យនីតិវិធីត្រូវតែ "អាចទទួលបានយ៉ាងគ្រប់គ្រាន់ ច្បាស់លាស់ និងអាចប្រមើលបានជាមុន"។[45] ដីកាដំណោះស្រាយដែលផ្ទុយគ្នានេះបណ្តាលឲ្យស្ថានភាពផ្លូវច្បាប់នាពេលបច្ចុប្បន្ន និងនាពេលអនាគតរបស់ អោ អាន មិនអាចទទួលបានព័ត៌មានគ្រប់គ្រាន់ ច្បាស់លាស់ ឬអាចប្រមើលដឹងជាមុនបានឡើយ។ ភាពមិនច្បាស់លាស់នេះនឹងមិនអាចដោះស្រាយបានឡើយ ប្រសិនបើដីកាដំណោះស្រាយទាំងពីរត្រូវបានអនុញ្ញាតឲ្យតម្កល់ទុក (ដោយសារតែកង្វះសំឡេងភាគច្រើនលើសលប់)។ ការពុំមានភាពច្បាស់លាស់ដោយសារតែលទ្ធផលនៃការស៊ើបអង្កេតនេះ គឺជាការរំលោភជាក់ស្តែងលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អោ អាន។

30. *សិទ្ធិទទួលបានព័ត៌មានភ្លាមៗ និងដោយលំអិតអំពីប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើខ្លួន*[46] ដែលតម្រូវឲ្យដីកាដំណោះស្រាយសម្រេចអំពីបទចោទប្រកាន់ ដែលត្រូវយកមកជំនុំជម្រះលើ អោ អាន (ប្រសិនបើមាន)។ ទោះបីជា អោ អាន ត្រូវបានជូនដំណឹងអំពីបទចោទប្រកាន់បឋម

---

[42] សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៥៥២-៥៥៥។ ទោះបីជា ស.ច.ស.ជ ពុំបានពិភាក្សាលើបន្ទុកនៃការបង្ហាញភ័ស្តុតាងរបស់សហព្រះរាជអាជ្ញាក៏ដោយ គេអាចសន្និដ្ឋានថា បន្ទុកនេះមិនបានបំពេញ ដោយសារមានការលើកលែងបទចោទប្រកាន់មួយចំនួន។

[43] ច្បាប់ អ.វ.ត.ក មាត្រា ២៧ *ថ្មី*។

[44] ICCPR មាត្រា ១៤(១)។ វិធាន ២១(១)(ក)។

[45] រឿងក្តី *Carbonara និង Ventura តទល់នឹង អ៊ីតាលី* ECtHR ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០០ កថាខណ្ឌ ៦៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២២។ រឿងក្តី *Toniolo តទល់នឹង San Marino និងអ៊ីតាលី Italy* ECtHR ចុះថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១២ កថាខណ្ឌ ៥១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២៣។

[46] ICCPR មាត្រា ១៤(៣)(ក)។ វិធាន ២១(១)(គ)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៥(ក)។

ប្រឆាំងនឹងរូបគាត់[47] បន្ទាប់ពីការចេញដីកាដំណោះស្រាយចម្រូងចម្រាស់គ្នាមកហើយក្តី ក៏នៅតែមិនច្បាស់លាស់ និងពិតប្រាកដ ថាតើប្រភេទ និងមូលហេតុនៃការចោទប្រកាន់មកលើរូបគាត់ដែលត្រូវបន្តទៅមុខទៀត គឺជាបទចោទប្រកាន់អ្វីនោះដែរ (ប្រសិនបើមាន)។ ការពុំមានភាពច្បាស់លាស់នេះ គឺជាការរំលោភជាក់ស្តែងលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អោ អាន។

31. *សិទ្ធិត្រូវបានជំនុំជម្រះដោយឥតពន្យារពេលយូរហួសហេតុ*[48] ដែលតម្រូវឲ្យកិច្ចដំណើរការនីតិវិធីបញ្ចប់នៅក្នុងពេលវេលាមួយសមហេតុផល។[49] ដីកាដំណោះស្រាយទាំងពីរនឹងនាំឲ្យមានវិមតិសង្ស័យយ៉ាងសមហេតុផលបំផុត ក្នុងពេលតម្រូវឲ្យមានការត្រួតពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់។[50] លើសពីនេះទៀត ប្រសិនបើដីកាដំណោះស្រាយណាមួយពុំត្រូវបានបដិសេធ (ដោយសារមិនមានសំឡេងលើសលប់នៅចំពោះមុខ អង្គបុរេជំនុំជម្រះ) ទេ នោះសំណុំរឿង ០០៤/២ នឹងត្រូវបន្សល់ទុកនូវស្ថានភាពមិនច្បាស់លាស់ ដែលមិនមានច្បាប់កំណត់នោះឡើយ។ កិច្ចដំណើរការនីតិវិធីក្នុងនៅក្នុងករណីទាំងពីរនេះ នឹងត្រូវបានអូសបន្លាយបន្តទៅទៀត។ យោងតាមកិច្ចស៊ើបដែលប្រើពេលស៊ើបអង្កេតរយៈពេលជិត ១០ ឆ្នាំកន្លងមកនេះ ការអូសបន្លាយណាមួយបន្ថែមទៀតដោយសំអាងលើការបកស្រាយមិនត្រឹមត្រូវចំពោះក្របខណ្ឌគតិយុត្តិរបស់តុលាការនេះ គឺពិតជារំលោភយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន។

32. លើសពីនេះទៀត ការចេញដីកាដំណោះស្រាយពីរដាច់ដោយឡែកពីគ្នា និងផ្ទុយគ្នាក្នុងសំណុំរឿង ០០៤/២ បែបនេះបង្កើតជាការមាក់ងាយដល់គោលការណ៍សច្ចភាពគតិយុត្តិជាមូលដ្ឋាន ដែល

---

[47] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ឯកសារ **D242** ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១៥ KH 01079991-01079992 ទំព័រ ៦-៧។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូងម្តងទៀត* ឯកសារ **D303** ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៦ KH 01218382-01218395 ទំព័រ ៣-១៦។

[48] ICCPR មាត្រា ១៤(៣)(គ)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៥(គ)។

[49] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២៨-៣១។

[50] ក្រៅពីមេធាវីការពារក្តី សហព្រះរាជអាជ្ញាបានបញ្ជាក់ថា ពួកគេនឹងដាក់បណ្តឹងឧទ្ធរណ៍ និងបណ្តឹងជំទាស់ដោយឡែក។

ជាសសរស្តម្ភ និងជាលក្ខខណ្ឌស្នូលនៃនីតិរដ្ឋ។[51] គោលការណ៍នេះតម្រូវឲ្យបណ្តាច្បាប់ទាំងឡាយ និងសេចក្តីសម្រេចតាមផ្លូវតុលាការ ត្រូវតែប្រាកដប្រជា និងច្បាស់លាស់ ដីកាសម្រេចរបស់តុលាការគឺជាការចងកាតព្វកិច្ច និងសេចក្តីរំពឹងតាមផ្លូវច្បាប់ត្រូវបានការពារ។[52] ដីកាដំណោះស្រាយដែលខ្វែងគ្នាបែបនេះ គឺជាការផ្ទុយគ្នាស្រឡះទៅនឹងសច្ចភាពច្បាប់ និងជាការចំអកដល់យុត្តិធម៌។ ការពិនិត្យឡើងវិញដោយតុលាការជាន់ខ្ពស់ ដែលផ្តល់លទ្ធផលដល់ការគាំទ្រចំពោះដីកាដំណោះស្រាយទាំងពីរ នឹងកាន់តែបណ្តាលឲ្យបន្តមានការមាក់ងាយដល់សច្ចភាពគតិយុត្តិ ជាជាងកាត់បន្ថយការមាក់ងាយនេះទៅវិញតែប៉ុណ្ណោះ។

## គ. ស្ថានភាពទាល់ច្រកផ្នែកនីតិវិធីដែលមិនធ្លាប់មានពីមុនមកនេះ ត្រូវតែដោះស្រាយដោយផ្តល់ជាប្រយោជន៍ដល់ អោ អាន

33. ការមានដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នាទាំងពីរនេះ បានបង្កើតឲ្យមានស្ថានភាពទាល់ច្រកមួយ ដែលមិនត្រូវបានសញ្ជឹងគិតឃើញដោយវិធាននៃនីតិវិធីរបស់កម្ពុជា ឬរបស់អន្តរជាតិនោះឡើយ។ រាល់ករណីវិមតិសង្ស័យទាំងអស់ ត្រូវតែដោះស្រាយដោយផ្តល់ផលប្រយោជន៍ឲ្យ អោ អាន។

34. យោងតាមសហចៅក្រមស៊ើបអង្កេតទាំងពីរ ការចេញដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នាពីរបែបនេះគឺបណ្តាលមកពីការមិនយល់ស្របគ្នារវាងពួកគាត់ទាំងពីរ។[53] ក្របខណ្ឌច្បាប់របស់ អ.វ.ត.ក ចែងថា ការខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេតទាំងពីរ ត្រូវតែសម្រេចដោយប្រើនីតិវិធីជាដំណោះស្រាយនៅក្នុងវិធាន ៧២។ ក្នុងករណីពុំមានដំណោះស្រាយពីអង្គបុរេជំនុំជម្រះ ទេ នោះ "ដីកា ឬ កិច្ចស៊ើបសួរដែលធ្វើឡើងដោយ ស.ច.ស ណាម្នាក់ត្រូវមានសុពលភាព"

---

[51] រឿងក្តី *Lupeni Greek Catholic Parish និងជនផ្សេងទៀត តទល់នឹង រ៉ូម៉ានី* ECtHR ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១១៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២៤។ រឿងក្តី *Brumărescu តទល់នឹង រ៉ូម៉ានី* ECtHR ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៩៩ កថាខណ្ឌ ៦១-៦២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២៥។

[52] រឿងក្តី *Harkins តទល់នឹង ចក្រភពអង់គ្លេស* ECtHR ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ៥៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២៦។ រឿងក្តី *Amministrazione delle finanze dello Stato តទល់នឹង SRL Meridionale Industria Salumi និងជនផ្សេងទៀត* ECJ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៨១ កថាខណ្ឌ ១០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២៧។ រឿងក្តី *Korchuganova តទល់នឹង រុស្ស៊ី* ECtHR ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ កថាខណ្ឌ ៤៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២៨។

[53] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៤, ១៦។ សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៥, ៥០។

។[54] អង្គបុរេជំនុំជម្រះ បានសម្រេចថា ការសំអាងទៅលើការខ្វែងយោបល់គ្នានៅក្នុង អង្គបុរេជំនុំជម្រះ គឺមិនមែនដាច់ខាតនោះឡើយ[55] និងច្បាស់ហើយថា នៅក្នុងសំណុំរឿងនេះសហចៅក្រមស៊ើបអង្កេតទាំងពីរបានសម្រេចមិនធ្វើដូច្នេះទេ។ ឯកសារដែលមានលេខដូចតទៅនេះបញ្ជាក់ថា *ដីកាដំណោះស្រាយ (លើកលែងការចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ* (ឧ. ឯកសារ D359) ត្រូវបានដាក់ចូលទៅក្នុងសំណុំរឿងមុន*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* (ឧ. ឯកសារ D360) មានន័យថា អនុលោមតាមវិធាន ៧២ ដីកាដំណោះស្រាយចេញមុនដែលជា “ដីកា [...] ធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត ណាម្នាក់” ត្រូវមានសុពលភាព។ លើសពីនេះទៀត កិច្ចស៊ើបសួរបានបញ្ចប់ហើយ ហើយការសន្មតស្តីពីការបន្តស៊ើបសួរ ដែលអាចអនុវត្តបាននៅក្នុងអំឡុងពេលបើកកិច្ចស៊ើបអង្កេតមិនអាចប្រើប្រាស់តទៅទៀតបានទេ។ ហេតុដូច្នេះ អនុលោមតាមវិធាន ៧២ ដំណោះស្រាយដែលអាចដំណើរការទៅបាន គឺត្រូវសម្រេចឱ្យ*ដីកាដំណោះស្រាយ (លើកលែងការចោទប្រកាន់) របស់សហចៅក្រមស៊ើបអង្កេតជាតិ* មានសុពលភាព។

35. ម្យ៉ាងវិញទៀត ដីកាដំណោះស្រាយផ្ទុយគ្នាបែបនេះ បង្កើតនូវស្ថានភាពទាល់ច្រកមួយ ដែលមិនអាចដោះស្រាយបានតាមរយៈវិធាននៃនីតិវិធីរបស់ អ.វ.ត.ក នៅកម្ពុជា ឬវិធាននៃនីតិវិធីអន្តរជាតិណាមួយបានទេ។ ក្នុងកាលៈទេសៈបែបនេះ ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ច្បាប់កម្ពុជា និងច្បាប់អន្តរជាតិបានចែងយ៉ាងច្បាស់ថា រាល់វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ អោ អាន។[56]

## ឃ. សេចក្តីសន្និដ្ឋានលើសំអាងហេតុទី១

36. ការចេញដីកាដំណោះស្រាយដាច់ដោយឡែក និងផ្ទុយគ្នាពីរបែបនេះ គឺមិនធ្លាប់មានពីមុនមក និងស្របនឹងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងរំលោភលើសិទ្ធិត្រូវសន្មតថាគ្មានទោសទុកជាមុនរបស់

---

[54] វិធាន ៧២(៤)(ឃ)។

[55] សំណុំរឿង ០០២-ឯកសារ **D427/1/30** កថាខណ្ឌ ២៧៤។

[56] រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨។ វិធាន ២១(១)។ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២២(២)។ សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ/អ.ជ.ត.ក (០៤) *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខគ្នាម១របស់ ខៀវ សំផន ស្តីពីសំណើសុំដោះលែងជាបន្ទាន់* ឯកសារ **E50/3/1/4** ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៣១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ២៩។ សំណុំរឿង ០០២-ឯកសារ **D427/2/15** កថាខណ្ឌ ១៣៩-១៤៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-T, *សាលក្រម* ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ១៩៩៨ កថាខណ្ឌ ៣១៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣០។

អោ អាន សិទ្ធិជាមូលដ្ឋានទទួលបានការជំនុំជម្រះដោយយុត្តិធម៌ ព្រមទាំងគោលការណ៍សច្ចភាពគតិយុត្តិ។ ក្របខណ្ឌច្បាប់ អ.វ.ត.ក អនុញ្ញាតឲ្យមានតែដីកាដំណោះស្រាយមួយប៉ុណ្ណោះ អាចជាការបញ្ជូនរឿងទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់។ ការមិនអាចឈានដល់ការចេញសេចក្តីសម្រេចមួយដោយព្រមព្រៀងគ្នា ស្តីពីលទ្ធផលនៃកិច្ចស៊ើបសួរ នោះយោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា ជំហរខុសឆ្គងបែបនេះ គឺគួរតែលើកលែងការចោទប្រកាន់ ដោយហេតុថា វិមតិសង្ស័យបណ្តាលមកពីដីកាដំណោះស្រាយផ្ទុយគ្នាបែបនេះ ត្រូវតែដោះស្រាយដោយផ្តល់ផលប្រយោជន៍ដល់ អោ អាន។ វិមតិសង្ស័យដែលកើតមាននេះ ត្រូវតែដោះស្រាយដោយផ្តល់ផលប្រយោជន៍ដល់ អោ អាន។ យោងតាមមូលហេតុទាំងអស់ខាងលើនេះ មេធាវីការពារក្តីសូមស្នើឲ្យអង្គបុរេជំនុំជម្រះ ប្រកាសថា ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាយ៉ាងនេះ គឺមិនស្របច្បាប់នោះឡើយ និងសុំឲ្យច្រានចោល*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ព្រមទាំងលើកលែងការចោទប្រកាន់លើ អោ អាន។

## II. សំអាងហេតុទី ២ ដល់ ៧ ពាក់ព័ន្ធនឹងការយល់ឃើញខុសរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ហើយហេតុដូច្នេះគាត់ស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់តុលាការនេះ

37. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញខុសថា អោ អាន ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះ ពីព្រោះគាត់ពិតជា "ជនម្នាក់ក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"។[57] ការយល់ឃើញនេះបានសំអាងទៅលើកំហុសអង្គច្បាប់ និងកំហុសអង្គហេតុដូចតទៅ៖ (ក) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រព្រឹត្តកំហុសចំពោះការអនុវត្តឆន្ទានុសិទ្ធិដោយសេរី នៅពេលធ្វើការពិចារណាថាតើ អោ អាន ស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះដែរ ឬអត់នោះ (ខ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បកស្រាយខុសអំពី "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខណៈមួយទូលំទូលាយហួសហេតុពេក (គ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុវត្តបទដ្ឋាននៃការបង្ហាញភ័ស្តុតាងមិនបានត្រឹមត្រូវ (ឃ) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្កើត និងសំអាង

[57] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៩៧, ៧១២។ ទោះបីជាមេធាវីការពារក្តីនៅតែលើកឡើងថា អោ អាន មិនមែនជា "មេដឹកនាំជាន់ខ្ពស់" ក៏ដោយ ក៏បញ្ហានេះមិនមែនជាចំណុចបណ្តឹងចំបងនៃបណ្តឹងឧទ្ធរណ៍នោះទេ ដោយសារ ស.ច.ស.អ មិនបានសម្រេចលើវានោះឡើយ។

ខុសចំពោះកម្រិតភ័ស្តុតាង ជាជាងការពិនិត្យលើខ្លឹមសារនៃភ័ស្តុតាង ដូចដែល អង្គបុរេជំនុំជម្រះបានកំណត់ទៅវិញ និង (ង) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញខុសថា អោ អាន មានតួនាទី និងមុខតំណែងកាន់តែសំខាន់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតនៅក្នុងភូមិភាគបណ្តាល និងនៅតំបន់ ៤១ លើសពីកម្មាភិបាលខ្មែរក្រហមដទៃទៀត។

38. ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតជាតិយល់ឃើញត្រឹមត្រូវថា អោ អាន មិនស្ថិតក្នុងយុត្តាធិការរបស់តុលាការនេះទេ។ នៅក្នុងការយល់ឃើញបែបនេះ គាត់អនុវត្តឆន្ទានុសិទ្ធិរបស់គាត់បានយ៉ាងត្រឹមត្រូវ ដើម្បីពិចារណាលើយុត្តាធិការបុគ្គលកំណត់យ៉ាងត្រឹមត្រូវទៅលើ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" អនុវត្តបទដ្ឋាននៃការបង្ហាញភ័ស្តុតាងបានត្រឹមត្រូវ ពិនិត្យខ្លឹមសារនៃភ័ស្តុតាង និងធ្វើការប្រៀបធៀបបានត្រឹមត្រូវអំពីតួនាទី និងមុខតំណែងរបស់ អោ អាន ដូចដែលបានចោទប្រកាន់ចំពោះឧក្រិដ្ឋកម្មដែលធ្ងន់ធ្ងរបំផុត។[58]

## ក. សំអាងហេតុទី ២៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ឃើញខុសថា គាត់មានឆន្ទានុសិទ្ធិដោយសេរី ដើម្បីសម្រេចអំពីយុត្តាធិការបុគ្គល

39. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើកឡើងខុសថា គាត់មានឆន្ទានុសិទ្ធិដោយសេរីដើម្បីសម្រេចថាតើ អោ អាន ស្ថិតនៅក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះ ឬទេនោះ។[59] ផ្ទុយពីការរិះគន់មុនៗរបស់គាត់[60] ចំពោះការយល់ឃើញរបស់អង្គជំនុំជម្រះតុលាការកំពូលនៅក្នុងសំណុំរឿង ០០១[61] សហចៅក្រមស៊ើបអង្កេតអន្តរជាតិបែរជាអនុវត្តតាមវិធីសាស្ត្រខុសឆ្គងទៅលើយុត្តាធិការនេះដដែលទៅវិញ និងមិនអើពើចំពោះការសម្រេចរបស់អង្គបុរេជំនុំជម្រះនាពេលថ្មីៗនៅក្នុងសំណុំ

---

[58] សំណុំរឿង ០០៤/២-ឯកសារ **D359** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ កថាខណ្ឌ ៤៣០-៤៣១, ៥៤៣។

[59] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៤ (គូសបញ្ជាក់ថា អ.ជ.ត.ក បានសន្និដ្ឋានថា ពាក្យ "មេដឹកនាំជាន់ខ្ពស់" និង "អ្នកទទួលខុសត្រូវខ្ពស់បំផុត" "ជាគោលការណ៍ ប្រភេទទាំងពីរនេះមិនត្រូវបានកំហិតដោយវិធាននៃការបកស្រាយបែបតឹងរ៉ឹងទេ ហើយជាខ្លឹមសារ វាពុំអាចធ្វើការវិនិច្ឆ័យបានទេ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬ អ.ជ.ត.ក ប្រសិនពុំមានបង្ហាញអំពីការបំពានឆន្ទានុសិទ្ធិដោយពុំសុចរិត ឬ ការវិនិច្ឆ័យមិនត្រឹមត្រូវប្រកបដោយវិជ្ជាជីវៈ') កថាខណ្ឌ ៦៩៩ (លើកឡើងថា ក.ស.ព និង ស.ច.ស នៅក្នុងសំណុំរឿង ០០១ 'មានសេរីភាពបដិសេធកិច្ចសន្យានយោបាយបែបនេះក្នុងរបៀបណាដែលរឹតត្បិតឆន្ទានុសិទ្ធិរបស់ ក.ស.ព និង ស.ច.ស ដែលមានចែងនៅក្នុងច្បាប់ជាធរមាន')។

[60] សំណុំរឿង ០០៤/១-ឯកសារ **D308/3** កថាខណ្ឌ ៦-១១។

[61] សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៦១, ៧៩។

រឿង ០០៤/១ ដែលបានច្រិតយ៉ាងត្រឹមត្រូវអំពីឆន្ទានុសិទ្ធិរបស់គាត់ទៅវិញនោះ។[62] បន្ថែមលើនេះទៀត ជំហររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិកំពុងតែដើរបញ្ច្រាសពីចេតនា និងការអនុវត្តជាបន្តបន្ទាប់របស់ភាគីនានាទៅនឹងកិច្ចព្រមព្រៀងរវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា។

**i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើចំពោះការលើកឡើងរបស់អង្គបុរេជំនុំជម្រះក្នុងសំណុំរឿង ០០៤ខុសឆ្គងសំអាងហេតុអនុវត្តតាមហើយបែរជា ១/ របស់អង្គជំនុំជម្រះតុលាការកំពូល ក្នុងសំណុំរឿង ០០១ ទៅវិញ**

40. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយការធ្វើមិនដឹងមិនឮចំពោះយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០១[63] និងកំពុងអនុវត្តតាមសំអាងហេតុខុសឆ្គងរបស់ អង្គជំនុំជម្រះតុលាការកំពូល នៅក្នុងសំណុំរឿង ០០១ ទៅវិញ។[64] ក្នុងសំណុំរឿង ០០៤/១ អង្គបុរេជំនុំជម្រះ បានសម្រេចថា ឆន្ទានុសិទ្ធិរបស់សហចៅក្រមស៊ើបអង្កេតពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល គឺមិនមែនសម្រេចតាមអំពើចិត្តនោះទេ។[65] ទោះបីជាសេចក្តីសម្រេចអំពីយុត្តាធិការបុគ្គល គឺជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិក្តី តែវាជាសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិតុលាការ ហើយការសម្រេចរបស់ខ្លួន "មិនអនុញ្ញាតឲ្យបំពេញកិច្ចតាមអំពើចិត្តទេ"។[66] អង្គបុរេជំនុំជម្រះ បានសម្រេចបន្ថែមទៀតថា ពាក្យថា "មេដឹកនាំជាន់ខ្ពស់" និង "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" "គឺជាព្រំដែនយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក" ហើយទោះបីជាសហចៅក្រមស៊ើបអង្កេតមាន"សិទ្ធិអំណាចមួយចំនួនក៏ដោយ" ក៏ "ឆន្ទានុសិទ្ធិនេះមិនមែនគ្មានព្រំដែន ហើយចៀសមិនផុតពីការត្រួតពិនិត្យរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នោះទេ"។[67]

41. ដោយការមិនអើពើចំពោះអង្គបុរេជំនុំជម្រះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បែរជាអនុវត្តតាម

---

[62] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២០។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៤។

[63] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២០។

[64] សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៦១, ៧៩។

[65] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២០។

[66] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២០។

[67] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២០។

យុត្តិសាស្ត្រខុសឆ្គង និងទស្សនៈហួសសម័យរបស់អង្គជំនុំជម្រះតុលាការកំពូល[68] ដែលមិនចង កាតព្វកិច្ចផងនោះ ហើយដែល ស.ច.ស បានទទួលស្គាល់ក្នុងសំណុំរឿង ០០៤/១ ទៅវិញ។[69] មេធាវីការពារក្តីសូមយកមកដាក់បញ្ចូលដោយយោងទៅលើទឡ្ហីករណ៍របស់ខ្លួននៅក្នុង*ចម្លើយតប របស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា*[70] និងសូមរំឭកឡើងវិញថា ជំហររបស់ អង្គជំនុំជម្រះតុលាការកំពូល គឺផ្តល់ឲ្យសហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើប អង្កេតនូវព្រំដែនយុត្តាធិការដ៏ទូលំទូលាយដែលមិនសមស្របដែលទាមទារយ៉ាងខ្លាំងឲ្យផ្តន្ទាទោស ចំពោះកម្មាភិបាលខ្មែរក្រហម ដែលនៅរស់រានមានជីវិតស្ទើរតែទាំងអស់។ ជំហរនេះ មិនស៊ី សង្វាក់គ្នា និងមិនស្របគ្នាជាមួយនឹងកិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាល ព្រមទាំងការ អនុវត្តជាបន្តបន្ទាប់របស់ភាគីទាំងឡាយនោះឡើយ ហើយជំហរនេះច្រានចោលនូវការពិនិត្យពិច័យ ដែលអាចជំទាស់តវ៉ាបាន ចំពោះបញ្ហាដ៏សំខាន់បំផុតនៅចំពោះមុខតុលាការនេះ។ សហចៅក្រម ស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានបង្ហាញការពន្យល់ណាមួយឲ្យបានរឹងមាំ សម្រាប់ការអនុវត្ត តាមយុត្តិសាស្ត្រខុសឆ្គង និងទស្សនៈហួសសម័យរបស់ អង្គជំនុំជម្រះតុលាការកំពូល និងការមិន អើពើចំពោះ អង្គបុរេជំនុំជម្រះ នោះឡើយ។

### ii. ចេតនា និងការអនុវត្តជាបន្តបន្ទាប់របស់ភាគីទាំងឡាយទៅនឹងកិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា គឺដើម្បីកម្រិតឆន្ទានុសិទ្ធិរបស់ ស.ច.ស

42. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយការមិនអើពើចំពោះចេតនាទាំឡាយ និងការ អនុវត្តជាបន្តបន្ទាប់របស់ភាគីនានានៃកិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា នៅ ពេលសម្រេចថាគាត់មានឆន្ទានុសិទ្ធិដោយសេរីក្នុងការសម្រេចអំពីយុត្តាធិការបុគ្គល។ ប្រវត្តិនៃកិច្ច ចរចា និងទស្សនៈរបស់រាជរដ្ឋាភិបាលកម្ពុជា និង អ.ស.ប គឺសំខាន់បំផុតដើម្បីបកស្រាយកិច្ចព្រម ព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ពីព្រោះ៖ (ក) គេមិនអាចពិចារណាទៅលើកម្មវត្ថុ

---

[68] ពាក់ព័ន្ធនឹងជំហរចាស់ និងមានកំហុសរបស់ អ.ជ.ត.ក មេធាវីការពារក្តីកត់សម្គាល់បន្ថែមទៀតថា បញ្ហាយុត្តាធិការបុគ្គលនៅ ក្នុងសណ្ណុំរឿង ០០១ មិនត្រូវបានដាក់ប្តឹងត្រឹមត្រូវនោះទេ។ សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៧៧។

[69] សំណុំរឿង ០០៤/១-ឯកសារ **D308/3** កថាខណ្ឌ ១០ (សម្រេចថា 'នេះជាករណីដែលថា អ.ប.ជ ជាស្ថាប័នតែមួយគត់ដែល ទទួលពិនិត្យមើលបណ្តឹងជំទាស់ទៅនឹងសេចក្តីសម្រេចរបស់ ក.ស.ច.ស ហើយថា នៅក្នុងប្រព័ន្ធស៊ីវិលឡដូចនៅកម្ពុជា ពុំមាន ទ្រឹស្តី*ប្រកាន់តាមអ្វីដែលបានសម្រេចមក*)។ សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៧៧-៨០។

[70] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៧៧-៧៩។

និងគោលបំណងរបស់កិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ជាពិសេសអំពីយុត្តាធិការបុគ្គល ដោយមិនសំអាងទៅលើការវិភាគលម្អិតចំពោះជំហរ និងទស្សនៈនានារបស់ភាគីនានានៃកិច្ចព្រមព្រៀងនេះបានឡើយ និង (ខ) ស្របតាមអនុសញ្ញាទីក្រុងវីយ៉ែន[71] ជំហរ និងទស្សនៈនានារបស់ភាគីទាំងឡាយនៃកិច្ចព្រមព្រៀងនេះ គឺជាការអនុវត្តជាបន្តបន្ទាប់ ដែលមិនអាចមើលរំលងចំពោះការខិតខំប្រឹងប្រែងបកស្រាយប្រកបដោយវិធីសាស្ត្ររឹងមាំ ជាពិសេសនៅពេលដែលភាពមិនច្បាស់លាស់កើតមានឡើង ដូចជា អត្ថន័យធម្មតារបស់ពាក្យពេចន៍ដែលមាននៅក្នុងរឿងក្តីនេះ។ មេធាវីការពារក្តីសូមយកមកដាក់បញ្ចូលដោយយោងទៅលើទឡ្ហីករណ៍របស់ខ្លួន នៅក្នុង*ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា*[72] និងសូមរំឭកឡើងវិញថា ចេតនាទាំងឡាយ និងការអនុវត្តជាបន្តបន្ទាប់ ដែលយ៉ាងហោចណាស់បង្ហាញថា សហព្រះរាជអាជ្ញា និងសហចៅក្រមស៊ើបអង្កេតមិនមែនមានឆន្ទានុសិទ្ធិដោយគ្មានព្រំដែន ដើម្បីសម្រេចអំពីយុត្តាធិការបុគ្គលនោះឡើយ។

## ខ. សំអាងហេតុទី ៣៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បកស្រាយអំពី "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខណៈទូលំទូលាយហួសហេតុពេក

43. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ច្រឡំ[73] ចំពោះព្រំដែននៃយុត្តាធិការបុគ្គលរបស់តុលាការនេះ ជាពិសេសចំពោះអត្ថន័យនៃពាក្យ ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត នេះតែម្តង។ ការបកស្រាយទូលំទូលាយពេករបស់គាត់ទៅលើពាក្យនេះ គឺជាកំហុសអង្គច្បាប់ ដែលនាំឲ្យមាន*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ពុំមានសុពលភាពឡើយ។ តាមការយល់ឃើញដ៏ត្រឹមត្រូវក្នុងន័យចង្អៀត ដូចដែលសហចៅក្រមស៊ើបអង្កេតជាតិបានអនុវត្ត[74] អោ អាន មិនមែនជាបុគ្គលម្នាក់ដែលស្ថិតនៅក្នុងចំណោមជនទាំង

---

[71] *សូមមើល* អនុសញ្ញាទីក្រុងវីយ៉ែន មាត្រា ៣១(៣)(ខ)។

[72] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៦២-៧៦។

[73] នៅពេលកំណត់ថាតើ អោ អាន ស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរឬទេ ស.ច.ស.អ ពុំកំណត់លក្ខណៈវិនិច្ឆ័យច្បាស់លាស់នោះទេ ប៉ុន្តែ បានស្នើសុំឲ្យភាគីពិនិត្យមើលសំអាងហេតុនៅក្នុង*ដីកាដំណោះស្រាយ* (សំអាងហេតុ) នៅក្នុងសំណុំរឿង ០០៤/០១។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៥-៥៦។ ជាធម្មតា គាត់បានយោងលើលក្ខណៈវិនិច្ឆ័យនេះនៅពេលសម្រេចដោយមានការពិភាក្សាតិចតួច។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៥, ៦៩៩។

[74] សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៤៣០, ៤៨២-៤៨៤, ៥៤២។

ឡាយដែលទទួលខុសត្រូវខ្ពស់បំផុតនោះទេ។

44. ពិសេសបំផុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយ (ក) ការធ្វើមិនដឹងមិនឮចំពោះការយល់ឃើញក្នុងន័យចង្អៀតរបស់ពាក្យនេះ ដោយបានសំអាងទៅលើប្រវត្តិនៃកិច្ចចរចារបស់ អ.វ.ត.ក និងជំហររបស់សហព្រះរាជអាជ្ញាជាតិ និងសំឡេងភាគច្រើនរបស់ចៅក្រមក្នុងសំណុំរឿង ០០៤ (ខ) ការខកខានអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ (in dubio pro reo)* និងការបកស្រាយតាក្នុងន័យចង្អៀត (គ) ការយល់ឃើញចំពោះជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតតាមរយៈការផ្ទុះបញ្ឆាំងពីសហឧក្រិដ្ឋម្ឋមទម្រង់ទី១ (JCE I) និង (ឃ) ដោយការប្រៀបធៀប អោ អាន ជាមួយ អ៊ឹម ចែម និង ឌុច[75] តែប៉ុណ្ណោះ ដោយមិនធ្វើការប្រៀបធៀបឲ្យបានពិតប្រាកដជាមួយនឹងកម្មាភិបាលខ្មែរក្រហមដទៃទៀតដែលគេស្គាល់ច្បាស់លាស់ ដូចជា កែ ពក, *តា* ម៉ុក និង សៅ សារុន ដូចដែលសហចៅក្រមស៊ើបអង្កេតជាតិបានធ្វើការប្រៀបធៀបនោះឡើយ។[76]

45. មេធាវីការពារក្តីសូមដាក់បញ្ចូលដោយយោងទៅលើទឡ្ហីករណ៍របស់ខ្លួន ដែលយកចេញពី*ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាដីកាសន្និដ្ឋានស្ថាពរ* ពាក់ព័ន្ធនឹងអត្ថន័យនៃពាក្យថា ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។[77] ដូចដែលមេធាវីការពារក្តីបានពន្យល់រួចមកហើយថា គេត្រូវតែយល់អពីពាក្យពេចន៍ទាំងនៅក្នុងបរិបទរបស់ អ.វ.ត.ក ព្រមទាំងការបង្កើត និងការពិចារណាទៅលើគោលបំណងរបស់ភាគីទាំងឡាយ នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជា ដើម្បីកម្រិតពីចំនួនបេក្ខជនសំខាន់ៗសម្រាប់យកមកវិនិច្ឆ័យទោស។ ដូច្នេះ យុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ត្រូវបានកំណត់ចំពោះ៖ (ក) មេដឹកនាំដែលបានដាក់ចេញនូវគោលនយោបាយ ឬមនុស្សសំខាន់ៗចាំបាច់សម្រាប់ការអនុវត្ត និងការផ្សព្វផ្សាយគោលនយោបាយរបស់ខ្លួន និង (ខ) អ្នកដែលបានដើរតួនាទីកាន់តែលេចធ្លោនៅក្នុងការចូលរួមប្រព្រឹត្តឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត នៅពេលប្រៀបធៀបទៅនឹងកម្មាភិបាលខ្មែរក្រហមដទៃទៀត ដែលគេបានស្គាល់ច្បាស់នោះ។ ដូចបានពន្យល់ក្នុងផ្នែក II (ង) អោ អាន មិនបានបំពេញលក្ខណៈវិនិច្ឆ័

[75] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៩៩។

[76] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៥៥២។

[77] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៩១-៩៨។

យទាំងនេះទេ។

### i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើទៅលើការយល់ឃើញក្នុងន័យចង្អៀតនៃពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" ដែលបានសំអាងលើប្រវត្តិនៃកិច្ចចរចា ការអនុវត្តជាបន្តបន្ទាប់របស់ភាគីនានា ព្រមទាំងទស្សនៈរបស់សហព្រះរាជអាជ្ញាជាតិ និងបណ្ដាចៅក្រមជាតិ

46. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដោយធ្វើមិនដឹងមិនឮចំពោះប្រវត្តិនៃកិច្ចចរចាបបង្កើត អ.វ.ត.ក ការអនុវត្តជាបន្ទាប់របស់ភាគីនានានៃកិច្ចព្រមព្រៀងនេះ ព្រមទាំងទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងចៅក្រមជាតិ នៅពេលពិចារណាអំពីអត្ថន័យនៃជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត។ ដូចបានលើកឡើងនៅក្នុង*ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា* ដែលបានសំអាងលើប្រវត្តិនៃកិច្ចចរចាបង្កើត អ.វ.ត.ក ការប្រកាសជាន្តបន្ទាប់ពីសំណាក់ភាគីនៃកិច្ចព្រមព្រៀងនេះ ព្រមទាំងព្រមទាំងទស្សនៈរបស់សហព្រះរាជអាជ្ញាអន្តរជាតិ និងចៅក្រមជាតិ នោះវាច្បាស់ហើយថាតុលាការនេះត្រូវបានបង្កើតឡើងដើម្បីវិនិច្ឆ័យទោសតែចំពោះមេដឹកនាំជាន់ខ្ពស់តែប៉ុណ្ណោះ។[78] ពាក្យថា "មេដឹកនាំ" គឺត្រូវបានកម្រិតពីដំបូងឡើយត្រឹមថ្នាក់ដឹកនាំកំពូលនៃបក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់មជ្ឈិមបក្ស ដោយមិនរាប់បញ្ចូលមេដឹកនាំថ្នាក់ភូមិភាគ និងថ្នាក់តំបន់ឡើយ។[79] វិសាលភាពនេះត្រូវបានពង្រីកបន្តបន្ទាប់មកទៀតដើម្បីបន្ថែម"អ្នកទទួលខុសត្រូវខ្ពស់បំផុត"ដើម្បីបង្កលក្ខណៈឲ្យមានកាត់សេចក្ដីឌុច ដែលកំពុងស្ថិតនៅក្នុងមន្ទីរឃុំឃាំង ហើយដែលខានពុំបានសម្រាប់មន្ទីរសន្តិសុខ ស-២១ ដែលជាគុកដ៏អសោចកេរ្ដិ៍ឈ្មោះបំផុតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។[80]

47. តាមការយល់ឃើញទៅលើបរិបទដ៏ត្រឹមត្រូវរបស់វា ការពង្រីកវិសាលភាពដោយមានកម្រិតនៃយុត្តាធិការរបស់តុលាការនេះ គឺដើម្បីស្រូបបញ្ចូលកម្មាភិបាលខ្មែរក្រហមទាំងឡាយដែលសំខាន់ចាំបាច់នៅក្នុងការបង្កើត និងការអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា និងដែលមានតួនាទីសំខាន់ជាងគេ ដោយតម្រូវឲ្យមានការប្រៀបធៀបនៅក្នុងជួរ បក្សកុម្មុយនីស្តកម្ពុជា ហើយមានមុខតំណែងសំខាន់ជាងគេ នៅក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតចន្លោះពីឆ្នាំ ១៩៧៥ ដល់

---

[78] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៨២-៩២, ៩៨។

[79] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៨២, ៨៤, ៨៧។

[80] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៨៥-៨៦, ៩១។

១៩៧៩។[81] ការពង្រីកវិសាលភាពដោយមានកម្រិតនេះមិនមានចេតនារាប់បញ្ចូលបុគ្គលទាំងឡាយដូចជា អោ អាន នេះទេ។ ដូចបានពន្យល់នៅក្នុងផ្នែក II (ង) អោ អាន មិនស្ថិតនៅក្នុងចំណោមមេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងមជ្ឈិមបក្សទេ មិនមានសិទ្ធិអំណាចសម្រេច ឬបកស្រាយគោលនយោបាយ និងមិនមែនជាមនុស្សសំខាន់ចាំបាច់ចំពោះការអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា នោះទេ។ លើសពីនេះទៀត ទោះជាការចោទប្រកាន់ទាំងអស់ត្រូវបានទទួលយកក្តី ក៏ អោ អាន អាចមានតួនាទី និងមុខតំណែងសំខាន់តិចតួចណាស់នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា និងចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតដែលបានយកមកចោទប្រកាន់ បើប្រៀបធៀបទៅនឹងកម្មាភិបាលខ្មែរក្រហមដទៃទៀត។

### ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តគោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀត

48. ទោះបីជាកង្វះខាតភាពច្បាស់លាស់អាចកើតមានបន្ទាប់ពីការបកស្រាយលើពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត"[82] ក្តី ក៏គោលការណ៍ស្តីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយក្នុងន័យចង្អៀត តម្រូវឱ្យអនុវត្តនិយមន័យចង្អៀតបំផុត ដើម្បីផ្តល់ជាប្រយោជន៍ឱ្យ អោ អាន។[83] ទោះបីជាមានការលើកឡើងអំពីគោលការណ៍ទាំងនេះនៅក្នុងសំណុំរឿង ០០៤/១[84] ក៏ដោយ ក៏ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តគោលការណ៍ទាំងនេះទេ។

### iii. ទស្សនៈរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចំពោះពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់

---

[81] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៩២។

[82] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ៩៨។ មេធាវីការពារក្តីបានតវ៉ានៅក្នុង*ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ* ថា ផ្អែកលើប្រវត្តិរៀបចំសេចក្តីព្រាង និងសេចក្តីថ្លែងការណ៍នាពេលក្រោយៗ មានការបញ្ជាក់យ៉ាងជាក់លាក់។

[83] វិធាន ២១(១)។ រដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៣៨។ *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ភ្លាមៗរបស់ ខៀវ សំផន* កថាខណ្ឌ ៣១។ រឿងក្តី *Renzaho តទល់នឹង រដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-97-31-A, *សាលដីកា* ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០១១ កថាខណ្ឌ ៤៧៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣១។ រឿងក្តី *Kokkinakis តទល់នឹង ប្រទេសក្រិច* ECtHR ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ១៩៩៣ កថាខណ្ឌ ៥២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣២។

[84] សំណុំរឿង ០០៤/១-ឯកសារ **D308/3** កថាខណ្ឌ ២៦-៣៦។

**បំផុត" តាមរយៈ ការស្តែងចេញពីសហឧក្រិដកម្មរួមទម្រង់ទី១ (JCE I) និងការភាន់ច្រឡំ ទៅលើទស្សនទានស្តីពីយុត្តាធិការបុគ្គល ជាមួយនឹងទម្រង់នៃការទទួលខុសត្រូវ**

49. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទំនងជាយល់ឃើញចំពោះពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" តាមរយៈការស្តែងចេញពីសហឧក្រិដ្ឋកម្មរួម I ដែលជាការយល់ច្រឡំមិនត្រឹមត្រូវទាល់តែសោះចំពោះទស្សនទានស្តីពីយុត្តាធិការបុគ្គល ជាមួយនឹងទម្រង់នៃការទទួលខុសត្រូវ។[85] ការសម្រេចលើនិយមន័យនៃពាក្យ "ជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត" មិនអាចសំអាងតែមួយមុខទៅលើសមាជិកភាពរបស់ អោ អាន ដូចដែលបានចោទប្រកាន់នៅក្នុងសហឧក្រិដ្ឋកម្មរួម ទម្រង់ទូលាយដែលរាប់បញ្ចូលជាចាំបាច់នូវខ្សែសង្វាក់នៃការបញ្ជាចាប់ពីកូនទាហានថ្មើរជើងរហូតដល់មេដឹកនាំជាន់ខ្ពស់ បក្សកុម្មុយនីស្តកម្ពុជា។ ការបកស្រាយនេះនឹងបណ្តាលឱ្យសមាជិកសំខាន់ៗទាំងអស់នៃសហឧក្រិដ្ឋកម្មរួម ក្លាយជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែលអាចធ្វើឱ្យបរាជ័យដល់កម្មវត្ថុ និងគោលបំណងនៃមាត្រា ២(១) នៃកិច្ចព្រមព្រៀងរវាង អ.ស.ប និងរាជរដ្ឋាភិបាលកម្ពុជាដែលកម្រិតយុត្តាធិការបុគ្គលរបស់តុលាការនេះ។

50. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គួរតែបានអនុវត្តលក្ខណៈវិនិច្ឆ័យនេះ[86] ដើម្បីពិចារណាថាតើ អោ អាន ស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតដូចដែលសហចៅក្រមស៊ើបអង្កេតជាតិបានអនុវត្តដែរឬទេ[87] ហើយបន្ទាប់មក ការយល់ឃើញជាវិជ្ជមានត្រូវបានធ្វើឡើងតែម្តងគត់ ហើយប្រសិនដូច្នេះមែន គាត់គួរតែបានពិនិត្យទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌ តាមរយៈទម្រង់នៃការទទួលខុសត្រូវ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ វាយតម្លៃអំពីតួនាទីរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មនានាដ៏ធ្ងន់ធ្ងរបំផុត ដូចជា ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ តាមរយៈទម្រង់ទូលាយនៃសហឧក្រិដ្ឋកម្មរួម រួចក៏ទាញសេចក្តីសន្និដ្ឋានលើយុត្តាធិការបុគ្គលតែម្តង។ ដោយការធ្វើដូច្នេះ គាត់គ្រាន់តែវាយតម្លៃអំពីការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មទាំងឡាយតែប៉ុណ្ណោះ ហើយគាត់ចៀសវាងមិនធ្វើការវាយតម្លៃឱ្យបានត្រឹមត្រូវ អំពីលក្ខណៈវិនិច្ឆ័យចំពោះ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះឡើយ។ វិធីសាស្ត្រថយក្រោយ និងសិប្បនិមិត្តបែបនេះ គឺបំភ្លើសយ៉ាង

---

[85] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៩៩, ៧០៦-៧១១, ៧៣០, ៨២៦-៨៣១។

[86] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ៣២៨។ សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៤២៨។ សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៦២។

[87] *ដីកាដំណោះស្រាយរបស់ ស.ច.ស.ជ* កថាខណ្ឌ ២, ១៧។

ខ្លាំងទៅលើតួនាទីរបស់ អោ អាន ចំពោះឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតដែលបានយកមកចោទប្រកាន់។

51. ឧទាហរណ៍ ពេលសម្រេចថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចង្អុលបង្ហាញយ៉ាងជាក់លាក់អំពីតួនាទីរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍លើប្រជាជនចាមនៅភូមិភាគកណ្តាល។[88] ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់ភ័ស្តុតាង[89] នៃការចូលរួមពាក់ព័ន្ធរបស់ អោ អាន ដូចដែលបានចោទប្រកាន់ នៅក្នុងតំបន់ ៤១ តែប៉ុណ្ណោះ មិនមែនតំបន់ ៤២ និងតំបន់ ៤៣ នោះទេ។[90] គាត់ថែមទាំងបានទទួលស្គាលថា មានភ័ស្តុតាងតិចតួចស្តីពីសកម្មភាពរបស់ អោ អាន នៅថ្នាក់ភូមិភាគ[91] ឬការគ្រប់គ្រងរបស់គាត់ទៅលើជនដែលនៅក្នុងតំបន់ ៤២ និងតំបន់ ៤៣។[92] ប៉ុន្តែនៅទីបំផុត តាមរយៈការស្តែងចេញពីសហឧក្រិដ្ឋកម្មរួម[93] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រេចថា អោ អាន មានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះអំពើប្រល័យពូជសាសន៍ នៅទូទាំងភូមិភាគ ហើយសម្រេចថា កាទទួលខុសត្រូវរបស់គាត់ គឺស្មើនឹងការទទួលខុសត្រូវដែលបានកំណត់ថាជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" សម្រាប់យុត្តាធិការបុគ្គល។[94]

52. ដោយការអនុវត្តទម្រង់ទូលាយនៃការទទួលខុសត្រូវព្រហ្មទណ្ឌក្រោមសហឧក្រិដ្ឋកម្មរួម សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្កើតឲ្យមានការភាន់ច្រឡំថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត។ តាមពិតទៅ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ងាកចេញពីលក្ខខណ្ឌតម្រូវសម្រាប់ការវាយតម្លៃឲ្យបានត្រឹមត្រូវនៃយុត្តាធិការបុគ្គល។

### iv. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កម្រិតការវិភាគប្រៀបធៀបរបស់គាត់យ៉ាងចម្លែក/ដោយមិនអាចឲ្យ

---

[88] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៧០៦-៧០៩, ៧៣០។

[89] មេធាវីការពារក្តីពន្យល់នៅក្នុងផ្នែក II (ង)(vi) និង (ច) ថា ភ័ស្តុតាងនេះពុំបានបំពេញបទដ្ឋាននៃការបង្ហាញភ័ស្តុតាងនោះឡើយ។

[90] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៣៥, ៨៤៨-៨៤៩។

[91] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥២, ២៥៥, ២៦០-២៦២។

[92] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៤៩។

[93] ដូចបានពន្យល់នៅក្នុងផ្នែក II (ង)(vi) ស.ច.ស.អ ពុំបានផ្តល់ភ័ស្តុតាងអំពីការចូលរួមរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ដូចបានចោទប្រកាន់នៅក្នុងតំបន់ ៤២ ឬ ៤៣ តាមរយៈទម្រង់នៃការទទួលខុសត្រូវនោះឡើយ។

[94] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៧០៧ បទចោទទី១។

## យល់បាន ទៅនឹង អ៊ឹម ចែម និង ឌុច

53. ដោយពុំមានការពន្យល់ណាមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានពុំបានធ្វើការប្រៀបធៀប អោ អាន និងកម្មាភិបាលខ្មែរក្រហមដទៃទៀតដែលគេស្គាល់ ពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យលើយុត្តាធិការបុគ្គលចំពោះ៖ (ក) កម្រិតនៃការទទួលខុសត្រូវ រួមទាំង ឋានៈ វិសាលភាពនៃអំណាច លទ្ធភាពតាក់តែងគោលនយោបាយ តួនាទីក្នុងការអនុវត្តគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា តួនាទីនៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និង (ខ) ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ រួមទាំងចំនួនជនរងគ្រោះ ព្រមទាំងវិសាលភាពភូមិសាស្ត្រ និងពេលវេលាផងដែរ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិធ្វើការប្រៀបធៀបសើៗ ដោយមានកម្រិត និងមិនសុក្រឹតអំពី អោ អាន ជាមួយ អ៊ឹម ចែម និង ឌុច។[95] ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬយុត្តិសាស្ត្រ (ឬយុត្តិកម្មផ្សេងទៀត) ពុំបានហាមឃាត់ចំពោះការវិភាគប្រៀបធៀប ដែលតម្រូវសម្រាប់ការវាយតម្លៃអំពីយុត្តាធិការបុគ្គល ដោយប្រៀបធៀបតែទៅនឹងកម្មាភិបាលខ្មែរក្រហមដែលត្រូវបានស៊ើបអង្កេត ឬចោទប្រកាន់ ឬផ្តន្ទាទោសដោយតុលាការនេះឡើយ។ ការខកខានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដើម្បីធ្វើការប្រៀបធៀបជាក់ស្តែង ទៅនឹងកម្មាភិបាលខ្មែរក្រហមដទៃទៀតដែលគេស្គាល់ ដូចជា កែ ពក, តា ម៉ុក និង សៅ សារុន គឺជាកំហុសអង្គច្បាប់។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើការវិភាគប្រៀបធៀបពិតប្រាកដមួយ ដូច សហចៅក្រមស៊ើបអង្កេតជាតិ បានប្រៀបធៀប[96] នោះគាត់ពុំអាចសម្រេចថា អោ អាន គឺជាបុគ្គលម្នាក់ ដែលស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតបានឡើយ។

54. សរុបសេចក្តីមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសចំពោះការបកស្រាយអំពីពាក្យ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខណៈមួយហួសហេតុពេក។ ប្រសិនបើគាត់បានអនុវត្តការយល់ដឹងឲ្យបានត្រឹមត្រូវក្នុងន័យចង្អៀតអំពីយុត្តាធិការបុគ្គល នោះគាត់ពុំអាចសម្រេចថា អោ អាន គឺជាបុគ្គលម្នាក់ដែលស្ថិត ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតបានឡើយ។ យុត្តាធិការរបស់តុលាការនេះត្រូវបានកម្រិតចំពោះ (ក) មេដឹកនាំដែលកំណត់គោលនយោបាយ ឬមនុស្សសំខាន់ចាំបាច់ចំពោះការអនុវត្ត និងការផ្សព្វផ្សាយគោលនយោបាយរបស់បក្ស និង (ខ) កម្មាភិបា

[95] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៩៩។

[96] សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៥១១-៥២០, ៥៤៣-៥៥១។

លខ្មែរក្រហមទាំងឡាយដែលតួនាទីរបស់ខ្លួននៅក្នុងជួរ បក្សកុម្មុយនីស្តកម្ពុជា និងមុខតំណែងនៅក្នុងឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតនាសម័យកម្ពុជាប្រជាធិបតេយ្យ សំខាន់ជាងកម្មាភិបាលដទៃទៀត។ ដូចបានពន្យល់ក្នុងផ្នែក II (ង) អោ អាន មិនស្ថិតនៅក្នុងរង្វង់យុត្តាធិការរបស់តុលាការនេះទេ ពីព្រោះ បើប្រៀបធៀបទៅ គាត់ពុំមានតួនាទី ឬមុខតំណែងអ្វីសំខាន់ខ្លាំង នៅក្នុងឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតនាសម័យកម្ពុជាប្រជាធិបតេយ្យនោះទេ បើប្រៀបធៀបទៅនឹងកម្មាភិបាលខ្មែរក្រហមដទៃទៀត។

## គ. សំអាងហេតុទី ៤÷ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុវត្តបទដ្ឋានស្តីពីការបង្ហាញភ័ស្តុតាងពុំបានត្រឹមត្រូវ

55. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានអនុវត្តបទដ្ឋានដែលត្រឹមត្រូវស្តីពីការបង្ហាញភ័ស្តុតាងក្នុងការពិចារណាថាតើតុលាការនេះមានយុត្តាធិការបុគ្គលទៅលើ អោ អាន ដែរឬអត់នោះទេ។ បទដ្ឋានស្តីពីការបង្ហាញភ័ស្តុតាងដែលត្រឹមត្រូវសម្រាប់យុត្តាធិការបុគ្គល គឺសមមូលទៅនឹងបទដ្ឋានស្តីពីការបង្ហាញភ័ស្តុតាងសម្រាប់ការចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ ស.ច.ស ត្រូវតែបង្ហាញភ័ស្តុតាងដែល "មានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឲ្យមានតម្លៃជាភ័ស្តុតាងបន្ទាល់"[97] ដល់ការបង្ហាញឲ្យលើសពីគ្រាន់តែជាភវនីយភាពថា អោ អាន គឺជាបុគ្គលម្នាក់ដែលស្ថិតនៅក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានយកមកចោទប្រកាន់។[98]

---

[97] ឧទាហរណ៍ សំណុំរឿង ០០២-ឯកសារ **D427** កថាខណ្ឌ ១៣២០-១៣២៦។

[98] វិធាន៦៧ (៣)(គ) (លើកឡើងថា ក្នុងករណី 'មិនមានភ័ស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងជនត្រូវចោទ' ស.ច.ស ត្រូវចេញដីកាលើកលែងការចោទប្រកាន់)។ ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០០៧) មាត្រា ២៤៧(៣) (លើកឡើងថា ចៅក្រមស៊ើបអង្កេតចេញដីកាមិនចាត់ការក្នុងករណីដែល "មានភ័ស្តុតាងមិនគ្រប់គ្រាន់សម្រាប់ការចោទប្រកាន់ជនត្រូវចោទ")។ ក្រមនីតិវិធីព្រហ្មទណ្ឌ (បារាំង) មាត្រា ១៨៤។ ទោះបីជា *វិធានផ្ទៃក្នុង អ.វ.ត.ក* និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (ឆ្នាំ២០០៧) ពុំកំណត់និយមន័យនៃបទដ្ឋាន 'ភ័ស្តុតាងគ្រប់គ្រាន់' ក៏ដោយ ក៏ ស.ច.ស បានកំណត់និយមន័យនៅក្នុងសំណុំរឿង ០០១ សំណុំរឿង ០០២ និងសំណុំរឿង ០០៤/០១។ សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ៦១-៦២។ សំណុំរឿង ០០៤/១-ឯកសារ **D308/3** កថាខណ្ឌ ២។ សំណុំរឿង ០០២-ឯកសារ **D427** កថាខណ្ឌ ១៣២១-១៣២៣។ សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស, *ដីកាដំណោះស្រាយ* ឯកសារ **D99** ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ១៣០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣៣។ នៅក្នុងសំណុំរឿង ០០២ ស.ច.ស បានបកស្រាយ 'ភ័ស្តុតាងគ្រប់គ្រាន់' មានន័យថា ការរំពឹងទុកនៃការដាក់ទោសពុំមែនត្រឹមតែលទ្ធភាពនៃការដាក់ទោសប៉ុណ្ណោះទេ។ សំណុំរឿង ០០២-ឯកសារ **D427** កថាខណ្ឌ ១៣២៣។ មានការ

56. ការអនុវត្តបទដ្ឋាននៃការបង្ហាញភ័ស្តុតាងដូចគ្នាបេះបិទនៅទូទាំងធាតុផ្សំសម្ភារៈទាំងអស់នៃដីកាដំណោះស្រាយមួយ គឺស្របគ្នាជាមួយនឹងយុត្តិសាស្ត្រអន្តរជាតិ[99] និងគោលការណ៍សច្ចភាពផ្លូវច្បាប់។ ការសម្រេចអំពីយុត្តាធិការបុគ្គល គឺជាបុរេលក្ខខណ្ឌសម្រាប់នីតិវិធីបន្តទៅទៀត ហើយការខកខានវាយតម្លៃភ័ស្តុតាងនៅដំណាក់កាលនេះបង្កើតបានជាបន្ទុកមកលើមេធាវីការពារក្តី ហើយថែមទាំងនាំឱ្យមានការខ្ជះខ្ជាយដល់ធនធានតុលាការទៀតផង។

57. ទោះបីជា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សំអាងដោយដោយអន្លើ[100] ឬប្រលយពាក្យចំពោះអត្ថិភាពនៃបទដ្ឋានមួយ ជាពិសេស ពេលរិះគន់ អង្គបុរេជំនុំជម្រះ[101] ក៏ដោយ ក៏គាត់ពុំដែលកំណត់អត្ថន័យជាក់ស្តែងអំពីបទដ្ឋាននេះទេ។ នៅពេលពិនិត្យ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* នោះវាច្បាស់ហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បត់បែន និងពន្លាតបទដ្ឋាននៃការបង្ហាញភ័ស្តុតាង ហេតុដូច្នេះ បទដ្ឋាននេះមិនអាចទទួលស្គាល់តទៅទៀតបានទេ។[102] ទីបំផុត បទដ្ឋានដែលត្រូវបានយកមកអនុវត្តនៅត្រង់ចំណុច

---

ពន្យល់ថា ភ័ស្តុតាងនៅក្នុងសំណុំរឿង 'ត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ដើម្បីឱ្យមានតម្លៃជាភ័ស្តុតាងបន្ទាល់' ដែលថា មានភវនីយភាពនៃពិរុទ្ធភាពរបស់ជនត្រូវចោទ។ សំណុំរឿង ០០២-ឯកសារ **D427** កថាខណ្ឌ ១៣២៣។ សូមមើលផងដែរ Chambon & Guery, *Droit et pratique de l'instruction préparatoire* (Paris: Dalloz, 2015) កថាខណ្ឌ ៦១៣.១២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣៤។

[99] *សូមមើល រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Mrkšić និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-95-13/1-A, *សាលក្រម* ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ២២០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣៥ (សម្រេចថា 'បទដ្ឋាននៃការបង្ហាញភ័ស្តុតាងនៅពេលជំនុំជម្រះតម្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចរកឃើញពិរុទ្ធភាពជនជាប់ចំពោះឧក្រិដ្ឋកម្ម តែក្នុងករណីដែលអយ្យការបានបង្ហាញធាតុផ្សំបទល្មើសនោះ និងទម្រង់នៃការទទួលខុសត្រូវ និងអង្គហេតុដែលចាំបាច់បំផុតសម្រាប់ការផ្តន្ទាទោស ឱ្យហួសពីវិមតិសង្ស័យ')។

[100] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៣០, ៤២២, ៧០៥, ៧៣៣, ៧៣៣, ៧៤០, ៧៤៥, ៧៥២, ៧៥៦, ៧៩៣, ៨០៩, ៨១៦, ៨៤៦, ៨៤៩, ៨៥៣។

[101] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៧ (vii)។

[102] ទោះបីជាឧទាហរណ៍នៃការអនុវត្តខុសរបស់ ស.ច.ស.អ ទៅលើបទដ្ឋាន មានចំនួនច្រើនពេកមិនអាចដាក់បញ្ចូលទាំងអស់នៅទីនេះបានក៏ដោយ ក៏ឧទាហរណ៍ច្បាស់ក្រឡែតបំផុតមួយចំនួន ពាក់ព័ន្ធនឹងការវាយតម្លៃរបស់គាត់លើយុត្តាធិការបុគ្គល។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥២, ៧០៣ (ស.ច.ស.អ លើកឡើងថា 'ភ័ស្តុតាងគាំទ្រការសន្និដ្ឋាន' ថា អោ អាន គឺជាអនុលេខាភូមិភាគកណ្តាលពីចុងឆ្នាំ១៩៧៧ ដល់ចុងឆ្នាំកម្ពុជាប្រជាធិបតេយ្យ។ ដើម្បីគាំទ្រការយល់ឃើញនេះ ស.ច.ស.អ សំអាងលើសាក្សីម្នាក់គឺ អ៊ឹម ប៉ុន ដែលជាអ្នកបើកឡានរបស់ អោ អាន និងភ័ស្តុតាងចចាមរ៉ាមពី

ណារវាងមូលដ្ឋាន*បឋម* និងមូលដ្ឋានសមហេតុសមផលដើម្បីធ្វើឲ្យជឿជាក់ដែលមូលដ្ឋានទាំងពីរនេះមិនត្រឹមត្រូវនោះទេ។ បើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុវត្តបទដ្ឋានត្រឹមត្រូវនៃការបង្ហាញភ័ស្តុតាងនៅក្នុងសំណុំរឿងនេះ នោះគាត់មិនអាចសម្រេចថា តុលាការនេះមានយុត្តាធិការបុគ្គលមកលើ អោ អាន ឡើយ។

## ឃ .សំអាងហេតុទី ៥÷ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្កើត និងសំអាងខុសទៅលើឋានានុក្រមនៃភ័ស្តុតាងជំនួសឲ្យការពិនិត្យខ្លឹមសារនៃភ័ស្តុតាងទៅវិញ

58. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសនៅក្នុងការបង្កើត និងសំអាងទៅលើឋានានុក្រមនៃភ័ស្តុតាង ដោយបានយោងទៅលើប្រភព និងទម្រង់ ដែលក្នុងនោះកំណត់ហេតុនៃការសម្ភាប់ចម្លើយនានាស្ថិតនៅលំដាប់ខ្ពស់បំផុត ហើយតាមរយៈនេះ ខកខានមិនបានបំពេញការវាយតម្លៃលើខ្លឹមសារនៃភ័ស្តុតាងឲ្យបានពេញលេញទេ។[103] ជាពិសេស គាត់មិនបាន (ក) ពិនិត្យលើភាពគួរឲ្យជឿជាក់បានរបស់សាក្សីសំខាន់ៗ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី[104] (ខ)

---

សាក្សីមួយទៀត។ គាត់ច្រានចោលចម្លើយរបស់ គូ សេម ប្រពន្ធរបស់ ស៊ឹម លេខាតំបន់ ៤៣ ដែលលោកស្រីបញ្ជាក់ថា អោ អាន មានតួនាទីបណ្តោះអាសន្នដោយសារប្ដីរបស់គាត់កាន់កាប់តួនាទីនោះយ៉ាងហោចណាស់ ៦ ខែ មុនពេលរបបនោះបានបញ្ចប់។ ដោយពុំបានពន្យល់អ្វីទាំងអស់ ស.ច.ស.អ ប្រកាសថា ចម្លើយរបស់ប្រពន្ធកម្មាភិបាល ដែលពិពណ៌នាអំពីតួនាទីរបស់ប្ដីហើយបានឆ្លើយដាក់ពិរុទ្ធភាពលើគាត់ មិនអាចជឿជាក់បានដូចចម្លើយរបស់អ្នកបើកឡានរបស់ អោ អាន ទោះបីអ្នកបើកឡានមិនត្រូវបានទទួលការងារជាប់ជាមួយបុគ្គល និងតែងតែប្ដូរតួនាទីក៏ដោយ។ កថាខណ្ឌ ២៥៥, ២៦១-២៦២, ៧០៥, ៨៤៩ (ស.ច.ស.អ សន្និដ្ឋានថា 'មានភ័ស្តុតាងគ្រប់គ្រាន់' ដែលថា អោ អាន 'បានកាន់កាប់មុខងាររបស់ កែ ពក ច្រើនឡើងៗ ក្នុងនាមជាលេខាភូមិភាគកណ្ដាលស្ដីទីនៅក្នុងស្ថានភាពជាក់ស្តែង ដោយសារថា កែ ពក នៅជាប់ការងារសឹកសង្គ្រាម'។ នៅក្នុងប្រយោគបន្ទាប់ ស.ច.ស.អ ទទួលស្គាល់ថា វា 'មិនច្បាស់ថាតើនៅពេលណាពិតប្រាកដ និងរយៈពេលយូរប៉ុណ្ណា ដែលតួនាទីជាក់ស្តែងនេះត្រូវបានអនុវត្ត។ ករណីដែលគាត់បានប្រើប្រាស់តួនាទីពិសេសនេះ ក៏មិនអាចរកឃើញមានដែរ [*sic*]'។ បន្ទាប់មក នៅក្នុងដីកាដំណោះស្រាយ ស.ច.ស.អ ក៏សន្និដ្ឋានផងដែរថា អោ អាន ពុំមានអំណាចគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើតំបន់ ៤២ និង ៤៣ ទេ។ ប្រសិនបើ ស.ច.ស.អ បានទទួលស្គាល់ថា គ្មានភ័ស្តុតាងបង្ហាញថា អោ អាន បានកាន់តួនាទីជាលេខាស្ដីទីភូមិភាគនៅពេលណា ហើយគាត់កាន់កាប់រយៈពេលប៉ុន្មាន តើគាត់មានតួនាទីជាក់លាក់អ្វីខ្លះ ករណីដែល អោ អាន អនុវត្តអំណាចនៅក្នុងតួនាទីនេះ ឬ ការគ្រប់គ្រងលើតំបន់ផ្សេងទៀតនៅក្នុងភូមិភាគនោះទេ នោះវាប្រាកដណាស់ថាបទដ្ឋានតម្រូវនៃភ័ស្តុតាងមិនត្រូវបានបំពេញ)។

[103] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៧(ក) ១២៣-១២៨ ១៥៦។

[104] មេធាវីការពារក្ដីនៅតែប្រកាន់ជំហរថា អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពុំទាន់ជាដើមបណ្ដឹងរដ្ឋប្បវេណីនោះទេដោយសារមានដីកាខ្វែងយោបល់គ្នារបស់ ស.ច.ស.អ និង ស.ច.ស.ជ។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត

ពិចារណាលើអានុភាពនៃវិធីសាស្ត្រគួរឱ្យសង្ស័យរបស់មន្ត្រីស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេតចំពោះការដកស្រង់ព័ត៌មាន ទោះបីជាមេធាវីការពារក្តីបានលើកឡើងនូវកំហុសទាំងនេះ នៅក្នុង*ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ* [105] (គ) ផ្តល់ភ័ស្តុតាងជាតម្រុងយដើម្បីគាំទ្រដល់ការយល់ឃើញផ្នែកអង្គហេតុស្តីពីយុត្តាធិការបុគ្គល និង (ឃ) យកចិត្តទុកដាក់ជាមួយនឹងភ័ស្តុតាងដែលចេញពីពាក្យចចាមអារ៉ាម។

59. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើនឹងការសម្រេចថ្មីៗរបស់អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/១ ដែលលើកឡើងថា ឋានានុក្រមនៃភ័ស្តុតាងបានយោងប្រភព ឬទម្រង់ទៅលើខ្លឹមសារ គឺជាកំហុសអង្គច្បាប់[106] ហើយគាត់មកស្រាយខុសចំពោះការពន្យល់របស់ អង្គបុរេជំនុំជម្រះ អំពីថាតើ សហចៅក្រមស៊ើបអង្កេតត្រូវវាយតម្លៃឱ្យបានពេញលេញលើខ្លឹមសារភ័ស្តុតាងដែរ ឬទេនោះ។[107] ប្រសិនបើសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានវាយតម្លៃឱ្យបានពេញលេញលើខ្លឹមសារភ័ស្តុតាងមែននោះ គាត់ពុំអាចសម្រេចថាបទដ្ឋាននៃការបង្ហាញភ័ស្តុតាងត្រូវបានបំពេញ និងថា តុលាការនេះមានយុត្តាធិការបុគ្គលទៅលើ អោ អាន ឡើយ។

### i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការខកខានអនុវត្តសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤១/

60. នៅក្នុង*ដីកាដំណោះស្រាយ (បញ្ជូនរឿងទៅជម្រះ)របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យល់ខុសចំពោះការយល់ឃើញរបស់ អង្គបុរេជំនុំជម្រះ ក្នុងសំណុំរឿង ០០៤/១។ គាត់លើកឡើងថា ការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ "មិនឆ្លុះបញ្ចាំងឱ្យបានត្រឹមត្រូវអំពីការពិចារណាលើភ័ស្តុតាងនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិលឡើយ" និងថា "កំហុសឆ្គងទាំងនេះមានលក្ខណៈដែល សហចៅក្រមស៊ើបអង្កេតមិនអាចទទួលយកការយល់ឃើញរបស់អង្គ

---

.ក/ក.ស.ច.ស, *ដីកាបដិសេធពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី* ឯកសារ **D361** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាសម្រេចលើភាពអាចទទួលស្គាល់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ឯកសារ **D362** ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[105] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ១៣០-១៨២, ១៨៨-២០០, ២១២។

[106] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ៥៦។

[107] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ៥២។

បុរេជំនុំជម្រះដោយគ្មានការជំទាស់ឡើយ”។[108] នៅក្នុងការការពាររបស់គាត់ចំពោះឋានានុក្រម ភ័ស្តុតាងដែលបានសំអាងទៅលើប្រភព សហចៅក្រមស៊ើបអង្កេតអន្តរជាតិបកស្រាយខុសចំពោះការយល់ឃើញរបស់ អង្គបុរេជំនុំជម្រះ។[109] ពេលអានក្នុងបរិបទនេះទៅ វាច្បាស់ហើយថាការរិះគន់របស់អង្គបុរេជំនុំជម្រះ អំពីវិធីសាស្ត្រនៃការវាយតម្លៃភ័ស្តុតាងក្នុងសំណុំរឿង ០០៤/១ ត្រូវបានកំណត់ចំពោះការបង្កើត និងការសំអាងលើឋានានុក្រមភ័ស្តុតាងឲ្យបានពេញលេញទៅលើខ្លឹមសារនៃភ័ស្តុតាងទាំងអស់។

---

[108] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៥។

[109] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៧ (ក)(ii) (ស.ច.ស.អ មានកំហុសនៅពេលសន្និដ្ឋានថា អ.ប.ជ ‘បានដកស្រង់ខ្លឹមសារដែលមិនមានប្រយោជន៍’ ដោយធ្វើការប្រៀបធៀបប្រព័ន្ធស៊ើបអង្កេតកម្ពុជាជាមួយនឹងប្រព័ន្ធស៊ើបអង្កេតបារាំង។ ទោះបីជាមេធាវីការពារក្តីយល់ស្របជាមួយ ស.ច.ស.អ ថា ប្រព័ន្ធច្បាប់ស៊ីវិលពីរមិនដូចគ្នាក៏ដោយ ក៏មេធាវីការពារក្តីមិនយល់ស្របឡើយដែលថា ការប្រៀបធៀបទៅនឹងប្រព័ន្ធបារាំងមិនត្រឹមត្រូវនោះ។ តាមពិត ប្រព័ន្ធកម្ពុជាផ្អែកលើប្រព័ន្ធបារាំង ហើយការប្រៀបធៀបមានប្រយោជន៍ ក៏ប៉ុន្តែពុំមែនជាកត្តាកំណត់នោះទេ) ។ កថាខណ្ឌ 37(ក)(iii) (ស.ច.ស.អ បកស្រាយមិនត្រឹមត្រូវចំពោះការសម្រេចរបស់ អ.ប.ជ អំពីភ័ស្តុតាងដែលប្រមូលបានដោយស្របច្បាប់ ដែលទទួលបាន សច្ចធារណ៍នៃភាពអាចជឿជាក់បានដូចគ្នា និងមានកំហុសនៅក្នុងទាញសេចក្តីសន្និដ្ឋានចេញពីការសម្រេចនេះដែលថា អ.ប.ជ នឹងចាត់ទុកភ័ស្តុតាងទទួលបានដោយការធ្វើទារុណកម្ម ឬផ្តល់ទម្ងន់ដូចគ្នាចំពោះលិខិតអនាមិកមួយដែលមានពាក្យថា “អោ អាន ជាអ្នកធ្វើលិខិតនេះ!” ថាជាកំណត់ហេតុនៃការស្តាប់ចម្លើយ ប្រសិនបើ ស.ច.ស ដាក់វត្ថុតាងទាំងពីរនេះនៅក្នុងសំណុំរឿង។ ស.ច.ស.អ បានបកស្រាយខុសទៅលើពាក្យពេចន៍របស់ អ.ប.ជ ។ ប្រសិនបើអានក្នុងបរិបទ ពោលគឺ នៅពេលអានប្រយោគនេះភ្លាមៗនៅមុន និងក្រោយប្រយោគដែល ស.ច.ស.អ ផ្តោតនោះ វាបង្ហាញយ៉ាងច្បាស់ថា អ.ប.ជ រិះគន់វិធីសាស្ត្រដែល ស.ច.ស.អ សម្រេចលើភាពអាចទុកចិត្តបាន ដោយផ្អែកលើឋានានុក្រមនៃភ័ស្តុតាង ដោយដាក់កំណត់ហេតុនៃការស្តាប់ចម្លើយរបស់គាត់នៅលើឋានានុក្រម និងវិធីសាស្ត្រដែលគាត់ច្រានចោលប្រភេទនៃភ័ស្តុតាងទាំងមូល ដោយផ្អែកលើតែអង្គហេតុថា គាត់មិនបានចូលរួមនៅក្នុងការប្រមូលភ័ស្តុតាង។ អ.ប.ជ ពុំបានសម្រេចថា ភ័ស្តុតាងទាំងអស់មានតម្លៃស្មើគ្នានោះទេ ប្រសិនបើពុំបានវាយតម្លៃបន្ថែមលើខ្លឹមសារ ឬ ថា ភ័ស្តុតាងទទួលបានក្រោមទារុណកម្មអាចទទួលយកបាននោះឡើយ) កថាខណ្ឌ ៣៧(ក)(iv) (ស.ច.ស.អ បកស្រាយមិនត្រឹមត្រូវលើសេចក្តីលើកឡើងរបស់ អ.ប.ជ អំពីប្រព័ន្ធជដែកស្ទួរដេញដោលរបស់ អ.វ.ត.ក ថា ប្រព័ន្ធនេះផ្អែកតែទៅលើភ័ស្តុតាងជាលាយលក្ខណ៍អក្សរ។ ស.ច.ស.អ បង្កប់ន័យថា អ.ប.ជ មានឆន្ទៈ ‘ចូលចិត្តចង់បានអ្វីដែលអាចមើលឃើញ’ ដោយមិនពិនិត្យលើខ្លឹមសារនៃភ័ស្តុតាង។ ការលើកឡើងនេះ គឺខុសពីអ្វីដែល អ.ប.ជ បានសម្រេច។ ផ្ទុយទៅវិញ អ.ប.ជ បានគូសបញ្ជាក់ជាច្រើនដងរួចហើយថា ស.ច.អ ត្រូវវាយតម្លៃលើខ្លឹមសារនៃភ័ស្តុតាង និងឥទ្ធិពលរបស់វាទៅលើជំនឿស្មោះត្រង់ពិតប្រាកដរបស់ខ្លួនអំពីថាតើបទដ្ឋាននៃភ័ស្តុតាងចំពោះយុត្តាធិការបុគ្គល និងការចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបានបំពេញដែរឬទេ។ អ.ប.ជ បានសម្រេចថា ប្រភព និងទម្រង់នៃភ័ស្តុតាងមិនមែនជាកត្តាកំណត់នោះឡើយ ហើយភាពអាចជឿជាក់បានគួរយកមកវាយតម្លៃទៅតាមករណីនីមួយៗ)។

61. ការយល់ឃើញរបស់អង្គបុរេជំនុំជម្រះ លើសំណុំរឿង ០០៤/១ ស្តីពីការវាយតម្លៃភ័ស្តុតាង គឺស្រប គ្នាជាមួយសេចក្តីសម្រេចមុនៗរបស់ខ្លួនក្នុងសំណុំរឿង ០០៤/២ និងយុត្តិសាស្ត្រដទៃទៀតរបស់ អ.វ.ត.ក។ វាជាតួនាទីរបស់ សហចៅក្រមស៊ើបអង្កេតដែលត្រូវវាយតម្លៃឲ្យបានពេញលេញលើខ្លឹម សារនៃភ័ស្តុតាង រួមទាំងភាពគួរឲ្យជឿជាក់បានផង នៅដំណាក់កាលចេញដីកាដំណោះស្រាយ។[110] អង្គបុរេជំនុំជម្រះ បានបញ្ជាក់ច្បាស់ថា ភាពគួរឲ្យជឿជាក់បានចាំបាច់សម្រាប់ការត្រួតពិនិត្យ (i) ភាពឲ្យជឿទុកចិត្ត[111] របស់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី[112] និង (ii) កាលៈទេសៈ

---

[110] នៅក្នុងដីកាដំណោះស្រាយ ស.ច.ស មានភារកិច្ចកំណត់ថាតើមានភ័ស្តុតាងស៊ីសង្វាក់ជាក់លាក់គ្រប់គ្រាន់បង្ហាញអំពីភវនីយភាពថា អោ អាន គឺជាបុគ្គលម្នាក់ក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត និងចំពោះពិរុទ្ធភាពរបស់ខ្លួនចំពោះបទល្មើសដែលត្រូវបានចោទប្រកាន់ដែរឬទេ។ នៅពេលធ្វើដូច្នេះបាន ពួកគេត្រូវវាយតម្លៃលើភាពអាចទុកចិត្តបាននៃភ័ស្តុតាង រួមទាំងកំណត់ហេតុនៃការស្តាប់ចម្លើយផងដែរ។ *សូមមើល* វិធាន៦៧(៣)។ សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក *សាលដីកា* ឯកសារ **F36** ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៣១៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣៦។ សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក-អ.ជ.ស.ជ *ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកនៅក្នុងឯកសារ E114, E114-1, E131/1/9, E131/6, E136 និង E158*, **ឯកសារ E162** ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣៧។ នេះការអនុវត្តដ៏ត្រឹមត្រូវបែបនេះនៅ អ.វ.ត.ក ហើយត្រូវបានអនុវត្តនៅក្នុងសំណុំរឿង ០០១ សំណុំរឿង ០០២ និងសំណុំរឿង ០០៤/០១។ សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ៥២-៥៩ (អ.ប.ជ យល់ឃើញថា វាជាកំហុសអង្គច្បាប់ 'ក្នុងការធ្វើការអះអាងទូទៅអំពីតម្លៃនៃប្រភេទភ័ស្តុតាងមួយចំនួន ហើយវាបង្កើតបានជាឋានានុក្រមនៃភ័ស្តុតាង ដោយផ្អែកលើលក្ខណៈនៃភ័ស្តុតាង ជាជាងផ្អែកទៅលើខ្លឹមសារនៃភ័ស្តុតាងនោះ'។ ផ្ទុយមកវិញ អ.ប.ជ ពេញចិត្តការវាយតម្លៃលើភាពអាចជឿជាក់បាន 'ទៅតាមករណីនីមួយ')។ សំណុំរឿង ០០៤/១-ឯកសារ **D308/3** កថាខណ្ឌ ២០៦, ២១៥។ សូមមើលផងដែរ សំណុំរឿង ០០២-ឯកសារ **F36** កថាខណ្ឌ ៣៧២។ សំណុំរឿង ០០១-ឯកសារ **E162** កថាខណ្ឌ ៣។ វាដោយសារការវាយតម្លៃរបស់ ស.ច.ស ថា ភ័ស្តុតាងដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយទទួលបាននូវការសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន។ សំណុំរឿង ០០២-ឯកសារ **F36** កថាខណ្ឌ ៣៧២។ សំណុំរឿង ០០១-ឯកសារ **E162** កថាខណ្ឌ ៣។

[111] ភាពជឿជាក់បានជាទូទៅសំដៅលើថាតើចម្លើយរបស់បុគ្គលម្នាក់អំពីអង្គហេតុជាក់ស្តែងពិតដែរឬទេ។ Sluiter *និងអ្នកផ្សេងទៀត នីតិវិធីព្រហ្មទណ្ឌអន្តរជាតិ* ('*Sluiter et al.*') (1st edn., Oxford: Oxford University Press, 2013) ទំព័រ ១០២៥ ដាក់ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣៨ ('ភាពជឿជាកបានត្រូវបានកំណត់និយមន័យថាជាការពិត ហើយអាចឆ្លើយតបទៅនឹងបញ្ហាថាតើសាក្សីកំពុងផ្តល់សក្ខីកម្មស្របតាមការជឿជាក់របស់ខ្លួន ឬ ផ្ទុយនឹងការជឿជាក់របស់ខ្លួន មានន័យថាតើសាក្សីកំពុងភូតកុហកដែរឬទេ')។ នៅពេលវាយតម្លៃភាពអាចជឿជាក់បាន អ.វ.ត.ក និងសាលាក្តីឧក្រិដ្ឋកម្មផ្សេងទៀត បានពិចារណាលើកត្តានានាដូចជា ភាពស៊ីសង្វាក់ផ្ទៃក្នុង និងចន្លោះប្រហោងនៃចម្លើយរបស់បុគ្គលលើបញ្ហាជាក់ស្តែងតែមួយដែរឬទេ អត្ថិភាព និងគុណភាពនៃភ័ស្តុតាងស៊ីសង្វាក់ ចេតនាដែលបុគ្គលអាចមានក្នុងការផ្តល់របស់បុគ្គលភ័ស្តុតាង ឬ ភាពលម្អៀង និងលទ្ធភាពខាងផ្នែករាងកាយ ឬ បុគ្គលិកលក្ខណៈផ្សេងទៀតរបស់បុគ្គលដែលអាចប៉ះពាល់ ភាពពិតប្រាកដ។ *សូមមើល* សំណុំរឿង ០០៤/១-ឯកសារ

នានាដែលទទួលបានភស្តុតាង។[113] ការពិនិត្យទាំងអស់នេះ គឺច្បាស់លាស់ណាស់នូវអ្វីដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានបំពេញ តែផ្ទុយទៅវិញ ជ្រើសរើសយកវិធីសាស្ត្រសម្រេចតាមទម្រង់ជាជាងខ្លឹមសារ រួមជាមួយនឹងឋានានុក្រមរបស់គាត់។ ដោយសារតែសារៈសំខាន់នៃ

---

**D308/3** កថាខណ្ឌ ២០៦, ២១៥។ សំណុំរឿង ០០២-ឯកសារ **F36** កថាខណ្ឌ ២៦៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-A, *សាលដីកា* (‘*សាលដីកា Popović*’) ចុះថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ១៣២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣៩។ រឿងក្តី *Nahimana និងអ្នកផ្សេងទៀត តទល់នឹង អយ្យការ* សំណុំរឿងលេខ ICTR-99-52-A, *សាលក្រម* ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៧ កថាខណ្ឌ ១៩៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤០។

[112] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ៥៥ (សំដៅលើព័ត៌មានដំបូងពីជនរងគ្រោះ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អ.ប.ជ បានសម្រេចថា ‘ភាពអាចជឿជាក់បានគួរត្រូវបានវាយតម្លៃទៅតាមករណីនីមួយៗនៅក្នុងដីកាដំណោះស្រាយ)។ សំណុំរឿង ០០៤/១-ឯកសារ **D308/3** កថាខណ្ឌ ២០៦, ២១៥ (ការពិភាក្សាការវាយតម្លៃរបស់ ស.ច.ស លើភាពអាចទទួលយកបាន រួមទាំងភាពអាចជឿជាក់បាននៃសាក្សីចំនួនពីរនាក់)។ Sluiter និងអ្នកផ្សេងទៀត ទំព័រ ១០២៥ (‘ភាពអាចទុកចិត្តបានគឺជាទស្សនាទានទូលំទូលាយមួយដែលរួមបញ្ចូលទស្សនទាននៃភាពអាចជឿជាក់បាន ព្រមទាំង បញ្ហាផ្សេងទៀត រួមទាំងភាពត្រឹមត្រូវ និងយថាភាពតាមការសង្កេត’)។ Klamberg, *ភស្តុតាងនៅក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មអន្តរជាតិ* (Leiden: Martinus Nijhoff publishers, 2013) ទំព័រ ១៧២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤១ (លើកឡើងអំពីភាពអាចជឿជាក់បាន និងភាពអាចទុកចិត្តបានគឺជាសមាសធាតុដែលមានអានុភាពលើតម្លៃ និងទម្ងន់នៃភស្តុតាង ប៉ុន្តែកត់សម្គាល់ឃើញថា យុត្តិសាស្ត្រនៃតុលាការ *មិនអចិន្ត្រៃយ៍* គឺមិនស៊ីសង្វាក់គ្នា ហើយជាធម្មតា ពាក្យទាំងនោះអាចត្រូវបានប្រើប្រាស់ប្តូរក្នុងន័យដូចគ្នា)។ សូមមើលផងដែរ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ongwen*, សំណុំរឿងលេខ ICC-02/04-01/15, *សំណៅសាធារណៈដែលមានការកោសលុប, សេចក្តីសម្រេចលើការតម្កល់បទចោទប្រឆាំងនឹង Dominic Ongwen* ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ១៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤២។

[113] [113] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ), *សាលដីកាលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពលើកំណត់ហេតុស្តាប់ចម្លើយនានាដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតបីរូប* ឯកសារ **D338/1/5** ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ២៣-២៥ (បញ្ជាក់ឡើងវិញថា ‘កាលៈទេសៈនៃការប្រមូលភស្តុតាង រួមទាំងភាពអាចជឿជាក់បាននៃកិច្ចស្តាប់ចម្លើយ ពាក់ព័ន្ធនឹងលក្ខណៈនៃសំណួរដែលបានសួរទៅកាន់សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវយកមកវាយតម្លៃពេញលេញនៅដំណាក់កាលចេញដីកាដំណោះស្រាយ’)។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ ២៨) *សេចក្តីពិចារណាលើសំណើរបស់ អ៊ឹម ចែម សុំឱ្យធ្វើមោឃភាពប្រតិចារឹក និងកំណត់ហេតុនៃការស្តាប់ចម្លើយ* ឯកសារ **D298/2/1/3** ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤, ៥៩ (គូសបញ្ជាក់ថា ‘កាលៈទេសៈទាំងឡាយ ដែលកើតមាននៅជុំវិញការស្តាប់ចម្លើយសាក្សី នឹងក្លាយជាធាតុផ្សំដែលត្រូវយកមកពិចារណានៅក្នុងដំណាក់កាលក្រោយក្នុងអំឡុងពេលធ្វើការវាយតម្លៃលើភស្តុតាងដោយ [ស.ច.ស] ដោយ [អ.ប.ជ] និងដោយអង្គជំនុំជម្រះសាលាដំបូង និងបានរំលឹកថា ‘កាលៈទេសៈជុះវិញការប្រមូលយកភស្តុតាង នឹងត្រូវចៅក្រមយកមកពិចារណា […] នៅដំណាក់កាលចេញដីកាដំណោះស្រាយ ដែលអាចរួមមាន [អ.ប.ជ] និង អង្គជំនុំជម្រះសាលាដំបូង ក្នុងករណីដែលមានដីកាបញ្ជូនរឿងទៅជំនុំជម្រះ’)។

ការស្វែងរកការពិតរបស់ អ.វ.ត.ក និងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានយកមកចោទប្រកាន់ ភ័ស្តុតាងគាំទ្រអង្គហេតុសម្ភារៈ ដែលបង្កើតមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ ត្រូវតែឲ្យជឿជាក់បានទាំងស្រុង។

### ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានវាយតម្លៃលើភាពអាចជឿទុកចិត្តបានរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីសំខាន់ៗដែលផ្តល់ភ័ស្តុតាងសំខាន់អំពីថាតើតុលាការមានយុត្តាធិការលើ អោ អាន ឬទេ?

62. ដោយមិនអើពើនឹងយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក ផ្សេងទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធមិនកែប្រែវិធីសាស្ត្ររបស់ខ្លួនចំពោះភ័ស្តុតាង[114] ហើយខកខានមិនបានពិនិត្យពេញលេញទៅលើខ្លឹមសារនិងភាពអាចជឿបាននៃកំណត់ហេតុស្តាប់ចម្លើយដែលមានអង្គហេតុជាក់ស្តែងពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មើលរំលងបញ្ហានៃភាពអាចជឿជាក់របស់សាក្សីនិងអ្នកតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដូចជា ប្រាក់ យុត, យូ វ៉ាន់, ពៅ សារ៉ុម, ពុត កុល, កែវ វឿន, ញ៉ែម ចេន, ជុំ វង្ស ហៅ ង៉ូវ, ពេញ វ៉ា និង ញឹម កុល ជាដើម លើបញ្ហាពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល។ អ្នកទាំងនេះខ្វះភាពគួរឲ្យជឿជាក់បាន ដោយមូលហេតុមួយចំនួន ដូចជាចេតនាក្នុងការបិទបាំងសកម្មភាពបទល្មើសរបស់ខ្លួន[115] អសង្គតិភាព(inconsistencies)ធ្ងន់ធ្ងរនៅក្នុងចម្លើយរបស់ខ្លួនដោយបង្ហាញពីភាពលម្អៀង និងកង្វះភ័ស្តុតាងស៊ើសង្វាក់។ មេធាវីការពារក្តីបានលើកនូវបញ្ហានៃភាពជឿជាក់ទាំងនេះនៅក្នុងចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ[116] ប៉ុន្តែដោយពុំបានផ្តល់នូវសំអាងហេតុណាមួយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនអើពើ។ មេធាវីការពារក្តីបាន បញ្ចូលទឡ្ហីករណ៍ទាំងនេះដោយការយោង និង សង្ខេបទឡ្ហីករណ៍ដូចខាងក្រោម៖

<u>ក) ប្រាក់ យុត</u>

---

[114] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១២៣-៣៥។

[115] Combs, 'វិភាគការតតាំងដោយសុពលភាពទៅនឹងការចោទប្រកាន់អំពើឃោរឃៅទ្រង់ទ្រាយធំ', 75.1.3 *Wash. and Lee L. Rev.* (2018), 223-300 ទំព័រ ២៥៩-២៦០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤៣។

[116] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ១២៧-១៨២។

63. នៅក្នុង*ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*របស់ខ្លួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកយ៉ាងច្រើន និងកន្លែងខ្លះ ផ្អែកស្ទើរតែទាំងស្រុង ទៅលើភ័ស្តុតាងបានពី ប្រាក់ យុត ចំពោះអង្គហេតុជាក់ស្តែងពាក់ព័ន្ធនឹងការសម្រេចចិត្តរបស់ខ្លួនលើយុត្តាធិការបុគ្គល ក្នុងនោះរួមទាំង តួនាទី និងសិទ្ធិអំណាច របស់ អោ អាន តាមការចោទប្រកាន់ បទបញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ (ជាអាទិ៍ ការសម្លាប់ប្រជាជនចាម) ការទទួលរបាយការណ៍ ការចាត់តាំងនិងការដកកម្មាភិបាល តួនាទីក្នុងការបោសសម្អាតអតីតកម្មាភិបាល និង ការចាត់ចែងធនធាននិងបុគ្គលិក[117]។ ប្រាក់ យុត មិនគួរឲ្យជឿជាក់បានទេទៅលើបញ្ហាទាំងនេះ ពីព្រោះចម្លើយរបស់គាត់មិនមានសង្គតិភាព (consistency)[118] និង មិនមានភ័ស្តុតាងសំអាង[119]។ គាត់មានហេតុផលជំរុញឲ្យឆ្លើយ

[117] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤១ ជើងទំព័រ ៥៨៩-៥៩០ កថាខណ្ឌ ២៤៤ ជើងទំព័រ ៥៩៤ កថាខណ្ឌ ២៤៥ ជើងទំព័រ ៥៩៦, ៥៩៨ កថាខណ្ឌ ២៤៦ ជើងទំព័រ ៥៩៩-៦០០ កថាខណ្ឌ ២៤៨ ជើងទំព័រ ៦០៥ កថាខណ្ឌ ២៥០ ជើងទំព័រ ៦១៣ កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣-៦៣៤, ៦៣៦ កថាខណ្ឌ ២៥៧ ជើងទំព័រ ៦៤០ កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥២ កថាខណ្ឌ ២៦៣ ជើងទំព័រ ៦៦០-៦៦២ កថាខណ្ឌ ២៦៥ ជើងទំព័រ ៦៦៣-៦៦៥ កថាខណ្ឌ ២៦៦ ជើងទំព័រ ៦៧៥, ៦៧៧ កថាខណ្ឌ ២៦៨ ជើងទំព័រ ៦៨២ កថាខណ្ឌ ២៧១ ជើងទំព័រ ៦៩៦ កថាខណ្ឌ ២៧៥ ជើងទំព័រ ៧១៨ កថាខណ្ឌ ២៧៦ ជើងទំព័រ ៧២០-៧២១ កថាខណ្ឌ ២៨២ ជើងទំព័រ ៧៣៧ កថាខណ្ឌ ២៩៣ ជើងទំព័រ ៧៦៥ កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៧ កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៣-៧៨៤ កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៤-៨០៩ កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១១, ៨១៤-៨១៥ កថាខណ្ឌ ៣០៤ ជើងទំព័រ ៨១៦ កថាខណ្ឌ ៣១៨ ជើងទំព័រ ៨៤១-៨៤៣ កថាខណ្ឌ ៣២៤ ជើងទំព័រ ៨៧៤ កថាខណ្ឌ ៣៣១ ជើងទំព័រ ៩១១ កថាខណ្ឌ ៣៦៤ ជើងទំព័រ ១០២៩-១០៣៣, ១០៣៧ កថាខណ្ឌ ៣៩៥ ជើងទំព័រ ១១៧០ កថាខណ្ឌ ៤២៣ ជើងទំព័រ ១២៧៨ កថាខណ្ឌ ៤២៩ ជើងទំព័រ ១៣២៦-១៣២៧, ១៣២៩ កថាខណ្ឌ ៤៤៤ ជើងទំព័រ ១៣៨៦ កថាខណ្ឌ ៦២០ ជើងទំព័រ ២០៩៥-២០៩៧ កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥២-២១៥៧ កថាខណ្ឌ ៦៣៤ ជើងទំព័រ ២១៦៣-២១៦៧ កថាខណ្ឌ ៦៣៥ ជើងទំព័រ ២១៧០-២១៧២។

[118] ប្រាក់ យុត លើកឡើងមិនស៊ីសង្វាក់គ្នានៅក្នុងចម្លើយរបស់គាត់ទាំង ១៩ ផ្តល់ជូន ក.ស.ច.ស អង្គជំនុំជម្រះសាលាដំបូង និងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ជាក់ស្តែង ឧទាហរណ៍ជាក់លាក់នៃភាពមិនស៊ីសង្វាក់គ្នារបស់ ប្រាក់ យុត មានច្រើនរាប់មិនអស់។ មេធាវីការពារក្តីបានបង្ហាញឧទាហរណ៍មួយចំនួនពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនៅក្នុង**ឧបសម្ព័ន្ធ ឃ**។

[119] ដូចបានពន្យល់នៅក្នុង*ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ* សាក្សីផ្សេងទៀត និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលផ្តល់ភ័ស្តុតាងនៅក្នុងសំណុំរឿង ០០៤ និងដែលធ្វើការនៅជិត ឬ ជាមួយ ប្រាក់ យុត នៅក្នុងឆ្នាំ១៩៧៧-ឆ្នាំ១៩៧៩ ពុំស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយរបស់គាត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន ដូចបានចោទប្រកាន់។ ម្យ៉ាងវិញទៀត ចម្លើយស៊ីសង្វាក់តែងតែមានការយកពន្យល់ខុសពីចម្លើយសាក្សី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ត្រឹមតែពាក្យចចាមអារ៉ាមពី ប្រាក់ យុត ការទាយស្មាន ឬ លទ្ធផលនៃព័ត៌មានដែលអ្នកស៊ើបអង្កេត ក.ស.ច.ស បានប្រាប់ទៅសាក្សី។ សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ១៥៤-១៥៦។

កុហក[120] ហើយ អ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេត (បន្ទាប់ពីនេះហៅកាត់ថា "អ្នកស៊ើបអង្កេត") បានផ្តល់នូវតម្រុយព័ត៌មានដាក់បន្ទុកនៅពេលស្តាប់ចម្លើយគាត់ដែលជាការបង្ហាញយ៉ាងជាក់ច្បាស់ថាខ្លួនមានបំណងចង់បង្កើតភស្តុតាងដាក់បន្ទុក[121] ។ សហចៅក្រម

[120] ដូចបានពន្យល់នៅក្នុង*ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ និងយោងនៅទីនេះ* ចាប់តាំងពីការចាប់ផ្តើមការស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០២ និង ០០៤ ប្រាក់ យុត មានចេតនាកុហក់ ជាពិសេស ទាក់ទងនឹងបញ្ហាអំពីតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន ដូចបានចោទប្រកាន់នៅតាមទីតាំងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ គាត់បានព្យាយាមការពារខ្លួនគាត់ និងបន្ថយតួនាទីរបស់គាត់ និងសមាជិកគ្រួសារគាត់។ មានពេលមួយនោះ នៅចន្លោះខែមិថុនា ឆ្នាំ២០១១ និងខែមករា ឆ្នាំ២០១២ ប្រាក់ យុត បានដឹងថា មានសំណុំរឿង ០០៤ ហើយគាត់អាចត្រូវបានចោទប្រកាន់។ នៅពេលទំនងដឹងថា ឧក្រិដ្ឋកម្មដែលចោទប្រកាន់លើរូបគាត់អាចត្រូវបានលាតត្រដាង ហើយគាត់អាចប្រឈមនឹងការចោទប្រកាន់ ប្រាក់ យុត ចាំបាច់ទម្លាក់កំហុសដាក់គេ។ អោ អាន គឺជាជម្រើសងាយស្រួល និងជាក់ស្តែងសម្រាប់គាត់ ដោយសារ អោ អាន ជាជនសង្ស័យរួចទៅហើយ។ អ្នកស៊ើបអង្កេត ក.ស.ច.ស បានបញ្ជាក់ជម្រើសរបស់គាត់ជ្រើសរើសយក អោ អាន ជាអ្នកទទួលរងជំនួស នៅក្នុងការស៊ើបអង្កេតលើសំណុំរឿង ០០៤ ទាំងមូល ដោយបានប្រាប់ទៅគាត់សុទ្ធតែព័ត៌មានដាក់បន្ទុក ផ្អែកលើព័ត៌មាននេះ គាត់បានយកមកធ្វើជាមូលដ្ឋានសម្រាប់ការភូតកុហកបន្ថែម។ នៅពេលសក្ខីកម្មរបស់ ប្រាក់ យុត ត្រូវបានពិនិត្យផ្អែកជាមួយពេលវេលាស៊ើបអង្កេត ចេតនារបស់គាត់កាន់តែលេចចេញច្បាស់។ មេធាវីការពារក្តីកត់សម្គាល់ឃើញថា ការភ័យខ្លាចរបស់ ប្រាក់ យុត រងការចោទប្រកាន់ ត្រូវបានបង្ហាញយ៉ាងជាក់លាក់តាំងពីដើមឆ្នាំ២០១២ នៅពេលអ្នកស៊ើបអង្កេត ក.ស.ច.ស បានចងក្រងជាឯកសារនូវការចូលរួមរបស់ ប្រាក់ យុត នៅក្នុងឧក្រិដ្ឋកម្មដែលបានចោទប្រកាន់ និងផ្តល់អនុសាសន៍ថា គាត់ ដូច អ៊ឹម ចែម ដែរ ត្រូវបានពិចារណាសម្រាប់ការចោទប្រកាន់ដូចគ្នា។ សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ១៤៥-១៥៣។

[121] ឧទាហរណ៍ ឯកសារ **D117/70** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ស.៣៧ ('សៈ ក្រៅពីការដកគណៈឃុំចាស់ៗទាំងនោះ តើតាអានមានបញ្ជាឲ្យអ្នកស្រីចាប់ខ្លួនមនុស្សនៅក្នុងស្រុករបស់អ្នកស្រីទេ?') ឆ៤៤-ឆ.៤៥ ('សៈ ក្រៅពីការចាប់ខ្លួនគណៈឃុំទាំងអស់នោះ តើអ្នកស្រីនៅចាំបានថា តាអាន បានបញ្ជាឲ្យចាប់ខ្លួនមនុស្សផ្សេងទៀតទេ? ឆ. ៤៤ៈ ចាស ខ្ញុំទទួលបញ្ជាពីតាអានឲ្យប្រមូលជនជាតិចាម និងអតីតទាហាន លន់ នល់។ បន្ទាប់មកខ្ញុំមិនដឹងថាមានអ្វីកើតឡើងចំពោះអ្នកទាំងនោះទេ។ សៈ តើការបញ្ជាឲ្យប្រមូលមនុស្សទាំងនោះ តាមរយៈសំបុត្រ ឬក៏លើកឡើងនៅក្នុងពេលប្រជុំជាមួយតាអាន? ឆ.៤៥ ៈ តាអានបញ្ជាក្នុងពេលប្រជុំប្រចាំខែ។ នៅក្នុងកិច្ចប្រជុំនោះតាអាន បានចេញបញ្ជាដូចគ្នាទៅកាន់គណៈស្រុកផ្សេងៗទៀត')។ ឯកសារ **D219/484** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត), ឆ.៤ ('សៈ តើលោកស្រីចាំអំពីចំនួនគ្រួសារចាមដែលរស់នៅក្នុងភូមិផ្សេងៗគ្នាទាំងអស់នោះដែរឬទេ? ឆ.៤ៈ ទេ ខ្ញុំមិនចាំទេ.'), ឆ.៥-ឆ.៦ ('សៈ តើលោកស្រីចង់ឲ្យខ្ញុំជួយឲ្យលោកស្រីចងចាំអំពីរឿងនេះដែរឬទេ? ឆ.៥ៈ ចាស។ កត់សម្គាល់អ្នកស៊ើបអង្កេតចំពោះ ប្រាក់ យុតៈ យោងតាមព័ត៌មានដែលយើងដឹងគឺៈ ច្រកស្តៅ ២០ គ្រួសារ វាលគ្រៀល ៣០ គ្រួសារ ទ្រាន ៣០ គ្រួសារ ភូមិត្រពាំងតាសុខ ៣០ គ្រួសារ ច្រនៀង ៣០ គ្រួសារ ប្រថង ១៥ គ្រួសារ ប៉ែន ៣០ គ្រួសារ ទួលចំបក់ ១៥ គ្រួសារ ត្រពាំងអំពិល ២០-៣០គ្រួសារ តាខុង ២០ គ្រួសារ ទួលត្រាច ១០ គ្រួសារ ពោន ២២-២៣ គ្រួសារ ប្រសិនបើយើងគិតថាជាមធ្យមគ្រួសារមួយមានសមាជិកចំនួន ៦ នាក់ ដូច្នេះ ចំនួនជនជាតិ

ស៊ើបអង្កេតអន្តរជាតិទទួលស្គាល់ត្រួសៗនូវបញ្ហានៃភាពគួរឱ្យជឿជាក់ទាំងនេះ[122] ប៉ុន្តែទោះជាយ៉ាងណាគឺនៅតែពឹងផ្អែកលើភ័ស្តុតាងទទួលបានពីសាក្សីនេះ។ នៅក្នុង **ឧបសម្ព័ន្ធ គ** មេធាវីការពារក្តីធ្វើការបង្ហាញបីចំណុចដែល ប្រាក់ យុត ចាប់ផ្តើមប្តូរដំណើររឿងរបស់ខ្លួនដើម្បីបន្ទោស អោ អាន ហើយបង្ហាញថាដំណើររឿងរបស់គាត់ ប្រែប្រួលពីមួយពេលទៅមួយពេល ដោយសារឥទ្ធិពលរបស់អ្នកស៊ើបអង្កេត និង ចេតនារបស់ ប្រាក់ យុត ចង់បិទបាំងការភូតកុហករបស់ខ្លួន។ នៅក្នុង**ឧបសម្ព័ន្ធ ឃ** មេធាវីការពារក្តី ចងក្រងបញ្ជីមួយរៀបរាប់ចម្លើយអសង្គតិភាពរបស់ ប្រាក់ យុត លើបញ្ហាសំខាន់ៗពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល។

64. ប្រាក់ យុត សារភាពខ្លួនឯងថា ខ្លួនគឺជាលេខាស្រុកខ្មែរក្រហមដាច់ខាតម្នាក់[123] មានទំនាក់ទំនង

---

ចាមសរុបដែលរស់នៅក្នុងឃុំទ្រាន គឺប្រមាណ ១៦០០ នាក់។ ស៖ តើលោកស្រីគិតថា ចំនួននេះសមស្របដែរឬទេ? ឆ.៦៖ ចាស សមស្រប។'), ឆ.៨ ('ស៖តើលោកស្រីដឹងដែរឬទេថាប្រជាជនចាមទាំងនោះត្រូវបានគេចាប់ខ្លួន និងយកទៅសម្លាប់? ឆ.៨៖ ចាស ខ្ញុំសូមគូសបញ្ជាក់ថា ខ្ញុំបានទទួលបញ្ជាពីថ្នាក់តំបន់ ដើម្បីចាប់ខ្លួន និងសម្លាប់ជនជាតិចាមទាំងអស់។ បញ្ជាដែលខ្ញុំបានទទួលមានភាពច្បាស់លាស់អំពីការសម្លាប់ជនជាតិចាមទាំងនោះ។ បន្ទាប់មក ខ្ញុំបានបញ្ជូនបញ្ជានេះបន្តទៅថ្នាក់ឃុំ និងអនុរបស់ខ្ញុំនៅថ្នាក់ស្រុក។ ខ្ញុំមិនដឹងថា ជនជាតិចាមទាំងអស់នោះត្រូវបានគេសម្លាប់ដោយរបៀបណា ឬ នៅកន្លែងណាឡើយ។ នៅពេលដែលការសម្លាប់ជនជាតិចាមទាំងនោះត្រូវបានធ្វើរួចរាល់ ខ្ញុំបានទទួលរបាយការណ៍មួយពីអនុរបស់ខ្ញុំ ឬ មេឈ្លបអំពីចំនួនជនជាតិចាមដែលគេបានសម្លាប់ ហើយខ្ញុំក៏បានបញ្ជូនរបាយការណ៍នោះទៅឱ្យតាអាន ដែលស្ថិតនៅថ្នាក់តំបន់។')

[122] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២២៩, ៣៦៨, ៤៥៤។

[123] ឯកសារ **D6.1.721** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.៣៤ ('ខ្ញុំជាអ្នកបដិវត្តន៍ថ្នាក់ខ្ពស់ម្នាក់ដែរ ព្រោះខ្ញុំបានលះបង់គ្រប់បែបយ៉ាងដើម្បីបដិវត្តន៍។ ខ្ញុំគ្មានកម្មសិទ្ធិសួនតួ ហើយសូម្បីតែប្តីខ្ញុំ ក៏ខ្ញុំលះបង់ដើម្បីបដិវត្តន៍ដែរ។ កាលដែលគេចាប់ខ្លួនគាត់ ខ្ញុំមិនស្រក់ទឹកភ្នែកមួយតំណក់ផង។ […] នៅពេលនោះ គណៈតំបន់ កង ចាប ហៅខ្ញុំទៅប្រាប់ថា ប្តីខ្ញុំនឹងត្រូវចាប់ខ្លួន។ […] មិនមែនត្រឹមតែគណៈតំបន់ទេដែលហៅខ្ញុំទៅប្រាប់ សូម្បីតែតាម៉ុកដែលជាគណៈភូមិភាគក៏ហៅខ្ញុំទៅប្រាប់ដែរ ថាប្តីខ្ញុំនឹងត្រូវគេចាប់ខ្លួន [*sic*]')។ ឯកសារ **D219/234.1.2** (កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី ប្រាក់ យុត), KH 00963100-01 ទំព័រ ១៣-១៤ (ប្រាក់ យុត ចូលបដិវត្តន៍តាំងពីក្មេង), KH 00963147-47 ទំព័រ ៦០-៦១ ('កម្មាភិបាលរបស់បក្សច្រើនណាស់ តែមិនដឹងថាគេយល់ថាម៉េច អីចឹងបានខ្ញុំ មានជីវិតរស់នៅដល់ថ្ងៃនេះ គេសរសើរខ្ញុំ ប្តីចាប់ហើយរស់ខ្លួនឯង [...] ហ្នឹងមកពី យើងហៅថា ទស្សនៈរបស់យើង យើងវិភាគទៅថាមានមនោសញ្ចេតនាទៅលើបក្សដែរ បើអត់ក៏យើងត្រូវបាត់ខ្លួនដែរ [...] ម្យ៉ាងចេះខ្ញុំគិតថា បើខាងលើទាំងអស់នេះខ្ញុំមិនអួតទេ អ្នកណាក៏ស្គាល់ខ្ញុំដែរ រាល់ថ្ងៃក៏ដោយណាក៏ស្គាល់ខ្ញុំដែរ ឈ្មោះខ្ញុំ ប្រាក់ យុត ម្នាក់នេះក៏ស្គាល់ទាំងអស់តែម្តង អីចឹងគេយល់ថា យើងអ្នកនយោបាយជាន់ខ្ពស់។')។ ឯកសារ **D219/422.5** (ប្រតិចារឹកបទសម្ភាសន៍ ញឹម កុល WRI D107/7), KH 01121169 ទំព័រ ១៥ ('[ប្រាក់ យុត] ចូលចិត្តការសរសើរជាជាងការបង្គាប់។ ហើយបើយើងបច្ចុប្បន្នយើងហៅថា "ស៊ីខ្សែជោរ" អីចឹង អ្ហបង! ចរិតរបស់គាត់អីចឹង។ [...] បាទ អត់ចេះអក្សរទេ តែដាច់ខតម៉ឺងម៉ាត់តែម្តង។ បើថាទៅគឺទៅអត់មានថាឃាត់កុំទៅអ អត់មានថាឃាត់កុំទៅអី បងខ្យល់អី ទូកឆ្លងទូក ថា "អ្ហែកុំទៅបងខ្យល់"

ជិតស្និទ្ធជាមួយ តា ម៉ុក[124]។ គាត់ចូលរួមយ៉ាងសកម្មនៅក្នុងបទល្មើសដែលបានចោទប្រកាន់នៅភូមិភាគកណ្តាល[125] ហើយគាត់លះបង់ខ្លួនសជាមួយបដិវត្តរហូតដល់ដែលអ្នកធ្វើការជិតដិតជាមួយ

---

ទៅគឺទៅហើយ')។ ឯកសារ **D219/322** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ចាន់ សុខជា), ឆ.៥ (ចាន់ សុខជា លើកឡើងថា គាត់ស្គាល់ ប្រាក់ យុត មានសិទ្ធិអំណាច ហើយមនុស្សគ្រប់គ្នាខ្លាចគាត់)។

[124] **ប្រាក់ យុត គឺជាលេខាស្រុក៖** ឯកសារ **D117/70** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.២៣, ឆ.២៥-ឆ. ២៨។ ឯកសារ **D6.1.730** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត), KH 00357510 ទំព័រ ៥ ។ ឯកសារ **D179/1.2.5** (ប្រតិចារឹក ប្រាក់ យុត ក្នុងសំណុំរឿង ០០២) KH 00773569 ទំព័រ ៥១។ ឯកសារ **D219/234.1.2** (កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយសាក្សី ប្រាក់ យុត), KH 00963151 ទំព័រ ៦៤។ ឯកសារ **D107/5** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង) ឆ.២២។ ឯកសារ **D117/28** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ វឿន) ឆ.១១។ ឯកសារ **D117/31** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.១៥។ ឯកសារ **D219/800** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សូ សារ៉េន), ឆ.៣៩, ឆ.៤១ **ប្រាក់ យុត ស្និទ្ធនឹង តាម៉ុក៖** ឯកសារ **D219/971** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.៥ (ប្រាក់ យុត ទទួលស្គាល់ថា គាត់ស្និទ្ធជាមួយនឹង តាម៉ុក)។

125

[125] ការចោទប្រកាន់អំពីការពាក់ព័ន្ធរបស់ ប្រាក់ យុត នៅក្នុងឧក្រិដ្ឋកម្ម៖ ឯកសារ **D179/1.2.6** (ប្រតិចារឹករបស់ ប្រាក់ យុត ក្នុងសំណុំរឿង ០០២), KH 00773657 ទំព័រ ៤៧ ('ខ្ញុំមិនមានការសម្រេចមកពីខាងណាទេ ព្រោះខ្ញុំអប់រំខ្លួនឯង ការខុសត្រូវគឺខ្ញុំអប់រំនៅកន្លែងហ្នឹង។ ស. គឺលោកស្រីជាអ្នកសម្រេចផ្ទាល់តែម្តង គឺថាលោកស្រីមិនបានទទួលបញ្ជាពីខាងណាទេមែនទេ? ឆ. ខ្ញុំសម្រេច តែការអប់រំហ្នឹង បើមិនស្តាប់ ខ្ញុំក៏បញ្ជូនឲ្យខាងតំបន់អីជួយអប់រំ មិនយកទៅណាទេ។ បើអប់រំមិនបាន។ នេះ ខ្ញុំសូមជម្រាប')។ ឯកសារ **D107/3** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កក់ ស្រឿន), KH 00784973 ទំព័រ ៤ ('ស. តើយាយយុតមានតួនាទីយ៉ាងណាដែរចំពោះការសំលាប់ និងចាប់មនុស្សពីឆ្នាំ១៩៧៧ ដល់ ១៩៧៩? ឆ. យាយយុតជាប្រធានស្រុកកំពង់សៀម ប៉ុន្តែគាត់បានប្រគល់ការសំលាប់នៅទីនេះទៅតាជាំ ដែល ជាអនុរប់គាត់)។ ឯកសារ **D117/42** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម នារី), ឆ.១៤ ('ពិតណាស់ [ទួលបេង] ស្ថិតនៅក្រោមការគ្រប់គ្រងរបស់គាត់ ដែលជាគណៈស្រុកកំពង់សៀម។ ឯកសារ **D117/53** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន់ ជាន), ឆ.២២ ('ស. តើលោកធ្លាប់ឃើញ តាជា ហើយនឹង ប្រាក់ យុត នៅជាមួយគ្នាដែរឬទេ នៅពេលដែលមានការចាប់ខ្លួនមនុស្ស? ឆ.២២ បាទ ភាគច្រើន ប្រាក់ យុត គាត់ធ្វើការនៅមន្ទីរស្រុករបស់គាត់ ប៉ុន្តែគាត់ក៏បានចុះមកធ្វើការនៅមន្ទីរឃុំរបស់តាជា នៅឃុំវិហារធំនេះដែរ។')។ ឯកសារ **D107/19** (កំណត់ហេតុនៃកិច្ចស៊ើបសួរ), KH 01347823-24 ទំព័រ ២-៣ (អ្នកស៊ើបអង្កេត ក.ស.ច.ស រាយការណ៍ថា ប្រាក់ យុត ប្រធានស្រុកកំពង់សៀម បានបញ្ជាឲ្យចាប់ខ្លួន ដែលធ្វើឡើងដោយថ្នាក់ក្រោមរបស់គាត់។ "ប្រាក់ យុត ត្រូវបានពិពណ៌នាថាជាមនុស្សសាហាវ ដែលក្រៅពីការកម្ទេចកម្មាភិបាល ក្នុងស្រុករបស់ខ្លួន គាត់គំនងជាបានឲ្យគេចាប់ និងសម្លាប់មនុស្សជាច្រើនផ្សេងទៀតដោយសារមូលហេតុផ្ទាល់ខ្លួន [...] ដូចគ្នានឹង អ៊ឹម ចែម ដែរ ប្រាក់ យុត គឺជាសមាសភាគសំខាន់មួយ ក្នុងប្រព័ន្ធគ្រប់គ្រង និងអនុម័តការបោសសម្អាត នៅតាមភូមិភាគ"។ អ្នកស៊ើបអង្កេត ក.ស.ច.ស ផ្តល់អនុសាសន៍ថា ក.ស.ព គួរពិចារណាបញ្ចូល ប្រាក់ យុត នៅក្នុងបញ្ជីឈ្មោះជនសង្ស័យ)។

គាត់ជឿថា គាត់បានសម្លាប់ប្ដីខ្លួនឯង នៅពេលប្ដីរបស់គាត់អស់ជំនឿលើរបប[126]។ ដោយហេតុថា ប្រាក់ យុត ផ្ដល់នូវអង្គហេតុជាក់ស្ដែងពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល និង ដោយហេតុថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកលើគាត់ជារឿយៗដោយគ្មានសម្អាងនោះ ភាពជឿជាក់ទៅលើគាត់ត្រូវតែវាយតម្លៃដោយប្រុងប្រយ័ត្ន។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដែលមិនបានវាយតម្លៃដោយប្រុងប្រយ័ត្ន និងបន្តផ្អែកលើ ប្រាក់ យុត ក្នុងការវាយតម្លៃលើយុត្តាធិការបុគ្គលរបស់ខ្លួន។

<u>ខ) យូ វ៉ាន់</u>

65. ដោយមិនបានស្ដាប់ចម្លើយពេញលេញនិងដោយសត្យានុម័ត អំពីភាពអាចជឿជាក់បានរបស់ ប្រាក់ យុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បែរជាផ្អែកទៅលើ ប្រាក់ យុត ក្នុងការកសាងសំណុំរឿងប្រឆាំងនឹង អោ អាន។ ឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកយ៉ាងច្រើនលើ យូ វ៉ាន់ ដែលជាអតីត និរសាររបស់ ប្រាក់ យុត និង សមាជិកឃុំរអាង ស្រុកកំពង់សៀម[127] ចំពោះអង្គហេតុជាក់ស្ដែងពាក់ព័ន្ធនឹងការសម្រេចចិត្តរបស់គាត់លើយុត្តាធិការបុគ្គល។ អង្គហេតុទាំងនេះពាក់ព័ន្ធនឹងតួនាទី និងសិទ្ធិអំណាចរបស់ អោ អាន តាមការចោទប្រកាន់ការគ្រប់គ្រងយោធាតំបន់វត្តមាននៅពេលប្រជុំ បទបញ្ជាចាប់និងសម្លាប់ និង របាយការណ៍(ក្នុងនោះរួម មានប្រជាជនចាមផងដែរ) ការចាត់តាំង និង ការដកកម្មាភិបាល ការចាត់ចែងធនធាន និង បុគ្គលិក និងសិទ្ធិអំណាចពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍[128]។

---

[126] ឯកសារ **D219/422.5** (ប្រតិចារឹក ញឹម កុល កំណត់ហេតុនៃការស្ដាប់ចម្លើយ D107/7) KH 0112166-68 ទំព័រ ១២, 14 ('បាទ សូម្បីប្អូនៗគាត់ ដូច រ៉ុម ហ្នឹង ជីដូនមួយបង្កើតក៏គាត់និយាយដែរ "ចិត្តដាច់ណាស់បងបាញ់ប្ដីគាត់ចោល"។ គាត់និយាយគ្នីគ្នាគេអីចឹង។ បានខ្ញុំដឹងថា អូ! យាយយុត បាញ់ប្ដីខ្លួនឯង។ ដឹងតែប៉ុណ្ណឹងឯង អត់មានដែលឃើញប្ដី យាយយុត ហ្នឹងមុខម៉េចផងហ្នឹង [...] ខ្ញុំឮសួរអ្នកទាំងនោះនិយាយថា យាយយុត ចិត្តដាច់ណាស់ ហ៊ានបាញ់សម្លាប់ប្ដីខ្លួនឯង')។ ឯកសារ **D107/19** (កំណត់ហេតុនៃការស៊ើបអង្កេត), KH 01347823 ទំព័រ ២ (អ្នកស៊ើបអង្កេត ក.ស.ច.ស រាយការណ៍ថា មានពាក្យចចាមអ៉ាមជាច្រើនថា ប្រាក់ យុត បានកំទេចប្ដីរបស់គាត់ពីព្រោះគាត់ចង់ចាកចេញពីបដិវត្តន៍)។

[127] ឯកសារ **D117/31** (កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី យូ វ៉ាន់), ឆ.១៥, ឆ.២៩។

[128] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៤ ជើងទំព័រ ៥៩៤ កថាខណ្ឌ ២៤៥ ជើងទំព័រ ៥៩៦, ៥៩៨ កថាខណ្ឌ ២៤៦ ជើងទំព័រ ៥៩៩ កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣, ៦៣៦, ៦៣៨ កថាខណ្ឌ ២៥៧ ជើងទំព័រ ៦៤០ កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥៣ កថាខណ្ឌ ២៦៣ ជើងទំព័រ ៦៦០-៦២ កថាខណ្ឌ ២៦៥ ជើងទំព័រ ៦៦៣-៦៥ កថាខណ្ឌ ២៦៦ ជើងទំព័រ

66. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏ប្រើប្រាស់ចម្លើយរបស់ យូ វ៉ាន់ ក្នុងការប៉ុនប៉ងធ្វើឱ្យស៊ីសង្វាក់ជាមួយចម្លើយ ប្រាក់ យុត ផងដែរ[129]។ ប៉ុន្តែ យូ វ៉ាន់ មិនអាចធ្វើឱ្យចម្លើយខ្លួនស៊ីសង្វាក់ជាមួយចម្លើយ ប្រាក់ យុត បានដោយសារគាត់ខ្វះភាពអាចជឿជាក់បាន ហើយត្រូវបានទទួលនូវព័ត៌មានដាក់បន្ទុកពីសំណាក់អ្នកស៊ើបអង្កេតក្នុងគោលបំណងបង្កើតភ័ស្តុតាងដាក់បន្ទុក[130]។ គាត់

---

៦៧៤-៦៧៥ កថាខណ្ឌ ២៦៨ ជើងទំព័រ ៦៨៧ កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៨២ កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៣-៧៨៤ កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៥-៨០៨ កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១១, ៨១៤-៨១៥ កថាខណ្ឌ ៣០៤ ជើងទំព័រ ៨១៦ កថាខណ្ឌ ៣១១ ជើងទំព័រ ៨៣១ កថាខណ្ឌ ៣១៦ ជើងទំព័រ ៨៣៩ កថាខណ្ឌ ៣១៨ ជើងទំព័រ ៨៤១ ៨៤៥ កថាខណ្ឌ ៣៥៣ ជើងទំព័រ ១០០១ កថាខណ្ឌ ៣៥៤ ជើងទំព័រ ១០០៤ កថាខណ្ឌ ៤២៣ ជើងទំព័រ ១២៧៩-១២៨០ កថាខណ្ឌ ៤២៧ ជើងទំព័រ ១៣២៣ កថាខណ្ឌ ៤២៩ ជើងទំព័រ ១៣២៧ ១៣២៩ កថាខណ្ឌ ៤៣១ ជើងទំព័រ ១៣៣៧ កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥២ ២១៥៧ ២១៦១ កថាខណ្ឌ ៦៣៤ ជើងទំព័រ ២១៦៣ កថាខណ្ឌ ៦៣៦ ជើងទំព័រ ២១៧៣ កថាខណ្ឌ ៦៣៦ ជើងទំព័រ ២១៧៥ កថាខណ្ឌ ៦៨៥ ជើងទំព័រ ២៣៥៥, ២៣៥៧-២៣៥៨។

[129] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៦៨ ជើងទំព័រ ៣៥៤ កថាខណ្ឌ ១៧៣ ជើងទំព័រ ៣៦៦ កថាខណ្ឌ ១៧៨ ជើងទំព័រ ៣៧៣ កថាខណ្ឌ ២១០ ជើងទំព័រ ៤៧៩ កថាខណ្ឌ ២១៣ ជើងទំព័រ ៤៨៨ កថាខណ្ឌ ២២៩ ជើងទំព័រ ៥៤០-៥៤១ កថាខណ្ឌ ២៣៥ ជើងទំព័រ ៥៦២ កថាខណ្ឌ ២៤២ ជើងទំព័រ ៥៩១ កថាខណ្ឌ ២៤៣ ជើងទំព័រ ៥៩៣ កថាខណ្ឌ ២៤៤ ជើងទំព័រ ៥៩៤។ កថាខណ្ឌ ២៤៥ ជើងទំព័រ ៥៩៦ កថាខណ្ឌ ២៤៥ ជើងទំព័រ ៥៩៨ កថាខណ្ឌ ២៤៦ ជើងទំព័រ ៥៩៩ កថាខណ្ឌ ២៥១ ជើងទំព័រ ៦១៥ កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣ កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៦ កថាខណ្ឌ ២៥៧ ជើងទំព័រ ៦៤០ កថាខណ្ឌ ២៦៣ ជើងទំព័រ ៦៦០-៦៦២ កថាខណ្ឌ ២៦៥ ជើងទំព័រ ៦៦៣-៦៦៥ កថាខណ្ឌ ២៦៦ ជើងទំព័រ ៦៧៤ កថាខណ្ឌ ២៦៦ ជើងទំព័រ ៦៧៥ កថាខណ្ឌ ២៧២ ជើងទំព័រ ៧០៤ កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៣-៧៨៤ កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៥-៨១០ កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១១-៨១៥ កថាខណ្ឌ ៣១៨ ជើងទំព័រ ៨៤១ កថាខណ្ឌ ៣៧៥ ជើងទំព័រ ១០៨៤ កថាខណ្ឌ ៤២៣ ជើងទំព័រ ១២៨៤ កថាខណ្ឌ ២៤២ ជើងទំព័រ ១២៩៣ កថាខណ្ឌ ៤២៩ ជើងទំព័រ ១៣២៧-១៣២៩ កថាខណ្ឌ ៤៣៥ ជើងទំព័រ ១៣៤៧ កថាខណ្ឌ ៤៤២ ជើងទំព័រ ១៣៧៨-១៣៧៩ កថាខណ្ឌ ៤៤៣ ជើងទំព័រ ១៣៨០ កថាខណ្ឌ ៥៣៧ ជើងទំព័រ ១៧៩៤ កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥២, ២១៥៥-២១៥៧ កថាខណ្ឌ ៦៣៥ ជើងទំព័រ ២១៦៩-២១៧០ កថាខណ្ឌ ៦៨៥ ជើងទំព័រ ២៣៥៥។

[130] ឧទាហរណ៍ ឯកសារ **D117/31** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់), ឆ.២៦-ឆ.២៨ (អ្នកស៊ើបអង្កេត ក.ស.ច .ស បង្ហាញយោបល់ដល់ យូ វ៉ាន់ អំពីសិទ្ធិអំណាចរបស់ អោ អាន ជាពិសេស វត្តមានរបស់គាត់នៅក្នុងកិច្ចប្រជុំ និងការធ្វើដំណើរជាមួយអ្នកផ្សេងទៀតទៅចូលរួមប្រជុំ។ ម្យ៉ាងវិញទៀត អ្នកស៊ើបអង្កេតបង្ហាញប្រាប់គាត់ថា ប្រាក់ យុត បានចូលរួមប្រជុំនៅស្រុកព្រៃឈរ ដែលជាទីតាំងចោទប្រកាន់ថាជាមន្ទីររបស់ អោ អាន)។ ឯកសារ **D219/138** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់), ឆ.៤៥ (អ្នកស៊ើបអង្កេត ក.ស.ច.ស បង្កើបប្រាប់ យូ វ៉ាន់ ថា ប្រាក់ យុត ត្រូវសុំការអនុញ្ញាតពី អោ អាន ប្តូរប្រធានឃុំ។ បន្ទាប់មក យូ វ៉ាន់ ទាយថា អ្នកស៊ើបអង្កេតប្រាកដជាលើកឡើងត្រឹមត្រូវ) ឆ.១០៦ (អ្នកស៊ើបអង្កេត ក.ស.ច.ស បង្កើបប្រាប់ យូ វ៉ាន់ ថា មានគេរាយការណ៍អំពីការកាប់សម្លាប់ទៅ អោ អាន)។

ឆ្លើយមិនស៊ីសង្វាក់គ្នាទៅលើបញ្ហាសំខាន់ៗ[131] ហើយជារឿយៗ ត្រឹមតែផ្តល់ព័ត៌មានច្រំដែលៗ ដែល ប្រាក់ យុត បានប្រាប់គាត់[132]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុស ដែលមិនបានពិនិត្យពេញលេញទៅលើខ្លឹមសារនិងភាពអាចជឿជាក់បានទៅលើភស្តុតាងរបស់ យូ វ៉ាន់ និង ខកខានមិនបានពន្យល់អំពីការណ៍ដែលគាត់ផ្អែកលើចម្លើយគាត់ ជាពិសេសដោយហេតុថា

---

[131] *ប្រៀបធៀប* ឯកសារ **D219/702.1.87** (ប្រតិចារឹកសវនាការរបស់ យូ វ៉ាន់ ក្នុងសំណុំរឿង ០០២), KH 01451945 ទំព័រ ៤៣ (ដំបូង យូ វ៉ាន់ លើកឡើងថា គាត់មិនបានបញ្ជូនសារពីរ ប្រាក់ យុត ឲ្យទៅ អោ អាន ដោយសារគាត់នៅឆ្ងាយពីកន្លែង ប្រាក់ យុត នៅ ហើយគាត់ស្មានថា គាត់បានទាក់ទងក្នុងចំណោមពួកគាត់) KH 01451946 ទំព័រ ៤៤ (ក្រោយព្យាយាមរកនឹក ឡើងវិញរួច យូ វ៉ាន់ បានផ្លាស់ប្តូរសក្ខីកម្មរបស់គាត់ ហើយអះអាងថា គាត់បានផ្ញើសំបុត្រទៅ អោ អាន ឆ្លើយតប)។ *ប្រៀបធៀប* ឯកសារ **D219/138** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៨០ (ពាក់ព័ន្ធនឹងការណែនាំអំពីអាពាហ៍ពិពាហ៍ ដូចបានចោទប្រកាន់ ដំបូង យូ វ៉ាន់ បានប្រាប់គាត់ថា អោ អាន គឺជាអ្នក "ប្រកាសបទបញ្ជាថា អ្នកដែលរៀបការត្រូវតែដេក ជាមួយគ្នា") *ជាមួយនឹង* ឯកសារ **D219/702.1.87** (ប្រតិចារឹក យូ វ៉ាន់ ក្នុងសំណុំរឿង ០០២), KH 01451962-63 ទំព័រ ៦០-៦១ (យូ វ៉ាន់ លើកឡើងថា ប្រាក់ យុត គឺជាអ្នកប្រកាសបទបញ្ជារៀបអាពាហ៍ពិពាហ៍) *ជាមួយ* KH 0145163 ទំព័រ ៨០ (ក្រោយពេលអានចម្លើយរបស់គាត់នាពេលមុនឲ្យគាត់ស្តាប់ យូ វ៉ាន់ ផ្លាស់ប្តូរចម្លើយ ហើយបន្ថែមថា អោ អាន ជាអ្នកចេញការ ណែនាំ) *និងជាមួយ* ឯកសារ **D219/702.1.94** (ប្រតិចារឹក យូ វ៉ាន់ ក្នុងសំណុំរឿង ០០២), KH 01253374-76 ទំព័រ ២៧-២៩ (ប៉ុន្មានថ្ងៃក្រោយមក យូ វ៉ាន់ ឆ្លើយផ្ទុយខ្លួនឯងម្តងហើយម្តងទៀត ហើយបញ្ជាក់ថា ប្រាក់ យុត បានប្រកាសបទបញ្ជាស្តីពី អាពាហ៍ពិពាហ៍)។

[132] ឧទាហរណ៍ ឯកសារ **D219/138** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៦៦ ('សៈ តើអនុប្រធានរបស់ តាអាន មានឈ្មោះអ្វី? ឆ.៦៦ ខ្ញុំឮតាម ប្រាក់ យុត ថាអនុរបស់ តាអាន គឺប្រពន្ធរបស់ តា អាន តែម្តង។') ឆ.៨០ ('ស. តើនរណាចេញ ច្បាប់ថា ប្តីប្រពន្ធដែលរៀបការហើយត្រូវតែរួមដំណេកក្នុងនាមជាប្តីប្រពន្ធ? ឆ.៨០៖ ប្រាក់ យុត ប្រាប់ខ្ញុំថាគឺតាអាន មេតំបន់ជា អ្នកចេញច្បាប់ថា អ្នកដែលរៀបការហើយត្រូវតែរួមដំណេកជាមួយគ្នា។ គាត់ថា ចាំបាច់ត្រូវធ្វើដូច្នេះដើម្បីចម្រើនជាតិ។ ខ្ញុំក៏មិន យល់ពាក្យនេះដែរ')។ ឯកសារ **D219/702.1.87** (ប្រតិចារឹក យូ វ៉ាន់ ក្នុងសំណុំរឿង ០០២), KH 01451942 ទំព័រ ៤០ ('ស. តើលោកស្រីប្រាប់ខ្ញុំថា តើលោកស្រីដឹងដោយរបៀបណាថា យោធាស្រុកហ្នឹងចូលរួមក្នុងការចាប់ខ្លួន? ឆ. ព្រោះខ្ញុំរត់សំបុត្រនី រសារ ព្រោះ ប្រាក់ យុត ហ្នឹងគាត់និយាយប្រាប់ ថ្ងៃនេះគេចាប់អ្នកនេះ ថ្ងៃនោះគេចាប់នោះ។), KH 01451947 ទំព័រ ៤៥ ('គាត់ [ប្រាក់ យុត] មក ប៉ុន្តែគាត់ជិះឡានជាមួយតាអាន។ គាត់ប្រាប់ថា គាត់មកប្រជុំ ប៉ុន្តែមិនដឹងប្រជុំឯណាខ្ញុំអត់បានដឹងទេ')។ ម្យ៉ាងវិញទៀត ពេលវេលានៃចម្លើយរបស់ ប្រាក់ យុត ប្រាប់ យូ វ៉ាន់ មិនច្បាស់លាស់ ពីព្រោះអ្នកស៊ើបអង្កេត ក.ស.ច.ស ខក ខានមិនបានបញ្ជាក់គាត់ទទួលបានព័ត៌មានដោយរបៀបណា ឬ នៅពេលណានោះឡើយ។ ដូច្នេះ ព័ត៌មានអាចផ្តល់ឲ្យនៅក្នុងឆ្នាំ ១៩៧៥-ឆ្នាំ១៩៧៩ ឬ នៅក្នុងឆ្នាំថ្មីៗនេះ ដោយសារមានការប៉ុនប៉ងពី ប្រាក់ យុត ចង់យកមកជាមូលដ្ឋានគាំទ្រការភូតកុហក របស់គាត់។ មេធាវីការពារក្តីកត់សម្គាល់ថា នៅក្នុងសំណុំរឿងកន្លែងផ្សេងទៀត មានភស្តុតាងបង្ហាញថា ប្រាក់ យុត ទាក់ទង សាក្សី និងពិភាក្សាអំពីការស៊ើបអង្កេត ហើយថែមទាំងព្យាយាមទាក់ទង អោ អាន ទៀត ឯកសារ **D117/26** (កំណត់ហេតុនៃ ការស្តាប់ចម្លើយសាក្សី ពុត កុល), ឆ.២៩។ ឯកសារ **D219/484** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.១៥។

យូ វ៉ាន់ អាចត្រូវបានទទួលឥទ្ធិពលដោយ ប្រាក់ យុត ដែលត្រូវបានជំរុញឲ្យបិទបាំងបទល្មើសរបស់ខ្លួន។

<u>គ) ពៅ សារ៉ុម, ពុត កុល និង កែវ រឿន</u>

67. ភស្តុតាងបន្ថែមទៀតនៃអំពីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្កើតករណីជុំវិញការកុហករបស់ ប្រាក់ យុត គឺការផ្អែករបស់គាត់[133]ទៅលើចម្លើយរបស់សាច់ញាតិ និង សមាជិកក្រុមរបស់ ប្រាក់ យុត៖ ពៅ សារ៉ុម អតីតមេឃុំក្រឡា[134] ពុត កុល ធ្លាប់ធ្វើការជាមួយ ប្រាក់ យុត ទាំងនៅភូមិភាគនិរតី និង ភូមិភាគកណ្តាល[135] និង កែវ រឿន អតីតចុងភៅរបស់ ប្រាក់ យុត ហើយក្រោយ

[133] <u>ពៅ សារុំ (រ៉ុ) (ពាក់ព័ន្ធនឹងការចោទប្រកាន់អំពីការតែងតាំង អោ អាន និងបញ្ជាដកកម្មាភិបាល ចាប់ខ្លួន និងសម្លាប់ និងពាក់ព័ន្ធនៅក្នុងការបោសសម្អាត)</u>៖ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣ កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៨ កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៣ កថាខណ្ឌ ៤២៩ ជើងទំព័រ ១៣២៧។ <u>ពុត កុល (ពាក្យព័ន្ធនឹងវត្តមានរបស់ អោ អាន ដូចបានចោទប្រកាន់ និងបញ្ជាចាប់ខ្លួន)</u>៖ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៤ ជើងទំព័រ ៥៩៤ កថាខណ្ឌ ២៤៥ ជើងទំព័រ ៥៩៦ កថាខណ្ឌ ២៤៦ ជើងទំព័រ ៥៩៩ កថាខណ្ឌ ២៦៣ ជើងទំព័រ ៦៦១ កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៨។ <u>កែវ រឿន (ពាក់ព័ន្ធនឹង អោ អាន ចុះពិនិត្យការដ្ឋានការងារ)</u>៖ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៥៣ ជើងទំព័រ ១០០១។

[134] <u>ពៅ សារ៉ុម (រ៉ុម)</u>៖ ឯកសារ **D117/70** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត), ឆ.១១ (ប្រាក់ យុត លើកឡើងថា ពៅ សារ៉ុមគឺជាសាច់ញាតិ)។ ឯកសារ **D117/24** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម), ឆ.២ (ពៅ សារ៉ុម លើកឡើងថា ម្តាយរបស់គាត់គឺជាមីងរបស់ ប្រាក់ យុត)។ ឯកសារ **D117/33** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម), ឆ.៣ (ពៅ សារ៉ុម ហៅ ប្រាក់ យុត ថាជាបងជីដូនមួយ)។ ឯកសារ **D107/8** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ឹម កុល), EN 00787219 ទំព័រ 3 (ញ៉ឹម កុល ហៅ រ៉ុម ថាជាប្រធានឃុំក្រឡា)។ ឯកសារ **D117/26** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុត កុល), ឆ.១៩ (ពុត កុល លើកឡើងថា រ៉ុម គឺជាប្រធានឃុំក្រឡា)។ ឯកសារ **D117/42** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ខឹម នារី), ឆ.១២ (ខឹម នារី លើកឡើងថា រ៉ុម គឺជាប្រធានឃុំក្រឡា)។ ឯកសារ **D219/191** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ រឿន), ឆ.៣ (កែវ រឿន ហៅ រ៉ុម ថាជាប្រធានឃុំក្រឡា)។

[135] <u>ពុត កុល</u>៖ ឯកសារ **D117/26**, (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុត កុល), KH 00951883 ទំព័រ ២ (ពុត កុល ពិពណ៌នា សោម ងិន ថាជាប្តីរបស់គាត់)។ ឯកសារ **D219/812** (កំណត់ហេតុនៃការស៊ើបអង្កេត), KH 01321329 ទំព័រ 2 ('ក្នុងពេលបំពេញបេសកកម្មមួយផ្សេងទៀតក្នុងខេត្តកំពត់ យើងបានកំណត់អត្តសញ្ញាណឈ្មោះ ពុត កុល ជាប្រពន្ធរបស់ឈ្មោះ សោម ងិន ត្រូវជាប្អូនប្រុសរបស់ ប្រាក់ យុត')។ ឯកសារ **D117/26**, (កំណត់ហេតុនៃការស្តាប់ចម្លើយ ពុត កុល), ឆ.១-ឆ.២, ឆ.៧, ឆ.១០ (ពុត កុល ធ្វើការងារជាមួយ ប្រាក់ ពុត នៅក្នុងកំពត ក្នុងភូមិភាគនីរតី។ នៅពេល ប្រាក់ យុត ត្រូវបានផ្ទេរទៅភូមិភាគកណ្តាល ពុត កុល ទៅតាមគាត់។ ពុត កុល បានស្នាក់នៅមន្ទីរស្រុកកំពង់សៀមជាមួយ ប្រាក់ យុត រយៈពេល ៤ ៥ ខែ និងតាម ប្រាក់ យុត ទៅគ្រប់កន្លែង)។

មកត្រូវតម្លើងជាអនុលេខាឃុំក្រឡា[136]។

68. បុគ្គលទាំងនេះមិនគួរឲ្យជឿជាក់បានទេទៅលើបញ្ហានានាពាក់ព័ន្ធនឹង តួនាទី និង ការទទួលខុសត្រូវរបស់ អោ អាន ពីព្រោះថា ពួកគេមានចេតនាភូតកុហក ជាអាទិ៍ បន្ទោស អោ អាន ដើម្បីការពារ ប្រាក់ យុត និង នាមត្រកូលរបស់ពួកគេ។ ដោយហេតុថាពួកគេមានទំនាក់ទំនងគ្រួសារជាមួយ ប្រាក់ យុត ពួកគេ ទំនងជាបានឃើញ និង និយាយជាមួយ ប្រាក់ យុត អំពីការស៊ើបអង្កេត[137]។ ទោះបីជាមានហានិភ័យទាំងនេះ ក៏ដោយ ក៏អ្នកស៊ើបអង្កេតស្តាប់ចម្លើយសាក្សីទាំងនេះឲ្យបានហ្មត់ចត់អំពីការទាក់ទង និង ការពិភាក្សាទៅវិញទៅមកអំពីការស៊ើបអង្កេតដែរ។ ហេតុដូច្នេះ ភ័ស្តុតាងបានមកពីបុគ្គលទាំងនេះខ្វះ នូវភាពគួរឲ្យជឿជាក់បាន ហើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដែលមិនបានពិនិត្យពិច័យខ្លឹមសារនៃកំណត់ហេតុ ស្តាប់ចម្លើយរបស់ពួកគេ ហើយបែរជាផ្អែកទាំងងងឹតងងុលទៅលើចម្លើយទាំងនោះដោយគ្មានការពន្យល់។

## ឃ) ញ៉ែម ចេន

69. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកយ៉ាងច្រើនទៅលើចម្លើយដោយគ្មានសម្អាងរបស់ ញ៉ែម ចេន ដែលជាអង្គរក្សការពារ អោ អាន ក្នុងការគាំទ្រការរកឃើញរបស់ខ្លួន លើបញ្ហាយុត្តាធិការបុគ្គល ក្នុងនោះរួមមាន អោ អាន បានប្រកាសផែនការបង្អត់អាហារប្រជាជននៅតំបន់៤១ រៀបចំការបោសសំអាតអតីកម្មាភិបាលនៅតំបន់ ៤១ បានចូលរួមនិងដឹកនាំប្រជុំរួមទាំងប្រជុំយោធា បានបញ្ជាឲ្យចាប់ខ្លួននិងសម្លាប់ ហើយធ្វើឲ្យប្រាកដថា ការណែនាំរបស់ អោ អាន ត្រូវបានអនុវត្ត និង

[136] កែវ វឿន៖ ឯកសារ **D107/8** (កំណត់ហេតុនៃការស្តាប់ចម្លើយ ញឹម កុល) KH 00784987-88 ទំព័រ ៤-៥ (ញឹម កុល លើកឡើងថា វឿន គឺដូចកូន ឬ ចៅរបស់ ប្រាក់ យុត អញ្ចឹង)។ ឯកសារ **D219/191** (កំណត់ហេតុនៃការស្តាប់ចម្លើយ កែវ វឿន), ឆ.៣ (កែវ វឿន លើកឡើងថា គាត់ដាំបាយឲ្យ ប្រាក់ យុត និងអ្នកដែលមកចូលរួមប្រជុំ)។ ឯកសារ **D117/28** (កំណត់ហេតុនៃការស្តាប់ចម្លើយ កែវ វឿន), ឆ.១២ (កែវ វឿន ដាំបាយឲ្យ ប្រាក់ យុត)។

[137] ឧទាហរណ៍ ឯកសារ **D117/26** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុត កុល), ឆ.២៩ ('ទេ បើទោះជាខ្ញុំនៅជាមួយគាត់ និងរួមដំណើរជាមួយគាត់ទៅកន្លែងផ្សេង និងបានជួបជាមួយប្រធានឃុំក៏ដោយ នៅពេលដែលគេបានជួប គេមិនអាចឲ្យខ្ញុំស្តាប់ការសន្ទនារបស់គេទេ។ [...] ខ្ញុំចង់ប្រាប់លោកថា ប្រាក់ យុត បានទូរស័ព្ទមកខ្ញុំមិនពេលបោះឆ្នោត គាត់បានបញ្ជាក់ប្រាប់ខ្ញុំថា ខ្ញុំដឹងរឿងការពិតអ្វីអំពីជំនាន់ខ្មែរក្រហមឲ្យខ្ញុំប្រាប់គាត់ទៅ មិនត្រូវលាក់លៀមអ្វីទេ')។

សម្របសម្រួលភស្តុភារសម្រាប់ការសម្លាប់[138]។

70. ដូចដែលបានពន្យល់នៅក្នុងចម្លើយតប របស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ[139] ញ៉ែម ចិន មិនមែនជាសាក្សី គួរឲ្យជឿទុកចិត្តបានទេទៅលើបញ្ហាទាំងនេះ។ ទីមួយ គាត់គឺជាកុមារ[140] នៅឆ្នាំ១៩៧៧-១៩៧៩ ដែលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសមត្ថភាពរបស់គាត់ក្នុងការរម្លឹកឡើងវិញនូវព្រឹត្តិការណ៍៤០ឆ្នាំក្រោយមក[141] ហើយភាពសុក្រឹតនៃការចងចាំរបស់គាត់[142]គឺទំនងជារងផលប៉ះពាល់ជាអវិជ្ជមានដោយសំណួរណែនាំរបស់អ្នកស៊ើបអង្កេត[143]។ ទីពីរ

---

[138] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៣ ជើងទំព័រ ៧១២, ៧១៤ កថាខណ្ឌ ២៧៦ ជើងទំព័រ ៧២២ កថាខណ្ឌ ២៧៧ ជើងទំព័រ ៧២៣-៧២៦ កថាខណ្ឌ ២៧៨ ជើងទំព័រ ៧២៧-៧២៩ កថាខណ្ឌ ២៧៩ ជើងទំព័រ ៧៣១-៧៣៣, ៧៣៥ កថាខណ្ឌ ២៨៣ ជើងទំព័រ ៧៣៩ កថាខណ្ឌ ២៨៥ ជើងទំព័រ ៧៤១ កថាខណ្ឌ ២៨៦ ជើងទំព័រ ៧៤៤-៧៤៥ កថាខណ្ឌ ២៨៧ ជើងទំព័រ ៧៤៦ កថាខណ្ឌ ២៩៤ ជើងទំព័រ ៧៧០ កថាខណ្ឌ ២៩៩ ជើងទំព័រ ៧៩២ កថាខណ្ឌ ៣០១ ជើងទំព័រ ៨០០-៨០៣ កថាខណ្ឌ ៣៩៤ ជើងទំព័រ ១១៦៦-១១៦៨ កថាខណ្ឌ ៣៩៦ ជើងទំព័រ ១១៧៩-១១៨០ កថាខណ្ឌ ៤០៦ ជើងទំព័រ ១២២៥-១២២៦ កថាខណ្ឌ ៥០៣ ជើងទំព័រ ១៦៥៦ កថាខណ្ឌ ៥៣៦ ជើងទំព័រ ១៧៨៩-១៧៩០ កថាខណ្ឌ ៥៤៦ ជើងទំព័រ ១៨២២-១៨២៤ កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៩៩៦។

[139] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ១៧០-១៧៦។

[140] ឯកសារ **D219/731** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.១៦ ('ខ្ញុំមានអាយុប្រហែល ១៣ ឬ ១៤ ឆ្នាំ')។ ឯកសារ **D219/731** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៨ ('យើងនៅក្មេង។ មិនដឹងអ្វីនោះទេ.')។ ឯកសារ **D219/731** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៤៧ ('ខ្ញុំមិនចាំច្បាស់ពីព្រោះខ្ញុំនៅក្មេងនៅពេលនោះ)។ ឯកសារ **D219/731** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៦៤ ('ខ្ញុំមិនដឹងទេដោយសារខ្ញុំនៅក្មេង')។ ឯកសារ **D219/855** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៤១ ('នៅពេលនោះ ខ្ញុំនៅក្មេង')។

[141] Australian Law Reform Commission, 'ALRC Report 84: Children as Reliable Witnesses' in *Seen and heard: priority for children in the legal process* (1997) កថាខណ្ឌ ១៤.២០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤៤ ('ទោះបីជាយ៉ាងនេះក្តី កូន ក្មេង និងមនុស្សចាស់បានបាត់ការចងចាំច្រើនក្រោយរយៈពេលយូរមកនេះ។ ពួកគេនឹងឃើញព័ត៌មានត្រឹមត្រូវតិចតួច ខណៈនៅតែបញ្ជាក់ថាវាជាព័ត៌មានមិនត្រឹមត្រូវជាដរាប។ ការសិក្សាបង្ហាញថា លទ្ធភាពចងចាំ និងពិពណ៌នាហេតុការណ៍ត្រឹមត្រូវទាំងនៅពេលសួរ និងនៅកាលបរិច្ឆេទក្រោយ អាចអាស្រ័យលើវិធីសាស្ត្រសម្ភាសន៍')។ Myers *និងអ្នកផ្សេងទៀត* 'Psychological Research on Children as Witnesses: Practical Implications for Forensic Interviews and Courtroom Testimony', *28 Pac. L.J. 3* (1996), ទំព័រ ៣-៩១ ទំព័រ ១៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤៥ ('វាបញ្ជាក់ច្បាស់ថា ការចងចាំអាចរសាត់បាត់ចំពោះជីវិតមនុស្សចាស់ និងកូនក្មេង។ ការស្រាវជ្រាវបង្ហាញថា ការចងចាំរបស់កូនក្មេងរសាត់បាត់លឿនជាងមនុស្សចាស់ចំពោះហេតុការណ៍មួយចំនួន')។

[142] Fredin, *Children as Eyewitnesses: Memory recall and face recognition* (Lund: Lund University, 2011) ទំព័រ ២០-២១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤៦ (ការដកស្រង់ផ្ទៃក្នុងត្រូវបានលុបចោល) ('ការរកឃើញទូទៅបង្ហាញថា ក្មេងតូចៗ

ភ័ស្តុតាងរបស់គាត់ភាគច្រើនគឺជាការស្មានៗនិងជាពាក្យចចាមអារ៉ាម[144] ដោយហេតុថាគាត់យល់ដឹងតិចតួចណាស់អំពីរចនាសម្ព័ន្ធបក្សកុម្មុយនីស្តកម្ពុជា[145] ហើយ កម្របានធ្វើការជាមួយ អោ អាន ណាស់[146]។ ជាងនេះទៀត គេដឹងជាទូទៅថា អ្នកបើកបរ និរសារ និង អ្នក ការពារ មិនត្រូវបានអនុញ្ញាតឲ្យដឹងរឿងសំខាន់របស់បក្សកុម្មុយនីស្តកម្ពុជា ឡើយ ហើយមិនចូលទៅកន្លែងប្រជុំទេ[147]។ ទីបី ចម្លើយ ញ៉ែម ចេន គឺមិនមានសំអាងនិងមិនមានសង្គតិភាពជាមួយចម្លើយរបស់អ្នក

---

ងាយឆាប់អួសទាញបានជាងមនុស្សចាស់ជរា ហើយកុមារជាទូទៅងាយឆាប់អួសទាញជាងមនុស្សពេញវ័យ [...] ការពន្យារពេលគឺជាកត្តាពាក់ព័ន្ធនៅក្នុងក្របខ័ណ្ឌកោសល្យវិច័យពីព្រោះក្មេងៗជាធម្មតាមិនផ្តល់សក្ខីកម្មអំពីបទល្មើសព្រហ្មទណ្ឌរហូតដល់ ២១ សប្តាហ៍ ខែ ឬ ឆ្នាំក្រោយហេតុការណ៍ដំបូង។ នៅក្នុងអំឡុងពេលនេះ កុមារដូចក្រដាសឆាប់ទទួលយក។ ចំណុចនេះអាចមានឥទ្ធិពលលើលទ្ធភាពក្នុងការកំណត់អត្តសញ្ញាណជនសង្ស័យ។ ព័ត៌មានរក្សាទុកនៅក្នុងការចងចាំទំនងរលាយបាត់ក្រោយរយៈពេលយូរ។ ការបាត់បង់ព័ត៌មានច្រើនកើតឡើងភ្លាមៗក្រោយហេតុការណ៍កើតឡើង។ កត្តាមួយដែលអាចបង្កើនភាពងាយទទួលយករបស់កុមារ និងភាពលេចឡើងការចងចាំខុសគឺអ្នកស៊ើបអង្កេតត្រូវផ្តោតលើសំណួរចំៗជាជាងសំណួរបើកនៅក្នុងកិច្ចសម្ភាសន៍')។

[143] ឧទាហរណ៍ ឯកសារ **D219/855** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេ), ឆ.១៦៦-ឆ.១៧២ (ញ៉ែម ចេន បានរំលឹកកិច្ចប្រជុំមួយនៅវត្តតាមាក់ ដែល "ពួកគេ" មិនមែន អោ អាន ឬ តំបន់ បានណែមេសហករណ៍ឲ្យអួសទាញអតីតទាហាន លន់ នល់ ឲ្យចូលប្រជុំ និងកំណត់អត្តសញ្ញាណពួកគេ។ ដល់ពេលអ្នកស៊ើបអង្កេត លើកឡើងថា អោ អាន ជាប់ទាក់ទងនឹងកិច្ចប្រជុំ ទើប ញ៉ែម ចេន ឈប់លើកឡើងពាក្យ "ពួកគេ" ហើយចាប់ផ្តើមចោទប្រកាន់ អោ អាន ថាជាអ្នកណែនាំ)។

[144] ឧទាហរណ៍ ឯកសារ **D219/855** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៧៩-ឆ.៨១ ('សៈ នៅក្នុងបទសម្ភាសន៍របស់លោកពីលើកមុន ក្នុងឯកសារ D219/732 នៅក្នុងចម្លើយលេខ ៤១ និង ៤២ នៅពេលនោះលោកបញ្ជាក់ថា តាអាន ទទួលបញ្ជាពីភូមិភាគ ដើម្បីសម្លាប់មនុស្សតាមរយៈនីរសារភូមិភាគ។ អីចឹងសុំសួរលោកថា តើបញ្ជាដែលគាត់ទទួលពីភូមិភាគតាមរយៈនីរសារហ្នឹង គឺគេបញ្ជូនតាមណា តាមពាក្យនីរសារ សំបុត្រ ឬ ក៏ធ្វើម៉េច ដើម្បីបញ្ជូនសារពីភូមិភាគមកឲ្យ តាអាន? ឆ.៧៩៖ សំបុត្រ នីរសារគេយកមកឲ្យ។ សៈ កងការពារគាត់ ខ្ញុំធ្លាប់បានជួបនិយាយលេង គាត់ថា ភូមិភាគគេឲ្យយកសំបុត្រមកឲ្យតំបន់ ថានីរសារគេយកមកឲ្យ។ មានតែរឿងហ្នឹង។')

[145] ឯកសារ **D219/731** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៨, ឆ.៤៧។

[146] ឯកសារ **D219/731** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៣១, ឆ.៨២-ឆ.៨៣។ ឯកសារ **D219/855** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៦, ឆ.១០២, ឆ.១០៤, ឆ.១៥៤។

[147] ឧទាហរណ៍ ឯកសារ **D117/20** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី លឹម សេង) ឆ.៨ ឆ.១០ (លឹម សេង គឺជាអ្នកបើកបរឲ្យ កែ ពក ពន្យល់ថា គាត់ និងនីរសារផ្សេងទៀត និងកងការពារ ត្រូវចាំនៅកន្លែងមួយផ្សេងនៅក្រៅកន្លែងប្រជុំ ហើយពួកគេពុំបានចូលរួមនោះឡើយ)។ ឯកសារ **D117/50** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ប៊ុន), ឆ.៥៤ (អ៊ឹម ប៊ុន ដែលជាអ្នកបើកបររបស់ អោ អាន ពន្យល់ថា គាត់បានឃើញ និងបានឮអំពីកិច្ចប្រជុំតំបន់ ប៉ុន្តែ ពុំបានដឹងប្រធានបទពិភាក្សាអ្វីទេ ពីព្រោះសមាជិកគណៈកម្មាធិការបានជួបគ្នានៅក្នុងផ្ទះមួយ)។ ឯកសារ **D219/870** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី រី ញ៉ា), ឆ

ផ្សេងទៀតដែលធ្វើការ ជាមួយគាត់ ក្នុងឆ្នាំ១៩៧៦-១៩៧៩[148]។ អ្នកស៊ើបអង្កេតបានកំណត់អត្តសញ្ញាណនិងស្តាប់ចម្លើយកុមារដទៃទៀតនៅក្នុងក្រុម ញ៉ែម ចេន ហើយពុំមាននណាម្នាក់អាចបញ្ជាក់ចម្លើយរបស់ ញ៉ែម ចេន បានទេ[149]។ ហេតុដូច្នេះ ញ៉ែម ចេន មិនអាចត្រូវបានចាត់ទុកជាសាក្សីគួរឱ្យទុកចិត្តបានទៅលើតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន បានទេ ហើយការណ៍ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកយ៉ាងច្រើនដោយគ្មានការពន្យល់ទៅលើចម្លើយរបស់គាត់ជាពិសេសចម្លើយដែលគ្មានសំអាងគឺជាកំហុសអង្គច្បាប់។

## ង) ជុំ វង្ស (ង៉ូវ)

71. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើចម្លើយរបស់ ង៉ូវ ក្នុងការគាំទ្រដល់សំអាងហេតុរបស់ខ្លួនលើយុត្តាធិការបុគ្គល ជាពិសេសការទទួលខុសត្រូវរបស់ អោ អាន ក្នុងការបោសសំអាតខ្មាំង និង

---

.២៧ (រី ញ៉ា ដែលជាកងការពារនៅតំបន់ ៤១ ពន្យល់ថា គាត់មិនដែលចូលប្រជុំដែល អោ អាន ជាប្រធាននោះឡើយពីព្រោះយើងនៅក្មេងពេក។ យើងមិនមានសិទ្ធិចូលមន្ទីរតំបន់ទេ។ យើងពុំមានសិទ្ធិចូលកិច្ចប្រជុំទេ')។ ឯកសារ **D6.1.437** (កែ អ៊ុន), KH 00283341 ទំព័រ ៣ (កែ អ៊ុន អ្នកបើកឡានឱ្យ កែ ពក ពន្យល់ថា កែ ពក បានបើកឡានជូនគាត់ទៅចូលរួមប្រជុំសំខាន់ៗ)។

[148] ទោះបីគាត់ជាកងការពាររបស់ អោ អាន និងក្រោយមក សុខ ក៏ដោយ ញ៉ែម ចេន អះអាងថា គាត់ធ្វើការនៅក្នុងអង្គភាពតែមួយជាមួយ ពឿន សាល់ ញ៉ា និង ខន និងអ្នកផ្សេងទៀត។ ឯកសារ **D219/731** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.១៩-ឆ.២៥។ ឯកសារ **D219/732** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.១-ឆ.៨។

[149] ឯកសារ **D219/791** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប៉ាំង ពេជ្រ), ឆ.៣៧-ឆ.៣៩ (ប៉ាំង ពេជ្រ ស្គាល់ ចេន ដែលរស់នៅភូមិត្រពាំងថ្លើង និងដាំស្រូវជាមួយគាត់។ គាត់មិនត្រូវបានគេឱ្យទៅនៅកងការពាររបស់ តាសុខ នោះទេ)។ ឯកសារ **D219/760** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាត់ ពឿន), ឆ.៩-ឆ.១៣ (សមាជិក បាត់ ពឿន ចាំឈ្មោះមិត្តភ័ក្ត្ររបស់ពួកគាត់ខ្លះនៅក្នុងកងជាមួយគ្នា រួមមាន ម៉ិល ខន ផៃ សល់ ចឹម ចន ប៉ុាំង ប៊ុច និង ញ៉ែម ចេន។ ពួកគេត្រូវបានបំបែកក្រោយរយៈពេល ៦ ខែ។ គាត់មិនស្គាល់ថាតើមិត្តរបស់គាត់នរណាខ្លះត្រូវបានចាត់ឱ្យការងារសន្តិសុខនៅមន្ទីរតំបន់ ៤១ នោះទេ។ គាត់បានលើកឡើងថា គាត់មិនត្រូវបានចាត់ឱ្យទៅធ្វើការងារនៅក្នុងកងសន្តិសុខនោះទេ ហើយវាផ្ទុយពី ញ៉ែម ចេន ដែលពន្យល់ថា "ពួកគេពុំឱ្យយើងដឹង ឃើញ ឬ ឮអ្វីនោះឡើយ។ ពួកគេមិនឱ្យយើងដឹងអ្វីទាំងអស់។ ពួកគេប្រាប់យើងថាកុំចង់ដឹងអំពីការងាររបស់ថ្នាក់លើៗ។ ពួកគេចង់ឱ្យយើងផ្តោតលើការងាររបស់យើង ដូចជា ចិញ្ចឹមមាន់ និងជ្រូក។ គេមិនឱ្យយើងចូលទៅជិតមន្ទីរតំបន់ឡើយ ដែលហ៊ុមព័ទ្ធតៅដោយលួសបន្លា')។ ឯកសារ **D219/761** (កំណត់ហេតុរបស់ ម៉ិល ខន), ឆ.៩-ឆ.១១ (ម៉ិល ខន លើកឡើងថា ចេន គឺជានីរសាររបស់ សុខ ដែលមិនមែនជាជនស៊ីវិលនោះទេ ប៉ុន្តែមានការងារធំ។ ប៉ុន្តែ គាត់ពុំបានឆ្លើយស៊ីសង្វាក់គ្នាជាមួយនឹងភ័ស្តុតាងរបស់ ញ៉ែម ចេន ដែលឆ្លើយអំពី អោ អាន នោះឡើយ)។ ឯកសារ **D219/759** (កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ផៃ សល់), ឆ.២២ (ផៃ សល់ មិនអាចបញ្ជាក់លើចម្លើយរបស់ ញ៉ែម ចេន បាននោះទេអំពីការងាររបស់គាត់)។

អតីត កម្មាភិបាល សិទ្ធិអំណាចក្នុងការធ្វើដំណើរក្នុងតំបន់ សេដ្ឋកិច្ច និង យោធា ការរាយការណ៍ទៅថ្នាក់ភូមិភាគ ការចេញដីកាចាប់ខ្លួន និង គ្រប់ គ្រងទៅលើបញ្ហាសន្តិសុខតំបន់និងមន្ទីរ[150]។

72. ប៉ុន្តែទោះជាយ៉ាងណា ង៉ូវ ខ្វះភាពគួរឱ្យជឿជាក់បានទៅលើបញ្ហាពាក់ព័ន្ធនឹង តួនាទី និងការទទួលខុសត្រូវរបស់ អោ អាន ពីព្រោះថា (ក) ក្នុងនាមជាប្រធានមន្ទីរសន្តិសុខមិត្តសសុប(គ)[151] គាត់មានចេតនា ភូតកុហកដើម្បីគេចវេសការទទួលខុសត្រូវផ្នែកសីលធម៌ និង ច្បាប់ (ខ) អ្នកស៊ើបអង្កេតផ្តល់ឱ្យគាត់នូវព័ត៌មានដាក់បន្ទុកតាមរយៈសំណួរបិទ និង វិធីគួរឱ្យសង្ស័យដទៃទៀត[152]។

73. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខ្លួនឯងផ្ទាល់ រកឃើញថា ង៉ូវ គឺជាបុគ្គលមិនអាចជឿបានពាក់ព័ន្ធនឹងបញ្ហាមួយចំនួន[153] ប៉ុន្តែ នៅតែផ្អែកលើគាត់ដោយពុំមានការពន្យល់អង្គហេតុសំខាន់ៗ[154]។

---

[150] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២១៤ ជើងទំព័រ ៤៨៩ កថាខណ្ឌ ២៤៣ ជើងទំព័រ ៥៩៣ កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៧ កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤២, ៦៤៤-៦៤៥, ៦៤៩ កថាខណ្ឌ ២៦៥ ជើងទំព័រ ៦៦៤, ៦៦៦ កថាខណ្ឌ ២៦៦ ជើងទំព័រ ៦៧៦-៦៧៧ កថាខណ្ឌ ២៧២ ជើងទំព័រ ៧០៥-៧០៦ កថាខណ្ឌ ២៧៣ ជើងទំព័រ ៧១០, ៧១៣ កថាខណ្ឌ ២៨២ ជើងទំព័រ ៧៣៧ កថាខណ្ឌ ២៨៥ ជើងទំព័រ ៧៤២ កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៨-៧៨០ កថាខណ្ឌ ៣៨៤ ជើងទំព័រ ១១៦៩ កថាខណ្ឌ ៣៩៥ ជើងទំព័រ ១១៧០-១១៧៧។ កថាខណ្ឌ ៣៩៦ ជើងទំព័រ ១១៧៨។

[151] ឯកសារ **D219/504** (កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី សាត ភាព), ឆ.៨៧។ ឯកសារ **D219/855** (កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ញ៉ែម ចេន), ឆ.២៧។ ឯកសារ **D117/54** (កំណត់ហេតុនៃការស្តាប់ចម្លើយរបស់សាក្សី ស៊ឹង លឹម), ឆ.៨។

[152] ឧទាហរណ៍ ឯកសារ **D117/56** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស), ឆ.៣៨ (អ្នកស៊ើបអង្កេតលើកឡើងប្រាប់ ង៉ូវ ថា អោ អាន ជាប់ទាក់ទងនឹងមន្ទីរសន្តិសុខ គរ)។ ឯកសារ **D219/442** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជុំ វង្ស), ឆ .១៥០-ឆ.១៥២ (អ្នកស៊ើបអង្កេត ក.ស.ច.ស លើកឡើងប្រាប់ ង៉ូវ ថា ការដឹកជញ្ជូនអ្នកទោសរវាងស្រុកតម្រូវសុំការអនុញ្ញាតពីលេខាតំបន់ ហើយការដឹកជញ្ជូនរវាងតំបន់តម្រូវឱ្យសុំការអនុញ្ញាតពីលេខាភូមិភាគ)។

[153] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤១១ (ស.ច.ស.អ យល់ឃើញថា ចម្លើយរបស់ ង៉ូវ ពាក់ព័ន្ធនឹងការប្រជុំជាមួយ អោ អាន មិនអាចទុកចិត្តបាន ដោយសារគាត់អាចព្យាយាមផ្តាច់គាត់ឱ្យឆ្ងាយពីប្រតិបត្តិការសម្លាប់នៅ មេសប់)។

[154] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧២ ជើងទំព័រ ៧០៦ (ស.ច.ស.អ សំអាងតែទៅលើ ង៉ូវ និងរកឃើញថា ការធ្វើដំណើរពីតំបន់ ៤១ ទៅតំបន់ ៤២ ឬ ៤៣ ត្រូវការការអនុញ្ញាតពី អោ អាន និងលេខាភូមិភាគ) កថាខណ្ឌ ២៧៣ ជើងទំព័រ ៧១៣ (ស.ច.ស.អ សំអាងតែទៅលើ ង៉ូវ និងរកឃើញថា អោ អាន ទទួលស្គាល់នៅក្នុងពេលប្រជុំថា ប្រជាជននៅក្នុងតំបន់ ៤១ បានទទួលអាហារមិនគ្រប់គ្រាន់) កថាខណ្ឌ ៣៩៥ ជើងទំព័រ ១១៧១-១១៧៧ (ស.ច.ស.អ សំអាងតែទៅលើ ង៉ូវ និងរកឃើញថា របាយការណ៍របស់ ង៉ូវ ទៅកាន់ "តំបន់" រួមមានព័ត៌មានអំពីលក្ខខណ្ឌសន្តិសុខនៅមន្ទីរសន្តិសុខ សុខ

មេធាវីការពារក្ដីរំលឹកឡើងវិញ និង បញ្ចូលទឡ្ហីករណ៍របស់ខ្លួនអំពី ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានស្ថាពររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ៖ ប្រសិនបើ ង៉ូវ ពង្រួញការចូលរួមរបស់គាត់នៅក្នុងបទល្មើស ដូចដែលអះអាងដោយ សហព្រះរាជអាជ្ញាអន្តរជាតិ និង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នោះ គ្មានហេតុផលនាំឲ្យជឿបានថា ចម្លើយរបស់គាត់ដែលឆ្លើយដាក់ អោ អាន ដែលជាមេកើយ មានលក្ខណៈ គួរឲ្យជឿទុកចិត្តបានជាងចម្លើយដោះបន្ទុកផ្សេងទៀតរបស់គាត់ឡើយ[155]។ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជ្រើសរើសយកវិធីមិនសមហេតុផលចំពោះសាក្សីនេះ។ គាត់មានកំហុសមិនត្រឹមតែមិនពិនិត្យដិតដល់ទៅលើខ្លឹមសារនៃភ័ស្តុតាងរបស់ ង៉ូវ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងផ្អែកលើភ័ស្តុតាងនោះដោយគ្មានការពន្យល់។

<u>ច) ពេញ វ៉ា និង ញឹម កុល</u>

74. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកលើកំណត់ហេតុស្ដាប់ចម្លើយរបស់ ពេញ វ៉ា និង ញឹម កុល ដែលជាអ្នកដាក់ពាក្យ តាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីគាំទ្រអង្គហេតុជាក់ស្ដែងពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលក្នុងនោះរួម មានតួនាទីរបស់ អោ អាន ការចូលរួមប្រជុំសំខាន់ៗ ការត្រួតពិនិត្យការដ្ឋាន ការតែងតាំងនិងការដក តំណែងកម្មាភិបាល ការបង្កើតគោលនយោបាយសម្លាប់ និង ភស្តុភារ និងការបញ្ជាឲ្យមានការចាប់ខ្លួន និង សម្លាប់[156]។ ដោយ សក្ខីកម្មរបស់ ពេញ វ៉ា និង

---

ភាពអ្នកទោស ការបង្កបង្កើនផល ចំនួនអ្នកទោសចេញចូល និងប្រភពអ្នកទោស ហើយក្រោយទទួលរបាយការណ៍ពី ង៉ូវ អូន បានរាយការណ៍ជូនគណតំបន់)។

[155] សំណុំរឿង ០០៤/២-ឯកសារ **D351/6** កថាខណ្ឌ ១៦៨។ *សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស, ដីកាសន្និដ្ឋានស្ថាពររបសសហព្រះរាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* (*'ដីកាសន្និដ្ឋានស្ថាពររបស់ ស.ព.អ'*), ឯកសារ **D351/5** ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ ១៤៦។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤១១។

[156] <u>ពេញ វ៉ា</u>៖ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៧ ជើងទំព័រ ៦០១-៦០៣ កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣, ៦៣៥។ កថាខណ្ឌ ២៦៣ ជើងទំព័រ ៦៦១ កថាខណ្ឌ ២៧២ ជើងទំព័រ ៧០៥ កថាខណ្ឌ ២៧៤ ជើងទំព័រ ៧១៧ កថាខណ្ឌ ២៧៩ ជើងទំព័រ ៧៣០ កថាខណ្ឌ ២៨៨ ជើងទំព័រ ៧៤៨-៧៤៩ កថាខណ្ឌ ២៩៣ ជើងទំព័រ ៧៦៦-៧៦៨ កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៨ កថាខណ្ឌ ៣០០ ជើងទំព័រ ៧៩៣ កថាខណ្ឌ ៣០៩ ជើងទំព័រ ៨២៨។ កថាខណ្ឌ ៤២៣ ជើងទំព័រ ១២៧៩ កថាខណ្ឌ ៥៦៤ ជើងទំព័រ ១៩០៤ កថាខណ្ឌ ៥៨៨ ជើងទំព័រ ១៩៩៤។ <u>ញឹម កុល</u>៖ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៤ កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥២ កថាខណ្ឌ ២៦៥ ជើងទំព័រ ៦៦៨ កថាខណ្ឌ ២៦៦ ជើងទំព័រ ៦៧៤ កថាខណ្ឌ ២៦៩ ជើងទំព័រ ៦៨៩ កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៤ កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៥

ញឹម កុល មិនធ្វើក្រោមសម្បថ និង ចម្លើយបុគ្គលទាំងនេះ មិនស៊ីសង្វាក់គ្នា ដូច្នេះភ័ស្តុតាងរបស់ពួកគេពាក់ព័ន្ធនឹងបញ្ហាយុត្តាធិការបុគ្គលគឺមិនអាចជឿជាក់បាន។

75. កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា និង ញឹម កុល ត្រូវបានធ្វើឡើងដោយគ្មានការធានានីតិវិធីជាធរមានសម្រាប់កំណត់ហេតុស្តាប់ចម្លើយសាក្សីឡើយ[157]។ ជាពិសេស អ្នកដាក់ពាក្យតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីមិនត្រូវបានតម្រូវឱ្យស្បថមុននឹងផ្តល់កំណត់ហេតុស្តាប់ចម្លើយ ហើយគ្មានទណ្ឌកម្មចំពោះសក្ខីកម្មក្លែងក្លាយឡើយ[158]។ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក៏មានចំណាប់អារម្មណ៍ក្នុងរឿងក្តីនេះ សមត្ថភាពក្នុងការចូលរួមក្នុងការស៊ើបអង្កេត ការចូលមើលសម្ភារៈភ័ស្តុតាងក្នុងសំណុំរឿង តាមរយៈមេធាវីរបស់ខ្លួន និង អាចពិគ្រោះជាមួយមេធាវីមុននឹងផ្តល់កំណត់ហេតុស្តាប់ចម្លើយ[159]។ ពួកគេមិនត្រូវបានហាមឃាត់មិនឱ្យទាក់ទងជាមួយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀត[160] ដូចដែល បានបង្ហាញដោយអង្គហេតុដែលថា ពេញ វ៉ា បានជួយអ្នកស៊ើបអង្កេតយ៉ាងសកម្មដោយភ្ជាប់ទំនាក់ទំនងជាមួយ និងស្វែងរកអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដទៃទៀត[161]។ ចំណុចចុងក្រោយ ពេញ វ៉ា[162]

---

កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១៤-៨១៥ កថាខណ្ឌ ៣១៨ ជើងទំព័រ ៨៤១ កថាខណ្ឌ ៤២៩ ជើងទំព័រ ១៣២៧-១៣២៩ កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥២ កថាខណ្ឌ ៦៣៤ ជើងទំព័រ ២១៦៣។

[157] *សូមមើល* សំណុំរឿង ០០២-ឯកសារ **F36** កថាខណ្ឌ ៣១៣-៣១៤។ សំណុំរឿង ០០២/១៩-០៩-២០០៧/អ.វ.ត.ក/អ.ជ.ស.ដ *សេចក្តីសម្រេចលើសំណើសុំរបស់មេធាវីការពារក្តី នួន ជា ពាក់ព័ន្ធនឹងការអនុវត្តរបស់អង្គជំនុំជម្រះសាលាដំបូងនៅពេលសួរដេញដួលដើមបណ្តឹងរដ្ឋប្បវេណី* **E336/3** ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៥ កថាខណ្ឌ ២២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤៧។

[158] វិធាន ២៣(៤), ២៣*ស្ទួន*, ២៤, ៣៦។ សំណុំរឿង ០០២-**E336/3** កថាខណ្ឌ ២១។

[159] វិធាន ២៣ *ស្ទួនពីរ*។

[160] *សូមមើល* វិធាន ២៣*ស្ទួនពីរ* (អនុញ្ញាតឱ្យតំណាងជាក្រុម)។ ២៣*ស្ទួនបី* (អនុញ្ញាតឱ្យបង្កើតសមាគមជនរងគ្រោះ)។

[161] ឯកសារ **D219/227** (កំណត់ហេតុនៃការស៊ើបអង្កេត), KH 01306481 ទំព័រ ១ (ពេញ វ៉ា មក អ.វ.ត.ក ជាមួយ ឆេន ជាអ្នកគាំទ្រលើកទឹកកចិត្ត ជជែកជាមួយអ្នកស៊ើបអង្កេត និងយល់ព្រមផ្តល់ចម្លើយ)។ ឯកសារ **D219/296** (កំណត់ហេតុនៃការស៊ើបអង្កេត), KH 01338973-74 ទំព័រ ២-៣ (ពេញ វ៉ា ខទ្មេសនាម សាក្សី ម្នាក់ឱ្យអ្នកស៊ើបអង្កេត ក.ស.ច.ស ជួយសន្ទនាជាមួយដោយគ្មានការថតសម្លេង)។ ឯកសារ **D219/530** (កំណត់ហេតុនៃការស៊ើបអង្កេត), KH 01215946 ទំព័រ ៦ (ពេញ វ៉ា លើឡើងសាក្សីបន្ថែមចំនួនពីររូបឱ្យទៅអ្នកស៊ើបអង្កេត ក.ស.ច.ស នៅក្នុងពេលជួបជជែកគ្នាមិនមានការថតសម្លេង)។ ឯកសារ **D219/619** (កំណត់ហេតុនៃការស៊ើបអង្កេត), KH 01353204-205 ទំព័រ ២-៣ (ពេញ វ៉ា ជួយអ្នកអ្នកស៊ើបអង្កេត ក.ស.ច.ស យ៉ាងសកម្មនៅក្នុងការស្វែងរកសាក្សី និងតម្រុយសក្តានុពល)។

និង ញ៉ឹម កុល[163] ផ្តល់នូវចម្លើយមិនស៊ីសង្វាក់។ ហេតុដូច្នេះ ពួកគេមិនអាចជឿទុកចិត្តបាន ហើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដែលមិនបានវាយតម្លៃឬត់ចត់ទៅលើខ្លឹមសារភ័ស្តុតាងរបស់ពួកគេ និង ផ្អែកលើភ័ស្តុតាងនេះដោយគ្មានការពន្យល់។

### iii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានពិចារណាវិធីសាស្ត្រគួរឲ្យសង្ស័យដែលប្រើប្រាស់ក្នុងកសារយកភ័ស្តុតាង និង ផ្អែកលើភ័ស្តុតាងដែលប្រឡូកប្រឡាក់នេះ

76. ដោយសន្និដ្ឋានថា អ.វ.ត.ក មានយុត្តាធិការបុគ្គលលើ អោ អាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើវិធីសាស្ត្រគួរឲ្យ សង្ស័យ និង កាលៈទេសៈក្នុងការស្រង់យកចម្លើយដោយអ្នកស៊ើបអង្កេតពីសាក្សីនិងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ វិធីសាស្ត្រទាំងនេះរួមមាន៖ (ក) ផ្តល់ព័ត៌មានដាក់បន្ទុកដល់ សាក្សី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី[164]

---

[162] ឧទាហរណ៍ *ប្រៀបធៀប* ឯកសារ **D219/226** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា), ឆ.៣២ (ពេញ វ៉ា លើកឡើងថា សមមិត្ត ម៉េង មិនមែន អោម ទេ ជាអ្នករៀបចំអាពាហ៍ពិពាហ៍) *ជាមួយ* ឯកសារ **D219/289** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេញ វ៉ា), ឆ.១០ (ពេញ វ៉ា លើកឡើងថា សមមិត្ត អួន បានរៀបចំអាពាហ៍ពិពាហ៍ឲ្យ សុត និង គាន់)។

[163] ឧទាហរណ៍ *ប្រៀបធៀប* ឯកសារ **D219/422.4** (ប្រតិចារឹក ញ៉ឹម កុល D107/8), KH 01121136-137 ទំព័រ ៦២-៦៣ (‘Christian: (អង់គ្លេស) ហើចុះខាងតំបន់? […] ញ៉ឹម កុល៖ (ខ្មែរ) តំបន់ ខ្ញុំសូម្បីតែម្នាក់ក៏ខ្ញុំអត់ស្គាល់ដែរ។ ប៉ុន្តែ តាអាន ហ្នឹងខ្ញុំគ្រាន់តែឮតែឈ្មោះ តែមិនដែលមុខ តាអាន ម៉េចផងទេ។ ខ្ញុំជម្រាបត្រង់’) *ជាមួយ* ឯកសារ **D219/422.4** (ប្រតិចារឹក ញ៉ឹម កុល D107/8), KH 01121136-137 ទំព័រ ៦២-៦៣ (‘អ្នកបកប្រែ៖ (ខ្មៅ) អត់ដែលឃើញគាត់សោះតែម្តង? ញ៉ឹម កុល៖ (ខ្មែរ) បាទ ជួបៗឃើញម្តង ពេលគាត់ជិះអាស្ស៊ីបម៉ូស័រមក។ ដល់ពេលគាត់ចុំ គ្រាន់តែឃើញកញ្ចប់ថ្នាំតែមួល គេថា “នោះ តាអាន””)។

[164] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥២ (ដកស្រង់ ឯកសារ **D219/484** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.១)។ ឆ.៤ (‘ស៖ តើលោកស្រីចាំអំពីចំនួនគ្រួសារចាមដែលរស់នៅក្នុងភូមិផ្សេងគ្នាទាំងអស់នោះដែរឬទេ? ឆ.៤៖ ទេ ខ្ញុំមិនចាំទេ។’) ឆ.៥-ឆ.៦ (‘ស៖ តើលោកស្រីចង់ឲ្យខ្ញុំជួយឲ្យលោកស្រីចងចាំអំពីរឿងនេះដែរឬទេ? ឆ.៥៖ ចាស។ កំណត់សម្គាល់អ្នកស៊ើបអង្កេតចំពោះប្រាក់ យុត៖ យោងតាមព័ត៌មានដែលយើងដឹងគឺ៖ ច្រកស្តៅ ២០គ្រួសារ វាលគ្រៀល ៣០គ្រួសារ ទ្រាន ៣០គ្រួសារ ភូមិត្រពាំងតាសុខ ៣០គ្រួសារ ច្រនៀង ៣០គ្រួសារ ប្រថង ១៥គ្រួសារ ប៉ែន ៣០គ្រួសារ ទួលចំបក់ ១៥ គ្រួសារ ត្រពាំងអំពិល ២០-៣០គ្រួសារ តាខុង ២០គ្រួសារ ទួលត្រាច ១០គ្រួសារ ពោន ២២-២៣គ្រួសារ។ ប្រសិនបើយើងគិតថាជាមធ្យមគ្រួសារមួយមានសមាជិកចំនួន ៦ នាក់ ដូច្នេះ ចំនួនជនជាតិចាមសរុបដែលរស់នៅក្នុងឃុំទ្រានគឺប្រមាណ ១៦០០ នាក់។ ស៖ តើលោកស្រីគិតថា ចំនួននេះសមស្របដែរឬទេ? ឆ.៦ ចាស សមស្រប’), ឆ.៨ (‘ឆ ស៖ តើលោកស្រីដឹងដែរឬទេថាប្រជាជនចាមទាំងនោះត្រូវបានគេចាប់ខ្លួន និងយកទៅសម្លាប់? ឆ.៨ ចាស ខ្ញុំសូមបញ្ជាក់ថា ខ្ញុំបានទទួលបញ្ជាពីថ្នាក់តំបន់ ដើម្បីចាប់ខ្លួន និងសម្លាប់ជនជាតិចាមទាំងអស់’). ឯកសារ **D219/138** (កំណត់ហេតុនៃការស្តាប់

(ខ) ធ្វើការសន្ទនាក្រៅផ្លូវការមុនពេលយក កំណត់ហេតុស្តាប់ចម្លើយ[165] (គ) ខកខានមិនបានសួរសាក្សីឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីអំពីប្រភពនៃភ័ស្តុតាង[166]។

**iv. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានជាប្រព័ន្ធមិនផ្តល់ភ័ស្តុតាងស៊ីសង្វាក់ដើម្បីគាំទ្រសំអាងហេតុ**

77. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដែលផ្អែកជាប្រព័ន្ធទៅលើសដំណើររឿងតែមួយ និងមិនមានសម្លាងរបស់ សាក្សី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីគាំទ្រអង្គហេតុជាក់ស្តែងដែលរំលេចសំអាងហេតុយុត្តាធិការបុគ្គល ដែលវិធីនេះមានលក្ខណៈប្រាសចាកឆ្ងាយពីលក្ខខណ្ឌបទដ្ឋានភ័ស្តុតាង[167]។ ទោះបីជានៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះ

---

ចម្លើយសាក្សី យូ វ៉ាន់), ឆ.៥១។ ឆ.៤៥ ('សះ តើ ប្រាក់ យុត មានសិទ្ធិផ្លាស់ប្តូរមេឃុំដែរឬទេ ឬក៏គាត់សុំការអនុញ្ញាតពី តាអាន? ឆ.៤៥៖ បទបញ្ជាច្បាស់ជាចេញពី តាអាន ហើយព្រោះគាត់ជាប្រធានតំបន់')។

[165] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥២៣ ជើងទំព័រ ១៧២៧ (ដកស្រង់ ឯកសារ **D219/116** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពិន ពៅ), ឆ.៥៤ (ពិន ពៅ លើកឡើងថា 'លោកប្រាប់យើងថា មានមនុស្សជាងមួយម៉ឺននាក់ត្រូវបានកាប់សម្លាប់នៅទីនោះ [មន្ទីរសន្តិសុខ]។ គឺវាត្រឹមត្រូវដែរ'។ កិច្ចសន្ទនានេះមិនត្រូវបានកត់ត្រាត្រឹមត្រូវនៅក្នុងកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីនោះឡើយ))។

[166] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៥ ជើងទំព័រ ៦៣២ (ដកស្រង់ ឯកសារ **D107/5** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ិន គឹមអេង), ឆ.២៨ (ត្រង់ ឆ.២៧ អ៊ិន គឹមអេង លើកឡើងថា អោ អាន គឺជាលេខារបស់ កែ ពក។ ក.ស.ច.ស មិនបានសួរថាតើមូលដ្ឋាននៃការដឹងឮនេះទេ។ កិច្ចសម្ភាសន៍នេះបានបញ្ឈប់ភ្លាមៗក្រោយការឆ្លើយឆ្លងគ្នាបែបនេះ។ ត្រង់ ឆ.២៦ សាក្សីទទួលស្គាល់ថា គាត់មិនដែលបានឃើញ អោ អាន នោះទេ)) កថាខណ្ឌ ២៥២ ជើងទំព័រ ៦២០ (ដកស្រង់ ឯកសារ **D107/15** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី បាន សៀក), KH 00800953-54 ទំព័រ ២-៣ (បាន សៀក លើកឡើងថា អោ អាន គឺជាអនុលេខាភូមិភាគកណ្តាល។ អ្នកស៊ើបអង្កេត ក.ស.ច.ស មិនបានព្យាយាមបង្ហាញមូលដ្ឋាននៃការដឹងឮនោះទេ ហើយបញ្ហាចោទខាងក្រោមពាក់ព័ន្ធនឹងប្រធានបទមួយទៀត។ ត្រង់ KH 00800955-56 ទំព័រ ៤ បាន សៀកក បញ្ជាក់ថា គាត់មិនដែរឃើញ អោ អាន ហើយបានជួបគាត់នៅក្រោយឆ្នាំ១៩៧៩ តែប៉ុណ្ណោះ ដូច្នេះធ្វើឲ្យប្រភពនៃការដឹងឮមិនច្បាស់))។

[167] ស.ច.ស.អ សំអាងលើចម្លើយមិនស៊ីសង្វាក់គ្នារបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីកំណត់ទិដ្ឋភាពផ្សេងៗនៃយុត្តាធិការបុគ្គល៖ ញ៉ែម ចេន៖ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៣ ជើងទំព័រ ៧១២, ៧១៤ កថាខណ្ឌ ២៧៦ ជើងទំព័រ ៧២២ កថាខណ្ឌ ២៧៧ ជើងទំព័រ ៧២៣-៧២៦ កថាខណ្ឌ ២៧៨ ជើងទំព័រ ៧២៧-៧២៩ កថាខណ្ឌ ២៧៩ ជើងទំព័រ ៨៣១-៧៣៣, ៧៣៥ កថាខណ្ឌ ២៨៣ ជើងទំព័រ ៧៣៩ កថាខណ្ឌ ២៨៥ ជើងទំព័រ ៧៤១ កថាខណ្ឌ ២៨៦ ជើងទំព័រ ៧៤៤-៧៤៥ កថាខណ្ឌ ២៨៧ ជើងទំព័រ ៧៤៦ កថាខណ្ឌ ២៩៤ ជើងទំព័រ ៧៧០ កថាខណ្ឌ ២៩៩ ជើងទំព័រ ៧៩២ កថាខណ្ឌ ៣០១ ជើងទំព័រ ៨០០-៨០៣ កថាខណ្ឌ ៣៩៤ ជើងទំព័រ ១១៦៦-១១៦៨ កថាខណ្ឌ ៣៩៦ ជើងទំព័រ ១១៧៩-១១៨០ កថាខណ្ឌ ៤០៦ ជើងទំព័រ ១២២៥-១២២៦ កថាខណ្ឌ ៥០៣ ជើងទំព័រ ១៦៥៦ កថាខណ្ឌ ៥៣៦ ជើងទំព័រ

តុលាការកំពូលសម្រេចថាគ្មានវិធានទូទៅ តម្រូវថាសំអាងហេតុត្រូវតែគាំទ្រដោយភ័ស្តុតាងមួយឬច្រើនក៏ដោយ ក៏អង្គជំនុំជម្រះតុលាការកំពូលចាត់ ទុកថាវត្តមាននៃភ័ស្តុតាងគាំទ្រគឺមានសារៈសំខាន់នៅពេលសម្រេចថាតើសំអាងហេតុរបស់អង្គជំនុំជម្រះ សាលាដំបូងមានហេតុផលក្នុងន័យភាពពាក់ព័ន្ធ និង ភាពអាចជឿជាក់បាន[168]។ ការអនុវត្តនិងយុត្តិសាស្ត្រ នៅតុលាការអន្តរជាតិក៏លើកឡើងអំពីភាពពាក់ព័ន្ធនៃការគាំទ្រដែរ[169]។ ស្រដៀងគ្នានេះដែរ សារៈសំខាន់នៃការគាំទ្របញ្ជាក់ គឺ

---

១៧៨៩-១៧៩០ កថាខណ្ឌ ៥៤៦ ជើងទំព័រ ១៨២២-១៨២៤ កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៩៩៦។ ប្រាក់ យុត៖ កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៤ កថាខណ្ឌ ៣១៨ ជើងទំព័រ ៨៤២-៨៤៤ កថាខណ្ឌ ៣៦៣ ជើងទំព័រ ១០២៨-១០២៩ កថាខណ្ឌ ៣៦៤ ជើងទំព័រ ១០៣០-១០៣១, ១០៣៣-១៣៣៧ កថាខណ្ឌ ៤៥៥ ជើងទំព័រ ១៤០៦ កថាខណ្ឌ ៦២០ ជើងទំព័រ ២០៩៥-២០៩៨ កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥៣-២១៥៤ កថាខណ្ឌ ៦៣៤ ជើងទំព័រ ២១៦៤-២១៦៨ កថាខណ្ឌ ៦៣៥ ជើងទំព័រ ២១៧១-២១៧២ កថាខណ្ឌ ៦៣៦ ជើងទំព័រ ២១៧៥។ ពេញ វ៉ា៖ កថាខណ្ឌ ២៤៧ ជើងទំព័រ ៦០៣ កថាខណ្ឌ ២៩៣ ជើងទំព័រ ៧៦៦-៧៦៨ កថាខណ្ឌ ៣០០ ជើងទំព័រ ៧៩៣, ៧៩៥-៧៩៧។ យូ វ៉ាន់៖ កថាខណ្ឌ ៣១១ ជើងទំព័រ ៨៣១ កថាខណ្ឌ ៣១៨ ជើងទំព័រ ៨៤៥ កថាខណ្ឌ ៤២៧ ជើងទំព័រ ១៣២៣ កថាខណ្ឌ ៤៣១ ជើងទំព័រ ១៣៣៧ កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៦១ កថាខណ្ឌ ៦៣៦ ជើងទំព័រ ២១៧៣-២១៧៤ កថាខណ្ឌ ៦៨៥ ជើងទំព័រ ២៣៥៧-២៣៥៨។ ពេជ្រ ជឹម៖ កថាខណ្ឌ ២៥១ ជើងទំព័រ ៦១៨ កថាខណ្ឌ ២៧៩ ជើងទំព័រ ៧៣០។ សាវ៉ាយ ប៊ាន៖ កថាខណ្ឌ ២៥៥ ជើងទំព័រ ៦៣១។ អ៊ុំ ដារ៖ កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥៥ កថាខណ្ឌ ៣០៨ ជើងទំព័រ ៨២៥-៨២៧។ ទុយ មៀច៖ កថាខណ្ឌ ២៦៧ ជើងទំព័រ ៦៨០ កថាខណ្ឌ ២៨៤ ជើងទំព័រ ៧៤០ កថាខណ្ឌ ៣១៨ ជើងទំព័រ ៨៤៦ កថាខណ្ឌ ៥៦៤ ជើងទំព័រ ១៩០៧ កថាខណ្ឌ ៦៨៥ ជើងទំព័រ ២៣៥៦, ២៣៥៩។ តូ សែម៖ កថាខណ្ឌ ២៧១ ជើងទំព័រ ៧០២។ ម៉ូវ៖ កថាខណ្ឌ ២៧២ ជើងទំព័រ ៧០៦។ សួរ សារេន៖ កថាខណ្ឌ ២៩០ ជើងទំព័រ ៧៥៤-៧៥៩។ សេង ស្រ៊ុន៖ កថាខណ្ឌ ២៩៨ ជើងទំព័រ ៧៩១ កថាខណ្ឌ ៣០៤ ជើងទំព័រ ៨១៧ កថាខណ្ឌ ៤៩១ ជើងទំព័រ ១៥៩៦-១៥៩៨។ កែ ពេជ្រវណ្ណៈ៖ កថាខណ្ឌ ៣០០ ជើងទំព័រ ៧៩៨-៩៩។ ហូ ហឿន៖ កថាខណ្ឌ ៣២៧ ជើងទំព័រ ៨៩២ កថាខណ្ឌ ៣៤៤ ជើងទំព័រ ៩៦៣។ ផន សុផល៖ កថាខណ្ឌ ៣៣០ ជើងទំព័រ ៩០២-៩០៤ កថាខណ្ឌ ៣៤៧ ជើងទំព័រ ៩៨០។ ហ៊ុង ហេង៖ កថាខណ្ឌ ៣៣២ ជើងទំព័រ ៩១២។ អ៊ឹម ប៊ុន៖ កថាខណ្ឌ ៤១១ ជើងទំព័រ ១២៣៧។ អន គឹម អេង៖ កថាខណ្ឌ ៥៤៥ ជើងទំព័រ ១៨២០។ តូច ចំរើន៖ កថាខណ្ឌ ៦៨០ ជើងទំព័រ ២៣៣៣។

[168] សំណុំរឿង ០០២-ឯកសារ **F36** កថាខណ្ឌ ៤១៩, ៤២៤, ៤២៨,-៤៣០, ៤៣៣-៤៣៥, ៤៥៧, ៤៧៤-៤៧៦។

[169] ទោះបីជានៅតុលាការ ICC, ក៏មានវិធានស្តីពីសក្ខីកម្មស៊ីសង្វាក់គ្នាផងដែរ ករណីខ្វះតម្រូវនីតិវិធីនេះ។ *សូមមើល* វិធានស្តីពីភ័ស្តុតាង និងនីតិវិធីនៃតុលាការឧក្រិដ្ឋកម្មអន្តរជាតិ ICC-PIDS-LT-02-002/13_Eng, ថ្ងៃទី៣-១០ ខែកញ្ញា ឆ្នាំ២០០២, វិធាន ៦៣(៤) ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤៨ (លើកឡើងថា អង្គជំនុំជម្រះមិនអាចត្រូវការចំណុចស៊ីសង្វាក់គ្នាដើម្បីបង្ហាញឧក្រិដ្ឋកម្មនៅក្នុងយុត្តាធិការពេលវេលា ជាពិសេស បទល្មើសនៃអំពើហិង្សាផ្លូវភេទនោះទេ)។ រឿងក្តី*រដ្ឋអាជ្ញា តទល់នឹង Ruto, Kosgey និង Sang*, សំណុំរឿងលេខ ICC-01/09-01/11, *សេចក្តីសម្រេចលើការតម្កល់បទចោទអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលន្តិក:ទីក្រុងរ៉ូម* ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ២៩៣-២៩៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៤៩ (បដិសេធបញ្ជាក់បទចោទប្រឆាំងនឹងចុងចោទដោយផ្អែកលើសក្ខីកម្មតែមួយគត់ពីសាក្សីអនាមិកដែលមិនស៊ីសង្វាក់គ្នា អំពីតួនាទីរបស់ចុង

មានលក្ខណៈច្បាស់លាស់ពីយុត្តិសាស្ត្រនៃយុត្តាធិការច្បាប់ស៊ីវិលជាតិដទៃៗទៀត[170]។

## v. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានប្រុងប្រយ័ត្នក្នុងការផ្អែកលើភ័ស្តុតាងចចាមអារ៉ាម

78. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកជានិច្ចទៅលើភ័ស្តុតាងចចាមអារ៉ាម ក្នុងនោះរួមមានប្រភពមិនស្គាល់[171] ក្នុងការធ្វើ សំអាងហេតុពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលរបស់តុលាការលើ អោ

ចោទនៅក្នុងអង្គការចាត់តាំង)។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Ruto *និង* Sang, សំណុំរឿង ICC-01/09-01/11, *សេចក្តីសម្រេចលើពាក្យសុំរបស់មេធាវីការពារក្តី សុំសាលក្រមសម្រេចឱ្យរួចផុតពីបទចោទ សំអាងហេតុរបស់ចៅក្រម* Fremr ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ៥៦-៥៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥០ (រកឃើញថា មានតែសាក្សីតែម្នាក់គត់ ដែលលើកឡើងមិនស៊ីសង្វាក់គ្នាអំពីការចោទប្រកាន់ជាក់លាក់ ភ័ស្តុតាងពុំ 'ផ្តល់មូ(លដ្ឋានរឹងមាំចាំបាច់ដែលល [អង្គជំនុំជម្រះសមហេតុផល] អាចសំអាងលើការផ្តន្ទាទោសសមស្រប')។ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06, *សេចក្តីសម្រេចលើការតម្កល់បទចោទ* ('*សេចក្តីសម្រេច* Lubanga *លើការតម្កល់បទចោទ*') ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ កថាខណ្ឌ ១២១-១២២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥១ (អនុវត្តតាមយុត្តិសាស្ត្ររបស់តុលាការ ICTR, អង្គបុរេជំនុំជម្រះទី I បានសម្រេចថា ជាទូទៅ ខ្លួនភ្ជាប់តម្លៃភ័ស្តុតាងនេះទៅសក្ខីកម្មត្រង់ផ្នែកទាំងឡាយដែលស៊ីសង្វាក់គ្នាប៉ុណ្ណោះ។

[170] Best, 'Fair and Accurate Fact-Finding in Dutch Atrocity Crimes Cases' (University of Amsterdam: Amsterdam Center for International Law ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ២០១៦) ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥២។ ក្រមនីតិវិធីព្រហ្មទណ្ឌ s342(2) (ប្រទេសហូឡង់ដ៏), ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥៣ (លើកឡើងថា '[តុ]លាការមិនអាចសម្រេចថា ភ័ស្តុតាងបញ្ជាក់ចុងចោទបានប្រព្រឹត្តបទល្មើសដែលចោទប្រកាន់នៅក្នុងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះ ដោយផ្អែកលើមូលដ្ឋានចម្លើយរបស់សាក្សីតែមួយប៉ុណ្ណោះទេ')។

[171] ស.ច.ស.អ សំអាងលើចម្លើយចចាមរ៉ាម ដើម្បីបង្ហាញសំអាងហេតុសំខាន់ៗពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២១៧ ជើងទំព័រ ៤៩៩ (ស.ច.ស.អ រកឃើញថា ការកាប់សម្លាប់មានការកើនឡើងច្រើនក្រោយ អោ អាន បានមកដល់ភូមិភាគនិរតី និងដកស្រង់ ញ៉ែម ចេន ដែលលើកឡើងថា គាត់បានឮអំពីបញ្ជាសម្លាប់ពីកងការពារគ្មានឈ្មោះ ដែលត្រូវបានអះអាងថាជាក្មួយរបស់ កែ ពក) កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣ (ស.ច.ស.អ រកឃើញថា អោ អាន បានតែងតាំង និងដកកម្មាភិបាល ហើយសំអាងលើ ពេញ វ៉ា ចំពោះការអះអាងនេះ។ ពេញ វ៉ា លើកឡើងថា គាត់ 'បានដឹងអំពីការចាប់ខ្លួនប្រធានឃុំ និងអនុរបស់គាត់តាមពាក្យល្បែចល្បៀង' ពេញ វ៉ា មិនបានបង្ហាញថានរណាលើកឡើងចម្លើយទាំងនេះទេ) កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥៥ (ស.ច.ស.អ រកឃើញថា កម្មាភិបាលស្រុកត្រូវបានបញ្ជាឱ្យចងក្រងបញ្ជីឈ្មោះមនុស្សដែលត្រូវបានចាប់ខ្លួន និងសម្លាប់ចោល ហើយសំអាងលើ ពៅ សារ៉ុម។ ពៅ សារ៉ុម លើកឡោះងថា 'ស្ត្រីចំណាស់ម្នាក់បានប្រាប់ខ្ញុំថា ប្រជាជនចាម គេទុកជីវិតឱ្យ' ប៉ុន្តែពុំបានកំណត់អត្តសញ្ញាណមនុស្សស្រីនោះទេ) កថាខណ្ឌ ២៥២ ជើងទំព័រ ៦២០ (ពាក់ព័ន្ធនឹងតួនាទីរបស់ អោ អាន ជាអនុលេខាភូមិភាគកណ្តាល ស.ច.ស.អ សំអាងលើ រី ណោ ដែលលើកឡើងថា គាត់បានដឹងពី'ប្រធានកង' ថា តាអាន គឺជាអនុលេខាភូមិភាគ។ គាត់មិនប្រាកដថាតើប្រធាននេះឈ្មោះឃឿន ឬ ធី នោះទេ) កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣ (ពាក់ព័ន្ធនឹងការតែងតាំង និងការដកកម្មាភិបាលដែលចោទប្រកាន់លើ អោ អាន ស.ច.ស.អ សំអាងលើ ពេញ វ៉ា ដែលលើកឡើងថា '[គាត់] បានដឹងអំពីការចាប់ខ្លួនមេឃុំ និងអនុ តាមពាក្យល្បែចល្បៀង')។

អាន[172]។ ទោះបីជាភ័ស្តុតាងចចាមអារ៉ាម អាចត្រូវបានទទួលយក និងពិចារណាក៏ដោយ ក៏ភ័ស្តុតាងបែបនេះគួរមានតម្លៃភ័ស្តុតាងតិចជាង ហើយចាំបាច់ត្រូវមានការប្រុងប្រយ័ត្នក្នុងការវាយតម្លៃលើភ័ស្តុតាងនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនមានការប្រុងប្រយ័ត្នបែបនេះឡើយ[173]។

---

[172] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣ (ពាក់ព័ន្ធនឹងការតែងតាំងរបស់ អោ អាន និងការដកកម្មាភិបាល ស.ច.ស.អ សំអាំងលើចម្លើយរបស់ យូ វ៉ាន់ និង ពេញ វ៉ា អ្នកទាំងពីរបានសំអាងលើពាក្យចចាមរ៉ាម) កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៦ (ពាក្យព័ន្ធនឹងការគ្រប់គ្រងលើការដ្ឋានរបស់ អោ អាន ស.ច.ស.អ សំអាងលើចម្លើយរបស់ យូ វ៉ាន់ ដែល ប្រាក់ យុត ជាអ្នកផ្ដល់ព័ត៌មាន) កថាខណ្ឌ ២៥៧ ជើងទំព័រ ៦៤០ (ពាក់ព័ន្ធនឹង អោ អាន បានទទួលរបាយការណ៍ពីថ្នាក់ក្រោម ស.ច.ស.អ សំអាងលើ យូ វ៉ាន់ ដែលបានទទួលព័ត៌មានរបស់គាត់ពី ផែន និង នី) កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤២ (ពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ អោ អាន លើយោធាស្រុក ស.ច.ស.អ សំអាងលើ យូ វ៉ាន់ ដែល នី ជាអ្នកប្រាប់ព័ត៌មាននេះ) កថាខណ្ឌ ៣១៦ ជើងទំព័រ ៨៣៩ (ពាក់ព័ន្ធនឹងសិទ្ធិអំណាចរបស់ អោ អាន លើអាពាហ៍ពិពាហ៍តំបន់ និងការឃោសនាគោលនយោបាយអាពាហ៍ពិពាហ៍ ស.ច.ស.អ សំអាំងលើ យូ វ៉ាន់ ដែល ប្រាក់ យុត ជាអ្នកប្រាប់ព័ត៌មាននេះ) កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥២, ២១៥៦, ២១៥៧, ២១៥៩, ២១៦១ (ពាក់ព័ន្ធនឹងបញ្ជារបស់ អោ អាន ឲ្យចាប់ខ្លួនប្រជាជនចាម ស.ច.ស.អ បានសំអាងលើប្រជាជនចាម ស.ច.ស.អ សំអាំងលើ ញឹម កុល ដែល 'បានឮថា ប្រាកក់ យុត បានប្រាប់ រ៉ុម' អំពីការណែនាំ ហើយក៏សំអាងលើ យូ វ៉ាន់ ដែល ខុំ ជាអ្នកប្រាប់ព័ត៌មាននេះ)។

[173] ស.ច.ស.អ សំអាងលការលើកឡើងនូវពាក្យចចាមរ៉ាមពីរដងដើម្បីគាំទ្រការរកឃើញរបស់ខ្លួនថា អោ អាន បានបញ្ជាឲ្យដឹកជញ្ជូនប្រជាជន "យកទៅកំទេចចោល"។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០០ ជើងទំព័រ ៧៩៩ (ស.ច.ស.អ លើកឡើងថា កែ ពេជ្រវណ្ណៈ បានឃើញឡានចំនួន ១០ គ្រឿង ដឹកមនុស្សទៅវត្តភ្នំប្រុសភ្នំស្រី និង 'បានរាយការណ៍អំពីហេតុការណ៍ [នេះ] ទៅឪពុករបស់គាត់ឈ្មោះ កែ ពពក ដែលបានសាកសួរជាមួយ វ័យ រាប ប្រធាកងពលយោធានៅក្នុងភូមិភាគកណ្ដាល ដែលបានលើកឡើងថា [...] "បង [អោ] អាន ... [បាន] ចេញបញ្ជាដឹកមនុស្សទៅទីនោះដើម្បីកំទេចចោល"' កែ ពេជ្រវណ្ណៈបានទទួលព័ត៌មាននេះពីឪពុករបស់គាត់ កែ ពក ដែលបានទទួលព័ត៌មាននេះពី វ័យ រាប។ ឯកសារ **D6.1.379** (កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី កែ ពេជ្រវណ្ណៈ), KH 00340571-72)។ ស.ច.ស.អ ក៏ខកខានមិនបានប្រុងប្រយ័ត្ននៅពេលសំអាងលើពាក្យចចាមរ៉ាមពីសាក្សីដែលមិនអាចជឿជាក់បាន ឬ ដែលឆ្លើយមិនស៊ីសង្វាក់គ្នា។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥៣ (ស.ច.ស.អ រកឃើញថា អោ អាន បានចូលរួមប្រជុំនៅភ្នំពេញ។ នៅពេលសម្រេចដូច្នេះ គាត់បានសំអាងលើការរៀបរាប់របស់ យូ វ៉ាន់ ដែលជាពាក្យចចាមរ៉ាមពី ប្រាក់ យុត សាក្សីលម្អៀង និងមិនអាចជឿជាក់បាន។ ឯកសារ **D219/702.1.87** (ប្រតិចារឹក យូ វ៉ាន់), KH 01451946, 01438503 ទំព័រ ៤៦ 62) កថាខណ្ឌ ២៦៧ ជើងទំព័រ ៦៨០ (ស.ច.ស.អ រកឃើញថា អោ អាន បានជម្រុញនូវប្រព័ន្ធសហករណ៍តំបន់ ដោយធ្វើដំណើរនៅតាមសហករណ៍តំបន់ ៤១ ភូមិ និងស្រុក ដើម្បីវាយតម្លៃការបំពេញការងារ។ គាត់សំអាងលើភ័ស្តុតាងចចាមរ៉ាមពី តួយ មៀច ដែលបានដឹងព័ត៌មាននេះ 'ពីមន្ទីរពាណិជ្ជកម្មដែលរៀបចំការផ្គត់ផ្គង់'។ ឯកសារ **D219/582** (កំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី តួច មៀច), ឆ.៦៦-ឆ.៦៨) កថាខណ្ឌ ៣៣០ ជើងទំព័រ ៩០៦ (ស.ច.ស.អ លើកឡើងថា សាក្សីម្នាក់បានផ្ដល់របាយការណ៍អំពីការបែងចែកអង្ករទៅប្រពន្ធរបស់គាត់ដែលបានឲ្យទៅ អោ អាន។ តាមការពិត ភ័ស្តុតាងនេះគឺជាពាក្យចចាមរ៉ាមពី

អង្គជំនុំជម្រះតុលាការកំពូលក្នុងសំណុំរឿង ០២/០១ សម្រេចថា ពាក្យ ចចាមអារ៉ាមមកពីប្រភពអនាមឹក ឬពាក្យចចាមអារ៉ាមត្រួតគ្នាមិនអាចបង្កើតបានជាធាតុផ្សំនៃបទល្មើស ឬទម្រង់នៃការទទួលខុសត្រូវហួសពីវិមតិសង្ស័យបានឡើយ[174]។ ទោះបីជាមេធាវីការពារក្តីទទួលស្គាល់បទដ្ឋាននៃភ័ស្តុតាងមានកម្រិតទាបនៅដំណាក់កាលដីកាដំណោះស្រាយ ជាងនៅក្នុងដំណាក់កាលជំនុំជម្រះក្តី ប៉ុន្តែការកម្រិតស្រដៀងគ្នាត្រូវតែអនុវត្តពាក់ព័ន្ធនឹងភ័ស្តុតាងប្រភេទនេះនៅពេលកំណត់ភាពគ្រប់គ្រាន់នៃ ភ័ស្តុតាងគាំទ្រយុត្តាធិការបុគ្គល ឬដីកាបញ្ជូនរឿងទៅជម្រះ។

### vi. សេចក្តីសន្និដ្ឋានលើសំអាងហេតុទី៥

79. សរុបមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដែលមិនអើពើដល់ការសម្រេចក្នុងករណី០០៤/១ថ្មីៗនេះ និងបន្តប្រ កាន់យកវិធីសាស្ត្រយកទម្រង់ធំជាងខ្លឹមសារ ចំពោះការវាយតម្លៃភ័ស្តុតាង ដោយគ្មានមូលដ្ឋានច្បាប់។ ក្នុងការខកខានមិនបានវាយតម្លៃខ្លឹមសារភ័ស្តុតាង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើលើបញ្ហាដ៏ធំនៃភាពគួរឲ្យជឿទុកចិត្ត របស់សាក្សី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី វិធីសាស្ត្រគួរឲ្យសង្ស័យនៃការយក ភ័ស្តុតាងដោយអ្នកស៊ើបអង្កេត កង្វះភ័ស្តុតាងសម្ភារៈដែលគាំទ្រសំអាងហេតុយុត្តាធិការបុគ្គល និង ភាពចាំបាច់ក្នុងការប្រុងប្រយ័ត្ននៅពេលផ្អែកលើភ័ស្តុតាងចចាមអារ៉ាម។

### ខ. សំអាងហេតុទី៦÷ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការរកឃើញថា អោ អាន មានមុខតំណែង កាន់តែសំខាន់នៅ ក្នុង បក្សកុម្មុយនីស្តកម្ពុជា និង ដើរតួនាទីនៅក្នុងបទល្មើសធ្ងន់ធ្ងរបំផុត ជាងមន្ត្រីខ្មែរក្រហម ដទៃទៀតដែលគេស្គាល់

80. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការរកឃើញថា អោ អាន មានមុខតំណែងបក្សកុម្មុយនីស្តកម្ពុជា កាន់តែសំខាន់ និង មាន តួនាទីក្នុងបទល្មើសធ្ងន់ធ្ងរបំផុតនៅក្នុងភូមិភាគកណ្តាល និង តំបន់៤១ ពីឆ្នាំ១៩៧៧ ដល់ឆ្នាំ១៩៧៩ ជាង មន្ត្រីខ្មែរក្រហមដទៃៗទៀតដែលគេស្គាល់។ តាមពិត អោ អាន មិនមានមុខនាទីសំខាន់នៅក្នុងភូមិភាគកណ្តាល ឬតំបន់៤១ឡើយ ហើយ

ប្រពន្ធរបស់សាក្សី។ ឯកសារ D219/435 (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី តូច ចំរើន), ឆ.១៨៨-១៩០, ឆ.១៩៦, ឆ.២៣៦-២៣៩)។

[174] សំណុំរឿង ០០២-ឯកសារ F36 កថាខណ្ឌ ៤៤១-៤២។

មិនមានតួនាទីនៅក្នុងបទល្មើសណាមួយដែលបានចោទប្រកាន់នោះដែរ។ ដូចដែល បានពន្យល់នៅក្នុង ផ្នែកទីII (ខ) (iv) មិនដូច សហចៅក្រមស៊ើបអង្កេតជ ទេ គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានធ្វើការប្រៀបធៀបពិតប្រាកដរវាង អោ អាន ជាមួយនឹងមន្ត្រីខ្មែរក្រហមដទៃទៀតដែលគេស្គាល់ឡើយ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កម្រិតការវិភាគបែបប្រៀបធៀបដែលមិនអាចពន្យល់បានទៅនឹង ឌុច និង អ៊ឹម ចែម[175]។

81. ការវិភាគស៊ីជម្រៅទៅលើភស្តុតាង បង្ហាញថា អោ អាន មិនបានសម្រេច ឬបកស្រាយគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា ឡើយ ហើយថា គាត់ មិនមែនជាឧបករណ៍ផ្សព្វផ្សាយ ឬអនុវត្តគោលនយោបាយទាំង នេះនៅក្នុងភូមិភាគកណ្តាលឬតំបន់៤១ឡើយ។ ជាងនេះទៀត គាត់មិនរៀបចំផែនការ សហការ ឬដឹកនាំ ការបោសសម្អាតអតីតកម្មាភិបាលភូមិភាគកណ្តាល ឬជនស៊ីវិលពីចុងឆ្នាំ១៩៧៦ ដល់ខែ កុម្ភៈ ឆ្នាំ១៩៧៧ ទេ។ អោ អាន មិនមែនជាលេខាស្តីទីនៃភូមិភាគកណ្តាល នៅពេល កែ ពក អវត្តមាន។ គាត់មិនមាន មុខនាទីជាអនុលេខាភូមិភាគកណ្តាលតាមច្បាប់ និង តាមព្រឹត្តិន័យឡើយ ឬជាលេខាតំបន់៤១ តាមនីតិន័យ ឬព្រឹត្តិន័យទេ។ ហើយបោះទោះជាគាត់មានមុខនាទីទាំងនេះក្តី ក៏មុខនាទីទាំងនេះមិនមែនជាមុខនាទីសំខាន់ ក្នុង បក្សកុម្មុយនីស្តកម្ពុជា នោះទេ បើប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមដទៃៗទៀតដែលគេស្គាល់។ អោ អាន មិនមែនជា អ្នកទទួលខុសត្រូវលើអំពើប្រល័យពូជសាសន៍នៅក្នុងភូមិភាគនោះ អាពាហ៍ពិពាហ៍ ឬការរំលោភសេពសន្ថវៈនៅក្នុងស្រុកព្រៃឈរ ឬ កំពង់សៀម ឬទទួលខុសត្រូវចំពោះបទល្មើសដែលបានចោទប្រកាន់ នៅទីតាំងបទល្មើសទាំងនោះទេ។ បើទោះជាមានភស្តុតាងគ្រប់គ្រាន់អំពីការទទួលខុសត្រូវ របស់គាត់ក្តី ក៏ភស្តុតាងគាំទ្រការលើកឡើងរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងការសន្និដ្ឋានអំពីចំនួនជនរងគ្រោះ នៅក្នុងភូមិភាគកណ្តាលមានមានលក្ខណៈគ្រប់គ្រាន់ដែរ។ ហេតុដូចនេះ អោ អាន មិនស្ថិតនៅក្នុងចំណោមជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុត និងស្ថិតក្នុងយុត្តាធិការបុគ្គលរបស់តុលាការដែរ។

### i. អោ អាន មិនបានកំណត់ ឬបកស្រាយគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា ទេ

82. សិទ្ធិអំណាចក្នុងការកំណត់គោលនយោបាល បក្សកុម្មុយនីស្តកម្ពុជា និង មធ្យោបាយក្នុងការអនុវត្ត

---

[175] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៦៩។

ឬបកស្រាយ គឺ កម្រិតតែចំពោះគណៈអចិន្ត្រៃយ៍ និង សេនាធិការនៅភ្នំពេញ[176]តែប៉ុណ្ណោះ ដែល អោ អាន មិនមែនជា សមាជិកឡើយ។ ទាំង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាំង កសព សុទ្ធតែមិនបានផ្តល់ភ័ស្តុតាងផ្ទុយណាមួយឡើយ។

## ii. អោ អាន មិនមែនជាឧបករណ៍ក្នុងការអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា បើប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហមដទៃៗទៀត ដែលគេស្គាល់

83. ជាការផ្ទុយទៅនឹងសំអាងហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អោ អាន មិនមែនជា "អ្នកដើរតួសំខាន់"នៅក្នុង រចនាសម្ព័ន្ធ កប" ឬ ជា "អ្នកចូលរួមដែលមានឆន្ទៈ ឬមានការជំរុញនៅក្នុងការអនុវត្តបែបឃោរឃៅ និង ឧក្រិដ្ឋកម្ម នៅក្នុងគោលនយោបាយរបស់ខ្លួនឡើយ[177]។ បើប្រៀបធៀបទៅនឹងមន្ត្រីខ្មែរក្រហម ដូចជា ឌុច កែ ពក តា ម៉ុក និង សៅ សារុន អោ អាន មិនមែនជាឧបករណ៍ក្នុងការអនុវត្តគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជា នោះឡើយ។

84. ទី១ អោ អាន មិនបានធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយគណៈអចិន្ត្រៃយ៍ ឬសេនាធិការ នៅភ្នំពេញ។ ទាំង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាំង សហព្រះរាជអាជ្ញាអន្តរជាតិ សុទ្ធតែមិនបានផ្តល់ភ័ស្តុតាងណាមួយថា អោ អាន បានបញ្ជូនសំបុត្រឆ្លើយឆ្លង ដោយផ្ទាល់(តាមទេឡេក្រាមឬនិរសារ)ទៅភ្នំពេញទេ។ អោ អាន ក៏មិនមែនជាមេដឹកនាំនៃតំបន់ស្វយ័ត ដូច សៅ សារុន ដែរ ដែល សៅ សារុន ឡើងឋានៈនៅក្នុង កប និងទទួលបញ្ជាដោយផ្ទាល់ពីមន្ត្រីជាន់ខ្ពស់នៅ ក្នុងគណៈអចិន្ត្រៃយ៍ នៅភ្នំពេញ ដូចដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានទទួលស្គាល់[178]។ នៅក្នុងសំអាងហេតុរបស់ខ្លួន ពាក់ព័ន្ធនឹង យុត្តាធិការបុគ្គល សហចៅក្រមស៊ើបអង្កេតជ បានសង្កត់ធ្ងន់

---

[176] សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៤៦៤, ៥២៣។ ឯកសារ **D1.3.15.1** (Craig Etcheson, ឋានានុក្រមនៃរបបកម្ពុជាប្រជាធិបតេយ្យ) កថាខណ្ឌ ១១, ១៩។ ឯកសារ **D1.3.20.1** (លក្ខន្តិកៈ ប.ក.ក ចុះឆ្នាំ១៩៧) មាត្រា ២៣។

[177] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៧១២។

[178] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៦០ (ស.ច.ស.អ រកឃើញថា លេខាតំបន់ស្វយ័ត ឧ. មកពីតំបន់ស្វយ័ត ១០៥ ១០៦ ៥០៥ និងក្រុងកំពង់សោមរំលងមេដឹកនាំភូមិភាគ ហើយរាយការណ៍ផ្ទាល់ទៅមជ្ឈិមនៅក្នុងក្រុងភ្នំពេញ)។ សូមមើលផងដែរ ឯកសារ **D6.1.141** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី សៅ សារុន), KH 00251438-39 (សៅ សារុន គឺជាលេខាតំបន់ស្វយ័ត ១០៥ ហើយពិភាក្សាអំពីការទំនាក់ទំនងផ្ទាល់ និងកិច្ចប្រជុំជាមួយ ប៉ុល ពត និង នួន ជា)។

លើទំនាក់ទំនងដោយផ្ទាល់រវាងមជ្ឈិម និង លេខា តំបន់ស្វយ័តទាំងឡាយ[179]។

85. ទី២ អោ អាន មិនមែនជាអ្នកកំណត់ថាកម្មាភិបាលមួយណាមកពីភូមិភាគកណ្ដាលឬតំបន់៤១ ត្រូវ បញ្ជូនទៅ ស-២១ ទេ ហើយគ្មានភ័ស្តុតាងបង្ហាញថាគាត់ទំនាក់ទំនងឬសហការជាមួយ ឌុច ឬអ្នកដទៃ នៅភ្នំពេញ ពាក់ព័ន្ធនឹងរឿងទាំងនេះឡើយ។ ទាំង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាំង សហព្រះរាជអាជ្ញាអន្តរជាតិ សុទ្ធតែមិនបានផ្តល់ភ័ស្តុតាងផ្ទុយ ឡើយ។ ប្រសិនបើ អោ អាន ជាឧបករណ៍អនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា សេចក្តីសម្រេចបែបនេះនឹងស្ថិត នៅក្នុងការទទួលខុសត្រូវរបស់គាត់។

86. ទី៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏ខកខានផងដែរក្នុងការផ្តល់ភ័ស្តុតាងពិតប្រាកដនិងភ័ស្តុតាងមានការបញ្ជាក់គ្រប់គ្រាន់ដែលបង្ហាញថា អោ អាន បានចូលរួមគណៈអចិន្ត្រៃយ៍ជាន់ខ្ពស់ នៅភ្នំពេញ[180]ជាមួយមេដឹកនាំជាន់ខ្ពស់ដូចជាប៉ុល ពត និង នួន ជា ហើយផ្ទុយមកវិញគឺ ពន្លើសភ័ស្តុតាងពាក់ព័ន្ធនឹងកន្លែងសម្រាកតាមផ្លូវតែមួយនៅភ្នំពេញ ក្នុងការធ្វើដំណើរពីភូមិភាគនិរតី ទៅភូមិភាគកណ្តាល[181]។ ហើយ បើទោះបីជា អោ អានបានចូលរួមប្រជុំទូទៅនៅភ្នំពេញជាមួយកម្មាភិបាលរាប់រយនាក់ក្តី ក៏វត្តមានរបស់គាត់ មិនមានន័យថាគាត់ជាសមាជិកគណៈ អចិន្ត្រៃយ៍ ឬសេនាធិ

---

[179] សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ 272-273។

[180] ក្រៅពីឈប់សម្រាក ស.ច.ស.អ តែងតែលើកឡើងដោយស្រពិចស្រពិលអំពី ‘កិច្ចប្រជុំនៅទីក្រុងភ្នំពេញ’ ដោយសំដៅលើសាក្សីដែលមិនស៊ីសង្វាក់គ្នា និងខកខានមិនបានផ្តល់ភ័ស្តុតាងគ្រប់គ្រាន់អំពីព័ត៌មានលម្អិតជុំវិញការប្រជុំទាំងនេះ។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥៣ (ស.ច.ស.អ សំអាងតែទៅលើសក្ខីកម្មនៅក្នុងការជំនុំជម្រះរបស់ យូ វ៉ាន់ ដែលគាត់បានផ្តល់ភ័ស្តុតាងចចាមអារ៉ាមមិនស៊ីសង្វាក់គ្នារបស់ ប្រាក់ យុត ដែលជាសាក្សីមិនអាចជឿជាក់បាន។ ប្រាក់ យុត បានប្រាប់ យូ វ៉ាន់ ថា អោ អាន បានធ្វើដំណើរតាមឡានជារៀងរាល់ខែ ទៅចូលរួមកិច្ចប្រជុំនៅក្រុងភ្នំពេញ ប៉ុន្តែ យូ វ៉ាន់ ពុំបានស្គាល់ទីតាំងប្រជុំជាក់លាក់ ពួកគេជួបនរណា ឬ ប្រជុំព័ត៌មានលម្អិតអ្វីខ្លះនោះទេ)។

[181] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៣-៤៤ ជើងទំព័រ ៥៩៤-៥៩៥ (ស.ច.ស.អ សំអាងលើ ពេជ្រ ជឹម ដែលឆ្លើយមិនស៊ីសង្វាក់គ្នា ដោយបានលើកឡើងថា គាត់បានធ្វើដំណើរជាមួយ អោ អាន ទៅកាន់ភូមិភាគកណ្តាល ប៉ុន្តែ មិនមែន អោ អាន នៅក្នុងកិច្ចប្រជុំ ហើយលើកឡើងអំពីការផ្តល់ការណែនាំខ្លីមួយ។ ស.ច.ស.អ សំអាងបន្ថែមលើ ប្រាក់ យុត ដែល យោងតាមចម្លើយបីក្នុងចំណោមបួន បដិសេធថា មានការផ្អាកកិច្ចប្រជុំ ហើយ យោងតាម យូ វ៉ាន់ ដែលផ្តល់ចម្លើយមិនស៊ីសង្វាក់គ្នា ថាតើ អោ អាន បានចូលរួមកិច្ចប្រជុំដែរឬទេ ហើយ ក្នុងករណីគាត់បានអះអាងបែបនេះ គឺផ្អែកលើពាក្យចចាមអារ៉ាមប៉ុណ្ណោះ។ ចំណុចចុងក្រោយ ពុត កុល និង ឌើ រ៉ាន់ កត់សម្គាល់ថា មានការផ្អាកនៅក្នុងក្រុងភ្នំពេញ ប៉ុន្តែ ពួកគេលើកឡើងថា ពួកគេពុំដឹងមូលហេតុ ហើយពុំបានលើកឡើងថាការប្រជុំធ្វើនៅទីណានោះទេ)។

ការឡើយ ឬថា គាត់បានកំណត់គោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា ឬ កំណត់មធ្យោបាយ អនុវត្ត និង ផ្សព្វផ្សាយ[182]។

87. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ថា អោ អាន រៀបចំប្រជុំឬ ដឹកនាំប្រជុំនយោបាយ សន្តិសុខ ឬយោធា ឬការបណ្តុះបណ្តាល នៅក្នុងតំបន់៤១ ឬភូមិភាគកណ្តាលដើម្បីផ្សព្វផ្សាយ ឬអនុវត្ត គោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា[183] ហើយបើទោះបីជាគាត់

---

[182] កម្មាភិបាលរាប់រយនាក់អាចទំនងចូលរួមនៅក្នុងផ្អាកនៅក្នុងក្រុងភ្នំពេញ។ ប្រសិនបើវត្តមានគ្រប់អាចសម្រេចលើយុត្តាធិការបុគ្គលបាន កម្មាភិបាលទាំងនេះនឹងចាំបាច់ត្រូវស៊ើបអង្កេត និងចោទប្រកាន់ដោយតុលាការ។ *ឧ.* ឯកសារ **D118/259** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម), ឆ.៧០ (ពេជ្រ ជឹម លើកឡើងថា 'ប្រជាជនដែលបានផ្ទេរទៅភូមិភាគកណ្តាលបានចូលរួមនៅក្នុងកិច្ចប្រជុំនោះ')។ សាក្សីដូចខាងក្រោមបញ្ជាក់ថា ពួកគេក៏មានវត្តមាននៅពេលផ្អាកក្រុងភ្នំពេញ ប៉ុន្តែពួកគេមិនបានលើកឡើងថា កិច្ចប្រជុំបានធ្វើឡើងនោះទេ៖ ឯកសារ **D219/762** (កំណត់ហេតុនៃការស្តាប់ចម្លើយ សាវ៉ាយ ប៊ិាន), ឆ.៣៦-ឆ.៣៨ (សាវ៉ាយ ប៊ិាន រំលឹកអំពី "ការឈប់សម្រាកមួយរយៈពេលខ្លី" ដើម្បីចាក់ប្រេង)។ ឯកសារ **D117/26** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ពុត កុល), ឆ.១-ឆ.២, ឆ.៥-ឆ.៧ (ពុត កុល លើកឡើងថា ប្រាក់ យុត ក៏មានវត្តមាននៅពេលឈប់នោះដែរ)។ ឯកសារ **D117/27** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ឌើ រួន), ឆ.១ (ឌើ រួន លើកឡើងថា ប្រាក់ យុត ក៏មានវត្តមាននៅពេលឈប់សម្រាកនៅតាមផ្លូវ)។ ឯកសារ **D117/28** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កែវ រឿន), ឆ.៥, ឆ.៨ (កែវ រឿន លើកឡើងថា ប្រាក់ យុត ក៏មានវត្តមាននៅពេលឈប់សម្រាកតាមផ្លូវផងដែរ)។ ឯកសារ **D117/29** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ម៉ែន នុន), ឆ.៤-ឆ.៥ (ម៉ែន នុន លើកឡើងថា ប្រាក់ យុត ក៏មានវត្តមាននៅពេលឈប់សម្រាកផងដែរតាមផ្លូវផងដែរ)។ ឯកសារ **D117/39** (កំណត់ហេតុនៃការសួរចម្លើយសាក្សី តូ សែម), ឆ.៨, ឆ.២០ (តូ សែម រំលឹកអំពីការឈប់សម្រាកពីរម៉ោងនៅភ្នំពេញ "ដើម្បីរកបាយហូប")។

[183] ស.ច.ស.អ ចង្អុលបញ្ជាក់អំពីកិច្ចប្រជុំមួយចំនួនតូចអំពីនយោបាយ សន្តិសុខ ឬ យោធានៅក្នុងតំបន់ ៤១ ដែលនីមួយៗគាំទ្រដោយសាក្សី ឬ អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដែលពុំបានឆ្លើយស៊ីសង្វាក់គ្នា។ ជារឿយៗ បុគ្គលទាំងនេះគ្មានភាពអាចជឿជាក់បាន ដូចបានពន្យល់នៅក្នុងផ្នែក II(ឃ)(ii)។ ម្យ៉ាងវិញទៀត ស.ច.ស.អ តែងតែពុំលើកអំពីកិច្ចប្រជុំតែមួយនេះ ដើម្បីគាំត្រការរកឃើញផ្សេងៗគ្នា ដោយពុំបានចង្អុលបញ្ជាក់ថា វាគឺជាកិច្ចប្រជុំតែមួយ ដូច្នេះ បានបំផ្លើសតួលេខប្រជុំដែលអាចកើតឡើង។ *សូមមើល ឧ.* សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៦ ជើងទំព័រ ៦០០ (ពាក់ព័ន្ធនឹងកិច្ចប្រជុំដែល អោ អាន តែងតាំងជាលេខាស្រុក និងបានបញ្ជាពួកគេឲ្យចាត់តាំងបុគ្គលិកយោធា និងស្រុក ស.ច.ស.អ សំអាងតែទៅលើភស្តុតាងមិនអាចជឿជាក់បានរបស់ ប្រាក់ យុត) កថាខណ្ឌ ២៤៧ ជើងទំព័រ ៦០១-០៣ (ពាក់ព័ន្ធនឹងការប្រជុំនៅក្នុងខែមីនា នៅវត្តតាមាយ ដែល អោ អាន បានប្រកាសដោយចោទប្រកាន់ថា គាត់គឺជាលេខាតំបន់ ៤១ ស.ច.ស.អ សំអាងតែទៅលើរឿងរ៉ាវដែលមិនអាចជឿជាក់បានរស់ ពេញ វ៉ា) កថាខណ្ឌ ២៧៥ ២៩៨ ៤៩១ ជើងទំព័រ ៧១៩ ៧៩០-៩១ ១៥៩៥ (ពាក់ព័ន្ធនឹងកិច្ចប្រជុំនៅវត្តអូរត្រកួន ស.ច.ស.អ សំអាងលើ សេង ស៊្រុន) កថាខណ្ឌ ២៨៣ ជើងទំព័រ ៧៣៩ (ពាក់ព័ន្ធនឹង "កិច្ចប្រជុំទៀងទាត់" ដែល អោ អាន បានបញ្ជាឲ្យថ្នាក់ក្រោមចាប់ខ្លួនខ្មាំង ស.ច.ស.អ សំអាងលើភស្តុតាងដែលមិនអាចជឿជាក់បានរបស់ ញ៉ែម ចេន) កថាខណ្ឌ ២៨៧ ជើងទំព័រ ៧៤៦ (ពាក់ព័ន្ធនឹងកិច្ចប្រជុំ 'កោះប្រជុំ' ដោយ អោ អាន 'អំពីផែនការកាប់សម្លាប់' ដែលគាត់

បានរៀបចំ ឬដឹកនាំក្តី ឬមានវត្តមានក្តី ក៏នេះមិនមានន័យ ថា គាត់គឺជាអ្នកអនុវត្តដ៏សំខាន់ ឬជាអ្នកទទួលខុសត្រូវខ្ពស់បំផុតនោះទេ។ ជាងនេះទៀត ប្រសិនបើ អោ អាន បានចូលរួមឬបានឡើងនិយាយនៅក្នុងអង្គប្រជុំ ការប្រជុំទាំងនេះអាចនឹងពាក់ព័ន្ធសេដ្ឋកិច្ច និង ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន ។ វាមិនពាក់ព័ន្ធនឹងបញ្ហានយោបាយ សន្តិសុខ ឬយោធា នោះទេ[184]។

---

បានបញ្ជា ង៉ូវ និងអ្នកក្រោមបង្គាប់ឲ្យ "អនុវត្ត "ផែនការឆ្នាំ១៩៧៧"" ស.ច.ស.អ សំអាងតែទៅលើ ញ៉ែម ចេន) កថាខណ្ឌ ៣០១ ជើងទំព័រ ៨០០-០៣ (ពាក់ព័ន្ធនឹងកិច្ចប្រជុំនៅវត្តតាមាឃនៅ 'ខែមេសា ឬ ខែឧសភា ឆ្នាំ១៩៧៧' ដែល អោ អាន បានបញ្ជាថ្នាក់ក្រោមកំណត់អត្តសញ្ញាណមនុស្សមួយចំនួន និងបានប្រើល្បិចបោកអ្នកផ្សេងឲ្យចូលខ្លួន ស.ច.ស.អ សំអាងតែទៅលើ ញ៉ែម ចេន) កថាខណ្ឌ ២៩៣ ជើងទំព័រ ៧៦៦-៦៨ (ពាក់ព័ន្ធនឹងកិច្ចប្រជុំនៅវត្តតាមាឃ ដែល អោ អាន "ចោទកម្មាភិបាលភូមិភាគកណ្តាលក្បត់" និងបានព្រមានថា 'មនុស្សកាន់តែច្រើននឹងស្លាប់ដោយសារសង្គ្រាមគ្មានហេតុផល' ជាងគ្រាប់បែក បេ-៥២ ស.ច.ស.អ សំអាងលើ ពេញ វ៉ា) កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៤ (ពាក់ព័ន្ធនឹង "កិច្ចប្រជុំ[តំបន់]ប្រចាំខែ" ដែលនៅពេលនោះ អោ អាន បានចោទថាបានបញ្ជាឲ្យលេខាស្រុកកំណត់អត្តសញ្ញាណ និងចាប់ "មនុស្សកំទេចចោល" ស.ច.ស.អ សំអាងលើ ប្រាក់ យុត) កថាខណ្ឌ ៣៦៤ ជើងទំព័រ ១០៣០-៣១ (ពាក់ព័ន្ធនឹងកិច្ចប្រជុំដែល អោ អាន បានណែនាំ ប្រាក់ យុត ឲ្យកំណត់អត្តសញ្ញាណ និងរៀបរាប់ 'ប្រភេទមនុស្សមួយចំនួន', ស.ច.ស.អ សំអាងលើតែ ប្រាក់ យុត) កថាខណ្ឌ ៣១១ ជើងទំព័រ ៨៣១ (ពាក់ព័ន្ធនឹងកិច្ចប្រជុំដែល អោ អាន បានបញ្ជាឲ្យមេស្រុក និងឃុំកំណត់អត្តសញ្ញាណដើម្បី "បោសសម្អាត" ចំពោះ "មនុស្សអាក្រក់" អ្នកដែល 'ជាប់ខ្សែ', និង 'ប្រជាជនជនជាតិពិន្ទុខុសគ្នា', ស.ច.ស.អ សំអាងលើ យូ វ៉ាន់) កថាខណ្ឌ ៤៦៥ ជើងទំព័រ ១៤៦៣ (ពាក់ព័ន្ធកិច្ចប្រជុំដើមឆ្នាំ១៩៧៧ នៅស្រុកកងមាស ដែល "ខ្មាំង" ត្រូវបានពិភាក្សា ហើយក្រោយមានការចោទប្រកាន់ថាការចាប់ខ្លួនកើនឡើង ស.ច.ស.អ សំអាងលើតែ សំរិត មុយ ដែល 'មិនប្រាកដទាំងស្រុង' ថា គាត់បានឃើញ អោ អាន នៅកិច្ចប្រជុំ) កថាខណ្ឌ ៥៨៩ ជើងទំព័រ ១៩៩៦ (ពាក់ព័ន្ធនឹងការចោទប្រកាន់ថា អោ អាន បានដឹកនាំកិច្ចប្រជុំយោធានៅវត្តតាមាឃ ស.ច.ស.អ សំអាងលើតែ ញ៉ែម ចេន) កថាខណ្ឌ ៦៣៦ ជើងទំព័រ ២១៧៣ (ពាក់ព័ន្ធនឹងកិច្ចប្រជុំ 'ដឹកនាំដោយ អោ អាន' ដែល យូ វ៉ាន់ 'ត្រូវបានណែនាំឲ្យធ្វើបញ្ជីឈ្មោះជនជាតិចាមលើកទីពីរ ស.ច.ស.អ សំអាងលើតែ យូ វ៉ាន់)។

[184] ឧទាហរណ៍ ឯកសារ **D78** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ជីន ស៊ីណាល់), ឆ.១-ឆ.៤ (ជីន ស៊ីណាល់ លើកឡើងថា អោ អាន បានចូលរួមកិច្ចប្រជុំប្រចាំខែនៅទំនប់អន្លង់ជ្រៃ នៅទីនោះ គាត់និយាយអំពីការបញ្ចប់ការសាងសង់ទំនប់)។ ឯកសារ **D117/31** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី យូ វ៉ាន់), ឆ.២៤-ឆ.២៦ (យូ វ៉ាន់ លើកឡើងថា "ពេលខ្លះ មួយខែម្តង ឬ ពីរខែម្តង" អោ អាន បានចូលរួមប្រជុំជាមួយ ប្រាក់ យុត និងប្រធានភូមិប្រធានឃុំស្រុកកំពង់សៀម នៅពេលនោះ មានការពិភាក្សាអំពីការធ្វើស្រែ។ យូ វ៉ាន់លើកឡើងថា គាត់មិនដែរធ្លាប់បានឮការពិភាក្សាអំពីការចាប់ខ្លួននៅក្នុងពេលប្រជុំទាំងនោះទេ)។ ឯកសារ **D117/50** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី អ៊ឹម ប៉ុន), ឆ. ៥៦ (អ្នកស៊ើបអង្កេត ក.ស.ច.ស. បានសាកសួរថា តើគាត់ធ្លាប់បានឮការប្រជុំរបស់អោ អាន ជាមួយប្រាក់យុត និង ស៊ីម ឬ ជាមួយ កែ ពក នៅក្នុងភូមិភាគ ហើយថាតើ អោ អាន បាននិយាយអំពីការបោសសម្អាតកម្មាភិបាលក្នុងពេលប្រជុំ ដែរឬទេ។ អ៊ឹម ប៉ុន លើកឡើងថា គាត់ពុំធ្លាប់បានឮអំពីការបោសសម្អាតកម្មាភិបាលទេ គាត់ពិភាក្សាតែប្រធានបទពាក់ព័ន្ធ ទំនប់ ប្រឡាយ និងការដ្ឋានការងារ។ គាត់ពុំបានឮអំពីការចាប់ខ្លួននោះទេ) ។ ឯកសារ **D117/53** (កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ស៊ន់ ជាន), ឆ. ២៥-ឆ.២៦ ( ស៊ន់ ជាន លើកឡើងថា គាត់ធ្លាប់ឮឈ្មោះ

### iii. អោ អាន មិនបានរៀបចំផែនការ សហការ ឬ ដឹកនាំការបោសសម្អាតអតីតកម្មាភិបាលភូមិភាគ កណ្តាល ឬជនស៊ីវិល នៅចុងឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៧ ឡើយ

88. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដែលសន្និដ្ឋានថា អោ អាន បានរៀបចំផែនការ បានសហការ និង បានដឹកនាំការបោសម្អាតអតីតកម្មាភិបាលភូមិភាគកណ្តាល និង ជនស៊ីវិលនៅចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧[185]។ ទីមួយ គាត់មិនអើពើនឹងភ័ស្តុតាងគ្រប់គ្រាន់ពីសាក្សីនានា និង អ្នកស្នើសុំតាំងខ្លួនជាដើមបណ្តឹង រដ្ឋប្បវេណី ដែលមានការដឹងឮផ្ទាល់ ដែលបង្ហាញថាការបោសសម្អាតបានកើតឡើងមុនពេលមកដល់នៃ កម្មាភិបាលភូមិភាគនិរតី និង អោ អាន[186] ដែលបង្ហាញទៀតថា កែ ពក និង អឿន គឺជាអ្នកដែលនៅសល់ ពេលកម្មាភិបាលនិរតីបានមកដល់ភូមិភាគកណ្តាល[187] និង ដែលបង្ហាញថា កម្មាភិបាលភូមិភាគនិរតី មកបំពេញតំណែងដែលទំនេរ[188]។ គោលការណ៍វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ត្រូវតែអនុវត្ត

---

គាត់ ហើយក្នុងសម័យនោះ ខ្ញុំបានឃើញគាត់ម្តងពីរម្តាយ គឺនៅការដ្ឋាន និងពេលប្រជុំ។ គាត់ធ្លាប់តែឮអំពីការណែនាំឱ្យប្រជាជនខិតខំធ្វើការ ប៉ុន្តែមិនដែលឮការណែនាំឱ្យកម្មាភិបាលថ្នាក់ក្រោមកំណត់អត្តសញ្ញាណសត្រូវទេ)។ ឯកសារ **D219/731** ( កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី ញ៉ែម ចេន), ឆ.៦៨-ឆ.៧០ ( ញ៉ែម ចេន លើកឡើងថា អោ អាន បានចូលរួមប្រជុំនៅវត្តបាធាយ នៅទីនោះ គាត់និយាយអំពីការសាងសង់ និងរបបអាហារ។ នៅពេលដែល ញ៉ែម ចេន ធ្វើដំណើរទៅវត្តបាធាយជាមួយពួសុក មិនមែនជាមួយ អោ អាន ទេ នៅពេលហ្នឹងហើយទើបមានការបញ្ជាឱ្យសម្លាប់)។

[185] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២១២-២១៧, ២៤២-២៤៥, ២៧៦។

[186] ឯកសារ **D117/19** (កំណត់ហេតុស្តាប់ចម្លើយ ទេព ប៉ូច) ឆ.៨។ ឯកសារ **D117/24** (កំណត់ហេតុស្តាប់ចម្លើយ ពៅ សារ៉ុម) ឆ.២៤។ ឯកសារ **D219/284** (កំណត់ហេតុស្តាប់ចម្លើយ ពៅ សារ៉ុម) ឆ.៣៤។ ឯកសារ **D117/27** (កំណត់ហេតុស្តាប់ចម្លើយ ឌើ វ៉ូន) ឆ.៤។ ឯកសារ **D117/31** (កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់) ឆ.១៤។ ឯកសារ **D117/57** (កំណត់ហេតុស្តាប់ចម្លើយ គាន ឡី) ឆ.៧-ឆ.៨។ ឯកសារ **D117/62** (កំណត់ហេតុស្តាប់ចម្លើយ គង់ យឿន) ឆ.២។ ឯកសារ **D219/285** (កំណត់ហេតុស្តាប់ចម្លើយ ហូ ហឿន) ឆ.៧។ ឯកសារ **D118/259** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.១៦៧។ ឯកសារ **D6.1.650** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) KH 00373460-00373461 ទំព័រ ៧-៨។ ឯកសារ **D6.1.690** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.៩។ ឯកសារ **D6.1.386** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) KH 00348792 ទំព័រ ៤។ ឯកសារ **D117/35** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) ឆ.២៨-ឆ.២៩។ ឯកសារ **D219/136** (កំណត់ហេតុស្តាប់ចម្លើយ ថន យ៉ង់) ឆ.៥, ឆ.៧។

[187] ឯកសារ **D6.1.386** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) KH 00348792 ទំព័រ ៤។ ឯកសារ **D117/35** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) ឆ.២៨, ឆ.៦៣។

[188] ឯកសារ **D117/62** (កំណត់ហេតុស្តាប់ចម្លើយ គង់ យឿន) ឆ.២។ ឯកសារ **D118/259** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.១៦៧។ ឯកសារ **D219/285** (កំណត់ហេតុស្តាប់ចម្លើយ ហូ ហឿន) ឆ.៧។ ឯកសារ **D6.1.650** (កំណត់ហេតុស្តាប់

ហើយដូច្នេះ គេមិនអាចកំណត់បានទេថា អោ អាន មានផែនការ បានសហការ និង ឬបានដឹកនាំការបោសសម្អាត។

89. ទី២ នៅពេលរកឃើញថា អោ អាន និង កម្មាភិបាលភូមិភាគនិរតីបានមកដល់ភូមិភាគកណ្ដាលនៅ ចុងឆ្នាំ១៩៧៦ ដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកលើសាក្សី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹង រដ្ឋប្បវេណី ដែលផ្ដល់ ដំណើររឿងមិនអាចជឿទុកចិត្តបាន មិនមានសង្គតិភាព ឬ មិនច្បាស់លាស់ និង មិនអាចកំណត់ពេលវេលាបាន ឬពួកគេខ្វះចំណេះដឹងផ្ទាល់អំពីការផ្ទេរនេះ[189]។ ជាងនេះទៀត គាត់ផ្អែកលើ សក្ខីកម្មរបស់ ឌុច និង កាលបរិច្ឆេទ

ចម្លើយ ពេជ្រ ជឹម) KH 00373460-00373461 ទំព័រ ៧-៨។ ឯកសារ **D6.1.690** (កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម) ឆ. ៩។

[189] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤២-២៤៣ ជើងទំព័រ ៥៩១, ៥៩៣។ ដំបូង ស.ច.ស.អ ផ្អែកទៅលើភស្តុតាងរបស់ ប្រាក់ យុត, យូ វ៉ាន់, ពេជ្រ ជឹម, សាន់ សុន, ផាន់ ឆេន, តូ សេម និង ញ៉ែម ចេន។ ទោះជាយ៉ាងនេះក្ដី ភស្តុតាងរបស់ ប្រាក់ យុត, យូ វ៉ាន់ និង ញ៉ែម ចេន មិនអាចជឿជាក់បានទេ ដូចដែលបានពន្យល់នៅក្នុងផ្នែក II(ឃ)(ii)។ **<u>ប្រាក់ យុត</u>** និង **<u>ពេជ្រ ជឹម</u>**៖ លើសពីនេះទៀត ស.ច.ស.អ មិនចាប់អារម្មណ៍លើភាពមិនស៊ីសង្វាក់គ្នាធ្ងន់ធ្ងរនៅក្នុងចម្លើយរបស់ ប្រាក់ យុត ដែលមេធាវីការពារក្ដីពន្យល់នៅក្នុងផ្នែក II(ឃ)(ii)(ក) និង**ឧបសម្ព័ន្ធ ឃ** និងចម្លើយរបស់ ពេជ្រ ជឹម ដែលគ្រប់គ្រងលើចម្ការកៅស៊ូនៅចម្ការអណ្ដូងក្នុងតំបន់ ៤២។ ឯកសារ **D6.1.650** (កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម) KH 00373457-00373459 ទំព័រ ៤-៦ (បន្ទាប់ពីត្រូវបានអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស សួរសំណួរបិទ ពេជ្រ ជឹម បានឆ្លើយថា គាត់ត្រូវបានតែងតាំងជាលេខាស្រុក១០៥ ស្ដីទី នៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧។ ក្រោយមក គាត់បានបន្ថែមទៀតថា គាត់មិនបានឮអំពីការបោសសម្អាតណាមួយនៅក្នុងរយៈពេលនោះទេ ហើយជាចុងក្រោយ គាត់បាននិយាយថា គាត់ត្រូវបានផ្ទេរទៅចម្ការកៅស៊ូនៅចម្ការអណ្ដូង នៅខែកុម្ភៈ ឆ្នាំ១៩៧៧។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់នោះទេ។) ជាមួយនឹងឯកសារ **D118/259** (កំណត់ហេតុស្ដាប់ចម្លើយ ពេជ្រ ជឹម) ឆ.១៦៨-ឆ.១៧១ (បន្ទាប់ពីអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានផ្ដល់ព័ត៌មានដាក់បន្ទុកអំពីការបញ្ជូន អោ អាន, ពេជ្រ ជឹម បានបន្ថែមថា គាត់បានមកដល់នៅខែកុម្ភៈ ឆ្នាំ១៩៧៦ និងថា អោ អាន បានមកដល់នៅថ្ងៃខែឆ្នាំតែមួយ) ជាមួយនឹងឯកសារ **D219/702.1.103** (ប្រតិចារឹកក្នុងសំណុំរឿង ០០២-ពេជ្រ ជឹម) KH 01441836-01441837, 01441878-01441879 ទំព័រ ៦-៧, ៤៨-៤៩ (ពេលផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ ពេជ្រ ជឹម ប្រឹងប្រែងកំណត់កាលបរិច្ឆេទយ៉ាងច្បាស់លាស់ និងអាចត្រឹមតែបញ្ជាក់អះអាងពីចម្លើយលើកមុនរបស់គាត់ បន្ទាប់ពីគាត់ចងចាំឡើងវិញ។)។ **<u>សាន់ សុន</u>**៖ លើសពីនេះទៀត សាន់ សុន ពុំបានដឹងដោយផ្ទាល់ពីការបញ្ជូន អោ អាន នោះទេ។ ឯកសារ **D107/2** (កំណត់ហេតុស្ដាប់ចម្លើយ សាន់ សុន) ឆ.៥-ឆ.៧, ឆ.១១ (សាន់ សុន បានឆ្លើយថា ក្រុមពួកភូមិភាគនិរតីបានមកដល់នៅដើមឆ្នាំ១៩៧៧ ប៉ុន្តែ គាត់មិនបានឮពី អោ អាន ទេ។)។ **<u>ផាន់ ឆេន</u>**៖ ចម្លើយរបស់ ផាន់ ឆេន ទូលំទូលាយ ដោយគ្រាន់តែលើកឡើងថា តាម៉ុក បានបញ្ជូនគាត់ទៅភូមិភាគកណ្ដាល ហើយគាត់ជំទាស់នឹងការសន្និដ្ឋានរបស់ ស.ច.ស.អ។ ឯកសារ **D219/41** (កំណត់ហេតុស្ដាប់ចម្លើយ ផាន់ ឆេន) ឆ.៣, ឆ.៧, ឆ.៣០ (ផាន់ ឆេន បានឆ្លើយថា វាពិបាកនឹងចងចាំពីកាលបរិច្ឆេទបញ្ជូន

ចូល ស-២១ ដើម្បីប៉ុនប៉ងបំពេញតាមបទដ្ឋានលក្ខខណ្ឌចាំបាច់[190]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យោងលើទស្សនាវដ្តីទង់បដិវត្ត ដែលរាយការណ៍អំពីវឌ្ឍនភាពនៃការបោសសម្អាតនៅភូមិភាគ កណ្តាល ប៉ុន្តែឯកសារទាំងនេះ មិនពិភាក្សាអំពីការមកដល់នៃកម្មាភិបាលភូមិភាគនិរតី ឬ អោ អាន ឡើយ[191]។

90. ទី៣ ដោយគ្មានភ័ស្តុតាងគ្រប់គ្រាន់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថា មូលហេតុនៃការផ្ទេរកម្មាភិបាលភូមិភាគ និរតីគឺដើម្បីធ្វើការបោសសម្អាតអតីតកម្មាភិបាល និងជនស៊ីវិល នៅភូមិភាគកណ្តាល[192]។ តាមការពិត ការ ផ្ទេរនេះគឺដើម្បីអនុវត្តការចាត់តាំងការងារថ្មី ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទទួលស្គាល់ថាបានកន្លងហួសទៅហើយ[193]។ សាក្សីនិងអ្នកដាក់

---

ពេជ្រ ជឹម និងបានឆ្លើយស្មានថា គឺនៅដើមឆ្នាំ១៩៧៧។)។ **<u>គូ សេម៖</u>** គូ សេម មិនបានផ្តល់នូវការយោងទៅពេលវេលាណាមួយទាក់ទងនឹងការបញ្ជូនពួកភូមិភាគនិរតីទេ។ ឯកសារ **D117/39** (កំណត់ហេតុស្តាប់ចម្លើយ គូ សេម) ឆ.៦-ឆ.៨។ **<u>ចម្លើយនៅសេសសល់ផ្សេងទៀត៖</u>** សាក្សី និងអ្នកដាក់ពាក្យសុំជាដើមបណ្តឹងរដ្ឋប្បវេណីផ្សេងទៀតដែលផ្តល់ដោយ ស.ច.ស.អ បានលើកឡើងពីរយៈពេលទូលំទូលាយ ឬមិនច្បាស់លាស់។)។ ឯកសារ **D107/7** (កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល), KH 00784980-00784981 (ញឹម កុល បានឆ្លើយថា ប្រាក់ យុត មកដល់នៅរដ្ឋវប្រាំង ឆ្នាំ១៩៧៧។)។ ឯកសារ **D117/32** (កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល) ឆ.២ (ញឹម កុល បានលើកឡើងថា កម្មាភិបាលភូមិភាគនិរតីមកនៅចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧។)។ ឯកសារ **D219/171** (កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល) ឆ.២ (ញឹម កុល បានបញ្ជាក់ថា កម្មាភិបាលភូមិភាគនិរតីបានមកដល់នៅរដូវប្រាំងនៅចុងឆ្នាំ១៩៧៦ ឬនៅឆ្នាំ១៩៧៧។)។ ឯកសារ **D117/26** (កំណត់ហេតុស្តាប់ចម្លើយ ពុត កុល) ឆ.២ (ពុត កុល បានលើកឡើងថា កម្មាភិបាលភូមិភាគនិរតីជាច្រើននាក់បានមកនៅរដូវប្រាំងឆ្នាំ១៩៧៧ ប្រហែលនៅខែមីនា។)។

[190] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២១៥ ជើងទំព័រ ៤៩១ កថាខណ្ឌ ២៤៧ ជើងទំព័រ ៦០៤ (ដោយផ្អែកជាបឋមទៅលើភ័ស្តុតាងរបស់ ឌុច ស.ច.ស.អ បានសន្និដ្ឋានថា ដោយសារតែកម្មាភិបាល ដូចជា លេខាភូមិភាគកណ្តាល កុយ ធួន និងកូនចៅជិតដិតរបស់គាត់ ត្រូវបានបញ្ជូនទៅមន្ទីរ ស-២១ ចាប់ពីដើមឆ្នាំ១៩៧៧ ការបោសសម្អាតត្រូវទម្លាក់ទៅលើកម្មាភិបាលភូមិភាគនិរតី និង អោ អាន ថាជាអ្នកធ្វើ។ ទោះជាយ៉ាងនេះក្តី នេះគ្រាន់តែជាការស្មានប៉ុណ្ណោះ ដោយហេតុថា ឌុច បាននិយាយតែពីការបោសសម្អាតផ្ទៃក្នុងជាទូទៅ និងការចាប់ខ្លួន កុយ ធួន និងចម្លើយសារភាពនៅ ស-២១ នៅដើមឆ្នាំ១៩៧៧ ប៉ុណ្ណោះ ប៉ុន្តែ គាត់មិនបានផ្តល់ភ័ស្តុតាងអំពីសកម្មភាព ឬការបញ្ជូនកម្មាភិបាលភូមិភាគនិរតីនោះទេ។ កាលបរិច្ឆេទចូល ស-២១ ក៏មិនកំណត់ថា កម្មាភិបាលភូមិភាគនិរតី ឬ អោ អាន ជាប់ពាក់ព័ន្ធជាមួយនឹងការបោសសម្អាតដែលត្រូវបានចោទប្រកាន់ដែរ ប៉ុន្តែ ផ្ទុយទៅវិញ គាត់គ្រាន់តែបង្ហាញថា បុគ្គលមួយចំនួនលែងមានវត្តមាននៅភូមិភាគកណ្តាលនៅពេលជាក់លាក់ប៉ុណ្ណោះ។)។

[191] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២១៦ ជើងទំព័រ ៤៩៨។

[192] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២១៤ ជើងទំព័រ ៤៨៩-៤៩០។

[193] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៣។

ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីភាគច្រើនដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្អែកលើ គ្រាន់តែ និយាយយោងថាកម្មាភិបាលភូមិភាគនិរតីមកជំនួស[194] ពួកគេមិនបានផ្តល់ព័ត៌មានណាមួយដែលបំពេញបាន នូវបទដ្ឋានលក្ខខណ្ឌចាំបាច់ដែលថាគោលបំណងនៃការផ្ទេរគឺដើម្បីបោសសម្អាតកម្មាភិបាលក្នុងតំណែង ឡើយ[195] ឬពួកគេមិនមានចំណេះដឹងផ្ទាល់នៃបញ្ហានេះទេ[196]។

91. ទី៤ ដូចដែលបានពន្យល់នៅក្នុងផ្នែកទីII(ង)(ii) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បំផ្លើសភ័ស្តុតាងពាក់ព័ន្ធនឹងការប្រជុំ រៀបចំផែនការសម្រាប់ការបោសសម្អាតនៅភ្នំពេញ ដែលតាមការពិតគឺ

[194] ឧទាហរណ៍ ឯកសារ **D219/435** (កំណត់ហេតុស្តាប់ចម្លើយ ទូច ចំរើន) ឆ.៦៥-៦៧, ឆ.១៣៩-១៤២ (ទូច ចំរើន បានលើកឡើងថា គាត់មិនដឹងថាហេតុអ្វីបានកម្មាភិបាលចាស់ត្រូវបានផ្លាស់ប្តូរនោះទេ។ គ្រាន់តែសួរគាត់នូវសំណួរនាំមុខហើយភ្លាម គាត់បានឆ្លើយថា កម្មាភិបាលភូមិភាគនិរតីបានមកជំនួសកម្មាភិបាលនៅថ្នាក់ស្រុក និងថ្នាក់ភូមិភាគ)។ ឯកសារ **D117/71** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត) ឆ.៦៩ (ប្រាក់ យុត បានបញ្ជាក់ថា លោកស្រីចាំថាបានជួបជាមួយលេខាស្រុកចាស់ ហើយលោកស្រីបានជំនួសគាត់។ នេះមិនមានន័យថា ការបញ្ជូនពួកភូមិភាគនិរតីទៅមានគោលដៅដើម្បីបោសសម្អាតកម្មាភិបាលដែលកំពុងកាន់តំណែងនោះទេ។)។ ឯកសារ **D219/285** (ហូ ហឿន) ឆ.៧ (ហូ ហឿន បានបញ្ជាក់ថា ការបោសសម្អាតកើតមានឡើងមុនពេលកម្មាភិបាលភូមិភាគនិរតីមកដល់។ ពួកគេត្រូវបានបញ្ជូនទៅដើម្បីជំនួសតំណែង។)។

[195] ឧទាហរណ៍ ឯកសារ **D219/504** (សាត ភាព) ឆ.១៣-១៥ (សាត ភាព បានឆ្លើយថា កម្មាភិបាលចាស់មួយចំនួនត្រូវបានចាប់ ក្រោយពេលកម្មាភិបាលភូមិភាគនិរតីមកដល់ ហើយអ្នកខ្លះទៀតត្រូវបានចាប់ខ្លួនមុនពេលកម្មាភិបាលភូមិភាគនិរតីមកដល់។)។ ឯកសារ **D6.1.386** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) KH 00348792 ទំព័រ ៤ (ពេលសួរគាត់ថាហេតុអ្វីបានជាកម្មាភិបាលចាស់ត្រូវបានបោសសម្អាត និងដោយរបៀបណា បាន សៀន មិនដឹងអំពីរឿងនេះទេ។)។ ឯកសារ **D219/442** (កំណត់ហេតុស្តាប់ចម្លើយ ជុំ វង្ស) ឆ.៣៨ (ងួវ បានបញ្ជាក់ថា មនុស្សជាច្រើន ដែលត្រូវបានចោទថាក្បត់បក្ស ត្រូវបានចាប់ខ្លួននៅពេលនោះ។ នេះមិនមែនមានន័យថា ការបញ្ជូនពួកភូមិភាគនិរតីទៅមានគោលដៅដើម្បីបោសសម្អាតកម្មាភិបាលដែលកំពុងកាន់តំណែងទេ។)។

[196] ឧទាហរណ៍ ឯកសារ **D219/331** (កំណត់ហេតុស្តាប់ចម្លើយ ផន សុផល) ឆ.១-ឆ.៣, ឆ.១៣-ឆ.១៧ (ផន សុផល ធ្វើការនៅក្នុងកងចល័តតំបន់ និងពុំមានភ័ស្តុតាងផ្ទាល់អំពីការបោសសម្អាតដែលត្រូវបានចោទប្រកាន់នោះទេ)។ ឯកសារ **D219/226** (កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា) ឆ.២, ឆ.១៣ (ពេញ វ៉ា ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ជាសមាជិកកងសិប្បកម្មតម្បាញនៅព្រៃទទឹង។ គាត់មិនដឹងថាអ្នកណាជាអ្នកចេញបញ្ជាឱ្យចាប់ខ្លួនកម្មាភិបាលចាស់ទេ និងបានឆ្លើយស្មានថាគាត់ច្បាស់ថា ការចាប់ខ្លួនទាំងនោះគឺធ្វើឡើងដោយកម្មាភិបាលភូមិភាគនិរតីចេញបញ្ជា។)។ ឯកសារ **D219/293** (កំណត់ហេតុស្តាប់ចម្លើយ ជាម ពៅ) ឆ.១, ឆ.៥-ឆ.៨, ឆ.១០ (ជាម ពៅ ជាអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មានអាយុប្រហែល ១៥ ឆ្នាំ នៅពេលពួកខ្មែរក្រហមឡើងកាន់អំណាច។ គាត់ធ្វើការនៅក្នុងកងចល័តឃុំនៅដើមឆ្នាំ១៩៧៧ និងមិនបានដឹងដោយផ្ទាល់អំពីការបោសសម្អាតដែលត្រូវបានចោទប្រកាន់ទេ។)។

គ្រាន់តែកន្លែងសម្រាកក្នុងកំឡុង ពេលធ្វើដំណើររបស់កម្មាភិបាលភូមិភាគនិរតីមកភូមិភាគកណ្ដាលតែប៉ុណ្ណោះ។

92. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្ដល់ភ័ស្ដុតាងគ្រប់គ្រាន់ណាមួយផ្សេងទៀតថា អោ អាន បញ្ជា ឬចូលរួមក្នុង ការបោសសម្អាតក្នុងតំបន់៤១ឡើយ[197]។ ដូចដែលបានពិភាក្សានៅក្នុងផ្នែកទីII(ង)(v)(ខ)(១) គឺពុំមានភ័ស្ដុតាងគ្រប់គ្រាន់បញ្ជាក់ថា អោ អាន បានទទួលបញ្ជាពី កែ ពក ពាក់ព័ន្ធនឹងការបោសសម្អាត បញ្ជាក់ថា អោ អាន បានបញ្ជាលេខាស្រុកឲ្យកំណត់អត្តសញ្ញាណ និងសម្លាប់ប្រជាជនដែលរអ៊ូរទាំងអំពី លក្ខខណ្ឌ ការងារ និងលក្ខខណ្ឌរស់នៅឡើយ[198] ឬបង្ហាញថា អោ អាន បានបោសសម្អាតនិងដាក់ជំនួសកម្មាភិបាលភូមិភាគកណ្ដាលជាប្រព័ន្ធនោះឡើយ[199] ។ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានផ្ដល់ភ័ស្ដុតាងប្រាកដប្រជា និងគាំទ្របញ្ជាក់ ដែលបង្ហាញថា អោ អាន រៀបចំផែនការ សហការ ឬដឹកនាំការបោសសម្អាត កម្មាភិបាលក្នុងតួនាទី ឬជនស៊ីវិលនៅក្នុងភូមិភាគកណ្ដាលឡើយ។

### iv. អោ អាន មិនមានតួនាទីឬសិទ្ធិអំណាចសំខាន់នៅក្នុងភូមិភាគកណ្ដាលឡើយ

93. អោ អាន មិនមានតួនាទីសំខាន់ៗថ្នាក់តំបន់នៅក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យឡើយ។ គាត់មិន មែនជាលេខាស្ដីទីភូមិភាគកណ្ដាលទេ នៅពេលដែល កែ ពក អវត្តមាន ហើយគាត់មិនមែនជាអនុលេខា តំបន់តាមច្បាប់ និង ព្រឹត្តិន័យនោះទេ។ គាត់ក៏មិនមានសិទ្ធិអំណាចធ្វើការសម្រេចចិត្ត ឬកំណត់មធ្យោបាយ ផ្សព្វផ្សាយឬអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា នៅក្នុងភូមិភាគកណ្ដាលដែរ។ ដូចដែលពន្យល់នៅខាងក្រោម សំអាងហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា អោ អាន កាន់តួនាទីទាំងនេះ ឬមានសិទ្ធិអំណាចថ្នាក់ភូមិភាគ គឺពុំ ផ្អែកលើភ័ស្ដុតាងច្បាស់លាស់គ្រប់គ្រាន់នោះឡើយ។ បើទោះជា អោ អាន បានកាន់តួនាទីទាំងនេះក្ដី ក៏គាត់ នៅតែមិនត្រូវចាត់ទុកថាជាអ្នកស្ថិតក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុតដែរ។

<u>ក) អោ អាន មិនមែនជាលេខាស្ដីទីនៃភូមិភាគកណ្ដាលឡើយនៅពេល កែ ពក អវត្តមាន</u>

---

[197] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨១-២៨៨ ជើងទំព័រ ៧៣៧-៧៥២។

[198] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៥ ជើងទំព័រ ៧១៨-៧១៩។

[199] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៣-២៩៨ ជើងទំព័រ ៧៦៥-៧៩១។

94. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រកឃើញថា អោ អាន ធ្វើជាលេខាស្តីទីភូមិភាគកណ្តាលក្នុងរយៈកាលដែល កែ ពក អវត្តមានពីភូមិភាគ[200]។ ប៉ុន្តែ នៅពេលពិនិត្យខ្លឹមសារភ័ស្តុតាង គឺឃើញច្បាស់ថាសំអាងហេតុទាំងនេះ មានកំហុស ហើយមិនផ្អែកលើភ័ស្តុតាងពិតប្រាកដនិងច្បាស់លាស់ឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថែមទាំងទទួលស្គាល់ ថា "គ្មានសាក្សីណាកំណត់ជាក់លាក់ថាពេលណា ឬដោយរបៀបណា ដែល [អោ អាន] កាន់តួនាទី បែបហ្នឹង នោះទេ"[201]។

95. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រកឃើញថា អោ អាន គឺជាលេខាភូមិភាគស្តីទី ដែលចាប់ផ្តើមកំឡុងខែតុលា ឆ្នាំ១៩៧៨ រហូតដល់របបនោះដួលរលំ ពោលគឺ ៣ខែចុងក្រោយនៃរបបកម្ពុជាប្រជាធិបតេយ្យ[202]។ បើទោះជាវាជាការ ពិតក៏ដោយ ក៏រយៈពេលខ្លីនេះមិនអាចទាក់ទម្ងន់ថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុត ដែលជាលក្ខខណ្ឌតម្រូវសម្រាប់យុត្តាធិការបុគ្គលនោះដែរ។ ជាងនេះទៅទៀត ភ័ស្តុតាងដែលគាំទ្ររយៈពេល៣ខែនេះគឺមិនពិតប្រាកដនិងមានការបញ្ជាក់ឡើយ ដោយហេតុថា សាក្សី៣ នាក់ក្នុងចំណោមសាក្សី៤នាក់ ដែលគេស្តាប់ចម្លើយ គឺនិយាយមិនស្របគ្នា ប្រឡូសប្រឡាក់ដោយ អ្នកស៊ើប អង្កេត ការិយាល័យសហចៅក្រមស៊ើបអង្កេត ឬមានចេតនាចង់ភូតកុហក[203]។

96. ក្រៅពីកង្វះភ័ស្តុតាងគ្រប់គ្រាន់អំពីពេលណាដែល អោ អាន គឺជាលេខាស្តីទីភូមិភាគ គឺគ្មានភ័ស្តុ

---

[200] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៥។

[201] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៥, ២៦២, ៧០៥។

[202] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៥។

[203] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៥ ជើងទំព័រ ៦៣០-៦៣២ (ស.ច.ស.អ ផ្អែកលើភ័ស្តុតាងរបស់ សារ៉ាយ ហៀន, កែ ពេជ្រវណ្ណៈ, អ៊ិន គឹមអេង និង អ៊ឹម ប៊ុន។ **<u>សារ៉ាយ ហៀន៖</u>** ពេលពិនិត្យភ័ស្តុតាងឱ្យដិតដល់ ច្បាស់ណាស់ថា សារ៉ាយ ហៀន បានឆ្លើយស្មានអំពីតំណែងរបស់ អោ អាន និងថាតាមអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស។ លើសពីនេះទៀត សារ៉ាយ ហៀន មិនអាចផ្តល់ឧទាហរណ៍ជាក់លាក់ថា អោ អាន បំពេញភារកិច្ចរបស់ កែ ពក បានទេ។ **<u>កែ ពេជ្រវណ្ណៈ៖</u>** ភ័ស្តុតាងរបស់ កែ ពេជ្រវណ្ណៈ មិនអាចជឿជាក់បានទេ ដោយសារតែគាត់ជាកូនប្រុសរបស់ កែ ពក ហើយដូច្នេះ គាត់អាចនឹងមានហេតុផលនិយាយកុហក ដើម្បីបន្ធូរបន្ថយតួនាទីរបស់ឪពុកគាត់។ លើសពីនេះទៀត គាត់មិនបានផ្តល់នូវព័ត៌មានលម្អិតណាមួយពីសកម្មភាពរបស់ អោ អាន នៅក្នុងតួនាទីនេះទេ។ **<u>អ៊ិន គឹមអេង៖</u>** ជាចុងក្រោយ សក្ខីកម្មរបស់ អ៊ិន គឹមអេង មិនស៊ីសង្វាក់គ្នាទេ។ ដំបូង គាត់បានឆ្លើយថា អោ អាន ជាអ្នកទទួលខុសត្រូវ នៅពេល កែ ពក អវត្តមាន ហើយក្រោយមក គាត់បានបញ្ជាក់ថា គាត់មិនបានឮគេនិយាយថា អោ អាន ជាអនុលេខាភូមិភាគរបស់ កែ ពក ទេ ដោយថែមទាំងកត់សម្គាល់ទៀតថា តាមឿន ឬហេន ជាអ្នកជំនួស កែ ពក ពេលអវត្តមាន។)។

តាង ផ្ទាល់ណាមួយបង្ហាញថា អោ អាន ពិតជាបានកាន់តួនាទីនេះពិតប្រាកដពេល កែ ពក អវត្តមាននោះ ឡើយ[204]។ គ្មានសាក្សីណាម្នាក់ផ្តល់ភ័ស្តុតាងផ្ទាល់អំពី៖ (ក) ពេលវេលា ឬថាតើ កែ ពក អាចបានធ្វើប្រតិភូ កម្មអំណាចសម្រេចចិត្តទៅ អោ អាន កំឡុងពេលដែលគាត់ អវត្តមាន[205] (ខ) របៀបដែល អោ អាន ទទួល បញ្ជា ការឆ្លងឆ្លើយ ការត្រួតពិនិត្យ ឬ ការណែនាំពីមជ្ឈិម ពាក់ព័ន្ធនឹងការអនុវត្តសិទ្ធិអំណាច (គ) របៀប ដែល អោ អាន រាយការណ៍ត្រឡប់ទៅមជ្ឈិមវិញ (ឃ) របៀបដែល អោ អាន បញ្ជូនបទបញ្ជា ការប្រាស្រ័យទាក់ទង ឬការណែនាំទៅកាន់អ្នកដទៃទៀត នៅក្នុងតំបន់៤២ និង ៤៣ ដើម្បីឲ្យត្រួតពិនិត្យ ឬអនុវត្ត សិទ្ធិអំណាចទៅលើពួកគេ (ង)ថាតើ អោ អាន បានអនុវត្តភារកិច្ចភូមិភាគទាំងនេះពី ស្រុកព្រៃទទឹង ឬ ក្រុង កំពង់ចាម ឬទេ ថាតើ លេខាតំបន់ដទៃៗទៀតឬ កម្មាភិបាលនៅក្នុងមន្ទី កែ ពក បានចុះទៅ និង រាយការណ៍ទៅ អោ អាន នៅក្នុងរយៈពេលទាំងនេះឬទេ (ច) អោ អាន ដឹកនាំការប្រជុំថ្នាក់ភូមិភាគ ឬ ការប្រជុំរវាង អោ អាន និង លេខាតំបន់ផ្សេងៗទៀត ឬ កម្មាភិបាលពីមន្ទីរ កែ ពក។

97. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើចំពោះភ័ស្តុតាងដែលផ្ទុយទៅនឹងសំអាងហេតុរបស់ខ្លួនដោយគ្មានការពន្យល់។ ភ័ស្តុតាងក្នុងសំណុំរឿងបង្ហាញថា កែ ពក មានអំណាចដាច់ណាត់នៅគ្រប់ពេលវេលា ហើយថា កម្មាភិបាលដទៃទៀត (មិនមែន អោ អាន ទេ) ជាអ្នកទទួលបន្ទុកនៅ

---

[204] ឯកសារ **D117/35** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) ឆ.៣៧ (បាន សៀក បានបញ្ជាក់ថា គាត់មិនដឹងថាអ្នកណាជំនួស កែ ពក ពេលគាត់អវត្តមានពីភូមិភាគនោះទេ។)។ ឯកសារ **D117/39** (កំណត់ហេតុស្តាប់ចម្លើយ តូ សេម) ឆ.១៦ (តូ សេម បានឆ្លើយថា កែ ពក មិនដែលទៅធ្វើការនៅខាងក្រៅដែនយុត្តាធិការរបស់ភូមិភាគទេ។)។ ឯកសារ **D117/50** (កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម ប៊ុន) ឆ.៦៩ (អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានសុំចំៗឲ្យ អ៊ឹម ប៊ុន ផ្តល់ឧទាហរណ៍ពីពេលដែល កែ ពក អវត្តមាន ហើយ អោ អាន បានជំនួសគាត់។ អ៊ឹម ប៊ុន គ្រាន់តែបានឆ្លើយថា ពេល កែ ពក អវត្តមាន អោ អាន ចាត់ចែងការងារនៅការដ្ឋាន និងក្រសួងនៅកំពង់ចាម និងជួបមនុស្សនៅទីនោះ ប៉ុន្តែ ថានេះមិនមែនទៀងទាត់ទេ។)។ ឯកសារ **D118/259** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.២១៧ (ពេជ្រ ជឹម បានបញ្ជាក់ថា គាត់មិនដឹងថាតើ អោ អាន ជាអ្នកជំនួស កែ ពក ពេលគាត់អវត្តមានទេ។)។ ឯកសារ **D219/762** (កំណត់ហេតុស្តាប់ចម្លើយ សារ៉ាយ ហៀន) ឆ.២៩-ឆ.៣០ (សារ៉ាយ ហៀន បានបញ្ជាក់ថា គាត់មិនដឹងថាមានពេលណាមួយដែល អោ អាន ទទួលការងាររបស់ កែ ពក ពេលគាត់អវត្តមានទេ។)។

[205] ឯកសារ **D117/18** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.៣-ឆ.៥ (ពេជ្រ ជឹម បានបញ្ជាក់ថា កែ ពក ធ្វើសេចក្តីសម្រេចតែម្នាក់ឯង និងថា គាត់បញ្ជូនរបាយការណ៍ទៅ កែ ពក ទោះបីពេលគាត់អវត្តមានក្តី។ អោ អាន មានតែសិទ្ធិអំណាចក្នុងការធ្វើសេចក្តីសម្រេចទាក់ទងនឹងតំបន់ ៤១ ប៉ុណ្ណោះ។)។

ពេល កែ ពក អវត្តមាន[206]។ យោងតាម គោលការណ៍ វិមតិសង្ស័យបានជាប្រយោជន៍ដល់ជនជាប់ចោទ គេមិនអាចកំណត់បានថា អោ អានកាន់តួនាទីជា លេខាស្តីទី ភូមិភាគ ពេល កែវ ពក អវត្តមានឡើយ។

<u>ខ) អោ អាន មិនមែនជាអនុលេខាតំបន់ តាមនីតិន័យនោះទេ</u>

98. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថា មានភាពទំនងខ្លាំងណាស់ដែលថា អោ អានគឺជាអនុលេខាភូមិភាគកណ្តាល ចាប់ពីចុងឆ្នាំ១៩៧៧ រហូតដល់ចុងរបបកម្ពុជាប្រជាធិបតេយ្យ[207]។ គាត់រកឃើញថា កិច្ចប្រជុំនៅខែកុម្ភៈ ឆ្នាំ១៩៧៧ នៅកំពង់ចាម កែ ពក ដំបូងប្រកាសថា អោ អានគឺជាអនុលេខាទីពីរ[208] ហើយក្រោយមក ក្រោយ ពេល គេដក កង ចាប (មិនបញ្ជាក់កាលបរិច្ឆេទ

---

[206] ឯកសារ **D6.1.707** (កំណត់ហេតុស្តាប់ចម្លើយ សួន កានិល), KH 00373508 ទំព័រ ៣ (សួន កានិល បានឆ្លើយថា ពេល កែ ពក អវត្តមាន គេមកជួប សួ បន្ទាប់មក ញាន, សែន និង មឿន។)។ ឯកសារ **D29** (កំណត់ហេតុស្តាប់ចម្លើយ សួន កានិល), KH 00705153 ទំព័រ ៥ (សួន កានិល បានឆ្លើយថា មឿន ប្រធានមន្ទីរភូមិភាគកណ្តាល ជាអ្នកទទួលខុសត្រូវ នៅពេល កែ ពក អវត្តមាន ហើយមុន មឿន គឺ សួរ និង ញៀន ជាអ្នកទទួលខុសត្រូវ នៅពេល កែ ពក អវត្តមាន។)។ ឯកសារ **D107/15** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក), KH 00800955 ទំព័រ ៤ (បាន សៀក បានឆ្លើយថា មឿន ជាមនុស្សតែម្នាក់គត់ដែលអាចទទួលការងារ នៅពេលដែល កែ ពក អវត្តមាន។)។ ឯកសារ **D117/18** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.៣-ឆ.៥ (ពេជ្រ ជឹម បានបញ្ជាក់ថា កែ ពក ធ្វើសេចក្តីសម្រេចតែម្នាក់ឯង និងថា ពេជ្រ ជឹម បញ្ជូនរបាយការណ៍ទៅ កែ ពក ទោះបីពេលគាត់អវត្តមានក្តី។)។ ឯកសារ **D117/19** (កំណត់ហេតុស្តាប់ចម្លើយ ទេព ប៉ូច) ឆ.១២, ឆ.១៤ (ទេព ប៉ូច បានបញ្ជាក់ថា ស៊ីម និង ចន ជាអនុរបស់ កែ ពក។ គាត់មិនដែលឮពី អោ អាន ទេ។)។ ឯកសារ **D117/35** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) ឆ.៣៧, ឆ.៦៥ (បាន សៀក បានឆ្លើយថា គាត់មិនដឹងថាអ្នកណាជាអ្នកជំនួស កែ ពក នៅពេលគាត់អវត្តមានពីភូមិភាគទេ និងថា អោ អាន មិនអាចចូលក្នុងតំបន់ ៤២ និង ៤៣ ដើម្បីចាប់មនុស្សបានទេ។)។ ឯកសារ **D117/66** (កំណត់ហេតុស្តាប់ចម្លើយ អ៊ិន គឹមអេង) ឆ.១០, ឆ.១៣ (អ៊ិន គឹមអេង បានបញ្ជាក់ថា មឿន ឬ ហេន ទទួលការងាររបស់ កែ ពក នៅពេលគាត់អវត្តមាន។)។ ឯកសារ **D118/259** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.២១៩ (ពេជ្រ ជឹម បានឆ្លើយថា ឆាំ ដែលធ្វើការនៅក្នុងមន្ទីរភូមិភាគរបស់ កែ ពក ជាអ្នកជំនួស នៅពេលដែល កែ ពក អវត្តមាន។)។ ឯកសារ **D219/504** (កំណត់ហេតុស្តាប់ចម្លើយ សាត ភាព) ឆ.១១០ (សាត ភាព បានបញ្ជាក់ថា គាត់មិនដឹងថាតើ អោ អាន កាន់តំណែងនៅថ្នាក់ភូមិភាគដែរឬអត់ទេ។)។ ឯកសារ **D219/704** (កំណត់ហេតុស្តាប់ចម្លើយ គឹម គឿន) ឆ.៤២ (គឹម គឿន មិនដឹងថាតើ អោ អាន នៅក្នុងគណៈភូមិភាគដែរឬអត់ទេ។)។ ឯកសារ **D219/774** (កំណត់ហេតុស្តាប់ចម្លើយ អ៊ុំ សេង) ឆ.៦៦ (អ៊ុំ សេង មិនស្គាល់ឈ្មោះអ្នកណាម្នាក់ផ្សេងក្រៅពី កែ ពក នៅភូមិភាគកណ្តាលទេ។)។

[207] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥០, ២៥២, ២៦១, ៧០៣, ៧០៥។

[208] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥១។

ច្បាស់លាស់[209]) អោ អាន ឡើងជា អនុលេខាទី១[210]។

99. ក៏ប៉ុន្តែ ដើម្បីគាំទ្រសំអាងហេតុរបស់ខ្លួន[211] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកលើសក្ខីកម្ម ដែលពុំមានភ័ស្តុតាង និង ដែលជារឿយៗប្រឡូសប្រឡាក់[212] ដែលគ្រាន់តែថ្លែងថា អោ អាន កាន់តួនាទីបែបនេះ[213]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនផ្តល់ ភ័ស្តុតាងទាល់តែសោះពាក់ព័ន្ធនឹង

---

[209] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៧០៤។

[210] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥២។

[211] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥២ ជើងទំព័រ ៦២០។

[212] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥២ ជើងទំព័រ ៦២០-៦២១ (ស.ច.ស.អ ផ្អែកទៅលើចម្លើយរបស់ បាន សៀក និង អ៊ុម ប៉ុន។ ទោះជាយ៉ាងនេះក្តី គឺបន្ទាប់តែពីអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានសួរសំណួរបិទប៉ុណ្ណោះទើប បាន សៀក ឆ្លើយថា អោ អាន ជាអនុរបស់ កែ ពក។ ពាក់ព័ន្ធនឹង អ៊ុម ប៉ុន អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានផ្តល់គំនិតឲ្យគាត់ថា អោ អាន ជាអនុលេខាភូមិភាគ រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ តាមរយៈការសួរសំណួរបិទមួយចំនួនជាបន្តបន្ទាប់។)។

[213] ឯកសារ **D6.1.652** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម), KH 003737472 ទំព័រ ១០ (ពេជ្រ ជឹម គ្រាន់តែបានឆ្លើយថា អោ អាន ជាអនុរបស់ កែ ពក ប៉ុណ្ណោះ។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់នោះទេ។)។ ឯកសារ **D6.1.707** (កំណត់ហេតុស្តាប់ចម្លើយ សួន កានិល) KH 00373509 ទំព័រ ៤ (សួន កានិល គ្រាន់តែបានឆ្លើយថា អោ អាន ក្លាយជាអនុតែប៉ុណ្ណោះ។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់នោះទេ។)។ ឯកសារ **D29** (កំណត់ហេតុស្តាប់ចម្លើយ សួន កានិល) KH 00705151-00705152 ទំព័រ ២-៣ (សួន កានិល បានឆ្លើយថា អោ អាន ជាអនុលេខាភូមិភាគកណ្តាល ប៉ុន្តែ ពេលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស សួរគាត់អំពីការងារប្រចាំថ្ងៃរបស់ អោ អាន គាត់បានឆ្លើយថា គាត់មិនដឹងទេ ពីព្រោះ អោ អាន ធ្វើការងាររបស់គាត់នៅក្នុងតំបន់។)។ ឯកសារ **D117/18** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.២ (ពេជ្រ ជឹម បានបញ្ជាក់ថា អោ អាន ជាអនុរបស់ កែ ពក ប៉ុន្តែ មិនបានផ្តល់ព័ត៌មានអំពីការងាររបស់ អោ អាន ក្នុងតំណែងនេះទេ ហើយ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់ទេ។)។ ឯកសារ **D117/35** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) ឆ.១៥ (បន្ទាប់ពីអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានសួរសំណួរបិទ បាន សៀក បាននិយាយថា អោ អាន ជាអនុរបស់ កែ ពក។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ពីប្រភពនៃភ័ស្តុតាងនេះទេ។)។ ឯកសារ **D117/39** (កំណត់ហេតុស្តាប់ចម្លើយ តូ សេម) ឆ.១៤ (តូ សេម បានឆ្លើយថា អោ អាន ជាអនុ ដោយមិនបានផ្តល់សេចក្តីលម្អិតណាមួយអំពីភារកិច្ចរបស់គាត់។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ពីប្រភពនៃភ័ស្តុតាងនេះទេ។)។ ឯកសារ **D117/50** (កំណត់ហេតុស្តាប់ចម្លើយ អ៊ុម ប៉ុន) ឆ.២៩, ឆ.៧៥ (បន្ទាប់ពីអ្នកស៊ើបអង្កេតនៃ ក.ស.ច .ស បានផ្តល់ព័ត៌មានដល់គាត់រួច អ៊ុម ប៉ុន បានអះអាងថា អោ អាន ជាអនុលេខារបស់ កែ ពក។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ថាគាត់ដឹងរឿងនេះពីប្រភពណានោះទេ។)។ ឯកសារ **D118/259** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.១៥៦, ឆ.១៦២, ឆ.១៦៥, ឆ.២០៨, ឆ.២១៦ (ពេជ្រ ជឹម គ្រាន់តែបានបញ្ជាក់ថា អោ អាន ជាអនុរបស់ កែ ពក ប៉ុណ្ណោះ។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់ទេ។)។ ឯកសារ **D219/178** (កំណត់ហេតុស្តា

កាលបរិច្ឆេទនៃការតែងតាំង អោ អាន[214] មូលហេតុដែល អោ អាន ទទួលបានការតម្លើងតួនាទី ឬ តើភារកិច្ចរបស់គាត់មានអ្វីខ្លះក្នុងតួនាទីនេះ[215]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏ខកខានមិនបានពន្យល់ អំពីវិធីដែលគាត់សម្របសម្រួលភ័ស្តុតាងប្រទាំងប្រទើសគ្នា ពាក់ព័ន្ធនឹងរយៈពេលដែល អោ អានធ្វើជាអនុលេខាតំបន់[216]។

---

ប់ចម្លើយ គុច វ៉ា) ឆ.៦ (គុច វ៉ា ជាទាហានឈរជើងនៅខេត្តកំពង់ចាម បានឆ្លើយថា អោ អាន ជាអនុរបស់ កែ ពក និងថាគាត់បានឃើញ អោ អាន ចូលរួមប្រជុំ។ ប៉ុន្តែ គាត់បានបញ្ជាក់ថា ខ្លួនគាត់មិនដែលបានចូលរួមប្រជុំទេ។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ពីប្រភពនៃភ័ស្តុតាងនេះទេ។)។ ឯកសារ **D219/249** (កំណត់ហេតុស្តាប់ចម្លើយ សួន កានិល) ឆ.៤ (សួន កានិល បានបញ្ជាក់ថា អោ អាន ជាអនុ ដោយមិនបានផ្តល់សេចក្តីលម្អិតអំពីភារកិច្ចរបស់គាត់នៅក្នុងតំណែងនេះ។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់នោះទេ។)។ ឯកសារ **D219/355** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) ឆ.៩ (បន្ទាប់ពីអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស លើកឡើងថា អោ អាន បានដឹកនាំការប្រជុំនៅភូមិភាគកណ្តាល បាន សៀក បានឆ្លើយថា អោ អាន ជាអនុរបស់ កែ ពក ប៉ុន្តែ ថាគាត់មិនដែលជួប អោ អាន នៅភូមិភាគកណ្តាល ឬសមាជិកគណៈភូមិភាគណាមួយផ្សេងទៀតទេ។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសំណួរផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ពីប្រភពនៃភ័ស្តុតាងនេះទេ។)។ ឯកសារ **D219/870** (កំណត់ហេតុស្តាប់ចម្លើយ រី ញ៉) ឆ.៣៣-ឆ.៣៤, ឆ.៣៧ (រី ញ៉ បានឆ្លើយថា ក្នុងពេលប្រជុំ នៅការដ្ឋានសង់ទំនប់ គាត់សន្និតថា អោ អាន ជាអនុប្រធានភូមិភាគ និងថា គាត់មិនដឹងថា អោ អាន ទទួលខុសត្រូវលើការងារអ្វីទេ។ ឯកសារ **D219/702.1.75** (ប្រតិចារឹកនៅក្នុងសំណុំរឿង 00២/0២-បាន សៀក), KH 01424073-01424074 ទំព័រ ៤៤-៤៥ (បន្ទាប់ពីសហព្រះរាជអាជ្ញាបានលើកឡើងប្រាប់ បាន សៀក ថា អោ អាន ជាអនុលេខារបស់ កែ ពក គាត់ក៏បានឆ្លើយថាពិតមែន។ សហព្រះរាជអាជ្ញាមិនបានសួរសំណួរផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ពីប្រភពនៃភ័ស្តុតាងនេះទេ។)។

[214] សំណុំរឿង 00៤/២-ឯកសារ **D360** កថាខណ្ឌ ៧0៤ (ស.ច.ស.អ គ្រាន់តែរកឃើញថា ក្រោយពេល កង ចាប ត្រូវបានបញ្ជូនទៅភូមិភាគឧត្តរថ្មី នៅកាលបរិច្ឆេទដែលគេមិនស្គាល់រួច អោ អាន បានក្លាយជាអនុលេខានៅភូមិភាគកណ្តាល។)។

[215] សាក្សីមិនបានផ្តល់ព័ត៌មានលម្អិតទាក់ទងនឹងការទទួលខុសត្រូវរបស់ អោ អាន នៅក្នុងតំណែងនេះទេ។ ឧទាហរណ៍ ឯកសារ **D29** (កំណត់ហេតុស្តាប់ចម្លើយ សួន កានិល) KH 00705151-00705152 ទំព័រ ២-៣ (សួន កានិល បានឆ្លើយថា អោ អាន ជាអនុលេខាភូមិភាគកណ្តាល ប៉ុន្តែ ពេលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស សួរគាត់អំពីការងារប្រចាំថ្ងៃរបស់ អោ អាន គាត់បានឆ្លើយថា គាត់មិនដឹងទេ។)។ ឯកសារ **D117/18** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.៣ (នៅពេលដែលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស សួរ ពេជ្រ ជឹម អំពីការងាររបស់ អោ អាន ជាអនុលេខាភូមិភាគ គាត់បានឆ្លើយថា អោ អាន ជាអនុលេខាភូមិភាគ ប៉ុន្តែ ពុំមានអំណាចក្នុងការធ្វើសេចក្តីសម្រេចទេ។)។ ឯកសារ **D219/178** (កំណត់ហេតុស្តាប់ចម្លើយ គុច វ៉ា) ឆ.៦-ឆ.៧ (គុច វ៉ា បានបញ្ជាក់ថា អោ អាន ជាអនុរបស់ កែ ពក និងជាសមាជិកគណៈភូមិភាគ។ ទោះជាយ៉ាងនេះក្តី គាត់មិនដឹងអំពីការងាររបស់គណៈភូមិភាគទេ។)។ ឯកសារ **D219/870** (កំណត់ហេតុស្តាប់ចម្លើយ រី ញ៉) ឆ.៤៥ (រី ញ៉ បានឆ្លើយថា គាត់មិនដឹងពីទំនួលខុសត្រូវរបស់ អោ អាន ជាអនុលេខាភូមិភាគទេ។)។

[216] សំណុំរឿង 00៤/២-ឯកសារ **D360** កថាខណ្ឌ ២៥២ ជើងទំព័រ ៦២១, ៦២៣ (ស.ច.ស.អ ផ្តល់ភ័ស្តុតាងទទួលបានពី អ៊ឹម ប៉ុន ដែលឆ្លើយថា អោ អាន នៅបន្តកាន់តំណែងជាអនុលេខាភូមិភាគរហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ និងពី តូ សេម

100. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រកឃើញដោយមិនមានហេតុផលថា អោ អាន មានការទទួលខុសត្រូវតាមនីតិន័យ ចំពោះបញ្ហាសន្តិសុខនៅភូមិភាគកណ្ដាល ប៉ុន្តែគាត់បានទទួលស្គាល់ថា គ្មានភស្តុតាងបញ្ជាក់ថា អោ អាន អនុវត្តសិទ្ធិអំណាចទៅលើមន្ទីរសន្តិសុខនៅក្នុងតំបន់៤២ និង ៤៣ ឡើយ[217]។

គ) អោ អាន មិនមែនជាអនុលេខាភូមិភាគតាមព្រឹត្តិន័យទេ

101. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រកឃើញទាំងភាន់ច្រឡំថា អោ អាន បានអនុវត្តអំណាចតាមព្រឹត្តិន័យក្នុងនាមជាអនុលខា នៅក្នុងភូមិភាគកណ្ដាល[218]។ ទី១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំណត់ថា អោ អាន បានគ្រប់គ្រង ត្រួតពិនិត្យគម្រោងសាងសង់ នៅទូទាំងភូមិភាគកណ្ដាល[219]។ ប៉ុន្តែ ពុំមានភស្តុតាងពិតប្រាកដ និងច្បាស់លាស់ដើម្បីគាំទ្រការសន្និដ្ឋាននេះ ទេ ដោយហេតុថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រឹមតែផ្អែកលើការរៀបរាប់ដំណើររឿងដែលគ្មានភស្តុតាង និង មិនមានការ បញ្ជាក់ របស់ ចាន់ សាង[220] និង ការប្រកាសរបស់ អោ អាន ផ្ទាល់អំពីការធ្វើកិច្ចការសាងសង់[221]។ ជាងនេះទៀត ការិយាល័យសហចៅក្រមស៊ើបអង្កេត មិនអើពើភស្តុ

---

ដែលបញ្ជាក់ថា អោ អាន ត្រូវបានទម្លាក់តំណែង ប្រហែលជាប្រាំមួយខែមុនពេលវៀតណាមចូលមក និងត្រូវបានជំនួសដោយ ស៊ឹម។ ដោយគ្មានការពន្យល់ ឬផ្តល់ហេតុផលបញ្ជាក់ ស.ច.ស.អ សន្និដ្ឋានថា សក្ខីកម្មរបស់ អ៊ឹម ប៊ុន អាចជឿជាក់បានជាងសក្ខីកម្មរបស់ តូ សេម។ អ៊ឹម ប៊ុន ជាអ្នកបើកឡានដែលគ្រាន់តែធ្វើការជាមួយ អោ អាន មួងម្កាលប៉ុណ្ណោះ ចំណែកឯ តូ សេម ជាប្រពន្ធរបស់កម្មាភិបាលមានតំណែង ដែលផ្តល់ភស្តុតាងដាក់បន្ទុកអំពីប្តីរបស់លោកស្រី។)។

[217] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៦១។

[218] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៩, ២៦០, ៧០៣-៧០៥។

[219] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥០ កថាខណ្ឌ ២៦៧ ជើងទំព័រ ៦៧០។

[220] ឯកសារ **D117/21** (កំណត់ហេតុស្តាប់ចម្លើយ ចាន់ សាង) ឆ.១៥-ឆ.១៦ (ចាន់ សាង គ្រាន់តែបញ្ជាក់ថា អោ អាន ជាប្រធានទំនប់ ៥ មករា ដែលមានទីតាំងស្ថិតនៅក្នុងតំបន់ ៤៣ និងថា លោកស្រីបានជួបគាត់ក្នុងពេលប្រជុំមួយដើម្បីប្រារព្ធពិធីបិទការដ្ឋាន ប៉ុណ្ណោះ។)។ ឯកសារ **D219/179** (កំណត់ហេតុស្តាប់ចម្លើយ ចាន់ សាង) ឆ.១២ (ចាន់ សាង បានបញ្ជាក់ថា អោ អាន ទទួលខុសត្រូវទំនប់ ៥ មករា ប៉ុន្តែ លោកស្រីមិនដឹងថាការងាររបស់គាត់មានអ្វីខ្លះនោះទេ។)។

[221] ឯកសារ **D219/847.1** (កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អោ អាន), KH 01337376-01337377, 01337381-01337382, 01337384-01337385 ទំព័រ ៦១-៦២, ៦៦-៦៧, ៦៩-៧០ (អោ អាន បានឆ្លើយថា គាត់ធ្វើការនៅទំនប់ ១ មករា និងនៅការដ្ឋានការងារផ្សេងទៀត ប៉ុន្តែ ក្រោយពីអ្នកសម្ភាសន៍សួរសំណួរបិទមួយចំនួនជាបន្តបន្ទាប់ទៀតរួច គាត់បានឆ្លើយថា គាត់គ្រាន់តែដឹកនាំកម្លាំងពលកម្មនៃតំបន់ ៤១ ក្នុងទីតាំងទាំងនេះប៉ុណ្ណោះ។)។

តាងដោះបន្ទុកអំពីទំនប់១មករា ដែលគេចោទថាជាការដ្ឋានដឹកនាំដោយភូមិភាគ[222]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏សន្និដ្ឋានផងដែរថា អោ អាន បានចុះពិនិត្យតំបន់ដទៃទៀត និង ការដ្ឋាននានា ទូទាំងភូមិភាគកណ្តាល[223]។ ប៉ុន្តែ ពុំមានភស្តុតាងគួរឲ្យជឿទុកចិត្តបានថា អោ អាន បានធ្វើដំណើរក្រៅតំបន់ ៤១ ដើម្បីទៅពិនិត្យការដ្ឋាន ហើយ សាក្សី៣នាក់ដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកលើ គឺពិភាក្សាត្រឹមតែការចុះទៅការដ្ឋាន មិនមែនថា អោ អាន គ្រប់គ្រងត្រួតពិនិត្យការដ្ឋានឡើយ[224]។

---

[222] មានភស្តុតាងសំខាន់ដែលគាំទ្រដល់ការដែលថា ទំនប់ ១ មករា ពិតជាស្ថិតក្រោមការគ្រប់គ្រងរបស់ កែ ពក មិនមែន អោ អាន ប្រាកដមែន។ ប្រសិនបើ អោ អាន មានសិទ្ធិអំណាចនៅថ្នាក់ភូមិភាគ ដូចដែល ស.ច.ស.អ បានរកឃើញ នោះ អោ អាន គួរតែមានតួនាទីមួយនៅទំនប់នោះ។ ឯកសារ **D6.1.379** (កំណត់ហេតុស្តាប់ចម្លើយ កែ ពេជ្រវណ្ណៈ), KH 00340563-00340564 ទំព័រ ៥-៦ (កែ ពេជ្រវណ្ណៈ បានបញ្ជាក់ថា គាត់បានជូនឪពុករបស់គាត់ កែ ពក ទៅរៀបចំផែនការសាងសង់ទំនប់ ១ មករា ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់គណៈភូមិភាគកណ្តាលដែលមានសមាសភាព កែ ពក, ស្រេង, តុល និង ចន។)។ ឯកសារ **D6.1.384** (កំណត់ហេតុស្តាប់ចម្លើយ ទេព ប៊ូច), KH 00348842 ទំព័រ ៥ (ទេព ប៊ូច បានបញ្ជាក់ថា កែ ពក ដឹកនាំការដ្ឋានសាងសង់ទំនប់ ១ មករា។)។ ឯកសារ **D6.1.410** (កំណត់ហេតុស្តាប់ចម្លើយ មាស ឡៃហួ), KH 00239931 ទំព័រ ៥ (មាស ឡៃហួ បាននិយាយថា កែ ពក មកត្រួតពិនិត្យទំនប់ ១ មករា។)។ ឯកសារ **D6.1.437** (កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ុន), KH 00271382 ទំព័រ ៥ (កែ អ៊ុន អ្នកបើកឡានឲ្យ កែ ពក បានឆ្លើយថា គាត់បានជូន កែ ពក នៅការដ្ឋានទំនប់ ១ មករា ស្ទើរតែរាល់ថ្ងៃ។)។ ឯកសារ **D6.1.675** (កំណត់ហេតុស្តាប់ចម្លើយ អៀង ឆាំ), KH 00402446-00402447 ទំព័រ ៩-១០ (អៀង ឆាំ បានឆ្លើយថា ផែនការមេទំនប់ ១ មករា ត្រូវបានកំណត់ដោយ កែ ពក ដែលដឹកនាំពិធីបើកការដ្ឋាន។)។ ឯកសារ **D6.1.722** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត) ឆ.១៨ (ប្រាក់ យុត បានបញ្ជាក់ថា ទំនប់ ១ មករា ជាគម្រោងរបស់ភូមិភាគកណ្តាល ក្រោមការគ្រប់គ្រងរបស់ កែ ពក។)។ ឯកសារ **D219/702.1.96** (ប្រតិចារឹកក្នុងសំណុំរឿង ០០២-ឱ ហូ) KH 01505370, 01505372 ទំព័រ ២៥, ២៧ (ឱ ហូ ជាកម្មករនៅទំនប់ ១ មករា និងទំនប់ ៦ មករា។ គាត់បានឆ្លើយថា កែ ពក ត្រូវបានចាត់តាំងពីថ្នាក់លើឲ្យទៅទទួលបន្ទុកនៅទីនោះ។ គាត់មិនបានលើកឡើងពី អោ អាន ទេ។)។

[223] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥១។

[224] ឯកសារ **D117/21** (កំណត់ហេតុស្តាប់ចម្លើយ ចាន់ សាង) ឆ.១៥-ឆ.១៦ (ចាន់ សាង បានបញ្ជាក់ថា លោកស្រីបានជួប អោ អាន ក្នុងពេលប្រជុំមួយដើម្បីប្រារព្ធពិធីបិទការដ្ឋានទំនប់ ៥ មករា។)។ ឯកសារ **D219/179** (កំណត់ហេតុស្តាប់ចម្លើយ ចាន់ សាង) ឆ.12 (ចាន់ សាង បានបញ្ជាក់ថា អោ អាន ទទួលខុសត្រូវទំនប់ ៥ មករា ប៉ុន្តែ លោកស្រីមិនដឹងថាការងាររបស់គាត់មានអ្វីខ្លះនោះទេ។)។ ឯកសារ **D117/50** (កំណត់ហេតុស្តាប់ចម្លើយ អ៊ឹម ប៊ុន) ឆ.៤១ (អ៊ឹម ប៊ុន បានបញ្ជាក់ថា អោ អាន ទៅទំនប់ ១ មករា និងទំនប់ ៦ មករា។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសាក្សីនូវសំណួរផ្ទៀងផ្ទាត់ដើម្បីបញ្ជាក់ពីប្រភពនៃភស្តុតាងនេះទេ។)។ ឯកសារ **D219/731** (កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន) ឆ.៧២-ឆ.៧៩ (ញ៉ែម ចេន បានឆ្លើយថា

102. ទី២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រកឃើញថា អោ អាន បានផ្តល់ដល់ពលករ និង ធនធាន ពីតំបន់៤១ ទៅការដ្ឋាន ទូទាំងភូមិភាគកណ្តាល[225] ប៉ុន្តែ ការវិភាគទៅលើខ្លឹមសារភ័ស្តុតាងមិនបាន គាំទ្រសំអាងនេះឡើយ[226]។ ជាងនេះ ទៀត ការរកឃើញនេះ អាចបង្ហាញតួនាទីកាន់តែទាប មិន មែនជាតួនាទីដែលបញ្ជាក់ថា អោ អាន ស្ថិតក្នុងចំណោមជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់ បំផុតនោះទេ។

103. ទី៣ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថា អោ អាន ច្បាស់ជា អនុលេខាភូមិភាគ ពីព្រោះគាត់បានចូលរួមប្រជុំ នៅភ្នំពេញ និង ប្រជុំថ្នាក់ភូមិភាគនៅកំពង់ចាម ដើម្បីរៀបចំផែនការ បោសសម្អាត[227]។ ប៉ុន្តែដូចដែលបាន ពន្យល់នៅក្នុងផ្នែក II(ង)(ii), (ង)(iv)(គ) ភ័ស្តុតាងមិនគាំ ទ្រសម្អាងហេតុនេះស្របតាមលក្ខខណ្ឌបទដ្ឋាន ភ័ស្តុតាង ឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរ ជាតិ ក៏កំណត់ផងដែរថា អោ អាន គឺជាអនុលេខាតំបន់ពីព្រោះគាត់មានវត្តមាន ក្នុង កិច្ចប្រជុំ យោធាថ្នាក់តំបន់ និង ការតែងតាំងមេបញ្ជាការមញ្ជនាក់ក្នុងវរសេនាធំលេខ៧១ ក្នុងកងពល ១១៧[228]។ ប៉ុន្តែ សម្អាងហេតុទាំងនេះមិនគាំទ្រដោយ ភ័ស្តុតាងផ្ទាល់ ពិតប្រាកដ និងមានការ

---

អោ អាន បានធ្វើទស្សនកិច្ចនៅចម្ការលើ (តំបន់ ៤២) កំពង់ធំ (តំបន់ ៤៣) និងភ្នំពេញ។ គាត់មិនបានលើកឡើងពីការដ្ឋានណាមួយទេ។)។

[225] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥២។

[226] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៩ ជើងទំព័រ ៦៥២ (ស.ច.ស.អ ផ្អែកលើកិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ អោ អាន ដែលនៅក្នុងនោះ គាត់គ្រាន់តែបានឆ្លើយថា ពួកគេបានយកកម្លាំង និងកងចល័តពីតំបន់ ៤១, តំបន់ ៤២ និងតំបន់ ៤៣ ដើម្បីទៅសង់ទំនប់ ១ មករា និងទំនប់ ៦ មករា។ លើសពីនេះទៀត ស.ច.ស.អ ផ្អែកលើចម្លើយរបស់ សាត ភាព និង ញ៉ឹម កុល។ ទោះជាយ៉ាងនេះក្តី សាត ភាព គ្រាន់តែបានឆ្លើយថា ទំនប់ (មិនច្បាស់ថាទំនប់មួយណាទេ) ជាគម្រោងរបស់ភូមិភាគដែលតំបន់នីមួយៗដែលនៅជិត ត្រូវបញ្ជូនកម្មករទៅ ប៉ុន្តែ មិនបានលើកឡើងពី អោ អាន ទេ។ ញ៉ឹម កុល បានឆ្លើយថា ជួនកាល គាត់ធ្វើដំណើរទៅកាន់ស្រុកផ្សេងទៀតដើម្បីយកអាហារនៅទីនោះ ប៉ុន្តែ មិនបានលើកឡើងពី អោ អាន ទេ។)។ ស.ច.ស.អ ក៏មិនបានបង្ហាញភ័ស្តុតាងផ្ទុយដែរ។ ឧទាហរណ៍ ឯកសារ **D6.1.722** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត) ឆ.១៦-ឆ.១៧, ឆ.១៩-ឆ.២០, ឆ.២២ (ប្រាក់ យុត បានឆ្លើយថា លោកស្រីត្រូវបានស្នើឱ្យបញ្ជូនកម្មករពីស្រុកកំពង់សៀមទៅការដ្ឋានទំនប់ ១ មករា ដោយសមមិត្ត ស្រេង មិនមែន អោ អាន ទេ។)។

[227] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៩។

[228] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៦០។ មេធាវីការពារក្តីកត់សម្គាល់ថា ស.ច.ស.អ ទទួលស្គាល់ថា មិនច្បាស់ថាតើ អោ អាន បានចូលរួមក្នុងការប្រជុំយោធាថ្នាក់ភូមិភាគជាទៀងទាត់ ក្នុងឋានៈជាលេខាតំបន់ ឬសមាជិកភូមិភាគ ឬយ៉ាងណាទេ។

បញ្ជាក់ ឡើយ[229]។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានផ្តល់នូវភ័ស្តុតាងគ្រប់គ្រាន់ណាមួយបញ្ជាក់ថាអោ អាន និយាយអំពីបញ្ហាសន្តិសុខថ្នាក់ភូមិភាគ ក្នុងនោះរួមមាន វត្តភ្នំប្រុស ដែលជាមន្ទីរសន្តិសុខភូមិភាគ[230]។

104. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានផ្តល់យុត្តិកម្មភ័ស្តុតាងផ្សេងទៀតសម្រាប់ការរកឃើញរបស់គាត់ ដែលថាអោ អាន គឺជាអនុលេខាភូមិភាគតាមព្រឹត្តិន័យ[231]។ គាត់ប្រើប្រាស់តួនាទី របស់

---

[229] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៦០ ជើងទំព័រ ៦៥៧-៦៥៨ (ស.ច.ស.អ ផ្អែកលើភ័ស្តុតាងរបស់ នីប គីមហេង, ញ៉ែម ចេន, គុច រ៉ា និង បាន សៀក។ ទោះជាយ៉ាងនេះក្តី នីប គីមហេង គ្រាន់តែបានឆ្លើយថា មន្ទីរភូមិភាគ ១១៧ ដំបូងមានទីតាំងស្ថិតនៅក្នុងទីរួមខេត្តកំពង់ចាម ប៉ុណ្ណោះ។ ពុំមានការលើកឡើងពី អោ អាន ទេ។ ញ៉ែម ចេន ដែលមិនអាចជឿជាក់បាន បានឆ្លើយថា អោ អាន ទៅប្រជុំយោធានៅកំពង់ចាម ប៉ុន្តែ មូលដ្ឋាននៃការដឹងរបស់គាត់មិនច្បាស់លាស់ ពីព្រោះគាត់បានទទួលស្គាល់ថាមិនបានធ្វើដំណើរជាមួយ អោ អាន ទៅប្រជុំទាំងនោះទេ។ គុច រ៉ា បានបញ្ជាក់ថា គាត់បានឃើញ អោ អាន ជាច្រើនដង ទៅចូលរួមប្រជុំនៅខេត្តកំពង់ចាម ជាមួយ កែ ពក ប៉ុន្តែ មូលដ្ឋាននៃការដឹងរបស់គាត់ក៏មិនច្បាស់លាស់ដែរ ដោយសារតែគាត់មិនបានចូលរួមក្នុងការប្រជុំទាំងនោះទេ។ បាន សៀក បាននិយាយថា សុន សេន ជាប្រធានភូមិភាគ និងបញ្ជាការយោធា ប៉ុន្តែ គាត់មិនបានលើកឡើងពីការប្រជុំណាមួយឡើយ។)។

[230] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៤២-៥៤៤ ជើងទំព័រ ១៨០៧-១៨០៩ (ស.ច.ស.អ ទទួលស្គាល់ថា វត្តភ្នំប្រុសស្ថិតនៅក្រោមការគ្រប់គ្រងរបស់ កែ ពក និង ឈិត ជឿន រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ។ គាត់មិនបានផ្តល់ភ័ស្តុតាងសំខាន់ៗគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់គាត់ថា អោ អាន បានរៀបចំផែនការជាមួយគណៈភូមិភាគកណ្តាល ដើម្បីបញ្ជូនមនុស្សទៅមន្ទីរសន្តិសុខនេះទេ) កថាខណ្ឌ ៥៤៥ ជើងទំព័រ ១៨២០ (ភ័ស្តុតាងដែលបានដកស្រង់ពី ញ៉ែម ចេន និង កែ ពេជ្រវណ្ណៈ បង្ហាញថា អោ អាន ស្ទើរតែគ្មានតួនាទីពាក់ព័ន្ធនឹងវត្តភ្នំប្រុសសោះ។ ញ៉ែម ចេន ដែលមិនអាចជឿងជាក់បាន បានលើកឡើងថា ពេលចេញលិខិតចាប់មនុស្សពីភូមិភាគបូព៌ា ពួកគេនឹងត្រូវចាប់ខ្លួន ដាក់នៅកន្លែងរបស់ អោ អាន និងបញ្ជូនទៅសម្លាប់នៅភ្នំប្រុសភ្នំស្រី។ គាត់មិនបានបញ្ជាក់ថា អ្នកណាជាអ្នកចេញលិខិតទេ ប៉ុន្តែ ផ្ទុយទៅវិញ គាត់ធ្វើការស្មាន។ ភ័ស្តុតាងរបស់ កែ ពេជ្រវណ្ណៈ ដែលគ្មានការបញ្ជាក់ និងមិនអាចជឿជាក់បាន ក៏មិនគ្រប់គ្រាន់ដើម្បីបំពេញតាមស្តង់ដារនៃភ័ស្តុតាងដែរ។ កែ ពេជ្រវណ្ណៈ មានហេតុផលនឹងកុហក ដើម្បីការពារឪពុករបស់គាត់ និងឈ្មោះគ្រួសាររបស់គាត់) កថាខណ្ឌ ៥៥៥ (ពុំមានភ័ស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អោ អាន បានធ្វើទស្សនកិច្ចនៅការដ្ឋាន។)។

[231] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៤៩ (ស.ច.ស.អ ទទួលស្គាល់ថា ពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីសន្និដ្ឋានថា អោ អាន គ្រប់គ្រងលើជនដែលនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលត្រូវបានចោទប្រកាន់នៅក្នុងតំបន់ ៤២ និងតំបន់ ៤៣។)។ មេធាវីការពារក្តីលើកឡើងថា មានភ័ស្តុតាងតិចតួច ប្រសិនបើមាន ដែលបង្ហាញថា អោ អាន បានចូលរួមក្នុងការប្រជុំថ្នាក់ភូមិភាគ ឬបានទទួល និងអនុវត្តបញ្ជាមកពី កែ ពក នៅទូទាំងភូមិភាគ។ ពុំមានភ័ស្តុតាងអំពីការដែលថា អោ អាន បានតែងតាំងលេខាតំបន់ ឬស្រុកណាមួយនៅក្នុងតំបន់ ៤២ និង ៤៣ ទស្សនកិច្ចនៅតំបន់ ៤១ របស់ថ្នាក់ភូមិភាគ នីរសារតំបន់ ៤២ ឬតំបន់ ៤៣ ឬភ័ស្តុតាងណាមួយបញ្ជាក់ថា នីរសាររបស់ អោ អាន ធ្វើដំណើរទៅទីរួមខេត្តកំពង់ចាម ឬតំបន់ផ្សេងទៀតដើម្បីប្រគល់ ឬទទួលទូរលេខ ឬរបាយការណ៍។

អោ អាន ជាអនុលេខាតំបន់ ដើម្បី ធ្វើសំអាងហេតុមួយចំនួនដោយពុំបានផ្តល់នូវមូលដ្ឋានភ័ស្តុតាងដែលមានហេតុផលឡើយ[232]។ សំអាងហេតុ ទាំងនេះពុំបំពេញបានតាមលក្ខខណ្ឌបទដ្ឋានភ័ស្តុតាងឡើយ ពីព្រោះមិនផ្អែកលើភ័ស្តុតាងគ្រប់គ្រាន់ពិតប្រាកដ ដែលមានការបញ្ជាក់ច្បាស់លាស់[233]។

105. បើទោះជា អោ អាន គឺជាអនុលេខាភូមិភាគ ក៏មិនមានន័យថា គាត់ស្ថិតក្នុងចំណោមជនដែលទទួលខុសត្រូវខ្ពស់បំផុត និង ស្ថិតក្រោមយុត្តាធិការបុគ្គលរបស់តុលាការដែរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានត្រឹមតែរកឃើញថា អោ អាន កាន់តួនាទីនេះក្នុងរយៈពេលខ្លី យ៉ាងយូរគឺចាប់ពីចុងឆ្នាំ១៩៧៧ រហូតដល់ចប់របបកម្ពុជាប្រជាធិបតេយ្យ ពោលគឺប្រហែល១ឆ្នាំ។ រយៈពេលដ៏ខ្លីនេះ មិនបង្ហាញថា អោ អាន កាន់តួនាទីសំខាន់ ឬតួនាទីដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាល ដំណើរការធ្វើសេចក្តីសម្រេច ឬការផ្សព្វផ្សាយឬអនុវត្ត គោល នយោបាយ បក្សកុម្មុយនីស្តកម្ពុជា នៅថ្នាក់តំបន់ លើយ។ ហេតុដូច្នេះ អោ អាន មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាបុគ្គលម្នាក់ក្នុងចំណោមបុគ្គលដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានចោទប្រកាន់នោះទេ។

### v. អោ អាន មិនមានតួនាទីឬសិទ្ធិអំណាចធំនៅក្នុងតំបន់៤១នោះទេ

106. ដូចដែលពិភាក្សានៅក្នុងអនុផ្នែកខាងក្រោម ការវិភាគទៅលើខ្លឹមសារភ័ស្តុតាង មិនបង្ហាញថា អោ អាន ជាលេខាតំបន់៤១ តាមនីតិន័យឬព្រឹត្តន័យទេ ឬថា គាត់មានសិទ្ធិអំណាចក្នុងការសម្រេចអំពីមធ្យោបាយនៃការផ្សព្វផ្សាយឬអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា ក្នុងភូមិភាគ៤១ទេ។ បើទោះជា អោ អាន មានតួនាទី ឬសិទ្ធិអំណាចនេះក៏ដោយ ក៏មិនមានន័យថាគាត់ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតដែរ។

107. មេធាវីការពារក្តីកត់សម្គាល់ថា នៅពេលកំណត់អំពីមុខតំណែង តួនាទី និង សិទ្ធិអំណាចរបស់ អោ

---

[232] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៧១៩ (អោ អាន ជាអ្នកចូលរួមដ៏សំខាន់ម្នាក់នៅក្នុងការវាយប្រហារជាប្រព័ន្ធ និងទូលំទូលាយប្រឆាំងនឹងប្រជាជនស៊ីវិល។) កថាខណ្ឌ ៨២៦ (អោ អាន បានដឹងពីសកម្មភាពទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងតំបន់ និងភូមិភាគរបស់គាត់។) កថាខណ្ឌ ៨៣៤ (អោ អាន ត្រួតពិនិត្យលើការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាស្តីពីការរៀបការ។)។

[233] ក្រមនីតិវិធីព្រហ្មទណ្ឌ (បារាំង) មាត្រា ១៨៤ (ចែងថា ដីកាបង្គាប់ដែលចេញដោយចៅក្រមស៊ើបអង្កេត "បញ្ជាក់ពីការកំណត់ប្រភេទបទល្មើសនៃអង្គហេតុដែលត្រូវបានចោទប្រកាន់ទៅលើបុគ្គលនោះ [បុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេតតាមផ្លូវតុលាការ] និងបញ្ជាក់យ៉ាងច្បាស់លាស់ពីមូលហេតុដែលមាន ឬមិនមានភ័ស្តុតាងគ្រប់គ្រាន់ប្រឆាំងនឹងបុគ្គលរូបនោះ។")។

អាន នៅក្នុងតំបន់៤១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើកឡើងពន្លើសម្តងហើយម្តងទៀត និងបង្ហាញភ័ស្តុតាងខុស[234] ព្រមទាំង ជារឿយៗប្រើភាសាខែមិនឆ្លុះបញ្ចាំងត្រឹមត្រូវទៅលើភ័ស្តុតាង[235] ដែលជាបរាជ័យមួយក្នុង ភារកិច្ចរបស់ខ្លួនក្នុងការស្វែងរកការពិតដោយមិនលម្អៀង។

## ក) អោ អាន មិនមែនជាលេខាតំបន់៤១ តាមនីតិន័យទេ

108. ការកំណត់របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថា អោ អាន គឺជាលេខាតំបន់៤១តាមនីតិន័យ[236] គឺមិនផ្អែកលើភ័ស្តុតាង គ្រប់គ្រាន់ឡើយ។ ពុំមានភ័ស្តុតាងពិតប្រាកដនិងច្បាស់លាស់ថា កែ ពក បានតែងតាំង អោ អាន ជំនួស តំណែងគាត់ កាលបរិច្ឆេទច្បាស់លាស់ និងទីតាំងនៃការ

---

[234] ឧទាហរណ៍ ស.ច.ស.អ បានកំណត់ប្រភេទភ័ស្តុតាងដោយមិនត្រឹមត្រូវ ទាក់ទងនឹងស្រុកកំពង់សៀម និងបង្ហាញវាថាជាភ័ស្តុតាងបង្ហាញពីសិទ្ធិអំណាចដែល អោ អាន មានទៅលើស្រុកទាំងអស់នៅក្នុងតំបន់ ៤១។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៣ (បន្ទាប់ពីពិចារណាលើភ័ស្តុតាងដែលគ្មានការបញ្ជាក់របស់ ប្រាក់ យុត អំពីបញ្ជីឈ្មោះប្រជាជនចាមដែលត្រូវបានរៀបចំនៅក្នុងស្រុកកំពង់សៀមរួច ស.ច.ស.អ បញ្ជាក់ថា៖ "មានភ័ស្តុតាងបញ្ជាក់ថា ក៏មានការធ្វើបញ្ជីឈ្មោះជនជាតិចាមនៅស្រុកកងមាស និងស្រុកជើងព្រៃផងដែរ គ្រង់នេះអាចទាញការសន្និដ្ឋានថា នេះក៏ជាបញ្ជារបស់ អោ អាន ផងដែរ"។ គ្មានភ័ស្តុតាងនៅក្នុងសំណុំរឿងគាំទ្រដល់ការសន្និដ្ឋាននេះទេ។)។ បន្ថែមលើសពីនេះទៀត ស.ច.ស.អ ទាញការសន្និដ្ឋានថា អោ អាន បានបញ្ជាឱ្យចាប់ និងសម្លាប់ តាមរយៈការកើតមានឡើងនូវហេតុការណ៍ទាំងនេះតែប៉ុណ្ណោះ និងដោយគ្មានភ័ស្តុតាងដែលបញ្ជាក់ថា អោ អាន ពិតជាបានចេញបញ្ជាទេ។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៥ ជើងទំព័រ ៧៧៤ (ពាក់ព័ន្ធនឹងការចាប់ខ្លួនមិត្តសុបដែលត្រូវបានចោទប្រកាន់ ស.ច.ស.អ ផ្អែកលើចម្លើយរបស់ តូច មៀច, យុន សារ៉េត, សាត ភាព, សឹង លឹម និង ដួង ស៊ឹម។ ក៏ប៉ុន្តែ តូច មៀច និង យុន សារ៉េត មិនបានលើកឡើងថា អោ អាន មានតួនាទីក្នុងការចាប់ ឬសម្លាប់ សុប ឬបណ្តាញរបស់ សុប។ សាត ភាព គ្រាន់តែបានបញ្ជាក់ថា សុប ត្រូវបានចាប់ខ្លួនដោយ "កម្មាភិបាលតំបន់" ដោយពុំមានការបញ្ជាក់ជាក់លាក់ពី អោ អាន ទេ។ សឹង លឹម, គង់ ទឹង និង ដួង ស៊ឹម បានឆ្លើយថា សុប ត្រូវបានចាប់ខ្លួន ពេល កម្មាភិបាលភូមិភាគនិរតី មកដល់ ប៉ុន្តែ ពួកគេមិនបានលើកឡើងថាបញ្ជាចេញពី អោ អាន ទេ។)។

[235] ពេលខ្លះ ស.ច.ស.អ ហាក់ដូចជាមានចេតនាប្រើប្រាស់បច្ចេកទេសដើម្បីចៀសវាងការទទួលស្គាល់ដោយផ្អែកលើភ័ស្តុតាងថា អោ អាន ពុំមានសិទ្ធិអំណាច ។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៥ ជើងទំព័រ ៧៧៥ (នៅពេលរៀបរាប់ពីបញ្ជារបស់ អោ អាន ឱ្យចាប់ និងសម្លាប់ សុប និងបក្សពួករបស់ សុប ស.ច.ស.អ បានប្រើប្រាស់ទម្រង់អកម្ម និងលើកឡើងថា ងួវ "ត្រូវបានតែងតាំងឱ្យជំនួស សុប"។ ក្នុងបរិបទនៃកថាខណ្ឌនេះ ភាសានេះនាំអ្នកអានឱ្យជឿជាក់ថា អោ អាន បានឱ្យ ងួវ ជំនួស សុប ។ តាមពិត ភ័ស្តុតាងមិនគាំទ្រដល់ការសន្និដ្ឋាននេះទេ។)។

[236] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៥-២៤៩, ៧០៣។

តែងតាំង ឬមូលហេតុនៃការតែងតាំង អោ អាន ឡើយ[237]។ ជាងនេះទៀត គឺភ័ស្តុតាងមិនមានលក្ខណៈគ្រប់គ្រាន់ ពោលគឺ មានតែចម្លើយរបស់អ្នកដាក់ពាក្យ សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីម្នាក់ប៉ុណ្ណោះ ដែលពុំមានការបញ្ជាក់ និង មិនអាចជឿជាក់បាន ដែល ថ្លែងថា អោ អាន បានប្រកាសថា គាត់កាន់តួនាទីជាលេខាតំបន់នៅខែមីនា ឆ្នាំ១៩៧៧ នៅក្នុងកិច្ចប្រជុំមួយ នៅវត្តតាមាក់[238]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានផ្តល់ភ័ស្តុតាងគ្រប់គ្រាន់ថា អោ អានគឺ

---

[237] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៥ ជើងទំព័រ ៥៩៨។ (ស.ច.ស.អ ផ្អែកលើចម្លើយរបស់ ប្រាក់ យុត និង ពេជ្រ ជឹម តែគ្មាននរណាម្នាក់ផ្តល់ភ័ស្តុតាងអាចជឿជាក់ ស៊ីសង្វាក់ និងមានការបញ្ជាក់នោះទេ។ ភ័ស្តុតាងរបស់ ប្រាក់ យុត មួយផ្នែកបានមកដោយសារអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស បានប្រាប់លោកស្រីពីព័ត៌មានដាក់បន្ទុក។ ឯកសារ **D117/70** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត) ឆ.២០, ឆ.២៣។ លើសពីនេះទៀត ដូចបានពន្យល់នៅក្នុងផ្នែក II(ឃ)(ii)(ក) និង **ឧបសម្ព័ន្ធ គ និង ឃ** ស.ច.ស.អ មិនបានពិចារណាលើការដែលថា ប្រាក់ យុត មានហេតុផលនឹងនិយាយកុហក និងបានលើកឡើងផ្ទុយនឹងខ្លួនឯងជាច្រើនដង ទាក់ទងនឹងតំណែងរបស់ អោ អាន នៅក្នុងតំបន់ ៤១។ ស្រដៀងគ្នានេះដែរ ពេជ្រ ជឹម ផ្តល់ចម្លើយមិនស៊ីសង្វាក់គ្នាអំពីការតែងតាំង និងកាលបរិច្ឆេទ។ ប្រៀបធៀបឯកសារ **D219/702.1.99** (ប្រតិចារឹកក្នុងសំណុំរឿង ០០២/០២-ពេជ្រ ជឹម), KH 01450017 ទំព័រ ៥២ (ពេជ្រ ជឹម ឆ្លើយថា ក្នុងពេលប្រជុំនៅកំពង់ចាមជាមួយ កែ ពក, កែ ពក ប្រគល់ទំនួលខុសត្រូវទៅស្រុក។ គាត់មិនបានលើកឡើងពីការតែងតាំង អោ អាន ទេ។) ជាមួយនឹងឯកសារ **D117/18** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.១ (ពេជ្រ ជឹម បានឆ្លើយថា គាត់ត្រូវបានបញ្ជូនទៅទីក្រុងភ្នំពេញ នៅខែកុម្ភៈ ឆ្នាំ ១៩៧៧។) ជាមួយនឹងឯកសារ **D6.1.651** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម), KH 00373389 ទំព័រ ៥ (ពេជ្រ ជឹម បានបញ្ជាក់ថា គាត់ត្រូវបានបញ្ជូនទៅភូមិភាគកណ្តាល នៅកំពង់ចាមនៅថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ១៩៧៧។) ជាមួយនឹងឯកសារ **D118/259** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.១៦៩, ឆ.១៧៣ (ពេជ្រ ជឹម បានឆ្លើយថា គាត់បានធ្វើដំណើរទៅទីក្រុងភ្នំពេញ និងមកដល់ភូមិភាគកណ្តាលនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ១៩៧៦ នៅថ្ងៃតែមួយជាមួយ អោ អាន។)។ ស.ច.ស.អ បានព្យាយាមដោយមិនជោគជ័យក្នុងការបញ្ជាក់ភ័ស្តុតាងរបស់ ប្រាក់ យុត និង ពេជ្រ ជឹម ជាមួយចម្លើយរបស់ យូ វ៉ាន់ និង ពុត កុល ដែលមិនអាចជឿជាក់បាន។ យូ វ៉ាន់ បានពន្យល់ថា លោកស្រីមិនដែលបានចូលរួមប្រជុំនៅកំពង់ចាម ឬជាមួយមេដឹកនាំជាន់ខ្ពស់ណាម្នាក់ និងមិនបានលើកឡើងពីការតែងតាំង អោ អាន ដែលត្រូវបានចោទប្រកាន់ទេ។ លោកស្រីទទួលស្គាល់ថា ប្រាក់ យុត បានប្រាប់លោកស្រីពីតំណែងរបស់បុគ្គលផ្សេងៗ។ ពុត កុល គ្រាន់តែបាននិយាយថា អោ អាន មានតំណែងជាលេខា ប៉ុន្តែ មិនបានផ្តល់ព័ត៌មានអំពីការតែងតាំង អោ អាន សេចក្តីលម្អិតអំពីសកម្មភាពរបស់គាត់ ឬភ័ស្តុតាងអំពីការចូលរួមប្រជុំនៅក្រុងកំពង់ចាមទេ។ លោកស្រីមានទំនាក់ទំនងជិតស្និទ្ធិជាមួយ ប្រាក់ យុត និងអាចផ្លាស់ប្តូរដំណើររឿងរបស់លោកស្រីដើម្បីការពារ ប្រាក់ យុត។)។

[238] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៧ ជើងទំព័រ ៦០៣ (ស.ច.ស.អ ផ្អែកលើចម្លើយ ពេញ វ៉ា ដែលបញ្ជាក់ថា អោ អាន បានប្រកាសថា គាត់ជាលេខាតំបន់ ៤១ ថ្មី នៅក្នុងការប្រជុំមួយនៅក្នុងវត្តនៅឃុំជ្រៃវៀន។ គាត់ព្យាយាមធ្វើការបញ្ជាក់ចំពោះចម្លើយរបស់ ពេញ វ៉ា ដែលមិនអាចជឿជាក់បានជាមួយនឹងភ័ស្តុតាងអំពីកាលបរិច្ឆេទដកអ្នកកាន់តំណែងមុន អោ អាន ឈ្មោះ តាតាំង។ ទោះជាយ៉ាងនេះក្តី ភ័ស្តុតាងនេះមិនមានភាពពាក់ព័ន្ធដោយផ្ទាល់ និងមិនបញ្ជាក់ចំពោះចម្លើយនេះទេ។)។

ជាលេខាតំបន់៤១ តាមនីតិន័យនោះឡើយ។

## ខ) អោ អាន មិនមែនជា លេខាតំបន់៤១តាមព្រឹត្តន័យឡើយ

109. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានបង្កើតបទដ្ឋានលក្ខខណ្ឌចាំបាច់ ដែលថា អោ អាន មានសិទ្ធិអំណាច តាមព្រឹត្តន័យ ជាលេខាតំបន់៤១៖ អោ អាន មិនបានទទួល ឬ អនុវត្តបទបញ្ជាពី កែពក ឬ គណៈភូមិភាគ កណ្តាលអំពីបញ្ហាណាមួយនៅក្នុងតំបន់៤១ ឬ រាយការណ៍អំពីសភាពការណ៍នៅក្នុងតំបន់៤១ ទៅកាន់ កែ ពក ឡើយ។ គាត់មិនបានតែងតាំងលេខាស្រុក លេខាឃុំ ឬ បុគ្គលិកសំខាន់ៗនៅក្នុងតំបន់៤១ឡើយ ហើយគាត់ក៏មិនមានសិទ្ធិអំណាចក្នុងការដកតែងតាំងជំនួស ឬ ដាក់ទណ្ឌកម្មចំពោះបុគ្គលទាំងនេះឡើយ។ អោ អាន មិនចេញបញ្ជា ឬអនុញ្ញាតឲ្យអនុវត្តចំណាត់ការទៅលើបុគ្គលទាំងនេះឡើយ ហើយគាត់ក៏មិនបាន ទទួលរបាយការណ៍ពីពួកគេវិញដែរ។ អោ អាន មិនបានចូលរួម ឬដឹកនាំកិច្ចប្រជុំអំពីបញ្ហានយោបាយ សន្តិសុខ ឬ យោធាឡើយ។ ជាការផ្ទុយទៅនឹងសំអាងហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អោ អាន មិនអនុវត្តអំណាចតាមផ្លូវច្បាប់ក្នុងឋានៈជាលេខាតំបន់ឡើយ[239]។

### *(១) អោ អាន មិនបានទទួល អនុវត្ត ឬរាយការណ៍បទបញ្ជាថ្នាក់ភូមិភាគ នៅក្នុងតំបន់៤១ឡើយ*

110. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់សំអាងហេតុទាំងភាន់ច្រឡំថា ក្នុងនាមជាលេខាតំបន់៤១ អោ អាន បានទទួល បានអនុវត្ត និង បានរាយការណ៍អំពីបទបញ្ជាពី កែ ពក ឬ គណៈកម្មាធិការភូមិភាគកណ្តាលឲ្យចាប់ និង សម្លាប់ អតីតកម្មាភិបាល និង ខ្មាំងនៅក្នុងតំបន់៤១[240]។ ជាងនេះទៀត គាត់មានកំហុសដែលសំអាងថា តាម បញ្ជាពី កែ ពក ឬ ក្រោយពីមានការពិគ្រោះគ្នាជាមួយគាត់ អោ អាន បានរៀបចំផែនការជំនួសអតីតកម្មា ភិបាល និង ដឹកនាំមនុស្សពីភូមិភាគបូព៌ាទៅតំបន់៤១ដើម្បីសម្លាប់[241]។ មានភ័ស្តុតាងតិចតួចណាស់ ប្រសិនបើ មាន អំពី អោ អាន ឬ អ្នកនៅក្រោមឱវាទរបស់គាត់ដែលបង្ហាញថា អោ អាន ធ្វើការទំនាក់ទំនងដោយ ផ្ទាល់ ឬដោយប្រយោល ជាមួយ កែ ពក ឬ កម្មាភិបាលថ្នាក់ភូមិភាគដទៃទៀត ដូចជាតាមរយៈប្រជុំ តេឡេក្រាម ឬ តាមរ

[239] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦។

[240] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧, ២៧៦-២៧៨, ៣៩៤។

[241] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៧, ៣០៩, ៣៩៤។

យៈអ្នកក្រោមឱវាទ របស់ កែ ពក។ ទោះបីជាមានឯកសារសហ័យទាំងអស់នៅក្នុង សំណុំរឿង នេះក៏ដោយ ក៏ពុំមានឯកសារណាមួយកត់ត្រាកិច្ចប្រជុំរវាង អោ អាន និង កែ ពក ឬ នណាម្នាក់ ផ្សេងទៀតនៅថ្នាក់ភូមិភាគឡើយ[242]។

111. ជាងនេះទៀត ការិយាល័យសហចៅក្រមស៊ើបអង្កេត ខកខានម្តងទៀត ក្នុងការពិនិត្យខ្លឹមសារភ័ស្តុតាងដែលគាត់យកមកធ្វើ សំអាង។ ផ្ទុយទៅវិញ គាត់ផ្អែកលើ (ក) ចម្លើយរបស់សាក្សីដែលមិននិយាយជាក់លាក់ អំពី អោ អាន ចូលរួម “ប្រជុំប្រចាំខែ” ជាមួយ កែ ពក[243] (ខ) ចម្លើយរបស់

[242] មានតែទូរលេខសម័យកម្ពុជាប្រជាធិបតេយ្យមួយប៉ុណ្ណោះនៅក្នុងសំណុំរឿអ ដែលលើកឡើងពី អោ អាន និង កែ ពក។ ឯកសារនេះមិនបង្ហាញថា អោ អាន បានទទួលបញ្ជាបញ្ជាពី កែ ពក ទេ។ ឯកសារ **D1.3.13.1** (ទូរលេខលេខ ៣២ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ១៩៧៨។)។

[243] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៦ ជើងទំព័រ ៧២១ (ស.ច.ស.អ ផ្អែកលើចម្លើយរបស់ ញ៉ែម ចេន, ពេជ្រ ជឹម, ប្រាក់ យុត និង បាន សៀក ដែលគ្មានភាពជាក់លាក់ និងក្នុងករណីខ្លះ មិនអាចជឿជាក់បាន។ លើសពីនេះទៀត ចម្លើយរបស់ ប្រាក់ យុត, បាន សៀក និង ពេជ្រ ជឹម មិនបញ្ជាក់អះអាងទៅលើចម្លើយរបស់ ញ៉ែម ចេន ទេ។ **<u>ញ៉ែម ចេន៖</u>** ញ៉ែម ចេន មិនមែនជាសាក្សីអាចជឿជាក់បានទេ ដូចដែលបានពន្យល់នៅក្នុងផ្នែក II(ឃ)(ii)(ឃ) ហើយចម្លើយរបស់គាត់មិនស៊ីសង្វាក់គ្នាទេ។ ឧទាហរណ៍ ប្រៀបធៀបឯកសារ **D219/731** (កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន) ឆ.៣១, ឆ.៣៣, ឆ.៣៥-ឆ.៣៦ (ញ៉ែម ចេន អះអាងថា ពេលខ្លះ គាត់បានជូន អោ អាន ទៅកំពង់ចាម ដើម្បីប្រជុំជាមួយ កែ ពក ប៉ន្តែ “ពេលទៅប្រជុំ អីខ្ញុំមិនដឹងទេ”។ គាត់ទទួលស្គាល់ថា គាត់មិនត្រូវបានអនុញ្ញាតឲ្យចូលរួមក្នុង “ការប្រជុំសម្ងាត់” ទេ។) ជាមួយនឹងឯកសារ **D219/855** (កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន) ឆ.៥ (ញ៉ែម ចេន ពិនិត្យមើលឡើងវិញចម្លើយរបស់គាត់អំពីភាពញឹកញាប់នៃការប្រជុំ និងបានឆ្លើយថា កែ ពក និង អោ អាន បានរៀបចំការប្រជុំ “បូកសរុប” នៅកំពង់ចាមម្តងក្នុងមួយខែ។)។ **<u>ពេជ្រ ជឹម៖</u>** ពេជ្រ ជឹម បានលើកឡើងពីការប្រជុំប្រចាំខែ ប៉ុន្តែ មិនបានលើកឡើងពី អោ អាន ឬការណែនាំរបស់ កែ ពក ទេ។ ផ្ទុយទៅវិញ គាត់បានលើកឡើងថា កែ ពក ធ្វើការជិតស្និទ្ធជាមួយប្រពន្ធរបស់គាត់ សឿន ប្អូនថ្លៃស្រីរបស់លោកស្រី អឿន និងដៃស្តាំរបស់គាត់ ឆាំ។ ឯកសារ **D117/18** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.៧-ឆ.៩។ ឯកសារ **D118/259** (កំណត់ហេតុស្តាប់ចម្លើយ ពេជ្រ ជឹម) ឆ.៥៩-ឆ.៦០។ **<u>ប្រាក់ យុត៖</u>** ប្រាក់ យុត បញ្ជាក់ថា លោកស្រីបានចូលរួមក្នុងការប្រជុំភូមិភាគដែលរៀបចំដោយ កែ ពក រៀងរាល់បីខែម្តង និងពិភាក្សាពីបញ្ហានានាពាក់ព័ន្ធនឹងសេដ្ឋកិច្ច វប្បធម៌ និងកិច្ចការសង្គម។ លោកស្រីមិនបានលើកឡើងពី អោ អាន ទេ ហើយពិតជាបានទទួលស្គាល់ថា លោកស្រីភ្លេចឈ្មោះសមាជិកគណៈតំបន់ ៤១ ទាំងអស់។ ឯកសារ **D6.1.730** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត), KH 00357509-00357510 ទំព័រ ៥-៦។ ឯកសារ **D117/71** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត) ឆ.៥៦-ឆ.៥៧។ **<u>បាន សៀក៖</u>** បាន សៀក មិនដែលបញ្ជាក់ថា គាត់បានចូលរួមក្នុងការប្រជុំប្រចាំខែជាមួយ អោ អាន ទេ ប៉ុន្តែ ផ្ទុយទៅវិញ គាត់បញ្ជាក់ថា អោ អាន នៅគណៈភូមិភាគ។ ឯកសារ **D107/15** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក) KH 00800954 ទំព័រ ៣។ ឯកសារ **D6.1.386** (កំណត់ហេតុស្តាប់ចម្លើយ បាន សៀក), KH 00348796-00348797 ទំព័រ ៨-៩។)។

ញ៉ែម ចិន[244] ដែលមិនអាចជឿទុកចិត្តបាន និង មិនមានការបញ្ជាក់ ដែលនិយាយថា កែ ពក ចេញបញ្ជាចាប់ខ្លួន ដល់ អោ អាន នៅក្នុងកិច្ចប្រជុំមួយនៅកំពង់ចាម[245] និយាយអំពី កែ ពក និង អោ អាន និង សមាជិកគណៈភូមិភាគ បង្កើតផែនការអញ្ជើញ កម្មាភិបាលកំពុងមានតួនាទីឲ្យទៅ "រៀនសូត្រ"ដែលជាការបោកបញ្ឆោតដើម្បីចាប់យកទៅសម្លាប់[246] ហើយថា អោ អាន ទទួល "បទបញ្ជាសម្លាប់" ជាលាយលក្ខណ៍អក្សរពី កែ ពក "១ខែទៅ៣ខែម្ដង[247]" និង (គ) ចម្លើយមិនមានការបញ្ជាក់ និង មិនគួរជឿជាក់បានរបស់ ប្រាក់ យុត ដែលថា អោ អាន បានពិគ្រោះជាមួយ កែ ពក[248]។

---

[244] ស.ច.ស.អ ក៏បានបន្លើស និងបង្ហាញខុសនូវការដឹងរបស់ ញ៉ែម ចេន អំពីហេតុការណ៍ទាំងនេះ ដោយសារតែ ញ៉ែម ចេន ទទួលស្គាល់ថា គាត់មិនមានវត្តមានជានិច្ចនៅក្នុងការប្រជុំទេ និងមិនអាចស្ដាប់ឮការពិភាក្សាបានទេ។ ឧទាហរណ៍ ឯកសារ **D219/731** (កំណត់ហេតុស្ដាប់ចម្លើយ ញ៉ែម ចេន) ឆ.៣៤ (ញ៉ែម ចេន អះអាងថា ពេលខ្លះ គាត់ "នៅជិត" ហើយពេលខ្លួននៅឆ្ងាយពី អោ អាន នៅក្នុងការប្រជុំ ប៉ុន្តែ ទោះជាយ៉ាងនេះក្ដី គាត់ "ស្ដាប់បានដែរ ព្រោះ [គាត់] យកចិត្តទុកដាក់ស្ដាប់។")។ ឯកសារ **D219/855** (កំណត់ហេតុស្ដាប់ចម្លើយ ញ៉ែម ចេន) ឆ.១០៨-ឆ.១១២ (ញ៉ែម ចេន ទទួលស្គាល់ថា គាត់មិនដែលឮ អោ អាន ពន្យល់ពីប្រធានបទនៃការប្រជុំកងពល/យោធាភូមិភាគ។) ឆ.២០៣-ឆ.២០៥ (នៅពេល អោ អាន កំពុងនិយាយនៅក្នុងការប្រជុំនៅកំពង់ចាម ញ៉ែម ចេន ទទួលស្គាល់ថា គាត់ "ស្ដាប់មិនបានគាត់និយាយពេលហ្នឹង យើងដើរចេញមក យើងមកបត់ដៃបត់ជើង គាត់ឡើងរាយការណ៍ផែនការ យើងចេញមកក្រៅ មកបត់ជើង [...] គាត់និយាយ ប៉ុន្តែ យើងមិនដឹងគេនិយាយពាក្យអ្វី។" នៅពេលលេខាតំបន់ផ្សេងទៀតនិយាយអំពីជំហានដើម្បី "អនុវត្តធ្វើការតាមផែនការចេញមក" ញ៉ែម ចេន ក៏បានបញ្ជាក់ថា គាត់ "មិនបានចាប់អារម្មណ៍ស្ដាប់ថាគេនិយាយថាម៉េចទេ។")។

[245] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៧ ជើងទំព័រ ៧២៣-៧២៦ (ស.ច.ស.អ ផ្ដល់តែចម្លើយរបស់ ញ៉ែម ចេន ប៉ុណ្ណោះ។)។

[246] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៨ ជើងទំព័រ ៧២៧-៧២៩ (ស.ច.ស.អ ដកស្រង់ដោយភាន់ច្រឡំនូវចម្លើយរបស់ បាន សៀក ដើម្បីធ្វើការបញ្ជាក់ចំពោះភស្តុតាងរបស់ ញ៉ែម ចេន។ ទោះជាយ៉ាងនេះក្ដី នៅក្នុងចម្លើយដែលបានយោង បាន សៀក ទទួលស្គាល់ថាខ្លួនមិនបានដឹងថាតើថ្នាក់លើត្រូវបានប្រាប់ពីការបោសសម្អាតដែលដឹកនាំធ្វើឡើងដោយថ្នាក់ក្រោមឬអត់ទេ និងមិនបានលើកឡើងពី អោ អាន, កែ ពក ឬការពិភាក្សាណាមួយអំពីផែនការនៅក្នុងវគ្គទាំងនេះទេ។)។

[247] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៧ ជើងទំព័រ ៧២៦ (ស.ច.ស.អ ផ្អែកលើភស្តុតាងរបស់ ញ៉ែម ចេន ដែលជាពាក្យចចាមអារ៉ាម និងការស្មាន។)។

[248] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៤ (ស.ច.ស.អ ផ្អែកទាំងស្រុងទៅលើភស្តុតាងរបស់ ប្រាក់ យុត ដែលខ្វះនូវភាពគួរឲ្យជឿជាក់បាន។ បុគ្គលផ្សេងទៀត ដូចជា យូ វ៉ាន់ និង ញឹម កុល មិនបាននិយាយពីការប្រជុំ និងមិនបញ្ជាក់អះអាងទៅលើភស្តុតាងរបស់ ប្រាក់ យុត ទេ។)។

112. ជាការផ្ទុយទៅនឹងសំអាងហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[249] អោ អាន មិនបាន រាយការណ៍ទៅថ្នាក់ភូមិភាគ ពាក់ព័ន្ធនឹងការចាប់ខ្លួន និង ការសម្លាប់ នៅក្នុងតំបន់៤១ឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានដកស្រង់សំដី សាក្សីណាមួយដែលបញ្ជាក់ ច្បាស់លាស់ថា អោ អាន បានធ្វើរបាយការណ៍ទាំងនេះ ហើយគាត់មិនបង្កើត បាននូវគំរូឬការអនុ វត្តមួយថាតើរបបរាយការណ៍មានលក្ខណៈយ៉ាងដូចម្តេចនៅក្នុងភុមិភាគកណ្តាល[250]។ ផ្ទុយទៅ វិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និយាយយោងទូលំទូលាយទៅដល់ផ្នែកចំនួន២ទៀតនៅ ក្នុងដីកាដំណោះស្រាយ របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជម្រះ) ដែលផ្នែកទាំងពីរនេះ ពុំមានផ្នែកណាមួយគាំទ្រដល់សំអាង ហេតុរបស់គាត់ឡើយ[251]។ សហ ចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកដោយភាន់ច្រឡំទៅឡោះ ឋានៈតាមនីតិន័យរបស់ អោ អាន ដើម្បីទាញសេចក្តីសន្និដ្ឋានអំពីតួនាទីតាមព្រឹត្តិន័យរបស់គាត់ ដែលជាការខកខានផ្តល់នូវភ័ស្តុតាង គ្រប់គ្រាន់ បញ្ជាក់ថា អោ អាន បានទទួលបានអនុវត្ត ឬបានរាយការណ៍ តាមបញ្ជារបស់ កែ ពក។

*(២) អោ អាន មិនមានសិទ្ធិអំណាចតែងតាំងលេខាស្រុក លេខាឃុំ ឬ បុគ្គលិកសំខាន់ៗដទៃទៀតនៅក្នុង តំបន់៤១ទេ*

113. ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជម្រះ)របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់ សំអាងហេតុថា អោ អាន តែងតាំងលេខាស្រុក[252] និង កម្មាភិបាលដទៃទៀតនៅថ្នាក់តំបន់ ស្រុក និងឃុំ[253]។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ ភ័ស្តុតាងពិតប្រាកដ ឬមានការ

[249] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧។

[250] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧ (ស.ច.ស.អ សន្និដ្ឋានថា អោ អាន បានរាយការណ៍ទៅថ្នាក់ភូមិភាគ ពីព្រោះការអនុវត្តនេះគឺ "តាមរចនាសម្ព័ន្ធរាយការណ៍តាមខ្សែបណ្តាយនៅក្នុង ប.ក.ក។")។

[251] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧ ជើងទំព័រ ៦៤១ (ស.ច.ស.អ យោងទៅផ្នែក ៦.១.៥ និងផ្នែក ៦.៣.៤.២ នៃដីកាដំណោះស្រាយ។ ផ្នែក ៦.១.៥ សិក្សាតែអំពី "អំណាចគ្រប់គ្រងតាមច្បាប់នៃភូមិភាគ និងតំបន់នៅក្នុងរបប កម្ពុជាប្រជាធិបតេយ្យ" និងមិនលើកឡើងពី អោ អាន ទាល់តែសោះ ហើយផ្នែក ៦.៣.៤.២ ផ្តោតលើ "ការយកសមាសធាតុ មិនល្អទៅរៀនសូត្រ និងការសម្លាប់ខ្មាំង" ប៉ុន្តែ មិនបានយោងទៅភ័ស្តុតាងអំពីការរាយការណ៍របស់ អោ អាន ដែលត្រូវបានចោទ ប្រកាន់នោះទេ។)។

[252] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៦។

[253] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦។

បញ្ជាក់ដើម្បីគាំទ្រសំអាងហេតុទាំងនេះឡើយ ហើយភ័ស្តុតាងដែលបាន ផ្តល់ គឺស្មើរតែពាក់ព័ន្ធទាំងស្រុងនឹងស្រុកមួយ គឺស្រុកកំពង់សៀម និង ពីសាក្សីម្នាក់ដែលមិនគួរឲ្យជឿទុកចិត្ត បាន គឺ ប្រាក់ យុត[254] ដែលគាត់ម្តងម្កាលព្យាយាមបន្ថែមជាមួយចម្លើយ យូ វ៉ាន់ ពៅ សារ៉ុម ពេញ វ៉ា សួន កានិល និង ប្រាក់ នី[255]។ ប៉ុន្តែ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្ហាញខុស និង ថ្លែងពន្លើស អំពីភ័ស្តុតាងពីបុគ្គលទាំងនេះ ដោយហេតុ ថា គ្មាននណាម្នាក់មានភ័ស្តុតាងផ្ទាល់ថា អោ អាន តែងតាំង ប្រាក់ យុត ឬ កម្មាភិបាលដទៃទៀតនៅថ្នាក់ ស្រុក ឬថ្នាក់ឃុំឡើយ[256]។

114. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏រកឃើញដែរថា អោ អាន ធ្វើប្រតិភូកម្មកិច្ចការសេដ្ឋកិច្ចទៅ

---

[254] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៤៦ ជើងទំព័រ ៦០០។

[255] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៣ កថាខណ្ឌ ៤២៣ ជើងទំព័រ ១២៧៨។

[256] **<u>យូ វ៉ាន់៖</u>** យូ វ៉ាន់ មិនបានផ្តល់ភ័ស្តុតាងអំពីការតែងតាំងថ្នាក់ស្រុក ហើយលោកស្រីបានឆ្លើយស្មានថា បញ្ហារបស់ ប្រាក់ យុត ឲ្យផ្លាស់ប្តូរប្រធានឃុំ ចេញមកពី អោ អាន។ លោកស្រីមិនបានដឹងដោយផ្ទាល់ពីបញ្ហា ឬការតែងតាំងទាំងនេះទេ ឬមិនបានចូលរួមក្នុងការប្រជុំ ដែលនៅពេលនោះ បញ្ហាទាំងនោះអាចត្រូវបានលើកយកពិភាក្សា ប៉ុន្តែ ផ្ទុយទៅវិញ លោកស្រីបានឮពី ខុម ថា គេត្រូវការប្រធានឃុំថ្មី។ ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់) ឆ.៤៥, ឆ.៤៧។ **<u>ពៅ សារ៉ុម៖</u>** ពៅ សារ៉ុម ទទួលស្គាល់ថា ប្រាក់ យុត បានប្រាប់លោកស្រីអំពីការតែងតាំង អោ អាន ធ្វើជាលេខាតំបន់ ៤១។ លោកស្រីមិនបានពិភាក្សាពីការតែងតាំងកម្មាភិបាលថ្នាក់ស្រុក ឬថ្នាក់ឃុំទេ។ ទោះបីជាលោកស្រីឆ្លើយថា អោ អាន បានតែងតាំង ប្រាក់ យុត ធ្វើជាលេខាស្រុកកំពង់សៀមក៏ដោយ ក៏ប្រភពនៃភ័ស្តុតាងនេះមិនច្បាស់លាស់ (ទំនងជាពាក្យចចាមអារ៉ាមចេញពី ប្រាក់ យុត) ដោយហេតុថា លោកស្រីហាក់ដូចជាមិនបានចូលរួមក្នុងការប្រជុំ ដែលនៅពេលនោះ រឿងនោះបានកើតឡើង។ អ្នកស៊ើបអង្កេតនៃ ក.ស.ច .ស មិនបានសួរ ពៅ សារ៉ុម អំពីប្រភពនៃភ័ស្តុតាងរបស់លោកស្រីទេ។ មេធាវីការពារក្តីលើកឡើងម្តងទៀតថា ពាក្យចចាមអារ៉ាមមកពី ប្រាក់ យុត មិនអាចយកប្រើប្រាស់ដើម្បីបញ្ជាក់អះអាងភ័ស្តុតាងរបស់ ប្រាក់ យុត បានទេ។ ឯកសារ **D117/24** (កំណត់ហេតុស្តាប់ចម្លើយ ពៅ សារ៉ុម) ឆ.៦, ឆ.៧, ឆ.១១។ **<u>ពេញ វ៉ា៖</u>** ពេញ វ៉ា បញ្ជាក់ថា អោ អាន បានប្រកាសពីតំណែងផ្ទាល់របស់ខ្លួននៅក្នុងការប្រជុំ ប៉ុន្តែ គាត់មិនបានលើកឡើងថា អោ អាន បានតែងតាំងអ្នកដទៃផ្សេងទៀតទេ។ គាត់ធ្វើការស្មានថា អោ អោន និង អួន បានចេញបញ្ជាឲ្យចាប់ខ្លួនកម្មាភិបាលចាស់ក្នុងតំបន់ ៤១ ប៉ុន្តែ គាត់មិនបានលើកឡើងអ្វីពាក់ព័ន្ធនឹងការតែងតាំងអ្នកជំនួសនោះទេ។ ឯកសារ **D219/226** (កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា) ឆ.១០, ឆ.១៣។ **<u>សួន កានិល និង ប្រាក់ នី៖</u>** សាក្សីទាំងពីរពិភាក្សាអំពីការគ្រប់គ្រងរបស់ ប្រាក់ យុត លើស្រុកកំពង់សៀម ប៉ុន្តែ ពួកគេមិនបាននិយាយអ្វីអំពីការដែលថា អោ អាន តែងតាំង ប្រាក់ យុត។ ឯកសារ **D6.1.697** (កំណត់ហេតុស្តាប់ចម្លើយ សួន កានិល), KH 00373496 ទំព័រ ៧។ ឯកសារ **D6.1.707** (កំណត់ហេតុស្តាប់ចម្លើយ សួន កានិល), KH 00373509 ទំព័រ ៤។ ឯកសារ **D219/26** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ នី) ឆ.២៦។

កម្មាភិបាលនានានៅក្នុង តំបន់[257]។ ប៉ុន្តែបើទោះជាលើកទឡ្ហីករណ៍ដើម្បីតែទឡ្ហីករណ៍ថា ភ័ស្តុតាងគាំទ្រសំអាងហេតុនេះមានលក្ខណៈ ពិតប្រាកដ និង មានការបញ្ជាក់ (ដែលតាមការពិតមិនមែនដូច្នេះក្តី[258]) វាមិនគាំទ្រដល់ការសន្និដ្ឋានថា អោ អាន មានសិទ្ធិអំណាចតែងតាំងបុគ្គលិកសំខាន់" និង សិទ្ធិអំណាចតាមព្រឹត្តិន័យទៅលើតំបន់៤១ឡើយ។ សិទ្ធិអំណាចក្នុងការធ្វើប្រតិភូកម្មកិច្ចការសេដ្ឋកិច្ចមិនសមមូលទៅនឹងសិទ្ធិអំណាចក្នុងការតែងតាំងលេខាស្រុក និង លេខាឃុំទេ។ វាគឺជាការបង្ហាញថា អោ អាន មានតួនាទីទាបជាង ក្នុងការពាក់ព័ន្ធនឹងសេដ្ឋកិច្ច និង មិនមែនជាលេខាតំបន់ទេ។

*(៣) អោ អាន មិនមានសិទ្ធិអំណាចដក ជំនួស ឬ ដាក់ទណ្ឌកម្មលើលេខាស្រុក លេខាឃុំ ឬ បុគ្គលិកសំខាន់ៗដទៃទៀតឡើយ*

115. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់សំអាងហេតុម្តងហើយម្តងទៀតថា អោ អាន មានសិទ្ធិអំណាចក្នុងការដកជំនួស និង ដាក់ទណ្ឌកម្មកម្មាភិបាលនៅក្នុងតំបន់៤១[259]។ ប៉ុន្តែ គាត់មិនបានពន្យល់ថាតើ "ដក" មានន័យថា ផ្ទេរតួនាទីកម្មាភិបាល បណ្តេញ ឬ បន្ថយឋានៈតួនាទី ឬ ការចាប់ ឬសម្លាប់ ឬ ដាក់ទណ្ឌកម្មពួកគេឡើយ។ ផ្ទុយ ទៅវិញ ជាទូទៅគាត់បញ្ចូលសកម្មភាពទាំងអស់ដើម្បីបង្កើតឱ្យមានការយល់ច្រឡំថា អោ អាន មានសិទ្ធិអំណាចធំ។ គាត់ក៏បញ្ចូលគ្នានូវប្រភេទកម្មាភិបាលទាំងអស់ ដោយខកខានមិនបានបែងចែកដាច់គ្នារវាងកម្មាភិបាលថ្នាក់តំបន់ ថ្នាក់ស្រុក និងថ្នាក់ឃុំឡើយ។ ពេលសកម្មភាពទាំងនេះត្រូវបំបែកលម្អិត វាជាការច្បាស់ថា គ្មានភ័ស្តុតាងពិតប្រាកដ ច្បាស់លាស់ថា អោ អាន មានសិទ្ធិអំណាចដក ដាក់ជំនួស ឬ ដាក់ទណ្ឌកម្មកម្មាភិបាលក្នុង

---

[257] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧១ (ស.ចៅ.ស.អ សន្និដ្ឋានថា អោ អាន បានស្នើឱ្យ តាអាំ ត្រួតពិនិត្យកម្មករតំបន់ ៤១ នៅទំនប់ ១ មករា និងបានបញ្ជូន ស៊ឹម ទៅសង់ទំនប់ ៦ មករា។) កថាខណ្ឌ ៣៣០ (ស.ចៅ.ស.អ សន្និដ្ឋានថា អោ អាន បានចាត់តាឈិន ឱ្យទទួលខុសត្រូវលើកងចល័តតំបន់នៅទំនប់អន្លង់ជ្រៃ។)។

[258] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧១ ជើងទំព័រ ៧០១-៧០២ (ស.ចៅ.ស.អ សន្និដ្ឋានថា អោ អាន បានផ្ទេរអំណាចឱ្យ តាអាំ គ្រប់គ្រងកម្មករមកពីតំបន់ ៤១ នៅការដ្ឋានសង់ទំនប់ ១ មករា និងបានដកស្រង់តែភ័ស្តុតាងមិនគ្រប់គ្រាន់របស់ សាត ភាព និង តូ សេម ប៉ុណ្ណោះ។) កថាខណ្ឌ ៣៣០ ជើងទំព័រ ៩០២ (ស.ចៅ.ស.អ សន្និដ្ឋានថា អោ អាន បានចាត់តាំង តាឈិន ឱ្យទទួលខុសត្រូវលើកងចល័តតំបន់នៅទំនប់អន្លង់ជ្រៃ និងបានដកស្រង់តែភ័ស្តុតាងមិនគ្រប់គ្រាន់របស់ ផន សុផល ប៉ុណ្ណោះ។)។

[259] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២១៤, ២៥៦, ២៩៣-២៩៤, ២៩៧។

តំបន់៤១។

116. នៅក្នុងផ្នែកII(ង)(iii),(v)(គ) មេធាវីលើកឡើងកំហុសអង្គហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹង តួនាទីរបស់ អោ អាន នៅក្នុងការបោសសំអាត ឬ ការដកអតីតកម្មាភិបាលភូមិភាគកណ្តាល និង បញ្ហា សន្តិសុខ។ ដូច្នេះ កំហុសទាំងនេះមិនត្រូវបានលើកឡើងនៅទីនេះទេ។ នៅទីនេះ មេធាវីការពារក្តីនឹងផ្តោត លើកំហុសអង្គហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹង ការដកបុគ្គលសំខាន់ៗ ក្នុងនោះរួមមាន មិត្ត សុប, តា អាំ និង ប្រាក់ យុត[260]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានផ្តល់ភ័ស្តុតាងគ្រប់គ្រាន់ថា អោ អាន បញ្ជា ឬ ពាក់ព័ន្ធ នឹងការដក និង ជំនួស ពួកគេ ដែលអាចជាទិដ្ឋភាពនៃកិច្ចការរបស់លេខាតំបន់។

117. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្ហាញខុសខ្លាំងអំពីភ័ស្តុតាងនៅពេលសន្និដ្ឋានថា អោ អាន បានបញ្ជាការចាប់ខ្លួន និង សម្លាប់ មិត្ត សុប[261] និង តែងតាំង ង៉ូវ ជំនួស[262]។ ពុំមានភ័ស្តុតាងពិត

---

[260] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៥, ២៩៦, ៤២៣។

[261] ស.ច.ស.អ ផ្អែកលើសាក្សីចំនួនប្រាំពីរនាក់ដើម្បីគាំទ្រដល់ការសន្និដ្ឋានខ្លួនថា អោ អាន បានបញ្ជាឲ្យចាប់ និងសម្លាប់មិត្តសុប។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៥ ជើងទំព័រ ៧៧៤។ **<u>តូច មៀច៖</u>** តូច មៀច ជាសាក្សីតែម្នាក់គត់ដែលបានលើកឡើងថា អោ អាន ជាប់ទាក់ទងជាមួយនឹងការចាប់ខ្លួនមិត្តសុប ដោយ ស.ច.ស.អ មិនបានយកចិត្តទុកដាក់ដោយចំហរទៅលើផ្នែកខ្លះនៃចម្លើយរបស់គាត់ដែលបង្ហាញថា ការដឹងរបស់គាត់មានកម្រិតខ្លាំងមែនទែន។ ឯកសារ **D219/582** (កំណត់ហេតុស្តាប់ចម្លើយ តូច មៀច) ឆ.១០២, ឆ.១០៩-ឆ.១១០ (តូច មៀច មិនដឹងថា អ្នកណាជាអ្នកជំនួសមិត្តសុប មិនបាននិយាយថា គាត់ដឹងថា អោ អាន ចាប់ខ្លួនមិត្តសុប ដោយរបៀបណាទេ ហើយដំបូង បានផ្តល់ភ័ស្តុតាងជាពាក្យចចាមអារ៉ាម។)។ **<u>ឃុន សារ៉េត, រី ញ៉, សាត ភាព, ស៊ឹង លឹម, គង់ ទឹង និង ដួង ស៊ឹម៖</u>** សាក្សីប្រាំមួយនាក់ផ្សេងទៀតដែល ស.ច.ស.អ បានដកស្រង់ពិភាក្សាតែអំពីការដែលថា មិត្តសុប ត្រូវបានចាប់ខ្លួននៅពេលណាមួយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ និងមិនបានទម្លាក់ការចាប់ខ្លួននេះទៅលើ អោ អាន ទេ។ ឯកសារ **D93** (កំណត់ហេតុស្តាប់ចម្លើយ ឃុន សារ៉េត), KH 00743582 (ឃុន សារ៉េត មិនដឹងថាមានអ្វីកើតឡើងចំពោះមិត្តសុបទេ និងបានឃើញគាត់ជិះឡានចេញទៅតែប៉ុណ្ណោះ។)។ ឯកសារ **D219/870** (កំណត់ហេតុស្តាប់ចម្លើយ រី ញ៉) ឆ.៥២, ឆ.១០៧-ឆ.១០៨ (រី ញ៉ ធ្វើការស្មានថា អោ អាន "ជាអ្នកចេញបញ្ជា" ពីព្រោះគាត់ជាកម្មាភិបាលមានឋានៈខ្ពស់បំផុត។ ទោះជាយ៉ាងនេះក្តី សាក្សីទទួលស្គាល់ នៅចម្លើយ១០៩ ថា គាតមិនបានដឹងថាតើមាននរណាផ្សេងមានសិទ្ធិចាប់ខ្លួនមនុស្សឬអត់ទេ និងនៅចម្លើយ១១០ គាត់និយាយថា គាត់មិនច្បាស់ពីពេលវេលានៃការចាប់ខ្លួន ពីព្រោះគាតមិនមែនធ្វើការនៅទីនោះ។)។ ឯកសារ **D219/460** (កំណត់ហេតុស្តាប់ចម្លើយ សាត ភាព) ឆ.៨ (សាត ភាព គ្រាន់តែឆ្លើយថា មិត្តសុបត្រូវបានចាប់ខ្លួនប៉ុណ្ណោះ និងមិនបានលើកឡើងពី អោ អាន ទេ។)។ ឯកសារ **D117/54** (កំណត់ហេតុស្តាប់ចម្លើយ ស៊ឹង លឹម) ឆ.៨ (ស៊ឹង លឹម មិនបានលើកឡើងពី អោ អាន ទេ ដោយគ្រាន់តែចងចាំថា "សុប" ប្រធានសន្តិសុខដំបូង ត្រូវបានចាប់ខ្លួន និងនាំយកទៅសម្លាប់ដោយកម្មាភិបាលភូមិភាគនិរតី។)។ ឯកសារ **D3/13** (កំណត់ហេតុស្តាប់ចម្លើយ គង់ ទឹង) ឆ.៤ (ស្រដៀងគ្នា

ប្រាកដ ច្បាស់លាស់ គាំទ្រដល់សំអាងហេតុដែលថា អោ អាន ទទួលខុសត្រូវចំពោះការដក មិត្ត សុប និង ការតែងតាំង ង៉ូវ ឡើយ។

118. ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់សំអាងហេតុថា នៅពាក់កណ្តាលឆ្នាំ ១៩៧៧ អោ អាន បានបញ្ជា ចាប់ខ្លួន ធ្វើទារុណកម្ម និងសម្លាប់ តា អាំ ដែលជាប្រធានមន្ទីរតំបន់ ៤១[263]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទទួលស្គាល់ថា មានភ័ស្តុតាងមិនស្របគ្នាអំពីកាល បរិច្ឆេទនៃការចាប់ តាអាំ ប៉ុន្តែខកខានមិនបានពន្យល់ថាគាត់មកដល់/ដោយ របៀបណា ក្នុងការ កំណត់របស់គាត់ថា ពាក់កណ្តាលឆ្នាំ១៩៧៧[264]។ ផ្អែកលើការពិនិត្យលើខ្លឹមសារភ័ស្តុតាង ជាការ ច្បាស់ថា សំអាងហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គឺផ្អែកលើតែភ័ស្តុតាង ចចាមអារ៉ាម និងការស្មាន[265] ហើយថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បង្ហាញខុសដំណើរ រឿងរបស់សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណីមួយចំនួនអំពី ការចាប់ តា អាំ[266]។ ការវាយតម្លៃ

---

នេះដែរ គង់ ទឹង មិនបានលើកឡើងពី អោ អាន ទេ ដោយគ្រាន់តែបញ្ជាក់ថា "សុប ត្រូវបានចាប់ខ្លួន នៅពេលដែលពួកនិរតីបាន មកដល់។")។ ឯកសារ **D3/15** (កំណត់ហេតុស្តាប់ចម្លើយ ដួង ស៊ឹម) ឆ.៦ (អោ អាន មិនត្រូវបានលើកឡើងទេ ដោយ ដួង ស៊ឹម គ្រាន់តែចាំថា សុប "ត្រូវបានពួកនិរតីចាប់ខ្លួន។")។

[262] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៥ ជើងទំព័រ ៧៧៥ (ស.ច.ស.អ បង្ហាញខុសនូវចម្លើយរបស់សាក្សី ប្រាំពីរនាក់ (សាត ភាព, ណៃ ស៊ី, គង់ ទឹង, ដួង ស៊ឹម, សឹង លឹម, ញ៉ែម ចេន និង ប្រាក់ យុត) ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់ ខ្លួនថា ង៉ូវ "ត្រូវបានតែងតាំងឲ្យជំនួស សុប"។ ស.ច.ស.អ ប្រើប្រាស់ទម្រង់អកម្មដោយចេតនាដើម្បីបង្កើតឲ្យមានភាពស្រពិច ស្រពិល និងនាំឲ្យមានការសន្និដ្ឋានមិនត្រឹមត្រូវអំពីតួនាទីរបស់ អោ អាន។ ពុំមានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីដែលបាន ដកស្រង់ ឆ្លើយថា អោ អាន បានតែងតាំង ង៉ូវ ទេ។ យ៉ាងច្រើនបំផុត ពួកគេកត់សម្គាល់ថា ង៉ូវ បានជំនួសមិត្តសុប ដោយមិន បានលើកឡើងពី អោ អាន។)។

[263] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៦។

[264] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៧។

[265] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៨ (ស.ច.ស.អ ផ្អែកតែទៅលើពាក្យចចាមអារ៉ាមចេញ មកពី សាត ភាព ដែលបានឮពីនីរសាររបស់ អ៊ូន ថា អោ អាន ជាអ្នកចេញបញ្ជា, ពី ង៉ូវ ដែលមិនដឹងថាអ្នកណាជាអ្នកចេញ បញ្ជា ប៉ុន្តែ សន្មតថា គឺ អោ អាន ក្រោយពេលអ្នកស៊ើបអង្កេតនៃ ក.ស.ច.ស ប្រាប់ព័ត៌មានដល់គាត់ និងពី ពេញ វ៉ា ដែលចាំថា បានឮថា អ៊ូន ចាប់ខ្លួន អាំ និងធ្វើការស្មានថា អោ អាន ជាអ្នកចាត់ចែងការជំនួសតំណែង។)។

[266] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៨ (ស.ច.ស.អ បង្ហាញខុសនូវភ័ស្តុតាងរបស់ ង៉ូវ, អ៊ឹម ប៉ុន, ពៅ សារ៉ុម, ពុត កុល និង ពេញ វ៉ា។ ពួកគេទាំងអស់បានលើកឡើងពីការចាប់ខ្លួនតាអាំ ប៉ុន្តែ មិនបានបញ្ជាក់ថា អោ អាន ជាអ្នកបញ្ជាទេ។)។

ដែលមានកំហុសឆ្គងនេះគឺបូករួមជាមួយនឹងអង្គហេតុដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើអំពីភ័ស្តុតាងដែលថា បញ្ជាចាប់ តា អាំ គឺតាមពិតត្រូវបានចេញដោយ ភូមិភាគនិរតី មិនមែន ដោយ អោ អាន ទេ[267]។

119. ស្រដៀងគ្នានេះដែរ ពាក់ព័ន្ធនឹង ការដក ប្រាក់ យុត និង ការផ្ទេរពីភូមិភាគកណ្តាលទៅ ភូមិភាគពាយ័ព្យ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអើពើលើភ័ស្តុតាង ពោលគឺពីប្រាក់ យុត ខ្លួនឯងដែលថា តា ម៉ុក មិនមែន អោ អាន ទេ ដែលដកគាត់ទៅភូមិភាគពាយ័ព្យ[268]។ ជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ប្រើដោយការយកចិត្តទុកដាក់នូវភាសាដើម្បី លាក់បាំងកង្វះភ័ស្តុតាងអំពីការពាក់ព័ន្ធរបស់ អោ អាន នៅក្នុងការដក ប្រាក់ យុត[269]។ មានភ័ស្តុតាងមិនគ្រប់គ្រាន់ដែលបង្ហាញថា អោ អាន បានតែងតាំងអ្នកជំនួស ប្រាក់ យុត[270]។

*(៤) អោ អាន មិនបានចេញបញ្ជា ឬអនុញ្ញាចំណាត់ការរបស់ លេខាស្រុក លេខាឃុំ ឬ អ្នកក្រោមបង្គាប់ឡើយ*

120. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់សំអាងហេតុដោយមានកំហុសថា អោ អាន បានបញ្ជាឱ្យលេខាស្រុក ឬ "អ្នកនៅក្រោមបង្គាប់" កំណត់អត្តសញ្ញាណ និង កំណត់មុខសញ្ញាក្រុមជាក់លាក់ បានបង្គាប់ឱ្យពួកគេចាប់ខ្លួន និង សម្លាប់អតីតកម្មាភិបាល ជនស៊ីវិល និង ប្រជាជនចាម និង បាន

267 ឯកសារ **D117/70** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត) ឆ.៤៦ (ប្រាក់ យុត ប្រពន្ធរបស់តាអាំ បញ្ជាក់ថា លិខិតមួយពីភូមិភាគនិរតីបញ្ជាឱ្យចាប់ខ្លួនគាត់។)។

268 ប្រាក់ យុត មិនបានលើកឡើងពី អោ អាន នៅពេលដែលលោកស្រីពិភាក្សាពីការដកលោកស្រីបញ្ជូនទៅបាត់ដំបងនៅឆ្នាំ ១៩៧៨ ទេ ប៉ុន្តែ បែរជាសន្និដ្ឋានថា តាម៉ុក ជាអ្នកបញ្ជារឿងនេះ។ ឯកសារ **D117/71** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត) ឆ.៧២ (ប្រាក់ យុត ឆ្លើយថា លោកស្រីបានជួបតាម៉ុក នៅពេលដែលលោកស្រីមកដល់នៅបាត់ដំបង។)។ ឯកសារ **D219/971** (កំណត់ហេតុស្តាប់ចម្លើយ ប្រាក់ យុត) ឆ.៤-ឆ.៧ (ប្រាក់ យុត បញ្ជាក់ថា លោកស្រីត្រូវបានបញ្ជូនទៅបាត់ដំបង។ នៅទីនោះលោកស្រីបានសួរតាម៉ុកថាហេតុអ្វីលោកស្រីត្រូវបាននាំមកទីនេះ ហើយតាម៉ុក បានបញ្ជូនលោកស្រីទៅជីប៉ាង។)។

269 សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤២៣។

270 សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤២៣ ជើងទំព័រ ១២៨៦-១២៨៨ (ស.ច.ស.អ ផ្អែកលើភ័ស្តុតាងរបស់ ញឹម កុល, អ៊ឹម ប៊ុន និង ងូវ។ គ្មានអ្នកណាម្នាក់លើកឡើងថា អោ អាន បានតែងតាំងអ្នកជំនួស ប្រាក់ យុត ទេ។)។

អនុញ្ញាតឲ្យវាយដំមនុស្សក្នុងកំឡុងពេល សួរចម្លើយ[271]។ គាត់ខកខានមិនបានផ្តល់ភ័ស្តុតាងពិតប្រាកដ ច្បាស់លាស់គ្រប់គ្រាន់ អំពីខ្សែសង្វាក់នៃការបញ្ជា នៅតំបន់៤១ និង ការបញ្ជាទៅលើបញ្ហាអ្វីមួយទៅលេខាស្រុកណាមួយ។ ភ័ស្តុតាងដែលគាំទ្រសំអាង ហេតុរបស់ សហចៅក្រមស៊ើបអង្កេត អំពី ការបញ្ជារបស់ អោ អាន ទៅលេខាស្រុក គឺស្ទើរតែមានតែមួយចេញពីសក្ខីកម្ម របស់ ប្រាក់ យុត ដែលមិនពិតប្រាកដគ្រប់គ្រាន់ និង មិនមានការបញ្ជាក់[272]។

121. ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យោងទៅលើ "ខ្សែចង្វាក់បញ្ជាដ៏តឹងរ៉ឹង ដោយមាន

[271] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៥, ២៧៩,២៨១-២៨៤, ២៨៧, ២៩៤, ២៩៩, ៣០១-៣០២, ៣១១, ៣៦៤, ៣៩៤, ៤២៧, ៤២៩, ៤៦៣, ៥០៣, ៥៦៤, ៦៣៣-៦៣៤, ៦៣៦។

[272] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៦៤ ជើងទំព័រ ១០៣០ (ស.ច.ស.អ ផ្អែកលើភ័ស្តុតាងរបស់ ប្រាក់ យុត ស្ទើរតែទាំងស្រុង។)។ នៅពេលដែល ស.ច.ស.អ យោងទៅភ័ស្តុតាងផ្សេងទៀត វាជារឿយៗ ជាពាក្យចចាមអារ៉ាម ឬមិនអាចបញ្ជាក់ដល់ការអះអាងរបស់ ប្រាក់ យុត បានទេ។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៥ (ស.ច.ស.អ ផ្តល់ភ័ស្តុតាងរបស់ យូ វ៉ាន់ ដែលគ្រាន់តែឮថា ប្រាក់ យុត ធ្វើតាមបញ្ជាចេញពី អោ អាន។ លោកស្រីមិនចាំទេថាបានអមដំណើរ ប្រាក់ យុត នៅពេលដែលលោកស្រីយកបញ្ជីទៅឲ្យតំបន់ និងគ្រាន់តែបានឮពីផែន ថា មានការប្រជុំ ដែលក្រោយពីប្រជុំរួច មនុស្សបានបាត់ខ្លួន។ យូ វ៉ាន់ ក៏ចាំផងដែរថាបានប្រគល់លិខិតរវាង អោ អាន និង ប្រាក់ យុត ប៉ុន្តែ មិនបានបញ្ជាក់ថា លោកស្រីដឹងខ្លឹមសារនៃលិខិតទាំងនេះទេ។ លើសពីនេះទៀត ស.ច.ស.អ ផ្អែកលើភ័ស្តុតាងរបស់ ញឹម កុល ដែលចាំថាបានចាប់ខ្លួនមនុស្សរបស់ លន់ នល់ ដោយផ្អែកលើបញ្ជីឈ្មោះ ប៉ុន្តែមិនបានលើកឡើងពី អោ អាន ទេ។) កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៧ (ស.ច.ស.អ ផ្អែកជាថ្មីម្តងទៀតទៅលើភ័ស្តុតាងរបស់ យូ វ៉ាន់ ដែលចាំថា ប្រាក់ យុត បានទទួលបញ្ជាផ្ទាល់ពី អោ អាន ទាក់ទងនឹងការចាប់ខ្លួនមនុស្សមួយចំនួន។ អ្នកស៊ើបអង្កេតនៃ ក.ស.ច.ស មិនបានសួរសាក្សីនូវសំណួរផ្ទៀងផ្ទាត់អំពីប្រភពនៃការដឹងរបស់សាក្សីនោះទេ។ នេះទាក់ទងជាពិសេស ផែន និង នី ដោយសារតែការអះអាងជាច្រើនរបស់ យូ វ៉ាន់ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយនេះ ផ្អែកលើព័ត៌មានដែលទទួលបានពី ប្រាក់ យុត។) កថាខណ្ឌ ៤២៩ ជើងទំព័រ ១៣២៦ (ស.ច.ស.អ ផ្អែកលើភ័ស្តុតាងរបស់ ជីន ស៊ីណាល់ ដែលគ្រាន់តែបញ្ជាក់ថា "មេដឹកនាំខ្មែរក្រហម" បានឃើញលក្ខខណ្ឌរស់នៅដ៏ "លំបាក" នៅការដ្ឋានសង់ទំនប់ និង "បានបង្គាប់ឲ្យប្រធានក្រុមតាមដានពួកអ្នកឈឺ ពីព្រោះគេយល់ថា អ្នកដែលឈឺ គឺជាពួកគិញ ឬខ្មាំង"។ គាត់ធ្វើការស្មានថា ការណែនាំទាំងនេះចេញពីថ្នាក់លើ ប៉ុន្តែមិនបានលើកឡើងពី ប្រាក់ យុត ឬ អោ អាន ទេ។ ភ័ស្តុតាងនេះមិនពាក់ព័ន្ធសោះជាមួយនឹងការសន្និដ្ឋានរបស់ ស.ច.ស.អ និងមិនបញ្ជាក់អះអាងភ័ស្តុតាងរបស់ ប្រាក់ យុតទេ។) កថាខណ្ឌ ៦៣៤ ជើងទំព័រ ២១៦៣ (ស.ច.ស.អ ជាថ្មីម្តងទៀត ផ្អែកលើភ័ស្តុតាងរបស់ ញឹម កុល ដែលចាំថា បានឮដោយចៃដន្យ ប្រាក់ យុត ប្រាប់ រ៉ុម ឲ្យពិនិត្យថាតើនៅមានជនជាតិចាមឬទេ និងរាយការណ៍ត្រឡប់ទៅលោកស្រីវិញ ប៉ុន្តែ មិនបានលើកឡើងថា បញ្ជានេះត្រូវបញ្ជូនទៅក្រោមតាម អោ អាន ទេ។ ស.ច.ស.អ ក៏បានផ្អែកម្តងទៀតទៅលើភ័ស្តុតាងរបស់ យូ វ៉ាន់ ដែលចាំអំពីការប្រាស្រ័យទាក់ទងរវាង ប្រាក់ យុត និង អោ អាន ពេលលោកស្រីមិននៅ។)។

**អោ អាន** នៅលើកំពូល"[273]។ ទោះបីជាយ៉ាងណាក៏ដោយ ឯកសារគាំទ្រពុំបានបង្ហាញអំពីខ្សែចង្វាក់បញ្ជាដ៏តឹងរ៉ឹងនេះស្របតាមលក្ខខណ្ឌតម្រូវឡើយ ហើយជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកទៅលើការរៀបរាប់ដែលមិនគួរឱ្យជឿជាក់បានរបស់ ប្រាក់ យុត[274]។ ប្រាក់ យុត ដឹងត្រឹមតែស្រុកកំពង់សៀមប៉ុណ្ណោះ ហើយការរៀបរាប់របស់គាត់អំពីលេខាស្រុកផ្សេងៗទៀតដែលទទួលបញ្ជានោះ មិនស៊ីសង្វាក់គ្នា និងកើតចេញមកពីការរម្លឹកឱ្យគាត់នឹកឃើញឡើងវិញពីសំណាក់ ក.ស.ព[275]។ សាក្សីផ្សេងៗទៀត ដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយកមកធ្វើជាសំអាងនោះ អាចបានឃើញ ប៉ុន្តែមិនបានស្តាប់ឮទេ នូវការសន្ទនារវាង អោ អាន និងអ្នកដទៃទៀត ដូចជា ង៉ូវ និង អូន។ ចម្លើយរបស់សាក្សីទាំងនេះមិនស៊ីសង្វាក់គ្នាជាមួយនឹងចម្លើយរបស់ ប្រាក់ យុត ឬក៏បង្ហាញនូវខ្សែចង្វាក់បញ្ជាដ៏តឹងរ៉ឹងនោះឡើយ"[276]។

---

[273] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨២។

[274] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨២ ជើងទំព័រ ៧៣៧។

[275] ឯកសារ **D219/702.1.94** (ប្រតិចារឹកក្នុងសំណុំរឿង ០០២/០២-ប្រាក់ យុត), KH 01253406-01253407, 012534420, 01253423-01253424 ទំព័រ ៥៩-៦០, ៧៣, ៧៦-៧៧ (ប្រាក់ យុត ប៉ុនប៉ងដោះបន្ទុកខ្លួនឯង ដោយបញ្ជាក់យ៉ាងទទូចថា លោកស្រីមិនបានចូលរួមក្នុងការសម្លាប់នៅក្នុងស្រុករបស់លោកស្រី មិនបានអនុវត្តបញ្ជាដោយខ្លួនលោកស្រីផ្ទាល់ គ្មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេច គ្រាន់តែបានបញ្ជូនបន្តបញ្ជាទៅអ្នកនៅក្រោមបង្គាប់របស់លោកស្រី និងក្តាប់សភាពការណ៍នៅក្នុងស្រុកមិនបានពេញលេញ។ ដើម្បីដកខ្លួនលោកស្រីចេញឱ្យឆ្ងាយពីការទទួលខុសត្រូវជាលក្ខណៈបុគ្គលចំពោះការសម្លាប់ លោកស្រីអះអាងថាបញ្ជាចេញមកពី អោ អាន និងថាលោកស្រីគ្រាន់តែរាយការណ៍ត្រឡប់ទៅគាត់វិញតែប៉ុណ្ណោះ ក្រោយពីថ្នាក់ក្រោមអនុវត្តបញ្ជារួច។ លោកស្រីក៏បាននិយាយថាបានចូលរួមក្នុងការប្រជុំជាមួយ "គណៈស្រុកទាំងបួន" ដែលនៅពេលនោះ អោ អាន បានប្រាប់ពួកគេឱ្យសម្លាប់ជនជាតិចាម ប៉ុន្តែ គ្មានសាក្សីណាផ្សេងទៀតចងចាំពីហេតុការណ៍នេះទេ ហើយលើសពីនេះទៀត ប្រាក់ យុត ក្រោយមក បានដកយកភ័ស្តុតាងនេះ ដោយសហព្រះរាជអាជ្ញាដាក់សម្ពាធគាត់ឱ្យថាតាម។)។ ឯកសារ **D219/702.1.95** (ប្រតិចារឹកក្នុងសំណុំរឿង ០០២/០២-ប្រាក់ យុត), KH 01253277-01253278, 01253280 ទំព័រ ៤-៥, ៧ (កាត់សម្តីដោយសហព្រះរាជអាជ្ញា ប្រាក់ យុត បានបញ្ជាក់ពីសក្ខីកម្មលើកមុនរបស់លោកស្រី។ លោកស្រីចាំថាបានទទួលបញ្ជាឱ្យ "សម្លាប់ ឬក៏កម្ទេច" ។ ទោះជាយ៉ាងនេះក្តី ភ័ស្តុតាងរបស់លោកស្រីមិនមានភាពស៊ីសង្វាក់ទេ ទាក់ទងនឹងថាតើ លេខាស្រុកផ្សេងទៀតបានទទួលបញ្ជាដូចគ្នាឬយ៉ាងណា។) KH 01253281 ទំព័រ ៨ (សហព្រះអាជ្ញាមិនចាប់អារម្មណ៍ថា ប្រាក់ យុត បាននិយាយជាពិសេសថា ទាក់ទងនឹងស្រុកផ្សេងទៀត លោកស្រីមិនបានដឹងអំពីបញ្ជាទេ និងមិនចងចាំពីព័ត៌មានលម្អិតទាំងនេះ រហូតដល់ពេលលោកស្រីរម្លឹកការចងចាំរបស់លោកស្រីវិញ។) KH 01253296-01253297 ទំព័រ ២៣-២៤ (សហព្រះរាជអាជ្ញា បានរម្លឹកការចងចាំរបស់ ប្រាក់ យុត ជាមួយនឹងសក្ខីកម្មលើកមុនរបស់លោកស្រីទាក់ទងនឹងបញ្ជា។)។

[276] ឧទាហរណ៍ ឯកសារ **D219/800** (កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន) ឆ.១៦០-ឆ.១៦៤ (សូ សារ៉េន ចងចាំបានឃើញ ង៉ូវ មកមន្ទីររបស់ អោ អាន និងឃើញពួកគេនិយាយជាមួយគ្នា ប៉ុន្តែ "មិនដឹងទេការងារគាត់។")។ ឯកសារ **D219/504**

122. ទីពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកទៅលើសាក្សីបួននាក់ក្នុងការសន្និដ្ឋានថា អោ អាន បានបញ្ជាឱ្យលេខាស្រុកកំណត់អត្តសញ្ញាណ និងសម្លាប់អ្នកត្អូញត្អែរអំពីលក្ខខណ្ឌរស់នៅ និងលក្ខខណ្ឌការងារ[277]។ ទោះបីជាយ៉ាងណាក៏ដោយ នៅពេលមានការពិនិត្យយ៉ាងហ្មត់ចត់ទៅលើខ្លឹមសារភស្តុតាង វាបង្ហាញយ៉ាងច្បាស់ថា មានតែ ប្រាក់ យុត ប៉ុណ្ណោះដែលគាំទ្រការសន្និដ្ឋាននេះ[278] ហើយការរៀបរាប់ដែលមិនគួរឱ្យជឿជាក់បានរបស់គាត់តែមួយនោះ មិនអាចបង្កើតបានជាភស្តុតាងសំខាន់ និងបញ្ជាក់បន្ថែមគ្រប់គ្រាន់ឡើយ។ ស្រដៀងគ្នានេះដែរ នៅពេលដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថា អោ អាន បានបញ្ជាឱ្យ ប្រាក់ យុត និងអ្នកដទៃទៀត ចាប់ខ្លួន និងសម្លាប់ប្រជាជនចាមទាំងអស់នោះ[279] គាត់យោងតែទៅលើភស្តុតាងដែលមិនគួរឱ្យជឿជាក់បានរបស់ ប្រាក់ យុត អំពីស្រុកកំពង់សៀមប៉ុណ្ណោះ។ ពុំមានភស្តុតាងពាក់ព័ន្ធនឹងស្រុកផ្សេងៗទៀតឡើយ[280]។

---

(កំណត់ហេតុស្តាប់ចម្លើយ សាត ភាព) ឆ.៨៧ (សាត ភាព លើកឡើងថា ងួរ បានរាយការណ៍ទៅ អោ អាន ប៉ុន្តែ ទទួលស្គាល់ថា គាត់គ្រាន់តែ "ដឹង" រឿងនេះ "ដោយសារតែ តាអាន ជាលេខាតំបន់"។ គាត់ក៏ចាំផងដែរថាបានឃើញ ងួរ បើកឡានទៅផ្ទះរបស់ អោ អាន រៀងរាល់ប្រាំថ្ងៃម្តង ឬមួយសប្តាហ៍ម្តង ប៉ុន្តែ មិនដែលឃើញដោយផ្ទាល់នូវការប្រជុំ ហើយគាត់មិនដឹងថាពួកគេនិយាយពីអ្វីខ្លះនោះទេ។)។ ឯកសារ **D219/837** (កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន) ឆ.១១៣ (សូ សារ៉េន ទទួលស្គាល់ថា គាត់មិនដឹងថា ងួរ រាយការណ៍ទៅអ្នកណាទេ និងគ្រាន់តែបានឃើញគាត់មកតំបន់ដើម្បីជួប "តាអាន ជូនកាលមកជួប បងអូន" ។ គាត់មិនដឹងអំពីខ្លឹមសារនៃការប្រជុំទេ។)។ ឯកសារ **D219/442** (កំណត់ហេតុស្តាប់ចម្លើយ ជុំ វង្ស) ឆ.២០៦ (ងួរ មិនបានលើកឡើងពី អោ អាន ឬសង្វាក់នៃការបញ្ជា និងគ្រាន់តែសន្មតថា អ្នកទោសត្រូវបានយកទៅសម្លាប់ចោល ពីព្រោះគាត់មិនឃើញពួកគេត្រឡប់មកវិញ និងបំភ្លឺថា ចម្លើយរបស់គាត់ទាក់ទងនឹងបញ្ហានេះក្នុងកិច្ចសម្ភាសន៍លើកមុន មិនត្រូវបានកត់ត្រាត្រឹមត្រូវនោះទេ។)។

[277] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៥ ជើងទំព័រ ៧១៨ (ដកស្រង់ ប្រាក់ យុត, ហុក ហឿន, បោ ទ្រព្យ និង ជីន ស៊ីណាល់)។

[278] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៥ ជើងទំព័រ ៧១៨។ (ប្រាក់ យុត គឺជាសាក្សីតែមួយរូបដែលត្រូវបានដកស្រង់ ដែលបានឆ្លើយដាក់ទៅលើ អោ អាន។ សាក្សីដទៃទៀតត្រូវបានដកស្រង់ ត្រឹមតែពិភាក្សាអំពីស្ថានភាពធ្វើការអាក្រក់ និងអះអាងថា កម្មាភិបាលកម្រិតតំបន់ដែលចុះមកមើល គឺបានដឹងអំពីស្ថានភាពទាំងអស់នេះ។ មិនមានការលើកឡើងអំពី អោ អាន ឬសិទ្ធិអំណាចរបស់គាត់ ទៅលើលេខាស្រុកនោះទេ)។

[279] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៤។

[280] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៤ ជើងទំព័រ ២១៦៣ (មិនមានភស្តុតាងណាមួយដែលគាំទ្រ ប្រាក់ យុត ឡើយ។ ញឹម កុល បានផ្តល់ភស្តុតាងចចាមអារាមអំពី ប្រាក់ យុត ប៉ុន្តែគាត់មិនបានលើកអំពី អោ អាន ទេ។ យូ វ៉ាន់ បានរំឮកថា ប្រាក់ យុត បានទៅ "និយាយជាមួយតា អាន អំពីការជំនួសមេឃុំ" ប៉ុន្តែគាត់មិនបានទៅជាមួយ ប្រាក់ យុត ឡើយ)។

123. ទីបី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បកស្រាយបំប្លែងភស្តុតាងយ៉ាងច្បាស់ក្រឡែត នៅពេលគាត់មានគោលបំណងភ្ជាប់ទំនាក់ទំនងរវាង អោ អាន ជាមួយនឹងលេខាស្រុកផ្សេងៗទៀត ដូចជា កាន និង ភឹម។ ឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថា អោ អាន បានណែនាំ កាន នៅស្រុកកងមាស និង "មេស្រុក" ផ្សេងទៀត នៅតំបន់ ៤១ អំពី "ប្រតិបត្តិការបោសសម្អាត" និងកិច្ចការផ្សេងទៀតនៅក្នុងតំបន់"[281]។ គាត់យោងទៅលើផ្នែកមួយទៀតនៃដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនទៅជំនុំជម្រះ) ដែលពុំគាំទ្រដល់ការសន្និដ្ឋាននេះទេ[282]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានធ្វើការទាយស្មានផងដែរ ជាជាងធ្វើការកំណត់អង្គហេតុ ដោយបញ្ជាក់ថា "ក្នុងឋានៈជាលេខាស្រុក ភឹម ប្រាកដជាទទួលបញ្ជាពី អោ អាន ពាក់ព័ន្ធនឹងការចាប់ខ្លួន និងការសម្លាប់ខ្នាំង"[283]។

124. ទីបួន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានថា អោ អាន បានចេញបញ្ជាទៅអ្នកក្រោមបង្គាប់សំខាន់ៗ ដូចជា អួន, សុខ និង ង៉ូវ ពាក់ព័ន្ធនឹងការចាប់ខ្លួន "ផែនការសម្លាប់" និងការសួរចម្លើយនៅមន្ទីរសន្តិសុខ[284]។ ទោះបីជាយ៉ាងណាក៏ដោយ ការពិនិត្យយ៉ាងហ្មត់ចត់ទៅលើខ្លឹមសារនៃភស្តុតាងបង្ហាញថា បុគ្គលទាំងនេះអាចបំពេញភារកិច្ច ឬការទទួលខុសត្រូវជាក់លាក់ ប៉ុន្តែ អោ អាន មិនបានបញ្ជា ឬអនុញ្ញាតឲ្យពួកគាត់ធ្វើបែបនេះឡើយ[285]។

---

[281] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤៦៣។

[282] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ៤៦៣ ជើងទំព័រ ១៤៥៤ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយោងទៅរកផ្នែក ៦.៣.៤.២។ នៅក្នុងផ្នែកនេះ មានការយោងមិនច្បាស់លាស់ទៅរក អោ អាន ថាចេញបញ្ជាទៅ "ថ្នាក់ក្រោម" អួន ឬ ង៉ូវ។ ប៉ុន្តែទាំងកាន និង "មេស្រុក" ដទៃទៀត មិនត្រូវបានលើកឡើងជាក់លាក់ឡើយ។ មានការយោងតែមួយគត់ដែលបានលើកឡើង នៅក្នុងផ្នែកនេះគឺ "លេខាស្រុក" នៅត្រង់កថាខណ្ឌ ២៨២ ដែលបានដកស្រង់ភស្តុតាង ដែលទាក់ទងតែទៅនឹង ប្រាក់ យុត)។

[283] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥០៣ (កថាខណ្ឌនេះយោងត្រឡប់ទៅរកកថាខណ្ឌ ២៨២ ដែលមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ សម្រាប់ភ្ជាប់ការទាក់ទងរវាង អោ អាន ជាមួយ ភឹម ទោះជាដោយផ្ទាល់ឬដោយប្រយោលក្តី)។

[284] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៩, ២៨២, ២៨៧, ៤២៧។

[285] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៩ ជើងទំព័រ ៧៣៥ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើព័ត៌មានមិនអាចជឿជាក់បាន និងមិនមានការគាំទ្ររបស់ ញ៉ឹម ចេន។ តុយ មាជ និង ញ៉ឹម កុល មិនបានគាំទ្រដល់ ញ៉ែម ចេន ឡើយ។ ពួកគេបញ្ជាក់ថា អួន និង ប្រាក់ យុត បានចេញបញ្ជាចាប់ខ្លួន និងសម្រេចពីជោគវាសនារបស់អនុប្រធានភូមិ ដែលត្រូវបានចាប់ខ្លួន ប៉ុន្តែពួកគេមិនបានលើកឡើងអំពីសិទ្ធិអំណាចរបស់ អោ អាន ឡើយ) កថាខណ្ឌ ២៨២ ជើងទំព័រ ៧៣៧។ ភស្តុ

125. ចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជូនកាលយោងទៅលើ “កម្មាភិបាលក្រោមបង្គាប់” ដែលគ្មានបញ្ជាក់អត្តសញ្ញាណ និងសេចក្តីប្រកាស ឬការណែនាំនៅក្នុងកិច្ចប្រជុំទូទៅ ដើម្បីសន្និដ្ឋានថា អោ អាន មានអំណាចនៅក្នុងតំបន់ ៤១[286]។ ការសន្និដ្ឋានទាំងនេះ តែងតែផ្អែកទៅលើសាក្សីដែលមិនមានការបញ្ជាក់ដែលអះអាងថាបានចូលរួមប្រជុំជាមួយ អោ អាន ប៉ុន្តែការយល់ដឹងអំពីខ្លឹមសារនៃកិច្ចប្រជុំទាំងនោះគឺនៅជាមន្ទិលនៅឡើយ ដោយសារតែអាយុ ឬមុខតំណែងរបស់ពួកគាត់ (ឧទា. ញ៉ែម ចេន)[287] ឬសក្ខីកម្មមិនស៊ីសង្វាក់គ្នា (ឧទា. យូ វ៉ាន់)[288]។ មេធាវីការពារក្តីសូមអះអាងថា ការនឹកឃើញឡើងវិញនូវសេចក្តីប្រកាសជាទូទៅ ទៅកាន់មនុស្សដែលគេមិនស្គាល់អំពីប្រធានបទដែលគ្មានការបញ្ជាក់ឲ្យបានច្បាស់នោះ គឺមិនមែនជាភ័ស្តុតាងគ្រប់គ្រាន់ក្នុងការសន្និដ្ឋានថា អោ អាន បានចេញបញ្ជាទៅកម្មាភិបាលក្រោមបង្គាប់ឡើយ ទោះបីជាសេចក្តីប្រកាសទាំងនោះពិតក៏ដោយ។

*(៥) អោ អាន មិនបានទទួលរបាយការណ៍ពីលេខាស្រុក ឬឃុំ ឬ “កម្មាភិបាលក្រោមបង្គាប់” ឡើយ*

126. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានដោយភាន់ច្រឡំថា អោ អាន “បានដឹងនូវសកម្មភាពទាំងអស់របស់បក្សកុម្មុយនីស្តកម្ពុជានៅក្នុងតំបន់ និងភូមិភាគរបស់គាត់” ដោយសារតែប្រព័ន្ធទំនាក់ទំនង និងរាយការណ៍ដ៏តឹងរ៉ឹង” របស់ បក្សកុម្មុយនីស្តកម្ពុជា[289] ហើយថា គាត់បានត្រួតពិនិ

---

តាងដែលនៅសល់ដែលសហចៅក្រមស៊ើបអង្កេតបានផ្តល់ឲ្យ គឺជាភស្តុតាងចចាមអារាម បានមកពីសាក្សី ញ៉ែម ចេន និង យូ វ៉ាន់ ដែលមិនមានការគាំទ្រ និងមិនអាចជឿជាក់បាន។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៧ ជើងទំព័រ ៧៤៦ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកតែទៅលើ ញ៉ែម ចេន ដែលមិនបានបញ្ជាក់ឲ្យច្បាស់លាស់ថាតើ គាត់បានចូលរួមដោយផ្ទាល់ក្នុងកិច្ចប្រជុំ អំពីបញ្ហា និងបានស្តាប់ការការពិភាក្សាអំពី “ផែនការសម្លាប់មនុស្ស” ដែរឬអត់នោះទេ)។ កថាខណ្ឌ ៤២៧ ជើងទំព័រ ១៣២៣ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកតែទៅលើ យូ វ៉ាន់ ដែលត្រូវបានសាកសួរដោយអ្នកស៊ើបអង្កេត របស់ ក.ស.ច.ស និងដែលបានបញ្ជាក់ថាគាត់បានស្តាប់ឮ អោ អាន “អនុញ្ញាតិ ផុន ឲ្យវាយដំមនុស្សក្នុងពេលសួរចម្លើយ”)។

[286] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៣, ២៩៤, ២៩៩, ៣០១, ៣១១, ៦៣៦។

[287] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៣ ជើងទំព័រ ៧៣៩ កថាខណ្ឌ ២៩៩ ជើងទំព័រ ៧៩២ កថាខណ្ឌ ៣០១ ជើងទំព័រ ៨០០-៨០៣។

[288] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣១១ ជើងទំព័រ ៨៣១ កថាខណ្ឌ ៦៣៦ ជើងទំព័រ ២១៧៥។

[289] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៧១៩, ៨២៦។

ឲ្យការវិវត្តនៃប្រតិបត្តិការសម្លាប់មនុស្ស តាមរយៈរបាយការណ៍ដែលបានរាយការណ៍ទៅគាត់[290]។ នៅទូទាំងដីកាដំណោះស្រាយរបស់គាត់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ យោងជាសំអាងថា អោ អាន ទទួលរបាយការណ៍ពីលេខាស្រុក[291] កម្មាភិបាលក្រោមបង្គាប់ដែលមិនបានបញ្ជាក់អត្តសញ្ញាណ ឬថ្នាក់ក្រោម[292] ប៉ុន្តែគាត់មិនបានផ្តល់នូវភ័ស្តុតាងគ្រប់គ្រាន់ ឬភ័ស្តុតាងបញ្ជាក់ឡើយ[293]

---

[290] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៣០, ៨៣៥។

[291] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៦៣, ២៦៦, ៤៣១។ ការសម្រេចយ៉ាងទូលាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អោ អាន ទទួលរបាយការណ៍ពី "ស្រុក" ឬពីលេខាស្រុក គឺជាថ្មីម្តងទៀតបានពឹងផ្អែកទៅលើភស្តុតាងទាក់ទងតែជាមួយ ប្រាក់ យុត និងស្រុកកំពង់សៀមប៉ុណ្ណោះ។ ជាទូទៅភស្តុតាងនេះមានត្រឹមតែ ចម្លើយដែលមិនអាចជឿជាក់បានរបស់ ប្រាក់ យុត ខ្លួនគាត់ផ្ទាល់ ដែលជាញឹកញាប់ត្រូវបានគាំទ្រដោយភស្តុតាងចចាមអារាម មិនមានការគាំទ្រ និងបង្ហាញដោយខុស។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៦៣ ជើងទំព័រ ៦៦២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ យូ វ៉ាន់ ដែលបានរំឭកថាបានបញ្ជូនលិខិតរវាង អោ អាន និង ប្រាក់ យុត ហើយបានឮពីបញ្ជីឈ្មោះមួយ ដែលត្រូវបញ្ជូនទៅ អោ អាន។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកចេញយ៉ាងល្អនូវចម្លើយរបស់ យូ វ៉ាន់ ដែលថាលិខិតនោះគឺអំពីការងារសេដ្ឋកិច្ច។ យូ វ៉ាន់ ក៏បាននិយាយយ៉ាងច្បាស់ថា របាយការណ៍ខ្លះមិនមានព័ត៌មានអំពីមនុស្សដែលបានបាត់ខ្លួន ឬត្រូវបានបញ្ជូនទៅ "កែប្រែ" ឬទៅមន្ទីរសន្តិសុខឡើយ។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ សូ សារ៉េន ដែលបានរំឭកថាបានយកលិខិតម្តងម្កាល ពីស្រុកទៅឲ្យ អោ អាន គឺមិនមែនរបាយការណ៍ទេ ហើយសូ សារ៉េន បានទទួលស្គាល់ថា គាត់មិនបានដឹងថាលិខិតទាំងនោះជាលិខិតអ្វីទេ។ គាត់គ្រាន់តែទាយស្មានថា អោ អាន "វាយលិខិតដែលត្រូវបញ្ជូនទៅ សុខ ហើយឲ្យគេបញ្ជូនលិខិតទាំងនោះទៅស្រុក"។ គាត់មិនបានដឹងអំពីខ្លឹមសារលិខិតទាំងនោះឡើយ។ កថាខណ្ឌ ៤៣១ ជើងទំព័រ ១៣៣៧ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកតែទៅលើ យូ វ៉ាន់ ដែលគ្រាន់តែឮពី ប្រាក់ នី ថា គាត់បានរាយការណ៍ទៅ អោ អាន)។

[292] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧, ២៨៥, ៣៨៦។

[293] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើចម្លើយដែលមិនមានការគាំទ្រ អំពីរបាយការណ៍មកពីស្រុកកំពង់សៀម។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧ ជើងទំព័រ ៦៤០ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកស្រង់ភស្តុតាងមកពី ប្រាក់ យុត និង យូ វ៉ាន់ អំពីស្រុកកំពង់សៀម)។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកបន្ថែមទៀតទៅលើ ភស្តុតាងទាយស្មាននិងមិនច្បាស់លាស់។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៥ ជើងទំព័រ ៧៤១ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកលើ ញ៉ែម ចេន ដែលបានរំឭកថាបញ្ជូនលិខិតបិទជិតពី ង៉ូវ ទៅឲ្យ អោ អាន ប៉ុន្តែគាត់មិនមានមូលដ្ឋានអ្វី ដែលអាចដឹងពីខ្លឹមសារនៃលិខិតទាំងនោះឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាពីការដែល ញ៉ែម ចេន បានទទួលស្គាល់ថា មិនបានដឹងអំពីការចាប់ខ្លួន និងការសម្លាប់មនុស្សនៅក្នុងតំបន់ ៤១ ឡើយ)។ កថាខណ្ឌ ៣៨៦ ជើងទំព័រ ១១៧៨ ដល់១១៧៩ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ ញ៉ែម ចេន ដែលបញ្ជាក់ថាគាត់មិនបានដឹង អំពីខ្លឹមសារនៃលិខិត ហើយមិនមានមូលដ្ឋានដឹងឮច្បាស់លាស់ អំពីរបាយការណ៍ពាក់ព័ន្ធ

។

127. តាមពិត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អាចកំណត់អត្តសញ្ញាណបានតែបុគ្គលពីររូបប៉ុណ្ណោះ គឺ ប្រាក់ យុត[294] និង ង៉ូវ[295] ដែលពាក់ព័ន្ធនឹងរបាយការណ៍។ ភស្តុតាងអំពីអត្ថិភាព និងខ្លឹមសារនៃរបាយការណ៍តាមការសន្មតទាំងនេះ គឺជាថ្មីម្តងទៀតផ្អែកជាចម្បងទៅលើចម្លើយដែលមិនគួរឲ្យជឿជាក់បានរបស់ ប្រាក់ យុត[296]។ សក្ខីកម្មរបស់គាត់អំពីរបាយការណ៍ដែលគាត់ផ្ញើជូនទៅ អោ អាន ត្រូវបានគាំទ្រដោយភស្តុតាងចចាមអារ៉ាមតែពី យូ វ៉ាន់[297] និងចម្លើយពីសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដទៃទៀតដែលត្រូវបានបកស្រាយបំភ្លៃការពិត។ តាមពិត ពួកគាត់មិនបានបញ្ជាក់អំពី អោ អាន ឡើយ[298]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេត

---

ការសម្លាប់មនុស្សឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកបន្ថែមទៀតទៅលើ ង៉ូវ ដែលគ្រាន់តែទាយស្មានថា កងទ័ពបានត្រៀមរបាយការណ៍លម្អិតសម្រាប់ "ថ្នាក់តំបន់" ប៉ុន្តែគាត់មិនបានលើកអំពី អោ អាន ទេ)។

[294] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៧, ៣០៣, ៣៦៤, ៤២៩, ៦៣៥។

[295] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៩, ២៨៥,៣៩៥។

[296] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៦៤ ជើងទំព័រ ១០៣១, ១០៣៧ កថាខណ្ឌ ៦៣៥ ជើងទំព័រ ២១៧១ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកតែទៅលើ ប្រាក់ យុត)។

[297] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤២៩ ជើងទំព័រ ១៣២៧ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តល់ភស្តុតាងចចាមអារាមមកពី យូ វ៉ាន់។ ឯកសារ **D219/702.1.87** (ប្រតិចារឹកសំណុំរឿង ០០២/០២ យូ វ៉ាន់) ភាសាអង់គ្លេស 01438507-08 (យូ វ៉ាន់ បានរំឮកពីការចងក្រងបញ្ជីឈ្មោះ និងថា ខុម បានប្រាប់គាត់ថា ប្រាក់ យុត បញ្ជូនឈ្មោះទៅ អោ អាន))។ កថាខណ្ឌ ៦៣៥ ជើងទំព័រ ២១៧០ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្តល់នូវពាក្យចចាមអារ៉ាមម្តងទៀតពី យូ វ៉ាន់។ ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់) ឆ. ៥៥ (យូ វ៉ាន់ បានឮពីផែនថា គាត់បានរាយការណ៍ទៅ ប្រាក់ យុត ហើយ ប្រាក់ យុត រាយការណ៍បន្តទៅ អោ អាន អំពី "ការបាត់ខ្លួន" មនុស្សដែលមានឈ្មោះក្នុងបញ្ជី))។

[298] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៣ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើ ពៅ សារ៉ុម ដែលបានរំឮកពីមេភូមិម្នាក់ ដែលត្រូវបានកម្មាភិបាលថ្នាក់តំបន់ ចាប់ខ្លួនយកទៅ ហើយនិងការដែល ណាន បានបញ្ជាគាត់ផ្ទាល់ឲ្យរៀបចំបញ្ជីឈ្មោះ ប៉ុន្តែគាត់មិនបានលើកឡើងពីឈ្មោះ ប្រាក់ យុត ឬពីនីតិវិធីរាយការណ៍ឡើយ) កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១៥ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើ ញឹម កុល ជាសាក្សីមិនអាចជឿជាក់បាន និង ពេជ្រ ជឹម។ ញឹម កុល បានរំឮកថាបានផ្តល់កំណត់ត្រាស្ថិតិទៅឲ្យ រ៉ុម ហើយ រ៉ុម បានបញ្ជូនបន្តទៅ តា ណាន ដែលទទួលខុសត្រូវលើស្រុក ប៉ុន្តែ ញឹម កុល មិនបានលើកឡើងពីឈ្មោះ ប្រាក់ យុត ឬ អោ អាន ឡើយ សម្រាប់បញ្ហានេះ។ ពេជ្រ ជឹម បានបញ្ជាក់ថារបាយការណ៍ត្រូវបានបញ្ជូន ពីមន្ទីរសន្តិសុខ ក្រាំង តាចាន់ ទៅតំបន់តាមរយៈស្រុក ប៉ុន្តែគាត់មិនបានលើកឡើងពី ប្រាក់ យុត ឬ អោ អាន ឡើយ) កថាខណ្ឌ ៤២៩ ជើងទំព័រ ១៣២៧ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើ ពៅ សារ៉ុម ដែលបានរំឮកពីការប្រជុំជាមួយមេភូមិ ហើយបានប្រាប់ពួកគេឲ្យរៀបចំបញ្ជីឈ្មោះ ប៉ុន្តែមិនបានលើក

អន្តរជាតិ ទទួលស្គាល់អំពីភាពមិនស៊ីសង្វាក់គ្នានៅក្នុងភ័ស្តុតាងរបស់ ប្រាក់ យុត នៅត្រង់ចំណុចនេះ[299] ប៉ុន្តែនៅតែបន្តផ្អែកទៅលើសក្ខីកម្មរបស់គាត់ទៀត។ នៅត្រង់កន្លែងជាច្រើន គាត់ទទួលស្គាល់ថា យូ វ៉ាន់ ផ្តល់ភ័ស្តុតាងផ្ទុយគ្នា ប៉ុន្តែគាត់មិនបានពន្យល់ឡើយថាហេតុអ្វីបានជាភ័ស្តុតាងនេះមិនត្រូវបានយកមកពិចារណា ឬទាត់ចោល ដោយសារតែមិនគួរឲ្យជឿជាក់បាន[300]។

128. ស្រដៀងគ្នានេះដែរ ភ័ស្តុតាងដែលគាំទ្រការសន្និដ្ឋានរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា ង៉ូវ បានបញ្ជូនរបាយការណ៍ជាលាយលក្ខណ៍អក្សរទៅ អោ អាន ដែលបញ្ជាក់អំពីការសម្លាប់មនុស្សនៅមន្ទីរសន្តិសុខ មិត្តសុប គឺមិនគ្រប់គ្រាន់ឡើយ ដោយសារមានតែការរៀបរាប់ដែលមិនគួរឲ្យជឿជាក់បានរបស់ ញ៉ែម ចេន ប៉ុណ្ណោះ[301]។ ការសន្និដ្ឋានម្តងហើយម្តងទៀតរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា ង៉ូវ បានចុះទៅមន្ទីរតំបន់ (ជារឿយៗ ឬជារៀងរាល់សប្តាហ៍) ដើម្បីរាយការណ៍ទៅ អ៊ូន និង អោ អាន ផ្អែកទៅលើសក្ខីកម្មពីសាក្សីដែលមិនមានវត្តមាននៅក្នុងកិច្ចប្រជុំទាំងនោះ[302] និងផ្អែកទៅលើ ភ័ស្តុតាងដែលមិនគួរឲ្យជឿជាក់បានពី ង៉ូវ ខ្លួនគាត់ផ្ទាល់តែម្តង[303]។

---

ឡើងពី អោ អាន ឡើយ និងទៅលើ ញឹម កុល ដែលបញ្ជាក់ថាមេភូមិត្រូវរាយការណ៍ ទៅស្រុកឬឃុំមុនពេលធ្វើការចាប់ខ្លួន ប៉ុន្តែគាត់មិនបាននិយាយពីឈ្មោះ ប្រាក់ យុត ឬ អោ អាន ទេ)។

[299] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៥។

[300] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៧ ជើងទំព័រ ៧៨៣ កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១៥។

[301] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៩ ជើងទំព័រ ៧៣៣ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកតែទៅលើ ញ៉ែម ចេន ដែលបញ្ជាក់ថាគាត់បានបញ្ជូន លិខិតបិទជិតមួយពីឈ្មោះ ង៉ូវ ទៅឲ្យ អោ អាន ប៉ុន្តែចំពោះខ្លឹមសារលិខិត គឺ ញ៉ែម ចេន ធ្វើការទាយស្មាន)។

[302] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៥ ជើងទំព័រ ៧៤២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកទៅលើឈ្មោះ ង៉ូវ ដែលបញ្ជាក់ថាគាត់បានរៀបចំកំណត់ត្រាទិន្នន័យ ដើម្បីរាយការណ៍ទៅឈ្មោះ អ៊ូន ហើយឈ្មោះ អ៊ូន រាយការណ៍ទៅប្រធានមន្ទីរតំបន់ ប៉ុន្តែគាត់មិនបានលើកឡើងអំពី អោ អាន ឡើយ)។ កថាខណ្ឌ ៣៩៥ ជើងទំព័រ ១១៧០ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើ ញ៉ែម ចេន ដែលបានរំឭកអំពី អោ អាន បានកោះហៅ ង៉ូវ ទៅប្រជុំនៅតំបន់ ប៉ុន្តែគាត់មិនបានរៀបរាប់ពីខ្លឹមសារនៃការប្រជុំ ឬបញ្ជាក់ថាគាត់បានចូលរួមប្រជុំទេ)។

[303] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៩៥ ជើងទំព័រ ១១៧១-៧៦ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែទៅលើ ង៉ូវ ដែលបានរំឭកពីការរាយការណ៍ទៅ អ៊ូន ប្រធានមន្ទីរតំបន់ អំពីចំនួនអ្នកទោស ហើយ ង៉ូវ បានដឹងតាមរយៈពាក្យចចាមអារាម ឬការទាយស្មាន អំពីរបាយការណ៍ទាំងអស់នេះ ដែលទាហានបានបញ្ជូនទៅ អោ អាន)។

*(៦) អោ អាន មិនបានដឹកនាំកិច្ចប្រជុំថ្នាក់តំបន់ អំពីនយោបាយ សន្តិសុខ ឬយោធាទេ*

129. ដូចបានពន្យល់នៅក្នុងផ្នែក II(ង)(ii) សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសនៅក្នុងការសន្និដ្ឋានថា អោ អាន ដឹកនាំកិច្ចប្រជុំថ្នាក់តំបន់ ឬវគ្គបណ្ដុះបណ្ដាលអំពីបញ្ហានយោបាយ សន្តិសុខ ឬយោធា ពីព្រោះភ័ស្តុតាងមិនមានការបញ្ជាក់ និងមានទម្ងន់គ្រប់គ្រាន់ឡើយ។ ភ័ស្តុតាងនៅក្នុងសំណុំរឿង យ៉ាងច្រើនបំផុត បង្ហាញថា អោ អាន អាចបានចូលរួមកិច្ចប្រជុំទូទៅជាមួយនឹងកម្មាភិបាលរាប់រយនាក់ផ្សេងទៀត ឬដឹកនាំកិច្ចប្រជុំថ្នាក់តំបន់ខ្លះៗអំពីបញ្ហាសេដ្ឋកិច្ច។ ចំណុចនេះ មិនបានបង្ហាញស្របតាមបទដ្ឋានតម្រូវថា អោ អាន *ជាក់ស្ដែង*ជាលេខាតំបន់នោះឡើយ។

130. ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្ដល់នូវភ័ស្តុតាងសំខាន់ និងបញ្ជាក់បន្ថែមគ្រប់គ្រាន់ថា អោ អាន *ជាក់ស្ដែង* ជាលេខាតំបន់ ៤១ ឡើយ។ គាត់មិនបានបង្ហាញស្របតាមបទដ្ឋានតម្រូវ ថា អោ អាន បានទទួល បានអនុវត្ត ឬបានរាយការណ៍ តាមបញ្ជាពី កែ ពក ឬសមាជិកគណៈភូមិភាគដទៃទៀត, ថា អោ អាន បានតែងតាំង ឬបានដកលេខាឃុំ លេខាស្រុក ឬបុគ្គលិកសំខាន់ៗដទៃទៀត, ថា អោ អាន បានចេញបញ្ជា ឬបានទទួលរបាយការណ៍ពីលេខាឃុំ លេខាស្រុក ឬកម្មាភិបាលសំខាន់ៗដទៃទៀត, ឬថា អោ អាន បានដឹកនាំកិច្ចប្រជុំថ្នាក់តំបន់អំពីបញ្ហានយោបាយ សន្តិសុខ ឬយោធានោះឡើយ។

<u>គ) អោ អាន មិនមានអំណាចទៅលើបញ្ហាសន្តិសុខ ឬមន្ទីរសន្តិសុខនៅក្នុងតំបន់ ៤១ ឡើយ ហើយបើទោះបីជាធ្លាប់ឃើញគាត់នៅទីនោះក៏ដោយ ក៏គាត់កម្រមានវត្តមាននៅទីនោះណាស់</u>

131. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសនៅក្នុងការសន្និដ្ឋានថា អោ អាន បានប្រើសិទ្ធិអំណាចលើបញ្ហាសន្តិសុខ រួមទាំង តាមរយៈការគ្រប់គ្រងមន្ទីរសន្តិសុខនៅក្នុងតំបន់ ៤១[304]។ តាមពិត បើទោះបីជាធ្លាប់ឃើញ អោ អាន នៅមន្ទីរសន្តិសុខទាំងនោះក៏ដោយ ក៏គាត់កម្រមានវត្តមាននៅទីនោះណាស់ ហើយពុំមានភ័ស្តុតាងពិតប្រាកដ និងភ័ស្តុតាងបញ្ជាក់បន្ថែមដែលបង្ហាញថា អោ អាន បានចេញបញ្ជាទៅប្រធានមន្ទីរសន្តិសុខ[305] បានទទួលរបាយការណ៍អំពីបញ្ហាសន្តិសុខ[306] ឬ

---

[304] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧។

[305] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨២, ២៨៧។

[306] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧, ២៨៥, ៣៩៦។

បានអនុញ្ញាតឲ្យមានការបញ្ជូនអ្នកទោសឡើយ[307]។

132. ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់គាត់ដែលថា អោ អាន បានចុះមើលមន្ទីរសន្តិសុខក្នុងតំបន់ ៤១ ជាទៀតទាត់នោះ[308] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់ភ័ស្តុតាងសម្រាប់ទីតាំងតែបីប៉ុណ្ណោះ ក្នុងចំណោមទីតាំងទាំងប្រាំពីរ[309] ដែលប្រការនេះមេធាវីការពារនៅតែអះអាងថាមិនគ្រប់គ្រាន់ឡើ

---

[307] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៩។

[308] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៦។

[309] **<u>មិត្តសុប៖</u>** សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤១០-៤១១ ជើងទំព័រ ១២៣៧-១២៣៩។ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការសម្រេចថា ព័ត៌មានរបស់ អ៊ឹម ប៉ុន ដែលតាមព័ត៌មាននោះដែលថា អ៊ឹម ប៉ុន មិនដែលបានបើកឡានជូន អោ អាន ទៅមិត្តសុប គឺមិនអាចជឿជាក់បាន ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាទៅដល់ សក្ខីកម្មផ្សេងទៀតដែល ញ៉ែម ចេន បានឆ្លើយផ្ទុយជាមួយចម្លើយខ្លួនឯង ហើយបញ្ជាក់ថាគាត់មិនដែលឃើញ អោ អាន ទៅមិត្តសុបទេ។ ជំនួសមកវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បែរជាពឹងផ្អែកទៅលើព័ត៌មានរបស់ ញ៉ែម ចេន ដែលបញ្ជាក់ថាគាត់អមដំណើរសុក ទៅគរ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានដកស្រង់ ង៉ូវ ដែលបានបញ្ជាក់ច្បាស់ថា គាត់ធ្វើការនៅមន្ទីរសន្តិសុខមិត្តសុប រយៈពេលរាប់ខែ ហើយមិនដែលឃើញឬដឹងថា អោ អាន បានទៅទីនោះទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចដោយខុសឆ្គងនិងមិនច្បាស់លាស់ថា ចម្លើយរបស់ ង៉ូវ មិនអាចជឿជាក់បាន។ **<u>វត្តអូរត្រកួន៖</u>** សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤៩១ ជើងទំព័រ ១៥៩៥- ១៥៩៧។ ដើម្បីគាំទ្រការសន្និដ្ឋានរបស់គាត់ដែលថា អោ អាន បានទៅពិនិត្យមន្ទីរសន្តិសុខវត្តអូរត្រកួនយ៉ាងតិចម្តង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើសាក្សីតែពីររូប៖ ញ៉ែម ចេន ដែលបញ្ជាក់ថា អោ អាន ទៅវត្តអូរត្រកួន ប៉ុន្តែមិនបានផ្តល់ព័ត៌មានលម្អិតឡើយ និង សេង ស្រ៊ុន ដែលបញ្ជាក់ថា គាត់បានចូលរួមក្នុងការប្រជុំ នៅវត្តអូរត្រកួនជាមួយ គិន ភាព ហន និង កាន ហើយក្នុងការប្រជុំនេះ អោ អាន និយាយអស់រយៈពេលរាប់ម៉ោង។ ភស្តុតាងនេះមិនគ្រប់គ្រាន់ដើម្បីសម្រេចថា អោ អាន បានប្រើប្រាស់សិទ្ធិអំណាចទៅលើមន្ទីរសន្តិសុខនេះ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏មិនបានពិចារណាទៅលើភស្តុតាងដោះបន្ទុក ដែលចង្អុលបង្ហាញថា អោ អាន មិនដែលបានទៅវត្តអូរត្រកួនទេ។ ឧទាហរណ៍ ឯកសារ **D117/50** (កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ឹម ប៉ុន) ឆ៥០-ឆ៥២ (អ៊ឹម ប៉ុន បានបញ្ជាក់ថា គាត់មិនដែលបើកឡានជូន អោ អាន ទៅមន្ទីរសន្តិសុខណាមួយឡើយនៅក្នុងតំបន់)។ ឯកសារ **D117/64** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ថុង គឹមឃុន) ឆ១៨ (បន្ទាប់ពីត្រូវបានស្តាប់ចម្លើយអំពីឃុំពាមជីកង [ទីតាំងវត្តអូរត្រកួន] ថុង គឹមឃុន បានបញ្ជាក់ថាគាត់មិនដែលឃើញ ឬបានជួប អោ អាន ទេ)។ ឯកសារ **D117/63** (កំណត់ហេតុស្តាប់ចម្លើយសាក្សី សាយ ឌឿន) ឆ.២៨ (សាយ ឌឿន បានបញ្ជាក់ថា គាត់មិនដែលបានឃើញ អោ អាន នៅមន្ទីរស្រុកកងមាសទេ)។ **<u>វត្តតាមាក់៖</u>** សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៨៨ ជើងទំព័រ ១៩៩៤-១៩៩៥។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើ ពេញ វ៉ា ដែលបានទាយស្មានអំពី អោ អាន ចុះពិនិត្យមើលអ្នកទោសនៅវត្តតាមាក់។ ញ៉ែម ចេន ដែលបានបញ្ជាក់ថា គាត់បានទៅចូលរួមការប្រជុំនៅវត្តតាមាក់ជាមួយ អោ អាន ប៉ុន្តែការប្រជុំនោះគឺអំពីសេដ្ឋកិច្ច គឺមិនមែនអំពីការសម្លាប់និងចាប់ខ្លួនទេ ហើយ សូ សារ៉េន ដែលបញ្ជាក់ថា អួន ដឹកនាំការប្រជុំនៅវត្តតាមាក់ ដែល តា អាន បានចូលរួម ប៉ុន្តែ សូ សារ៉េន បានទទួលស្គាល់ថាគាត់នៅក្មេង ហើយមិនបានស្តាប់ថាគេពិភាក្សា អំពីបញ្ហាអ្វីនោះទេ។

យ។ គាត់ទទួលស្គាល់ថា ពុំមានភស្តុតាងបង្ហាញថា អោ អាន ចុះទៅទស្សនកិច្ចទីតាំងសម្លាប់មនុស្សគោកព្រីង[310] វត្ត អង្គញដី ឬទួលបេង[311] វត្តបាធាយ[312] និងវត្តភ្នំប្រុសឡើយ[313]។

133. លើសពីនេះទៀត ដើម្បីគាំទ្រដល់ការសន្និដ្ឋានរបស់គាត់ដែលថា អោ អាន បានបញ្ជាឲ្យ ង៉ូវ ធ្វើគ្រប់យ៉ាងតាមការចាំបាច់ដើម្បីសម្លាប់ខ្មាំងទាំងអស់មុនឆ្នាំ១៩៧៨ នោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកតែទៅលើការរៀបរាប់របស់ ញ៉ែម ចេន ដោយគ្មានការបញ្ជាក់បន្ថែមដែលមិនគួរឲ្យជឿជាក់បាន[314]។ លើសពីនេះទៀត គាត់ពុំបានផ្តល់នូវភស្តុតាងគ្រប់គ្រាន់ឡើយក្នុងការសន្និដ្ឋានថា អោ អាន បានផ្សព្វផ្សាយបទបញ្ជាបោសសម្អាតទៅកាន់កម្មាភិបាលក្រោមបង្គាប់របស់គាត់ រួមទាំង ង៉ូវ ផងដែរ[315]។ គាត់ក៏ពុំបានផ្តល់នូវភស្តុតាងដែរអំពីការប្រាស្រ័យទាក់ទងគ្នារវាង អោ អាន ជាមួយនឹងប្រធានសន្តិសុខដទៃ[316]។

---

[310] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៨៥។

[311] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤៥៥។

[312] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៣៥។

[313] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៥៥។

[314] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៧ ជើងទំព័រ ៧៤៦ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកតែទៅលើ ញ៉ែម ចេន ដែលបញ្ជាក់ថា នៅក្នុងការប្រជុំមួយនៅគរ អោ អាន បានបញ្ជាដល់អ្នកចូលរួម ត្រូវធ្វើអ្វីដែលត្រូវស្របទៅតាមផែនការឆ្នាំ១៩៧៧។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានសួរសំណួរដេញដោល អំពីមូលដ្ឋាននៃព័ត៌មាននេះ)។

[315] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨២ ជើងទំព័រ ៧៣៧ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើប្រាក់ យុត ដែលមិនបាននិយាយពីឈ្មោះ ង៉ូវទេ។ សូ សារ៉េន ដែលបញ្ជាក់ថាគាត់បានឃើញ ង៉ូវ ចេញចូលមន្ទីរតំបន់ដើម្បីជួប អោ អាន បានទទួលស្គាល់ថា គាត់មិនមានវត្តមានឡើយ នៅពេលដែលពួកគេជួបគ្នា ហើយគាត់មិនបានដឹងថាពួកគេនិយាយគ្នាអំពីអ្វីដែរ។ សាត ភាព គ្រាន់តែបញ្ជាក់ថា គាត់បានឃើញ ង៉ូវ បើកឡានទៅមន្ទីរតំបន់ ហើយបានផ្តល់ព័ត៌មានជាការទាយស្មាន ហើយ ង៉ូវ ដែលគ្រាន់តែបញ្ជាក់ថា គាត់បានរាយការណ៍ទៅ អួន និងទាយស្មានអំពីអ្នកទោសត្រូវគេសម្លាប់ (ដោយកែប្រែនូវចម្លើយកន្លងមក)។

[316] ឧទាហរណ៍ **<u>វត្តអូរត្រកួន៖</u>** សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤៦៣។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភស្តុតាងថា អោ អាន បានទំនាក់ទំនងជាមួយ កាន (លេខាស្រុកកងមាស) ហាន (ប្រធានមន្ទីរសន្តិសុខវត្តអូរត្រកួន) ឬឈ្លបដារវែងអំពីបញ្ហាសន្តិសុខទេ។ ដើម្បីគាំទ្រដល់ការសម្រេចរបស់គាត់ដែលថា កាន និងប្រធានស្រុកដទៃទៀតនៅក្នុងតំបន់៤១ បានទទួលបញ្ជាពី អោ អាន និងបានរាយការណ៍ទៅ អោ អាន អំពីប្រតិបត្តិការណ៍បោសសម្អាត និងកិច្ចការដទៃទៀតក្នុងតំបន់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយោងទៅរកកថាខណ្ឌ ២៩៤ នៃ*ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនទៅជំនុំជម្រះ)* ដែលមិនបានលើកឡើងអំពី កាន ហាន ឬការចេញបញ្ជាឡើយ។ **<u>វត្តបាធាយ៖</u>** សំណុំ

134. លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានផ្តល់នូវភ័ស្តុតាងសំខាន់ និងបញ្ជាក់បន្ថែមគ្រប់គ្រាន់ថា អោ អាន បានត្រួតពិនិត្យ និងទទួលរបាយការណ៍អំពីបញ្ហាសន្តិសុខពីថ្នាក់ក្រោម[317] ឬពី ង៉ូវ[318] ឬថា អោ អាន បានបញ្ជូននិរសាផ្ទាល់ខ្លួនឲ្យទៅប្រមូលរបាយការណ៍ជាលាយលក្ខណ៍អក្សរអំពីការសម្លាប់នោះឡើយ[319]។ ភ័ស្តុតាងដែលគាំទ្រការសន្និដ្ឋាននេះ គឺផ្អែកលើពាក្យចចាមអារ៉ាម ការទាយស្មាន ឬគ្មានការបញ្ជាក់បន្ថែម[320]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏ពុំបានផ្តល់នូវភ័ស្តុតាងផងដែរអំពីទស្សនកិច្ច ឬរបាយការណ៍ពីប្រធានសន្តិសុខផ្សេងទៀត។

---

រឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥០៣។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភស្តុតាងថា អោ អាន បានទំនាក់ទំនងជាមួយ ឃឹម ជាអតីតប្រធានមន្ទីរសន្តិសុខវត្តបាធាយ ឬ ភឹម លេខាស្រុកបាធាន ហើយពឹងផ្អែកទាំងស្រុងទៅលើព័ត៌មានដែលមិនមានការគាំទ្ររបស់ ញ៉ែម ចេន។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គ្រាន់តែសន្មតឬទាយស្មានថា ក្នុងនាមជាលេខាស្រុក ភឹម បានទទួលបញ្ជាពី អោ អាន ទាក់ទងការចាប់ខ្លួននិងសម្លាប់ខ្មាំង។ **<u>វត្តភ្នំប្រុស៖</u>** សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៤២-៥៤៣, ៥៤៥។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថាភ្នំប្រុសស្ថិតក្រោមការគ្រប់គ្រងរបស់ កែ ពក និង ជឿន ប៉ុន្តែមិនបានផ្តល់ភស្តុតាង អំពីការទំនាក់ទំនងរវាង អោ អាន ជាមួយពួកគេទេ។

[317] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧ ជើងទំព័រ ៦៤០ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់ភស្តុតាងជាសំខាន់ទាក់ទងស្រុកកំពង់សៀម ហើយពឹងផ្អែកសឹងតែទាំងស្រុងទៅលើ សក្ខីកម្មដែលមិនអាចជឿជាក់បាន គ្មានការគាំទ្ររបស់ ប្រាក់ យុត។ ប្រាក់ យុត បានបញ្ជាក់ថា គាត់បានរាយការណ៍ទៅ អោ អាន ប៉ុន្តែគាត់មិនអាចផ្តល់ព័ត៌មានលម្អិត អំពីទម្រង់នៃរបាយការណ៍ ខ្លឹមសាររបាយការណ៍ និងការរាយការណ៍ញឹកញាប់កម្រិតណា។ ឧទាហរណ៍ ឯកសារ **D117/72** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.៥។ ឯកសារ **D117/73** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.៥, ឆ.៧, ឆ.១០, ឆ.១៥។ ឯកសារ **D219/702.1.95** (ប្រតិចារឹក ប្រាក់ យុត), ភាសាអង់គ្លេស 01441027, 01441043-44, 01441046 ទំព័រ ១៨, ៣៤-៣៥, ៣៧។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ព្យាយាមផ្តល់ការគាំទ្រ ប៉ុន្តែពឹងផ្អែកទៅលើ យូ វ៉ាន់ ដែលបានផ្តល់ភស្តុតាងចចាមអារាម។ ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ. ៤៩, ឆ. ៥៥, ឆ. ១០៦។

[318] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៥ ជើងទំព័រ ៧៤២ (ដើម្បីគាំទ្រដល់ការសម្រេចរបស់គាត់ដែលថា ង៉ូវ បានធ្វើដំណើរញឹកញាប់ទៅរាយការណ៍ជូន អោ អាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកស្រង់សាក្សីពីររូបគឺ សាត ភាព និង សូ សារ៉េន ដែលមិនបានផ្តល់ព័ត៌មានលម្អិត អំពីចំនួន រយៈពេល និងមូលហេតុដែលធ្វើដំណើរ ឬអ្វីដែលបានរាយការណ៍នៅពេលធ្វើដំណើរទៅដល់នោះ)។

[319] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៥ ជើងទំព័រ ៧៤១ កថាខណ្ឌ ៣៩៦ ជើងទំព័រ ១១៧៨ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទាំងស្រុងទៅលើព័ត៌មានមិនអាចជឿជាក់បាន គ្មានការគាំទ្ររបស់ ញ៉ែម ចេន)។

[320] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៧ ជើងទំព័រ ៦៤០ កថាខណ្ឌ ២៨៥ ជើងទំព័រ ៧៤១ -៧៤២ កថាខណ្ឌ ៣៩៦ ជើងទំព័រ ១១៧៨។

135. ចុងក្រោយ ពាក់ព័ន្ធនឹងការណ៍ដែល អោ អាន អនុញ្ញាតឲ្យឡានដឹកអ្នកទោសពីមន្ទីរសន្តិសុខមួយទៅមន្ទីរសន្តិសុខមួយទៀតនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកទៅលើសក្ខីកម្មរបស់ ញ៉ែម ចេន ដោយគ្មានការបញ្ជាក់បន្ថែមដែលមិនគួរឲ្យជឿជាក់បាន[321] និងការសន្និដ្ឋានពីផ្សេងៗទៀត[322]។ ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានបង្ហាញស្របតាមបទដ្ឋានតម្រូវថា អោ អាន បានគ្រប់គ្រងមន្ទីរសន្តិសុខតំបន់ ៤១ ឬមានសិទ្ធិអំណាចលើបញ្ហាសន្តិសុខនោះឡើយ។

<u>ឃ) អោ អាន ពុំមានសិទ្ធិអំណាចលើយោធាតំបន់ ៤១ ឡើយ</u>

136. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សន្និដ្ឋានដោយភាន់ច្រឡំថា អោ អាន "បានប្រើសិទ្ធិអំណាចពេញលេញខាងស៊ីវិល និងយោធាទៅលើតំបន់"[323]។ ដើម្បីបង្ហាញអំពីសិទ្ធិអំណាចខាងយោធារបស់ អោ អាន តាមការសន្មតនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកជាចម្បងលើសាក្សីចំនួនបួននាក់[324] ដែលមិនបានផ្តល់នូវព័ត៌មានលម្អិតណាមួយឡើយអំពីតួនាទីរបស់ អោ អាន នៅក្នុងផ្នែកយោធាតំបន់[325] ហើយដែលមិនបានបញ្ជាក់សូម្បីតែអំពី អោ អាន នៅក្នុងចម្លើយរបស់ពួក

---

[321] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧៩ ជើងទំព័រ ៧៣១-៧៣២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកតែទៅលើ ញ៉ែម ចេន ដែលមិនអាចជឿជាក់បាន ហើយដឹកមុខដោយអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស)។

[322] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៨ ជើងទំព័រ ៧៤៨-៧៤៩ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ ពេញ វ៉ា ដែលបញ្ជាក់ថា "ពួកគេ" ដឹកមនុស្សទៅមន្ទីរសមមិត្តសុប ហើយទាយស្មានថាបញ្ជាគឺប្រាកដជាចេញពី អោ អាន, ឃុត ឃី ដែលបញ្ជាក់ថា អោ អាន បានចូលទៅក្នុងយានដ្ឋាន ហើយឲ្យគាត់ជួសជុលឡាន ប៉ុន្តែមិនបាននិយាយអំពីសិទ្ធិអំណាចរបស់ អោ អាន ក្នុងការដឹកជញ្ជូនអ្នកទោសទេ, តូច មៀច ដែលបញ្ជាក់ថាឡានហ្សីមដែលជារបស់មន្ទីរតំបន់ ត្រូវបានប្រើប្រាស់ដើម្បីដឹកអ្នកដែលត្រូវបានចាប់ខ្លួន ប៉ុន្តែមិនបានបញ្ជាក់អំពីសិទ្ធិអំណាចរបស់ អោ អាន ទេ, សាត ភាព ដែលបញ្ជាក់ថាបានឃើញរថយន្តរបស់ អួន ប៉ុន្តែមិនបានលើកឡើងអំពីសិទ្ធិអំណាចដែលបានចោទប្រកាន់របស់ អោ អាន)។

[323] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦, ២៥៨។

[324] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤២-៦៤៩ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើ យូ វ៉ាន់ សូ សារ៉េន និង ញ៉ែម ចេន)។

[325] ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៩៨ (យូ វ៉ាន់ បានផ្តល់ភស្តុតាងចចាមអារាម នៅពេលដែលគាត់បញ្ជាក់ថា គាត់បានឮយោធាតំបន់និយាយអំពីបញ្ហារបស់ អោ អាន ប្រាប់យោធាស្រុក)។ ឯកសារ **D219/435** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ទូច ចំរើន) ឆ. ១៩៧, ឆ.២០០ -ឆ.២០២ (ទូច ចំរើន បានបញ្ជាក់ថា អោ អាន ទទួលខុសត្រូវលើកងទ័ពតំបន់ ប៉ុន្តែមិនបានប្រាប់អំពីមូលដ្ឋាននៃការដឹកឮនេះទេ)។

គាត់[326] និងដែលបានផ្តល់នូវភស្តុតាងគ្មានការបញ្ជាក់បន្ថែម ឬភស្តុតាងបំប្លែង (ពន្យល់នៅខាងក្រោម)។ នៅពេលពិនិត្យឲ្យហ្មត់ចត់ទៅលើខ្លឹមសារភស្តុតាង វាបង្ហាញឲ្យឃើញច្បាស់ថា ការសន្និដ្ឋានរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្អែកទៅលើ ភស្តុតាងសំខាន់ និងភស្តុតាងបញ្ជាក់បន្ថែមគ្រប់គ្រាន់ឡើយ។

137. ជាដំបូង សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា យោធាស្រុករួមមាន ប្រាក់ នី ក៏រាយការណ៍ទៅ អោ អាន ផងដែរ តាមរយៈយោធាតំបន់ ដោយផ្ទាល់មាត់ឬក៏តាមលិខិត អំពីអ្នកដែលត្រូវបានសម្លាប់[327] ហើយថា អោ អាន ទទួលរបាយការណ៍ពីយោធាតំបន់[328]។ ទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់ ដើម្បីកំណត់អំពីរចនាសម្ព័ន្ធបញ្ជាយោធា នៅថ្នាក់ស្រុកឬថ្នាក់តំបន់ឡើយ[329] ហើយដើម្បីគាំទ្រដល់ការសម្រេចរបស់គាត់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែក ទៅលើភស្តុតាងចចាមអារាម មិនអាចជឿជាក់

---

[326] ឯកសារ **D118/259** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ពេជ្រ ជឹម) ឆ.១១២ (ពេជ្រ ជឹម បានបញ្ជាក់ថាយោធាតំបន់ រាយការណ៍ទៅលេខតំបន់ ដោយមិនមាននិយាយអំពីឈ្មោះ អោ អាន)។ ឯកសារ **D219/442** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ជុំ វង្ស) ឆ.១១៥, ឆ.១២៥-ឆ.១២៦, ឆ.១៣៨ (ង៉ូវ មិនបានដឹងថានរណាដែលទទួលខុសត្រូវលើយោធាទេ។ គាត់បានឃើញ សុក ចេញបញ្ជាទៅកងទ័ព ហើយដោយសារតែមិនមាននរណាម្នាក់ ទទួលខុសត្រូវលើកងទ័ពនៅពេលវៀតណាមមកដល់ ទើបសុក ទទួលខុសត្រូវលើកងទ័ព)។ ឯកសារ **D219/837** (កំណត់ហេតុស្តាប់ចម្លើយសាក្សី សូ សារ៉េន) ឆ.៣៧-ឆ.៣៨ (សូ សារ៉េន បញ្ជាក់ថា ហ៊ុំ ទទួលខុសត្រូវលើកងទ័ពតំបន់៤១ ហើយបន្ទាប់មកគឺបងទ្រី។ គាត់មិនបានដឹងថាប្រធានកងទ័ព ត្រូវរាយការណ៍ទៅនរណាឡើយ។ មិនមានការនិយាយអំពី អោ អាន ទេ)។ ឯកសារ **D219/731** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន) ឆ.១៤ (ញ៉ែម ចេន បានបញ្ជាក់ថា ហ៊ុំ គឺជាប្រធានយោធា)។ ឯកសារ **D219/870** (កំណត់ហេតុស្តាប់ចម្លើយសាក្សី វី ញ៉) ឆ.៤៩, ឆ.៨១ (វី ញ៉ បញ្ជាក់ថាលេខាតំបន់ ទទួលខុសត្រូវលើយោធាតំបន់ ប៉ុន្តែគាត់ទទួលស្គាល់ថា គាត់មិនដឹងអំពីរចនាសម្ព័ន្ធតំបន់ទេ ហើយក្រោយមកគាត់បញ្ជាក់ថា សុក គឺជាប្រធានយោធា)។

[327] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤៣១។

[328] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨។

[329] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩០, ៥៦២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា ឈឿន (ឃួន ប៉េង) គឺជាប្រធានមន្ទីរភស្តុភារយោធាតំបន់៤១ ហើយ សុខ និង ហាម គឺជាប្រធានយោធាតំបន់៤១ នៅពេលវេលាផ្សេងគ្នា។ មិនមានការផ្តល់នូវព័ត៌មានលម្អិតអំពីមុខងារ របស់យោធាតំបន់ ទីតាំងរបស់មូលដ្ឋានយោធាតំបន់ និងប្រព័ន្ធរបាយការណ៍រវាងថ្នាក់លើនិងថ្នាក់ក្រោម។ ជាឧទាហរណ៍នៅពេលដែលយោធាមកពីតំបន់៤១ ត្រូវបានបញ្ជូនទៅប្រយុទ្ធជាមួយវៀតណាមនៅព្រំដែនថៃ គឺមិនមានភស្តុតាងអំពី អោ អាន ជួយសម្របសម្រួលដល់ប្រតិបត្តិការនេះជាមួយ កែ ពក ឡើយ)។

បាន និងមិនមានអ្វីគាំទ្ររបស់ យូ វ៉ាន់[330] និងព័ត៌មានដទៃទៀតផ្អែកលើ ពាក្យចចាមអារាមឬការទាយស្មាន[331]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏មិនបានពិចារណាអំពីភស្តុតាង ដែលចង្អុលបង្ហាញថា កម្មាភិបាលយោធាមិនបានរាយការណ៍ តាមរយៈច្រកធម្មតានៅភូមិភាគកណ្តាលឡើយ[332]។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបញ្ជាក់ថា អោ អាន បានប្រជុំជាមួយយោធាតំបន់ ដើម្បីពិភាក្សាអំពីបញ្ហាសន្តិសុខនិងការការពារ ដូចជាការប្រជុំនៅវត្តតាមាក់ជាដើម[333]។ ប៉ុន្តែការវិភាគបែបលម្អិតមួយទៅលើភស្តុតាងនេះបានបង្ហាញថា មិនមានសាក្សីដែលបានដកស្រង់ណាម្នាក់ ក្រៅពីសាក្សី ញ៉ែម ចេន[334] ដែលជាសាក្សីមិនអាចជឿជាក់បាន បាន

---

[330] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤៣១ ជើងទំព័រ ១៣៣៧ (ដកស្រង់ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.១០៦ (អ្នកស៊ើបអង្កេតរបស់ ក.ស.ចៃ.ស មិនបានសួរសំណួរបន្តអំពីភាពញឹកញាប់ នៃប្រព័ន្ធរបាយការណ៍នេះ ឬនរណាម្នាក់មកពីយោធាស្រុកឬតំបន់ ត្រូវរាយការណ៍ទៅ អោ អាន)។

[331] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤៤ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើ ង៉ូវ ដែលបញ្ជាក់ថា គាត់មិនដែលឃើញរបាយការណ៍មកពីយោធា ហើយមិនបានដឹងថាតើយោធា រាយការណ៍ដោយរបៀបណាទៅ អោ អាន ទេ។ ង៉ូវ សន្មតថារបាយការណ៍មានជាលាយលក្ខណ៍អក្សរនិងផ្ទាល់មាត់។ ឯកសារ **D219/442** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ជុំ វង្ស) ឆ.១១៨, ឆ.១២០។ បន្ថែមលើនេះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ យូ វ៉ាន់ ដែលបានស្តាប់ឮពី នី ថា គាត់បានរាយការណ៍ទៅ អោ អាន ដោយផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ អំពីការសម្លាប់តាមរយៈយោធាតំបន់។ ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.១០៦-ឆ.១០៧)។

[332] ឯកសារ **D219/774** (កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ុំ សេង) ឆ.២២, ឆ.២៥-ឆ.៣០, ឆ.៥៣-ឆ.៥៥, ឆ.៥៨, ឆ.៦១-ឆ.៦៣, ឆ.៦៥, ឆ.៧៥-ឆ.៧៨, ឆ.១០៧, ឆ.១៣២-ឆ.១៣៣, ឆ.១៣៦-ឆ.១៣៨, ឆ.១៤០ (អ៊ុំ សេង ដែលជាមេបញ្ជាការកងវរសេនាធំ នៅក្នុងភូមិភាគកណ្តាល បានបញ្ជាក់ថា គាត់រាយការណ៍ផ្ទាល់ទៅ កែ ពក។ គាត់ជួបជាមួយ កែ ពក ប្រហែលម្តងក្នុងមួយខែ ហើយពេលខ្លះពីរខែម្តង ដើម្បីទទួលការណែនាំ។ អ៊ុំ សេង មិនបានបញ្ជាក់ថា អោ អាន មានវត្តមាននៅក្នុងការជួបទាំងអស់នោះទេ ឬថាគាត់រាយការណ៍ទៅ អោ អាន ឡើយ។ តាមពិតទៅគាត់បានទទួលស្គាល់ថា គាត់ស្គាល់ អោ អាន មិនទាំងច្បាស់ផង ហើយមិនដឹងច្បាស់ពីតួនាទីរបស់ អោ អាន នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យទេ។ គាត់គ្រាន់តែឮថា អោ អាន ជា "គណៈ")។ ឯកសារ **D6.1.726** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ឃុន គីម) ឆ. ២, ឆ.៨, ឆ.១៣ (ឃុន គីម ដែលជាមេបញ្ជាការកងវរសេនាធំនៃកងពលធំ២៣០ បានបញ្ជាក់ថា គាត់រាយការណ៍ទៅ យឿន និងមេបញ្ជាការកងពលធំ ប៉ុន្តែគាត់មិនបានរាយការណ៍ទៅមេដឹកនាំជាន់ខ្ពស់ណាឡើយ ហើយក៏មិនបានដឹងអំពីការរាយការណ៍ទៅមជ្ឈិមដែរ)។

[333] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨, ៥៨៩។

[334] ឯកសារ **D219/855** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន) ឆ.៩៣, ឆ.១០៣។

បញ្ជាក់ថា អោ អាន បានដឹកនាំការប្រជុំជាមួយយោធាតំបន់[335]។ គឺមិនមានភ័ស្តុតាងច្បាស់លាស់ និងមានការគាំទ្រណាមួយ សម្រាប់ការសម្រេចថាយោធាស្រុក និងយោធាតំបន់ បានរាយការណ៍ទៅ អោ អាន ឡើយ។

138. ទីពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា អោ អាន បញ្ជាឲ្យចាប់ខ្លួន និងសម្លាប់ឈ្មោះ ហម ប្រធានយោធាតំបន់ ៤១ ដោយសារតែគាត់មានទំនាក់ទំនងផ្លូវភេទ ជាមួយប្អូនថ្លៃរបស់ អោ អាន[336]។ ទោះជាយ៉ាងនេះក្តី ភ័ស្តុតាងគាំទ្រគឺគ្រាន់តែជាការទាយស្មានប៉ុណ្ណោះ[337] ហើយមិនមានព័ត៌មានលម្អិតគួរឲ្យជឿជាក់ អំពីកាលៈទេសៈដែលមានការចាប់ខ្លួន និងការសម្លាប់នោះឡើយ[338]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានសន្និដ្ឋានផងដែរថា អោ អាន បានតែងតាំងដោយផ្ទាល់នូវឈ្មោះ សុខ ជំនួយឈ្មោះ ហម ជាប្រធានយោធាតំបន់៤១[339]។ ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកចេញនូវព័ត៌មានសំខាន់ៗដូចជា កាលបរិច្ឆេទឬទីតាំងនៃការតែងតាំង ហើយពឹងផ្អែកតែទៅលើភ័ស្តុតាងដែលប្រឡាក់ប្រឡូស ហើយមិនអាចជឿជាក់បាន

---

[335] ឯកសារ **D219/800** (កំណត់ហេតុស្តាប់ចម្លើយសាក្សី សូ សារ៉េន) ឆ.២១៧-ឆ.២១៨។ ឯកសារ **D219/442** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ជុំ វង្ស) ឆ.១០០-ឆ.១០៣, ឆ.១២៦, ឆ.១២៨, ឆ.១៣០។ ឯកសារ **D219/837** (កំណត់ហេតុស្តាប់ចម្លើយសាក្សី សូ សារ៉េន) ឆ.២៤-ឆ.២៩, ឆ.៣៣។ ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៤៩, ឆ.៩៦។

[336] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៦។

[337] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៨២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើការទាយស្មានរបស់ សូ សារ៉េន ដែលមិនបានដឹងថានរណាជាអ្នកបញ្ជា ឲ្យចាប់ខ្លួន ហ៊ុំ តែបែរជាសន្មតថាគឺជា អោ អាន ទៅវិញ ហើយនិង ញ៉ែម ចេន ដែលបញ្ជាក់ថា ហ៊ុំ ត្រូវបានចាប់ខ្លួន ប៉ុន្តែមិនបានលើកឡើងពីការសម្លាប់ ឬពីនរណាជាអ្នកបញ្ជាឲ្យចាប់ខ្លួនឡើយ)។

[338] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៨២ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើ យូ វ៉ាន់ ដែលបញ្ជាក់ថា អោ អាន ចាប់ខ្លួន ហ៊ុំ ហើយឲ្យគេសម្លាប់ ហ៊ុំ ព្រោះតែគាត់ខុសសីលធម៌ជាមួយនារីពេទ្យ។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានសួរសំណួរបន្តរ អំពីប្រភពនៃភស្តុតាងនេះ អំពីទម្រង់នៃការបញ្ជា (ផ្ទាល់មាត់ឬជាលាយលក្ខណ៍អក្សរ) និងអំពីទីតាំងនៃការចាប់ខ្លួននិងសម្លាប់។ បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ ញ៉ែម ចេន ដែលបញ្ជាក់ថា អោ អាន បញ្ជាឲ្យចាប់ខ្លួន ហ៊ុំ ព្រោះគាត់ប្រព្រឹត្តខុសសីលធម៌។ អ្នកស៊ើបអង្កេតរបស់ ក.ស.ច .ស មិនបានសួរសំណួរបន្តរដើម្បីកំណត់ អំពីប្រភពនៃភស្តុតាងនេះ ឬកំណត់អំពីកាលបរិច្ឆេទ និងទីតាំងនៃការចាប់ខ្លួន)។

[339] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨។

របស់ ញ៉ែម ចេន និងភ័ស្តុតាងចចាមអារាមរបស់ សាត ភាព ប៉ុណ្ណោះ[340]។

139. ទីបី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសម្រេចថា អោ អាន បញ្ជាដល់កងយោធាតំបន់ ៤១ ឲ្យពង្រាយឬបញ្ជូនកងទ័ពទៅក្រៅតំបន់៤១[341]។ ប៉ុន្តែមិនមានសាក្សីឬភ័ស្តុតាងណាមួយដែលបញ្ជាក់ថា អោ អាន បានចេញបញ្ជាទាំងអស់នេះទេ[342]។ ចំណែក ញ៉ែម ចេន បានអះអាងថាបញ្ជាបែបនេះ គឺចេញមកពីមជ្ឈឹមនិងភូមិភាគ[343]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានសម្រេចផងដែរថា អោ អាន បានបញ្ជាដល់កងទ័ពតំបន់ ឲ្យដឹកជញ្ជូនអ្នកទោសទៅ មន្ទីរសន្តិសុខតំបន់៤១ ឬទៅវត្តអូរត្រកួន ដែលនៅទីនោះពួកគេត្រូវបានសម្លាប់ចោល[344] ប៉ុន្តែសហចៅក្រមស៊ើបអង្កេតអន្តរជាតិពឹងផ្អែក តែទៅលើសាក្សីពីរនាក់ដែលផ្តល់ភ័ស្តុតាងចចាមអារាម និងមិនអាចជឿជាក់

---

[340] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤៣ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើ ញ៉ែម ចេន និង សាត ភាព។ ញ៉ែម ចេន បញ្ជាក់ថា អោ ងាន ចាត់តាំង សុខ ជាមេបញ្ជាការតំបន់ ប៉ុន្តែគាត់ឆ្លើយបែបនេះ ក្រោយពេលដែលអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស បានផ្តល់នូវព័ត៌មាននេះទៅគាត់ប៉ុណ្ណោះ។ ឯកសារ **D219/855** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន) ឆ.២៥០, ឆ.២៧០-ឆ២៧២។ សាត ភាព បញ្ជាក់ថាគាត់បានដឹងពីមិត្តភក្តិម្នាក់ថា សុខ គឺជាប្រធានយោធាតំបន់ ហើយធ្វើការក្រោមការដឹកនាំរបស់លេខា ប៉ុន្តែគាត់មិនបានលើកឡើងថានរណាជាអ្នកតែងតាំងសុខទេ។ ឯកសារ **D219/504** (កំណត់ហេតុស្តាប់ចម្លើយសាក្សី សាត ភាព) ឆ.៤១, ឆ.៥៣។

[341] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨។

[342] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤៥ (ដកស្រង់ ឯកសារ **D219/855** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន) ឆ.៩៣-ឆ.៩៨, ឆ.១០០-ឆ.១០៤ ឆ.១១៦-ឆ.១១៧ ។ ឯកសារ **D219/800** ((កំណត់ហេតុស្តាប់ចម្លើយសាក្សី សូ សារ៉េន) ឆ.២១៧-ឆ.២១៨ ។ ឯកសារ **D219/731** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន) ឆ.៩៧។ ឯកសារ **D219/442** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ជុំ វង្ស) ឆ.១០១-ឆ.១០៤, ឆ.១២៦, ឆ.១២៨, ឆ.១៣០។ ឯកសារ **D219/837** (កំណត់ហេតុស្តាប់ចម្លើយសាក្សី សូ សារ៉េន) ឆ.២៤-ឆ.២៥ ឆ.២៧, ឆ.២៨-ឆ.២៩, ឆ.៣៣។ ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៤៩, ឆ.៥៤, ឆ.៥៦, ឆ.៩៦) កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤៦ (ដកស្រង់ ឯកសារ **D219/855** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន) ឆ.១១៦-ឆ.១២២, ឆ.២៤៦។ ឯកសារ **D117/10** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ឃឹម ជឿង) ឆ.២៤។ ឯកសារ **D219/294** (កំណត់ហេតុស្តាប់ចម្លើយសាក្សី មូល អេង) ឆ .១៨២-ឆ.១៨៤ ។ ឯកសារ **D1.3.13.1** (ទូរលេខ ៣២៖ ជំរាបមកគណៈ៨៧០ ជាទីនឹករលឹក) ភាសាខ្មែរ 00020977 ទំព័រ ១)។

[343] ឯកសារ **D219/855** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន) ឆ.៩៨, ឆ.១១៦ (ញ៉ែម ចេន បានបញ្ជាក់ថា មជ្ឈឹមឬភូមិភាគចេញបញ្ជាដំបូងឲ្យចល័តទ័ព ទៅតាមបណ្តោយព្រំដែន ហើយនៅពេលដែលមានសំណើពីមជ្ឈឹម កងទ័ពត្រូវបញ្ជូនទៅការពារស្រុកនិងសហជីពនៅ អណ្តូងក្រឡឹង និងចំការកប្បាសនៅស្រុកចំការលើ)។

[344] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៩៤ ជើងទំព័រ ៧៧១។

បាន[345]។ លើសពីនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការសន្និដ្ឋានថា អោ អាន បញ្ជាដល់កងទ័ពឲ្យដឹកជញ្ជូនមនុស្ស នៅវត្តភ្នំប្រុសនិងកម្ទេចពួកគេ[346] ដោយពឹងផ្អែកតែទៅលើភ័ស្តុតាងលម្អៀង មិនមានការគាំទ្ររបស់ កែ ពេជ្យវណ្ណៈ តែប៉ុណ្ណោះ[347]។ ប្រហែលគ្នានេះ ដោយគ្រាន់តែពឹងផ្អែកទៅលើព័តមានតែមួយ ដែលមិនមានការគាំទ្រសោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចដោយខុសឆ្គងថា កងយោធាតំបន់ត្រូវបានពង្រាយ ឲ្យទៅបំពេញការងារសាងសង់ និងកសិកម្មទៅវិញ[348]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានដកស្រាយសាក្សីដែលមិនអាចជឿជាក់បាន ដែលផ្តល់ភ័ស្តុតាងមិនគ្រប់គ្រាន ដើម្បីសម្រេចថា អោ អាន បានបញ្ជាដល់កងទ័ពតំបន់ ឲ្យចាប់ខ្លួនជនជាតិចាម អតីតអ្នករដ្ឋការនិងយោធា លន់ នល់ ប្រជាជនវៀតណាម និង "សមាសភាពមិនល្អ" ដទៃទៀត នៅក្នុងស្រុកកំពង់សៀម[349]។

140. ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចដោយខុសឆ្គងថា សុខ ដែលជា

---

[345] ឯកសារ **D219/732** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ញ៉ែម ចេន) ឆ.២៣ - ឆ.២៦, ឆ.៣៥, ឆ.៥០ (ក្រៅពីជាសាក្សីដែលមិនអាចជឿជាក់បានហើយ ញ៉ែម ចេន បានបញ្ជាក់ថា អោ អាន បានបញ្ជាយោធាឲ្យប្រាប់ដល់សន្តិសុខ ឲ្យសម្លាប់អ្នកទោសប្រមាណ៤០នាក់ នៅមន្ទីរសន្តិសុខគរ ប៉ុន្តែអ្នកស៊ើបអង្កេតរបស់ ក.ស.ច.ស មិនបានសួរសំណួរបន្តរ អំពីមូលដ្ឋាននៃការដឹងឮអំពីទម្រង់ និងមធ្យោបាយនៃការផ្សព្វផ្សាយបញ្ជាឡើយ)។ ឯកសារ **D219/582** (កំណត់ហេតុស្តាប់ចម្លើយសាក្សី តុយ មាជ ) ឆ.១០០-ឆ.១០១ (តុយ មាជ បានផ្តល់ភស្តុតាងចចាមអារាម នៅពេលដែលគាត់បញ្ជាក់ថាគាត់បានឮ បញ្ជារបស់ អោ អាន ឲ្យបញ្ជូនមនុស្សទៅវត្តអូរត្រកួន)។

[346] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០០។

[347] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០០ ជើងទំព័រ ៧៩៩ (ពឹងផ្អែកលើព័ត៍មានគ្មានការគាំទ្ររបស់ កែពេជ្រ វណ្ណៈ)។

[348] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៨ ជើងទំព័រ ៦៤៩ (ពឹងផ្អែកទៅលើព័ត៍មានគ្មានការគាំទ្ររបស់ ង៉ូវ)។

[349] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១១ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកលើ ប្រាក់ យុត និង យូ វ៉ាន់។ **<u>យូ វ៉ាន់</u>**៖ យូ វ៉ាន់ បានបញ្ជាក់ថា ផុន ទទួលខុសត្រូវលើយោធាស្រុក ហើយអនុប្រធានរបស់គាត់ឈ្មោះ ផែន ប៉ុន្តែគាត់មិនបាននិយាយអំពីយោធាតំបន់ ឬអ្នកណាបញ្ជាឲ្យចាប់ខ្លួនទេ។ ឯកសារ **D219/702.1.87** (ប្រតិចារឹក យូ វ៉ាន់) ភាសាអង់គ្លេស 01438494-96, 01438508-09, 01438512 ទំព័រ ៥៣-៥៥, ៦៧-៦៨, ៧១។ ឯកសារ **D117/31** ((កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៣២, ឆ.៣៥។ ឯកសារ **D219/702.1.94** (ប្រតិចារឹក យូ វ៉ាន់) ភាសាអង់គ្លេស 01431628 ទំព័រ ៤២។ **<u>ប្រាក់ យុត</u>**៖ ប្រាក់ យុត មិនបានពិភាក្សាអំពីបញ្ជារបស់ អោ អាន ទៅកាន់យោធាតំបន់ទេ។ ឯកសារ **D219/120** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.១៧, ឆ.២៨។ ឯកសារ **D117/71** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.៥០ ។ ឯកសារ **D117/73** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.៥, ឆ.៧, ឆ.១០។ ឯកសារ **D219/702.1.94** (ប្រតិចារឹក ប្រាក់ យុត) ភាសាអង់គ្លេស 01431666-67 ទំព័រ ៨០-៨១)។

ប្រធានយោធាតំបន់ គឺជាដៃស្តាំរបស់ អោ អាន[350]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គាំទ្រការសម្រេចនេះដោយព័តមាន ដែលមិនមានការគាំទ្ររបស់ឈ្មោះ សូ សារ៉េន[351]។ ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានកំណត់នូវបទដ្ឋានតាមការតម្រូវថា អោ អាន បានប្រើប្រាស់សិទ្ធិអំណាចទៅលើ យោធាតំបន់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

*ង) អោ អាន មិនមានសិទ្ធិអំណាចទៅលើ ធនធានភស្តុតាងនិងដឹកជញ្ជូន ឬការផ្លាស់ទីមនុស្ស នៅក្នុងតំបន់៤១ទេ*

141. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភស្តុតាងដែលមានការគាំទ្រ និងច្បាស់លាស់គ្រប់គ្រាន់ថា អោ អាន៖ (ក) គ្រប់គ្រងលើកចលនាបុគ្គល និងគ្រឿងផ្គត់ផ្គង់ (ខ) សម្របសម្រួលរចនាសម្ព័ន្ធភស្តុភារ និងអនុញ្ញាតដល់យានយន្តក្នុងការដឹកជញ្ជូនអ្នកទោស ពីមន្ទីរសន្តិសុខមួយទៅមន្ទីរសន្តិសុខមួយទៀត (គ) ត្រួតពិនិត្យមើលលើការដឹកជញ្ជូន ប្រជាជនភូមិភាគបូព៌ាទៅតំបន់៤១ និង (ឃ) បានសិទ្ធិអំណាចចេញលិខិតអនុញ្ញាតធ្វើដំណើរផ្លូវការ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចដោយខុសឆ្គងថា អោ អាន "គ្រប់គ្រងចលនាបុគ្គលិក និងគ្រឿងផ្គត់ផ្គង់នៅទូទាំងតំបន់"[352]។ ដើម្បីគាំទ្រដល់ការសម្រេចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើភស្តុតាងដែលផ្ទុយ[353] ផ្អែកលើពាក្យចចាមអារាម[354] ឬមិនត្រឹមត្រូវ[355]។ ប្រហែលគ្នានេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្ហាញដោយខុសឆ្គងជាថ្មីម្តងទៀតនូវភស្តុតាង ឬមិនបានគិត

[350] *ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* កថាខណ្ឌ ៥៦២។

[351] *ដីកាដំណោះស្រាយរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* កថាខណ្ឌ ៥៦២ ជើងទំព័រ ១៨៩៩ (ពឹងផ្អែកទាំងស្រុងទៅលើព័ត៌មាន ដែលមិនមានការគាំទ្ររបស់ សូ សារ៉េន)។

[352] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦ ជើងទំព័រ ៦៣៦។

[353] *ប្រៀបធៀប* ឯកសារ **D179/1.2.4** (ប្រតិចារឹកសំណុំរឿង ០០២ ប្រាក់ យុត) ភាសាអង់គ្លេស 00774126-27 ទំព័រ ៩៤-៩៥ (ប្រាក់ យុត បានបញ្ជាក់ថាទំនប់ត្រូវបានសាងសង់ នៅក្នុងស្រុកព្រៃឈរ) *ជាមួយ*ឯកសារ **D219/120** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.៨៨-ឆ.៨៩ (ប្រាក់ យុត បញ្ជាក់ថា អោ អាន មិនដែលសាកសួរអំពីកម្លាំងពលកម្ម នៅទំនប់អន្លង់ជ្រៃឡើយ ហើយថាគាត់មិនចាំពីការកសាងទំនប់តំបន់៤១ នៅក្នុងស្រុកព្រៃឈរឡើយ)។

[354] ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៧៤ (យូ វ៉ាន់ បានផ្តល់នូវព័ត៌មានចចាមអារាមពី ប្រាក់ យុត)។

[355] ឯកសារ **D179/1.2.4** (ប្រតិចារឹកសំណុំរឿង ០០២ របស់ប្រាក់ យុត) ភាសាអង់គ្លេស 00774128 ទំព័រ ៩៥។ ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៧០។

អំពីភ័ស្តុតាងដែលផ្ទុយ នៅពេលលើកឡើងថា អោ អាន ដើរតួនាទីយ៉ាងសំខាន់ ក្នុងការសម្របសម្រួលដល់ការបញ្ជូន បុគ្គលិកនិងគ្រឿងផ្គត់ផ្គង់[356]។

142. ទីពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសក្នុងការសម្រេចថា អោ អាន សម្របសម្រួលដល់រចនាសម្ព័ន្ធភស្តុភារ ដើម្បីដឹកជញ្ជូនអ្នកទោស ពីមន្ទីរសន្តិសុខមួយទៅមន្ទីរសន្តិសុខមួយទៀត[357] ហើយអនុញ្ញាតិឲ្យប្រើប្រាស់ យានយន្តរបស់តំបន់៤១សម្រាប់ការងារទាំងនេះ[358]។ ដូចដែលបានពន្យល់នៅក្នុងផ្នែក II(ង)(v)(គ) ភ័ស្តុតាងដែលបានប្រើប្រាស់ គឺត្រូវបានដកស្រង់ដោយមិនត្រឹមត្រូវ មិនមានការគាំទ្រ មិនស៊ីសង្វាក់គ្នា ឬជាការទាយស្មានសុទ្ធសាធ។ បន្ថែមលើនេះ ក្នុងការសម្រេចថាយានយន្តសម្រាប់ ដឹកជញ្ជូនអ្នកទោស គឺដូចគ្នាទៅនឹងយានយន្តដែល អោ អាន បើកបរទៅប្រជុំនោះ[359] គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាដល់ភ័ស្តុតាងដែលផ្ទុយឡើយ[360] ហើយពឹងផ្អែកទៅលើភ័ស្តុតាងដែលមិនស៊ីសង្វាក់គ្នា[361] ជាការទាយ

---

[356] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧២ ជើងទំព័រ ៧០៤ (សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបង្ហាញដោយមិនត្រឹមត្រូវនូវភស្តុតាងរបស់ ទូច ចំរើន, សាត ភាព, គឹម គឿន, ខេងថៃ, យូ វ៉ាន់ និង ពេញ វ៉ា។ ទូច ចំរើន គ្រាន់តែបញ្ជាក់ថា អោ អាន ទទួលរបាយការណ៍អំពីបរិមាណស្រូវ/អង្ករ ដែលត្រូវចែកចាយទៅតាមក្រសួង។ សាត ភាព បញ្ជាក់ថា គាត់មិនបានពិភាក្សាអំពីភស្តុភារជាមួយ អោ អាន ទេ ហើយបន្ទាប់មកគាត់នឹកឃើញថា បានស្នើសុំពូជស្រូវ ហើយលេខាស្រុកត្រូវទាក់ទងផ្ទាល់ទៅមន្ទីរតំបន់។ គឹម គឿន បានរំឭកថាបានកត់ត្រា សម្ភារៈផ្គត់ផ្គង់នៅឃ្លាំងតំបន់ ហើយបានរាយការណ៍ត្រឡប់ទៅ អ៊ួន។ គាត់មិនបាននិយាយអំពី អោ អាន លើបញ្ហានេះឡើយ។ គាត់គ្រាន់តែលើកឡើងថា គាត់បានឮពីឈ្មោះ អោ អាន ក្នុងពេលឆ្លើយតបទៅនឹងសំណួរនាំមុខ។ ខេងថៃបានរំឭកថា អ៊ួន ដាក់បញ្ហាដែលទទួលបានពីថ្នាក់តំបន់ ទៅឲ្យថ្នាក់ស្រុក ទាក់ទងសម្ភារៈផ្គត់ផ្គង់។ យូ វ៉ាន់ បានលើកឡើងពីមេភូមិ ដែលត្រូវតែចេញលិខិតអនុញ្ញាតធ្វើដំណើរ ប៉ុន្តែមិនបានលើកឡើងពី អោ អាន ឡើយ។ ជាចុងក្រោយ ពេញ វ៉ា បានលើកឡើងពីកម្មករដែលត្រូវសុំការអនុញ្ញាត ពីប្រធានកងដើម្បីទៅហូបបបរ នៅសហករណ៍ផ្សេងទៀត)។

[357] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៨ ជើងទំព័រ ៧៤៨។

[358] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៨ ជើងទំព័រ ៧៤៩។

[359] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៨៨ ជើងទំព័រ ៧៥១។

[360] ឯកសារ **D219/686** (កំណត់ហេតុស្តាប់ចម្លើយ ឃុត ឃី) ឆ.១៣០-ឆ.១០៤ (ឃុត ឃី បញ្ជាក់ថា ឡានហ្ស៊ីបរបស់ អោ អាន គឺជាឡានហ្ស៊ីបអាមេរិក ហើយឡាននោះខុសពីឡានហ្ស៊ីបពណ៌ខៀវដែលប្រើប្រាស់ដឹកអ្នកទោស)។

[361] ឯកសារ **D107/7** (កំណត់ហេតុស្តាប់ចម្លើយ ញឹម កុល) KH 00784981 ទំព័រ ៣ (សំដៅលើ "ឡានស៊ីប")។ ឯកសារ **D219/752** (កំណត់ហេតុស្តាប់ចម្លើយ ឡោ វេងហួ) ឆ.៣០, ឆ.៣៨, ឆ.៤៥ (សំដៅលើ អាហ្ស៊ីពអាអង អាខៃ) ឯកសារ **D219/800** (កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន) ឆ.៨៩ (ពណ៌នាអំពីឡានហ្ស៊ីបអាមេរិកពណ៌ស)។

ស្មាន[362] និងជាពាក្យចចាមអារាម[363]។

143. ទីបី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា អោ អាន "ដើរតួនាទីសំខាន់" ក្នុងការជម្លៀសប្រជាជនចាមពី ភូមិភាគបូព៌ាទៅភូមិភាគកណ្ដាល ថា អោ អាន "សម្របសម្រួល និងត្រួតពិនិត្យផ្ទាល់នូវប្រតិបត្តិការ" ដឹកជញ្ជូនមនុស្សពីភូមិភាគបូព៌ា ទៅមន្ទីរសន្តិសុខនៅភូមិភាគកណ្ដាល និងថាធនធានពីតំបន់៤១ ត្រូវបានប្រើប្រាស់ក្នុងដំណើរការនេះ[364]។ គាត់សម្រេចបែបនេះដោយផ្អែកមួយផ្នែកលើ តួនាទីតាមផ្លូវច្បាប់ដែលត្រូវបានចោទប្រកាន់របស់ អោ អាន ជាលេខាតំបន់៤១ និងជាអនុលេខាភូមិភាគ[365] ដែលតួនាទីនេះគឺមេធាវីការពារក្ដី ជំទាស់នៅក្នុងផ្នែក II(ង)(iv) និង(v)។ លើសពីនេះទៅទៀត សាក្សីពីររូបក្នុងចំណោមសាក្សីទាំងបួន ដែលបានដកស្រង់ដើម្បីគាំទ្រដល់ "ការត្រួតពិនិត្យផ្ទាល់របស់ អោ អាន"[366] មិនបាននិយាយយោងដល់ អោ អានទេ[367]។ ភស្តុតាងផ្សេងទៀតគឺជាការទាយស្មាន មិនស៊ីសង្វាក់គ្នា និងជាពាក្យចចាមអារាម[368]។

---

[362] ឯកសារ **D219/315** (កំណត់ហេតុស្តាប់ចម្លើយ សាត ភាព) ឆ.៣០-ឆ.៣៤ (សាត ភាព បញ្ជាក់ថា គាត់បានឃើញ អោ អាន ជិះទៅប្រជុំជារៀងរាល់ថ្ងៃ ប៉ុន្តែ មិនដឹងអំពីការងាររបស់ អោ អាន ទេ។ គាត់ស្មានពីព្រោះថា គាត់គ្រាន់តែបានឃើញ អោ អាន ពីចម្ងាយតែប៉ុណ្ណោះ អោ អាន)។

[363] ឯកសារ **D219/504** (កំណត់ហេតុស្តាប់ចម្លើយ សាត ភាព) ឆ.៨៩, ឆ.៩១ (សាត ភាព ផ្ដល់ភស្តុតាងពាក្យចចាមអារ៉ាមចំនួនពីរ)។ ឯកសារ **D219/802** (កំណត់ហេតុស្តាប់ចម្លើយ ហុង ហេង) ឆ.៥២ (ហុង ហេង មិនដែលបានឃើញទេ ប៉ុន្តែ គ្រាន់តែបានឮពីមនុស្សមិនស្គាល់ឈ្មោះអំពីការដឹកអ្នកទោស)។

[364] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០៩,៦៣៧។

[365] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៧។

[366] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០៩ ជើងទំព័រ ៨២៨ (ស.ច.ស.អ ពឹងផ្អែកលើ ញ៉ែម ចេន, អ៊ិន គឹមអេង, មួក សេងលី និងសូរ សារ៉េន)។

[367] ឯកសារ **D117/66** (កំណត់ហេតុស្តាប់ចម្លើយ អ៊ិន គឹមអេង) ឆ.៧។ ឯកសារ **D219/502** (កំណត់ហេតុស្តាប់ចម្លើយ មួក សេងលី) ឆ.២៤-ឆ.២៥។

[368] ឯកសារ **D219/800** (កំណត់ហេតុស្តាប់ចម្លើយ សូ សារ៉េន) ឆ.២១៦( សូ សារ៉េន មិនបានដឹងថាតើ អោ អាន បានចេញបញ្ជាដែរឬអត់នោះទេ)។ ឯកសារ **D219/855** (កំណត់ហេតុស្តាប់ចម្លើយ ញ៉ែម ចេន) ឆ.១៤០, ឆ.១៥៩, ឆ.១៦០-ឆ.១៦៤ (ញ៉ែម ចេន មិនបានបញ្ជាក់ថា នរណាជាអ្នកដឹកមនុស្ស ឬនរណាជាប្រភពព័ត៌មានរបស់គាត់ទេ។ គាត់មិនបានឮ អោ អាន និយាយអំពីការបញ្ជូនឡានតំបន់ទៅដឹកមនុស្សពីភូមិភាគបូព៌ាទេ។ គាត់មិនដឹងថាតើនរណាជាអ្នកសម្របសម្រួលការដឹកមនុស្សតាមទន្លេទេ ហើយគាត់បានឮថា ឡានភូមិភាគបានមកដល់ដើម្បីប្រមូលមនុស្ស)។ ឯកសារ **D219/498** (កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា) ឆ.១៦ (ពេញ វ៉ា អាចបានឮពីប្អូនថ្លៃប្រុសរបស់គាត់អំពីការសម្លាប់កម្មាភិបាលភូមិភាគបូព៌ា)។ ឯកសារ

144. ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា អោ អាន ត្រួតពិនិត្យលើការចេញលិខិតអនុញ្ញាតធ្វើដំណើរផ្លូវការ នៅក្នុងតំបន់៤១[369] និងរវាងតំបន់ដទៃទៀត[370]។ ទោះជាយ៉ាងនេះក្តី ភ័ស្តុតាងភាគច្រើនដែលបានផ្តល់ មិនបានបង្ហាញអំពីតួនាទីរបស់ អោ អាន ក្នុងការអនុញ្ញាតឱ្យធ្វើដំណើរឡើយ ប៉ុន្តែបែរជាយោងទៅរកអ្នកដទៃ ដែលទទួលខុសត្រូវក្នុងការធ្វើដំណើរទៅវិញ[371]។ ង៉ូវ ដែលមិនអាចជឿជាក់បាន គឺជាសាក្សីតែមួយរូបគត់ ជាមូលដ្ឋានដល់ការសម្រេចនេះ[372]។ សរុបមក ដោយផ្អែកលើសំអាងហេតុខាងលើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភ័ស្តុតាងដែលមានការគាំទ្រ និងច្បាស់លាស់គ្រប់គ្រាន់ថា អោ អាន រក្សាការគ្រប់គ្រងផ្នែកភស្តុភារ ទៅលើចលនាធនធាននិងបុគ្គលិក នៅក្នុងតំបន់៤១ឡើយ។

<u>ច) បើទោះបីជា អោ អាន ជាលេខាតំបន់ ៤១ ឬមានសិទ្ធិអំណាចនៅកម្រិតតំបន់ ក៏ការនេះមិនមានន័យថាគាត់ស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតដែរ</u>

145. បើទោះបីជា អោ អាន គឺជាលេខាតំបន់ និងមានសិទ្ធិអំណាចនៅក្នុងតំបន់៤១ ក៏គាត់មិនត្រូវបានចាត់ទុកថាស្ថិតក្នុងចំណោម អ្នកដែលទទួលខុសត្រូវខ្ពស់បំផុត ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ដែរ។ តំបន់៤១គឺជាតំបន់ភូមិសាស្ត្រតូច ហើយលេខាតំបន់មានអ្នកនៅក្រោមបង្គាប់ផ្ទាល់តិចតួចប៉ុណ្ណោះ។ លើសពីនេះទៅទៀត នៅពេលពិនិត្យមើលលើបក្សកុម្មុយនីស្តកម្ពុជាទាំងមូល តួនាទីកម្រិតតំបន់ យ៉ាងច្រើនបំផុតត្រឹមជាតួនាទីកម្រិតកណ្តាលប៉ុណ្ណោះ ដែលតួនាទីនេះមិនអនុញ្ញាតឱ្យមាន ការធ្វើការសម្រេចចិត្តដោយឯករាជ្យ ឬអាចសម្រេចអំពីមធ្យោបាយនៃការអនុវត្ត

---

**D219/776.1.1** (កិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយនឹង សូ សារ៉េន) KH 01249888 ទំព័រ ៣២ (សូ សារ៉េន ប៉ាន់ស្មានថា អោ អាន ជាអ្នកចេញបញ្ជា)។

[369] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៥៦, ២៧២ ជើងទំព័រ ៦៣៧, ៧០៥ (ពឹងផ្អែកតែលើ ង៉ូវ), កថាខណ្ឌ ២៧២ ជើងទំព័រ ៧០៥(ពេញ វ៉ា, គាន ឡឺ និងប្រាក់ យុត ពិភាក្សាតែ(“លក្ខខណ្ឌទូទៅត្រូវមានលិខិតអនុញ្ញាតធ្វើដំណើរនៅថ្នាក់តំបន់ ស្រុក និងឃុំ”)។

[370] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៧២ ជើងទំព័រ ៧០៥។

[371] ឧទាហរណ៍ ឯកសារ **D219/226** (កំណត់ហេតុស្តាប់ចម្លើយ ពេញ វ៉ា) ឆ.១៤ (ពេញ វ៉ា បញ្ជាក់ថា មិត្តស្រេង បានចេញលិខិតធ្វើដំណើរឲ្យគាត់)។ ឯកសារ **D117/57** (កំណត់ហេតុស្តាប់ចម្លើយ គាន ឡឺ) ឆ.១៦ (គាន ឡឺ នៅចាំថា ឃុំបានចេញលិខិតធ្វើដំណើរឲ្យគាត់)។ ឯកសារ **D219/792.1.3** (ប្រតិចារឹកសំណុំរឿង ០០២/០២ ប្រាក់ យុត) KH 01427768 ទំព័រ ៤០ (ប្រាក់ យុត លើកឡើងថា មានតែស្រុក និងឃុំមានសិទ្ធិចេញលិខិតធ្វើដំណើរ)។

[372] ឯកសារ **D219/442** (កំណត់ហេតុស្តាប់ចម្លើយ ជុំ វង្ស) ឆ.១៣៤-ឆ.១៣៦។

ឬការផ្សព្វផ្សាយគោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជាឡើយ។

### vi. អោ អាន មិនមានតួនាទីនៅក្នុងអំពើ ប្រល័យពូជសាសន៍ជនជាតិចាម ដែលត្រូវបានចោទប្រកាន់នោះទេ

146. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្ដល់នូវភ័ស្ដុតាងដែលមានការគាំទ្រ និងច្បាស់លាស់គ្រប់គ្រាន់ថា អោ អាន មានតួនាទីនៅក្នុងអំពើ ប្រល័យពូជសាសន៍ជនជាតិចាម ដែលត្រូវបានចោទប្រកាន់ នៅក្នុងខេត្តកំពង់ចាមឡើយ។ បន្ថែមពីលើកំហុសឆ្គងអង្គច្បាប់ ដែលបានលើកឡើងនៅក្នុងផ្នែក III(ឈ) អោ អាន មិនបានចូលរួមចំណែកជាសំខាន់ ចំពោះគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលត្រូវបានចោទប្រកាន់ថា កំណត់គោលដៅទៅលើប្រជាជនចាម ឬមានចេតនាជាក់លាក់ ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ឬរៀបចំផែនការ បញ្ជា ឬញុះញង់ឱ្យមានអំពើប្រល័យពូជសាសន៍។ ដោយផ្អែកសឹងតែទាំងស្រុងទៅលើ សាក្សីដែលមិនអាចជឿជាក់បានគឺ ប្រាក់ យុត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំហុសឆ្គងក្នុងការសម្រេចថា អោ អាន បានបញ្ជាដល់អ្នកក្រោមបង្គាប់ ជាពិសេសលេខាស្រុកនៅតំបន់៤១ ឱ្យធ្វើការកំណត់អត្តសញ្ញាណ រៀបចំបញ្ជី ធ្វើការចាប់ខ្លួននិងសម្លាប់ប្រជាជនចាម ហើយថា អោ អាន ត្រួតត្រានិងគ្រប់គ្រងលើការវិវឌ្ឍន៍ នៃបញ្ហាទាំងអស់នេះតាមរយៈរបាយការណ៍ និងថាគាត់បានចូលរួមក្នុងការជម្លៀស ប្រជាជនចាមពីភូមិភាគបូព៌ា[373]។

147. ជាដំបូង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្ដល់ភ័ស្ដុតាងគ្រប់គ្រាន់ថា អោ អាន បានបញ្ជាដល់អ្នកក្រោមបង្គាប់ ដូចជាលេខាស្រុក ឱ្យកំណត់អត្តសញ្ញាណ (តាមរយៈរៀបចំបញ្ជីឬវិធីណាមួយ) ធ្វើការចាប់ខ្លួន និងសម្លាប់ប្រជាជនចាម[374]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដកស្រង់សឹងតែទាំងស្រុង នូវចម្លើយដែលមិនអាចជឿជាក់បាន មិនមានការគាំទ្ររបស់ ប្រាក់ យុត និង យូ វ៉ាន់ ដែលបានផ្ដល់ព័ត៌មានតែអំពីស្រុកកំពង់សៀម[375]។ បន្ទាប់មក សហចៅក្រមស៊ើប

---

[373] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០២-០៣, ៦៣៣-៣៧។

[374] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០២-០៣, ៦៣៣-៣៧។

[375] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០២ ជើងទំព័រ ៨០៤-៨០៥, ៨០៧, កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១១, កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥៣-២១៥៤, កថាខណ្ឌ ៦៣៤ ជើងទំព័រ ២១៦៣,២១៦៨, កថាខណ្ឌ ៦៣៦ ជើងទំព័រ ២១៧៣-២១៧៦។ ពាក់ព័ន្ធនឹងការបញ្ជា ស.ច.ស.អ ពឹងផ្អែកស្ទើរតែស្រុងលើចម្លើយគ្មានការបញ្ជាក់ និងមិនអាចជឿជាក់បានរបស់ ប្រាក់ យុត។ ស.ច.ស.អ ព្យាយាមបញ្ជាក់ព័ត៌មានរបស់ប្រាក់ យុត ជាមួយនឹងចម្លើយរបស់សាក្សីដែលមិនអាចជឿជាក់

អង្កេតអន្តរជាតិ បានទាញចេញដោយមិនត្រឹមត្រូវ និងមិនមានមូលដ្ឋាន ពីសក្ខីកម្មរបស់ ប្រាក់ យុត ដែលថា អោ អាន បានបញ្ជាដល់លេខាស្រុកទាំងអស់ នៅក្នុងតំបន់ ៤១ ឲ្យរៀបបញ្ជីប្រជាជនចាម និងបានបង្ហាញដោយមិនត្រឹមត្រូវ នូវសក្ខីកម្មរបស់បុគ្គលដទៃទៀត ក្នុងចេតនាដើម្បីគាំទ្រដល់ការសន្និដ្ឋាននេះ[376]។

148. ទីពីរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភ័ស្តុតាងគ្រប់គ្រាន់ថា អោ អាន ត្រួតត្រានិងគ្រប់គ្រងលើការវិវឌ្ឍន៍ នៃការសម្លាប់ជនជាតិចាមដែលត្រូវបានចោទប្រកាន់ តាមរយៈរបាយការណ៍ឬបញ្ជី ដែលគាត់បានទទួលពីថ្នាក់ក្រោម[377]។ ជាថ្មីម្តងទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកសឹងតែទាំងស្រុងទៅលើ ភ័ស្តុតាងមិនមានការគាំទ្រ មិនអាចជឿជាក់បានរបស់ ប្រាក់ យុត[378]។

---

បានគឺយូ វ៉ាន់ និងញឹម កុល។ ប៉ុន្តែ ទាំង ញឹម កុល ទាំង យូ វ៉ាន់ មិនបានបញ្ជាក់តាមប្រាក់ យុត ទេ។ ចំពោះការបញ្ជាឲ្យធ្វើ "បញ្ជីឈ្មោះទី២" ស.ច.ស.អ ពឹងផ្អែកតែលើសក្ខីកម្មមិនអាចជឿជាក់បានរបស់ យូ វ៉ាន់។

[376] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៦២ (ស.ច.ស.អ ពឹងផ្អែកលើ សាយ ឌឿន ដែលព័ត៌មានរបស់គាត់ជាក់ស្តែងមិនមានការបញ្ជាក់ទេ ពីព្រោះថា ភស្តុតាងរបស់សេង ស៊្រុន ត្រូវបានបំភាន់ ឬមិនអាចជឿជាក់បាន។ ឯកសារ **D219/702.1.85** (ប្រតិចារឹកសំណុំរឿង ០០២/០២ សាយ ឌឿន) KH 01453112 ទំព័រ ៥៨។ ឯកសារ **D219/702.1.88** (ប្រតិចារឹកសំណុំរឿង ០០២/០២ សេង ស៊្រុន) KH 01416956 ទំព័រ ៤៥-៤៧ (សេង ស៊្រុន ផ្តល់ភស្តុតាងពាក្យចចាមអារ៉ាមពាក់ព័ន្ធនឹងបញ្ជីឈ្មោះជនជាតិចាម ហើយមិនលើកឡើងពីឈ្មោះ អោ អាន ទេ)។ ឯកសារ **D6.1.700** (កំណត់ហេតុស្តាប់ចម្លើយ សេង ស៊្រុន) ឆ.៣, ឆ.៨, ឆ.១០, ឆ.១២ (សេង ស៊្រុន មិនបានលើកឡើងពីឈ្មោះអោ អាន ពាក់ព័ន្ធនឹងបញ្ជីឈ្មោះជនជាតិចាម ទេ))។

[377] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១៤-៨១៥, កថាខណ្ឌ ៦៣៣ ជើងទំព័រ ២១៥៧, ២១៦១, កថាខណ្ឌ ៦៣៥, ជើងទំព័រ ២១៦៨-២១៧២។

[378] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣០៣ ជើងទំព័រ ៨១៤-៨១៥ (ស.ច.ស.អ ព្យាយាមបញ្ជាក់ភស្តុតាងរបស់ ប្រាក់ យុត ជាមួយនឹងភស្តុតាងពីសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីដែលមិនអាចជឿជាក់បានគឺ យូ វ៉ាន់, ញឹម កុល និងពេជ្រ ជឹម។ ញឹម កុល ផ្តល់ព័ត៌មានអំពីការចាប់ខ្លួនពាក់ព័ន្ធតែជាមួយនឹង ប្រាក់ យុត ទេ ហើយមិនបានភ្ជាប់ការចាប់ខ្លួនទាំងនោះជាមួយនឹង អោ អាន ទេ។ នៅក្នុងអំឡុងពេលស៊ើបសួរសំណុំរឿង ០០៤ យូ វ៉ាន់ បានបញ្ជាក់ថា អោ អាន ទទួលរបាយការណ៍អំពីការសម្លាប់មនុស្ស តែក្រោយពេលដែលអ្នកស៊ើបអង្កេត ក.ស.ច.ស បានសួរសំណួរនាំមុខតែប៉ុណ្ណោះ ហើយ យូ វ៉ាន់ ផ្តល់ភស្តុតាងពាក្យចចាមអារ៉ាមពីឈ្មោះផែន ថា ប្រាក់ យុត រាយការណ៍ទៅ អោ អាន។ ក្រោយមក បន្ទាប់ពីរំឭកឡើងវិញពីការចងចាំរបស់គាត់ យូ វ៉ាន់ បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ ថា គាត់នាំសាររវាងប្រាក់ យុត ជាមួយនឹង អោ អាន ម្តងម្កាល។ ក្រោយមក គាត់បានពន្យល់ថា នៅពេលដែលគាត់ជាប្រធានកងចល័ត គាត់បានផ្ញើរបាយការណ៍ឲ្យ

149. ទីបី សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានសន្និដ្ឋានថា ដោយសារតែតួនាទីរបស់ អោ អាន នៅក្នុងតំបន់ ៤១ និងភូមិភាគកណ្ដាល គាត់ពិតជាបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការរៀបចំផែនការជម្លៀសប្រជាជនចាម ពីភូមិភាគបូព៌ាទៅភូមិភាគកណ្ដាល ដែលនៅទីនោះមានការចោទប្រកាន់ថាពួកគេត្រូវបានសម្លាប់[379]។ នៅក្នុងផ្នែក II(ង)(iv) និង (ង)(v) មេធាវីការពារក្ដីបានបង្ហាញថា មិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីសម្រេចថា អោ អាន ជាលេខាតំបន់៤១ *តាមផ្លូវច្បាប់* ឬ *តាមជាក់ស្ដែង* ឬជាអនុលេខាភូមិភាគកណ្ដាលទេ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្ដល់ផងដែរនូវភស្តុតាងឲ្យបានគ្រប់គ្រាន់ ដើម្បីភ្ជាប់ អោ អាន ជាមួយការជម្លៀសនិងការសម្លាប់ប្រជាជនចាមមកពីភូមិភាគបូព៌ា[380] និងបានពិភាក្សាដោយខ្លីៗប៉ុណ្ណោះទៅលើបញ្ហានេះ ទាក់ទងនឹងតំបន់ ៤២[381] ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិទទួលស្គាល់ថា អោ អាន មិនមានអំណាចនៅតំបន់ ៤២ ទេ[382]។

150. ហេតុដូច្នេះមិនមានភស្តុតាងដែលមានការគាំទ្រ និងសំខាន់ដែលថា អោ អាន មានតួនាទីណាមួយនៅក្នុង អំពើប្រល័យពូជសាសន៍ ទៅលើជនជាតិចាម ដែលត្រូវបានចោទប្រកាន់នោះ។ អោ អាន មិនបានចូលរួមពាក់ព័ន្ធ ក្នុងការកំណត់អត្តសញ្ញាណ ការចាប់ខ្លួន ឬការសម្លាប់ប្រជាជនចាម នៅក្នុងខេត្តកំពង់ចាមឡើយ។ គាត់ក៏បានមិនមានរៀបចំផែនការ បញ្ជា ឬញុះញង់ដល់អំពើទាំងអស់នេះ ឬបានចូលរួមចំណែកយ៉ាងសំខាន់ ចំពោះផែនការរួមណាមួយឡើយ ហើយគាត់មិនបានត្រួតត្រាលើបុគ្គល ដែលត្រូវបានចោទប្រកាន់ថា បានអនុវត្តបញ្ជារបស់អ្នកដទៃទេ។

## vii. អោ អាន មិនមានតួនាទីនៅក្នុងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ ឬ ការរំលោភផ្លូវភេទដែលត្រូវបាន

ប្រាក់ យុត ប៉ុន្តែ មិនបានបញ្ជាក់ថា បន្ទាប់មក ប្រាក់ យុត រាយការណ៍ទៅ អោ អាន ទេ), កថាខណ្ឌ ៦៣៣, ៦៣៥ ជើងទំព័រ ២១៥៧, ២១៦៩-២១៧០ (ស.ច.ស.អ មិនបានបញ្ជាក់ភស្តុតាងរបស់ប្រាក់ យុត ជាមួយនឹងភស្តុតាងរបស់ យូ វ៉ាន់ ទេ), កថាខណ្ឌ ៦៣៣, ជើងទំព័រ ២១៦១ (ស.ច.ស.អ យោងទាំងស្រុងតែលើព័ត៌មានគ្មានការបញ្ជាក់របស់ យូ វ៉ាន់ តែប៉ុណ្ណោះ), កថាខណ្ឌ ៦៣៥ ជើងទំព័រ ២១៧១-២១៧២ (ស.ច.ស.អ យោងទាំងស្រុងតែលើព័ត៌មានគ្មានការបញ្ជាក់របស់ ប្រាក់ យុត តែប៉ុណ្ណោះ)។

[379] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៧។

[380] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៧ (ស.ច.ស.អ មិនបានបង្ហាញភស្តុតាងណាមួយដើម្បីគាំទ្រការយល់ឃើញរបស់ខ្លួនទេ)។

[381] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៥៦, ៦៦០។

[382] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៤៩។

# ចោទប្រកាន់ នៅស្រុកកំពង់សៀមនិងព្រៃឈរ

151. បន្ថែមពីលើកំហុសឆ្គងអង្គច្បាប់ ដែលបានលើកឡើងនៅក្នុងផ្នែក III(ឆ) និង (ជ) ពាក់ព័ន្ធការរៀបការដោយបង្ខំ និងអំពើអមនុស្សធម៌ដទៃទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភ័ស្តុតាងគ្រប់គ្រាន់ដែលថា អោ អាន បានចូលរួមចំណែកយ៉ាងសំខាន់ នៅក្នុងគោលនយោបាយរបស់ បក្សកុម្មុយនីស្តកម្ពុជាស្តីពី ការរៀបអាពាហ៍ពិពាហ៍ ឬការរំលោភផ្លូវភេទដែលត្រូវបានចោទប្រកាន់ នៅក្នុងស្រុកកំពង់សៀមនិងព្រៃឈរ។

152. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភ័ស្តុតាងថា អោ អាន គ្រប់គ្រងឬគាំទ្រដល់គោលនយោបាយ របស់បក្សកុម្មុយនីស្តកម្ពុជា ចំពោះការរៀបអាពាហ៍ពិពាហ៍ ឬការបង្កើនចំនួនប្រជាជន[383] ត្រួតពិនិត្យលើការអនុវត្តគោលនយោបាយទាំងនេះ នៅស្រុកកំពង់សៀមនិងព្រៃឈរ[384] ធ្វើជាអធិបតីយលើពិធីរៀបអាពាហ៍ពិពាហ៍[385] ឬដឹកនាំការប្រជុំស្តីពីការរៀបអាពាហ៍ពិពាហ៍[386]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកជាចម្បងទៅលើ តួនាទីដែលបានចោទប្រកាន់របស់ អោ អាន ជាលេខាតំបន់ ៤១ និងអនុលេខាភូមិភាគកណ្តាល ដើម្បីគាំទ្រដល់ការសម្រេចទាំងអស់នេះ ប៉ុន្តែដូចដែលបានពន្យល់នៅក្នុងផ្នែក II(ង)(iv) និង (ង)(v) គឺមិនមានភ័ស្តុតាងគ្រប់គ្រាន់បង្ហាញថា អោ អាន កាន់តួនាទីទាំងអស់នេះទេ។

153. ពាក់ព័ន្ធទៅនឹងការសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អោ អាន ដឹកនាំការប្រជុំស្តីពីការរៀបអាពាហ៍ពិពាហ៍[387] សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកទៅលើភ័ស្តុតាងមិនជាក់លាក់ និងមិនមានការគាំទ្រ[388] ហើយគាត់បានបង្ហាញដោយខុសឆ្គងនូវភ័ស្តុតាង របស់

---

[383] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២២៤-២៣២, ៣១៤-៣១៩។

[384] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២២៤។

[385] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២២៤, ៣១៩, ៦៨៥ ជើងទំព័រ ៨៥៣, ២៣៥៥-២៣៥៩។

[386] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣១៤។

[387] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣១៤ ជើងទំព័រ ៨៣៥ (ស.ច.ស.អ ផ្តល់ភស្តុតាងតែពីសាត ភាព និង សារាយ ហៀន)។

[388] ឯកសារ **D219/504** (កំណត់ហេតុស្តាប់ចម្លើយ សាត ភាព) ឆ.២៥, ឆ.២៧-ឆ.២៨(សាត ភាព ផ្តល់សេចក្តីលម្អិតតិចតួចអំពីការចោទប្រកាន់ពាក់ព័ន្ធនឹងការនិយាយជាសាធារណៈរបស់ អោ អាន អំពីការរៀបការ។ ទាល់តែដល់ពេលដែលអ្នកស៊ើប

សាក្សីមួយរូបដែលពិភាក្សាតែអំពី គោលនយោបាយការរៀបអាពាហ៍ពិពាហ៍ នៅក្នុងតំបន់៤២ ដោយមិនមានការនិយាយអំពី អោ អាន ឡើយ[389]។ លើសពីនេះទៅទៀត ដើម្បីគាំទ្រដល់ការសម្រេចរបស់គាត់ ពាក់ព័ន្ធ អោ អាន ដឹកនាំការប្រជុំនៅចុងឆ្នាំ ១៩៧៧ នៅវត្តតាមាក់ អំពីការរៀបអាពាហ៍ពិពាហ៍និងកូន សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកម្តងទៀតទៅលើ ភ័ស្តុតាងដែលមិនមានការគាំទ្រ[390] ឬបានផ្តល់នូវការគាំទ្រអះអាង ដោយភ័ស្តុតាងពាក្យចចាមអារាម មិនគួរឲ្យជឿជាក់បាន[391]។ ប្រហែលគ្នានេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់នូវភ័ស្តុតាងគ្រប់គ្រាន់អំពី អោ អាន ដឹកនាំពិធីរៀបអាពាហ៍ពិពាហ៍ឡើយ[392]។

154. ក្រៅពីនេះទៅទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការសម្រេចថា អោ អាន បានប្រកាសពីគោលនយោបាយ ពាក់ព័ន្ធការផ្សំដំណេក[393]។ ដើម្បីគាំទ្រដល់ការសម្រេចរបស់គាត់ដែលថា "ប្តីប្រពន្ធទើបរៀបការរួច ត្រូវបានណែនាំយ៉ាងច្បាស់ឲ្យផ្សំដំណេក" ទាំងនៅស្រុកកំពង់សៀម និងនៅស្រុកព្រៃឈរ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកលើសក្ខី

---

អង្កេតផ្តល់ឲ្យគាត់នូវព័ត៌មានដាក់បន្ទុកអំពី"ការរៀបការដោយបង្ខំ"ទេ ទើបសាក្សីនេះលើកឡើងពី"ផែនការការរៀបការ" និង "ផែនការរបស់ប៉ុល ពត")។

[389] ឯកសារ **D219/762** (កំណត់ហេតុស្តាប់ចម្លើយ សារាយ ហៀន) ឆ.១-ឆ.២, ឆ.១៣៥-ឆ.១៣៧។

[390] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣១៥ ជើងទំព័រ ៨៣៦-៨៣៨ (ពឹងផ្អែកទាំងស្រុងតែលើព័ត៌មានគ្មានការបញ្ជាក់របស់សាត ភាព)។

[391] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣១៦ ជើងទំព័រ ៨៣៩ (យូ វ៉ាន់ ផ្តល់ភស្តុតាងពាក្យចចាមអារ៉ាម ហើយមិនបានបញ្ជាក់ពីព័ត៌មានរបស់ សាត ភាព ទេ)។ ឯកសារ **D219/138** (កំណត់ហេតុស្តាប់ចម្លើយ យូ វ៉ាន់) ឆ.៨០។ ឯកសារ **D219/702.1.87** (ប្រតិចារឹកសំណុំរឿង ០០២/០២ យូ វ៉ាន់) KH 01451960-61 ទំព័រ ៦២-៦៣)។

[392] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២២៨ ជើងទំព័រ ៥៣០ (ក្នុងចំណោមសាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់ដែល ស.ច.ស. អ ដកស្រង់ តែមាន យូ វ៉ាន់ ដែលជាសាក្សីមិនអាចជឿជាក់បាន ដែលបញ្ជាក់ថា អោ អាន ឲ្យគេរៀបការនៅក្នុងពិធីរៀបការចំនួនពីរលើក), កថាខណ្ឌ ៦៨៥ ជើងទំព័រ ២៣៥៥ (ស.ច.ស.អ ពឹងផ្អែកលើសាក្សីមិនអាចជឿជាក់បាន គឺ ប្រាក់ យុត និង យូ វ៉ាន់), កថាខណ្ឌ ៦៨៥ ជើងទំព័រ ២៣៥៦ (ស.ច.ស.អ ពឹងផ្អែកទាំងស្រុងតែលើព័ត៌មានគ្មានការបញ្ជាក់របស់ តូច មៀច), កថាខណ្ឌ ៦៨៥ ជើងទំព័រ ២៣៥៧-២៣៥៨ (ស.ច.ស.អ ពឹងផ្អែកទាំងស្រុងតែលើព័ត៌មានគ្មានការបញ្ជាក់របស់ យូ វ៉ាន់), កថាខណ្ឌ ៦៨៥ ជើងទំព័រ ២៣៥៩ (ស.ច.ស.អ ពឹងផ្អែកទាំងស្រុងតែលើព័ត៌មានគ្មានការបញ្ជាក់របស់ ទូច ចំរើន)។

[393] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣១៦, ៦៨៦-៨៧, ៨៣១។

កម្មមិនជាក់លាក់ ដែលមិនបានភ្ជាប់ទំនាក់ទំនង អោ អាន ទៅនឹងការណែនាំណាមួយ[394] ឬដែលបានឆ្លើយដាក់អ្នកដទៃឡើយ[395]។ ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភស្តុតាងដើម្បីបំពេញតាម បទដ្ឋានដែលបានតម្រូវ ដើម្បីគាំទ្រដល់ការសម្រេចរបស់គាត់ដែលថា អោ អាន ទទួលខុសត្រូវលើការរៀបអាពាហ៍ពិពាហ៍ ឬការរំលោភផ្លូវភេទនៅស្រុកកំពង់សៀម ឬស្រុកព្រៃឈរ។

### viii. អោ អាន មិនមានតួនាទីនៅក្នុងឧក្រិដ្ឋកម្ម ដែលត្រូវបានចោទប្រកាន់ នៅទីតាំងឧក្រិដ្ឋកម្មឡើយ

155. ដោយសារតែ អោ អាន មិនមានសិទ្ធិអំណាច មិនមានតួនាទី និងការទទួលខុសត្រូវនៅក្នុងតំបន់ ៤១ និងនៅភូមិភាគកណ្តាល និងដោយសារតែគាត់មិនមានសកម្មភាព និងវត្តមាន នៅឯទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់នោះ[396] ទើបសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការសម្រេចថា អោ អាន ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ តាមរយៈទម្រង់នៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់។ អោ អាន មិនបានរៀបចំផែនការ បញ្ជា ឬញុះញង់ទៅលើឧក្រិដ្ឋកម្មណាមួយ នៅទីតាំងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ឡើយ។ គាត់ក៏មិនបានចូលរួមចំណែកជាសំខាន់ ក្នុងផែនការរួមឡើយ ហើយគាត់ក៏មិនបានត្រួតត្រាទៅលើ អ្នកទាំងឡាយដែលអនុវត្តបញ្ជារបស់អ្នកដទៃដែរ។ ជាចុងក្រោយ អោ អាន មិនមានព័ត៌មានតាមការតម្រូវ ឬមានចេតនាក្នុងការប្រព្រឹត្ត ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ទេ។

### ix. ការសន្និដ្ឋានលើសំអាងហេតុទី៦

156. ហេតុដូច្នេះសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការសម្រេចថា អោ អាន មានតួនាទីសំខាន់ នៅក្នុងបក្សកុម្មុយនីស្តកម្ពុជា និងមានតួនាទីសំខាន់នៅក្នុង ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ ជាងកម្មាភិបាលខ្មែរក្រហមដែលត្រូវបានគេស្គាល់ដទៃផ្សេងទៀត។ ដូចដែលបានពន្យល់ពីខាងលើ អោ អាន មិនបានសម្រេចឬបកស្រាយ ទៅលើគោលនយោបាយរបស់ បក្ស

---

[394] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៨៦ ជើងទំព័រ ២៣៦០ (គ្មានសាក្សីណាម្នាក់ក្នុងចំណោមសាក្សីដែល ស.ច.ស.អ ដកស្រង់ បានបញ្ជាក់ថា អោ អាន បានផ្តល់សេចក្តីណែនាំជាក់លាក់ឱ្យផ្សំដំណេកទេ)។

[395] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៨៦ ជើងទំព័រ ២៣៦១ (ស.ច.ស.អ ពឹងផ្អែកលើ មួក សេងលី ដែលឆ្លើយថា ប្រាក់ យុត គឺជាអ្នកដែលជំរុញប្តីប្រពន្ធឱ្យ "បង្កើតកូនឱ្យអង្គការ")។

[396] ផ្នែក II(ង)(iv), (v) និង (viii)។

កុម្មុយនីស្តកម្ពុជាឡើយ ហើយក៏មិនបានជួយរួមចំណែក ក្នុងការផ្សព្វផ្សាយឬអនុវត្ត គោលនយោបាយទាំងអស់នេះ នៅក្នុងភូមិភាគកណ្តាលទេ។ បន្ថែមលើនេះ អោ អាន មិនបានរៀបចំផែនការ សម្របសម្រួល ឬដឹកនាំការបោសសម្អាត អតីតជនស៊ីវិល ឬកម្មាភិបាលភូមិភាគកណ្តាល ចាប់ពីចុងឆ្នាំ១៩៧៦ រហូតដល់ខែកុម្ភៈ ឆ្នាំ១៩៧៧ទេ។ អោ អាន មិនបានកាន់តួនាទីដូចការចោទប្រកាន់ នៅក្នុងភូមិភាគកណ្តាល ឬតំបន់៤១ឡើយ។ បើទោះបីជាគាត់កាន់តួនាទីទាំងអស់នេះក្តី ក៏តួនាទីទាំងនេះមិនមែនជាតួនាទីសំខាន់ របស់បក្សកុម្មុយនីស្តកម្ពុជាទេ នៅពេលប្រៀបធៀបជាមួយតួនាទី របស់កម្មាភិបាលខ្មែរក្រហមដែលល្បីៗផ្សេងទៀត ដូចជា កែ ពក តា ម៉ុក ឌុច និង សៅ សារុន។ ជាចុងក្រោយ អោ អាន មិនមានតួនាទីនៅក្នុង អំពើប្រល័យពូជសាសន៍ដែលបានចោទប្រកាន់ ថាប្រព្រឹត្តទៅលើប្រជាជនចាម នៅក្នុងខេត្តកំពង់ចាម ការចោទប្រកាន់ពីការរៀបការដោយបង្ខំ និងការរំលោភផ្លូវភេទនៅក្នុងស្រុកព្រៃឈរ ឬស្រុកកំពង់សៀម ឬឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅទីតាំងឧក្រិដ្ឋកម្មនានាឡើយ។

## ច. សំអាងហេតុទី៧៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការសម្រេចថា ឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ មានស្ថានទម្ងន់ល្មមគ្រប់គ្រាន់

157. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការសម្រេចថា ស្ថានទម្ងន់នៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ គឺល្មមគ្រប់គ្រាន់សម្រាប់ឱ្យតុលាការ មានយុត្តាធិការបុគ្គលលើ អោ អាន[397]។ ភស្តុតាងដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានផ្តល់ គឺសឹងតែទាំងអស់បានមកពីតំបន់៤១ ជាទីតាំងភូមិសាស្ត្រដ៏តូចមួយ។ លើសពីនេះទៅទៀត មិនមានភស្តុតាងគ្រប់គ្រាន់សម្រាប់គាំទ្រ ដល់ការគណនារបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើចំនួនជនរងគ្រោះនៅក្នុងភូមិភាគកណ្តាល ឬតំបន់៤១។ ជាចុងក្រោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអាចដាក់បន្ទុកចំពោះអំពើប្រល័យពូជសាសន៍ ឬការចោទប្រកាន់ពីចំនួនជនរងគ្រោះ មកពីតំបន់៤២និងតំបន់៤៣ ទៅលើ អោ អាន តាមរយៈទម្រង់នៃការទទួលខុសត្រូវ ដែលបានចោទប្រកាន់ឡើយ។

### i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់ភស្តុតាងជាចម្បង ពាក់ព័ន្ធតែតំបន់ភូមិសាស្ត្រតូចមួយ

158. ដូចដែលបានពន្យល់នៅក្នុងផ្នែក II(ង)(v) ខាងលើ ភាគច្រើននៃភស្តុតាងដែលសហចៅក្រមស៊ើប

[397] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៧០៦-០៨។

អង្កេតអន្តរជាតិបានផ្ដល់ ពាក់ព័ន្ធកម្រិតនៃការទទួលខុសត្រូវ ដែលត្រូវបានចោទប្រកាន់របស់ អោ អាន និងតួនាទីក្នុងឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅក្នុងតំបន់៤១[398] គឺជាតំបន់ភូមិសាស្ត្រតូចមួយ បើប្រៀបធៀបជាមួយតំបន់ដទៃទៀត ដែលគ្រប់គ្រងដោយកម្មាភិបាលដទៃទៀត ដូចជា កែ ពក (ភូមិភាគកណ្ដាល)[399] និង តា ម៉ុក (ភូមិភាគនិរតី ភូមិភាគបស្ចឹម ភូមិភាគពាយ័ព្យ)[400]។ តំបន់ភូមិសាស្ត្រតូចមួយនេះ មិនបានគាំទ្រដល់ការសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អោ អាន ស្ថិតក្នុងចំណោមអ្នកទទួលខុសត្រូវខ្ពស់បំផុតឡើយ។

## ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្ដល់ភ័ស្ដុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការគណនារាបស់គាត់ ទៅលើចំនួនជនរងគ្រោះយ៉ាងខ្ពស់ នៅក្នុងភូមិភាគកណ្ដាល ឬតំបន់៤១

159. មិនមានភ័ស្ដុតាងគ្រប់គ្រាន់ ដើម្បីគាំទ្រដល់ការសម្រេចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីចំនួនជនរងគ្រោះដែលបានចោទប្រកាន់ ដែលអាចដាក់បន្ទុកចំពោះ អោ អាន ដែលជាលទ្ធផលនៃឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ នៅក្នុងតំបន់៤១ និងភូមិភាគកណ្ដាល[401]។ ទោះបីជាមេធាវីការពារក្ដីសូមសរសើរចំពោះ ការព្យាយាមរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការអនុវត្តវិធីសាស្ត្រវាយតម្លៃកម្រិតទាប ដើម្បីគណនាចំនួនជនរងគ្រោះក្ដី[402] តែមេធាវីការពារក្ដីសូមលើកឡើងថា វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅតែពឹងផ្អែកលើការទាយស្មាន

---

[398] សូម្បីតែពិនិត្យភស្ដុតាងពាក់ព័ន្ធនឹងតំបន់ ៤១ ក៏ដោយ ក៏ភាគច្រើនក្នុងចំណោមភស្ដុតាងនេះពាក់ព័ន្ធសំខាន់តែជាមួយនឹងស្រុកចំនួនបីប៉ុណ្ណោះ(ស្រុកកំពង់សៀម ស្រុកព្រៃឈរ និងស្រុកកងមាស)។

[399] ឯកសារ **D6.1.1105** (សៀវភៅនិពន្ធដោយ Kiernan *របបប៉ុល ពត៖ ពូជសាសន៍ អំណាចអំពើប្រល័យពូជសាសន៍ ក្នុងប្រទេសកម្ពុជា ក្រោមខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩)* ទំព័រ ៩១, ២៧៨ ភាសាអង់គ្លេស។ ឯកសារ **D6.1.659** (កំណត់ហេតុស្ដាប់ចម្លើយ ប៊ិច សុខា) KH 00389526 ទំព័រ ៨។ ឯកសារ **D3/19** (កំណត់ហេតុស្ដាប់ចម្លើយ វង សុគន្ធ) ឆ.១៣។ ឯកសារ **D107/5** (កំណត់ហេតុស្ដាប់ចម្លើយ អ៊ន គឹមអេង) ឆ.៤។ ឯកសារ **D107/13** (កំណត់ហេតុស្ដាប់ចម្លើយ ឡុង សុខែ) KH 007916600 ទំព័រ ៣។

[400] ឯកសារ **D6.1.1105** សៀវភៅនិពន្ធដោយ Kiernan *របបប៉ុល ពត៖ ពូជសាសន៍ អំណាចអំពើប្រល័យពូជសាសន៍ ក្នុងប្រទេសកម្ពុជា ក្រោមខ្មែរក្រហម ឆ្នាំ១៩៧៥-៧៩)* ទំព័រ ៨៧, ៣៩២, ៤១៧។ ឯកសារ **D219/193** (កំណត់ហេតុស្ដាប់ចម្លើយ វ៉ាត ផាត) ឆ.២០៨, ឆ.២១៥។

[401] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣៥០, ៣៨៣, ៤០៧, ៤៥២, ៤៩០, ៥៣៣, ៥៨២។

[402] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៣៧-១៥៤។

ដដែល[403] ហើយមិនអាចនាំទៅដល់ ចំនួនជនរងគ្រោះដែលអាចបំពេញបាន តាមបទដ្ឋានបង្ហាញភ័ស្តុតាងដែលបានតម្រូវឡើយ។

### iii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអាចដាក់បន្ទុកអំពើប្រល័យពូជសាសន៍ ទៅលើ អោ អាន តាមរយៈទម្រង់នៃការទទួលខុសត្រូវ ដែលបានចោទប្រកាន់នោះឡើយ

160. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តលក្ខខណ្ឌតម្រូវគតិយុត្តិដើម្បីដាក់បន្ទុកអំពើប្រល័យពូជសាសន៍ ដែលបានប្រព្រឹត្តនៅក្នុងតំបន់៤២ និងតំបន់៤៣ ទៅលើ អោ អាន តាមរយៈទម្រង់នៃការទទួលខុសត្រូវ ដែលបានចោទប្រកាន់ឡើយ។ ជាលទ្ធផល សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរួមបញ្ចូលដោយខុសឆ្គងនូវការស្លាប់របស់ប្រជាជនចាមមកពីតំបន់៤២និងតំបន់៤៣ ទៅក្នុងចំនួនជនរងគ្រោះទាំងអស់ដោយអំពើប្រល័យពូជសាសន៍។

161. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចថា អោ អាន ត្រូវទទួលខុសត្រូវចំពោះការស្លាប់របស់ប្រជាជនចាមចំនួន ១៧១១៥ នៅទូទាំងភូមិភាគកណ្តាល[404]។ ដើម្បីគណនាចំនួននេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរួមបញ្ចូលការស្លាប់របស់ប្រជាជនចាមនៅក្នុងតំបន់៤២និងតំបន់៤៣[405]។ ទោះបីជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់ភ័ស្តុតាងថា អោ អាន ត្រូវទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ នៅក្នុងតំបន់៤២ ឬតំបន់៤៣ តាមរយៈការរៀបចំផែនការ[406] ការបញ្ជា[407] ការញុះញង់[408] ឬការទទួលខុសត្រូវរបស់ថ្នាក់លើ[409]ឡើយ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏បានសម្រេចផងដែរថាមិនមានភ័ស្តុតាងអំពី អោ អាន “ប្រើសិទ្ធិ

[403] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៤២-១៤៤, ១៥០-១៥៤។

[404] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦១៨, ៧០៩, ៨១៥។

[405] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦១៨, ៦៦៣, ៦៦៧, ៦៧៥-៦៧៧។

[406] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៣៥។

[407] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៣៩។

[408] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៤៣។

[409] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៤៩។

អំណាចយ៉ាងសកម្ម លើមន្ទីរសន្តិសុខនៅក្នុងតំបន់៤២ និងតំបន់៤៣ នោះឡើយ"[410]។

162. បន្ថែមលើនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តលក្ខខណ្ឌតម្រូវគតិយុត្តិដើម្បីកំណត់ថា អោ អាន ត្រូវទទួលខុសត្រូវចំពោះ អំពើប្រល័យពូជសាសន៍នៅក្នុងតំបន់៤២ និងតំបន់៤៣ តាមរយៈសហឧក្រិដ្ឋកម្មរួម។ ដើម្បីកំណត់ថាសមាជិកមួយរូបនៃសហឧក្រិដ្ឋកម្មរួម ត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយចារីផ្ទាល់ ដែលមិនមែនជាសមាជិកនៃសហឧក្រិដ្ឋកម្មរួម ជាការចាំបាច់ដែលត្រូវបង្ហាញថាឧក្រិដ្ឋកម្មអាចត្រូវបានដាក់បន្ទុកទៅលើយ៉ាងហោចណាស់ក៏សមាជិកមួយរូបនៃសហឧក្រិដ្ឋកម្មរួម ហើយសមាជិករូបនេះនៅពេលប្រើប្រាស់ចារីផ្ទាល់ គឺធ្វើសកម្មភាពដើម្បីជម្រុញដល់ផែនការរួម[411]។ នៅក្នុង *ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ចារីដែលត្រូវបានចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍នៅតំបន់៤២ និងតំបន់៤៣ គឺមិនមានឈ្មោះទាំងអស់ លើកលែងតែមួយករណីប៉ុណ្ណោះ[412]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានកំណត់អត្តសញ្ញាណកម្មាភិបាលដែលត្រួតពិនិត្យមើល លើការស្លាប់ប្រជាជនចាមនៅក្នុង តំបន់៤២និងតំបន់៤៣ ហើយគាត់មិនបានពន្យល់ថាតើ ឧក្រិដ្ឋកម្មទាំងអស់នេះទាក់ទងដោយរបៀបណាជាមួយសមាជិកណាម្នាក់នៃសហឧក្រិដ្ឋកម្មរួម ហើយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានព្យាយាមភ្ជាប់ទំនាក់ទំនងឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តដោយ ចារីដែលមិនមានឈ្មោះទាំងអស់ ជាមួយសមាជិកសហឧក្រិដ្ឋកម្មរួម ដែលអាចកំណត់អត្តសញ្ញាណណាម្នាក់ឡើយ។ ហេតុដូច្នេះឧក្រិដ្ឋកម្មទាំងអស់នេះ មិនអាចដាក់បន្ទុកចំពោះក្រុមសហឧក្រិដ្ឋកម្មរួម ឬចំពោះ អោ អាន តាមរយៈការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមបានឡើយ។

---

[410] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២៦១, ២៦២។ គួរកត់សម្គាល់ថា អោ អាន មិនត្រូវចោទបញ្ជូនទៅជំនុំជម្រះចំពោះឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅតំបន់ ៤២ ឬ ៤៣ ទេ។

[411] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១២០។ សំណុំរឿង ០០២-**E313** កថាខណ្ឌ ៦៩៣។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សំណុំរឿងលេខ IT-99-36-A *សាលដីកា* ('*សាលដីកា Brđanin*') ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០០៧ កថាខណ្ឌ ៤១៣, ភ្ជាប់ជាមួយជាឯកសារឧបសម្ព័ន្ធ ៥៤។

[412] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៧០-៦៧១ (នៅក្នុងការយល់ឃើញរបស់ខ្លួនអំពីការសម្លាប់ជនជាតិចាមនៅតំបន់ ៤២ និង ៤៣ ស.ច.ស.អ បង្ហាញឈ្មោះចារីតែម្នាក់គត់ប៉ុណ្ណោះ ដែលជាឈ្លប។ ជាបញ្ហាចោទដែរដែលកម្មាភិបាលថ្នាក់ទាបនេះនឹងត្រូវចាត់ទុកថាជាសមាជិកម្នាក់នៅក្នុងសហឧក្រិដ្ឋកម្ម ហើយមិនមានការព្យាយាមភ្ជាប់សកម្មភាពរបស់គាត់ជាមួយនឹងសមាជិកនៅក្នុងសហឧក្រិដ្ឋកម្មរួមទេ)។

163. សរុបមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការរាប់ចំនួនប្រជាជនចាមដែលស្លាប់នៅក្នុងតំបន់៤២ និងតំបន់៤៣ ក្នុងចំណោមចំនួនជនរងគ្រោះទាំងអស់ និងនៅក្នុងការកំណត់លើយុត្តាធិការបុគ្គលរបស់គាត់។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងការសម្រេចថាឧក្រិដ្ឋកម្មដែលត្រូវបានចោទប្រកាន់ គឺមានស្ថានទម្ងន់គ្រប់គ្រាន់ដែលដូច្នេះហើយ អោ អាន គឺស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មសម័យកម្ពុជាប្រជាធិបតេយ្យ។

### ង. ការសន្និដ្ឋានសម្រាប់សំអាងហេតុទី២ដល់ទី៧

164. ដូចមូលហេតុដូចបានរៀបរាប់ខាងលើ មេធាវីការពារក្តីសូមលើកឡើងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងខាងអង្គហេតុ និងខាងអង្គច្បាប់ជាច្រើន ក្នុងការវាយតម្លៃថា អោ អាន គឺស្ថិតក្នុងចំណោមអ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មសម័យកម្ពុជាប្រជាធិបតេយ្យ និងស្ថិតក្រោមយុត្តាធិការបុគ្គល។ កំហុសឆ្គងទាំងអស់នេះ ធ្វើឲ្យមោឃភាព*ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ដែលដូច្នេះហើយ អង្គបុរេជំនុំជម្រះចាំបាច់ត្រូវតែច្រានចោលដីកានេះ ហើយលើកលែងបទចោទប្រកាន់ទាំងអស់នៃសំណុំរឿង។

## III. សំអាងហេតុទី៨ ដល់ទី១៧ ពាក់ព័ន្ធកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ លើច្បាប់សារធាតុ

165. *ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* មានកំហុសឆ្គងអង្គច្បាប់សំខាន់ៗ ពាក់ព័ន្ធទៅនឹងការវាយតម្លៃរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើយុត្តាធិការបុគ្គល និងយុត្តាធិការលើបទល្មើស។ ទោះបីជាកំហុសឆ្គងមួយចំនួន ត្រូវបានអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះដទៃទៀត ពិចារណារួចហើយក្តី តែមេធាវីការពារក្តីកត់សម្គាល់ថា អង្គបុរេជំនុំជម្រះមិនត្រូវបានចងកាតព្វកិច្ចដោយទ្រឹស្តី តុលាការជាន់ទាបត្រូវអនុវត្តតាមការសម្រេចរបស់តុលាការជាន់ខ្ពស់ *(stare decisis)* [413]។

### ក. សំអាងហេតុទី៨៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុវត្តដោយខុសឆ្គងនូវ ច្បាប់

[413] សំណុំរឿង ០០៤/១-ឯកសារ **D308/3** កថាខណ្ឌ ១០។

## ទំនៀមទម្លាប់អន្តរជាតិ ដោយរំលោភបំពានទៅលើ គោលការណ៍នីត្យានុកូលភាព

166. ការអនុវត្តដោយខុសរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ កើតចេញពីវិធីសាស្ត្រមិនត្រឹមត្រូវរបស់គាត់ក្នុងការសម្រេចលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងការដែលគាត់ពឹងផ្អែកជ្រុលពេកទៅលើយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ (*ad hoc* tribunals)[414]។ កំហុសបែបនេះបាននាំទៅដល់ការរំលោភបំពានទៅលើគោលករណ៍នីត្យានុកូលភាព[415] និងសំអាងហេតុមិនគ្រប់គ្រាន់[416] នៅក្នុង*ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ទាំងស្រុង។

167. ការសម្រេចលើអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចាំបាច់ត្រូវតែមានមូលដ្ឋាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលនៅជាធរមានក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[417]។ ទោះជាយ៉ាងនេះក្តី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានបង្ហាញថាការសម្រេចលើអង្គហេតុរបស់គាត់ កើតចេញពីការអនុវត្តរបស់រដ្ឋដែលទូលំទូលាយនិងស៊ីសង្វាក់គ្នា ដែលត្រូវបានធ្វើឡើងដោយការជឿជាក់ថាអំពីនេះត្រូវបានអនុញ្ញាតតម្រូវ ឬហាមឃាត់ដោយច្បាប់អន្តរជាតិ (ទស្សនៈច្បាប់

---

[414] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣-១២០។

[415] សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៩១, ៩៥,៩៦ (សម្រេចថា "គោលការណ៍នីត្យានុកូលភាពអន្តរជាតិ ដែលផ្តោតទៅលើការធានានូវការគោរពសិទ្ធិមនុស្សក្នុងនីតិវិធីព្រហ្មទណ្ឌណ គឺជាប់ពាក់ព័ន្ធទៅនឹងគោលការណ៍ទូទៅនៃច្បាប់ស្តីពីការហាមឃាត់ក្នុងការបង្កើតបទល្មើស និងទណ្ឌកម្មដែលមានលក្ខណៈប្រតិសកម្ម"។ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២២។ Cassese *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* ('*Cassese*') (បោះពុម្ពលើកទី២ អុកស្វ៊ដ៖ Oxford University Press ឆ្នាំ២០០៨) ទំព័រ ៣៦-៥១ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥៥។

[416] សំណុំរឿង ០០២-ឯកសារ **D97/15/9** កថាខណ្ឌ ៥៧, ៧៣ (សម្រេចថា ក្នុងករណីដែល ស.ច.ស បានពឹងផ្អែកតែលើយុត្តិសាស្ត្រតុលាការពិសេសដើម្បីកំណត់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ វិធីសាស្ត្របែបនេះ"បានបង្ហាញហេតុផលមិនគ្រប់គ្រាន់ទាក់ទិននឹងបញ្ហានេះ")។ សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៩៧។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Vasiljević* សំណុំរឿងលេខ IT-98-32-T *សាលក្រម* ចុះថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០០២ កថាខណ្ឌ ១៩៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥៦ (សម្រេចថា "មិនអាចទទួលយកបានទាល់តែសោះ [...] ប្រសិនបើផ្តន្ទាទោសជនត្រូវចោទណាម្នាក់ ដោយផ្អែកលើការហាមឃាត់មួយដែលមិនច្បាស់លាស់គ្រប់គ្រាន់អាចកំណត់អំពីអំពើ និងបែងចែកអំពើឧក្រិដ្ឋឲ្យខុសពីអំពើដែលអាចអនុញ្ញាតបាន ឬមិនអាចដឹងបានគ្រប់គ្រាន់ថាមានការហាត់ឃាត់បែបនោះទេ ដោយពិចារណាលើភាពជាក់លាក់នៃ[ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] និងអនុញ្ញាតឲ្យមានការបញ្ជាក់បំភ្លឺជាបន្តបន្ទាប់អំពីវិធានច្បាប់ព្រហ្មទណ្ឌ)"។

[417] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣។

(*opinio juris*) នៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[418]។ ជាពិសេស សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានមើលរំលងលើតម្រូវការក្នុងយល់ដឹងអំពីភ័ស្តុតាងគ្រប់គ្រាន់នៃការអនុវត្តរបស់រដ្ឋ[419]។ ផ្ទុយទៅវិញការរកឃើញច្បាប់ទំនៀមទម្លាប់អន្តរជាតិរបស់គាត់ គឺជាចំណុចបន្ទាប់បន្សំ ដោយសារតែគាត់អនុម័តដោយអកម្មនូវការអះអាងរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានការគាំទ្រនៅក្នុងសេចក្តីសម្រេចតាមផ្លូវតុលាការរបស់តុលាការមិនអចិន្ត្រៃយ៍[420]។ ការពឹងផ្អែកខ្លាំងពេកទៅលើយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ និងការមិនបានពិចារណាទៅលើប្រភពដទៃផ្សេង

---

[418] *រឿងក្តីតំបន់ថ្មសមុទ្រខាងជើង(North Sea Continental Shelf Cases)(សាធារណៈសហព័ន្ធអាល្លឺម៉ង់តទល់នឹងដាណឺម៉ាក់ និងសាធារណៈសហព័ន្ធអាល្លឺម៉ង់តទល់នឹងហុល្លង់)* (“*រឿងក្តីសមុទ្រខាងជើង*”) ឆ្នាំ១៩៦៩ តុលាការព្រហ្មទណ្ឌអន្តរជាតិ ៣ ចុះថ្ងៃទី ២០ ខែកុម្ភៈ ឆ្នាំ ១៩៦៩ កថាខណ្ឌ ៧៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥៧។ សំណុំរឿង ០០២-ឯកសារ **D97/15/9** កថាខណ្ឌ ៥៣ (ដកស្រង់*រឿងក្តីសមុទ្រខាងជើង* កថាខណ្ឌ ៧៧)។ Degan “អំពីប្រភពច្បាប់ព្រហ្មទណ្ឌអន្តរជាតិ” (‘*Degan*’) *ទិន្នានុប្បវត្តិចិនស្តីពីច្បាប់អន្តរជាតិ* ឆ្នាំទី៤ លេខ១ ទំព័រ ៤៥-៨៣, ទំព័រ ៦៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥៨។

[419] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣-១២០។ ស.ច.ស.អ បង្ហាញឲ្យឃើញថាបានអនុវត្តតាមវិធីសាស្ត្ររបស់ អ.ជ.ត.ក ដែលធ្លាប់ព្យាយាមកាត់បន្ថយសារៈសំខាន់នៃការអនុវត្តរបស់រដ្ឋ ដោយគាំទ្រវិធីសាស្ត្រតាមគតិយុត្តក្នុងការបកស្រាយច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៩៣។ វិធីសាស្ត្រនេះដើរចេញពីវិធីសាស្ត្រជាប្រពៃណី និងជាមូលដ្ឋានគ្រឹះរឹងមាំរបស់តុលាការយុត្តិធម៌អន្តរជាតិក្នុងការបកស្រាយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលជាវិធានមួយនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងអំឡុងឆ្នាំ១៩៧៥-ឆ្នាំ១៩៧៩។ លក្ខខណ្ឌតម្រូវសម្រាប់ការអនុវត្តជាទូទៅ និងសង្គតិភាពរបស់រដ្ឋគួរនៅតែសំខាន់សម្រាប់ការបកស្រាយទាំងអស់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចបានបង្ហាញដោយតុលាការព្រហ្មទណ្ឌអន្តរជាតិនៅក្នុង*រឿងក្តីសមុទ្រខាងជើង* កថាខណ្ឌ ៧៧។ ទោះបីជាប្រសិនបើថា វិធីសាស្ត្ររបស់ អ.ជ.ត.ក ក្នុងការកំណត់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ត្រូវចាត់ទុកថាត្រឹមត្រូវក៏ដោយ ក៏មេធាវីការពារក្តី ជំទាស់ថា ស.ច.ស.អ មិនបានបំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ការអនុវត្តត្រឹមត្រូវរបស់រដ្ឋ ដើម្បីគាំទ្រការកំណត់របស់ ស.ច.ស.អ អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែរ។ *សូមមើលផងដែរ* Kok *អាជ្ញាយុកាលនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (‘*Kok*’) (T.M.C. Asser Press ឆ្នាំ២០០៧) ទំព័រ ៣២០-៣២៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៥៩ (ពិភាក្សាអំពីភាពខុសគ្នារវាងវិធីសាស្ត្រតាមគតិយុត្តជាមួយនឹងវិធីសាស្ត្រតាមការអនុវត្តរបស់រដ្ឋ ក្នុងការកំណត់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។

[420] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦២-១២០។ ស.ច.ស.អ ពឹងផ្អែកទាំងស្រុងលើការកំណត់របស់តុលាការពិសេសអំពីច្បាប់ទំនៀមទម្លប់អន្តរជាតិ។ ការពឹងផ្អែកលើយុត្តិសាស្ត្ររបស់តុលារពិសេស ជារឿយៗមិនមែនជាការពឹងផ្អែកដោយផ្ទាល់ទេ ដោយសារថា ស.ច.ស.អ ដកស្រង់យុត្តិសាស្ត្ររបស់ អ.វ.ត.ក ដែលពឹងផ្អែកយ៉ាងខ្លាំងលើតុលាការពិសេសៗ។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣ (កត់សម្គាល់ថា ‘យុត្តិសាស្ត្ររបស់តុលាការពិសេសដែលបានបង្កើតចាប់តាំងពីទស្សវត្សឆ្នាំ១៩៩០ មិនជាប់កាតព្វកិច្ចនៅក្នុងកិច្ចដំណើរការនីតិវិធីនៅចំពោះ អ.វ.ត.ក ទេ ប៉ុន្តែ អង្គជំនុំជម្រះនានានៅ អ.វ.ត.ក បានពឹងផ្អែកយ៉ាងខ្លាំងលើសេចក្តីសម្រេចនានារបស់តុលាការពិសេសទាំងនោះ ពាក់ព័ន្ធនឹងធាតុផ្សំបទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវ’)។

ទៀតរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ទើប*ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* មានសំអាងហេតុមិនគ្រប់គ្រាន់[421]។

168. សេចក្ដីសម្រេចរបស់តុលាការមិនអចិន្ត្រៃយ៍ គឺជាប្រភពដែលមិនត្រឹមត្រូវ នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារមូលហេតុដូចខាងក្រោម៖ (ក) លក្ខន្តិកៈរបស់តុលាការមិនអចិន្ត្រៃយ៍ មិនមែនជាលទ្ធផលនៃការប្រឹក្សាយោបល់របស់រដ្ឋពហុភាគី ហើយមិនបានតំណាងនូវការព្រមព្រៀងជាឯកច្ឆន្ទជាអន្តរជាតិទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិសំខាន់ៗឡើយ[422] (ខ) តុលាការមិនអចិន្ត្រៃយ៍ត្រូវបានបង្កើតឡើង ដើម្បីឆ្លើយតបចំពោះកាលៈទេសៈបរិបទជាក់លាក់ ហើយផ្ដោតទៅលើពេលវេលាក្រោយឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩ ប៉ុណ្ណោះ (គ) តុលាការមិនអចិន្ត្រៃយ៍ប្រកាន់ពីលទ្ធភាពច្បាស់លាស់ក្នុងការងាកចេញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ[423] (ឃ) តុលាការមិនអចិន្ត្រៃយ៍ប្រកាន់យក វិធីសាស្ត្រទស្សនៈច្បាប់ (*opinio juris*) ដើម្បីបកស្រាយច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយច្រានចោលនូវតម្រូវការការអនុវត្តរបស់រដ្ឋ[424] និង (ង) តុលាការមិនអចិន្ត្រៃយ៍មិនស្ថិតក្រោមរចនាសម្ព័ន្ធនីតិបញ្ញត្តិ ឬច្បាប់ជាលាយលក្ខណ៍អក្សរ ដែលបានបង្កើតឡើងច្បាស់លាស់ល្អឡើយ ហេតុដូច្នេះហើយចៅក្រមតែងងាកទៅរក ការឆ្នៃប្រឌិតផ្នែកតុលាការ ដើម្បីបំពេញចន្លោះប្រហោងនៅក្នុងច្បាប់[425]។ សរុបមក តុលាការមិនអចិន្ត្រៃយ៍ មិនមែនជាតំណាងនៃច្បាប់ទំនៀម

---

[421] សំណុំរឿង ០០២-ឯកសារ **D97/15/9** កថាខណ្ឌ ៥៧, ៧៣។ សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៩៧។

[422] Powderly 'ការបកស្រាយតាមតុលាការនៅតុលាការពិសេស៖វិធីសាស្ត្រចេញពីភាពច្របូកច្របល់? នៅក្នុងសៀវភៅរបស់ Darcy & Powderly *ចំណោងជើង ភាពច្នៃប្រឌិតតាមតុលាការនៅសាលាក្ដីព្រហ្មទណ្ឌអន្តរជាតិ* (អុកស្វដ៖ Oxford University Press ឆ្នាំ២០១០) ទំព័រ ២២ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦០ ('ដោយពិនិត្យមើលលក្ខន្តិកៈតុលាការ ជាការត្រឹមត្រូវអាចនិយាយថា វាបង្ហាញពីកិច្ចខិតខំប្រឹងប្រែងយ៉ាងឈ្លាសឈ្លៃរបស់បុគ្គលប៉ុន្មាននាក់')។

[423] *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Duško Tadić* សំណុំរឿងលេខ IT-94-1-A *សាលដីកា* ('*សាលដីកា Tadić*') ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩៩ កថាខណ្ឌ២៩៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦១ (សម្រេចថា 'ជាគោលការណ៍ទូទៅ បទប្បញ្ញត្តិនៃលក្ខន្តិកៈដែលចែងអំពីឧក្រិដ្ឋកម្មនៅក្នុងយុត្តិសាស្ត្ររបស់សាលាក្ដីនេះ គួរត្រូវបកស្រាយជាការឆ្លុះបញ្ចាំងពី[ច្បាប់ទំនៀមទម្លាប់អន្តរជាតិ] ប្រសិនបើ ចេតនាដើរចេញពី[ច្បាប់ទំនៀមទម្លាប់អន្តរជាតិ]មិនមានបង្ហាញនៅក្នុងលក្ខខណ្ឌនៃលក្ខន្តិកៈ ឬពីប្រភពអំណាចផ្សេងទៀត')។

[424] សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៩៣។ Kok ទំព័រ ៣២១-៣២៧ [ភាសាអង់គ្លេស]។

[425] Degan ទំព័រ ៤៨។ Mettraux *ឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការពិសេស* (អុកស្វហ៖ Oxford University Press ឆ្នាំ២០០៦) ទំព័រ ១៦ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦២ ('ការវិវត្តន៍នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងវិស័យនេះជួនកាល

ទម្លាប់អន្តរជាតិ ជាពិសេសនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ហើយដោយមិនមានការស្រាវជ្រាវបន្ថែម មិនគួរជាសំអាងហេតុ និងការពិចារណាជាមធ្យោបាយជំនួស ដែល អ.វ.ត.ក អាចពឹងផ្អែកបានឡើយ។

169. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់យុត្តិកម្មចំពោះការពឹងផ្អែករបស់គាត់ទៅលើតុលាការមិនអចិន្ត្រៃយ៍ ឬមិនបានពិចារណាទៅលើប្រភពអង្គច្បាប់ផ្សេង ដែលអាចឆ្លុះបញ្ចាំងបានប្រសើរជាងទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ជាឧទាហរណ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាត្រួសៗទៅលើច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ។ ផ្ទុយពីតុលាការមិនអចិន្ត្រៃយ៍ សហគមន៍អន្តរជាតិបានចូលរួមក្នុងការតាក់តែងចងក្រងនូវឧក្រិដ្ឋកម្មនានានៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដែលត្រូវបានរដ្ឋជាច្រើនរួមទាំងកម្ពុជាផង បានអនុម័តជាផ្លូវការ[426]។

170. ឧទាហរណ៍នៃកំហុសឆ្គង ដែលកើតចេញពីការកំណត់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺមាននៅគ្រប់សំអាងហេតុទាំងអស់នៃបណ្តឹងសារទុក្ខ ដូចដែលនឹងរៀបរាប់នៅផ្នែកខាងក្រោម។ ទោះជាក្នុងករណីណាក៏ដោយ ក៏ឧទាហរណ៍ទាំងអស់នេះមិនមែនមានត្រឹមប៉ុណ្ណឹងទេ តែឧទាហរណ៍ទាំងនេះគ្រាន់ជាការចង្អុលបង្ហាញនូវវចនាសម្ព័ន្ធដ៏ជ្រៅនៅក្នុងគ្រឹះនៃសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ មេធាវីការពារក្តីអះអាងថា កំហុសឆ្គងលើច្បាប់ទំនៀមទម្លាប់អន្តរជាតិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាំបាច់ត្រូវតែពិនិត្យមើលរួមគ្នា ជាកំហុសឆ្គងរួមទាក់ទងគោលការណ៍នីត្យានុកូលភាព។

## ខ. សំអាងហេតុទី៩÷ សហឧក្រិដ្ឋកម្មរួមមិនមែនជា ទម្រង់នៃការទទួលខុសត្រូវ ដែលអាចអនុវត្តបាននៅ អ.វ.ត.ក ឡើយ

171. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការដែលគាត់ ពឹងផ្អែករបស់គាត់ទៅលើ

---

បានវិវត្តទៅមុខដោយប៉ះពាល់ការធានាមួយចំនួនក្នុងចំណោមការធានាជាសារវ័ន្តដោយសារជនត្រូវចោទ ហើយគោលការណ៍នីត្យានុកូលភាពជួនកាលប្រហែលជាមិនបានទប់ស្កាត់ភាពច្នៃប្រឌិតតាមផ្លូវតុលាការទេ')។

[426] ភាគី និងហត្ថលេខីនៃលក្ខន្តិកៈទីក្រុងរ៉ូម ទំព័រ ២ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦៣។

សហឧក្រិដ្ឋកម្មរួម ថាជាទម្រង់នៃការទទួលខុសត្រូវ។ សហឧក្រិដ្ឋកម្មរួមមិនមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវឡើយ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬច្បាប់កម្ពុជា នៅអំឡុងឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩។

172. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានផ្តល់ភស្តុតាងអំពីការអនុវត្តរបស់រដ្ឋជាទ្រង់ទ្រាយធំ និងស៊ីសង្វាក់គ្នា ដើម្បីបង្ហាញថាសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបានតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ សហឧក្រិដ្ឋកម្មរួមគឺផ្អែកទៅលើ ទ្រឹស្តីច្បាប់ខំមិនឡ (common law)[427] ហើយត្រូវបានបង្កើតតាមផ្លូវតុលាការ នៅតុលាការ ICTY ដើម្បីដោះស្រាយកាលៈទេសៈពិសេស ដែលតុលាការនេះបានជួបប្រទះ[428]។ លិខិតុបករណ៍ដែលតុលាការ ICTY បានពឹងផ្អែក សម្រាប់ជាយុត្តិកម្មបង្កើតសហឧក្រិដ្ឋកម្មរួម[429] និងលិខិតុបករណ៍ទាំងនោះ ដែល អ.វ.ត.ក បានពឹងផ្អែកនាពេលក្រោយមក[430] គឺមានចំនួនតិចតួចបំផុត ហើយមិនសំខាន់ទាល់តែសោះ ដែលមិនអាចបំពេញបានតាមលក្ខខណ្ឌតម្រូវរបស់តុលាការយុត្តិធម៌អន្តរជាតិ សម្រាប់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ[431]។

173. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពិចារណាពីភស្តុតាងដែលចងកាតព្វកិច្ច អំពីការអនុវត្តរបស់រដ្ឋ ដែលមានលក្ខណៈទូលំទូលាយនិងស៊ីសង្វាក់គ្នា ដែលចង្អុលបង្ហាញថា សហឧក្រិដ្ឋកម្មរួម គឺមិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ។ អ្វីដែលគួរឲ្យកត់សម្គាល់បំផុតនោះ គឺ សហគមន៍អន្តរជាតិមិនបានទទួលស្គាល់ អំពីអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ថាជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមឡើយ[432]។ ជាពិសេសទ្រឹស្តីរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនៃសហ

---

[427] Guilfoyle ‘ការទទួលខុសត្រូវចំពោះអំពើឃោរឃៅសមូហភាព៖ ការកំណត់ត្រឹមត្រូវ និងរបៀបប្រព្រឹត្តនៅក្នុងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ’ (‘*Guilfoyle*’) លេខ ៦៤ *បញ្ហាច្បាប់បច្ចុប្បន្ន* (ឆ្នាំ២០១១) ទំព័រ ២៥៥-៨៦ ទំព័រ ២៦៤ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦៤។

[428] *សាលដីកា Tadić* កថាខណ្ឌ ១៨៩-១៩៣ (សម្រេចថា ការបង្កើតសហឧក្រិដ្ឋកម្មរួម ‘ត្រូវបានកំណត់តាមគោលដៅ និងគោលបំណងនៃលក្ខន្តិកៈ’)។

[429] ឧទាហរណ៍ *សាលដីកា Tadić* កថាខណ្ឌ ១៩៥-២២៩។

[430] ឧទាហរណ៍ សំណុំរឿង ០០២-ឯកសារ **D97/15/9** កថាខណ្ឌ ៣៦-៨៩។

[431] *រឿងក្តីសមុទ្រខាងជើង* កថាខណ្ឌ ៧៧។

[432] *សេចក្តីសម្រេចរឿងក្តី Lubanga អំពីការបញ្ជាក់ពីបទចោទ* កថាខណ្ឌ ៣៣៥-៣៤១។

ចារីភាព គឺជាទម្រង់នៃការទទួលខុសត្រូវមួយផ្សេង ដែលគេអាចពឹងផ្អែកទៅលើបាននៅ អ.វ.ត.ក[433]។សហចារីភាពមានភាពស្របគ្នាជាងជាមួយប្រព័ន្ធច្បាប់ស៊ីវិលឡ (Civil Law)[434] ហើយត្រូវបានកំណត់និយមន័យយ៉ាងច្បាស់នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម[435] ហើយលក្ខខណ្ឌតម្រូវនៃការចូលរួមចំណែកដ៏សំខាន់ គឺតម្រូវឱ្យមានការវាយតម្លៃដោយសត្យានុម័តថា ចារីមានកម្រិតការគ្រប់គ្រងយ៉ាងទាបបំផុតទៅលើការប្រព្រឹត្តឧក្រិដ្ឋកម្ម[436]។ ជាលទ្ធផល សហចារីភាពធានានូវ កម្រិតកំណត់អប្បបរមាដែលខ្ពស់ជាង សហឧក្រិដ្ឋកម្មរួម សម្រាប់ការទទួលខុសត្រូវជាបុគ្គល ហើយបានគូសវៀសនូវខ្សែបន្ទាត់បែងចែកច្បាស់ជាង រវាងការទទួលខុសត្រូវជាចារី ដែលខុសពីការទទួលខុសត្រូវជាអ្នកសមគំនិត។ កម្រិតកំណត់អប្បបរមាដែលខ្ពស់ជាងដែលតម្រូវដោយសហចារីភាពនេះ គឺស្របគ្នាជាងជាមួយគោលដៅ និងគោលបំណងរបស់ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដើម្បីជំនុំជម្រះតែបុគ្គលណា ដែលទទួលខុសត្រូវខ្ពស់បំផុតប៉ុណ្ណោះ។

174. យ៉ាងហោចណាស់ វានៅមិនមានការសម្រេចច្បាស់លាស់ថាតើ សហឧក្រិដ្ឋកម្មរួម ឬសហចារីភាពរបស់ តុលាការព្រហ្មទណ្ឌអន្តរជាតិ មានលក្ខណៈតំណាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិជាង ឬយ៉ាងណា[437]។ ក្នុងករណីដែលមានភាពមិនប្រាកដប្រជាទាក់ទិននឹងច្បាប់ទំនៀមទម្លាប់អន្តរជាតិ

---

[433] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៥(៣)(ក)។ *សេចក្តីសម្រេចរឿងក្តី Lubanga អំពីការបញ្ជាក់ពីបទចោទ* កថាខណ្ឌ ៣២២-៣៣៨។

[434] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Katanga និង Chui* សំណុំរឿងលេខ ICC-01/04-01/07 *សេចក្តីសម្រេចអំពីការបញ្ជាក់ពីបទចោទ* (‘*សេចក្តីសម្រេចរឿងក្តីKatanga អំពីការបញ្ជាក់ពីបទចោទ*’) ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៨ កថាខណ្ឌ ៤៨៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦៥ (ពិភាក្សាអំពីសហចារី ដូចដែលមានការជំរុញយ៉ាងច្រើនពីស្នាដៃរបស់អ្នកសិក្សាស្រាវជ្រាវអាល្លឺម៉ង់ឈ្មោះ Claus Roxin ហេតុនេះហើយជាគោលការណ៍ទ្រឹស្តីមួយដែលមានដើមកំណើតនៅក្នុងច្បាប់ស៊ីវិល)។

[435] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៥(៣)(ក)។

[436] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Abu Garda* សំណុំរឿងលេខ ICC-02/05-02/09 *សេចក្តីសម្រេចអំពីការបញ្ជាក់ពីបទចោទ* ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌ ១៦០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦៦។ *សេចក្តីសម្រេចរឿងក្តី Lubanga អំពីការបញ្ជាក់ពីបទចោទ* កថាខណ្ឌ ៣៤២-៤៨ ។ Guilfoyle ទំព័រ ២៦៥ [ភាសាអង់គ្លេស]។

[437] Shahabuddeen ‘ភាពច្នៃប្រឌិតតាមតុលាការ និងសហឧក្រិដ្ឋកម្មរួម’ នៅក្នុងសៀវភៅរបស់ Darcy & Powderly ចំណងជើង *ភាពច្នៃប្រឌិតតាមតុលាការនៅសាលាក្តីព្រហ្មទណ្ឌអន្តរជាតិ* (អុកស្វដ៖ Oxford University Press ឆ្នាំ២០១០) ទំព័រ ១៩០ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦៧ (បញ្ជាក់ថា ទាំងអំពើជាសហចារី ទាំងសហឧក្រិដ្ឋកម្ម មិនមែនជាច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ ប៉ុន្តែ ‘តុលាការ ICTY បានជ្រើសយក[សហឧក្រិដ្ឋកម្មរួម] ទោះបីថាមានមូលដ្ឋាននៅក្នុងអំពើសហចារីផងដែរក៏ដោយ’)។

ដែលនៅជាធរមាននោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិចាំបាច់ត្រូវតែអនុវត្តច្បាប់ ដែលផ្តល់ជាប្រយោជន៍ដល់ជនជាប់ចោទ។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការពឹងផ្អែកលើសហឧក្រិដ្ឋកម្មរួមជាទម្រង់នៃការទទួលខុសត្រូវក្នុងសំណុំរឿងនេះ។

**គ. សំអាងហេតុទី១០÷ ប្រសិនបើសហឧក្រិដ្ឋកម្មរួម គឺជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានកំណត់និយមន័យឲ្យបានគ្រប់គ្រាន់ និងមិនបានអនុវត្តលក្ខខណ្ឌរបស់សហឧក្រិដ្ឋកម្មរួមឲ្យបានគ្រប់គ្រាន់**

175. ដោយសារការកំណត់និយមន័យ និងការអនុវត្តន៍សហឧក្រិដ្ឋកម្មរួម ក្នុងលក្ខណៈទូលំទូលាយជ្រុលពេក គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានកំណត់និយមន័យឲ្យច្បាស់លាស់នូវក្រុមសហឧក្រិដ្ឋកម្មរួម ហើយពង្រីកដោយខុសឆ្គងនូវវិសាលភាពភូមិសាស្ត្ររបស់សហឧក្រិដ្ឋកម្មរួម និងដាក់បញ្ចូលគ្នានូវគោលបំណងរួមផ្សេងៗគ្នារបស់ក្រុមសហឧក្រិដ្ឋកម្មរួមជាច្រើនក្រុម[438]។ ទីមួយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានរៀបរាប់ក្រុមសហឧក្រិដ្ឋកម្មរួមថា "តា ពក, អោ អាន និងកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាដទៃទៀត បានដឹងអំពីគោលបំណងរួមនៃការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា [...] នៅភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ"[439]។ ការរៀបរាប់នេះ ជាពិសេសភាពមិនច្បាស់លាស់នៃពាក្យ "កម្មាភិបាលបក្សកុម្មុយនីស្តដទៃទៀត"

---

[438] *សាលដីកា Brđanin* កថាខណ្ឌ ៤៣០ ('នៅក្នុងបញ្ជាក់ពី[ធាតុផ្សំនៃសហឧក្រិដ្ឋកម្ម] អង្គជំនុំជម្រះ ក្នុងចំណោមបញ្ហាផ្សេងទៀត ត្រូវ៖ បង្ហាញពីចំនួនពហុនៃអ្នកចូលរួមសហឧក្រិដ្ឋកម្មរួម(ទោះបីជាថាមិនចាំបាច់បង្ហាញឈ្មោះមនុស្សម្នាក់ៗដែលជាប់ពាក់ព័ន្ធក៏ដោយ) បញ្ជាក់ពីគោលបំណងឧក្រិដ្ឋកម្មរួម ពាក់ព័ន្ធនឹងចេតនាគោលដៅឧក្រិដ្ឋ និងវិសាលភាព(ឧទាហរណ៍ ដែនកំណត់ពេលវេលា និងភូមិសាស្ត្រនៃគោលដៅនោះ ព្រមទាំងអត្តសញ្ញាណទូទៅនៃគោលដៅជនរងគ្រោះ) រកឲ្យឃើញថា គោលបំណងឧក្រិដ្ឋនេះមិនមែនត្រឹមតែជាគោលបំណងដូចគ្នាប៉ុណ្ណោះទេ ប៉ុន្តែក៏ជាគោលបំណងរួមសម្រាប់ជនទាំងអស់ដែលធ្វើសកម្មភាពរួមគ្នានៅក្នុង[សហឧក្រិដ្ឋកម្មរួម] ហើយកំណត់ពីការចូលរួមចំណែករបស់ជនត្រូវចោទនៅក្នុងផែនការរួមនេះ')។ រឿងក្តី*Nizeyimana តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-00-55C-A *សាលក្រម* ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០១៤ កថាខណ្ឌ ៣២៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦៨។ *សូមមើលផងដែរ* Fry *គម្រោងនៃការចោទប្រកាន់អន្តរជាតិ* (ទីក្រុងឡាអេ៖ អន្តរជាតិលើកទី១១ ឆ្នាំ២០១៥) ទំព័រ ៣៧-៨០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៦៩ (ពិភាក្សាអំពីលក្ខខណ្ឌតម្រូវច្បាប់សម្រាប់ការចោទបញ្ជូនទៅជំនុំជម្រះនៅតុលាការ និងសាលាក្តីអន្តរជាតិ ព្រមទាំងសារៈសំខាន់នៃភាពជាក់លាក់)។

[439] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៩៥។

គឺមិនបានកំណត់អត្តសញ្ញាណនៃក្រុមដែលមានមុខងារឡើយ[440]។ មានភាពមិនច្បាស់លាស់ថាតើក្រុមនេះពង្រីកវិសាលភាពឆ្ងាយកម្រិតណា ទាំងថ្នាក់លើ និងថ្នាក់ក្រោមនៃខ្សែសង្វាក់បញ្ជា ឬនរណាគឺជាអ្នកចូលរួមសំខាន់របស់ក្រុមនេះ[441]។

176. ទីពីរ វិសាលភាពភូមិសាស្ត្រនៃសហឧក្រិដ្ឋកម្មរួមមិនបានឆ្លុះបញ្ចាំងដល់ឧក្រិដ្ឋកម្ម ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានបញ្ជូន អោ អាន ទៅជំនុំជម្រះទេ[442]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរៀបរាប់អំពីគោលបំណងរួម ក្នុងការអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជា នៅទូទាំងភូមិភាគកណ្តាលទាំងមូល[443]។ ប៉ុន្តែឧក្រិដ្ឋកម្មដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានដាក់បន្ទុកទៅលើ អោ អាន តាមរយៈការទទួលខុសត្រូវ សហឧក្រិដ្ឋកម្មរួមទម្រង់ទី១ គឺ

---

[440] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krajišnik* សំណុំរឿងលេខ IT-00-39-A *សាលដីកា* (‘*សាលដីកា Krajišnik*’) ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ១៥៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧០ (សម្រេចថា ‘ត្រង់ចំណុចដែលអង្គជំនុំជម្រះសាលាដំបូងបានបញ្ចូលជន នានាទៅក្នុងសហឧក្រិដ្ឋកម្មរួមដោយគ្រាន់តែយោងលើមន្ត្រីធម្មតាដែលចូលរួមសហឧក្រិដ្ឋកម្មរួម “រួមមានអ្នកនយោបាយ មេបញ្ជាការយោធា មេបញ្ជាការនគរបាល និងមេដឹកនាំទាហានប៉ារ៉ាទៅមូលដ្ឋាន និងអ្នកផ្សេងទៀត”នោះ ការកំណត់អត្តសញ្ញាណរបស់អង្គជំនុំជម្រះសាលាដំបូងអំពីសមាជិកសហឧក្រិដ្ឋកម្មរួមទាំងនេះ មានលក្ខណៈមិនច្បាស់លាស់មិនអាចទទួលយកបានទេ’)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stanišić and Simatović* សំណុំរឿងលេខ IT-03-69-A *សាលដីកា* (‘សាលដីកា *Stanišić និង Simatović*’) ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥ កថាខណ្ឌ ៨៦-៨៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧១។

[441] ស.ច.ស.អ ទទួលស្គាល់ថា របបខ្មែរក្រហមបានដំណើរការជារចនាសម្ព័ន្ធឋានានុក្រមតឹងរឹង ដោយមានប្រព័ន្ធរាយការណ៍តាមខ្សែបណ្តោយ។ ពាក្យថា “គម្មាភិបាល ប.ក.ក ផ្សេងទៀត”ជាពាក្យទូទៅពេកមិនអាចឲ្យច្បាស់លាស់ថាតើការចោទប្រកាន់អំពីសហឧក្រិដ្ឋកម្មមាននៅត្រឹមកម្រិតណា ឬថាតើពាក្យនេះមានមុខងារយ៉ាងណានៅក្នុងប្រព័ន្ធនេះ។ ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៥៧, ២៥៧, ៦២៣។

[442] *សាលដីកា Stanišić និង Simatović* កថាខណ្ឌ ៨២-៨៨ (‘ការកំណត់អំពីអត្ថិភាព និងវិសាលភាពនៃគោលបំណងឧក្រិដ្ឋរួមដែលចូលរួមដោយជនច្រើននាក់(រួមមានដែនកំណត់ភូមិសាស្ត្រ និងពេលវេលា)គឺជាបុរេលក្ខខណ្ឌចាំបាច់’ ហើយ‘ការពិចារណារបស់អង្គជំនុំជម្រះសាលាដំបូងអំពីគោលបំណងឧក្រិដ្ឋរួម និងចំនួនជនច្រើននាក់តាមការចោទប្រកាន់នៅក្នុងដីកាបញ្ជូនទៅជំនុំជម្រះ មិនបង្ហាញឲ្យឃើញថា អាចមានលទ្ធភាពថា [...] តាមធាតុផ្សំចេតនារបស់ Stanišić's និង Simatović អាចមានគោលបំណងឧក្រិដ្ឋដែលមានវិសាលភាពពេលវេលា និង/ឬភូមិសាស្ត្រកាន់តែតូច ឬចំនួនអ្នកចូលរួមសហឧក្រិដ្ឋកម្មរួមកាន់តែតិចនោះទេ’)។ *សាលដីកា Krajišnik* កថាខណ្ឌ ១៥៧ (សម្រេចថា ‘ការយោងលើវិសាលភាពភូមិសាស្ត្រ (“តំបន់ និងទីក្រុងនៅសាធារណរដ្ឋប៊ូស្នៀស៊ើប គឺទូទៅពេកមិនអាចឲ្យច្បាស់លាស់ថាតើនរណាដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាជាសមាជិកធម្មតានៅក្នុងសហឧក្រិដ្ឋកម្មរួមទេ’)។

[443] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៩៥។

ទាក់ទងតែទៅនឹងតំបន់៤១ប៉ុណ្ណោះ[444]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់ភ័ស្តុតាងគ្រប់គ្រាន់ថា អោ អាន បានចូលរួម មានចេតនាប្រព្រឹត្ត ឬបានរួមចំណែកយ៉ាងសំខាន់ដល់ឧក្រិដ្ឋកម្មនៅក្នុងតំបន់៤២ និងតំបន់៤៣ ឬថាឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្រៅតំបន់៤១ អាចដាក់បន្ទុកចំពោះក្រុមសហឧក្រិដ្ឋកម្មរួមបាន[445]។ ហេតុដូច្នេះ ការរៀបរាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីសហឧក្រិដ្ឋកម្មរួម ថាបានដំណើរការនៅទូទាំងភូមិភាគកណ្តាល គឺមិនបានឆ្លុះបញ្ចាំងអំពីអង្គហេតុ និងឧក្រិដ្ឋកម្មដែលបានរៀបរាប់នៅក្នុង*ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ*ឡើយ។

177. ទីបី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរួមបញ្ចូលនូវគោលបំណងរួមផ្សេង របស់ក្រុមសហឧក្រិដ្ឋកម្មរួមដទៃ[446]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានកំណត់និយមន័យគោលបំណងរួមរបស់សហឧក្រិដ្ឋកម្មរួមថា "ការអនុវត្តគោលនយោបាយ បក្សកុម្មុយនីស្តកម្ពុជាដូចខាងក្រោម នៅភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ"[447]។ ដោយសារការកំណត់ដូច្នេះ គឺសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរួមបញ្ចូលនូវគោលបំណងរួមរបស់៖ (ក) មេដឹកនាំជាន់ខ្ពស់របស់បក្សកុម្មុយនីស្តកម្ពុជាដែលរៀបចំគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ដូចបានបង្ហាញនៅក្នុងសំណុំរឿង ០០២[448] ជាមួយនឹង (ខ) សហឧក្រិដ្ឋកម្មរួមដែល អោ អាន ត្រូវបានចោទប្រកាន់ថាស្ថិតនៅក្នុងនោះ[449]។ ជាលទ្ធផល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពឹងផ្អែកជ្រុលពេលទៅលើភ័ស្តុតាងនៃ

---

[444] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣២០-៥៩៦, ៦៣៨-៦៥៥, ៦៧៨-៦៩៦។

[445] ស.ច.ស.អ ចោទប្រកាន់បញ្ជូន អោ អាន ទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍នៅតំបន់ ៤២ និង ៤៣ ប៉ុន្តែ អំពើបែបនេះតាមផ្លូវច្បាប់មិនអាចចាត់ទុកថាកើតឡើងដោយសារ អោ អាន តាមរយៈទម្រង់នៃការទទួលខុសត្រូវ ដូចជា សហឧក្រិដ្ឋកម្មរួម បានទេ។ *សូមមើល* មូលដ្ឋានទី ៧ ផ្នែក II (ច)(iii)។

[446] *សាលដីកាTadić* កថាខណ្ឌ ២២៧ (សម្រេចថា សហឧក្រិដ្ឋកម្មរួម តម្រូវឱ្យមាន'អត្ថិភាពនៃផែនការ ការរៀបចំ និងគោលបំណងរួមដែលស្មើនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម ឬពាក់ព័ន្ធនឹងការប្រព្រឹត្តិឧក្រិដ្ឋកម្ម')។ *សាលដីកា Stanišić និង Simatović* កថាខណ្ឌ ៨២, ៨៨-៨៩ (សម្រេចថា អង្គជំនុំជម្រះសាលាដំបូង មានកំហុសអង្គច្បាប់ ដោយមិនបានវិភាគថាហេតុដូចម្តេចបានជាភស្តុតាង និងអង្គហេតុបញ្ជាក់ពីអត្ថិភាព និងវិសាលភាពនៃគោលបំណងឧក្រិដ្ឋរួមដែលចូលរួមដោយជនច្រើននាក់)។

[447] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៩៥។

[448] សំណុំរឿង ០០២-**E313** កថាខណ្ឌ ៧២៤, ៧៧៧, ៨០៤, ៨៣៥។ សំណុំរឿង ០០២/១៩-០៩-២០០៧/អវតក/អជសដ *សាលក្រមសង្ខេប* ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០១៨ កថាខណ្ឌ ៦, ៤២-៤៣, ៤៥-៤៧, ៤៩, ៥៦-៥៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧២។

[449] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៩៥។

គោលបំណងរួម និងចេតនាក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មដែលកើតចេញពីសហឧក្រិដ្ឋកម្មរួមក្នុងសំណុំរឿង០០២ ដើម្បីបំពេញនូវលក្ខខណ្ឌតម្រូវគតិយុត្តនៃសហឧក្រិដ្ឋកម្មរួមនៅក្នុងសំណុំរឿង ដែលស្ថិតក្នុងដៃនេះ[450]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានកំណត់ដោយគ្រប់គ្រាន់ និងមិនបានអនុវត្តគ្រប់គ្រាន់នូវលក្ខខណ្ឌនៃសហឧក្រិដ្ឋកម្មរួមទាក់ទង អោ អាន ឡើយ។

## ឃ. សំអាងហេតុទី១១÷ ការរៀបចំផែនការ គឺមិនមែនជាទម្រង់នៃការទទួលខុសត្រូវជាធរមាន នៅ អ.វ.ត.ក ឡើយ

178. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទៅលើយុត្តិសាស្ត្រខុសឆ្គង របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការអនុវត្តន៍ការរៀបចំផែនការ ថាជាទម្រង់នៃការទទួលខុសត្រូវ[451]។ អង្គជំនុំជម្រះសាលាដំបូងពឹងផ្អែកជាសំខាន់ ទៅលើយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ ហើយមិនបានផ្តល់ភ័ស្តុតាងនៃការអនុវត្តរបស់រដ្ឋ ជាទ្រង់ទ្រាយធំទូលាយនិងស៊ីសង្វាក់គ្នា ដើម្បីសម្រេចថា ការរៀបចំផែនការ គឺជាទម្រង់នៃការទទួលខុសត្រូវជាធរមាន តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ឡើយ[452]។

179. ការរៀបចំផែនការមិនមានអត្ថិភាពជាទម្រង់នៃការទទួលខុសត្រូវ នៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ នៅក្នុងអំឡុងរយៈពេលនោះ។ ឧទាហរណ៍ បើទោះបីជាការរៀបចំផែនការ ឬការរៀបចំ សង្គ្រាមឈ្លានពាន ត្រូវបានកំណត់លក្ខណៈជាឧក្រិដ្ឋកម្ម តាមមាត្រា៦(ក) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិទីក្រុងនូរឹមប៊ែក (Nuremberg) និងមាត្រា ៥(ក) នៃធម្មនុញ្ញតុលាការយោធាអន្តរជាតិទីក្រុងតូក្យូក្តី តែការកំណត់នេះកម្រិតត្រឹមតែឧក្រិដ្ឋកម្មប្រឆាំងសន្តិភាពប៉ុណ្ណោះ គឺមិនបានពង្រីកទៅដល់ឧក្រិដ្ឋកម្មដទៃទៀតនៅក្នុងយុត្តាធិការរបស់តុលាការយោធាអន្តរជាតិទាំង

[450] ឧទាហរណ៍ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៩៥-២៣២។ នៅពេលដែលពិភាក្សាអំពីអត្ថិភាពគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ស.ច.ស.អ ជាទូទៅពឹងផ្អែកលើភស្តុតាងពីគោលនយោបាយជាទូទៅរបស់ ប.ក.ក ជាជាងបញ្ជាក់ពីអត្ថិភាព និងវិសាលភាពជាក់ស្តែងនៃគោលបំណងរួមក្នុងចំណោមសមាជិកសហឧក្រិដ្ឋកម្មរួមដែលត្រូវបានចោទនៅក្នុងសំណុំរឿងនេះ។

[451] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១០១។

[452] សំណុំរឿងលេខ ០០១/១៨-០៧-២០០៧/អវតក/អជសដ *សាលក្រម* ឯកសារ **E188** ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ៥១៨-៥១៩។ សំណុំរឿង ០០២-ឯកសារ **E313** កថាខណ្ឌ ៦៩៧-៦៩៨។

ពីរនេះឡើយ[453]។ ស្រដៀងគ្នានេះដែរអនុសញ្ញាស្តីពីអំពីប្រល័យពូជសាសន៍ មិនបានយោងទាល់តែសោះអំពីការរៀបចំផែនការ[454]។ លក្ខន្តិកៈទីក្រុងរ៉ូមក៏មិនមានចែងផងដែរ អំពីការរៀបចំផែនការ ឬការរៀបចំ ថាជាទម្រង់នៃការទទួលខុសត្រូវសម្រាប់ឧក្រិដ្ឋកម្មសង្គ្រាម ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ឡើយ[455]។ ហេតុដូច្នេះ ការដាក់បញ្ចូលការរៀបចំផែនការ ជាទម្រង់នៃការទទួលខុសត្រូវនៅក្នុង*ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* គឺជាកំហុសអង្គច្បាប់ ដោយសារតែមិនមានភ័ស្តុតាងថា បញ្ហានេះមានអត្ថិភាពនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ទេ។

## ខ. សំអាងហេតុទី១២៖ ការទទួលខុសត្រូវរបស់ថ្នាក់លើ គឺមិនមែនជាទម្រង់នៃការទទួលខុសត្រូវជាធរមាន នៅក្នុងសំណុំរឿង អោ អាន ឡើយ ហើយបើទោះបីជាជាទម្រង់នៃការទទួលខុសត្រូវជាធរមានក្តី ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុវត្តដោយមិនត្រឹមត្រូវនូវធាតុផ្សំគតិយុត្តិ

180. ជាដំបូង សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសឆ្គងក្នុងសំណុំរឿងនេះដោយពឹងផ្អែកលើការទទួលខុសត្រូវរបស់ថ្នាក់លើថាជា ទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន តាមច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩[456]។ ទោះបីជា អ.វ.ត.ក បានសម្រេចក្នុងពេលកន្លងមកថា ការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តចំពោះមេបញ្ជាការស៊ីវិលក្តី ការសម្រេចបែបនេះមិនបានផ្តល់ឲ្យបានគ្រប់គ្រាន់នូវភ័ស្តុតាង ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្នុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ ដែលគាំទ្រដល់ភាពអាចអនុវត្តបាននៃ ការទទួលខុសត្រូវរបស់ថ្នាក់លើ

[453] Cryer *និងអ្នកផ្សេងទៀត សេចក្តីណែនាំអំពីនីតិវិធី និងច្បាប់ព្រហ្មទណ្ឌអន្តរជាតិ* (*'Cryer និងអ្នកផ្សេងទៀត'*) (បោះពុម្ពលើកទី ៣ ខេមប្រ៊ីជ៖ Cambridge University Press ឆ្នាំ២០១៤) ទំព័រ ៣៧៩-៣៨០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧៣(ពិភាក្សាអំពីការរៀបចំផែនការជាទម្រង់នៃការទទួលខុសត្រូវនៅសាលាក្តីយោធាអន្តរជាតិ)។

[454] អនុសញ្ញាស្តីពីការបង្ការ និងការផ្តន្ទាទោសចំពោះបទឧក្រិដ្ឋប្រល័យពូជសាសន៍ 78 UNTS 277 ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ ១៩៤៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧៤។

[455] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៥។

[456] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១០៤-០៩។

ដែលអាចអនុវត្តបានចំពោះមេបញ្ជាការស៊ីវិល *នៅក្រៅ*ជម្លោះប្រដាប់អាវុធអន្តរជាតិ[457]។ ហេតុដូច្នេះ ការចោទប្រកាន់ទៅលើជនស៊ីវិលតាមការទទួលខុសត្រូវរបស់ថ្នាក់លើ ចាំបាច់ត្រូវមានទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិ។ ការបញ្ជូន អោ អាន ទៅជំនុំជម្រះតាមការទទួលខុសត្រូវរបស់ថ្នាក់លើ ក្នុងនាមជាមេដឹកនាំស៊ីវិល នៅក្រៅបរិបទនៃជម្លោះប្រដាប់អាវុធអន្តរជាតិ ជាការរំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាព។

181. ទីពីរ បើទោះបីជាការទទួលខុសត្រូវរបស់ថ្នាក់លើអាចអនុវត្តបានក្តី ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុវត្តដោយខុសឆ្គងនូវធាតុផ្សំគតិយុត្តិចំពោះទម្រង់នៃការទទួលខុសត្រូវនេះ[458]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកទាំងស្រុងតែទៅលើយុត្តិសាស្ត្ររបស់តុលាការមិនអចិន្ត្រៃយ៍ ដើម្បីច្រានចោលនូវលក្ខខណ្ឌតម្រូវហេតុនិងផល[459]។ ទោះជាយ៉ាងនេះក្តី អត្ថិភាពនៃលក្ខខណ្ឌតម្រូវហេតុនិងផល ត្រូវបានគាំទ្រដោយភស្តុតាង នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ (ជាទូទៅអាចអនុវត្តបានចំពោះការទទួលខុសត្រូវរបស់ថ្នាក់លើ) ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានគិតពិចារណា[460]។ ទីពីរសហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុវត្តធាតុផ្សំអត្តនោម័ត

[457] ឧទាហរណ៍ សំណុំរឿង ០០២ ឯកសារ-**D427/2/15** កថាខណ្ឌ ១៩០-២៣២។ សំណុំរឿង ០០២ ឯកសារ-**D427/1/30** កថាខណ្ឌ ៤១៣-៤៦០។ សំណុំរឿង ០០១ ឯកសារ-**E188** កថាខណ្ឌ ៤៧៦-៤៧៧។ សំណុំរឿង ០០២ ឯកសារ-**E313** កថាខណ្ឌ ៧១៨-៧១៩។

[458] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១០៤-០៩។

[459] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១០៥ (យល់ឃើញថា 'យោងតាមយុត្តិសាស្ត្ររបស់សាលាក្តីពិសេស មិនចាំបាច់ត្រូវបញ្ជាក់ពីទំនាក់ទំនងហេតុផលរវាងការខកខានរបស់ថ្នាក់លើក្នុងការបង្ការឧក្រិដ្ឋកម្មរបស់ថ្នាក់ក្រោម ជាមួយនឹងការកើតឡើងនូវឧក្រិដ្ឋកម្មទាំងនេះទេ')។

[460] ពិធីសារ I បន្ថែមលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ ១៩៤៩ និងពាក់ព័ន្ធនឹងការការពារជនរងគ្រោះដោយសារជម្លោះប្រដាប់អាវុធអន្តរជាតិ 1125 UNTS 3 ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ១៩៧៧ មាត្រា ៨៦(១) ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧៥ (បញ្ជាក់ថា 'រដ្ឋភាគី និងភាគីនៅក្នុងជម្លោះ ត្រូវបង្ក្រាបការរំលោភបំពានធ្ងន់ធ្ងរ ហើយចាត់វិធានការដែលចាំបាច់ដើម្បីបង្ក្រាបការរំលោភបំពានផ្សេងទៀតទៅលើអនុសញ្ញានេះ ឬពិធីសារនេះ ដែលកើតឡើងដោយសារការខកខានមិនបានធ្វើសកម្មភាពនៅពេលដែលត្រូវស្ថិតនៅក្នុងករណីយកិច្ចត្រូវធ្វើបែបនេះ')។ លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៨ ('ចំពោះទំនាក់ទំនងរវាងថ្នាក់លើជាមួយនឹងថ្នាក់ក្រោម [...] ថ្នាក់លើត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះឧក្រិដ្ឋកម្មស្ថិតនៅក្នុងយុត្តាធិការរបស់តុលាការដែលបានប្រព្រឹត្តឡើងដោយថ្នាក់ក្រោមស្ថិតនៅក្រោមការគ្រប់គ្រង និងអំណាចជាក់ស្តែងរបស់គាត់ ដោយសារគាត់ខកខានមិនបានអនុវត្តការគ្រប់គ្រងឲ្យបានត្រឹមត្រូវលើថ្នាក់ក្រោមបែបនោះ')។

មិនត្រឹមត្រូវសម្រាប់ការទទួលខុសត្រូវរបស់ថ្នាក់លើ[461] ដោយមិនពិចារណាលើភ័ស្តុតាងនៃលក្ខខណ្ឌតម្រូវអប្បបរមាដែលខ្ពស់ជាងចំពោះធាតុផ្សំអត្តនោម័តសម្រាប់មេបញ្ជាការស៊ីវិល តាមលក្ខន្តិកៈទីក្រុងរ៉ូម[462]។ មេធាវីការពារក្តីសូមរំឭកថា ក្នុងករណីមានវិមតិសង្ស័យទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចាំបាច់ត្រូវតែអនុវត្តដដែលជាប្រយោជន៍ដល់ជនជាប់ចោទ។

## ច. សំអាងហេតុទី១៣÷ អ.វ.ត.ក មិនមានយុត្តាធិការក្នុងការជំនុំជម្រះឧក្រិដ្ឋកម្មជាតិដែលបានប្រព្រឹត្តចន្លោះពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩

182. អ.វ.ត.ក មិនមានយុត្តាធិការជំនុំជម្រះ អោ អាន ពីបទឧក្រិដ្ឋកម្មអំពើមនុស្សឃាតគិតទុកមុន តាមក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ របស់កម្ពុជាឡើយ ដោយសារតែអាជ្ញាយុកាលសម្រាប់ការជំនុំជម្រះឧក្រិដ្ឋកម្មជាតិដែលបានប្រព្រឹត្ត នៅអំឡុងឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩ បានកន្លងផុតទៅហើយ[463]។ សហព្រះរាជអាជ្ញាអន្តរជាតិ បានយល់ស្របជាមួយមេធាវីការពារក្តីថា មិនគួរបញ្ជូន អោ អាន ទៅជំនុំជម្រះពីបទឧក្រិដ្ឋកម្មជាតិឡើយ បើទោះបីជាមានមូលហេតុផ្សេងពីគ្នាក្តី[464]។ ស្រដៀងគ្នានេះដែរ អង្គជំនុំជម្រះសាលាដំបូងមិនបានឈានដល់សម្លេងឆ្នោតភាគច្រើនលើសលប់ ហើយដែលដូច្នេះបានសម្រេចថា ជនជាប់ចោទក្នុងសំណុំរឿង០០២ មិនអាចជំនុំជម្រះពីបទឧក្រិដ្ឋកម្មជាតិឡើយ[465]។

---

[461] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១០៦ (យល់ឃើញថា 'ថ្នាក់លើ ត្រូវតែបានដឹង ឬមានមូលហេតុត្រូវដឹង')។

[462] លក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៨(ខ) (តម្រូវថា 'ថ្នាក់លើ បានដឹង ឬទាំងដឹង តែមិនបានពិចារណាលើព័ត៌មានដែលបានបង្ហាញយ៉ាងច្បាស់ទេ')។

[463] មេធាវីការពារក្តី យោងលើ និងបញ្ចូលទទ្បីករណ៍របស់ខ្លួននៅក្នុងសំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អវតក /កសចស *សំណើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបសួរដោយសារកង្វះយុត្តាធិការលើបទល្មើស* ឯកសារ **D258** ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១៥ កថាខណ្ឌ ១៨-៣៤។

[464] សំណុំរឿង ០០៤/២-ឯកសារ **D351/5** កថាខណ្ឌ ៦៣៦-៦៣៨។

[465] សំណុំរឿង ០០១/១៨-០៧-២០០៧/អវតក/អជសដ *សេចក្តីសម្រេចស្តីពីអញ្ញត្រកម្មទាក់ទងនឹងថិរវេលានៃអាជ្ញាយុកាលចំពោះបទល្មើសជាតិដែលលើកឡើងដោយមេធាវីការពារក្តី* ឯកសារ **E187** ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១០ កថាខណ្ឌ ២៧-៣៥, ៣៩-៥៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧៦។ មេធាវីការពារក្តី យល់ស្របតាមសំអាងហេតុរបស់ចៅក្រមអន្តរជាតិនៅក្នុងសេចក្តីសម្រេចនេះ។

183. ឧក្រិដ្ឋកម្មជាតិដែលបានប្រព្រឹត្ត នៅក្នុងប្រទេសកម្ពុជាក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ គឺជាកម្មវត្ថុនៃអាជ្ញាយុកាលដែលមានរយៈពេល១០ឆ្នាំ[466]។ ដោយសារថាឧក្រិដ្ឋកម្មនៅក្នុង*ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ត្រូវបានចោទប្រកាន់ថាប្រព្រឹត្តនៅក្នុងដែនដីកម្ពុជាប្រហែលពីចុងឆ្នាំ១៩៧៦ ឬដើមឆ្នាំ១៩៧៧ រហូតដល់យ៉ាងហោចណាស់ត្រឹមថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[467] ទើបរយៈពេលអាជ្ញាយុកាល១០ឆ្នាំ បានកន្លងផុតទៅហើយ ដែលយ៉ាងយូរបំផុតត្រឹមថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៨៩។

184. មិនមានភ័ស្តុតាងបង្ហាញថារយៈកាលអាជ្ញាយុកាលត្រូវបានរំខានឡើយ៖ (ក) មិនមាន "កិច្ចស៊ើបអង្កេតឬការចោទប្រកាន់" ដែលអាចប៉ះពាល់ដល់ថេរវេលានៃអាជ្ញាយុកាល តាមមាត្រា១១២ និងមាត្រា១១៤ នៃក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៦របស់កម្ពុជា[468] (ខ) មិនមានកាលៈទេសៈពិសេសណាមួយដែលអាចផ្តល់យុត្តិកម្មដល់ការផ្អាក ថេរវេលាអាជ្ញាយុកាល នៅពេលណាមួយឡើយចាប់តាំងពីថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[469] (គ) នីតិបញ្ញត្តិរបស់កម្ពុជាមិនបានអនុម័តច្បាប់ដែលអាច មានគោលដៅក្នុងការនាំឲ្យមាននូវការជំនុំជម្រះបទល្មើសដែលអាចត្រូវបានរារាំងដោយផុតថេរវេលាឡើយ[470] និង (ឃ) ថេរវេលាអាជ្ញាយុកាលបានផុតរលត់តាំងពីមុនពេលអនុម័តមាត្រា៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ដូច្នេះហើយការអះអាងអំពីការពន្យាថេរវេលាអាជ្ញាយុកាលណា

---

[466] Royaume Du Cambodge Code Pénal et Lois Penales (1956) ('ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦') មាត្រា ១០៩, ១១១,១១២, ១១៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧៧។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ១៩៦៤) មាត្រា ៣៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧៨។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក-កសចស *ការជម្រាបជូនអំពីក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ និងសំណើសុំផ្តល់ការបញ្ជាក់លើក្រមផ្លូវការ* ឯកសារ **E91/6** ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៧៩។ សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក-កសចស *លិខិតពីទីស្តីការគណៈរដ្ឋមន្ត្រី អំពីក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦* ឯកសារ **E91/6/1** ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០០៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨០។

[467] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៩៥។

[468] សំណុំរឿង ០០១-ឯកសារ **E187** កថាខណ្ឌ ១២។

[469] សំណុំរឿង ០០១-ឯកសារ **E187** កថាខណ្ឌ ២៧, ៣១-៣៥ (កត់សម្គាល់អំពីភស្តុតាងសំខាន់ដើម្បីបង្ហាញថា ប្រព័ន្ធច្បាប់កម្ពុជាមានដំណើរការក្រោយឆ្នាំ១៩៧៩)។

[470] សំណុំរឿង ០០១-ឯកសារ **E187** កថាខណ្ឌ ៤៣-៤៩។

មួយនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក នឹងត្រូវធ្វើប្រតិសកម្ម ហើយមិនមានអានុភាពឡើយ[471]។

185. បន្ថែមលើនេះ ប្រសិនបើមានភាពមិនប្រាកដប្រជាអំពីថេរវេលាអាជ្ញាយុកាល រឹមតិសង្ស័យណាមួយពាក់ព័ន្ធការអនុវត្តចំពោះឧក្រិដ្ឋកម្មជាតិដែលបានប្រព្រឹត្តក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ត្រូវបានជាប្រយោជន៍ដល់ អោ អាន[472]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសឆ្គងក្នុងការបញ្ជូន អោ អាន ទៅជំនុំជម្រះ ពីបទអំពើមនុស្សឃាតដោយគិតទុកមុន ហើយបទចោទនេះត្រូវតែបានច្រានចោល។

## ឆ. សំអាងហេតុទី១៤÷ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តលក្ខខណ្ឌតម្រូវគតិយុត្តិត្រឹមត្រូវ សម្រាប់អំពើមនុស្សធម៌ផ្សេងទៀត

186. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានចោលនូវតម្រូវការ ក្នុងការកំណត់ឧក្រិដ្ឋភាពជាមូលដ្ឋានសម្រាប់អំពើមួយដែលជា អំពើអមនុស្សធម៌ផ្សេងទៀត ហើយបានអនុវត្តនូវធាតុផ្សំអត្តនោម័តដោយមិនត្រឹមត្រូវ សម្រាប់ប្រភេទឧក្រិដ្ឋកម្មនេះ។ ការនេះបណ្តាលឲ្យមានការសម្រេចដោយខុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលថា អោ អាន អាចត្រូវទទួលខុសត្រូវចំពោះអំពើអមនុស្សធម៌ផ្សេងទៀតនៃអំពើរំលោភផ្លូវភេទ ការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ និងស្ថានភាពអមនុស្សធម៌នៃការឃុំឃាំង និងការធ្វើបាបអ្នកទោស។

### i. តម្រូវឲ្យមានពិរុទ្ធភាពជាមូលដ្ឋានសម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀត

187. សហចៅក្រមស៊ើបអង្កេត ពឹងផ្អែកលើយុត្តិសាស្ត្រប្រកបដោយកំហុសរបស់ អ.វ.ត.ក ដែលសម្រេចថា ពិរុទ្ធភាពជាមូលដ្ឋានមិនចាំបាច់ ដើម្បីឲ្យអំពើមួយក្លាយជាអំពីអមនុស្សធម៌ផ្សេងៗ

---

[471] សំណុំរឿង ០០១-ឯកសារ **E187** កថាខណ្ឌ ៥០-៥៤។ ការព្យាយាមពង្រីករយៈពេលកំណត់តាមមាត្រា ៣*ថ្មី* គឺជាបង្កើតឡើងវិញប្រតិសកម្មនូវសិទ្ធិចោទប្រកាន់ ដោយរំលោភលើមាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ និងគោលការណ៍នីត្យានុកូលភាព។

[472] ដោយពិនិត្យឃើញថា ចៅក្រមនៅអង្គជំនុំជម្រះសាលាដំបូង មិនអាចឈានដល់សេចក្តីសម្រេចជាឯកច្ឆន្ទបាន ទើបអាចមានការខ្វែងយោបល់គ្នានៅក្នុងសំណុំរឿងនេះប្រសិនបើសំណុំរឿងនេះបញ្ជូនទៅជំនុំជម្រះ។ ដើម្បីចៀសវាងការពន្យារពេលដែលមិនចាំបាច់ និងការច្របូកច្របល់នៅពេលខាងមុខ និងដើម្បីសម្រួលការរៀបចំការពារក្តី អោ អាន បញ្ហានេះត្រូវតែដោះស្រាយជាប្រយោជន៍ដល់ជនជាប់។ សំណុំរឿង ០០១-ឯកសារ **E187** កថាខណ្ឌ ៤ ជើងទំព័រ ៦, កថាខណ្ឌ ៥៤-៥៦។

ទៀតឡើយ[473]។ ដើម្បីក្លាយជាអំពីអមនុស្សធម៌ផ្សេងទៀត ការប្រព្រឹត្តនូវអំពើដែលមានការគូស បញ្ជាក់ត្រូវតែចែងជាបទល្មើសក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[474]។

188. យុត្តិសាស្ត្រ អ.វ.ត.ក ពាក់ព័ន្ធនឹងអំពើអនុស្សធម៌ផ្សេងទៀត គឺពុំត្រឹមត្រូវទេ ដោយមានមូលហេតុ ដូចខាងក្រោម៖ ទី១ គោលបំណងនៃអំពើអមនុស្សធម៌ផ្សេងៗទៀតគឺត្រូវបញ្ចូលបទល្មើសក្រោម ច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលអាចត្រូវបានលុបចោលនៅពេលតាក់តែងច្បាប់ ឬនៅពេលមាន ការវិវត្តទៅតាមពេលវេលា ដោយគ្មានការចាំបាច់ត្រូវធ្វើវិសោធនកម្មលិខិតូបករណ៍ច្បាប់អន្តរជាតិ ឡើយ[475]។ ហេតុដូច្នេះ ជាចំណុចស្នូលនៃគោលបំណងនៃអំពើអមនុស្សធម៌ផ្សេងៗទៀត ដើម្បី បង្កើតពិរុទ្ធភាពដែលបានគូសបញ្ជាក់។ ទី២ ដោយធ្វេសប្រហែសបំពេញលក្ខខណ្ឌតម្រូវនៃពិរុទ្ធ ភាពដែលបានគូសបញ្ជាក់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អនុញ្ញាតផ្លូវក្រោយដែលអត្តនោម័ត និងស្រពេចស្រពិលចំពោះការផ្តន្ទាទោសព្រហ្មទណ្ឌដែលរំលោភលើគោលការណ៍នីត្យានុកូល ភាព[476]។ ទី៣ អំពើអមនុស្សធម៌ផ្សេងៗទៀតតម្រូវថា អំពើមួយដែលមានចរិតភាពធ្ងន់ធ្ងរ ស្រ

---

[473] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨១។

[474] មេធាវីការពារក្តី យោងលើ និងបញ្ចូលទឡ្ហីករណ៍របស់ខ្លួននៅក្នុងសំណុំរឿងលេខ០០៤/០៧-០៩-២០០៩-អវតក /កសចស, *សំណើរបស់ តា អាន សុំឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេត ពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ* (‘*សំណើរបស់ តា អាន សុំធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ*’) ឯកសារ **A259** ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៤ កថាខណ្ឌ ២៧-៣២។

[475] Eboe-Osuji *ច្បាប់អន្តរជាតិ និងអំពើហិង្សាផ្លូវភេទនៅក្នុងជម្លោះប្រដាប់អាវុធ* (‘*Eboe-Osuji*’)(Leiden: Martinus Nijhoff Publishers ឆ្នាំ២០១២) ទំព័រ ២៤៣ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨១។

[476] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-T សាលក្រម (‘សាលក្រម*Stakić*’) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០០៣ កថាខណ្ឌ ៧១៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨២ (ដកស្រង់ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-T *សេចក្តីសម្រេចលើញត្តិយោងតាមវិធាន៩៨ស្ទួន សុំសាលក្រមគ្មានទោស* ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ ១៣១)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kordić និង Čerkez*សំណុំរឿងលេខ IT-95-14/2-A *សាលក្រម* ចុះថ្ងៃទី១៧ ខែធ្នូ ឆ្នាំ ២០០៤ កថាខណ្ឌ ១១៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨៣ (អង្គេតឃើញថា ‘ការដែលអាចមានច្រើនជាទូទៅនូវក្រិដ្ឋកម្មនៃអំពើ អមនុស្សធម៌ អាចនាំឱ្យមានសេចក្តីព្រួយបារម្ភអំពីគោលការណ៍*គ្មានបទល្មើសបើគ្មានច្បាប់ចែង*’)។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Kupreškić និងអ្នកផ្សេងទៀត* សំណុំរឿង IT-95-16-T *សាក្រម* (‘*សាលក្រម Kupreškić*’) ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ៥៦៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨៤ (សម្រេចថា ‘មានសេចក្តីព្រួយបារម្ភថា ប្រភេទ[អំពើអមនុស្សធម៌ផ្សេងទៀត] នេះ ខ្វះភាពច្បាស់លាស់ ហើយមានលក្ខណៈទូទៅពេកមិនអាចធ្វើជារង្វាស់ត្រឹមត្រូវសម្រាប់ការងាររបស់សាលាក្តីនេះបានទេ

ដៀងគ្នាទៅនឹងបទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិដែលបានចែង[477]។ ការផ្អែកតែទៅលើច្បាប់សិទ្ធិមនុស្សអន្តរជាតិមិនគ្រប់គ្រាន់ទេ ដោយហេតុថា ការរំលោភសិទ្ធិមនុស្សមិនអាចប្រៀបធៀបជាលក្ខណៈចរិតឬកម្រិតធ្ងន់ធ្ងរទៅនឹងការរំលោភច្បាប់ព្រហ្មទណ្ឌអន្តរជាតិ ហើយរាល់ការរំលោភសិទ្ធិមនុស្សណាមួយ តម្រូវឲ្យមានការស៊ើបអង្កេតព្រហ្មទណ្ឌ[478]។

189. បើទោះជាមិនមានលក្ខខណ្ឌតម្រូវសម្រាប់ការគូសបញ្ជាក់ពីពិរុទ្ធភាពនៃអំពើអមនុស្សធម៌ផ្សេងៗទៀតក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសក្នុងការរកឃើញថា "មិនមានការចាំបាច់ក្នុងការចែងអំពីធាតុផ្សំទាំងឡាយណានៃការប្រព្រឹត្តដែលគេចោទ[ថាជាអំពើអមនុស្សធម៌ផ្សេងៗទៀត]"[479]។ ដោយខកខានមិនបានបញ្ជាក់ច្បាស់លាស់អំពីធាតុផ្សំនៃការប្រព្រឹត្តដែលគេចោទថាជាអំពើអមនុស្សធម៌ផ្សេងទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិកាត់បន្ថយអានុភាពនៃគោលការណ៍នីត្យានុកូលភាព និង សិទ្ធិរបស់ អោ អាន ក្នុងការរៀបចំការការពារក្ដីរបស់ខ្លួនឲ្យបានគ្រប់គ្រាន់[480]។ តាមវិធីសាស្ត្រនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដាក់បញ្ចូលគ្នានូវអំពើដាច់ពីគ្នានិងខុសគ្នា ដូចជា រំលោភសេពសន្ថវៈ និង អាពាហ៍ពិពាហ៍ដោយបង្ខំ ដើម្បីឲ្យស្របតាម

---

ហេតុនេះ វាផ្ទុយទៅនឹងគោលការណ៍ "ភាពជាក់លាក់"នៃច្បាប់ព្រហ្មទណ្ឌ')។ Cassese ទំព័រ ៣៦-៣៧ [ភាសាអង់គ្លេស]។ Eboe-Osuji ទំព័រ ២៣៩[ភាសាអង់គ្លេស]។

[477] សំណុំរឿង ០០២-ឯកសារ **F36** កថាខណ្ឌ ៥៨៦។

[478] *សាលក្រម Kupreškić* កថាខណ្ឌ ៦១៨ (សម្រេចថា 'ទោះបីជាវិស័យច្បាប់សិទ្ធិមនុស្សមានសន្ទុះ និងរីកវិសាលភាព យ៉ាងណាក៏ដោយ ក៏មិនមែនរាល់ការបដិសេធសិទ្ធិមនុស្សអាចជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិដែរ')។ *សាលក្រម Stakić* កថាខណ្ឌ ៧២១។ Cryer និងអ្នកផ្សេងទៀត ទំព័រ ១៤-១៥[ភាសាអង់គ្លេស] (រៀបរាប់អំពីភាពខុសគ្នារវាងច្បាប់ទំនៀមទម្លាប់អន្តរជាតិជាមួយនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិ)។ *សូមមើល* ឧទាហរណ៍ មូលដ្ឋាន ១៥។

[479] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨១-៨២។ ស.ច.ស.អ បញ្ជាក់ថា 'យ៉ាងណាក៏ដោយ អាចចាំបាច់ត្រូវបង្កើតប៉ារ៉ាម៉ែត្រកំណត់អំពីនោះដើម្បីកំណត់ថាតើជនត្រូវចោទអាចដឹង និងអាចដឹងជាមុនថា អំពើនោះគឺជាបទល្មើសដែរឬអត់' ប៉ុន្តែនេះមិនបានលើកកម្ពស់គោលការណ៍នីត្យានុកូលភាពឲ្យដល់បទដ្ឋានចាំបាច់ដើម្បីផ្ដន្ទាទោសព្រហ្មទណ្ឌទេ។

[480] ស.ច.ស.អ កត់សម្គាល់ថា សច្ចភាពផ្លូវច្បាប់ តម្រូវថា លក្ខណៈ និងស្ថានទម្ងន់នៃអំពើអមនុស្សធម៌ផ្សេងទៀតដែលត្រូវបានចោទ ត្រូវតែយកមកប្រៀបធៀបជាមួយនឹងឧក្រិដ្ឋកម្មផ្សេងទៀតនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងបទដ្ឋានផ្សេងទៀតនៃច្បាប់អន្តរជាតិ។ ប៉ុន្តែ មេធាវីការពារក្ដី បញ្ជាក់ថា មិនអាចធ្វើការប្រៀបធៀបនេះឲ្យបានគ្រប់គ្រាន់ទេប្រសិនបើមិនបញ្ជាក់ពីធាតុផ្សំនៃអំពើដែលត្រូវបានចោទថាជាអំពើអមនុស្សធម៌ផ្សេងទៀត។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៣។

លក្ខខណ្ឌភាពធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌ផ្សេងៗទៀត[481]។

**ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិអនុវត្តមិនត្រឹមត្រូវនូវបទដ្ឋានធាតុផ្សំអត្តនោម័តចំពោះអំពើអមនុស្សធម៌ផ្សេងៗទៀត**

190. អនុលោមតាម ច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង ដូចដែលមានឆ្លុះបញ្ចាំងនៅក្នុងធាតុផ្សំបទល្មើសរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ធាតុផ្សំអត្តនោម័តសម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀតតម្រូវថា៖ (ក) ចារីមានចេតនាបង្កការឈឺចាប់ ឬព្យសនកម្មធ្ងន់ធ្ងរ និង (ខ) ចារីបានដឹងពីកាលៈទេសៈជាក់ស្តែងដែលបង្កើតចរិតនៃអំពើនោះ[482]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានអនុវត្តលក្ខខណ្ឌធាតុអត្តនោម័តនេះចំពោះអំពើអមនុស្សធម៌ផ្សេងៗទៀត ឬពិចារណាច្បាប់និងយុត្តិសាស្ត្រតុលាការព្រហ្មទណ្ឌអន្តរជាតិ[483]។

191. សូមលើកឧទាហរណ៍ បទល្មើសរំលោភសេពសន្ថវៈ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិសន្និដ្ឋានថា អោ អាន "បានប្រកាសគោលនយោបាយមួយថា ប្តីប្រពន្ធដែលរៀបការរួចត្រូវតែ "*រួមដំណេកជាមួយគ្នា*" ដើម្បី "*បង្កើតកូន*" សម្រាប់ "*ប្រទេសជាតិរីកចម្រើន*"[484]។ ប្រការនេះមិនបានបង្ហាញថា អោ អាន មានចេតនាចាំបាច់ក្នុងការប្រព្រឹត្តបទរំលោភសេពសន្ថវៈនោះទេ។ មានការចែកដាច់ពីគ្នារវាងការជំរុញឱ្យមានកំណើនប្រជាជន និង ចេតនាចង់បង្កការបង្ខិតបង្ខំតាមផ្លូវភេទ។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក៏មិនបានពន្យល់អំពីរបៀបដែល អោ អាន មានចេតនាបង្កការឈឺចាប់ ឬការខូចខាតធ្ងន់ធ្ងរឱ្យបានជាក់លាក់តាមរយៈអំពីរំលោភសេពសន្ថវៈដែលបានគូសបញ្ជាក់ឡើយ។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានផ្តល់ភ័ស្តុតាងដើម្បីបង្ហាញថា អោ អាន បានដឹងអំពីកាលៈទេសៈជាក់ស្តែងដែលបង្កើតនូវចរិតនៃអំពើនោះ ពោលគឺគ្មានភ័ស្តុតាងបង្ហាញថា អោ អាន បានដឹង ឬ ត្រូវបានគេប្រាប់ឱ្យដឹងថាប្តីប្រពន្ធរៀបការរួចជាការ

[481] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៩២-៦៩៦, ៨២០-៨២២។

[482] តុលាការ ICC ធាតុផ្សំនៃបទឧក្រិដ្ឋ មាត្រា ៧(១)(ជ)។ *សេចក្តីសម្រេចរឿងក្តី Katanga អំពីការបញ្ជាក់ពីបទចោទ* កថាខណ្ឌ ៤៥៥។

[483] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨០។

[484] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៣១៦។

អនុវត្តអំពើរំលោភសន្ថវៈ[485]។ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបាន អនុវត្ត គោលការណ៍ធាតុផ្សំអត្តនោម័តបានត្រឹមត្រូវក្នុងការចោទប្រកាន់ពីបទល្មើសសេពសន្ថវៈជាអំពើអមនុស្សធម៌ផ្សេងទៀត ហើយក្នុងបទដ្ឋានត្រឹមត្រូវ គឺមិនអាចកំណត់បានថា អោ អាន មានចេតនាប្រព្រឹត្តបទល្មើសសេពសន្ថវៈនោះទេ។

## ៥. សំអាងហេតុទី៥÷ អាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសក្រោមយុត្តាធិការ អ.វ.ត.ក ទេ

192. ដោយផ្អែកលើយុត្តិសាស្ត្រដែលមានកំហុស សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុសដែលរកឃើញ[486]ថា អាពាហ៍ពិពាហ៍ដោយបង្ខំត្រូវបានចាត់ទុកជាឧក្រិដ្ឋកម្មមួយក្រោមអំពើអមនុស្សធម៌ផ្សេងទៀត[487]។ អាពាហ៍ពិពាហ៍ដោយបង្ខំមិនមែនជាបទល្មើសក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬ ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ នៅក្នុងកំឡុងឆ្នាំ១៩៧៥-១៩៧៩[488]។ ជាងនេះទៀត ការផ្អែករបស់តុលាការពីមុនៗមកលើច្បាប់សិទ្ធិមនុស្សដើម្បីបង្កើតពិរុទ្ធភាពនៃអាពាហ៍ពិពាហ៍ដោយ

---

[485] ល្អបំផុតគឺថា ប្រសិនបើទទួលយកថា ការរៀបការដោយបង្ខំបានកើតឡើង នោះអាចមានការចោទប្រកាន់ថា អាចដឹងជាមុនថា ការរំលោភផ្លូវភេទកើតឡើងដោយសារការរៀបការដោយបង្ខំ។ ប៉ុន្តែ ការអាចដឹងជាមុន ប្រសិនបើគ្មានចេតនាបង្កឲ្យមានការឈឺចាប់ធ្ងន់ធ្ងរតាមរយៈអំពើនោះ និងមិនដឹងអំពីអំពើនោះទេ អាចឲ្យការរំលោភផ្លូវភេទត្រូវដាក់ជាបទចោទបានតែតាមរយៈការទទួលខុសត្រូវក្រោមសហឧក្រិដ្ឋកម្មប្រភេទទី ៣ ដែលមិនអនុវត្ត នៅ អ.វ.ត.ក ទេ។

[486] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៤។

[487] ជាថ្មីម្តងទៀត មេធាវីការពារក្តី យោងលើ និងបញ្ចូលទឡ្ហីករណ៍របស់ខ្លួននៅ កថាខណ្ឌ ២៧ ដល់ ៤៩ នៃ *សំណើរបស់ តា អាន សុំធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបការដោយបង្ខំ*។

[488] Nguyen 'ការដោះស្រាយបញ្ហាផ្លូវភេទ ការរៀបការ និងអំពើឧក្រិដ្ឋផ្សេងទៀតនៅក្នុងការរៀបការដោយបង្ខំ' ទិន្នានុប្បវត្តិច្បាប់អន្តរជាតិ *Goettingen* ឆ្នាំទី ៦ (ឆ្នាំ២០១៤) ទំព័រ ១៣-៤៦ ទំព័រ ១៤-១៥ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨៥។ Eboe-Osuji ទំព័រ ២២៨ [ភាសាអង់គ្លេស] ('មិនមានភស្តុតាងបញ្ជាក់ថា ការរៀបការដោយបង្ខំត្រូវបានទទួលស្គាល់នៅក្រោម[ច្បាប់ទំនៀមទម្លាប់អន្តរជាតិ]ជាបទឧក្រិដ្ឋ ឬនៅក្នុងប្រភពច្បាប់អន្តរជាតិផ្សេងទៀតដែលបានបង្ហាញនៅមាត្រា ៣៨ (I)នៃលក្ខន្តិកៈតុលាការ ICJទេ')។ ការរៀបការដោយបង្ខំ មិនមានចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមទេ ដែលនេះបង្ហាញថា ការរៀបការដោយបង្ខំ មិនបានឈានដល់កម្រិតទទួលស្គាល់ជាទូទៅជាអន្តរជាតិថាជាបទឧក្រិដ្ឋនៅក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិទេរហូតដល់ត្រឹមឆ្នាំ ១៩៩៨។

បង្ខំក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ គឺជាកំហុសឆ្គង[489]។

193. បើទោះជា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនត្រូវបានតម្រូវឱ្យបង្ហាញពិរុទ្ធភាព អាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏គាត់ខកខានមិនបានបង្ហាញថា អាពាហ៍ពិពាហ៍ដោយបង្ខំមានចរិតនិងភាពធ្ងន់ធ្ងរប្រហាក់ប្រហែលគ្នានឹង បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិដែលបានបញ្ញត្តិ ហើយបញ្ចូលមិនត្រឹមត្រូវនូវអំពើនៃអាពាហ៍ពិពាហ៍ដោយបង្ខំ និង អំពើរំលោភសេពសន្ថវៈ ដើម្បីបង្កើនការយល់ឃើញអំពីភាពធ្ងន់ធ្ងរពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ[490]។ ជាងនេះទៀត អាពាហ៍ពិពាហ៍ដោយបង្ខំដែលបានចោទប្រកាន់នៅក្នុងអំឡុងឆ្នាំ១៩៧៥-១៩៧៩ គឺ មិនអាចបែងចែកឱ្យបានច្បាស់លាស់ពីអាពាហ៍ពិពាហ៍ដោយការផ្សំផ្គុំ ដែលជាការអនុវត្តមានការទទួលស្គាល់ និងអនុវត្តជាទូទៅនៅក្នុងប្រទេសកម្ពុជា[491]។

## ឈ. សំអាងហេតុទី១៦÷ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានកំណត់ និងអនុវត្តបានត្រឹមត្រូវនូវធាតុផ្សំនៃអំពើប្រល័យពូជសាសន៍

194. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធលក្ខខណ្ឌដើម្បីបង្កើតធាតុផ្សំតាមបរិបទនៃអំពើប្រល័យពូជសាសន៍ ជាអាទិ៍ ខកខានមិនបានបង្ហាញថា ប្រជាជនចាមត្រូវបានកំណត់មុខសញ្ញាជាវិជ្ជមាន ហើយខកខានមិនបានអនុវត្តធាតុផ្សំអត្តនោម័តនៃអំពើប្រល័យពូជសាសន៍ចំពោះ អោ អាន។ កំហុសបែបនេះបណ្តាលឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំណត់ទាំងមានកំហុសថា អោ អាន អាចត្រូវដាក់ឱ្យទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ហើយស្ថិតនៅក្រោមយុត្តាធិការបុគ្គលរបស់តុលាការ។

---

[489] *សូមប្រៀបធៀប* សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៣-៨៤ (ដកស្រង់ សំណុំរឿង ០០២-ឯកសារ **D427** កថាខណ្ឌ ១៣១៤) ជាមួយនឹង*សាលក្រម* Stakić កថាខណ្ឌ ៧២១។

[490] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២២៩, ៦៩០, ៦៩១, ៦៩៦, ៨២០-៨២២។

[491] អត្ថបទនិពន្ធដោយ Jain 'ការរៀបការដោយបង្ខំ ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ បញ្ហានិយមន័យ និងការចោទប្រកាន់' *ទិន្នានុប្បវត្តិតុលាការព្រហ្មទណ្ឌអន្តរជាតិ* ឆ្នាំទី ៦ (ឆ្នាំ២០០៨) (6 *Journal of Int'l Criminal Justice* (2008)) ទំព័រ ១០១៣-៣២ ទំព័រ ១០២៣ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨៦។ សៀវភៅនិពន្ធដោយ Heuveline & Poch 'តើការរៀបការបំភ្លេចអតីតកាលដែរឬទេ? ស្ថិរភាពអាពាហ៍ពិពាហ៍នៅក្នុងប្រទេសកម្ពុជាក្រោយរបបខ្មែរក្រហម' *ប្រជាសាស្ត្រ* ឆ្នាំទី៤៣ (លេខ ១) (ខែកុម្ភៈ ឆ្នាំ២០០៦) ទំព័រ ១,៣ [ភាសាអង់គ្លេស] ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨៧។

195. ជាការសង្កេតបឋម មេធាវីការពារក្តីកត់សម្គាល់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចោទប្រកាន់ អោ អាន អំពីបទប្រល័យពូជសាសន៍ "មកលើជនជាតិចាមនៅខេត្តកំពង់ចាម"[492] ដែលរាប់បញ្ចូលទាំងភូមិភាគកណ្តាល និង ភូមិភាគបូព៌ា និង រកឃើញថា អោ អាន "ចូលរួមធ្វើផែនការបោសសំអាតភូមិភាគបូព៌ាក្នុងកំឡុងពេលដែលជនជាតិចាមត្រូវបានសម្លាប់"[493]។ប៉ុន្តែ អោ អាន មិនត្រូវបានចោទពីអង្គហេតុ ឬបទល្មើសនៅក្នុងភូមិភាគបូព៌ាឡើយ។ អង្គបុរេជំនុំជម្រះ បានសម្រេចថា "[ក្នុង]ប្រព័ន្ធច្បាប់ស៊ីវិលឡូ មានតែអង្គហេតុដែលត្រូវបានចោទប្រកាន់ជាមុនតែប៉ុណ្ណោះ ទើបអាចយកមកពិចារណាចោទប្រកាន់បញ្ជូនទៅជំនុំជម្រះបាន" ហើយ "នីតិវិធីចោទប្រកាន់តម្រូវឱ្យមានការបញ្ជូនទៅជំនុំជម្រះជាបន្តបន្ទាប់"[494]។ ហេតុដូចនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដែលចោទ អោ អាន ពីបទប្រល័យពូជសាសន៍លើជនជាតិចាមនៅខេត្តកំពង់ចាម។

## i. សហចៅក្រមស៊ើបអង្កេតអន្តរជាតិបដិសេធលក្ខខណ្ឌបង្កើតអត្ថិភាពនៃធាតុផ្សំនៃអំពើប្រល័យ ពូជសាសន៍តាមបរិបទ

196. ដោយផ្អែកតែទៅលើយុត្តិសាស្ត្រនៃតុលាការមិនអចិន្ត្រៃយ៍ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធលក្ខខណ្ឌច្បាប់ទំនៀមទម្លាប់អន្តរជាតិសម្រាប់ធាតុផ្សំនៃអំពើប្រល័យពូជសាសន៍តាមបរិបទ[495]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានពិនិត្យប្រភពផ្សេងៗទៀតនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលគាំទ្រលក្ខខណ្ឌនេះ ជាពិសេស គឺ ធាតុផ្សំបទល្មើសរបស់តុលាការ

---

[492] សំណុំរឿង ០០៤/២-ឯកសារ **D360** ទំព័រ ៤០៩។

[493] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៧។

[494] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ១១០ (ដកស្រង់សំណុំរឿង ០០៤/១/០៧-០៩-២០០៩-អវតក /កសចស (អបជ៥២) *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរទាក់ទងអំពហិង្សាផ្លូវភេទនៅគុកលេខ ៨ និងនៅក្នុងស្រុកបាកាន* ឯកសារ **D365/3/1/5** ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ ២០១៨ កថាខណ្ឌ ៣៥)។

[495] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៦ ('មិនមានលក្ខខណ្ឌតម្រូវថា អំពើដែលត្រូវបានចោទត្រូវកើតឡើងនៅក្នុងបរិបទនៃទម្រង់ច្បាស់លាស់ជាអំពើស្រដៀងគ្នាទេ។ ស្រដៀងគ្នានេះដែរ អត្ថិភាពនៃគោលនយោបាយ ឬផែនការរបស់រដ្ឋ (ឬគោលនយោបាយ ឬផែនការផ្សេងទៀត)ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍ មិនមែនជាធាតុផ្សំមួយនៃឧក្រិដ្ឋកម្មអំពើប្រល័យពូជសាសន៍ទេ')។

ព្រហ្មទណ្ឌអន្តរជាតិ[496]។ ដោយមើលរំលងលក្ខខណ្ឌនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបន្ថយកម្រិតបទល្មើសនោះ[497]។ ជាងនេះទៀត លក្ខខណ្ឌច្បាប់ទំនៀមទម្លាប់អន្តរជាតិចំពោះធាតុផ្សំបទល្មើសប្រល័យពូជសាសន៍តាមបរិបទ គឺស្របតាមគោលដៅ និងគោលបំណងរបស់ច្បាប់ អ.វ.ត.ក[498]។

## ii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានបង្ហាញថា ប្រជាជនចាមត្រូវបានកំណត់អត្តសញ្ញាណ និងកំណត់មុខសញ្ញាជាវិជ្ជមាន "ជាអាទិ៍"

197. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានអនុវត្តធាតុផ្សំអត្តនោម័តបានត្រឹមត្រូវសម្រាប់អំពីប្រល័យពូជសាសន៍ដែលតម្រូវថាចារីត្រូវតែកំណត់និយមន័យក្រុមជនរងគ្រោះជាវិជ្ជមាន[499]។ កំហុសនេះបណ្តាលឲ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំណត់ខុសថា អោ អាន និង ក្រុមសហឧក្រិដ្ឋកម្មរួម មានចេតនាចាំបាច់ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិចាម។

198. ដើម្បីបំពេញលក្ខខណ្ឌ "ជាអាទិ៍"[500] ចារីត្រូវតែកំណត់មុខសញ្ញាក្រុមដែលមានការការពារតាម

---

[496] តុលាការ ICC ធាតុផ្សំនៃបទឧក្រិដ្ឋ មាត្រា ៦(ក)(៤) (ដើម្បីឲ្យអំពើណាមួយកើតឡើងជាអំពើប្រល័យពូជសាសន៍ ត្រូវតម្រូវថា អំពើនោះត្រូវកើតឡើងនៅក្នុងបរិបទនៃទម្រង់ច្បាស់លាស់ជាអំពើស្រដៀងគ្នាសំដៅលើក្រុមនោះ ឬជាអំពើដែលអាចនាំឲ្យមានការបំផ្លាញបែបនោះ')។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Al Bashir* សំណុំរឿងលេខ ICC-02/05-01/09 *សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាសុំដីកាចាប់ខ្លួន Omar Hassan Ahmad Al Bashir* ('*សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាសុំដីកាចាប់ខ្លួន Al Bashir*') ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៩ កថាខណ្ឌ ១២៣-២៤, ១៣៣ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨៨។

[497] Cryer និងអ្នកផ្សេងទៀត ទំព័រ ២២០ [ភាសាអង់គ្លេស] (កត់សម្គាល់ថា ធាតុផ្សំបរិបទ តម្រូវឲ្យមានដែនកំណត់សត្យានុម័តអំពីវិសាលភាព និងស្ថានទម្ងន់ ដែលឆ្លុះបញ្ចាំងពីភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្ម)។ ប្រសិនបើមានភាពមិនច្បាស់លាស់អំពីលក្ខខណ្ឌតម្រូវតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិត្រូវមានធាតុផ្សំបរិបទ នោះ ស.ច.ស.អ គួរតែបានអនុវត្តច្បាប់ក្នុងន័យជាប្រយោជន៍ដល់ជនជាប់ចោទ។

[498] ច្បាប់ អ.វ.ត.ក មាត្រា ១។

[499] ស.ច.ស.អ ទទួលស្គាល់ពីលក្ខខណ្ឌតម្រូវត្រូវមានអត្តសញ្ញាណជាក់លាក់ ប៉ុន្តែ ស.ច.ស.អ មិនអនុវត្តលក្ខខណ្ឌនេះទេ។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៨៩។

[500] រឿងក្តី *Niyitegeka តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-96-14-A *សាលក្រម* ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៥៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៨៩ (កត់សម្គាល់ថា 'អង្គជំនុំជម្រះសាលាដំបូង ត្រឹមត្រូវដែលបកស្រាយថា ពាក្យថា "បែបនោះ/ហេតុនេះ" មានន័យថា អំពើដែលត្រូវបានហាមឃាត់ បានប្រព្រឹត្តឡើងមកលើជនរងគ្រោះ *ដោយសារ* សមាជិកភាព

រយៈការកំណត់អត្តសញ្ញាណជាវិជ្ជមាន ដោយយោងទៅលើអត្តសញ្ញាណក្រុមជាក់លាក់មួយ ផ្ទុយទៅនឹងការកំណត់អត្តសញ្ញាណជាអវិជ្ជមាន ដោយយោងទៅលើកង្វះអត្តសញ្ញាណ ឬលក្ខណៈជាក់លាក់[501]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បដិសេធដោយតុល្យភាពនូវលក្ខខណ្ឌ *អត្តនោម័ត* សម្រាប់អំពើប្រល័យពូជសាសន៍ ដោយខកខានមិនបានបង្ហាញថា ប្រជាជនចាមត្រូវបានកំណត់មុខសញ្ញាជាវិជ្ជមាន។ ផ្ទុយទៅមក សហចៅក្រមស៊ើបអង្កេតអន្តរជាតិប៉ុនប៉ងបង្ហាញថា ពួកគេត្រូវបានកំណត់មុខសញ្ញាជាអវិជ្ជមាន ជាផ្នែកមួយនៃក្រុមជនរងគ្រោះទូលាយ[502]។ សហចៅក្រម

---

របស់ពួកគាត់នៅក្នុងក្រុមត្រូវការពារ')។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Musema* សំណុំរឿង ICTR-96-13-T *សាលក្រម* ចុះថ្ងៃទី ២៧ ខែមករា ឆ្នាំ២០០០ កថាខណ្ឌ ១៦៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩០។

[501] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-A *សាលដីកា* ('*សាលដីកា Stakić*') ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ ២០០៦ កថាខណ្ឌ ១៦-២៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩១ (សម្រេចថា 'ពាក្យថា "បែបនោះ-as such"មានសារៈសំខាន់ខ្លាំង ដោយសារថា ពាក្យនេះបង្ហាញថា បទល្មើសតម្រូវឱ្យមានចេតនាបំផ្លាញក្រុមមនុស្សដែលមានអត្តសញ្ញាជាក្រុមជាក់លាក់។ ប៉ុន្តែ ក្នុងករណីដែលជនណាម្នាក់ដាក់គោលដៅលើបុគ្គលនានាដោយសារបុគ្គលទាំងនោះខ្វះលក្ខណៈជនជាតិ ជាតិពិន្ទុ ពូជសាសន៍ ឬសាសនាជាក់លាក់ណាមួយ ចេតនាគឺមិនមែនដើម្បីបំផ្លាញក្រុមជាក់លាក់ដែលមានអត្តសញ្ញាណជាក់លាក់បែបនោះទេ ប៉ុន្តែ គឺដើម្បីបំផ្លាញបុគ្គលនានាដោយសារបុគ្គលទាំងនោះខ្វះលក្ខណៈជនជាតិ ជាតិពិន្ទុ ពូជសាសន៍ ឬសាសនាជាក់លាក់ណាមួយ')។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Karadžić* សំណុំរឿងលេខ IT-95-5/18-T *សាលក្រម* ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ៥៤១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Brđanin* សំណុំរឿងលេខIT-99-36-T *សាលក្រម* ('*សាលក្រម Brđanin*') ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០០៤ កថាខណ្ឌ ៦៨៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩៣។ *សេចក្តីសម្រេចលើពាក្យសុំរបស់រដ្ឋអាជ្ញាសុំដីកាចាប់ខ្លួន Al Bashir* កថាខណ្ឌ ១៣៥។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-T *សាលក្រមវ៉ុល I* ('*សាលក្រម Popović វ៉ុល I*') ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ ៨០៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩៤។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Jelisić* សំណុំរឿងលេខ IT-95-10-T *សាលក្រម* ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ១៩៩៩ កថាខណ្ឌ ៧០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩៥ (សម្រេចថា 'កាន់តែសមស្របដែលត្រូវវាយតម្លៃឋានៈជាក្រុមជនជាតិ ជាតិពិន្ទុ ឬសាសនា តាមទស្សនៈរបស់ជនដែលមានបំណងដាក់គោលដៅលើក្រុមនោះឱ្យចេញដាច់ពីសហគមន៍')។

[502] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២០៨ ("គោលដៅរបស់ ប.ក.ក មានច្រើនយ៉ាង។ ប.ក.ក ព្យាយាមលុបបំបាត់អ្នកទំនាស់នឹងរបបនោះឱ្យអស់ ហាមឃាត់សាសនា និងលុបបំបាត់វណ្ណៈសង្គម ដើម្បីបង្កើតបក្ស និងសង្គមស្អាតស្អំខាងនយោបាយ និងមនោគមន៍វិជ្ជា។") កថាខណ្ឌ ៥៩៧ ("មេដឹកនាំ ប.ក.ក មានគោលដៅបង្កើតសង្គមមួយដែលមានជាតិសាន៍តែមួយ ដែលគ្មានសាសនា និងគ្មានវណ្ណៈ ដោយលុបបំបាត់ភាពខុសគ្នាខាងវប្បធម៌ វណ្ណៈ សាសនា និងជាតិសាសន៍ទាំងអស់។") កថាខណ្ឌ ៥៩៨ ("ជាក់ស្តែង និយមន័យសាសនាប្រតិកិរិយារបស់ ប.ក.ក ត្រូវបានពង្រីកដោយរួមបញ្ចូលសាសនាទាំងអស់ ដោយរួមទាំងសាសនាព្រះពុទ្ធ និងសាសនាអ៊ីស្លាម។") កថាខណ្ឌ ៦០៨ ("សាក្សីជនជាតិចាមមួយរូបទៀត ត្រូវបាន "*តំណាងអង្គការថ្នាក់កណ្តាល*" មួយរូប ប្រាប់ថា "*មិនមានប្រជាជនថ្មី មិនមានប្រជាជនចាស់ មិនមានជនជាតិថ្លៃ ឬជនជាតិចាមនោះឡើយ គឺមានតែប្រជាជនខ្មែរតែមួយប៉ុណ្ណោះ*"។")។

ស៊ើបអង្កេតអន្តរជាតិ ផ្តល់សំអាងហេតុថា របបខ្មែរក្រហមមានចេតនាបង្កើតនូវសង្គមគ្មានវណ្ណៈ គ្មានសាសនា និង មានជាតិសាសន៍ តែមួយ[503]។ គាត់ក៏ផ្តល់សំអាងហេតុដែរថា អ្នកទាំងឡាយ ដែលខ្វះលក្ខណៈចាំបាច់ដើម្បីបញ្ចូលទៅក្នុងសង្គមនេះ ត្រូវបានចាត់ទុកថាជាអ្នកប្រឆាំងនឹងគោលដៅនៃរបបនេះ ចាត់ទុកជា "ខ្មាំង"និង កំណត់មុខសញ្ញាជាអរិជ្ជមានជាអាទិ៍[504]។ ហេតុដូចនេះ គាត់ខកខានមិនបានសន្និដ្ឋានថា ប្រជាជនចាម និង អ្នកដទៃទៀតត្រូវបានកំណត់មុខសញ្ញាជាវិជ្ជមានដោយហេតុថា ពួកគេមានអត្តសញ្ញាណជាក់លាក់របស់ខ្លួន។ ដំណើរការកំណត់អត្តសញ្ញាណជាអរិជ្ជមាននេះខកខានមិនបានបំពេញតាមលក្ខខណ្ឌ *អត្តនោម័ត*នៃអំពើប្រល័យពូជសាសន៍។

### iii. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានអនុវត្តលក្ខខណ្ឌអត្តនោម័តនៃអំពើប្រល័យពូជសាសន៍ចំពោះ អោ អាន និង ខកខានមិនបានបង្ហាញថា អោ អាន មានចេតនាជាក់លាក់

199. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានអនុវត្តលក្ខខណ្ឌ*អត្តនោម័ត*នៃអំពើប្រល័យពូជសាសន៍ចំពោះ អោ អាន និងខកខានមិនបានបង្ហាញថា អោ អាន មានចេតនាប្រល័យពូជសាសន៍ជាក់លាក់[505]។ ដើម្បីបង្ហាញភាវចិត្តរបស់បុគ្គលម្នាក់តាមការសន្និដ្ឋាន គឺត្រូវធ្វើការសន្និដ្ឋានដោយ

---

[503] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៩៧។

[504] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ២០៥ ("ក្នុងការអនុវត្ត សកម្មភាពខ្មាំងត្រូវបានបកស្រាយយ៉ាងទូលំទូលាយ និងជារឿយៗ តាមទំនើងចិត្ត។") កថាខណ្ឌ ២០៦ ("ជារឿយៗ មនុស្សជាច្រើនត្រូវគេចាត់ទុកថាជាខ្មាំង មិនមែនដោយសារអំពើរបស់ពួកគេទេ គឺដោយសារតែការសង្ស័យសុទ្ធសាធថា ពួកគេមើលមិនឃើញគុណតម្លៃរបស់ ប.ក.ក ឬអាចមិនស្មោះត្រង់នៅថ្ងៃអនាគត។") កថាខណ្ឌ ២២០ ("កែ ពក បានរាយការណ៍ជូន ប៉ុល ពត អំពីសភាពការណ៍ខ្មាំង នៅភូមិភាគកណ្តាល (ឧត្តរចាស់) ដោយបានហៅប្រជាជនចាម អតីតទាហាន លន់ នល់ និងអ្នកគាំទ្ររបប លន់ នល់ ថាជាខ្មាំង។") កថាខណ្ឌ ៧១៦ ("ប.ក.ក បានកំណត់អត្តសញ្ញាណ ផ្តោតគោលដៅ និងបោសសម្អាតជាប្រព័ន្ធនូវប្រភេទមនុស្សជាក់លាក់ដែលត្រូវគេសន្មតថាជាគ្រោះគម្រាមកំហែងដ៏មានសក្តានុពល ចំពោះរបបកម្ពុជាប្រជាធិបតេយ្យ ឬមានទស្សនៈផ្ទុយពីទ្រឹស្តីរបស់ ប.ក.ក។ មនុស្សទាំងអស់នេះ រួមមានកម្មាភិបាលភូមិភាគកណ្តាល ប្រជាជនដែលត្រូវបានបង្ខំឱ្យផ្លាស់ទីលំនៅចេញពីតំបន់ទីក្រុង អតីតយោធា និងមន្ត្រីផ្សេងៗទៀតរបស់សាធារណរដ្ឋខ្មែរ ប្រជាជនមកពីភូមិភាគបូព៌ា ប្រជាជនចាម និងមនុស្សផ្សេងទៀតដែលមានអត្តសញ្ញាណសាសនា ជាតិពន្ធុ នយោបាយ សេដ្ឋកិច្ច ឬជាតិ ដែលត្រូវគេសន្មតថាជាគ្រោះគំរាមកំហែងចំពោះគោលដៅរបស់ ប.ក.ក ក្នុងការផ្លាស់ប្តូរសង្គមកម្ពុជា។")។

[505] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Krstić* សំណុំរឿងលេខ IT-98-33A សាលដីកា ("សាលដីកាក្នុងរឿងក្តី Krstić") ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០៤ កថាខណ្ឌ ១៣៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩៦ (ចែងថា "អំពើប្រល័យពូជសាសន៍ជាឧក្រិដ្ឋកម្មមួយក្នុង

មានហេតុផលផ្អែកលើភ័ស្តុតាងដែលមាន[506]។ ខណៈដែលមេធាវីការពារក្តីជំទាស់ទៅនឹងភ័ស្តុតាងនៅក្នុងដីកាដំណោះស្រាយ(ដីកាបញ្ជូនទៅជំនុំជម្រះ) ទោះបីជាពិចារណាឲ្យអស់លទ្ធភាពប៉ុណ្ណាក៏ដោយ ក៏មិនអាចនាំដល់ការសន្និដ្ឋានតែមួយដែលថា អោ អាន មានចេតនាប្រល័យពូជសាសន៍ដែរ[507]។

200. ទី១ អោ អាន មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយក៏មិនមែនជាស្ថាបនិកនៃអំពើប្រល័យពូជសាសន៍តាមការចោទប្រកាន់នោះដែរ[508]។ ជាងនេះទៀត គ្មានភ័ស្តុតាងផ្ទាល់ដែលថាគាត់បានបង្កើតបានដឹង ឬ មានចេតនាក្នុងការចូលរួមក្នុងផែនការ ឬគោលនយោបាយប្រព្រឹត្តអំពើប្រល័យពូជសាសន៍លើជនជាតិចាមឡើយ។

201. ទី២ ចេតនាប្រល័យពូជសាសន៍មិនមែនជាសេចក្តីសន្និដ្ឋានតែមួយដែលមាននៅពេលពិនិត្យលើសកម្មភាពរបស់ អោ អាន នោះឡើយ។ បក្សកុម្មុយនីស្តកម្ពុជា ប្រព្រឹត្តទៅជាប្រព័ន្ធឋានានុក្រមតឹងរ៉ឹង ហើយបទបញ្ជាឲ្យកំណត់មុខសញ្ញាខ្មាំរបស់របបនេះ គឺត្រូវបានបញ្ជូនពីថ្នាក់ដឹកនាំជាន់ខ្ពស់បក្សកុម្មុយនីស្តកម្ពុជា ដល់ថ្នាក់ក្រោមក្នុងនាមជាសេចក្តីណែនាំទូទៅ[509]។ ដោយពិចារណាថា អោ

---

ចំណោមឧក្រិដ្ឋកម្មដ៏សែនអាក្រក់បំផុតដែលមនុស្សជាតិបានស្គាល់ ហើយភាពធ្ងន់ធ្ងររបស់វាត្រូវបានឆ្លុះបញ្ចាំងក្នុងលក្ខខណ្ឌតម្រូវតឹងរ៉ឹងនៃចេតនាជាក់លាក់មួយ។ ការប្រកាសពិរុទ្ធភាពពីបទប្រល័យពូជសាសន៍អាចត្រូវបានធ្វើឡើង តែនៅពេលចេតនានោះត្រូវបានស្តែងឲ្យឃើញយ៉ាងច្បាស់លាស់តែប៉ុណ្ណោះ")។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Kvočka *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-98-30/1-A សាលដីកា ("*Kvočka* សាលដីកា") ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៥ កថាខណ្ឌ ១០៩-១១០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩៧ (ចែងពីឧក្រិដ្ឋកម្មនៃចេតនាជាក់លាក់ថា "អ្នកចូលរួមក្នុងសហឧក្រិដ្ឋកម្មរួមទម្រង់មូលដ្ឋាន ឬជាប្រព័ន្ធ ត្រូវបានបង្ហាញឲ្យឃើញថាមានចេតនាដូចគ្នានឹងជនដែលដល់ដែរ")។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Setako* លេខ ICTR-04-81-T *សាលក្រម និងការប្រកាសទោស* ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១០ កថាខណ្ឌ ៤៥៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩៨។

[506] សាលដីកាក្នុងរឿងក្តី Krstić កថាខណ្ឌ ៤១។ សាលក្រមក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៩៧០។

[507] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៣-៦៣៧ (ការពិភាក្សារបស់ ស.ច.ស.អ អំពីតួនាទី និងការចូលរួមរបស់ អោ អាន នៅក្នុងអំពើប្រល័យពូជសាសន៍ មានរៀបរាប់តែនៅក្នុងកថាខណ្ឌទាំងនេះប៉ុណ្ណោះ។)។

[508] សាលក្រមក្នុងរឿងក្តី *Popović* ភាគ ១ កថាខណ្ឌ ១៤១០ (ពិចារណាថា គេអាចទាញការសន្និដ្ឋានថាគ្មានចេតនាប្រល័យពូជសាសន៍បាន ដោយសារជនជាប់ចោទមិនមែនជាអ្នករៀបចំប្រតិបត្តិការប្រល័យពូជសាសន៍)។ សាលដីកា ក្នុងរឿងក្តី *Popović* កថាខណ្ឌ ២០០៥-២០០៧។

[509] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៥៧, ៦២៣ (សន្និដ្ឋានថា "ដោយសារប្រព័ន្ធប្រាស្រ័យទាក់ទងគ្នាតាមខ្សែបណ្តោយរបស់ ប.ក.ក ហាមមិនឲ្យប្រាស្រ័យទាក់ទងគ្នាតាមខ្សែទទឹង នោះទើបស្ទើរតែមិនអាចថា ថ្នាក់ក្រោមអាចរៀបចំ

អាន មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃបក្សកុម្មុយនីស្តកម្ពុជា ហើយគាត់អាចទទួលតែបទបញ្ជាពីថ្នាក់លើ[510] ភ័ស្តុតាងតាមការចោទប្រកាន់ដែលថាគាត់បានបញ្ជាឱ្យគេបង្កើតបញ្ជីឈ្មោះ ការចាប់ខ្លួននិងសម្លាប់ជនជាតិចាម ឬថាគាត់បានអនុញ្ញាតឱ្យគេប្រើធនធានរបស់តំបន់៤១ ដើម្បីដឹកជញ្ជូនជនជាតិចាមពីភូមិភាគបូព៌ា[511]គឺមិននាំដល់ការសន្និដ្ឋានមានហេតុផលតែមួយថា គាត់មានចេតនាប្រល័យពូជសាសន៍ឡើយ។ ផ្អែកលើភ័ស្តុតាងនេះ ការសន្និដ្ឋានមានហេតុផលមួយទៀតគឺ អាចថា "ការងប់ងុល" របស់ អោ អាន ទៅលើបក្សកុម្មុយនីស្តកម្ពុជាអាចនាំឱ្យគាត់ "មានភាពស្ទិតស្វាញ"អនុវត្តភារកិច្ចរបស់គាត់ ដោយគ្មានចេតនាប្រល័យពូជសាសន៍[512]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានផ្តល់ភ័ស្តុតាងថា អោ អាន បានអនុវត្ត បញ្ជូនបន្ត ឬ ទទួលយកបញ្ជារបស់គាត់ ដោយមានចេតនាជាក់លាក់ក្នុងការប្រព្រឹត្តអំពើប្រល័យពូជសាសន៍។

202. ទី៣ ភ័ស្តុតាងដែលថា អោ អាន អាចបានដឹងតាមរយៈរបាយការណ៍ ឬការចូលរួមរបស់គាត់នៅក្នុងកិច្ចប្រជុំថា ប្រជាជនចាមត្រូវបានចាប់ខ្លួន និងសម្លាប់ គឺពុំអាចសន្និដ្ឋានថាជាចេតនាប្រល័យពូជសាសន៍ឡើយ[513]។ ភ័ស្តុតាងនេះយ៉ាងច្រើនបំផុតក៏បង្ហាញថា អោ អាន បានដឹងអំពីឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនចាមដែរ។ ទោះជាយ៉ាងនេះក្តី ការដឹងតែមួយមុខមិនបំពេញលក្ខខណ្ឌតម្រូវ

---

ផែនការ និងអនុវត្តប្រតិបត្តិការចាប់ខ្លួន និងសម្លាប់ដែលមានលក្ខណៈទូទៅ និងសម្របសម្រួលបានយ៉ាងល្អបែបនេះឡើយសម្រាប់ថ្នាក់ក្រោម")។

[510] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៩៧។

[511] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៣-៦៣៧។

[512] សាលក្រមក្នុងរឿងក្តី *Popović* ភាគ ១ កថាខណ្ឌ ១៤១៤ ("ដោយថ្លឹងថ្លែង និងពិចារណាទៅលើកត្តាខាងលើម្តងមួយៗ និងទាំងអស់រួមគ្នាតែម្តង អង្គជំនុំជម្រះសាលាដំបូងមិនជឿថា គេអាចទាញការសន្និដ្ឋានសមហេតុផលតែមួយអំពីអំពើរបស់ Nikolić គឺថា គាត់មានចេតនាប្រល័យពូជសាសន៍។ គេអាចទាញការសន្និដ្ឋានសមហេតុផលមួយផ្សេងទៀត គឺថា ភាពប្តូរផ្តាច់ងងឹតងងល់របស់ Nikolić ចំពោះសេវាសន្តិសុខ (Security Service) បាននាំឱ្យគាត់បន្តអនុវត្តយ៉ាងមុតមាំនូវភារកិច្ចដែលគេប្រគល់ឱ្យគាត់យ៉ាងមានប្រសិទ្ធភាព នៅក្នុងប្រតិបត្តិការនេះ ទោះបីជាមានលក្ខណៈមនុស្សឃាត ហើយថ្នាក់លើរបស់គាត់មានគោលដៅប្រល័យពូជសាសន៍ក៏ដោយ។")។ សាលដីកា ក្នុងរឿងក្តី *Popović* កថាខណ្ឌ ៥១៦។ សាលដីកាក្នុងរឿងក្តី Krstić កថាខណ្ឌ ១៣៤ (សន្និដ្ឋានថា ការដឹងរបស់ជនជាប់ចោទថា ធនធានដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួន ត្រូវបានប្រើប្រាស់ដើម្បីបង្កភាពងាយស្រួលដល់ការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍ "មិនអាចគាំទ្រដល់ការសន្និដ្ឋានថាមានចេតនាប្រល័យពូជសាសន៍បានទេ")។

[513] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦៣៥-៦៣៦។

តឹងរ៉ឹងនៃចេតនាប្រល័យពូជសាជន៍ទេ[514]។

## ញ. សំអាងហេតុទី១៧÷ សហចៅក្រមស៊ើបអង្កេតអន្តរជាតិខកខានមិនបានបញ្ចូលបទប្រល័យពូជសាសន៍នៅក្នុងគោលបំណងរួមនៃក្រុមសហកម្មឧក្រិដ្ឋកម្មរួម

203. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានបញ្ចូលបទប្រល័យពូជសាសន៍នៅក្នុងគោលបំណងរួមនៃក្រុមសហកម្ម ឧក្រិដ្ឋកម្មរួម។ ដើម្បីដាក់ការទទួលខុសត្រូវតាមរយៈសហកម្មឧក្រិដ្ឋកម្មរួម I គោលបំណងរួមត្រូវតែមានជាប់ពាក់ព័ន្ធឬជាបទល្មើសនោះ[515]ដើម្បីឲ្យសមាជិកក្រុមមានចេតនាប្រព្រឹត្ត[516]។

204. ទី១ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនត្រឹមតែមិនបញ្ចូលឲ្យបានច្បាស់លាស់នូវបទប្រល័យពូជសាសន៍នៅក្នុងគោលបំណងរួមនៃសហកម្មឧក្រិដ្ឋកម្មរួមប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមិនលើកឡើងនូវក្នុង "ការរកឃើញខាងអង្គហេតុស្តីអំពី[សហកម្មឧក្រិដ្ឋកម្មរួម]ទៀតផង[517]។ គ្មានចំណុចណាមួយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្តល់ទឡ្ហីករណ៍ថា គោលបំណងរួមនៃសហកម្មឧក្រិដ្ឋកម្មរួមពាក់ព័ន្ធឬជាអំពើប្រល័យពូជសាសន៍ឡើយដែលមិនអាចបង្ហាញថា សមាជិកនៃសហកម្មឧក្រិដ្ឋកម្មរួមមានចេតនាប្រព្រឹត្តបទល្មើសនោះ។ គោលបំណងរួមដែលរៀបរាប់ដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បញ្ជាក់ថា អំពើប្រល័យពូជសាសន៍អាចជាលទ្ធផលដែលអាចប្រមើលឃើញនៃការអនុវត្តផែនការរបស់បក្សកុម្មុយនីស្តកម្ពុជា ក្នុងការកំណត់មុខសញ្ញាក្រុមជាក់

---

[514] សាលដីកាក្នុងរឿងក្តី Krstić កថាខណ្ឌ ១២៩, ១៣៣-១៣៤ (ចែងថា "ការដឹងរបស់ Radislav Krstić ដោយគ្មានអ្វីផ្សេងទៀត មិនគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការសន្និដ្ឋានថាមានចេតនាប្រល័យពូជសាសន៍ឡើយ")។

[515] សាលដីកាក្នុងសំណុំរឿង *Tadić* កថាខណ្ឌ ២២៧។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤១៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* *Krnojelac* សំណុំរឿងលេខ IT-97-25-A សាលដីកា ("សាលដីកាក្នុងរឿងក្តី *Krnojelac*") ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០០៣ កថាខណ្ឌ ៣១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៩៩។

[516] សំណុំរឿង ០០២-ឯកសារ **F36** កថាខណ្ឌ ១០៥៣-១០៥៤។ សាលដីកាក្នុងរឿងក្តី *Krnojelac* កថាខណ្ឌ ១១១-១១២។ សាលដីកាក្នុងរឿងក្តី *Kvočka* កថាខណ្ឌ ១០៩-១១០។ សាលដីកាក្នុងរឿងក្តី *Tadić* កថាខណ្ឌ ១៩៦។ សាលដីកាក្នុងរឿងក្តី *Brđanin* កថាខណ្ឌ ៤១៨។ សាលដីកាក្នុងរឿងក្តី *Stakić* កថាខណ្ឌ ៦៥។

[517] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៩៥-២៣២ (កំណត់ថា គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមមួយផ្នែក ជាការអនុវត្តគោលនយោបាយ ប.ក.ក តាមរយៈការកំណត់គោលដៅក្រុមជាក់លាក់ ប៉ុន្តែមិនរាប់បញ្ចូលអំពើប្រល័យពូជសាសន៍ជាពិសេសនោះទេ)។

លាក់ ដូច្នេះ គឺជាការទទួលខុសត្រូវក្នុងទម្រង់សហកម្មឧក្រិដ្ឋកម្មរួមIII ដែលត្រូវបានបដិសេធដោយ អ.វ.ត.ក[518]។

205. ទី២ តាមរយៈសំអាងហេតុតាមអង្គហេតុ គេមិនអាចសន្និដ្ឋានបានថា អំពើប្រល័យពូជសាសន៍បង្កើតផ្នែកមួយនៃគោលបំណងរួមរបស់សមាជិកក្រុមសហកម្មឧក្រិដ្ឋកម្មរួមបានឡើយ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ផ្អែកហួសហេតុទៅលើភ័ស្តុតាងនៃចេតនាប្រល័យពូជសាសន៍ពីក្រៅក្រុមសហកម្មឧក្រិដ្ឋកម្មរួម[519]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ កំពុងបញ្ចូលគ្នានូវក្រុមសហកម្មឧក្រិដ្ឋកម្មរួមនានា និងគោលបំណងរួម ហើយប្រើប្រាស់ភ័ស្តុតាងនេះដើម្បីបំពេញលក្ខខណ្ឌសហកម្មឧក្រិដ្ឋកម្មរួមក្នុងករណី អោ អាន។ ប៉ុន្តែ បើទោះជាខំប្រឹងយកភ័ស្តុតាងឲ្យអស់លទ្ធភាពក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ខកខានមិនបានបង្ហាញថា សហកម្មឧក្រិដ្ឋកម្មមួយដែលអាចមាន ការពាក់ព័ន្ធនឹង អោ អាន មានចេតនាជាក់លាក់ក្នុងការអនុវត្តគោលបំណងរួមដែលពាក់ព័ន្ធ ឬ ដែលជាអំពើប្រល័យពូជសាសន៍ឡើយ។ ដោយមិនមានការយល់ស្របគ្នាទៅលើក្រុមសហកម្មឧក្រិដ្ឋកម្មរួមនានាដែលមាននៅក្នុងរបបខ្មែរក្រហម[520] និង ខណៈដែលគោលនយោបាយបក្សកុម្មុយនីស្តកម្ពុជា ត្រូវបានបង្កើតដោយក្រុមសំណុំរឿងមេដឹកនាំជាន់ខ្ពស់លេខ ០០២ ជាការទំនងថា ចារីថ្នាក់ក្រោមអាចស៊ាំទៅនឹងការអនុវត្តទៅហើយ[521]។ ហេតុដូច្នេះ កម្មាភិបាលនៅក្នុងតំបន់៤១ អាចដកជាច្រើនជំហានពីចេតនាប្រល័យពូជសាសន៍របស់ស្ថាបនិក

---

[518] សំណុំរឿង ០០២-ឯកសារ **D97/15/9** កថាខណ្ឌ ៧៥-៨៣។

[519] ភ័ស្តុតាងអំពីចេតនាប្រល័យពូជសាសន៍ពីខាងក្រៅតំបន់ ៤១ និងភូមិភាគកណ្តាល មិនបង្ហាញថា ការសម្លាប់ជនជាតិចាមដែលត្រូវបានចោទប្រកាន់ ត្រូវបានអនុវត្តដោយក្រុមសហឧក្រិដ្ឋកម្មរួមក្នុងរឿងក្តីបច្ចុប្បន្ន ជាមួយនឹងចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ជាផ្នែកមួយនៃគោលបំណងរួម។ សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៩៧-៦១៥។

[520] ប្រៀបធៀបសំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ១៩៥ (“កែ ពក អោ អាន និងកម្មាភិបាល ប.ក.ក ដទៃទៀត បានដឹងអំពីគោលបំណងរួមនៃការអនុវត្តគោលនយោបាយ ប.ក.ក ដូចខាងក្រោម នៅភូមិភាគកណ្តាលនៃកម្ពុជាប្រជាធិបតេយ្យ”) ជាមួយនឹងសំណុំរឿង ០០២-ឯកសារ **E313** កថាខណ្ឌ ៧២៤, ៧៧៧, ៨០៤, ៨៣៥។

[521] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៦២៣ (សន្និដ្ឋានថា “ដោយសារប្រព័ន្ធប្រាស្រ័យទាក់ទងគ្នាតាមខ្សែបណ្តោយរបស់ ប.ក.ក ហាមមិនឲ្យប្រាស្រ័យទាក់ទងគ្នាតាមខ្សែទទឹង នោះទើបស្ទើរតែមិនអាចថា ថ្នាក់ក្រោមអាចរៀបចំផែនការ និងអនុវត្តប្រតិបត្តិការចាប់ខ្លួន និងសម្លាប់ដែលមានលក្ខណៈទូទៅ និងសម្របសម្រួលបានយ៉ាងល្អបែបនេះឡើយសម្រាប់ថ្នាក់ក្រោម”) កថាខណ្ឌ ១៩៥ (សន្និដ្ឋានថា គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមនៅភូមិភាគកណ្តាលដែលត្រូវបានចោទប្រកាន់ គឺការអនុវត្តគោលនយោបាយ ប.ក.ក)។

យុទ្ធនាការដែលរងការចោទប្រកាន់[522]។

## ៥. សេចក្តីសន្និដ្ឋានសំអាងហេតុទី៨-១៧

206. ដោយសារមានកំហុសខ្លឹមសារអង្គច្បាប់ជាច្រើន មេធាវីការពារក្តីសូមគោរពស្នើសុំអង្គបុរេជំនុំជម្រះ លើកលែងការចោទប្រកាន់ទាំងមូលដែលតុលាការពុំមានយុត្តាធិការលើរឿងក្តី និង បិទសំណុំរឿងប្រឆាំងនឹង អោ អាន ដោយសារតែពុំមានយុត្តាធិការបុគ្គល។

## IV. សំអាងហេតុទី១៨៖ សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានកំហុស ឬរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដោយខកខានមិនបានបដិសេធ ឬ ផ្អាកសំណុំរឿង០០៤/០២ ដើម្បីធានាភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចនីតិវិធី និង សិទ្ធិរបស់អោ អាន

207. ចាប់ពីការចាប់ផ្តើមកិច្ចស៊ើបសួររហូតដល់ការចេញដីកាដំណោះស្រាយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានតួនាទីជាវិជ្ជមានក្នុងការចាត់វិធានការបែបនេះដែលជាការចាំបាច់ក្នុងការធានាភាពត្រឹមត្រូវនិងសុចរិតភាពនៃកិច្ចនីតិវិធីបច្ចុប្បន្ននិងអនាគតក្នុងសំណុំរឿង០០៤/២ និង សិទ្ធិរបស់ អោ អាន[523]។ វិធានបោះឆ្នោតមតិភាគច្រើនលើសលុប ធ្វើឱ្យប៉ះពាល់ដល់សច្ចធារណ៍និរទោសពេញកំឡុងពេលស៊ើបអង្កេត។ ជាងនេះទៀត កំហុស ការមិនអនុវត្ត និង ការអនុវត្តដោយធ្វេសប្រហែសទាំងឡាយ បានរំលោភបទដ្ឋានជំនុំជម្រះក្តីដោយយុត្តិធម៌ជាមូលដ្ឋាន ក្នុងនោះរួមមានសិទ្ធិរបស់ អោ អាន ក្នុងការមានមេធាវី សិទ្ធិទទួលការជូនដំណឹងអំពីបទចោទ សិទ្ធិរៀបចំការការពារក្តីប្រកបដោយប្រសិទ្ធភាព សិទ្ធិមានសមភាពនៃមធ្យោបាយតទល់ក្តី និង សិទ្ធិប្តឹងឧទ្ធរណ៍ជាដើម។ វិបត្តិថវិការបស់សាលាក្តី និង ភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុទៅថ្ងៃអនាគត (គ្មានផែនការដោះស្រាយក្នុងករណីបរាជ័យ) ធ្វើឱ្យសិទ្ធិរបស់ អោ អាន និង សុចរិតភាពរបស់សាលាក្តីកាន់តែគ្រោះថ្នាក់ថែមទៀត។ ខណៈដែលការរំលោភបំពាននីមួយៗប៉ះពាល់ដល់លទ្ធភាពរបស់ អោ អាន ក្នុងការទទួលការជំនុំជម្រះក្តីដោយយុត្តិធម៌ ផលប៉ះពាល់កាន់តែច្រើនឡើងៗនៃការ

---

[522] សាលក្រមក្នុងរឿងក្តី *Popović* ភាគ ១ កថាខណ្ឌ ១៤១០។ សាលដីកាក្នុងរឿងក្តី *Popović* កថាខណ្ឌ ២០០៥-២០០៧។

[523] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចរួមលើផលប៉ះពាល់ដោយសារស្ថានភាពថវិកាមកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២ និងសារណាពាក់ព័ន្ធនានារបស់មេធាវីការពារ យឹម ទិត្យ* ឯកសារ **D349/6** ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ ៦៧។ កត់សម្គាល់ថា ទំនួលខុសត្រូវធ្លាក់ទៅលើសហចៅក្រមស៊ើបអង្កេតទាំងពីរ ប៉ុន្តែ សាលដីកានេះធ្វើឡើងប្រឆាំងតែទៅនឹងការប្រព្រឹត្តិរបស់ ស.ច.ស.អ ពាក់ព័ន្ធនឹងករណីនេះប៉ុណ្ណោះ។

រំលោភទាំងនេះ ប៉ះពាល់ដល់ភាពយុត្តិធម៌និងសុចរិតភាពនៃកិច្ចនីតិវិធីនៅក្នុងលក្ខណៈដែលធ្ងន់ធ្ងរ និងមិនអាចជួសជុលបានដែលធ្វើឲ្យការជំនុំជម្រះក្ដីដោយយុត្តិធម៌នៅ អ.វ.ត.ក មិនអាចធ្វើទៅបាន។ ក្នុង**ឧបសម្ព័ន្ធ ខ** មេធាវីការពារក្ដីសូមផ្ដល់ជូនប្រវត្តិនីតិវិធីពាក់ព័ន្ធនឹងការរំលោភសិទ្ធិទទួលបានការជំនុំជម្រះក្ដីដោយយុត្តិធម៌ ដែលបានពិភាក្សានៅក្នុងផ្នែកនេះ។

208. ការប្រព្រឹត្តិរបស់សហចៅក្រមស៊ើបអង្កេត ទាក់ទិននឹងតួនាទីរបស់ពួកគាត់ក្នុងការធានាភាពយុត្តិធម៌និងសុចរិតភាពនៃកិច្ចនីតិវិធីគឺស្ថិតក្នុងដំណាក់កាលប្ដឹងឧទ្ធរណ៍[524]។ មេធាវីការពារក្ដីអះអាងថា ការខកខាន របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបដិសេធ(ឬផ្អាក)សំណុំរឿងប្រឆាំងនឹង អោ អាន ទោះបីជាមានផលប៉ះពាល់កើនឡើងជាលំដាប់ចំពោះភាពត្រឹមត្រូវនិងសុចរិតភាពក្ដី គឺផ្អែកលើការសន្និដ្ឋានមិនត្រឹមត្រូវជាក់ស្ដែងទៅលើអង្គហេតុដែលធ្វើឲ្យមានការសម្រេចក្ដីដោយមិនយុត្តិធម៌ ឬ អយុត្តិធម៌ឬមិនសមហេតុផល ដែលបង្កើត បានជាការរំលោភធន្ទានុសិទ្ធិរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ តួនាទីក្នុងការធានាភាពត្រឹមត្រូវនិងសុចរិតភាពនៃកិច្ចនីតិវិធី និង សិទ្ធិជាសារវន្តរបស់ អោ អាន បច្ចុប្បន្នគឺធ្លាក់ទៅលើអង្គបុរេជំនុំជម្រះ[525]។ ជាលទ្ធផល មេធាវីសូមគោរពស្នើសុំអង្គបុរេជំនុំជម្រះបដិសេធដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង បដិសេធ សំណុំរឿង អោ អាន។

## ក. សហចៅក្រមស៊ើបអង្កេតអន្តរជាតិមានតួនាទីធានាឯករាជភាពតុលាការ ភាពយុត្តិធម៌ និង សុចរិតភាពកិច្ចនីតិវិធី និង សិទ្ធិ របស់ អោ អាន

209. អ.វ.ត.ក ត្រូវតែ “អនុវត្តយុត្តាធិការរបស់ខ្លួនសមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវ និងកិច្ចដំណើរការត្រឹមត្រូវតាមច្បាប់”[526]។ សហចៅក្រមស៊ើបអង្កេត គឺជាអ្នកធានាជាចម្បងនូវភាពយុត្តិធម៌ និងសុចរិតភាព និង កិច្ចនីតិវិធីត្រឹមត្រូវតាមច្បាប់[527]។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានសម្រេចកន្លងមកថា ការរក្សាសុចរិតភាពនៃកិច្ចនីតិវិធី គឺជា“ការទទួលខុសត្រូវ

[524] សំណុំរឿង ០០៤/១-ឯកសារ **D308/3/1/20** កថាខណ្ឌ ២១។

[525] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៥៥។

[526] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១២។ ច្បាប់ អ.វ.ត.ក មាត្រា ៣៣ ថ្មី។

[527] សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ១៧-១៨។

ចម្បង"[528] និង "កាតព្វកិច្ចជាសារវន្ត"[529] របស់សហចៅក្រមស៊ើបអង្កេត។ ជាងនេះទៀត សហចៅក្រមស៊ើបអង្កេត បានទទួលស្គាល់ថាអាណត្តិរបស់ខ្លួនក្នុងការធានាភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចនីតិវិធី តម្រូវឱ្យពួកគាត់ពិនិត្យមើលសំណុំរឿងទាំងមូល ហួសពីក្របខ័ណ្ឌពេលវេលានៃការស៊ើបអង្កេត[530]។ ប៉ុន្តែ ខណៈដែលការវាយតម្លៃរបស់ពួកគាត់មិនទាន់រួចរាល់នៅឡើយ ឱកាសក្នុងការធានាកិច្ចនីតិវិធីបញ្ចប់ជាមួយនឹងការចេញដីកាដំណោះស្រាយ[531]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេត មិនត្រឹមតែមានយុត្តាធិការក្នុងការជម្រះរឿងក្តីណាមួយដែលមានឥទ្ធិពលទៅលើភាពត្រឹមត្រូវនៃកិច្ចនីតិវិធីបច្ចុប្បន្ន និងអនាគតប៉ុណ្ណោះទេ[532] ប៉ុន្តែពួកគេថែមទាំង មានតួនាទីជាវិជ្ជមានក្នុងការ"ធ្វើចំណាត់ការចាំបាច់" ដើម្បីដោះស្រាយបញ្ហាទាំងនេះ[533]។ អន្តរាគមន៍របស់ពួកគាត់ត្រូវតែមានលក្ខណៈគ្រប់គ្រាន់ ដើម្បីធានាកិច្ចនីតិវិធីកុំឱ្យមានផលប៉ះពាល់ និង ការគំរាមកំហែងដូចបានប្រមើលទុក[534]។ ក្នុងករណីមានផលប៉ះពាល់មិនអាចជួសជុលបាន ឬការគំរាម

---

[528] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើរបស់ជនសង្ស័យសុំឯកសារចំនួនប្រាំ* ឯកសារ **D226/1** ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៤ កថាខណ្ឌ ៩។

[529] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើបន្ទាន់របស់ យឹម ទិត្យ សុំឱ្យសហចៅក្រមស៊ើបអង្កេតអន្តរជាតិពិចារណាឡើងវិញលើការដាក់បង្ហាញចម្លើយសាក្សីនៃសំណុំរឿង ០០៤ ទៅក្នុងសំណុំរឿង ០០២/០២* ឯកសារ **D229/3** ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ២០១៥ កថាខណ្ឌ ២៦។

[530] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/០២* ឯកសារ **D349** ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៥២ ("ចក្ខុវិស័យរបស់យើង មិនអាចផ្តោតតែនៅត្រឹមក្របខណ្ឌពេលវេលាដែលចេញដីកាដំណោះស្រាយរួចហើយ ថាជាពេលវេលាចុងបញ្ចប់នៃអាណត្តិការងាររបស់យើងទេ។ ការងាររបស់ ក.ស.ច.ស នៅតែបើកចំហ ហើយពាក់ព័ន្ធនឹងការចាប់ផ្តើមកសាងសំណុំរឿងប្រសិនបើមាន គឺខុសពីការងាររបស់អង្គជំនុំជម្រះផ្សេងៗនៅ អ.វ.ត.ក ដែលទទួលពិនិត្យសំណុំរឿងណាមួយតែនៅពេលដែលមានបណ្តឹងឧទ្ធរណ៍/បណ្តឹងសាទុក្ខ ឬពាក្យសុំ (អ.ប.ជ និង អ.ជ.ត.ក) ឬប្រសិនបើមានដីកាបញ្ជូនទៅជំនុំជម្រះ (អង្គជំនុំជម្រះសាលាដំបូង)។")។

[531] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤៤។

[532] សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ១៧-១៨។

[533] សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ៦៧។

[534] រឿងក្តី *Kajelijeli តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-98-44A-A *សាលដីកា* ("សាលដីកាក្នុងរឿងក្តី *Kajelijeli*") ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០០៥ កថាខណ្ឌ ២៥៥, ៣២៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០០ ("រាល់ការរំលោភសិទ្ធរបស់ជនជាប់ចោទនាំឱ្យមានការដោះស្រាយដោយស័ក្តិសិទ្ធិ យោងតាមមាត្រា ២(៣)(ក) នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង

កំហែងធ្ងន់ធ្ងរចំពោះកិច្ចនីតិវិធី សហចៅក្រមស៊ើបអង្កេតមានភារកិច្ចបញ្ចប់កិច្ចនីតិវិធីដោយទម្លាក់បទចោទ ឬបង្គាប់ឲ្យផ្អាកជាអចិន្ត្រៃយ៍[535]។ ការខកខានមិនបានដោះស្រាយផលប៉ះពាល់ឬបង្ការទប់ស្កាត់ការគំរាមកំហែងបែបនេះ គឺជាការខកខានដ៏អាម៉ាស់របស់ការិយាល័យសហចៅក្រមស៊ើបអង្កេតក្នុងការបំពេញភារកិច្ចក្នុងនាមជាអ្នកធានានូវភាពយុត្តិធម៌ និងសុចរិតភាព។

### ខ. វិធានមតិភាគច្រើនលើសលុបបានរំលោភសច្ចធាណ៌និរទោសរបស់ អោ អាន

210. សច្ចធាណ៍និរទោសរបស់ អោ អាន ត្រូវបានរំលោភបំពានតាមរយៈការស៊ើបអង្កេតដែលជាលទ្ធផលនៃការអនុវត្តវិធានមតិភាគច្រើនលើសលុប[536]។

211. សច្ចធាណ៍និរទោសនេះដាក់បន្ទុកក្នុងការបង្ហាញភ័ស្តុតាងដោយអយ្យការ[537]។ នៅក្នុងតុលាការព្រហ្មទណ្ឌទាំងអស់ ប្រការនេះមានន័យថា សំណុំរឿងមួយអាចប្រព្រឹត្តទៅបានប្រសិនបើអ្នក

---

សិទ្ធិ

នយោបាយ។”)។

[535] សំណុំរឿងលេខ ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ស.ដ/អ.ជ.ត.ក(២៨) *សេចក្តីសម្រេចលើបណ្តឹងសាទុកខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២* ឯកសារ **E284/4/8** ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ ៧៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០១។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Brđanin *និង* Talic សំណុំរឿងលេខ IT-99-36 *សេចក្តីសម្រេចលើញត្តិលើកទីពីររបស់* Brdanin *សុំលើកលែងការចោទប្រកាន់* ចុះថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ ៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០២។ សូមមើលផងដែរ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Slobodan Milošević សំណុំរឿងលេខ IT-02-54-AR73.4 *យោបល់ជំទាស់របស់ចៅក្រម* David Hunt *ទៅលើភាពអាចទទួលយកបាននៃភ័ស្តុតាងចម្លងក្នុងទម្រង់ជាចម្លើយជាលាយលក្ខណ៍អក្សរ* ចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ ២១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០៣។ សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06 *សេចក្តីសម្រេចលើផលវិបាកនៃការមិនដាក់បង្ហាញឯកសារដោះបន្ទុកដែលស្ថិតនៅក្នុងកិច្ចព្រមព្រៀង មាត្រា ៥៤(៣)(ង) និងពាក្យសុំផ្អាកការកាត់សេចក្តីជនជាប់ចោទ រួមគ្នាជាមួយបញ្ហាមួយចំនួនផ្សេងទៀតដែលត្រូវបានលើកឡើងនៅ* Status Conference *នៅថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៨* ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៨ កថាខណ្ឌ ៩២-៩៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០៤។

[536] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ៧(៤)។ វិធានផ្ទៃក្នុង អ.វ.ត.ក វិធាន ៧១(៤)(គ), ៧២(៤)(ឃ), ៧៧(១៣)។ ប្រសិនបើ អ.ប.ជ មិនអាចស្វែងរកសម្លេងគាំទ្រភាគច្រើនបានទេ គោលជំហរមូលដ្ឋានសម្រាប់រឿងក្តីរបស់ អោ អាន គឺថា ការកាត់ក្តីបន្ត។

[537] ច្បាប់ អ.វ.ត.ក មាត្រា ៣៥ ថ្មី។ វិធានផ្ទៃក្នុង អ.វ.ត.ក វិធាន ២១(ឃ), ៨៧(១)។ ICCPR មាត្រា ១៤(២)។

សម្រេចអង្គហេតុយល់ស្របទៅលើអង្គសេចក្ដីនៃសំណុំរឿងរបស់អយ្យការ ទោះជាដោយមតិភាគច្រើន ឬដោយមតិឯកច្ឆន្ទក្ដី។ ក្នុងសំណុំរឿង អោ អាន បន្ទុកនេះត្រូវបានអនុវត្តបញ្ច្រាសដោយអនុញ្ញាតឲ្យបន្តការស៊ើបអង្កេត និងចោទប្រកាន់ ទោះបីជាមានការជំទាស់ដោយចៅក្រមភាគច្រើនក៏ដោយ។

212. មុនពេលចាប់ផ្ដើមកិច្ចស៊ើបសួរ ចៅក្រមអង្គបុរេជំនុំជម្រះ ភាគច្រើនសម្រេចថា សំណុំរឿងប្រឆាំងនឹង អោ អាន មិនគួរបន្តនីតិវិធីឡើយ[538]។ ក៏ប៉ុន្ដែ សំណុំរឿងនេះត្រូវបានបញ្ជូនទៅសហចៅក្រមស៊ើបអង្កេត[539]។ ក្នុងកំឡុងពេល ស៊ើបសួរ ចៅក្រមភាគច្រើននៃ អង្គបុរេជំនុំជម្រះ ដដែលសម្រេចគ្រប់ពេលវេលាថា តុលាការពុំមានយុត្តាធិការទេ[540]។ ប៉ុន្ដែការស៊ើបអង្កេតចេះតែបន្ត។ នៅចុងបញ្ចប់នៃការស៊ើបអង្កេត សហចៅក្រមស៊ើបអង្កេត.ជ ទម្លាក់ការចោទប្រកាន់[541] ចំណែក

---

[538] ករណីខ្វែងយោបល់គ្នាលេខ ០០១/១៨-១១-២០០៨/អ.វ.ត.ក/អ.ប.ជ *ឧបសម្ព័ន្ធ I៖ សំណៅសាធារណៈមានកោសល្យ សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង* ឯកសារ **D1/1.3** ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ *យោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ន័យ ថុល និង ហួត វុទ្ធី* កថាខណ្ឌ ១៨-១៩។

[539] សំណុំរឿង ០០៤-ឯកសារ **D1/1.3** កថាខណ្ឌ ១៧, ៤៥។

[540] ឧទាហរណ៍ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ២១) *សេចក្ដីពិចារណាលើសំណើរបស់ អោ អាន សុំឲ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកិច្ចស៊ើបអង្កេតពាក់ព័ន្ធនឹងការរៀបអាពាហ៍ពិពាហ៍ដោយបង្ខំ* ឯកសារ **D257/1/8** ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ *យោបល់របស់ចៅក្រមជាតិនៃ អ.ប.ជ* កថាខណ្ឌ ១១-១៥។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ២៤) សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចលើសំណើលើកទីប្រាំរបស់ អោ អាន សុំបំពេញកិច្ចស៊ើបសួរ ឯកសារ **D260/1/1/3** ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ *យោបល់របស់ចៅក្រមជាតិនៃ អ.ប.ជ* កថាខណ្ឌ ២៧-៣០។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ២៣) *សេចក្ដីពិចារណាលើសំណើសុំរបស់ អោ អាន សុំមោឃភាពកិច្ចស៊ើបអង្កេតទាក់ទងនឹងវត្តតាមាក់* ឯកសារ **D263/1/5** ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៦ *យោបល់របស់ចៅក្រមជាតិនៃ អ.ប.ជ* កថាខណ្ឌ ៤១-៤២។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ២៧) *សេចក្ដីពិចារណាលើសំណើរបស់ អោ អាន សុំអង្គបុរេជំនុំជម្រះទទួលពិចារណាលើការធ្វើមោឃភាពកិច្ចស៊ើបសួរពាក់ព័ន្ធនឹងទួលបេង និងវត្តអង្គញ្ជី និងបទចោទនានាទាក់ទងនឹងទួលបេង* ឯកសារ **D299/3/2** ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ *យោបល់របស់ចៅក្រមជាតិនៃ អ.ប.ជ* កថាខណ្ឌ ៣៥-៣៩។ សំណុំរឿង ០០៤/២-ឯកសារ **D343/4** *យោបល់របស់ចៅក្រមជាតិនៃ អ.ប.ជ* កថាខណ្ឌ ១៥-១៩។

[541] សំណុំរឿង ០០៤/២-ឯកសារ **D359** កថាខណ្ឌ ៥៥៤-៥៥៥។

ឯ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅតែចេញដីកាចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះ[542]។ និយាយម្យ៉ាងទៀត ចាប់ពី ពេលចាប់ផ្តើមដំបូង ចៅក្រមភាគច្រើនបានសម្រេចស្របគ្នាបដិសេធ សំណុំរឿងប្រឆាំងនឹង អោ អាន ប៉ុន្តែ ទស្សនៈមតិភាគច្រើនត្រូវចាញ់ចៅក្រមភាគតិច ពោលគឺ ចៅក្រមអន្តរជាតិ។ ទោះបីជា ចៅក្រមទាំងអស់ មានសមភាពរវាងគ្នានឹងគ្នាតែឈ្មោះក្តី[543] ប៉ុន្តែ ទស្សនៈភាគតិច(ចៅក្រមអន្តរជាតិ) បានចង្អុលបង្ហាញទៅ រកទិសដៅនៃសំណុំរឿងនេះ ពោលគឺ ស្ថានភាពមួយដែលមានលទ្ធភាពទៅបានដោយសារវិធានមតិភាគច្រើនលើសលុបដែលប្រឆាំងនឹងសច្ចធានិរទោស ដូចដែលបានអនុវត្តចំពោះ អង្គបុរេជំនុំជម្រះ។ អ្នកដែលជ្រាបអំពីការ ចរចារវាង អ.ស.ប និង រាជរដ្ឋាភិបាលកម្ពុជា ដឹងថា វិធានមតិភាគច្រើនលើសលុបគឺត្រូវបានអនុម័តដោយហេតុថាអ្នកចរចាអន្តរជាតិមិនទុកចិត្តថាចៅក្រមខ្មែរមានឯករាជភាព[544]។ ប្រការនេះគឺខ្វះសុភវិនិច្ឆ័យ និង បង្កើតឡើងដោយមិនត្រឹមត្រូវ[545] ពោលគឺ ឬមួយចៅក្រមកម្ពុជា មានសមភាព

[542] សំណុំរឿង ០០៤/២-ឯកសារ **D360** KH 01588970-01588978 ទំព័រ ៦៨១-៦៨៩។ លេខឯកសារបង្ហាញថា ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ (លើកលែងការចោទប្រកាន់) ត្រូវបានដាក់នៅក្នុងសំណុំរឿង មុនដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (បញ្ជូនទៅជំនុំជម្រះ) ហើយទោះក្នុងករណីណាក៏ដោយ ស.ច.ស.អ បានដឹងយ៉ាងច្បាស់ពីគោលជំហរយូរមកហើយរបស់ ស.ច.ស.ជ ទៅលើយុត្តាធិការ។

[543] ច្បាប់ អ.វ.ត.ក មាត្រា ១២។

[544] យោងតាមអ្នកជំនាញ អ.វ.ត.ក John Ciorciari និង Anne Heindel, Scheffer បានលើកឡើងពីការតម្រូវឲ្យមានមតិភាគច្រើន ដើម្បី "គ្រប់គ្រងចៅក្រមកម្ពុជាដែលមានសម្លេងភាគច្រើន (ប្រសិនបើវាបង្ហាញថាជាល្បែងចុងក្រោយ)" និងបង្កើតនូវ "កម្រិតអប្បរមានៃការឃ្លាំមើលរបស់អន្តរជាតិក្នុងដំណើរការធ្វើសេចក្តីសម្រេចរបស់ចៅក្រម""។ Ciorciari & Heindel, *Hybrid Justice* (ការបោះពុម្ពលើកទី១ សហរដ្ឋអាមេរិក៖ The University of Michigan Press ឆ្នាំ២០១៤), ឯកសារ **D297.1** ទំព័រ ២២។ Cambodia Tribunal Monitor & Center for International Human Rights, Northwestern University School of Law, 'Composite Chronology of the Evolution and Operation of the Extraordinary Chambers in the Courts of Cambodia' ទំព័រ ៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០៥។ សូមមើលផងដែរ Human Rights Watch, 'Serious Flaws: Why the U.N. General Assembly Should Require Changes to the Draft Khmer Rouge Tribunal Agreement' ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ២០០៣ ទំព័រ ៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០៦។

[545] កំណត់សម្គាល់លើសំណុំឯកសារពី Katarina Grenfell កម្មវត្ថុ៖ កិច្ចប្រជុំថ្ងៃទី២៧ ខែមីនា ឆ្នាំ២០០២ ជាមួយរដ្ឋាភិបាលជប៉ុន ចុះថ្ងៃទី១ ខែមេសា ឆ្នាំ២០០២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០៧ (លើកឡើងសង្ខេបពីការប្រជុំ និងកត់សម្គាល់ថា Ralph Zacklin ជឿថា មតិភាគច្រើនជាយន្តការមានភាពសាំញ៉ាំ និងលំបាកខ្លាំងមែនទែន និងថា អង្គការសហប្រជាជាតិមិនដែលសប្បាយចិត្តជាមួយនឹងវាទេ)។ កំណត់សម្គាល់ផ្ញើទៅលោក Prendergast និង Knutsson ពី Hans Corell កម្មវត្ថុ៖ ការរៀបចំប្រជុំជាមួយរដ្ឋចំនួនបីដែលចូលរួមក្នុងតុលាការខ្មែរក្រហម ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០០០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០៨។ លិខិតរបស់ Human Rights Watch ផ្ញើទៅអគ្គលេខាធិការអង្គការសហប្រជាជាតិ កម្មវត្ថុ៖ វិធាននៃមតិភាគច្រើន ចុះថ្ងៃទី១៩

ឬមួយ មិនមានសមភាព។ ប្រសិនបើចៅក្រមខ្មែរមានសមភាព ទស្សនៈភាគច្រើនរបស់ពួកគាត់ត្រូវតែទទួលការគោរព។ ប្រសិនបើ ពួកគាត់មិនមានសមភាព ដោយសារគេយល់ឃើញថាខ្វះឯករាជភាព នោះសំណុំរឿងនេះត្រូវតែបដិសេធ ដោយសារវារំលោភសិទ្ធិ របស់ អោ អាន ក្នុងការទទួលបានប្រព័ន្ធយុត្តិធម៌ដែលមានឯករាជភាព[546]។ វិធាន មតិភាគច្រើនលើសលុប កើតចេញពីការសម្របសម្រួលផ្នែកនយោបាយនៅក្នុងលក្ខណៈមួយដែលគ្មាន តុលាការព្រហ្មទណ្ឌជាតិឬអន្តរជាតិណាមួយបានធ្វើនៅក្នុងសម័យទំនើបនេះ។ មិនអាចនឹកស្មានដល់ថា ការសម្របសម្រួលនេះធ្វើឡើងក្នុងន័យអនុវត្តប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សិទ្ធិទទួលបានការជំនុំជម្រះក្តីរបស់ជនត្រូវចោទទាល់តែសោះ។

## គ. កំហុស ការខកខានមិនបានអនុវត្ត និង ការអនុវត្តដោយធ្វេសប្រហែសទាំងឡាយដែលរំលោភ សិទ្ធិនីតិវិធីរបស់ អោ អាន

213. នៅក្នុងកំឡុងពេលស៊ើបអង្កេតសំណុំរឿង០០៤/២ សិទ្ធិនីតិវិធីរបស់ អោ អានត្រូវបានរំលោភដោយ កំហុស ការខកខានមិនបានអនុវត្ត និង ការអនុវត្តដោយធ្វេសប្រហែសជាច្រើន ដែលធ្វើឱ្យសិទ្ធិរបស់គាត់ ក្នុងការចូលរួមដោយប្រសិទ្ធភាពក្នុងការស៊ើបអង្កេតជាការបំភ័ន្តភ្នែក។ ការរំលោភទាំងនេះត្រូវតែបានពិចារណា(ឬពិចារណាឡើងវិញ)ក្នុងបរិបទនៃកិច្ចស៊ើបសួរទាំងមូល[547]។

---

ខែមិថុនា ឆ្នាំ២០០០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១០៩។ កំណត់សម្គាល់លើសំណុំឯកសារពី Stadler Trengove កម្មវត្ថុ៖ ការប្រជុំថ្ងៃទី១១ខែ វិច្ឆិកា ឆ្នាំ១៩៩៩ ដើម្បីពិនិត្យមើលការវិវត្តន៍ទៅមុខនៃការចរចាជាមួយរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១០។

[546] ច្បាប់ អ.វ.ត.ក មាត្រា ១០ ថ្មី។ វិធានផ្ទៃក្នុង អ.វ.ត.ក វិធាន ១៤(១)។ ICCPR មាត្រា ១៤(១)។

[547] សំណុំរឿង ០០២-ឯកសារ **E313** កថាខណ្ឌ ៤០-៤១។ សូមមើល *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06 *សេចក្តីសម្រេចកោសលុបអំពី "សំណើរបស់មេធាវីការពារក្តីសុំផ្អាកកិច្ចដំណើរការនីតិវិធីជាអចិន្ត្រៃយ៍"* ("*សេចក្តីសម្រេចកោសលុបក្នុងរឿងក្តី* Lubanga *អំពីសំណើរបស់មេធាវីការពារក្តីសុំផ្អាកជាអចិន្ត្រៃយ៍*") ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១១ កថាខណ្ឌ ១៦៥-១៦៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១១។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Lubanga Dyilo, សំណុំរឿងលេខ ICC-01/04-01/06 *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក* Thomas Lubanga Dyilo *ប្រឆាំងនឹងសេចក្តីសម្រេចអំពីការជំទាស់របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការតុលាការយោងតាមមាត្រា ១៩(២)(ក) នៃលក្ខន្តិកៈ ចុះថ្ងៃទី០៣ ខែតុលា ឆ្នាំ២០០៦* ("*សាលដីកាក្នុងរឿងក្តី* Lubanga *លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចអំពីការជំទាស់របស់មេធាវីការពារក្តីទៅនឹងយុត្តាធិការ*") ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ២៨-២៩, ៣៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១២។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Bemba សំណុំរឿងលេខ ICC-01/05-01/08 *សេចក្តីសម្រេចលើ "សំណើរបស់មេធាវីការពារក្តីសុំការអនុញ្ញាតប្តឹង*

214. អោ អាន ត្រូវបានបដិសេធ*សិទ្ធិទទួលបានការការពារក្ដីដោយមេធាវីតាមការជ្រើសរើសរបស់ខ្លួន*[548] ក្នុងរយៈពេល៤ខែកន្លះ គិតចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ ដល់ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០១២[549]។ នៅថ្ងៃ ទី១៥ ខែកក្កដា ឆ្នាំ២០១១ អង្គភាពគាំពារការការពារក្ដីបានអនុម័តយល់ព្រម

---

*ខណ្ឌរណ៍ប្រឆាំងនឹង "សេចក្ដីសម្រេចលើសំណើរបស់មេធាវីការពារក្ដីសុំសំណងចំពោះការរំលោភលើដំណើរការ"* ("*សេចក្ដីសម្រេចក្នុងរឿងក្ដី Bemba លើសំណើរបស់មេធាវីការពារក្ដីសុំការអនុញ្ញាតប្ដឹងឧទ្ធរណ៍*") ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០១៥ កថាខណ្ឌ ១២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១៣។ រឿងក្ដី *Barayagwiza តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-97-19-AR72 *សេចក្ដីសម្រេច* ("*សេចក្ដីសម្រេចក្នុងរឿងក្ដី Barayagwiza*") ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ១៩៩៩ កថាខណ្ឌ ៧៣, ៧៦-៧៧ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១៤។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Nikolić* សំណុំរឿងលេខ IT-94-2-PT *សេចក្ដីសម្រេចលើញត្តិរបស់មេធាវីការពារក្ដីសុំជំទាស់នឹងការអនុវត្តយុត្តាធិការរបស់តុលាការ* ("*សេចក្ដីសម្រេចក្នុងរឿងក្ដី Nikolić លើញត្តិរបស់មេធាវីការពារក្ដីសុំជំទាស់នឹងការអនុវត្តយុត្តាធិការ*") ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០០២ កថាខណ្ឌ ១១១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១៥។ នៅក្នុងរឿងក្ដីប្រឆាំងនឹង *Florence Hartmann* សំណុំរឿងលេខ IT-02-54-R77.5 *សំអាងហេតុអំពីញត្តិរបស់មេធាវីការពារក្ដីសុំផ្អាកកិច្ចដំណើរការនីតិវិធីចំពោះការរំលោភលើដំណើរការនីតិវិធី* ("*សំអាងហេតុក្នុងរឿងក្ដី Hartmann អំពីញត្តិរបស់មេធាវីការពារក្ដីសុំផ្អាក*") ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០០៩ កថាខណ្ឌ ៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១៦។

[548] ច្បាប់ អ.វ.ត.ក មាត្រា ២៤ ថ្មី។ វិធានផ្ទៃក្នុង អ.វ.ត.ក វិធាន ២១(១)(ឃ) និង ២២(១)។ ICCPR មាត្រា ១៤(៣)(ឃ)។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើញត្តិ និងសារណាបន្ថែមស្ដីពីសិទ្ធិរបស់ជនសង្ស័យក្នុងការមានមេធាវី* ឯកសារ **D122/6** ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៣ កថាខណ្ឌ ៧៦ ("សិទ្ធិជាសារវ័ន្តដែលអាចត្រូវដាក់កំហិតបាន លុះត្រាតែនៅក្នុងកាលៈទេសៈមួយចំនួនដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់ [...] ហើយអនុវត្តតាមដំណើរការដែលត្រូវបានកំណត់យ៉ាងច្បាស់លាស់។")។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Martić*, សំណុំរឿងលេខ IT-95-11-PT *សេចក្ដីសម្រេចលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អ្នកកាន់ឯកសារ* ចុះថ្ងៃទី០២ ខែសីហា ឆ្នាំ២០០២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១៧។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Lubanga Dyilo* សំណុំរឿងលេខ ICC-01/04-01/06 *សេចក្ដីសម្រេចលើ "សំណើបន្ទាន់យោងតាមវិធាន ២១-៣ នៃវិធាននីតិវិធី និងភស្តុតាង" និង "សំណើបន្ទាន់សុំតែងតាំងមេធាវីប្រចាំការ" ដែលត្រូវបានដាក់ដោយ Thomas Lubanga Dyilo នៅចំពោះមុខប្រធាន នៅថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០០៧ និងថ្ងៃទី១០ ខែឧសភា ឆ្នាំ២០០៧* ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០០៧ កថាខណ្ឌ ៩, ២៤-២៥, ៥២-៥៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១៨។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Akayesu* សំណុំរឿងលេខ ICTR-96-4-A *សេចក្ដីសម្រេចទាក់ទងនឹងការចាត់តាំងមេធាវី* ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៩៩ ទំព័រ ៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១៩។ *រឿងក្ដីរដ្ឋអាជ្ញា តទល់នឹង Gérard Ntakirutimana* សំណុំរឿងលេខ ICTR-96-10-T/ICTR-96-17-T *សេចក្ដីសម្រេចលើញត្តិរបស់ជនជាប់ចោទសុំជំនួសមេធាវីដែលត្រូវបានចាត់តាំង/កែតម្រូវ* ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ១៩៩៧ ទំព័រ ៥ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២០។

[549] ទោះបីជា Rogers ត្រូវបានតែងតាំងជាមេធាវីការពារក្ដី អោ អាន រហូតដល់ខែកុម្ភៈ ឆ្នាំ២០១៤ ក៏ដោយ Göran Sluiter ត្រូវបានតែងតាំងជាសហមេធាវីបរទេសនៅថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១២។

លើ ពាក្យសុំរបស់ Richard Rogers ជំនួសក្នុងបញ្ជីរបស់អង្គភាពគាំពារការការពារក្តី[550]។ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ អោ អាន បាន ជ្រើសរើសយក Richard Rogers ពីបញ្ជីឈ្មោះក្នុងនាមជាសហមេធាវីអន្តរជាតិតាមការជ្រើសរើសរបស់ គាត់[551]។ នីតិវិធីនៃការជ្រើសរើស Richard Rogers ជាសហមេធាវីអន្តរជាតិរបស់ អោ អាន និង ការទទួលស្គាល់របស់គណៈមេធាវីកម្ពុជា បានបង្កើតនូវការអនុវត្តដែលយល់ព្រមដោយសហចៅក្រមស៊ើបអង្កេត គណៈមេធាវីកម្ពុជា និង ការិយាល័យរដ្ឋបាល[552]។ ការិយាល័យរដ្ឋបាលបានបដិសេធមិនផ្តល់កិច្ចសន្យាផ្តល់សេវាច្បាប់របស់ Richard Rogers រហូតដល់ពេលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចេញដីកាបង្គាប់ឱ្យផ្តល់កិច្ចសន្យា ផ្តល់សេវាច្បាប់នៅខែកុម្ភៈ ឆ្នាំ២០១៤[553]។ ចាប់ពីថ្ងៃទី២២ ខែមីនា ឆ្នាំ២០១២ តរហូតដល់ ខែកុម្ភៈ ឆ្នាំ២០១៤ ការិយាល័យរដ្ឋបាល(តាមរយៈប្រធានអង្គភាពគាំពារការការពារក្តី) បានចាត់វិធានការវិសាមញ្ញក្នុងការ រារាំងការចាត់តាំង Richard Rogers ជាសហមេធាវីការពារក្តី អោ អាន[554]។ អង្គបុរេជំនុំជម្រះ បដិសេធដាច់អហង្ការថាសំអាងហេតុរបស់ការិយាល័យរដ្ឋបាល

---

[550] លិខិតផ្ញើទៅ Richard J. Rogers កម្មវត្ថុ៖ ពាក្យសុំមេធាវីបរទេស ឯកភាពដោយអង្គភាពគាំពារការការពារក្តី ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២១។

[551] អោ អាន បានបញ្ជាក់ជាផ្លូវការពីការជ្រើសរើស Rogers របស់ខ្លួន ចេញពីបញ្ជីរបស់អង្គភាពគាំពារការការពារក្តី ដោយចុះហត្ថលេខាលើ៖ (ក) ទម្រង់បែបបទរបស់អង្គភាពគាំពារការការពារក្តីលេខ ៧៖ សំណើសុំជួល/ចាត់តាំងសហមេធាវីការពារក្តី ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២២ (ខ) លិខិតផ្ទេរសិទ្ធិ ចុះហត្ថលេខានៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២៣ និង (គ) លិខិត កម្មវត្ថុ៖ សិទ្ធិក្នុងការជ្រើសរើសមេធាវី ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២៤។

[552] លិខិតផ្ញើជូន Patricia O'Brien ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២៥។

[553] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចទទួលស្គាល់មេធាវីតំណាងជនសង្ស័យ តាអាន* ឯកសារ **D122/12** ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤។ សូមមើលផងដែរ សំណុំរឿងលេខ ១០-០៧-២០១៣-អ.វ.ត.ក/អ.ប.ជ ដីកាសម្រេចលើ "បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធពាក្យសុំរបស់ *Richard Rogers ដាក់បញ្ចូលឈ្មោះនៅក្នុងបញ្ជីមេធាវីបរទេស* ("*ដីកាសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Rogers*") ឯកសារលេខ ៨ ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០១៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២៦។

[554] ទាំងនេះរួមបញ្ចូលទាំងការដកហូតសេចក្តីសម្រេចចុះខែកក្កដា ឆ្នាំ២០១១ លើការដាក់បញ្ចូល Rogers ទៅក្នុងបញ្ជីរបស់អង្គភាពគាំពារការការពារក្តី នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ ការបដិសេធពាក្យសុំថ្មីសុំបញ្ចូលទៅក្នុងបញ្ជីរបស់អង្គភាពគាំពារការការពារក្តីនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០១៣ ការព្យាយាមប្តឹងជិតចិត្តចៅក្រម អ.ប.ជ Downing មិនឱ្យធ្វើសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងការបដិសេធលើកក្រោយ ការចោទប្រកាន់ដែលគ្មានមូលដ្ឋានប្រឆាំងនឹងក្រមសីលធម៌ និងភាពខ្វះខ្វែងរបស់ Rogers និងការបដិសេធផ្តល់ឱកាសដល់ Rogers ដើម្បីធ្វើការឆ្លើយតប ជាមួយនឹងទម្រង់ផ្សេងទៀតនៃការខ្ទះខ្ជាយពេល

មិនស្របច្បាប់ មានកំហុស និង មិនពាក់ព័ន្ធ[555]។ ការពន្យារពេល៤ខែកន្លះគឺមានលក្ខណៈតាមទំនើងចិត្ត និង រារាំងដោយចេតនា ហើយគឺជាការបដិសេធតាមការសន្មតនូវសិទ្ធិរបស់ អោ អាន ក្នុងការតំណាងដោយមេធាវីតាមការជ្រើសរើសរបស់គាត់។ ការពន្យារនេះក៏ជា ផលវិបាកទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ផ្សេងៗទៀត ក្នុងនោះរួមមានការបដិសេធ របស់សហចៅក្រមស៊ើបអង្កេត មិនពិចារណាសំណើសំខាន់មួយរបស់មេធាវីការពារក្តីដោយសារមានឈ្មោះ Richard Rogers[556] ការពន្យារកិច្ចនីតិវិធីមិនសមស្រប និង បង្វែរពេលវេលានិងធនធានដែលមិនចាំបាច់របស់ មេធាវីការពារក្តី។

215. អោ អាន ត្រូវបានបដិសេធ*សិទ្ធិទទួលបានការជូនដំណឹងទាន់ពេលវេលា និង ដោយពិស្តារអំពីលក្ខណៈ និង មូលហេតុនៃបទចោទប្រឆាំងនឹងគាត់*[557] អស់រយៈពេលយ៉ាងហោចណាស់ចំនួន៣ឆ្នាំ ក្រោយពេលគាត់ត្រូវបានជូនដំណឹងអំពីការចោទប្រកាន់។ នៅថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបម្រុង បានជូនដំណឹងដល់ អោ អាន ថា "គាត់ត្រូវបានចាត់ទុកជាជនសង្ស័យនៅក្នុងកិច្ចស៊ើបសួរដែលកំពុងដំណើរការ" និងបានជម្រាបគាត់អំពីសិទ្ធិរបស់គាត់ (រួមមានសិទ្ធិក្នុងការចូលពិនិត្យសំណុំរឿង)[558]។ ទោះជាយ៉ាងណាក៏ដោយ អោ អាន មិនបានទទួលព័ត៌មានអំពីបទចោទនានាប្រឆាំងនឹងរូបគាត់ ឬអង្គហេតុគាំទ្របទចោទរហូតដល់ថ្ងៃទី២៧

---

វេលា និងការបង្កភាពរាំងស្ទះ។ ការពិនិត្យមើលពេញលេញ និងប្រវត្តិលម្អិតនៃការបង្កភាពរាំងស្ទះរបស់ការិយាល័យរដ្ឋបាលក្នុងបញ្ហានេះ អាចរកមើលបាន និងត្រូវបានបញ្ចូលដោយយោងទៅសេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ *Rogers* កថាខណ្ឌ ២-៣៩។

[555] សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ *Rogers* កថាខណ្ឌ ៥៨-៨៤។ សូមមើលផងដែរ កថាខណ្ឌ ៨៥ (ដែល អ.ប.ជ យល់ឃើញថា "មិនចាំបាច់ពិនិត្យមើលបន្ថែម" នូវកង្វះភាពត្រឹមត្រូវនៃនីតិវិធី កង្វះភាពសុទ្ធចិត្ត និងភាពលម្អៀងពីសំណាក់ប្រធានអង្គភាពគាំពារការការពារក្តីទេ)។

[556] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ចម្លើយតបទៅនឹងលិខិតផ្ញើទៅសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងការខកខានរបស់សហចៅក្រមស៊ើបអង្កេតក្នុងការផ្តល់លទ្ធភាពចូលពិនិត្យសំណុំរឿងដល់សហមេធាវីការពារក្តី អោ អាន* ឯកសារ **D122/7/1** ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០១៣។

[557] វិធានផ្ទៃក្នុង អ.វ.ត.ក វិធាន ២១(ឃ)។ សូមមើលផងដែរ វិធានផ្ទៃក្នុង អ.វ.ត.ក សទ្ទានុក្រម ដែលកំណត់និយមន័យ "ជនត្រូវចោទ" ជា "បុគ្គលណាម្នាក់ដែលត្រូវចោទប្រកាន់ចំពោះរឿងក្តីណាមួយ ក្នុងចន្លោះពេលពីមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ រហូតដល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬដីកាលើកលែងចោទប្រកាន់"។

[558] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ការជូនដំណឹងអំពីសិទ្ធិរបស់ជនសង្ស័យ វិធាន ២១.១ឃ* ឯកសារ **D110** ចុះថ្ងៃទី២៩ ខែកុម្ភៈ ឆ្នាំ២០១២។

ខែមីនា ឆ្នាំ២០១៥[559]។ អស់រយៈពេល៣ឆ្នាំ មេធាវីការពារក្តីត្រូវបានបដិសេធមិនឱ្យចូលពិនិត្យសំណុំរឿងទាល់តែសោះ[560] ដែលជាកំហុសអង្គច្បាប់មួយអនុលោមតាមសហចៅក្រមអន្តរជាតិនៃអង្គបុរេជំនុំជម្រះ[561]។ ប្រការនេះ បង្ហាញអំពីការប្រាសចាកពីការតព្វកិច្ចរបស់ សហចៅក្រមស៊ើបអង្កេត ក្នុងការផ្តល់ព័ត៌មាន "ទាន់ពេលវេលា"[562] ធ្វើឱ្យ អោ អាន ចាញ់ប្រៀបយ៉ាងខ្លាំងជាមួយនឹង សហព្រះរាជអាជ្ញាអន្តរជាតិ ហើយធ្វើឱ្យគាត់ស្រេ្តសនិងព្រួយបារម្ភ ដែលមិនចាំបាច់។ ការពន្យារពេលនេះគឺផ្អែកលើការបកស្រាយតាមរូបមន្តវិធានផ្ទៃក្នុង ជាជាងវិធីសាស្ត្រ ជាក់ស្តែងយោងតាមយុត្តិសាស្ត្រអន្តរជាតិ[563]។ សហចៅក្រមស៊ើបអង្កេត មិនបានលើកឡើងនូវផល

---

[559] សំណុំរឿង ០០៤-ឯកសារ **D242** KH 01079997 ទំព័រ ១២។

[560] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *សេចក្តីសម្រេចលើសំណើរបស់ក្រុមការពារតាអាន សុំចូលពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ឯកសារ **D121/4** ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៣។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចបឋមលើសំណើពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិដែលបដិសេធមិនអនុញ្ញាតឱ្យតាអាន ចូលពិនិត្យមើលសំណុំរឿង* ឯកសារ **D121/4/5** ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៤។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើពិចារណាឡើងវិញលើសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិលើសំណើរបស់ក្រុមមេធាវីការពារក្តីតាអាន សុំពិនិត្យមើលសំណុំរឿង និងចូលរួមការស៊ើបអង្កេត* ឯកសារ **D121/4/6** ចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៤។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើញត្តិរបស់តាអាន ស្នើសុំ (១) ចូលពិនិត្យមើលសេចក្តីសម្រេចទាំងអស់ទាក់ទងនឹងការចូលពិនិត្យមើលសំណុំរឿង និង (២) ការបំភ្លឺអំពីលក្ខណៈវិនិច្ឆ័យសម្រាប់ការធ្វើចំណាត់ថ្នាក់ឯកសារ* ឯកសារ **D217/1** ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១៤។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើញត្តិរបស់តាអាន ស្នើសុំ (១) ចូលពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម និង (២) ការបញ្ជាក់បំភ្លឺពាក់ព័ន្ធនឹងការចូលពិនិត្យមើលសំណុំរឿងរបស់ភាគី និងជនសង្ស័យ* ឯកសារ **D218/1** ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤។

[561] សំណុំរឿង ០០៤-ឯកសារ **D121/4/1/4** *មតិយោបល់របស់ចៅក្រម* *Chang-Ho Chung* *និង* *Rowan Downing* កថាខណ្ឌ ១៧, ២៥-២៩។

[562] ICCPR មាត្រា ១៤។ សេចក្តីអត្ថាធិប្បាយទូទៅរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៣២ កថាខណ្ឌ ៣១ (ចែងថា "សិទ្ធិក្នុងការទទួលព័ត៌មានពីបទចោទ "ភ្លាមៗ" តម្រូវឱ្យផ្តល់ព័ត៌មាននោះភ្លាម នៅពេលបុគ្គលពាក់ព័ន្ធត្រូវបានចោទប្រកាន់ជាផ្លូវការពីបទឧក្រិដ្ឋ ក្រោមច្បាប់ជាតិ ឬបុគ្គលនោះត្រូវបានកំណត់ឈ្មោះថាបែបនេះជាសាធារណៈ")។

[563] សំណុំរឿង ០០៤-ឯកសារ **D121/4/1/4** *មតិយោបល់របស់ចៅក្រម* *Chang-Ho Chung* *និង* *Rowan Downing* កថាខណ្ឌ ១៩, ២៥ (ដកស្រង់រឿងក្តី *Adolf* *តទល់នឹងប្រទេសអូទ្រីស* ECtHR ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ១៩៨២ កថាខណ្ឌ ៣០ (ចែងថាច្បាប់សិទ្ធិមនុស្ស "ចង់បានសារធាតុ ជាជាងការចាប់ផ្តើមបទចោទ ជាផ្លូវការ [ហើយ] ច្បាប់នេះតម្រូវឱ្យតុលាការពិនិត្យមើលហួសពីលក្ខណៈខាងក្រៅ និងត្រូវពិនិត្យតថភាពជាក់ស្តែងនៃនីតិវិធី ដើម្បីកំណត់ថាតើពិតជាមានបទចោទដែរឬអត់")។ សូមមើលផងដែរ *Foti* *តទល់នឹងប្រទេសអ៊ីតាលី* ECtHR ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ1982 កថាខណ្ឌ ៥២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ

ប្រយោជន៍ស្របច្បាប់ ដើម្បីផ្តល់យុត្តិកម្មក្នុងការផាត់ អោ អាន ចេញពីការស៊ើបអង្កេតឡើយ[564]។ ជាងនេះទៀត ក្រោយពីការចេញដីកាដំណោះស្រាយផ្សេងគ្នា និង ប្រឆាំងគ្នា រួចមក អោ អាន ត្រូវបានបដិសេធម្តងទៀតនូវការដឹងឮច្បាស់លាស់ ជាក់លាក់អំពីលក្ខណៈ និង មូលហេតុនៃបទចោទប្រឆាំងនឹងគាត់[565]។

216. ពេញរយៈពេលស៊ើបអង្កេត អោ អានត្រូវបានបដិសេធជាប្រព័ន្ធនូវសិទ្ធិរៀបចំការការពារក្តីប្រកបដោយប្រសិទ្ធភាព[566]ហើយត្រូវបានដាក់ឱ្យស្ថិតក្នុងស្ថានភាពចាញ់ប្រៀបយ៉ាងខ្លាំងទៅនឹង សហព្រះរាជអាជ្ញាអន្តរជាតិ ជាការ រំលោភ*គោលការណ៍សមភាពនៃមធ្យោបាយតទល់ក្តី*[567]។ ការិយាល័យសហព្រះរាជអាជ្ញា បានចូលពិនិត្យសំណុំរឿងចាប់តាំងពី ដើម ដំបូង ហើយមានលទ្ធភាពចូលរួមយ៉ាងសកម្មក្នុងការបង្កើតកិច្ចស៊ើបសួរ[568]។ មេធាវីការពារក្តីមិនមានលទ្ធភាពតាមដានការស៊ើបអង្កេតដោយសារខ្លួនលាតត្រដាង ដើម្បីផ្តល់សហចៅក្រមស៊ើបអង្កេត នូវជំនួយទាន់ពេល

---

១២៧។ សូមមើលផងដែរ *Kangasluoma តទល់នឹងប្រទេសហ្វាំងឡង់* ECtHR ចុះថ្ងៃទី ២០ ខែមករា ឆ្នាំ២០០៤ កថាខណ្ឌ ២៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២៨។

[564] សូមមើល *រឿងក្តី El Sayed* សំណុំរឿងលេខ CH/PTJ/2010/005 *ដីកាបង្គាប់ទាក់ទងនឹងយុត្តាធិការរបស់តុលាការក្នុងការសម្រេចលើពាក្យសុំរបស់លោក El Sayed* ចុះថ្ងៃទី១៧ ខែមីនា ឆ្នាំ២០១០ និងថាតើលោក *El Sayed* បានចូលរួមសវនាការឬទេ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ៥៣ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២៩។

[565] សូមមើល មូលដ្ឋានទី ១។

[566] ច្បាប់ អ.វ.ត.ក មាត្រា ៣៥ ថ្មី។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៣។ ICCPR មាត្រា ១៤។

[567] សេចក្តីអត្ថាធិប្បាយទូទៅរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៣២ កថាខណ្ឌ ៨, ១៣, ៣២, ៣៩, ៦២។

[568] សូមមើលឧទាហរណ៍ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំឱ្យបំពេញកិច្ចស៊ើបសួរទាក់ទងនឹងទីតាំងឧក្រិដ្ឋកម្មនៃសំណុំរឿងលេខ ០០៤ នៅភូមិភាគកណ្តាល និងការទទួលខុសត្រូវរបស់ជនសង្ស័យឈ្មោះតាអាន* ឯកសារ **D41** ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១១។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *សំណើរបស់សហព្រះរាជអាជ្ញាអន្តរជាតិសុំបំពេញកិច្ចស៊ើបសួរ* ឯកសារ **D216** ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១៤។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងទៅនឹងទីតាំងឧក្រិដ្ឋកម្មនានានៅក្នុងតំបន់ ១ និងការធ្វើទុក្ខបុកម្នេញចំពោះខ្មែរក្រោម* ឯកសារ **D65** ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ* ឯកសារ **D191** ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៤។

វេលាក្នុង តួនាទីប្រមូលភស្តុតាងដោះបន្ទុក[569] ឬ ដើម្បីកំណត់ឲ្យដំណឹង និង លើកការជំទាស់ទៅនឹងកំហុសនីតិវិធី នៅពេលកើតមាន ដោយទុកឲ្យ អោ អាន ស្ថិតក្នុងស្ថានភាពចាញ់ប្រៀបជាក់ស្តែងនិងអចិន្ត្រៃយ៍ទៅនឹង សហព្រះរាជអាជ្ញាអន្តរជាតិ[570]។ គិតត្រឹមខែមីនា ឆ្នាំ២០១៥ អោ អាន ត្រូវបានប្រគល់ជូននូវសំណុំរឿងដ៏ស្មុគស្មាញមួយ សំណើ ក្រោយអង្គហេតុត្រូវបានបដិសេធពីព្រោះយឺតពេក[571] ឆ្ងាយពីទ្រឹស្តីសំណុំរឿងដែលបានបង្កើតរួចហើយ[572] ឬ ហួសពីមធ្យោបាយរបស់តុលាការ[573]។ ការប្រឈមរបស់គាត់ចំពោះការអនុវត្តការស៊ើបអង្កេតដោយធ្វេស ប្រហែសត្រូវ

---

[569] វិធានផ្ទៃក្នុង អ.វ.ត.ក វិធាន ៥៥(៥)។

[570] សូមមើល រឿងក្តី *Salduz តទល់នឹងប្រទេសទួរគី* (“*Salduz*”) ECtHR ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៨ កថាខណ្ឌ ៥០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣០ (ថែងថា “ភាពត្រឹមត្រូវនៃការជំនុំជម្រះទំនងជារងព្យសនកម្មយ៉ាងធ្ងន់ធ្ងរពីការខកខានមិនអនុលោមតាមបទប្បញ្ញត្តិស្តីពី[សិទ្ធិទទួលបានការជំនុំជម្រះដោយត្រឹមត្រូវ] តាំងពីដើមដំបូង”)។

[571] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៥ របស់ អោ អាន* ឯកសារ **D260/1** ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខណ្ឌ ១៦, ២៣, ២៥។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៣ របស់ អោ អាន* ឯកសារ **D189/2** ចុះថ្ងៃទី ២០ ខែកញ្ញា ឆ្នាំ២០១៦ កថាខណ្ឌ ៣០, ៣២-៣៣។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើទីប្រាំមួយរបស់ អោ អាន សុំឱ្យបំពេញកិច្ចស៊ើបសួរ* ឯកសារ **D276/1** ចុះថ្ងៃទី១២ ខែតុលា ឆ្នាំ២០១៦ កថាខណ្ឌ ១៨-២០, ២៥-២៨, ៣១-៤១។

[572] សំណុំរឿង ០០៤-ឯកសារ **D260/1** កថាខណ្ឌ ១៧, ២៤-២៥។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសេចក្តីកែសម្រួលសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ៤ របស់ អោ អាន* ឯកសារ **D244/1** ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០១៦ កថាខណ្ឌ ២១-២៣។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស (អបជ) *បណ្តឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីប្រាំមួយរបស់ អោ អាន* ឯកសារ **D276/1/1/1** ចុះថ្ងៃទី ០៩ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២, ១៩, ២៨-៣១។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើលើកទីប្រាំពីររបស់ អោ អាន សុំឱ្យបំពេញកិច្ចស៊ើបសួរ* ឯកសារ **D277/1** ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៦ កថាខណ្ឌ ៤២-៤៣, ៥០, ៥៧-៥៨។ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *សេចក្តីសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ អា អាន* ឯកសារ **D311/1** ចុះថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០១៦ កថាខណ្ឌ ១៤, ២០-២១, ៣០, ៤៧, ៦៥។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៥) *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី១២ របស់ អោ អាន* ឯកសារ D320/1/1/4 ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ ២៥-២៨។

[573] សំណុំរឿង ០០៤-ឯកសារ **D276/1** កថាខណ្ឌ ៣០ (ថែងថា “សំណើសុំកំណត់អត្តសញ្ញាណ និងស្តាប់ចម្លើយសមាជិកគ្រួសារទាំងអស់របស់ កែ ពក និងតាម៉ុក ដែលមានតំណែងផ្លូវការ ឬមិនផ្លូវការនៅតំបន់ ៤១ គឺជាសំណើជារួមមានលក្ខណៈទូ

បានចាត់ទុកថាជាអកុសល[574]ប៉ុន្តែមកត្រឹមពេលនោះវាមានលក្ខណៈចង្អៀតពេលក្នុងការជួសជុល។ ជាងនេះទៀត *ដីកាសន្និដ្ឋានស្ថាពរ*របស់អ្នកស្រីសហព្រះរាជអាជ្ញាជាតិយោងដល់ (និងបញ្ចូលតាមការយោង) ឯកសារពីការខ្វែងគំនិតគ្នាតាមវិធាន៧១ រវាងសហព្រះរាជអាជ្ញា[575]។ គ្មានសម្ភារៈភស្តុតាងណាមួយ ដែលបានយោងដល់ឬបញ្ចូលគ្នាត្រូវបានលាតត្រដាងជូនមេធាវីការពារក្តីឡើយ[576] ដែលមានន័យស្មើនឹងការ បដិសេធមធ្យោបាយគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការការពារក្តីរបស់គាត់[577]។

217. អោ អាន ត្រូវបានបដិសេធមិនផ្តល់ឱកាសតទល់ជាមួយសាក្សីដាក់បន្ទុក និង ឱកាសទទួលបានការបង្ហាញនិងតទល់ជាមួយសាក្សីក្នុងនាមជាតំណាងឲ្យគាត់ក្នុងលក្ខខណ្ឌដូចគ្នានឹងភ័ស្តុតាងដាក់បន្ទុកដែលប្រឆាំងនឹងរូបគាត់[578]។ មេធាវីការពារក្តីបានរកឃើញកំហុសធំៗ ភាពមិនសុក្រឹត និងការអនុវត្តដោយធ្វេសប្រហែសក្នុងការស៊ើបអង្កេតជាច្រើនចំណុចនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ[579]ដែលជាទម្រង់ដើមនៃភស្តុតាង និង ទទួលបានការសន្មត់ថាអាចជឿទុកចិត្តបាន[580]។

---

ទៅ។ ខ្ញុំមិនមានគម្រោងចំណាយធនធានដើម្បីបំពេញកិច្ចស៊ើបសួរដែលត្រូវការការងារយ៉ាងច្រើនបែបនេះឡើយ")។ សូមមើលផងដែរ សំណុំរឿង ០០៤-ឯកសារ **D277/1** កថាខណ្ឌ ៥១-៥៦។

[574] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើរបស់ អោ អាន សុំបកប្រែ និងធ្វើប្រតិចារឹកខ្សែអាត់សំឡេង និងដាក់ឯកសារមួយចំនួនចូលក្នុងសំណុំរឿង* ឯកសារ **D274/1** ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ២១, ២៤, ២៧-២៨, ៥២, ៦១-៦៤, ៦៦-៦៧។ សូមមើលផងដែរ សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើសំណើសុំបំពេញកិច្ចស៊ើបសួរលើកទី ១៣ របស់ អោ អាន* ឯកសារ **D345/1** ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ ១៥-១៩។

[575] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសន្និដ្ឋានស្ថាពរទាក់ទងករណី អោ អាន អនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង* ឯកសារ **D351/4** ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ ៣, ៥-៩, ១១, ២៨, ៣៧។

[576] *ដីកាសម្រេចលើសំណើបន្ទាន់របស់ អោ អាន សុំដាក់បង្ហាញឯកសារ* កថាខណ្ឌ ៤-៦, ១៩-២០។

[577] ច្បាប់ អ.វ.ត.ក មាត្រា ៣៥(ខ) ថ្មី។ ICCPR មាត្រា ១៤(៣)(ខ)។ សេចក្តីអត្ថាធិប្បាយទូទៅរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៣២ កថាខណ្ឌ ៣៣ (ចែងថា "សម្ភារៈដោះបន្ទុកគួរត្រូវបានយល់ថាមិនត្រឹមតែរួមបញ្ចូលនូវសម្ភារៈដែលបង្ហាញពីភាពគ្មានទោសប៉ុណ្ណោះនោះទេ ប៉ុន្តែរួមបញ្ចូលទាំងនូវភ័ស្តុតាងផ្សេងទៀតដែលអាចជួយដល់ការការពារក្តីបាន")។

[578] ច្បាប់ អ.វ.ត.ក មាត្រា ៣៥ ថ្មី។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១៣។ ICCPR មាត្រា ១៤។ សេចក្តីអត្ថាធិប្បាយទូទៅរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ ៣២ កថាខណ្ឌ ៣៣, ៣៩។

[579] សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *សំណើសុំការបកប្រែ និងការធ្វើប្រតិចារឹកនៃខ្សែអាត់ថតសំឡេង និងសំណើសុំដាក់ឯកសារមួយចំនួនក្នុងសំណុំរឿង* ឯកសារ **D274** ចុះថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០១៥ កថាខណ្ឌ ២-៣

កំណត់ហេតុស្ដាប់ចម្លើយជាងពាក់កណ្ដាលទាក់ទិននឹងសំណុំរឿងរបស់ អោ អាន មិនមានអាត់ថតសំឡេង[581]ដែលស្របតាមការណែនាំរបស់សហចៅក្រមស៊ើបអង្កេតឡើយ[582]។ អង្គបុរេជំនុំជម្រះ បដិសេធសំណើរបស់ អោ អាន សុំមោឃភាពកំណត់ហេតុស្ដាប់ចម្លើយដែលពុំមានអាត់សំឡេង[583]។ ជាលទ្ធផល អោ អាន ពុំមានឱកាសកំណត់បាននូវកំហុស និង ភាពមិនសុក្រឹតនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយដែលពុំមានអាត់សំឡេងឬបដិសេធការសន្មតថាអាចជឿទុកចិត្តបាននៃកំណត់ហេតុ ស្ដាប់ចម្លើយទាំងនោះ[584]។ ស្រដៀងគ្នានេះដែរ យ៉ាងហោចណាស់មានការអនុវត្តដោយធ្វេសប្រហែសរបស់អ្នកស៊ើបអង្កេតចំនួនបីនាក់[585]បានធ្វើឲ្យលាយឡំភាគច្រើននៃភ័ស្តុតាងសាក្សីដែលពាក់ព័ន្ធជាមួយនឹងការរៀបរាប់ដំណើររឿងដាក់បន្ទុកដែលបានបង្កើតជាមុនរួចហើយ

---

ឧបសម្ព័ន្ធ ក និង ខ (រួមមានការប្រើប្រាស់ដោយពុំសមស្របនូវសំណួរនាំមុខលើបញ្ហាដ៏ចម្រូងចម្រាស់ ការមិនធ្វើកំណត់ហេតុអំពីភ័ស្តុតាងដោះបន្ទុក ឬភ័ស្តុតាងដែលអាចប៉ះពាល់ការពិពណ៌នារបស់សាក្សី ការបំផ្លើសភ័ស្តុតាងដែលសន្មតជាភ័ស្តុតាងដាក់បន្ទុក ការធ្វើកំណត់ហេតុដោយពុំត្រឹមត្រូវអំពីការពិពណ៌នារបស់សាក្សី ដើម្បីធ្វើឲ្យការពិពណ៌នានោះហាក់ដូចជាមានភាពសមហេតុផលដោយការក្លែងបន្លំ ការបកស្រាយទូទៅដោយពុំត្រឹមត្រូវអំពីភ័ស្តុតាង ការធ្វើការស្ដាប់ចម្លើយដែលត្រូវបានរៀបចំទុក និងការស្ដាប់ចម្លើយ "ក្រៅផ្លូវការ" និង វត្តមានរបស់បុគ្គលដែលមិនត្រូវបានស្គាល់អត្តសញ្ញាណនៅក្នុងការស្ដាប់ចម្លើយ និងការចូលរួមរបស់បុគ្គលនោះក្នុងការស្ដាប់ចម្លើយ)។

580 សំណុំរឿង ០០៤/២-ឯកសារ **D338/1/5** កថាខណ្ឌ ១៦, ២០, ២៤-២៥។

581 ក្នុងចំណោមកំណត់ហេតុស្ដាប់ចម្លើយទាំង ៣៥៤ ដែលមេធាវីការពារក្ដីបញ្ជាក់ថាមានភាពពាក់ព័ន្ធជាមួយនឹងរឿងក្ដីប្រឆាំងនឹង អោ អាន យ៉ាងហោចណាស់មានកំណត់ហេតុស្ដាប់ចម្លើយចំនួន ១៩៥ ពុំមានខ្សែអាត់ថតសម្លេង។

582 សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *សេចក្ដីណែនាំស្ដីពីការស្ដាប់ចម្លើយសាក្សី* ឯកសារ **D116** ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១២ KH 00867633 ទំព័រ ២ (អោ អាន មិនអាចជំទាស់នឹងប្រការនេះបានទេ ដោយសារតែគាត់ពុំមានលទ្ធភាពចូលពិនិត្យមើល ឬដឹងពីសេចក្ដីណែនាំទាំងនេះ។)។

583 សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *សាលដីកាលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពកំណត់ហេតុនៃការស្ដាប់ចម្លើយដែលមិនមានខ្សែអាត់សំឡេង* ឯកសារ **D296/1/1/4** ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ២៦-២៧។

584 សំណុំរឿង ០០៤/២-ឯកសារ **D338/1/5** កថាខណ្ឌ ១៦, ២០, ២៤-២៥។

585 សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៧) *សំណើសុំធ្វើមោឃភាពកំណត់ហេតុស្ដាប់ចម្លើយនានាដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតចំនួនបីរូប* ឯកសារ **D338/1/2** ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១៧ កថាខណ្ឌ ៣, ២២, ២៧-៣១ (រួមមានការផ្ដល់ព័ត៌មានដាក់បន្ទុកដល់សាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ការខកខានក្នុងការបន្តស្វែងរកតម្រុយដោះបន្ទុក ការខកខានក្នុងការវិនិច្ឆ័យចម្លើយដាក់បន្ទុកដោយមិនលម្អៀង និងការសន្ទនាដោយមិនបានថតយកសំឡេងត្រឹមត្រូវ)។

សង្កត់ជាតម្រុយអាចដោះបន្ទុក និង ការរំលឹកឡើងវិញរបស់សាក្សីអំពីព្រឹត្តិការណ៍ដែលបានផ្លាស់ប្តូរជាអចិន្ត្រៃយ៍[586]។ ការលាយឡំដ៏ច្រើននេះកើតឡើងមុនពេល អោ អាន ត្រូវបានអនុញ្ញាតឱ្យចូលពិនិត្យសំណុំរឿង។ ជាងនេះទៀត សាក្សីសំខាន់ៗត្រូវបានគេបង្ហាញ កំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេនៅពេលបន្ទាប់ដែលមាននៅក្នុងសំណុំរឿង០០២ ដែលការណ៍នេះអនុញ្ញាតឱ្យសហព្រះរាជអាជ្ញាអន្តរជាតិ ពិនិត្យ បង្កើតភ័ស្តុតាង និង កសាងសំណុំរឿងប្រឆាំងនឹង អោ អាន ក្នុងកំឡុងពេលកិច្ចនីតិវិធីសវនាការ ដោយគ្មានការចូលរួមរបស់ អោ អាន[587]។ ការធ្វើឱ្យប្រឡូសប្រឡាក់នូវភ័ស្តុតាងសំខាន់នេះបានធ្វើឱ្យសិទ្ធិរបស់ អោ អាន ក្នុងការតទល់ជាមួយសាក្សីនៅក្នុងសវនាការបន្ទាប់មានលក្ខណៈជាការបំភាន់ (កាន់តែបំភាន់ថែមទៀតប្រសិនបើសាក្សីស្លាប់ ឬមិនអាចមកផ្តល់សក្ខីកម្មបាន)[588]។

218. អោ អាន ត្រូវបានដកហូតនូវ*សិទ្ធិប្តឹងឧទ្ធរណ៍*[589]ពាក់ព័ន្ធនឹងការបដិសេធរបស់ ក.សច.ស ទៅលើ

---

[586] ក្នុងសេចក្តីសម្រេចរបស់ខ្លួនលើពាក្យសុំរបស់មេធាវីការពារក្តី អ.ប.ជ សន្និដ្ឋានថា ការជំទាស់របស់មេធាវីការពារក្តីទៅនឹងសច្ចធារណ៍នៃភាពមិនលម្អៀងរបស់អ្នកស៊ើបអង្កេតមិនទទួលបានជោគជ័យទេ ប៉ុន្តែ សេចក្តីសម្រេចនោះពុំបានបញ្ជាក់អ្វីទេអំពីឥទ្ធិពលនៃការប្រឡូកប្រឡាក់ភ័ស្តុតាងដោយអ្នកស៊ើបអង្កេតទៅលើសិទ្ធិនីតិវិធីរបស់ អោ អាន ទេ។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាសម្រេចលើសំណើសុំរបស់ អោ អាន ឱ្យអង្គបុរេជំនុំជម្រះធ្វើមោឃភាពកំណត់ហេតុស្តាប់ចម្លើយរបស់អ្នកស៊ើបអង្កេតបីរូប* ឯកសារ **D338/1** ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១៧ កថាខណ្ឌ ៦-៨។

[587] ដើម្បីមានព័ត៌មានលម្អិតបន្ថែមទៅលើជំហររបស់មេធាវីការពារក្តី សូមមើល សំណុំរឿងលេខ ០០៤/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស (អបជ) *បណ្តឹងឧទ្ធរណ៍របស់ អោ អាន ជំទាស់នឹងដីកាសម្រេចលើចម្លើយតប ឯកសារ D193/47, D193/49, D193/51, D193/53, D193/56 និង D193/60* ឯកសារ **D284/1/2** ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១៦ កថាខណ្ឌ ២-៥។ មេធាវីការពារក្តីបានបញ្ចូលទឡ្ហីករណ៍របស់ខ្លួនដោយការយោង។ បណ្តឹងឧទ្ធរណ៍នេះមិនត្រូវបានពិចារណាយ៉ាងត្រឹមត្រូវដោយ អ.ប.ជ ទេ ដោយសារតែវាត្រូវបានច្រានចោលថាមិនអាចទទួលយកបាន។

[588] ឧទាហរណ៍ សាក្សី កែ អ៊ុន ដែលអ្នកបើកបររបស់ កែ ពក បានស្លាប់នៅថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១០។ ឯកសារ **D219/702.1.141** (របាយការណ៍របស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ-កែ អ៊ុន ហៅ ឌិក) KH 01106548 ទំព័រ ១។ ឯកសារ **D6.1.437** (កំណត់ហេតុស្តាប់ចម្លើយ កែ អ៊ុន) KH 00271378-00271386 ទំព័រ ១-៩។ ឧទាហរណ៍ ការស្លាប់របស់សាក្សី កែ ពេជ្រវណ្ណៈ ត្រូវបានបញ្ជាក់ដោយម្តាយរបស់គាត់ ស៊ូ សឿន នៅក្នុងពេលសួរដេញដោលក្នុងសំណុំរឿង ០០២/០២ នៅថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៦។ កែ ពេជ្រវណ្ណៈ ជាកូនប្រុសរបស់ កែ ពក។ ឯកសារ **D6.1.379** (កែ ពេជ្រវណ្ណៈ) KH 00340559-00340578 ទំព័រ ១-២០។

[589] កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា មាត្រា ១២(២)។ ច្បាប់ អ.វ.ត.ក មាត្រា ៣៣ ថ្មី, ៣៦ ថ្មី។ វិធានផ្ទៃក្នុង អ.វ.ត.ក វិធាន ២១, ៧៤។ ICCPR មាត្រា ១៤(៥)។

សំណើសុំបើកការស៊ើបសួររបស់គាត់។ ក្រោយពីបានបដិសេធ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យ ស៊ើបសួរលើកទីពីររបស់ សហព្រះរាជអាជ្ញាអន្តរជាតិ តាំងពីដំបូង[590] ចៅក្រមជាតិភាគច្រើននៅក្នុងអង្គបុរេជំនុំជម្រះ បានរក្សាជំហរដដែល ថា គ្មានសកម្មភាពស៊ើបអង្កេតណាមួយគួរត្រូវបានអនុញ្ញាតនៅក្នុងសំណុំរឿង អោ អាន ឡើយ[591]។ ជំហរនេះនាំឲ្យ អង្គបុរេជំនុំជម្រះ បដិសេធបណ្ដឹងឧទ្ធរណ៍ទាំងអស់របស់ អោ អាន ពាក់ព័ន្ធនឹងសំណើសុំបើកការស៊ើបសួរ ដោយមិនគិតពីទឡ្ហីករណ៍ដែលបានលើកឡើង ខណៈដែលការស៊ើបអង្កេតចេះតែបន្តទៅមុខ[592]។ ការហាម ឃាត់ទាំងស្រុងទៅលើសិទ្ធិជាសារវ័ន្តដោយគ្មានយុត្តិកម្មត្រឹមត្រូវ ដូចក្នុងករណី អោ អាន ត្រូវបានអង្គសិទ្ធិ មនុស្សនិងតុលាការសិទ្ធិមនុស្សរកឃើញថា ជាការរំលោភសិទ្ធិទាំងនោះ[593]។

## គ. ភាពមិនប្រាកដប្រជាផ្នែកហិរញ្ញវត្ថុគំរាមកំហែងដល់ភាពយុត្តិធម៌និងសុចរិតភាពនៃកិច្ចដំណើរការ

---

[590] សំណុំរឿងលេខ ០០១/១៨-១១-២០០៨-អ.វ.ត.ក/អ.ប.ជ *ឧបសម្ព័ន្ធ II៖ សម្រង់សេចក្ដីពិចារណារបស់អង្គបុរេជំនុំជម្រះពាក់ព័ន្ធនឹងករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៧១ នៃវិធានផ្ទៃក្នុង* ឯកសារ **D11.1** ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣១។ សំណុំរឿង ០០៤-ឯកសារ **D1/1.3** *មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ន័យ ថុល និង ហួត វុទ្ធី*។

[591] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៣) *សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីប្រាំមួយរបស់ អោ អាន* ឯកសារ **D276/1/1/3** ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០១៧ កថាខណ្ឌ ២៥-៣០។ សំណុំរឿង ០០៤-ឯកសារ **D257/1/8** កថាខណ្ឌ ១-១៥។ សំណុំរឿង ០០៤-ឯកសារ **D263/1/5** កថាខណ្ឌ ៤១-៤២ (ដកស្រង់មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០០៩ ថា "អោ អាន មិនមែនជាមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម")។ សំណុំរឿង ០០៤/២-ឯកសារ **D320/1/1/4** កថាខណ្ឌ 15-20។ សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អបជ៣៦) *សាលដីកាសម្រេចលើបណ្ដឹងឧទ្ធរណ៍ជំទាស់នឹងដីកាសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរលើកទីដប់របស់ អោ អាន* ឯកសារ **D343/4** ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ២០១៧ កថាខណ្ឌ ១៤-១៩។ សូមមើលផងដែរ សំណុំរឿង ០០៤-ឯកសារ **D299/3/2** កថាខណ្ឌ ៣៤-៣៩។

[592] ផ្នែក IV(ខ)។

[593] *រឿងក្ដី Hirst តទល់នឹងចក្រភពអង់គ្លេស* (លេខ ២) ECtHR ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០០៥ កថាខណ្ឌ ៨២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣២ (ចែងថា "ការដាក់កំហិត [រួម] ជាទូទៅ ស្វ័យប្រវត្តិ និងដោយចៃដន្យទៅលើសិទ្ធិអនុសញ្ញាដ៏សំខាន់មួយត្រូវបានមើលឃើញថាស្ថិតនៅក្រៅកម្រិតនៃការវាយតម្លៃដែលអាចទទួលយកបាន ទោះបីកម្រិតនោះមានលក្ខណៈធំទូលាយយ៉ាងណាក៏ដោយ និងត្រូវបានមើលឃើញថាមានវិសមិតភាពជាមួយនឹងមាត្រា ៣ នៃពិធីសារលេខ ១")។ សូមមើលរឿងក្ដី *Alajos Kiss តទល់នឹងប្រទេសហុងគ្រី* ECtHR ចុះថ្ងៃទី ២០ ខែឧសភា ឆ្នាំ២០១០ កថាខណ្ឌ ៤២ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣៣។

## នីតិវិធី

219. នៅខែឧសភា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត ទាំងពីររូបបានសំដែង "ការព្រួយបារម្ភយ៉ាងខ្លាំង" ចំពោះការ រៀបចំថវិកាបច្ចុប្បន្នសម្រាប់ អ.វ.ត.ក និង មានទស្សនៈថា "ស្ថានភាពបច្ចុប្បន្ន និងទៅអនាគតមានភាព មិនស្របគ្នាជាមួយនឹងគោលការណ៍ជាមូលដ្ឋាននៃការជំនុំជ្រះក្ដីដោយយុត្តិធម៌ នីតិរដ្ឋ និង ឯករាជភាព តុលាការ"[594]។ ផលប៉ះពាល់នៃយន្តការផ្ដល់ថវិកាតុលាការនេះ ជាបញ្ហាចាប់តាំងពីការបង្កើត មកម្ល៉េះ[595]។ ការបិទទ្វារតុលាការឆាប់ពេក (ឬពេលវេលាមិន

---

[594] សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ១។

[595] នៅខែសីហា ឆ្នាំ២០០៧ អគ្គលេខាធិការអង្គការសហប្រជាជាតិ បានព្រមានថា អ.វ.ត.ក ទំនងជាមិនអាចបំពេញអណត្តិរបស់ខ្លួនបានទេ ដោយសារតែបានរកឃើញថា "ខ្វះបុគ្គលិក និងថវិកាយ៉ាងច្រើន"។ សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ២៤ (ដកស្រង់របាយការណ៍មហាសន្និបាតអង្គការសហប្រជាជាតិរបស់អគ្គលេខាធិការស្ដីពីការជំនុំជម្រះក្ដីខ្មែរក្រហម លេខ A/62/304 ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ១, ៤២)។ នៅឆ្នាំ២០១២ អគ្គលេខាធិការអង្គការសហប្រជាជាតិបានគូសបញ្ជាក់ពីវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងររបស់តុលាការ ដែលអាចធ្វើឲ្យប៉ះពាល់ប្រតិបត្តិការនាពេលអនាគតរបស់តុលាការ"។ សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ២៥ (ដកស្រង់របាយការណ៍មហាសន្និបាតអង្គការសហប្រជាជាតិរបស់អគ្គលេខាធិការស្ដីពីការជំនុំជម្រះក្ដីខ្មែរក្រហម លេខ A/67/380 ចុះថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០១២ ទំព័រ ១)។ នៅឆ្នាំ២០១៣ កង្វះហិរញ្ញវត្ថុធ្វើឲ្យតុលាការមិនអាចបើកបៀវត្សរ៍ដល់បុគ្គលិកជាតិ និងបណ្ដាលឲ្យបុគ្គលិកដើរចេញ និងធ្វើកូដកម្មជាបន្តបន្ទាប់។ សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ២៧ (ដកស្រង់របាយការណ៍មហាសន្និបាតអង្គការសហប្រជាជាតិរបស់អគ្គលេខាធិការ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/68/532 ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ កថាខណ្ឌ ៣, ៣៦)។ នៅឆ្នាំ២០១៥ វិបត្តិហិរញ្ញវត្ថុបាននាំឲ្យអគ្គលេខាធិការអង្គការសហប្រជាជាតិលើកឡើងថា "បរាជ័យផ្នែកហិរញ្ញវត្ថុរបស់អង្គជំនុំជម្រះនឹងក្លាយជាសោកនាដកម្មជាថ្មីម្ដងទៀត នៅក្នុងស្វះស្វែងរកយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា"។ សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ៣០ (ដកស្រង់របាយការណ៍មហាសន្និបាតអង្គការសហប្រជាជាតិរបស់អគ្គលេខាធិការ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* លេខ A/70/403 ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៥ កថាខណ្ឌ ៤៦)។ នៅឆ្នាំ២០១៦ អង្គការសហប្រជាជាតិបានរាយការណ៍ពីកង្វះហរិញ្ញវត្ថុដែល "ទំនងជាប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សកម្មភាពរបស់អង្គជំនុំជម្រះទាំងមូល"។ សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ៣១ (ដកស្រង់របាយការណ៍មហាសន្និបាតអង្គការសហប្រជាជាតិរបស់អគ្គលេខាធិការ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ("*សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់ អ.វ.ត.ក* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦") លេខ A/71/338 ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ៣៩)។ នៅពេលចរចាពីបញ្ហាថវិកានៅឆ្នាំ២០១៧ ការិយាល័យរដ្ឋបាលផ្ដល់យោបល់ថា "ចក្ខុវិស័យអំពីថវិកាមិនដែលមិនល្អបែបនេះទេ" ថា "ការចរចាថវិកានាពេលអនាគត នឹងក្លាយជាបញ្ហាលំបាកហួសពីកម្រិតធម្មតានៃការខិតខំប្រឹងប្រែង" និងថាតុលាការ "ស្ថិតនៅក្នុងសភាពគ្រោះថ្នាក់អាចធ្លាក់ទៅជាជនរងគ្រោះដោយសារការបិទបញ្ចប់ដោយចៃដន្យ ដោយគ្រាន់តែមូលហេតុថាថវិកាអាចឈប់បន្ត"។ សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ២៥។

ប្រាកដប្រជាដែលពុំមាននិយ័តកម្ម) អាចទុក ឱ្យដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "នៅរស់រវើក" ជុំវិញ អោ អាន ជារឿងរហូត និង "មិនស្របទៅនឹង តម្រូវការជាមូលដ្ឋាននៃនីតិរដ្ឋ " និង "ចោទជាសំណួរសំខាន់ៗអំពីភាពយុត្តិធម៌"សម្រាប់មេធាវីការពារក្តី[596]។ និយាយម្យ៉ាងទៀត សហចៅក្រមស៊ើបអង្កេត (ឥឡូវ អង្គបុរេជំនុំជម្រះ)ត្រូវបានរារាំងមិនឱ្យបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ប្រសិនបើមានហានិភ័យជាក់ស្តែងអំពីថវិកាមិនគ្រប់គ្រាន់ដើម្បីបញ្ចប់កិច្ចនីតិវិធីជំនុំជម្រះក្តី និង ការពិនិត្យលើបណ្តឹងសាទុក្ខ[597]។

220. យោងតាមព័ត៌មានបោះពុម្ពផ្សាយដោយ ការិយាល័យរដ្ឋបាល នៅក្នុងខែតុលា ឆ្នាំ២០១៨[598] ថវិកាដែលម្ចាស់ជំនួយសន្យាផ្តល់សម្រាប់ឆ្នាំ២០១៨ គឺមានចំនួន ១២,៥លានដុល្លារ ដែលតិចជាងតម្រូវការរបស់ តុលាការ ខណៈដែលកង្វះថវិកាពិតប្រាកដ(ផ្អែកលើថវិកាដែលទទួលបាន)មានចំនួន ១៧,៥១លានដុល្លារ។ ហេតុដូច្នេះ បើទោះជាការសន្យាទាំងអស់ត្រូវបានអនុវត្តតាម ហើយឧបត្ថម្ភធនរបស់អង្គការសហប្រជាជាតិ ពេញលេញចំនួន៨លានដុល្លារត្រូវបានអនុវត្ត[599]នោះ តុលាការនឹងខ្វះថវិកាចំនួន ៤,៥លានដុល្លារ។ ការសន្យារទាំងនេះមិនគ្រប់គ្រាន់ក្នុងការកាត់បន្ថយការព្រួយបារម្ភឡើយ មិនមែនដោយសារការសន្យាទាំងអស់ អាច មិនក្លាយជាការពិតទៅតាមការធ្វើវិភាគទានជាក់ស្តែងប៉ុណ្ណោះទេ ប៉ុន្តែសំខាន់ជាងនេះគឺដោយសារ "ការអនុវត្តរបស់ប្រធានគណនេយ្យរបស់អង្គការសហប្រជាជាតិក្នុងការបញ្ចេញបុរេប្រទានតែនៅពេលដែល បានទទួលកិច្ចព្រមព្រៀងដែលមានចុះហត្ថលេខាពាក់ព័ន្ធនឹងផ្តល់វិភាគទាន មិនមែនដោយឈរលើមូលដ្ឋាន

---

[596] សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ៥២-៥៤។

[597] សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ៥៨។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង Hinga Norman* សំណុំរឿងលេខ SCSL-20040140AR72(E) *សេចក្តីសម្រេចលើញត្តិបឋមផ្អែកលើកង្វះយុត្តាធិការ (ឯករាជ្យតុលាការ)* ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៤ កថាខណ្ឌ ២៦, ២៨, ៣០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣៤។ សូមមើលផងដែរ យោបល់ដាច់ដោយឡែករបស់ចៅក្រម Geoffrey Robertson ដែលគាត់បញ្ជាក់ថា ហិរញ្ញវត្ថុមានសុវត្ថិភាពសម្រាប់តុលាការទាំងមូល មានសារៈសំខាន់ដើម្បីការពារសិទ្ធិទទួលបានការពារក្តី និងឯករាជ្យភាពតុលាការ។

[598] គម្រោងបញ្ចប់ផែនការ អ.វ.ត.ក កែតម្រូវលើកទី ១៨ ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៨ កថាខណ្ឌ ១៣, ១៦។

[599] មហាសន្និបាតអង្គការសហប្រជាជាតិ *ប្រធានបទពិសេសៗទាក់ទងនឹងថវិកា-កម្មវិធីដែលត្រូវបានស្នើឡើងសម្រាប់ឆ្នាំ ២០១៨-២០១៩* លេខ A/RES/72/262 ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៨ ទំព័រ ៥-៦ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣៥ (កត់សម្គាល់ថា តុលាការបានស្នើសុំពីដំបូងនូវទឹកប្រាក់ ១០,៤ លានដុល្លារ។)។

នៃការគ្រាន់តែសន្យានោះឡើយ"[600]។ ក្នុងខែសីហា ឆ្នាំ២០១៨ មេធាវីការពារក្តីបានស្នើសុំបច្ចុប្បន្នភាព ហិរញ្ញវត្ថុរបស់តុលាការពីការិយាល័យរដ្ឋបាល[601]។ នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ប្រធានអង្គភាពការការពារក្តីបានឆ្លើយតប ដោយបង្ហាញថា កង្វះថវិកាគិតត្រឹមខែធ្នូ ឆ្នាំ២០១៨នេះគឺ មានចំនួន ១.៩៥៤.000 ដុល្លារ[602]។ ប៉ុន្តែ មិនប្រាកដថាតើកង្វះខាតថវិកាដូចដែលបានបង្ហាញជូនត្រូវបានគណនាដោយឈរលើ មូលដ្ឋាននៃតួលេខដែលបានផ្តល់ឱ្យឬយ៉ាងណា ដោយហេតុថាចំនួនតួលេខទាំងនេះមិនកើនឡើយ[603]។ នៅពេលសួរចំណុចនេះ ប្រធានអង្គភាពគាំពារការការពារក្តីមិនអាចពន្យល់បាននូវភាពខុសគ្នានេះឡើយ។

221. មិនត្រឹមតែថវិកាត្រូវបានទម្លាក់ឱ្យនៅក្រោមអ្វីដែល សហចៅក្រមស៊ើបអង្កេត ចាត់ទុកថាគ្រប់គ្រាន់សម្រាប់ បញ្ចប់ទាន់ពេលវេលានូវសំណុំរឿង០០៤/២[604]ប៉ុណ្ណោះទេ ប៉ុន្តែ អង្គការសហប្រជាជាតិ និង ម្ចាស់ជំនួយបានបង្ហាញថា ពួកគេមិនមានលទ្ធភាពអាចបំពេញតាមថវិកាដែលបានព្រមព្រៀងនោះទេ។ ជាងនេះទៀត អង្គការសហប្រជាជាតិ បានទទួលស្គាល់ថា ខ្លួនមិនអាចធានាផ្តល់ហិរញ្ញប្បទានគ្រប់គ្រាន់សម្រាប់តុលាការនាពេលអនាគតបាន ឡើយ[605]។ អង្គការសហប្រជាជាតិក៏ជឿថាពុំមានលក្ខខណ្ឌច្បាប់បង្ខំឱ្យខ្លួននិងរាជរដ្ឋាភិបាលត្រូវតែធានាថវិកាសម្រាប់ អ.វ.ត.ក

---

[600] សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ២៥។

[601] លិខិតគោរពជូនឯកឧត្តម ក្រាញ់ តូនី និងលោក Knut Rosandhaug កម្មវត្ថុ៖ ស្ថានភាពថវិកានៅក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣៦។

[602] លិខិតផ្ញើជូនសហមេធាវីការពារក្តីលោក អោ អាន កម្មវត្ថុ៖ ស្ថានភាពថវិកានៅក្នុងសំណុំរឿង ០០៤/២ ចុះថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣៧។

[603] ទឹកប្រាក់ហិរញ្ញប្បទានទាំងអស់ដែលបានទទួលនាំឱ្យខ្វះទឹកប្រាក់ចំនួន ២,៨២ លានដុល្លារអាមេរិក។ ទឹកប្រាក់ហិរញ្ញប្បទានទាំងអស់ដែលបានស្នើសុំ នាំឱ្យខ្វះទឹកប្រាក់ចំនួន 0,៥៤ លានដុល្លារអាមេរិក។

[604] គម្រោងបញ្ចប់ផែនការ អ.វ.ត.ក កែតម្រូវលើកទី ១៧ ចុះថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ១៩ (ចែងថា "ចំនួនបុគ្គលិកនៅក្នុងការិយាល័យឥឡូវកាន់តែតិចទៅៗ សូម្បីតែការលាឈប់បន្តិចបន្តួចក៏ធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់ស្មារតីរបស់ស្ថាប័ន និងលទ្ធភាពរបស់ការិយាល័យក្នុងការអនុវត្តតាមពេលវេលាដែលបានគ្រោងទុក")។

[605] សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *មតិយោបល់របស់ការិយាល័យរដ្ឋបាលស្តីពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២* ឯកសារ **D349/3** ចុះថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៧ កថាខណ្ឌ ១៣។

ពេញមួយរយៈពេលប្រតិបត្តិការរបស់ខ្លួនដែរ[606]។ អង្គការសហប្រជាជាតិ ក៏បានទទួលស្គាល់ផងដែរថាគ្មានយន្តការថវិកាសម្រាប់ដោះស្រាយចំណាយប្រតិបត្តិការផ្សេងៗជាយថាហេតុដែលមិនអាចប្រមើលទុកបាននោះ ឡើយ[607]។ ហើយ អង្គការសហប្រជាជាតិ ក៏ពុំមានផែនការចំណាយជាយថាហេតុ ឬយុទ្ធសាស្ត្រកផ្លូវចេញក្នុងករណី មានបញ្ហាថវិកាដែរ[608]។ ហេតុដូចនេះ ជំហររបស់ម្ចាស់ជំនួយលើការខ្វះថវិការបស់តុលាការ គឺជា "ការ សារភាពនូវបរាជ័យរបស់រដ្ឋដើម្បីឆ្លើយតបទៅនឹងអ្វីដែលបានរំពឹងទុកទៅលើរដ្ឋទាំងនោះ ក្រោមសន្ធិសញ្ញា ឬសេចក្តីសម្រេចដែលពួកគេបានបង្កើត[609]។

222. ក្នុងខែសីហា ឆ្នាំ២០១៧ សហចៅក្រមស៊ើបអង្កេត សន្យា "ចាត់វិធានការចាំបាច់ ប្រសិនបើបញ្ហានានាកាន់តែអាក្រក់ ទៅៗ សាជាថ្មីដល់កម្រិតមួយដែលក្នុងទស្សនៈ[ពួកគាត់]យល់ឃើញថាឯករាជភាពតុលាការ យុត្តិធម៌ និង សុចរិតភាពនៃកិច្ចនីតិវិធីត្រូវបានគំរាមកំហែង"[610]។ ស្ថិតក្នុងស្ថានភាពកង្វះថវិកាដែលចេះតែបន្តនេះ កង្វះ ការធានាគ្រប់គ្រាន់ពីម្ចាស់ជំនួយនិងការសារភាពរបស់អគ្គលេខាធិការ អង្គការសហប្រជាជាតិ ថាវិភាគទានស្ម័គចិត្ត ត្រូវបាន "ប៉ាន់ស្មានថានឹងថយចុះបន្ថែមទៀត"[611] កម្រិតរបស់ សហចៅក្រមស៊ើបអង្កេត ផ្ទាល់ក្នុងការអន្តរាគមន៍ត្រូវបាន បំពេញរួចហើយ។ ការខកខានរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការផ្អាកឬបដិសេធសំណុំរឿងដោយឈរលើមូលដ្ឋាន នេះតែមួយគឺជាការរំលោភនូវតួនាទីរបស់ខ្លួន។

## ខ. ផលប៉ះពាល់នៃការរំលោភបំពានដែលចេះតែកើនឡើង បណ្តាលឲ្យមានព្យួរកម្មដែលមិនអាចជួសជុលបាន

---

[606] សំណុំរឿងលេខ ០០៤/២ *ឧបសម្ព័ន្ធ I៖ សេចក្តីសង្កេតរបស់លេខាធិការដ្ឋានអង្គការសហប្រជាជាតិទាក់ទិននឹងសំណើសុំមតិតយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២* ឯកសារ **D349/3.1.1** កថាខណ្ឌ ១៧។

[607] សំណុំរឿង ០០៤/២-ឯកសារ **D349** កថាខណ្ឌ ៣១ (ដកស្រង់ *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់ អ.វ.ត.ក* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ៣០)។

[608] សំណុំរឿង ០០៤/២-ឯកសារ **D349/3** កថាខណ្ឌ ២៦។

[609] សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ២៨។

[610] សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ៦៧។

[611] *សំណើសុំថវិកាឧបត្ថម្ភធនសម្រាប់ អ.វ.ត.ក* ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៦ កថាខណ្ឌ ៣៨ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣៨។

223. ផលប៉ះពាល់ដែលចេះតែកើនឡើងនៃការរំលោភបំពានសិទ្ធិទទួលបានការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌ ដូចដែលបានរៀបរាប់ខាងលើ ធ្វើឱ្យប៉ះពាល់ដល់ភាពត្រឹមត្រូវនៃកិច្ចនីតិវិធីក្នុងលក្ខណៈដែលអា ក្រក់ខ្លាំង និង មិនអាចជួសជុលបាន បណ្តាលឱ្យសវនាការប្រកបដោយយុត្តិធម៌របស់ អោ អាន មិនអាចធ្វើទៅបាន។ ការបូកបញ្ចូលគ្នានូវការរំលោភបំពានការជំនុំជម្រះក្តីដោយយុត្តិធម៌ អាចមានឥទ្ធិពលខ្លាំងជាងផ្នែកផ្សេងៗដែលសរុបចូលគ្នាទៅទៀត[612]។ ជាមួយនឹងការរំលោភបំពាននីមួយៗ គឺមានការបំផ្លាញភាពស្របច្បាប់ទូទៅនៃកិច្ចនីតិវិធី[613]។ ក្នុងការវាយតម្លៃភាពត្រឹមត្រូវទូទៅនៃកិច្ចដំណើរការនីតិវិធី ចៅក្រមមានតួនាទី ពិចារណាការរំលោភបំពាននីមួយៗនៅក្នុងបរិបទរួមនៃដំណាក់កាលស៊ើបអង្កេតទាំងមូល ក៏ដូចជា ផលប៉ះពាល់ដែលចេះតែកើនឡើងនៃការរំលោភបំពានទូទៅទៅលើ លទ្ធភាពរបស់ អោ អាន ក្នុងការទទួលការជំនុំជម្រះក្តីដោយ

[612] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Ntagerura *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ ICTR-99-46-A, *Judgement* ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ១១៤ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣៩។ *រឿងក្តី Ngirabatware តទល់នឹងរដ្ឋអាជ្ញា* សំណុំរឿងលេខ ICTR-99-54-A *សេចក្តីសម្រេចលើបណ្តឹងឧទ្ធរណ៍របស់ Augustin Ngirabatware ជំទាស់នឹងសេចក្តីសម្រេចបដិសេធញត្តិសុំផ្លាស់ប្តូរកាលបរិច្ឆេទជំនុំជម្រះ* ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ៣០ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៤០។ *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Karadžić សំណុំរឿងលេខ IT-95-5/18-T *សេចក្តីសម្រេចលើញត្តិរបស់ជនជាប់ចោទសុំឱ្យមានការជំនុំជម្រះជាថ្មីចំពោះការរំលោភលើការដាក់បង្ហាញឯកសារ* ចុះថ្ងៃទី០៣ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ ១៤-១៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៤១។ សូមមើលផងដែរ *រឿងក្តី Ibrahim និងអ្នកផ្សេងទៀត តទល់នឹងចក្រភពអង់គ្លេស*ECtHR ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ កថាខណ្ឌ ២៥០-២៥១ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៤២។ *រឿងក្តី Barberà, Messegué និង Jabardo តទល់នឹងប្រទេសអេស្ប៉ាញ* ECtHR ចុះថ្ងៃទី០៦ ខែធ្នូ ឆ្នាំ១៩៨៨ កថាខណ្ឌ ៨៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៤៣។ សេចក្តីសម្រេចក្នុងរឿងក្តី *Barayagwiza* កថាខណ្ឌ ៧៣។

[613] *រឿងក្តីរដ្ឋអាជ្ញា តទល់នឹង* Bemba សំណុំរឿងលេខ ICC-01/05-01/08 *យោបល់ឯកភាពដាច់ដោយឡែករបស់ចៅក្រម* Eboe-Osuji ("*យោបល់ឯកភាពដាច់ដោយឡែករបស់ចៅក្រម Eboe-Osuji ក្នុងរឿងក្តី Bemba*") ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៨ កថាខណ្ឌ ៨៩ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៤៤ ("កំហុសអង្គច្បាប់ ឬអង្គហេតុ ឬនីតិវិធីជាក់ស្តែង និងតែឯកឯង មិនអាចត្រូវបានមើលឃើញថាជាការសម្រេចដែលមានភាពមិនយុត្តិធម៌បាននោះទេ។ ប៉ុន្តែ ប្រសិនបើកំហុសអង្គច្បាប់ ឬអង្គហេតុ ឬនីតិវិធីតូចៗមានច្រើន ផ្អែកលើទម្ងន់កើនឡើង ឬលក្ខណៈឃោរឃៅ និងសមាមាត្ររបស់វា កំហុសទាំងនោះអាចបង្កើតឱ្យមានភាពមិនត្រឹមត្រូវដែលធ្វើឱ្យសេចក្តីសម្រេចមានភាពមិនយុត្តិធម៌បាន នៅពេលដែលការកើតមានឡើងជារួម ឬច្រើនដងនូវកំហុសទាំងនោះ ហួសពីសម្បទានៃកិច្ចដំណើរការនីតិវិធី និងសាលក្រម ឬការប្រកាសទោស ក្នុងការបញ្ជាក់ថាជាការបង្ហាញពីភាពយុត្តិធម៌ដែលអាចជឿជាក់បាន។")។

យុត្តិធម៌[614]។

224. អោ អាន ត្រូវបានផាត់ចេញពីការចូលទៅពិនិត្យសំណុំរឿង ឬពីការចូលរួមក្នុងការស៊ើបអង្កេត ក្នុងរយៈពេល៥ ឆ្នាំកន្លះ នៃរយៈពេលស៊ើបអង្កេតសរុបចំនួន ៧ឆ្នាំ។ នៅអំឡុងពេលនេះ ខណៈពេលដែល សហព្រះរាជអាជ្ញាអន្តរជាតិ ទទួលបានសិទ្ធិចូលរួមពេញលេញ និង មានលទ្ធភាពបង្កើតការស៊ើបអង្កេត និង កសាងសំណុំរឿងប្រឆាំង នឹង អោ អាន ចំណែក អោ អាន វិញគឺមិនបានទទួលសិទ្ធិអ្វីទាំងអស់។ អោ អាន ត្រូវបានជូនដំណឹង ចុងក្រោយអំពីការចោទប្រកាន់នៅ អ.វ.ត.ក ។ គាត់ត្រូវការរង់ចាំ៣ឆ្នាំទៀតមុនពេលដឹងអំពីលក្ខណៈ និង មូលហេតុនៃបទចោទប្រកាន់ប្រឆាំងនឹងរូបគាត់។ មន្ត្រីតុលាការម្នាក់ជូនដំណឹងដល់គាត់នូវសិទ្ធិក្នុងការតំណាងដោយ មេធាវីតាមការជ្រើសរើសរបស់គាត់ ខណៈដែលមន្ត្រីតុលាការម្នាក់ទៀតបដិសេធតាមទំនើងចិត្តនូវសិទ្ធិនោះ អស់រយៈពេល៤ខែកន្លះ។ នៅពេលដែលចុងក្រោយគាត់ត្រូវគេអនុញ្ញាតឱ្យចូលពិនិត្យសំណុំរឿង អោ អាន រកឃើញថា ទ្រឹស្តីសំណុំរឿងត្រូវបានបង្កើតរួចបាត់ទៅហើយ ហើយភ័ស្តុតាងគាំទ្រភាគច្រើនត្រូវបាន ប្រមូលរួចជាស្រេច ដែលធ្វើឱ្យគាត់មានការយល់ខុសទៅលើការចូលរួមនៅក្នុងកិច្ចស៊ើបអង្កេត។

225. ជាមួយនឹងវិធានមតិភាគច្រើនលើសលុបដែលបណ្តាលឱ្យមានសច្ចធាណ៍និរទោសរបស់គាត់គ្មានន័យ អោ អាន ព្យាយាមបង្កើតនិរទោសរបស់គាត់។ ការប៉ុនប៉ងរបស់គាត់ក្នុងការទទួលភ័ស្តុតាងដោះបន្ទុកត្រូវបានរារាំងដោយចៅក្រមម្នាក់រកឃើញថា ភ័ស្តុតាងបែបនេះមិនត្រូវតាមទ្រឹស្តីសំណុំរឿងដែលបានបង្កើតរួចហើយនោះទេ ហើយក្នុងករណីណាក៏ដោយក៏វាយឺតពេល ឬមានតម្លៃខ្ពស់ពេកក្នុងការអនុវត្ត ដែលចៅក្រមនោះបានរងសម្ពាធដោយកង្វះថវិកាដ៏រ៉ាំរ៉ៃ និង សម្ពាធរបស់ម្ចាស់ជំនួយដើម្បីបញ្ចប់កិច្ចស៊ើបអង្កេត[615]។ រាល់ការប៉ុនប៉ងប្តឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធបែប

---

[614] សំណុំរឿង ០០២-ឯកសារ **E313** កថាខណ្ឌ ៤០-៤១។ *សេចក្តីសម្រេចកោសលុបក្នុងរឿងក្តី Lubanga លើពាក្យសុំរបស់មេធាវីការពារក្តីសុំផ្អាកជាអចិន្ត្រៃយ៍* កថាខណ្ឌ ១៦៥-១៦៦។ *សាលដីកាក្នុងរឿងក្តី Lubanga លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងសេចក្តីសម្រេចលើការជំទាស់របស់មេធាវីការពារក្តីនឹងយុត្តាធិការ* កថាខណ្ឌ ២៨-២៩, ៣៧។ *សេចក្តីសម្រេចក្នុងរឿងក្តី Bemba លើសំណើរបស់មេធាវីការពារក្តីសុំការអនុញ្ញាតធ្វើបណ្តឹងសាទុក្ខ* កថាខណ្ឌ ១២។ *សេចក្តីសម្រេចក្នុងរឿងក្តី Barayagwiza* កថាខណ្ឌ ៧៣, ៧៦-៧៧។ *សេចក្តីសម្រេចក្នុងរឿងក្តី Nikolić លើញត្តិរបស់មេធាវីការពារក្តីដែលជំទាស់នឹងការអនុវត្តយុត្តាធិការ* កថាខណ្ឌ ១១១។ *សំអាងហេតុក្នុងរឿងក្តី Hartmann លើញត្តិរបស់មេធាវីការពារក្តីសុំផ្អាក* កថាខណ្ឌ ៥។

[615] សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ១៩-២៧, ៤៨-៥៦។

នេះត្រូវបានរារាំងដោយការបដិសេធទាំងស្រុងទៅលើបណ្ដឹងឧទ្ធរណ៍ពាក់ព័ន្ធនឹងសំណើសុំបើកកិច្ចស៊ើបសួរពីសំណាក់ចៅក្រមជាតិបីរូបរបស់អង្គបុរេជំនុំជម្រះ។ ទន្ទឹមគ្នានេះដែរ ភ័ស្តុតាងសាក្សីនៅក្នុងសំណុំរឿងត្រូវបានលាយឡំដោយកំហុស និងការខ្វះការប្រុងប្រយ័ត្នរបស់អ្នកស៊ើបអង្កេត ឬដោយការសួរតទល់ជាមួយសាក្សីនៅក្នុងសវនាការក្នុងសំណុំរឿង០០២។ ទោះបីជាមានការបង្ហាញកំហុសនៅក្នុងកំណត់ហេតុស្ដាប់ចម្លើយក្ដី ក៏ការស្ដាប់ចម្លើយសាក្សីជាងពាក់កណ្ដាលមិនដែលត្រូវបានថតខ្សែអាត់សំឡេង ធ្វើឱ្យភាពសុក្រឹតនៃចម្លើយរបស់ពួកគេនអាចផ្ទៀងផ្ទាត់បាន។ ថ្ងៃណាមួយ កំណត់ហេតុស្ដាប់ចម្លើយដដែលនោះអាចបង្កើតជាមូលដ្ឋានសំណុំរឿងរបស់សហព្រះរាជអាជ្ញាអន្តរជាតិនៅពេលសវនាការ ពោលគឺសាក្សីខ្លួនឯងទទួលមរណភាព ឬមិនមានសម្បទាគ្រប់គ្រាន់ក្នុងការផ្ដល់សក្ខីកម្ម។ កាន់តែអាក្រក់ទៀតនោះគឺ ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាជាតិត្រូវបានផ្អែកលើទឡ្ហីករណ៍ និង ភ័ស្តុតាងស្ថាពរដែលមិនបានបង្ហាញដល់មេធាវីការពារក្ដី។

226. នៅពេលបញ្ចប់ការស៊ើបអង្កេត អោ អាន ត្រូវបានបង្ហាញនូវដីកាដំណោះស្រាយចំនួន២ដែល ផ្ទុយគ្នា ដែលក្លាយជាបុគ្គលទី១នៅក្នុងប្រវត្តិសាស្ត្រដែលសំណុំរឿងរបស់ខ្លួនត្រូវបានបដិសេធនិងបញ្ជូនទៅជំនុំជម្រះក្នុងពេលតែមួយ។ ជាថ្មីម្ដងទៀត គាត់ត្រូវបានទុកឱ្យស្មានអំពីលក្ខណៈ និង មូលហេតុនៃបទចោទប្រកាន់ មកលើរូបគាត់។

227. ដោយតុលាការរងកង្វះថវិកាដ៏រ៉ាំរ៉ៃ អោ អាន បច្ចុប្បន្នប្រឈមនឹងទិដ្ឋភាពដ៏លំបាកមួយដែលដីកាបញ្ជូនរឿងទៅជំនុំជម្រះនឹងអន្ទោលតាមប្រាណមិនចប់មិនហើយ ដោយគ្មានលទ្ធភាពការពារខ្លួនប្រឆាំងនឹង បទចោទព្រហ្មទណ្ឌដ៏ធ្ងន់ធ្ងរបំផុតក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ ទម្ងន់នៃកំហុសខាងអង្គច្បាប់ឬអង្គហេតុ ឬនីតិវិធីតិច តួច(ឬធំ) ច្បាស់ណាស់វាគឺជា “ភាពមិនត្រឹមត្រូវនាំដល់ភាពអយុត្តិធម៌”[616]។ ក្នុងករណីបែបនេះ “ការទាក់ទិនរួមគ្នា ឬជាច្រើនលុបលើសម្បទាកិច្ចនីតិវិធីនិងសាលក្រមដែលបានមកនេះ ឬការកំណត់ទោស ឈរជាបង្គោលនៃការសំដែងចេញនូវយុត្តិធម៌”[617]។

## ខ. ការផ្អាកបណ្ដោះអាសន្នឬការបដិសេធ គឺជាឧបាស្រ័យគ្រប់គ្រាន់តែមួយគត់

---

[616] *យោបល់ឯកភាពដាច់ដោយឡែករបស់ចៅក្រម Eboe-Osuji ក្នុងរឿងក្ដី Bemba* កថាខណ្ឌ ៨៩។

[617] *យោបល់ឯកភាពដាច់ដោយឡែករបស់ចៅក្រម Eboe-Osuji ក្នុងរឿងក្ដី Bemba* កថាខណ្ឌ ៨៩។

228. មាត្រា២(៣)(ក)នៃកតិកាសញ្ញាស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយតម្រូវឱ្យតុលាការនេះធានាថា ជនដែលត្រូវគេរំលោភសិទ្ធិឬសេរីភាពមានឧបាស្រ័យដោយប្រសិទ្ធភាព[618]។ សហចៅក្រមស៊ើបអង្កេត បានសម្រេចពីពេលកន្លងទៅថា អំណាចរបស់ខ្លួនក្នុងការផ្អាកកិច្ចនីតិវិធីដើម្បីការពារសុចរិតភាពនិងភាពយុត្តិធម៌ គឺហួសពីវិមតិសង្ស័យ[619]។ អង្គបុរេជំនុំជម្រះ បានសម្រេចថា នៅពេលមានការធ្វើបាបធ្ងន់ធ្ងរលើជនត្រូវចោទ ឬ ការរំលោភធ្ងន់ធ្ងរលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ តុលាការ*ត្រូវតែ*ផ្អាកកិច្ចនីតិវិធីជាអចិន្ត្រៃយ៍[620]។ អ.ជ.ត.ក បានសម្រេចថា "ការរំលោភធ្ងន់ធ្ងរលើសិទ្ធិ[ជនជាប់ចោទ]ដែលអាចបង្ហាញថាប៉ះពាល់ដល់សុចរិតភាពរបស់ អ.វ.ត.ក" ត្រូវតែមានឧបាស្រ័យសមស្រប ក្នុងនោះរួមមានលទ្ធភាពនៃការមិនជំនុំជម្រះជនជាប់ចោទ[621]។ ក្នុងទិសប្រហាក់ប្រហែលគ្នានេះដែរ អ.ជ.ត.ក មានទស្សនៈថា នៅពេលកាលៈទេសៈធ្វើឱ្យតុលាការអសមត្ថភាពធានាឱ្យមានសវនាការមួយជំរុញដោយច្បាប់នោះកិច្ចដំណើរការនីតិវិធីទាំងអស់ត្រូវតែបញ្ចប់[622]។

229. ការស៊ើបអង្កេតគឺជាគោលការណ៍ជាសារវ័ន្តមួយដែលជាមូលដ្ឋានសម្រាប់កសាងសំណុំរឿង ហើយ "ភាពយុត្តិធម៌នៃសវនាការគឺទំនងជារងព្យសនកម្មយ៉ាងធ្ងន់ធ្ងរដោយសារការខកខានតាំងពីដើមដំបូងក្នុងការអនុវត្តបទបញ្ញត្តិ[អំពីសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌]"[623]។ ក្នុងបរិបទនៃកិច្ច ស៊ើបអង្កេតទាំងមូល ការរំលោភលើសិទ្ធិនីតិវិធីរបស់ អោ អាន បានធ្វើឱ្យគាត់ចាញ់ប្រៀប សហព្រះរាជអាជ្ញាអន្តរជាតិ ជា អចិន្ត្រៃយ៍។ ផលប៉ះពាល់ដែលចេះតែកើនឡើងនៃការ

[618] សាលដីកាក្នុងរឿងក្តី *Kajelijeli* កថាខណ្ឌ ២៥៥, ៣២៤។

[619] សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ១៦។

[620] សំណុំរឿង ០០២-ឯកសារ **D264/2/6** កថាខណ្ឌ ២៧។ សូមមើលផងដែរ សំណុំរឿង ០០៤/២-ឯកសារ **D349/6** កថាខណ្ឌ ១៦-១៧។ សូមមើលផងដែរ *សេចក្តីសម្រេចក្នុងរឿងក្តី* Nikolić *លើញត្តិរបស់មេធាវីការពារក្តីដែលជំទាស់នឹងការអនុវត្តយុត្តាធិការ* កថាខណ្ឌ ១១១។ *សំអាងហេតុក្នុងរឿងក្តី* Hartmann *លើញត្តិរបស់មេធាវីការពារក្តីសុំផ្អាក* កថាខណ្ឌ ៤។

[621] សំណុំរឿង ០០១-ឯកសារ **F28** កថាខណ្ឌ ៣៨៣-៣៨៩។

[622] សំណុំរឿង ០០២-ឯកសារ **E284/4/8** កថាខណ្ឌ ៧៥។ សូមមើលផងដែរ *សេចក្តីសម្រេចកោសលុបក្នុងរឿងក្តី* Lubanga *លើពាក្យសុំរបស់មេធាវីការពារក្តីសុំផ្អាកជាអចិន្ត្រៃយ៍* កថាខណ្ឌ ១៦៤-១៦៦។ *សេចក្តីសម្រេចក្នុងរឿងក្តី* Barayagwiza កថាខណ្ឌ ១០៨។

[623] *រឿងក្តី* Salduz កថាខណ្ឌ ៥០, ៥៤ (លើកឡើងថា "ភស្តុតាងទទួលបានក្នុងដំណាក់កាលនេះ កំណត់ពីក្របខណ្ឌដែលបទល្មើសដែលត្រូវបានចោទប្រកាន់ នឹងត្រូវបានពិចារណានៅពេលជំនុំជម្រះ")។

រំលោភបំពាន និង ការគំរាមកំហែងទៅលើសុចរិត ភាពតុលាការ បានឈានដល់កម្រិតមួយ ដែលការជំនុំជម្រះក្តីដោយយុត្តិធម៌ពុំអាចទៅរួចលើសពីនេះឡើយ។ ស្ថានភាពកាន់តែអាក្រក់ជាងនេះទៀតក្នុងករណីទៅថ្ងៃអនាគតដំណើរការនីតិវិធីនឹងត្រូវកាត់ផ្តាច់ឬជាប់គាំងអចិន្ត្រៃយ៍ ប្រសិនបើវិបត្តិហិរញ្ញវត្ថុរបស់តុលាការចេះតែបន្ត។ ហេតុដូចនេះ គ្មាន ឧបាស្រ័យណាលើសពីការបដិសេធ ឬផ្អាកកិច្ចនីតិវិធីនោះទេដើម្បីមានលក្ខណៈគ្រប់គ្រាន់ក្នុងការជួសជុល ព្យសនកម្មដែលបានកើតឡើង។

## ច. សេចក្តីសន្និដ្ឋានសម្រាប់សំអាងហេតុទី១៨

230. ផ្អែកលើសំអាងហេតុខាងលើ សហមេធាវីការពារក្តីសូមធ្វើសេចក្តីសន្និដ្ឋានដោយគោរពថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានភារកិច្ចផ្អាក ឬលើកលែងការចោទប្រកាន់លើ អោ អាន ដើម្បីធានាសិទ្ធិជាសារវ័ន្តរបស់គាត់ និង សុចរិតភាពរបស់តុលាការ ប៉ុន្តែគាត់បានខកខានមិនបានធ្វើដូច្នេះឡើយ។ ការខកខាននេះគឺផ្អែកលើអង្គហេតុ ដូចជាការខកខានមិនបានមើលឃើញនូវផលប៉ះពាល់នៃការរំលោភកិច្ចនីតិវិធីនីមួយៗនិងជារួម និងការគំរាមកំហែងដល់ សុចរិតភាពតុលាការទៅលើលទ្ធភាពរបស់ អោ អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ម្យ៉ាងវិញទៀត សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរំលោភឆន្ទានុសិទ្ធិរបស់ខ្លួនដោយសម្រេចមិនផ្អាកឬទម្លាក់ការចោទប្រកាន់ សំណុំរឿង០០៤/២ ហើយ បច្ចុប្បន្ន សិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌របស់ អោ អាន គឺស្ថិត នៅលើការសម្រេចអង្គបុរេជំនុំជម្រះ[624]។ ដើម្បីសម្រេចបានគោលដៅនេះ សហមេធាវីការពារក្តីសូមគោរពស្នើសុំ អង្គបុរេជំនុំជម្រះ បដិសេធ *ដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* និង លើកលែងការចោទប្រកាន់លើ អោ អាន។

## សេចក្តីសន្និដ្ឋាន និងសំណើ

231. ផ្អែកលើមូលហេតុដូចបានរៀបរាប់ខាងលើ *ដីកាដំណោះស្រាយ(ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* មានកំហុសខាងអង្គច្បាប់និងអង្គហេតុជាច្រើនពាក់ព័ន្ធនឹងយុត្តាធិការបុគ្គលនិងយុត្តាធិការរឿងក្តីរបស់តុលាការ និង ការរំលោភធ្ងន់ធ្ងរលើសិទ្ធិរបស់ អោ

[624] សំណុំរឿង ០០៤/២-ឯកសារ **D360** កថាខណ្ឌ ៤៤-៤៥។

អាន ក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ អាស្រ័យហេតុនេះ សហមេធាវីការពារក្តី សូមស្នើសុំដោយគោរពដល់អង្គបុរេជំនុំជម្រះ មេត្តា៖ (ក) ទទួលយកបណ្តឹងឧទ្ធរណ៍នេះ និង (ខ) លើកលែងការចោទប្រកាន់ប្រឆាំងនឹង អោ អាន។

232. សហមេធាវីការពារក្តីគោរពស្នើសុំ អង្គបុរេជំនុំជម្រះ ធ្វើចំណាត់ថ្នាក់បណ្តឹងឧទ្ធរណ៍នេះសាជាថ្មី ថាជាឯកសារ ផ្លូវការ ដោយធ្វើការកោសលុបតាមការចាំបាច់ដើម្បីការពារព័ត៌មានផ្ទាល់ខ្លួនរបស់ អោ អាន សាក្សី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។

ធ្វើនៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨

**សហមេធាវីការពារក្តីរបស់លោក អោ អាន**

| | | |
|---|---|---|
| មុំ លុជ្ស | Richard ROGERS | Göran SLUITER |